# អដ្ឋកថាជាតក

## ឯកនិបាត

## ភាគ ១



បិដក លេខ ៥៨

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ព.ស.២៥៥៩

# អដ្ឋកថាជាតក

## ឯកនិបាត

## ភាគ ១



## បិដក លេខ ៥៨

ផ្សព្វផ្សាយដោយសមាគមធម្មទានអរិយវង្សយង់សុផាត

ព.ស.២៥៥៩

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
ក្រសួងមហាផ្ទៃ

លេខ : ២២៥ សជណ៧

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
### ពិតថេរដីកា
### ព្រះតេជគុណ យង់ សុផាត ប្រធានសមាគមធម្មទានអរិយវង្ស យង់ សុផាត

**កម្មវត្ថុ** : អំពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្សយង់ សុផាត*** នៅក្រសួងមហាផ្ទៃ ។

**យោង** : លិខិតលេខ***០១/១០ស.ធ.អ.យ.ផ*** ចុះថ្ងៃទី***២៣*** ខែ***តុលា*** ឆ្នាំ***២០០៩*** ស្តីពីការសុំចុះបញ្ជីរបស់***សមាគមធម្មទានអរិយវង្ស យង់ សុផាត*** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំព្រះករុណាសូមពិតថេរដីកាព្រះតេជគុណប្រធានថា ក្រសួងមហាផ្ទៃយល់ព្រមចុះបញ្ជី***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ដែលមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលនៅភូមិ***រំចេក៣*** សង្កាត់***រតនៈ*** ក្រុង***បាត់ដំបង*** ខេត្ត***បាត់ដំបង*** នោះហើយ ។ ***សមាគមធម្មទានអរិយវង្សយង់ សុផាត*** ត្រូវអនុវត្តតាមលក្ខន្តិកៈដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ និងធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌជាសមាគមអព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើសកម្មភាពបម្រើឱ្យគណបក្សនយោបាយ និងមិនធ្វើជាឧបករណ៍គណបក្សនយោបាយ ។

ក្រោយពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចូលជាធរមាន សមាគមធម្មទានអរិយវង្ស យង់ សុផាត ត្រូវដាក់ពាក្យសុំចុះបញ្ជីសាជាថ្មីអោយបានត្រឹមត្រូវតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមព្រះតេជគុណប្រធានជ្រាបជាព័ត៌មាន
សូមព្រះតេជគុណប្រធាន ទទួលនូវការគោរពអំពីខ្ញុំព្រះករុណា ។

ស ខេង

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- សាលាខេត្តបាត់ដំបង
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# ពាក្យប្រារព្ធ

*គម្ពីរ* **អដ្ឋកថាជាតក** *នេះ ជាគម្ពីរមួយដែលពន្យល់សេចក្ដីក្នុងព្រះត្រៃបិដក ចាប់ពីលេខ ៥៨ ដល់លេខ ៦៣ ដែលព្រះអរហន្តអ្នកជំនាញ ៥០០ អង្គ សង្គាយនាមកមុនគេបង្អស់ និងសង្គាយនាតៗ មកក្នុងកាលជាខាងក្រោយ ដែលមហិន្ទត្ថេរនាំមកកាន់កោះសីហឡ រចនាជាសីហឡភាសា ដើម្បីជាប្រយោជន៍ដល់អ្នកកោះ ហើយព្រះពុទ្ធឃោសាចារ្យក៏បរិវត្តមកជាមគធភាសា ( ភាសាបាលី ) ដើម្បីបានជាប្រយោជន៍ដល់កុលបុត្តអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់ជាតិសាសន៍ក្នុងពិភពលោកដែលអាចប្រែពីភាសាបាលីមកជាភាសាជាតិរៀងៗខ្លួន ។ ដោយហេតុនេះកុលបុត្តដែលអានព្រះត្រៃបិដក ចាប់ពីលេខ ៥៨ ដល់ ៦៣ បើមិនអាចយល់សេចក្ដីបាន សូមអាន* **អដ្ឋកថាជាតក** *នេះចុះ ។*

*សៀវភៅ* **អដ្ឋកថាជាតក** *ភាគ ១ នេះ មានន័យចង្អៀតស្មុគស្មាញជាងភាគដទៃៗ ព្រោះព្រះអដ្ឋកថាចារ្យលើកយកព្រះពុទ្ធដីកាច្រើនកន្លែង ដូចជាគម្ពីរពុទ្ធវំស: ចរិយាបិដក ថេរគាថា វិមានវត្ថុ ធម្មបទ និងសំយុត្តនិកាយជាដើម មកជាគ្រឿងអាង លំបាកក្នុងការស្វែងរកព្រះពុទ្ធដីកានោះ ៗ មកបញ្ចូលក្នុងទីនេះ តែដោយកម្លាំងព្យាយាម សៀវភៅនេះក៏សម្រេចហើយ ។ តែការសម្រេចនេះ ក៏ព្រោះអាស្រ័យបានការចូលរួមរបស់លោកអ្នកសប្បុរសជាច្រើន ដូចជាលោកអ្នកជួយវាយអក្សរ លោក*

អ្នកជួយពិនិត្យអក្ខរាវិរុទ្ធ លោកអ្នកឧបត្ថម្ភប្រាក់សម្រាប់បោះពុម្ព និង លោកអ្នកដែលជួយខ្នះខ្នែងក្នុងការផ្សាយធម្មទាននេះជាដើម ។

ដោយអានុភាពកុសលធម្មទាននេះ សូមលោកអ្នកទាំងនោះ មួយអន្លើដោយសព្វសត្វដែលត្រូវការចំណែកបុណ្យ បានអនុមោទនាត្រេកអរក្នុងកុសលធម្មទាននេះគ្រប់អង្គគ្រប់គ្នា ដើម្បីជាឧបនិស្ស័យរួចចាកទុក្ខដល់នូវព្រះនិព្វានហោង ។

កំហុសឆ្គងដោយអចេតនា និងការដឹងមិនដល់ក្នុងសៀវភៅនេះ សូមលោកអ្នកប្រាជ្ញដែលមានចំណេះដឹងខ្ពង់ខ្ពស់ ជួយកែលម្អឲ្យទាន ។

**យំបត្តំ កុសលំ តស្ស អានុភាវេន បណិនោ**
**សព្វេ សទ្ធម្មរាជស្ស ញត្វា ធម្មំ សុខាវហំ ។**

ដោយអានុភាពនៃកុសលនោះ សូមសត្វមានជីវិតទាំងពួង
ត្រាស់ដឹងនូវធម៌ ដែលនាំមកនូវសេចក្ដីសុខ (គឺព្រះនិព្វាន)
របស់ព្រះធម្មរាជាហោង ។

បាត់ដំបង ថ្ងៃ ១៥ កើត ខែ ពិសាខ ព.ស. ២៥៥៨

ឧបាសក **ឡាន សុខុម**

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## អដ្ឋកថា អបណ្ណកវគ្គ ទី ១


| | | | |
|---|---|---|---|
| បណាមគាថា | | ........................................ | ១ |
| សម្តែងអំពីនិទាន ៣ | | ........................................ | ៣ |
| អបណ្ណកវគ្គ ទូរេនិទាន | | ........................................ | ៤ |
| អបណ្ណកវគ្គ អវិទូរេនិទាន | | ........................................ | ១៥០ |
| អបណ្ណកវគ្គ សន្តិកេនិទាន | | ........................................ | ២២៧ |
| អដ្ឋកថា អបណ្ណកជាតក | ទី ១ | ........................................ | ២៨២ |
| អដ្ឋកថា វណ្ណុបថជាតក | ទី ២ | ........................................ | ៣១៣ |
| អដ្ឋកថា សេរិវវាណិជជាតក | ទី ៣ | ........................................ | ៣២៤ |
| អដ្ឋកថា ចុល្លកសេដ្ឋិជាតក | ទី ៤ | ........................................ | ៣៣១ |
| អដ្ឋកថា តណ្ឌុលនាឡិជាតក | ទី ៥ | ........................................ | ៣៥៣ |
| អដ្ឋកថា ទេវធម្មជាតក | ទី ៦ | ........................................ | ៣៦០ |
| អដ្ឋកថា កដ្ឋហារិជាតក | ទី ៧ | ........................................ | ៣៨០ |
| អដ្ឋកថា គាមណិជាតក | ទី ៨ | ........................................ | ៣៨៧ |
| អដ្ឋកថា មឃទេវជាតក | ទី ៩ | ........................................ | ៣៩០ |
| អដ្ឋកថា សុខវិហារិជាតក | ទី ១០ | ........................................ | ៣៩៦ |

# អដ្ឋកថា សីលវគ្គ ទី ២


អដ្ឋកថា លក្ខណជាតក ទី ១ ........................................ ៤០៣

អដ្ឋកថា និគ្រោធមិគជាតក ទី ២ ........................................ ៤១០

អដ្ឋកថា កណ្ឌិនជាតក ទី ៣ ........................................ ៤៣៣

អដ្ឋកថា វាតមិគជាតក ទី ៤ ........................................ ៤៣៩

អដ្ឋកថា ខរាទិយជាតក ទី ៥ ........................................ ៤៤៧

អដ្ឋកថា តិបល្លត្ថមិគជាតក ទី ៦ ........................................ ៤៥០

អដ្ឋកថា មាលុតជាតក ទី ៧ ........................................ ៤៦១

អដ្ឋកថា មតកភត្តជាតក ទី ៨ ........................................ ៤៦៤

អដ្ឋកថា អាយាចិតភត្តជាតក ទី ៩ ........................................ ៤៧០

អដ្ឋកថា នឡបានជាតក ទី ១០ ........................................ ៤៧៣


# អដ្ឋកថា កុរុង្គវគ្គ ទី ៣


អដ្ឋកថា កុរុង្គមិគជាតក ទី ១ ........................................ ៤៨១

អដ្ឋកថា កុក្កុរជាតក ទី ២ ........................................ ៤៨៥

អដ្ឋកថា ភោជាជានីយជាតក ទី ៣ ........................................ ៤៩៤

អដ្ឋកថា អាជញ្ញជាតក ទី ៤ ........................................ ៥០០

អដ្ឋកថា តិត្ថជាតក ទី ៥ ........................................ ៥០៣

អដ្ឋកថា មហិឡាមុខជាតក ទី ៦ ........................................ ៥១២

អដ្ឋកថា អភិណ្ហជាតក ទី ៧ ........................................ ៥២០
អដ្ឋកថា នន្ទិវិសាលជាតក ទី ៨ ........................................ ៥២៦
អដ្ឋកថា កណ្ហជាតក ទី ៩ ........................................ ៥៣២
អដ្ឋកថា មុណិកជាតក ទី ១០ ........................................ ៥៣៩

## អដ្ឋកថា កុលាវកវគ្គ ទី ៤

អដ្ឋកថា កុលាវកជាតក ទី ១ ........................................ ៥៤៥
អដ្ឋកថា នច្ចជាតក ទី ២ ........................................ ៥៦៤
អដ្ឋកថា សម្មោទមានជាតក ទី ៣ ........................................ ៥៦៩
អដ្ឋកថា មច្ឆជាតក ទី ៤ ........................................ ៥៧៤
អដ្ឋកថា វដ្តកជាតក ទី ៥ ........................................ ៥៧៨
អដ្ឋកថា សកុណជាតក ទី ៦ ........................................ ៥៨៧
អដ្ឋកថា តិត្តិរជាតក ទី ៧ ........................................ ៥៩១
អដ្ឋកថា ពកជាតក ទី ៨ ........................................ ៦០០
អដ្ឋកថា នន្ទជាតក ទី ៩ ........................................ ៦១០
អដ្ឋកថា ខទិរង្គារជាតក ទី ១០ ........................................ ៦១៦

# ខុទ្ទកនិកាយ
# អដ្ឋកថាជាតក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ឯកនិបាត

## អបណ្ណកវគ្គទី ១

### បណាមគាថា

ខ្ញុំសូមនមស្ការព្រះសម្ពុទ្ធដ៏ឧត្តម មិនមានបុគ្គលប្រៀបស្មើឡើយ ទ្រង់ឡើងអំពីសាគរនៃញេយ្យធម៌ ទ្រង់ឆ្លងសង្សារសាគរបានហើយ ដោយសិរសោគឹត្បូង ព្រមទាំងព្រះធម៌ដ៏ជ្រាលជ្រៅ ជាធម៌ស្ងប់ល្អិតសុខុម លំបាកនឹងឃើញបាន ជាធម៌ទម្លាយនូវភពតូចនិងភពធំ ដែលបុគ្គលគួរបូជា មួយអន្លើដោយព្រះសង្ឃដែលប្រាសចាកកិលេស ឧត្តមជាងមហាជន ជាអគ្គទក្ខិណេយ្យបុគ្គល មានឥន្ទ្រិយស្ងប់ហើយ មិន

មានអាសវៈ ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ។

ដោយបណាមគាថា ដែលខ្ញុំធ្វើហើយចំពោះព្រះរតនត្រ័យ ដោយការរាប់អានវិសេសនេះ ខ្ញុំដែលអ្នកប្រាជ្ញ អ្នកចេះបរិយត្តិ ជាវិញ្ញូជនមានយសធំ អារាធនាហើយ ឲ្យរចនាអដ្ឋកថា អបទាន ( ជីវប្រវត្តិ ) ព្រោះដូច្នោះ ខ្ញុំនឹងពណ៌នាអត្ថដ៏វិចិត្រនៃព្រះបាលីក្នុងព្រះត្រៃបិដក មួយអន្លើដោយប្រវត្តិដែលនៅសេសសល់ ដើម្បីកុំឲ្យច្ងល់ថា រឿងរ៉ាវដ៏អស្ចារ្យនេះ អ្នកណាពោលទុក ពោលទុកក្នុងទីណា ពោលទុកក្នុងកាលណា ពោលទុកព្រោះហេតុដូចម្តេចជាដើម ខ្ញុំនឹងពោលរឿងនោះៗ ព្រោះធ្វើឲ្យអ្នករៀននិងអ្នកទ្រទ្រង់ចាំបានងាយ ព្រោះដូច្នោះ រឿងរ៉ាវដែលលោកពោលទុកទាំងមុននិងក្រោយ រចនាទុកក្នុងភាសាសីហឡបុរាណក្តី ក្នុងអដ្ឋកថាបុរាណក្តី នឹងមកដល់ហើយ គឺរមែងឲ្យសម្រេចប្រយោជន៍តាមដែលសាធុជនត្រូវការ ព្រោះហេតុនោះ ខ្ញុំនឹងអាស្រ័យន័យរបស់អដ្ឋកថាបុរាណនោះ វៀរអត្ថដែលខុសភ្លាំងភ្លាត់ចេញ សម្តែងតែអត្ថដែលត្រឹមត្រូវ ធ្វើការពណ៌នាចំពោះបទដែលប្លែក ដែលល្អបំផុតប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

បណាមគាថា ចប់ ។

ព្រោះហេតុដែលបានប្តេជ្ញាទុកហើយថា រឿងរ៉ាវដែលល្អបំផុត បុគ្គលណាពោលទុក ពោលទុកក្នុងទីណា និងពោលទុកអំពីកាលណា

ពោលទុកព្រោះហេតុដូចម្តេច ខ្ញុំនឹងធ្វើការពណ៌នាអត្ថនោះ ។ ការពណ៌នាអត្ថនៃជីវប្រវត្តិនោះ ខ្ញុំនឹងសម្តែងនិទាន ៣ គឺ **ទូរេនិទាន ១ អវិទូរេនិទាន ១ សន្តិកេនិទាន ១** ដើម្បីឲ្យយល់បានងាយ ព្រោះបុគ្គលនឹងបានយល់ ក្នុងខណៈដែលបានអាន បានស្តាប់ហើយ ព្រោះដូច្នោះ ខ្ញុំនឹងសម្តែងនិទាន គឺជីវប្រវត្តិទាំងនោះ ។ បណ្តានិទានទាំងនោះ ជាបឋមបុគ្គលគួរជ្រាបបរិច្ឆេទជាមុន ។

កថាមគ្គដែលពោលរឿង តាំងអំពីព្រះមហាសត្វចាប់ផ្តើមប្រាថ្នាទៀបបាទមូលរបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមទីបង្ករ រហូតដល់ចុតិអំពីអត្តភាពជាព្រះវេស្សន្តរ ទៅកើតក្នុងឋានសួគ៌ជាន់តុសិត នេះហៅថា **ទូរេនិទាន** ។

កថាមគ្គដែលពោលរឿង តាំងអំពីព្រះបរមពោធិសត្វចុតិចាកតុសិតភព រហូតដល់សម្រេចសព្វញ្ញុតញ្ញាណត្រង់មណ្ឌលពោធិព្រឹក្សហៅថា **អវិទូរេនិទាន** ។

ចំណែក **សន្តិកេនិទាន** ប្រាកដត្រង់ទីផ្សេងៗ របស់ព្រះមានព្រះ-ភាគដែលទ្រង់ប្រថាប់គង់ក្នុងទីនោះៗ ( ចាប់ពីពេលត្រាស់ដឹងតទៅ ) ដោយប្រការដូច្នេះ ។

# ទូរេនិទាន

ក្នុងនិទានទាំងនោះ ឈ្មោះថា **ទូរេនិទាន** មានដូចតទៅនេះថា

បានឮមកថា ក្នុងទីបំផុត ៤ អសង្ខេយ្យនិង ១ សែនកប្ប រាប់ថយក្រោយអំពីភទ្ទកប្បនេះ មាននគរមួយឈ្មោះថា អមរវតី ក្នុងនគរនោះមានព្រាហ្មណ៍ឈ្មោះថា សុមេធ អាស្រ័យនៅ លោកមានកំណើតល្អ មានគភ៌បរិសុទ្ធ ទាំងខាងចំណែកមាតា ទាំងខាងចំណែកបិតា រាប់បាន ៧ ជួរត្រកូល ជាត្រកូលបរិសុទ្ធ មិនមានអ្នកដទៃតិះដៀលបាន ។ សុមេធ-ព្រាហ្មណ៍ មានរូបស្អាត គួរពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយពណ៌សម្បុរស្រស់ស្អាតក្រៃលែង ។ សុមេធព្រាហ្មណ៍មិនធ្វើការងារដទៃឡើយ សិក្សាតែសិប្បៈរបស់ព្រាហ្មណ៍ប៉ុណ្ណោះ ។ មាតានិងបិតារបស់សុមេធព្រាហ្មណ៍នោះ រស់នៅសមគួរដល់វ័យហើយ ក៏ធ្វើកាលកិរិយាតាំងអំពីសុមេធព្រាហ្មណ៍នៅក្មេងនោះឯង ។ ថ្ងៃមួយ បុរសជិតស្និទ្ធដែលធ្វើនូវប្រយោជន៍ បានកាន់បញ្ជីទ្រព្យមក បើកទ្វារឃ្លាំងដែលពេញទៅដោយមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម ហើយប្រាប់ឲ្យសុមេធព្រាហ្មណ៍ជ្រាបដល់ទ្រព្យដែលជីដូនជីតាទាំង ៧ ជួរត្រកូលបន្សល់ទុកមកថា បពិត្រកុមារ ទ្រព្យមានប្រមាណប៉ុណ្ណេះជារបស់មាតា ទ្រព្យមានប្រមាណប៉ុណ្ណេះជារបស់បិតា ទ្រព្យមានប្រមាណប៉ុណ្ណេះជារបស់ជីដូនជីតា ទ្រព្យមានប្រមាណប៉ុណ្ណេះជារបស់តាទួតយាយទួត របស់

លោកម្ចាស់ សូមលោកម្ចាស់ចាត់ចែងទ្រព្យនេះចុះ ។ សុមេធបណ្ឌិតគិតថា ជីតាជាដើមរបស់អញសន្សំទ្រព្យនេះទុក កាលទៅកាន់បរលោក គួរតែកាន់កហាបណៈ ១ ជាប់តាមខ្លួនទៅ តែយកទៅពុំបានឡើយ ណ្ហើយចុះ អញគួរកាន់យកទ្រព្យនេះទៅឲ្យបាន ។ សុមេធបណ្ឌិត គិតដូច្នេះហើយ ក៏ចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់ឲ្យមនុស្សទូងស្គរក្នុងនគរ ប្រកាសដល់មហាជន ឲ្យទៅយកទ្រព្យដែលទូលបង្គំមានចុះ ហើយក៏ចេញបួសជាតាបស ។ ដើម្បីឲ្យសេចក្តីនេះជាក់ច្បាស់ គួរពោលសុមេធកថាទុកក្នុងទីនេះផងដែរ តែសុមេធកថានោះ មានហើយក្នុងគម្ពីរពុទ្ធវំសៈ ព្រោះដូច្នោះ ខ្ញុំនឹងពោលតែប្រព័ន្ធគាថាទុកក្នុងចន្លោះៗ តែប៉ុណ្ណោះ ដែលមានសេចក្តីដូចតទៅនេះ ។

# សុមេធកថា

ក្នុងទីបំផុត ៤ អសង្ខេយ្យនិង ១ សែនកប្ប មាននគរមួយឈ្មោះថា អមរវតី ឬមានឈ្មោះមួយទៀតថា អមរ ជានគរអឺងកង់ដោយសំឡេង ១០ ប្រការ ដែលលោកពោលទុកក្នុងគម្ពីរពុទ្ធវំសៈថា

កប្បេ ច សតសហស្សេ ចតុរោ ច អសង្ខិយេ
អមរំ នាម នគរំ ទស្សនេយ្យំ មនោរមំ ។
ទសហិ សទ្ទេហិ អវិវិត្តំ អន្នបានសមាយុតំ

**ហត្ថិសទ្ទំ អស្សសទ្ទំ ភេរិសង្ខរថានិ ច ។**

*ក្នុង ៤ អសង្ខេយ្យនិងមួយសែនកប្ប មាននគរឈ្មោះអមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយនិងទឹក ទាំងមិនស្ងាត់ ដោយមានសំឡេង ១០ យ៉ាង គឺ សំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ដូច្នេះ ។*

*បណ្ដាបទទាំងនោះ បទថា* **ទសហិ សទ្ទេហិ អវិវិត្តំ** *សេចក្ដីថា អឺងកងទៅដោយសំឡេងទាំងនេះ គឺ សំឡេងដំរី សំឡេងសេះ សំឡេងរថ សំឡេងស្គរ សំឡេងសំភោរ សំឡេងពិណ សំឡេងមហោស្រព សំឡេងប្រគំ សំឡេងស័ង្ខ និងសំឡេងជាគម្រប់ ១០ ថា អញ្ជើញបរិភោគ អញ្ជើញទំពា អញ្ជើញផឹក លោកកាន់យកត្រឹមតែចំណែកមួយនៃសំឡេងទាំងនោះ ទើបពោលគាថានេះ ទុកក្នុងគម្ពីរពុទ្ធវំសៈថា*

**ខាទថ បិវថ ចេវ អន្នបានេន ឃោសិតំ**
**នគរំ សព្វង្គសម្បន្នំ សព្វកម្មមុបាគតំ ។**
**សត្តរតនសម្បន្នំ នានាជនសមាកុលំ**
**សមិទ្ធំ ទេវនគរំវ អាវាសំ បុញ្ញកម្មិនំ ។**

*ទាំងជានគរគឹកកងដោយសំឡេង ដែលប្រកបដោយបាយនិងទឹកថា ចូរស៊ី ចូរផឹក ជានគរសម្បូណ៌ដោយសត្វ និង*

*គ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង ។ បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេង ៗ សម្រេច ( ដោយគ្រឿងបរិភោគ និងឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។*

នគរេ អមរវតិយា សុមេធោ នាម ព្រាហ្មណោ
អនេកកោដិសន្និចយោ បហូតធនធញ្ញវា ។
អជ្ឈាយិកោ មន្តធរោ តិណ្ណំ វេទាន បារគូ
លក្ខណេ ឥតិហាសេ ច សធម្មេ បារមឹ គតោ ។

*វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត ចងចាំនូវមន្ត ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមី ក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ដូច្នេះ ។*

*ថ្ងៃមួយ សុមេធបណ្ឌិតនោះ ចូលទៅកាន់ទីពួនសម្ងំលើផ្ទៃប្រាសាទខាងលើ អង្គុយពត់ភ្នែន គិតថា នៃបណ្ឌិត ការកើតទៀត គឺបដិសន្ធិ ជាទុក្ខ ការបែកធ្លាយនៃសរីរៈក្នុងទីដែលកើតហើយ ក៏ជាទុក្ខដូចគ្នា អាត្មាអញមានការកើតជាធម្មតា មានការចាស់ជាធម្មតា មានការឈឺថ្កាត់ជាធម្មតា មានការស្លាប់ជាធម្មតា គួរតែអាត្មាអញស្វែងរកព្រះនិព្វានដែល*

មិនកើត មិនចាស់ មិនមានទុក្ខ មានតែសុខ ត្រជាក់ អមតៈ ផ្លូវផុតចាកភពមានប្រក្រតីនាំទៅកាន់ព្រះនិព្វាន ពិតជាមាន ពិតប្រាកដ ព្រោះហេតុនោះ ទើបលោកពោលថា

រហោគតោ និសីទិត្វា ឯវំ ចិន្តេសិហន្តទា
ទុក្ខោ បុនព្ភវោ នាម សរីរស្ស បភេទនំ ។
សម្មោហំ មរណំ ទុក្ខំ ជរាយ អភិមទ្ទិតំ
ជាតិធម្មោ ជរាធម្មោ ព្យាធិធម្មោ ចហន្តទា
អជរំ អមរំ ខេមំ បរិយេសិស្សាមិ និព្វុតឹ ។

កាលនោះ តថាគត នៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា (សេចក្តីស្លាប់ប្រកបដោយមោហៈនាំមកនូវទុក្ខ រូបដែលជរាញាំញីហើយ ក៏នាំមកនូវទុក្ខ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ដូច្នេះ ។

បន្ទាប់អំពីនោះ សុមេធបណ្ឌិតក៏គិតយ៉ាងនេះថា ឈ្មោះថាសេចក្តីសុខជាបដិបក្ខចំពោះទុក្ខ មានក្នុងលោកយ៉ាងណា បើភពមាន វត្ថុដែលប្រាសចាកភពក៏មានពិត ដូចការក្តៅមាន ការត្រជាក់ជាទីរម្ងាប់នៃកម្តៅ

*នោះ នឹងមានពិតប្រាកដយ៉ាងណា ព្រះនិព្វានជាទីរម្ងាប់នូវភ្លើង មានរាគៈជាដើម គប្បីមានដូច្នេះ ធម៌ដែលមិនមានទោស ជាធម៌ស្អាត ជាបដិបក្ខចំពោះធម៌ដែលអាក្រក់លាមក រមែងមានយ៉ាងណា កាលជាតិ គឺការកើតដ៏លាមកមាន សូម្បីព្រះនិព្វាន ពោលគឺការមិនកើត ព្រោះឲ្យការកើតគ្រប់យ៉ាងអស់ទៅ ក៏គប្បីមានយ៉ាងនោះ ព្រោះហេតុនោះ ទើបលោកពោលថា*

**យថាបិ ទុក្ខេ វិជ្ជន្តេ    សុខំ នាមបិ វិជ្ជតិ**
**ឯវំ ភវេ វិជ្ជមានេ    វិភវោ ឥច្ឆិតព្វកោ ។**
**យថាបិ ឧណ្ហេ វិជ្ជន្តេ    អបរំ វិជ្ជតិ សីតលំ**
**ឯវំ តិវិធគ្គិ វិជ្ជន្តេ    និព្វានំ ឥច្ឆិតព្វកំ ។**

*កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន ការប្រាសចាកភព បុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។ កាលបើក្តៅមាន ត្រជាក់ដទៃក៏មាន យ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះដែរ ដូច្នេះ ។*

*សុមេធបណ្ឌិតគិតប្រការដទៃៗ ទៀតថា បុរសដែលលិចទៅក្នុងគំនរលាមក ឃើញស្រះបោក្ខរណីធំ ដេរដាសទៅដោយផ្កាឈូក មានពណ៌ ៥ អំពីចម្ងាយ គួរតែស្វែងរកស្រះនោះ ដោយគិតថា អញគួរទៅ*

កាន់ស្រះនោះដោយផ្លូវណាហ្ន៎ ការមិនស្វែងរកស្រះនោះ មិនមែនជាទោសរបស់ស្រះនោះឡើយ តែជាទោសរបស់បុរសនោះ យ៉ាងណា កាលស្រះធំ គឺអមតមហានិព្វាន ជាទីលាងជម្រះមន្ទិល គឺកិលេសមាន ការមិនស្វែងរកស្រះនោះ មិនមែនជាកំហុសរបស់ស្រះធំ គឺអមតមហានិព្វាននោះទេ តែជាកំហុសរបស់បុរសនោះ ក៏យ៉ាងនោះដែរ ។ កាលបុរសត្រូវពួកចោរចោមរោម កាលផ្លូវសម្រាប់គេចមាន បើបុរសនោះមិនរត់គេចទៅ សេចក្ដីនេះ មិនមែនជាកំហុសរបស់ផ្លូវឡើយ តែជាកំហុសរបស់បុរសនោះ យ៉ាងណា កិលេសដែលចោមរោមនូវសត្វលោកមានហើយ កាលផ្លូវដែលត្រជាក់ជាទីទៅកាន់ព្រះនិព្វានមាន តែបុគ្គលមិនស្វែងរកផ្លូវនោះ សេចក្ដីនោះ មិនមែនជាកំហុសរបស់ផ្លូវនោះទេ ជាកំហុសរបស់បុគ្គលនោះ ក៏យ៉ាងនោះដែរ ។ បុរសត្រូវព្យាធិបៀតបៀន កាលគ្រូពេទ្យជាអ្នករក្សារោគមាន បើបុរសនោះមិនស្វែងរកគ្រូពេទ្យឲ្យមកព្យាបាលជំងឺ សេចក្ដីនោះ មិនមែនជាកំហុសរបស់គ្រូពេទ្យទេ តែជាកំហុសរបស់បុរសនោះ យ៉ាងណា បុគ្គលកាលត្រូវព្យាធិ គឺកិលេសបៀតបៀន មិនស្វែងរកអាចារ្យដែលជាអ្នកឈ្លាសក្នុងការរម្ងាប់កិលេស សេចក្ដីនោះ មិនមែនជាកំហុសរបស់អាចារ្យ ដែលជាអ្នកធ្វើកិលេសឲ្យវិនាសទៅនោះឡើយ តែជាកំហុសរបស់បុគ្គលនោះ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ទើបលោកពោលថា

**យថា គូថគតោ បុរិសោ តឡាកំ ទិស្វាន បូរិតំ**

ន គវេសតិ តឡាកំ ន ទោសោ តឡាកស្ស សោ ។
ឯវំ កិលេសមលធោវនំ វិជ្ជន្តេ អមតន្តឡេ
ន គវេសតិ តឡាកំ ន ទោសោ អមតន្តឡេ ។

*បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយមិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វាន មានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាង នូវកិលេសជាមន្ទិលចេញទេ ទោសនោះ មិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។*

យថា អរីហិ បរិរុទ្ធោ វិជ្ជន្តេ គមនំ បថេ
ន បលាយតិ សោ បុរិសោ ន ទោសោ អញ្ជសស្ស សោ ។
ឯវំ កិលេសបរិរុទ្ធោ វិជ្ជមានេ សិវេ បថេ
ន គវេសតិ តំ មគ្គំ ន ទោសោ សិវមញ្ជសេ ។

*បុរស ដែលត្រូវសត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះ មិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោស នៃផ្លូវនិព្វានទេ គឺជាទោស*

របស់បុគ្គលនោះឯង យ៉ាងនោះដែរ ។

យថា ព្យាធិតោ បុរិសោ  វិជ្ជមានេ តិកិច្ឆកេ
ន តិកិច្ឆាបេតិ តំ ព្យាធឹ  ន សោ ទោសោ តិកិច្ឆកេ ។
ឯវំ កិលេសព្យាធីហិ  ទុក្ខិតោ បរិបីឡិតោ
ន គវេសតិ អាចរិយំ  ន សោ ទោសោ វិនាយកេ ។

បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយ បៀតបៀនហើយ ដល់នូវសេចក្ដីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះមិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ដូច្នេះ ។

សុមេធបណ្ឌិតពិចារណាដល់ធម៌ដទៃៗ ទៀតថា បុគ្គលអ្នកចូលចិត្តតែងខ្លួន គប្បីបោះបង់សាកសពដែលគេព្យួរត្រង់ក ហើយទៅដោយមានសេចក្ដីសុខយ៉ាងណា សូម្បីអាត្មាអញ ក៏គួរលះបង់កាយស្អុយនេះមិនអាឡោះអាល័យ ចូលទៅកាន់និព្វានមហានគរ ក៏ដូច្នោះដែរ ។

បុរសស្ត្រីទាំងឡាយ បន្ទោបង់ឧច្ចារៈនិងបស្សាវៈ ដាក់លើផែនដីដ៏ស្មោកគ្រោកហើយ មិនប្រាថ្នារើសដុំលាមកដាក់ក្នុងថ្នក់ ឬជាយសំពត់វេចខ្ចប់ទៅ តែងមានសេចក្ដីរង្កៀស មិនមានអាល័យ បោះបង់ចោលទៅ

យ៉ាងណា សូម្បីអាត្មាអញក៏គួរមិនមានអាល័យ បោះបង់នូវកាយស្អុយនេះ ចូលទៅកាន់និព្វានមហានគរដែលជាទីអមតៈ ក៏យ៉ាងនោះដែរ ។ នាយទូកមិនមានអាល័យក្នុងទូកចាស់ ដែលបាក់បែកយ៉ាងណា សូម្បីអាត្មាអញ ក៏នឹងលះបង់រាងកាយដែលរសាប់រសល់ ដែលជាទីហូរចេញនូវរបស់មិនស្អាតតាមទ្វារទាំង ៩ មិនមានអាឡោះអាល័យ ចូលទៅកាន់និព្វានបុរីក៏ដូច្នោះ ។ម្យ៉ាងទៀត បុរសកាន់យករតនៈច្រើនប្រភេទ ធ្វើដំណើរទៅជាមួយពួកចោរ ក៏បោះបង់ពួកចោរទាំងនោះ ព្រោះខ្លាចអន្តរាយដល់រតនៈរបស់ខ្លួន កាន់យកផ្លូវក្សេមយ៉ាងណា ករជកាយ ( កាយដែលកើតអំពីធូលី ) នេះ ក៏ដូច្នោះ ដូចគ្នានឹងចោរដែលប្លន់រតនៈ បើអាត្មាអញធ្វើតណ្ហាឲ្យកើតឡើងក្នុងកាយនេះ រតនៈគឺកុសលធម៌ បានដល់អរិយមគ្គនឹងសាបសូន្យទៅ ព្រោះដូច្នោះ អាត្មាអញគួរលះបង់កាយនេះដែលដូចជាចោរ ហើយទៅកាន់និព្វានមហានគរដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា

យថាបិ កុណបំ បុរិសោ កណ្ឋេ ពទ្ធំ ជិគុច្ឆិយំ
មោចយិត្វាន គច្ឆេយ្យ សុខី សេរី សយំ វសី ។
តថេវិមំ បូតិកាយំ នានាកុណបសញ្ចយំ
ឆឌ្ឌយិត្វាន គច្ឆេយ្យំ អនបេក្ខោ អនត្ថិកោ ។

បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើម ដែលជាប់ព្វដ៏ក

គប្បីជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាច ខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញ គួរតែលះបង់កាយស្អុយ នេះ ដែលជាទីប្រមូលមក នូវសាកសពផ្សេងៗ ចេញ ហើយ គប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ចេញ ទៅ យ៉ាងនោះដែរ ។

យថា ឧស្សាសហានម្ហិ [១] ករីសំ នរនារិយោ
ឆឌ្ឌយិត្វាន គច្ឆន្តិ អនបេក្ខា អនត្តិកា ។
ឯវមេវាហំ ឥម កាយំ នានាកុណបបូរិតំ
ឆឌ្ឌយិត្វាន គច្ឆិស្សំ វច្ចំ កត្វា យថា កុដឹ ។

បុរសស្ត្រីទាំងឡាយ ទៅបន្ទោបង់នូវករីសៈ ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញ ទៅ យ៉ាងណាមិញ ឯអាត្មាអញ នឹងលះបង់នូវកាយស្អុយ នេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរស ស្ត្រីទាំងឡាយ ដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។

យថាបិ ជជ្ជរំ នាវំ បលុត្តំ ឧទកគាហិនឹ
សាមិកា ឆឌ្ឌយិត្វាន អនបេក្ខា អនត្តិកា ។

---

១-ឆដ្ឋសង្គាយនាថា ឧច្ចារដ្ឋានម្ហិ ។

**ឯវមេវាហំ ឥមំ កាយំ នវច្ឆិទ្ទំ ធុវស្សវំ**
**ឆឌ្ឌយិត្វាន គច្ឆិស្សំ ជិណ្ណនាវំ វ សាមិកា ។**

*ម្ចាស់ទូកទាំងឡាយ តែងលះបង់ទូកចាស់ ដែលពុកផុយលេចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូក លះចោលទូកចាស់ ដូច្នោះឯង ។*

**យថា បុរិសោ ចោរេហិ គច្ឆន្តោ ភណ្ឌមាទិយ**
**ភណ្ឌច្ឆេទភយំ ទិស្វា ឆឌ្ឌយិត្វាន គច្ឆតិ ។**
**ឯវមេវ អយំ កាយោ មហាចោរសមោ វិយ**
**បហាយិមំ គមិស្សាមិ កុសលច្ឆេទនា ភយា ។**

*បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅ យ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូតខាតកុសលធម៌ យ៉ាងនោះដែរ ដូច្នេះ ។*

*សុមេធបណ្ឌិត ពិចារណាប្រកបដោយនេក្ខម្មៈយ៉ាងនេះ ដោយឧបមាផ្សេងៗ ហើយ លះនូវគំនរភោគសម្បត្តិរាប់មិនអស់ក្នុងផ្ទះរបស់ខ្លួន*

ដល់មហាជន មនុស្សកំព្រា និងអ្នកដំណើរជាដើម តាមន័យដែលពោល ហើយខាងដើម ធ្វើនូវមហាទាន លះវត្ថុកាមនិងកិលេសកាមហើយ ចេញចាកអមរនគរម្នាក់ឯងប៉ុណ្ណោះ អាស្រ័យភ្នំឈ្មោះថា ធម្មិក ក្នុងព្រៃហិមពាន្ត សាងអាស្រម ធ្វើបណ្ណសាលា និងទីចង្រ្កមដោយកម្លាំងបុណ្យរបស់ខ្លួន វៀរនូវទោសនៃនីវរណៈទាំង ៥ នាំមកនូវកម្លាំង ពោលគឺអភិញ្ញា ប្រកបដោយហេតុដែលជាគុណ ៨ យ៉ាង តាមដែលពោលទុកហើយដោយន័យជាដើមថា **កាលចិត្តតាំងមាំហើយយ៉ាងនេះ** ដូច្នេះហើយ លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការ ទុកក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើដែលប្រកបដោយគុណ ១២ ប្រការ បួសជាឥសីហើយ ។ កាលសុមេធបណ្ឌិតបួសហើយយ៉ាងនេះ ក៏លះបណ្ណសាលានោះ ដែលច្រឡូកច្រឡំដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ ប្រការ លះបង់នូវបាយផ្សេងៗ បរិភោគផ្លែឈើដែលជ្រុះឯង ផ្ដើមតម្កល់សេចក្ដីព្យាយាមដោយការអង្គុយ ការឈរ និងការចង្រ្កម ក្នុងវេលា ៧ ថ្ងៃប៉ុណ្ណោះ ក៏បានអភិញ្ញា ៥ សមាបត្តិ ៨ ដល់នូវកម្លាំងអភិញ្ញាតាមដែលប្រាថ្នាទុក ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលទុកថា

**ឯវាហំ ចិន្តយិត្វាន នេកកោដិសតំ ធនំ**
**នាថានាថានំ ទត្វាន ហិមវន្តំ ឧបាគមឹ ។**

ហិមវន្តស្សាវិទូរេ ធម្មិកោ នាម បព្វតោ
អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។

*លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើអាស្រម សាងបណ្ណ-សាលាក្បែរភ្នំនោះ ។*

ចង្កមំ តត្ថ មាបេសឹ បញ្ចទោសវិវជ្ជិតំ
អដ្ឋគុណសមុបេតំ អភិញ្ញាពលមាហរឹ ។
សាដកំ បជហឹ តត្ថ នវទោសមុបាគតំ
វាកចីរំ និវាសេសឹ ទ្វាទសគុណមុបាគតំ ។

*តថាគត និម្មិតនូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញាពលៈ ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់សាដក ដែលប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការវិញ ។*

អដ្ឋទោសសមាកិណ្ណំ បជហឹ បណ្ណសាលកំ
ឧបាគមឹ រុក្ខមូលំ គុណេហិ ទសហុបាគតំ ។

**វាបិតំ រោបិតំ ជញ្ញ បជហឹ និរវសេសតោ**
**អនេកគុណសម្បន្នំ បវត្តផលមាទយឹ ។**

*លះបង់បណ្ណសាលា ដែលប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង ។ លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។*

**តត្ថប្បធានំ បទហឹ និសជ្ជដ្ឋានចង្កមេ**
**អព្ភន្តរម្ហិ សត្តាហេ អភិញ្ញាពលចាបុណឹ ។**

*តថាគតផ្គង់ព្យាយាមក្នុងអាស្រមបទនោះ ( ញុំាងយប់និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្រ្កម បានលុះអភិញ្ញាពលៈ ក្នុងរវាង ៧ ថ្ងៃ ដូច្នេះ ។*

*ក្នុងគាថានោះ បទថា* **អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា** *លោកពោលសំដៅដល់បណ្ណសាលា ទីចង្រ្កម ហាក់ដូចជាសុមេធបណ្ឌិតធ្វើឡើងដោយដៃខ្លួនឯង តែក្នុងគាថានេះ មានសេចក្ដីដូចតទៅនេះថា សក្កទេវរាជទ្រង់ឃើញថា ព្រះបរមពោធិសត្វចូលទៅកាន់ព្រៃហិមពាន្តហើយ ក្នុងថ្ងៃនេះ នឹងដល់ភ្នំឈ្មោះធម្មិក ទើបត្រាស់ហៅវិស្សុកម្មទេវបុត្តថា នៃបាវិស្សុកម្ម សុមេធបណ្ឌិតចេញមកដោយគិតថា អញនឹងបួស ចូរអ្នកនិម្មិតទីលំនៅឲ្យដល់ព្រះមហាសត្វ ។*

វិស្សុកម្មទេវបុត្តនោះ ទទួលព្រះតម្រាស់របស់សក្កទេវរាជហើយ ក៏និម្មិតអាស្រមគួរជាទីរីករាយ មានបណ្ណសាលាយ៉ាងល្អ ទីចង្ក្រមគួរជាទីត្រេកអរ តែព្រះដ៏មានព្រះភាគអាស្រ័យអាស្រមបទនោះ ដែលសម្រេចដោយអានុភាពនៃបុណ្យរបស់ព្រះអង្គ ទើបត្រាស់ថា

**ហិមវន្តស្សាវិទូរេ ធម្មិកោ នាម បព្វតោ**
**អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា ។**

មានភ្នំមួយ ឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើ
អាស្រម សាងបណ្ណសាលាក្បែរភ្នំនោះ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សុកតោ មយ្ហំ** ប្រែថា តថាគតសាងអាស្រមទុកយ៉ាងល្អហើយ ។

បទថា **បណ្ណសាលា សុមាបិតា** សេចក្តីថា សូម្បីបណ្ណសាលាដែលប្រក់ដោយស្លឹកឈើ ក៏តថាគតសាងទុកល្អហើយ ។

បទថា **បញ្ចទោសវិវជ្ជិតំ** សេចក្តីថា ឈ្មោះថាទោសរបស់ទីចង្ក្រមមាន ៥ យ៉ាងគឺ ផ្ទៃដីរឹងនិងពុំរាបស្មើ ១ មានដើមឈើនៅខាងក្នុងទីចង្ក្រម ១ មានសំរាមឬស្លឹកឈើស្មុគស្មាញ ១ តូចពេក ១ ធំទូលាយពេក ១ ។ ពិតហើយ បុគ្គលកាលដើរចង្ក្រមលើទីចង្ក្រមដែលមានផ្ទៃដីរឹងពុំរាបស្មើ ជើងទាំងពីរនឹងឈឺចាប់ ចិត្តមិនតាំងនៅដោយឯកគ្គតា កម្មដ្ឋាននឹងវិបត្តិ តែកម្មដ្ឋាននឹងដល់ព្រម ព្រោះអាស្រ័យការនៅសប្បាយ

ក្នុងផ្ទៃដីដែលទន់និងរាបស្មើ ព្រោះដូច្នោះ គប្បីជ្រាបថា ផ្ទៃដីដែលរឹងនិងពុំរាបស្មើ ជាទោសប្រការទី ១ ។ កាលដើមឈើនៅខាងក្នុងក្តី នៅត្រង់កណ្តាលក្តី នៅខាងចុងទីចង្ក្រមក្តី កាលអាស្រ័យសេចក្តីប្រមាទដើរចង្ក្រម ថ្ងាសឬក្បាលនឹងប៉ះទង្គិច ព្រោះដូច្នោះ ទើបដើមឈើខាងក្នុងទីចង្ក្រម ជាទោសប្រការ ទី ២ ។ កាលដើរចង្ក្រមក្នុងទីចង្ក្រមដែលស្មុគ-ស្មាញដោយស្មៅនិងវល្លិជាដើម ក្នុងវេលារាត្រី ក៏នឹងជាន់សត្វមានពស់ជាដើម ធ្វើឲ្យសត្វនោះស្លាប់ ឬត្រូវសត្វនោះខាំ បានទទួលសេចក្តីក្តៅក្រហាយ ព្រោះដូច្នោះ ទើបទីចង្ក្រមដែលស្មុគស្មាញ ជាទោសប្រការទី ៣ ។ កាលដើរចង្ក្រមលើទីចង្ក្រមដែលតូចពេក ដែលមានកំណត់ដោយទទឹងត្រឹមតែ ១ ហត្ថឬកន្លះហត្ថ ក្រចកក្តី ម្រាមជើងក្តី នឹងជំពប់ហើយបែក ព្រោះដូច្នោះ ទើបទីចង្ក្រមដែលតូចពេក ជាទោសប្រការទី ៤ ។ កាលដើរចង្ក្រមលើទីចង្ក្រមដែលទូលាយពេក ចិត្តរមែងរាយ-មាយ មិនបាននូវឯកគ្គតាចិត្ត ព្រោះដូច្នោះ ទើបទីចង្ក្រមដែលទូលាយពេក ជាទោសប្រការទី ៥ ។ ទីចង្ក្រមដែលមានទទឹង ១ ហត្ថកន្លះ និងជាយម្ខាង ១ ហត្ថ ( រួមជា ៣ ហត្ថកន្លះ ) [១] បណ្តោយមានប្រមាណ ៦០ ហត្ថ មានផ្ទៃដីទន់ គឺមានខ្សាច់រោយទុកស្មើល្អក៏ប្រើការបាន ដូចទីចង្ក្រម

១- ក្នុងទីខ្លះ លោកពោលត្រឹមតែទទឹងមួយហត្ថកន្លះប៉ុណ្ណោះ ។

របស់ព្រះមហិន្ទត្ថេរដែលទៅផ្សាយសាសនាក្នុងកោះសីហឡ ត្រង់ចេតិយគិរីវិហារដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា តថាគតបានសាងទីចង្ក្រមក្នុងអាស្រមនោះ ដែលវៀរទោស ៥ ប្រការ ។

បទថា **អដ្ឋគុណំ សមុបេតំ** គឺប្រកបដោយសុខរបស់សមណៈ ៨ ប្រការ ឈ្មោះថា សុខរបស់សមណៈ ៨ ប្រការនោះ គឺ មិនមានការហួងហែងទ្រព្យ មានស្រូវអង្ករជាដើម ១ ស្វែងរកតែបិណ្ឌបាតដែលមិនមានទោស ១ បរិភោគតែបិណ្ឌបាតដែលត្រជាក់ ១ មិនមានការបៀតបៀនអំពីព្រះរាជាទាំងឡាយ មានបៀតបៀនដោយភាសី ឬដោយការរឹបអូសយកទ្រព្យ មានតម្លៃនិងកហាបណៈជាដើម ១ ប្រាសចាកតម្រេកដោយការពេញចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ ១ មិនខ្លាចចំពោះភ័យក្នុងរឿងចោរប្លន់ជាដើម ១ មិនច្រឡូកច្រឡំជាមួយព្រះរាជានិងរាជអាមាត្យជាដើម ១ មិនទើសទាក់ក្នុងទិសទាំងបួន ១ ។ លោកពោលអធិប្បាយទុកថា បុគ្គលដែលនៅក្នុងអាស្រមនោះ អាចជួបនូវសេចក្ដីសុខរបស់សមណៈ ៨ យ៉ាង បានយ៉ាងណា តថាគតសាងអាស្រមនោះ ប្រកបដោយគុណ ៨ យ៉ាង ក៏យ៉ាងនោះដែរ ។

បទថា **អភិញ្ញាពលមាហរឹ** សេចក្ដីថា ក្រោយមក កាលតថាគតនៅក្នុងអាស្រមនោះ ធ្វើបរិកម្មនៅក្នុងកសិណហើយ ផ្ដើមវិបស្សនាដោយភាពជារបស់មិនទៀង ជាទុក្ខ ដើម្បីការកើតឡើងនៃអភិញ្ញានិងសមាបត្តិ

ហើយ ក៏បាននូវវិបស្សនាដ៏មានកម្លាំង អធិប្បាយថា កាលតថាគតនៅក្នុងអាស្រមនោះ អាចនាំកម្លាំងមកបានដោយប្រការណា តថាគតបានសាងអាស្រមនោះ ធ្វើឲ្យសមគួរដល់កម្លាំងវិបស្សនា ដើម្បីប្រយោជន៍ដល់អភិញ្ញាដោយប្រការនោះ ។

ក្នុងបទថា **សាជកំ បជហឹ តត្ថ ឆវទោសមុបាគតំ** មានពាក្យពោលទុកតាមលំដាប់ដូចតទៅនេះថា

បានឮថា ក្នុងកាលនោះ កាលវិស្សកម្មទេវបុត្តនិម្មិតអាស្រមនោះ ដែលប្រកបដោយខ្ទម ទីសម្ងំ និងទីចង្ក្រម មួយអន្ទើដោយផ្លូវកោង ដេរ-ដាសទៅដោយដើមឈើចេញផ្លែនិងផ្កា មានទឹកប្រកបដោយរសឆ្ងាញ់ គួរជាទីត្រេកអរ ប្រាសចាកសត្វសាហាវ និងបក្សីដែលមានសំឡេងគួរខ្លាចផ្សេងៗ គួរដល់ការស្ងប់ស្ងាត់ និម្មិតនូវភ្នាក់ដែលសម្រាប់ផ្អែកក្នុងទីបំផុតនៃទីចង្ក្រម និម្មិតដុំថ្មដែលមានពណ៌ដូចសណ្តែកបាយ មានផ្ទៃរាបស្មើ ទុកក្បែរទីចង្ក្រម ( ត្រង់ពាក់កណ្តាលនៃទីចង្ក្រមនោះ ) ។ ក្នុងខាងក្នុងបណ្ណ-សាលា និម្មិតវត្ថុគ្រប់យ៉ាងដែលប្រព្រឹត្តទៅដើម្បីឧបការដល់បព្វជិត យ៉ាងនេះ គឺ ជដាមណ្ឌល ( ជដាមូល ) សំពត់សម្បកឈើ បរិក្ខាររបស់តាបស មានឈើចម្លាមបីជាដើម ត្រង់បន្ទប់ទឹក មានក្អមទឹកផឹក ស័ង្ខសម្រាប់ដងទឹក និងផ្តិលសម្រាប់ដងទឹកជាដើម ត្រង់រោងភ្លើង មានអំបែងសម្រាប់ដាក់រងើកភ្លើងនិងឧសជាដើម ត្រង់ជញ្ជាំងបណ្ណសាលា មានរចនាអក្សរ

ទុកថា **បុគ្គលណាទីមួយមានបំណងនឹងបួស ចូរកាន់យកបរិក្ខារទាំងនេះបួសចុះ** ហើយក៏ត្រឡប់ទៅកាន់ទេវលោកវិញ ។ សុមេធបណ្ឌិតទៅកាន់ព្រៃហិមពាន្តតាមផ្លូវដែលជាញកភ្នំ សម្លឹងឃើញទីដែលជាផាសុកគួរអាស្រ័យនៅរបស់ខ្លួន និងអាស្រមគួរជាទីត្រេកអរ ដែលវិស្សុកម្មទេវបុត្តនិម្មិតទុក ដែលសក្កទេវរាជប្រទានឲ្យ ក្នុងទីដែលហូរមកនៃស្ទឹង ទើបទៅកាន់ទីចង្ក្រម មិនបានឃើញស្នាមជើង ក៏គិតថា បព្វជិតស្វែងរកភិក្ខាក្នុងស្រុកជិតហើយហាត់នឿយ ចូលទៅក្នុងបណ្ណសាលាអង្គុយហើយ ។ ( សុមេធបណ្ឌិត ) រង់ចាំបន្តិច គិតថា បព្វជិតយឺតយូរពន់ពេក អញចង់ដឹងថា តើក្នុងសាលានេះមានអ្វី ទើបបើកទ្វារចូលទៅក្នុងបណ្ណសាលាពិនិត្យមើលឆ្វេងស្តាំ អានអក្សរត្រង់ជញ្ជាំងហើយគិតថា កប្បិយបរិក្ខារទាំងនេះជារបស់អញ អញនឹងកាន់យកបរិក្ខារទាំងនេះបួស ទើបដោះសំពត់សាដកទាំងគូដែលខ្លួនស្លៀកដណ្តប់មក ព្រោះហេតុនោះ ទើបលោកពោលថា តថាគតដោះសំពត់សាដកទុកក្នុងបណ្ណសាលានោះ ។ ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត តថាគតចូលទៅខាងក្នុងយ៉ាងនេះហើយ ដោះសំពត់សាដកដែលប្រកបដោយទោស ៩ ប្រការទុកក្នុងបណ្ណសាលានោះ ព្រោះដូច្នោះ កាលតថាគតដោះសំពត់សាដកក៏ដោះចោលទៅ ព្រោះឃើញទោស ៩ ប្រការ ។ ពិតហើយ សម្រាប់បុគ្គលដែលបួសជាតាបស ទោស ៩ ប្រការ រមែងប្រាកដក្នុងសំពត់សាដក

គឺមានតម្លៃច្រើន ជាទោស ១ កើតឡើងព្រោះទាក់ទងនឹងអ្នកដទៃ ជាទោស ១ សៅហ្មងរហ័សព្រោះការប្រើប្រាស់ ជាទោស ១ សៅហ្មងហើយចាំបាច់ត្រូវជួសជុល ត្រូវបោកនិងជ្រលក់ ការដែលចាស់ទៅព្រោះការប្រើប្រាស់នោះ ជាទោស ១ សម្រាប់សំពត់ដែលចាស់ហើយ ត្រូវធ្វើការដេរប៉ះ ការដែលបានទទួលដោយការស្វែងរកទៀតក៏លំបាក ជាទោស ១ មិនសមជាមួយការបួសជាតាបស ជាទោស ១ ជារបស់ទូទៅដល់សត្រូវ ជាទោស ១ ព្រោះត្រូវគ្រប់គ្រងដោយអាការកុំឲ្យសត្រូវកាន់យកបាន និងជាគ្រឿងប្រដាប់ ( អលង្ការ ) របស់បុគ្គលដែលប្រើប្រាស់ ជាទោស ១ សម្រាប់បុគ្គលដែលត្រាច់ទៅ ( ឈ្មោះថា ) ជាបុគ្គលប្រាថ្នាច្រើន ក្នុងវត្ថុដែលជារបស់ប្រើប្រាស់ប្រចាំខ្លួន ជាទោស ១ ។

បទថា **វាកចីរំ និវាសេសឹ** សេចក្តីថា ម្នាលសារីបុត្ត កាលនោះ តថាគតឃើញទោស ៩ ប្រការនេះ ទើបដោះចោលនូវសំពត់សា - ដក ស្លៀកនូវសំពត់សម្បកឈើ ប្រើប្រាស់សំពត់សម្បកឈើដែលច្រៀកស្មៅជំណោកទន្សាយឲ្យជាចម្រៀកតូចធំ ត្បាញហើយ ធ្វើឡើងដើម្បីប្រ-យោជន៍ប្រើប្រាស់ជាសំពត់ស្លៀកដណ្តប់ ។

បទថា **ទ្វាទសគុណមុបាគតំ** គឺ ប្រកបដោយអានិសង្ស ១២ ប្រការ ក្នុងសំពត់សម្បកឈើមានអានិសង្ស ១២ ប្រការ គឺ តម្លៃថោកសមគួរ នេះជាអានិសង្សទី ១ អាចធ្វើដោយដៃឯង នេះជាអានិសង្សទី ២

សៅហ្មងយឺតដោយការប្រើប្រាស់ សូម្បីបោកក៏មិនយឺតយូរ នេះជាអានិ-សង្សទី ៣ សូម្បីចាស់ទៅព្រោះការប្រើប្រាស់ក៏មិនចាំបាច់ដេរ នេះជាអានិសង្សទី ៤ កាលស្វែងរកជាថ្មីក៏ធ្វើបានងាយ នេះជាអានិសង្សទី ៥ សមគួរដល់ការបួសជាតាបស នេះជាអានិសង្សទី ៦ បុគ្គលដែលជាសត្រូវមិនប្រើប្រាស់ នេះជាអានិសង្សទី ៧ កាលប្រើប្រាស់ក៏មិនជាទីតាំងនៃការប្រដាប់តាក់តែង នេះជាអានិសង្សទី ៨ កាលស្លៀកដណ្ដប់ក៏ស្រាល នេះជាអានិសង្សទី ៩ បញ្ជាក់ថាជាអ្នកប្រាថ្នាតិចក្នុងបច្ច័យ គឺចីវរ នេះជាអានិសង្សទី ១០ ការកើតឡើងនៃសំពត់សម្បកឈើជារបស់កើតឡើងដោយធម៌ មិនមានទោស នេះជាអានិសង្សទី ១១ កាលសំពត់សម្បកឈើនោះវិនាសទៅ ក៏មិនមានអាល័យ នេះជាអានិសង្ស ទី ១២ ។

បទថា **អដ្ឋទោសសមាកិណ្ណំ បជហឹ បណ្ណសាលកំ** សេចក្ដីថា តថាគតលះបង់ដូចម្ដេច ? បានឮថា សុមេធបណ្ឌិតនោះដោះសំពត់សាដកដែលមានសាច់ល្អទាំងគូចេញហើយ កាន់យកសំពត់សម្បកឈើពណ៌ក្រហមដូចផ្កានទោង ដែលពាក់ត្រង់ស្នូចីវរ ហើយស្លៀក ១ ផ្ទាំង ដណ្ដប់សំពត់សម្បកឈើដែលមានពណ៌ដូចមាស ១ ផ្ទាំងទៀតលើសំពត់សម្បកឈើនោះ ធ្វើស្បែកខ្លាទាំងក្រចកដូចគ្នានឹងសណ្ឋានរបស់ផ្កាបុសនាគធៀងស្មាម្ខាង ប្រមូលជដាមណ្ឌលហើយដោតនូវស្នៀតសក់ត្រង់ផ្នួងសក់នោះ ធ្វើមិនឲ្យកម្រើកបាន ដាក់កុណ្ឌីទឹកដែលមាន

ពណ៌ដូចកែវប្រពាល ក្នុងសង្រ្វែកដែលមានពណ៌ដូចកែវមុក្តា កាន់ដង-វែកកោងក្នុងទីបីអន្លើ ពាក់កុណ្ឌិទឹកត្រង់ចុងដងវែក តម្លក់ កំប្រោង និង ឈើដែលមានចម្លាមបី ពាក់ត្រង់ចុងម្ខាង វែកបរិក្ខារលើស្មា ដៃស្តាំកាន់ ឈើច្រត់ចេញពីបណ្ណសាលា ដើរចង្រ្កមលើទីចង្រ្កមដែលមានបណ្តោយ ៦០ ហត្ថ សម្លឹងមើលភេទរបស់ខ្លួនហើយគិតថា មនោរថរបស់អញដល់ ទីបំផុតហើយ បព្វជ្ជារបស់អញល្អពិតហ្ន៎ ឈ្មោះថាបព្វជ្ជានេះ អ្នកប្រាជ្ញ ទាំងពួង មានព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធជាដើម សរសើរហើយ ចំណងនៃ គ្រហស្ថអញលះបង់ហើយ អញកំពុងចេញបួស អញចេញបួសហើយ បាននូវបព្វជ្ជាដ៏ឧត្តម អញនឹងធ្វើសមណធម៌ អញនឹងបានសុខដែល កើតអំពីមគ្គផល ដូច្នេះហើយ កើតនូវឧស្សាហៈ ដាក់ដងវែកនិងបរិក្ខារ ចុះ អង្គុយលើផ្ទាំងថ្មដែលមានពណ៌ដូចសណ្តែកបាយ ប្រៀបដូចបដិមា មាសដូច្នោះ ឲ្យពេលថ្ងៃកន្លងទៅ ចូលកាន់បណ្ណសាលាក្នុងពេលល្ងាច ដេកលើកន្ទេលផែងដែលត្បាញដោយមែកឈើនិងផ្តៅ ឲ្យខ្លួនបានទទួល អាកាសល្មមជាទីសប្បាយ ហើយក្រោកឡើងក្នុងវេលាទៀបភ្លឺ ពិចារណា ដល់ការមករបស់ខ្លួនថា អញឃើញទោសក្នុងឃរាវាសហើយ លះបង់ ភោគសម្បត្តិរាប់មិនអស់និងយសមិនមានទីបំផុត ចូលកាន់ព្រៃបួស ស្វែង រកនេក្ខម្មៈ ចាប់តាំងពីពេលនេះទៅ អញនឹងប្រព្រឹត្តខ្លួនដោយសេចក្តីមិន ប្រមាទ ព្រោះរុយគឺមិច្ឆាវិតក្ក រមែងខាំស៊ីនូវបុគ្គលដែលលះបង់នូវវិវេក

ត្រាច់ទៅ ។ ឥឡូវនេះ អញគួរចម្រើននូវសេចក្ដីស្ងប់ ព្រោះថា អាត្មាអញឃើញការនៅគ្រប់គ្រងផ្ទះ ដោយភាពជារបស់មានតែកង្វល់ ទើបចេញមក ។ បណ្ណសាលាគួរពេញចិត្តនេះ មានផ្ទៃដីរាបស្មើ ព័ទ្ធដោយរបងមានពណ៌ដូចផ្លៃព្នៅទុំ មានជញ្ជាំងពណ៌សដូចកម្រាលប្រាក់ ដំបូលស្លឹកឈើមានពណ៌ដូចជើងព្រាប គ្រែផ្ដៅមានពណ៌ដ៏ស្រស់ស្អាត គួររស់នៅយ៉ាងផាសុក ការដល់ព្រមនៃផ្ទះរបស់អាត្មាអញប្រាកដដូចនឹងមានក្រៃលែងជាងនេះ ដូច្នេះ ។ ពិចារណាទោសរបស់បណ្ណសាលា ក៏បានឃើញទោស ៨ ប្រការ ។ ពិតហើយ ក្នុងការប្រើប្រាស់បណ្ណសាលាមានទោស ៨ ប្រការគឺ ត្រូវស្វែងរកដោយការប្រមូលទព្វសម្ភារយកមកធ្វើ ជាទោសទី ១ ត្រូវជួសជុលជានិច្ច ព្រោះកាលស្មៅ ស្លឹកឈើ និងដីឥដ្ឋជ្រុះមក ត្រូវយករបស់ទាំងនោះចេញ ហើយបន្ថែមរបស់ថ្មីចូលទៅ នេះជាទោសទី ២ ធម្មតាសេនាសនៈតែងបានដល់បុគ្គលជាថេរៈ ( ចាស់ជាង ) កាលជនដែលចាស់ជាងចូលមក ឲ្យអញក្រោកឡើងក្នុងវេលាមិនសមគួរ ឯកគ្គតាចិត្តក៏មិនមាន ព្រោះដូច្នោះ កាលដែលត្រូវដាស់ឲ្យក្រោកឡើង ទើបជាទោសទី ៣ ព្រោះកម្ចាត់បង់នូវរងានិងកម្ដៅ ក៏ធ្វើឲ្យរាងកាយចុះខ្សោយ នេះជាទោសទី ៤ បុគ្គលចូលទៅកាន់ផ្ទះ អាចធ្វើអាក្រក់ណាមួយបាន ព្រោះដូច្នោះ ទីបិទបាំងគួរតិះដៀល ជាទោសទី ៥ ការហួងហែងដោយគិតថា នេះជារបស់អញ ជាទោសទី ៦ ធម្មតាការមានផ្ទះ

បញ្ញាក់ថាជារបស់បុគ្គលដែលមានភរិយា នេះជាទោសទី ៧ ជារបស់សាធារណៈដល់ជនច្រើន ព្រោះជាសាធារណៈដល់សត្វមានសុច សង្កើច និងតុកកែជាដើម ជាទោស ទី ៨ ។ ព្រះមហាសត្វឃើញទោស ៨ ប្រការយ៉ាងនេះហើយ ក៏លះបង់បណ្ណសាលា ព្រោះហេតុនោះ ទើបលោកពោលថា តថាគតលះបង់បណ្ណសាលាដែលច្រឡូកច្រឡំដោយទោស ៨ ប្រការ ។

បទថា **ឧបាគមឹ រុក្ខមូលំ គុណេហិ ទសហុបាគតំ** សេចក្តីថា ព្រះដ៏មានព្រះភាគត្រាស់ថា តថាគតហាមទីប្រក់ទីបាំង ចូលទៅរកគល់ឈើដែលប្រកបដោយគុណ ១០ ប្រការ ។ គុណ ១០ ប្រការនោះ មានដូចតទៅនេះថា មានការខ្វល់ខ្វាយតិច ជាគុណទី ១ គ្រាន់តែចូលទៅប៉ុណ្ណោះ ក៏នៅក្នុងទីនោះបាន ព្រោះដូច្នោះ ទើបមិនចាំបាច់ថែរក្សា ជាគុណទី ២ ក្នុងទីនោះ ទោះបោសក្តី មិនបោសក្តី ក៏ប្រើប្រាស់បានតាមសប្បាយ មិនចាំបាច់ព្យាយាមខ្លាំងក្លាពេក ជាគុណទី ៣ ទីនោះបិទបាំងដោយការនិន្ទាមិនបាន ព្រោះកាលបុគ្គលធ្វើអាក្រក់ក្នុងទីនោះរមែងខ្មាស ព្រោះដូច្នោះ ការបិទបាំងនូវការនិន្ទាមិនបាន ជាគុណទី ៤ គល់ឈើដូចគ្នានឹងនៅក្នុងទីវាល ព្រោះមិនញ៉ាំងរាងកាយឲ្យទន់ គឺឲ្យរឹងមាំ ព្រោះដូច្នោះ ទើបជាគុណទី ៥ មិនមានការត្រូវធ្វើនូវការហួងហែង ជាគុណទី ៦ ហាមបាននូវសេចក្តីអាល័យក្នុងលំនៅ ជាគុណទី ៧

មិនមានការដែលត្រូវពោលថា អ្នកចូរចេញសិន ខ្ញុំនឹងបោស ខ្ញុំនឹងជូត ហើយដេញទៅដូចផ្ទះទូទៅ នេះជាគុណទី ៨ បុគ្គលអ្នកនៅក៏បាន ទទួលនូវបីតិ នេះជាគុណទី ៩ មិនចាំបាច់អាល័យក្នុងអារម្មណ៍ ព្រោះសេនាសនៈគឺគល់ឈើរកបានងាយ ទោះទៅក្នុងទីណា ក៏អាចរកបាន នេះជាគុណទី ១០ ព្រះមហាសត្វឃើញគុណ ១០ យ៉ាងនេះ ទើបពោលថា តថាគតចូលអាស្រ័យត្រង់គល់ឈើ ដូច្នេះ ។ ព្រះមហាសត្វកំណត់ហេតុមានប្រមាណប៉ុណ្ណោះហើយ ស្អែកឡើងក៏ចូលទៅដើម្បីភិក្ខា ។

គ្រានោះ ពួកមនុស្សក្នុងស្រុកដែលព្រះពោធិសត្វទៅដល់ បានប្រគេនភិក្ខាដោយឧស្សាហៈដ៏ធំ ព្រះពោធិសត្វធ្វើភត្តកិច្ចហើយមកកាន់អាស្រមអង្គុយចុះ គិតថា អញបួសដោយគិតថា នឹងបានអាហារក៏មិនមែន ធម្មតាអាហារដែលឆ្ងាញ់នេះ រមែងញ៉ាំងនូវសេចក្តីស្រវឹងដោយអំណាចនៃមានះ និងស្រវឹងដោយអំណាចនៃបុរសឲ្យចម្រើន ទីបំផុតនៃទុក្ខដែលមានអាហារជាមូលមិនមានឡើយ បើដូច្នោះ អាត្មាអញគប្បីលះបង់អាហារដែលកើតអំពីស្រូវ ដែលគេសាបព្រោះ បរិភោគផ្លៃឈើដែលជ្រុះឯង ដូច្នេះ ។

ចាប់តាំងអំពីពេលនោះមក ព្រះពោធិសត្វធ្វើយ៉ាងនោះ បំពេញព្យាយាមក្នុង ១ សប្តាហ៍ ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើងហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ភាបិតំ ភេបិតំ ចញ្ញំ   បជហឹ និរវសេសតោ
អនេកគុណសម្បន្នំ   បវត្តផលមាទយឹ ។

*លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការដូច្នេះ ។*

*កាលសុមេធតាបសសម្រេចអភិញ្ញាពលៈយ៉ាងនេះហើយ ឲ្យពេលវេលាកន្លងទៅដោយសុខដែលកើតអំពីសមាបត្តិ ។ ព្រះបរមសាស្តា ព្រះនាមថា ទីបង្ករ ទ្រង់កើតឡើងហើយក្នុងលោក កាលទ្រង់បដិសន្ធិ ប្រសូតត្រាស់ដឹង និងកាលទ្រង់ប្រកាសធម្មចក្ក លោកធាតុទាំង ១ ម៉ឺនញាប់ញ័រខ្ទរខ្ទារទាំងអស់ បុព្វនិមិត្ត ៣២ ប្រការ ប្រាកដឡើងហើយ ។ សុមេធបណ្ឌិតឲ្យពេលវេលាកន្លងទៅដោយសុខដែលកើតអំពីសមាបត្តិ មិនបានឮសំឡេងនោះឡើយ ថែមទាំងមិនបានឃើញនិមិត្តទាំងនោះដែរ ព្រោះហេតុនោះ ទើបលោកពោលថា*

ឯវំ មេ សិទ្ធិបត្តស្ស   វសីភូតស្ស សាសនេ
ទីបង្ករោ នាម ជិនោ   ឧប្បជ្ជិ លោកនាយកោ ។
ឧប្បជ្ជន្តេ ច ជាយន្តេ   ពុជ្ឈន្តេ ធម្មទេសនេ
ចតុរោ និមិត្តេ នាទ្ទសំ   ឈានរតិសមប្បិតោ ។

*កាលតថាគត សម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុង*

សាសនានៃតាបស កាលនោះ ព្រះជិនស្រី ព្រះនាមទីបង្ករ ជានាយកនៃលោក ទ្រង់កើតឡើង ។ កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្តែងធម្មចក្រផង តថាគតជាអ្នកឆ្អែតស្កប់ស្កល់ ដោយសេចក្តីត្រេកអរក្នុងឈាន ប៉ុន្តែមិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ដូច្នេះ ។

ក្នុងកាលនោះ ព្រះទសពលព្រះនាមទីបង្ករ មានព្រះខីណាស្រព ៤ សែនចោមរោមហើយ ទ្រង់ចារិកទៅតាមលំដាប់ ដល់នគរឈ្មោះរម្មៈ ទ្រង់ប្រថាប់នៅក្នុងសុទស្សនមហាវិហារ ។ ពួកអ្នកស្រុករម្មនគរ បានដំណឹងថា ព្រះសម្ពុទ្ធទ្រង់ព្រះនាមទីបង្ករ ជាធំជាងសមណៈ ទ្រង់សម្រេចសម្ពោធិដ៏ក្រៃលែង ទ្រង់ប្រកាសធម្មចក្រដ៏បវរ យាងមកដោយលំដាប់ដល់រម្មនគរហើយ ទ្រង់គង់នៅក្នុងសុទស្សនមហាវិហារ ក៏នាំគ្នាកាន់ភេសជ្ជៈ មានសប្បិនិងនវនីត មួយអន្លើដោយសំពត់ ផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃនៅក្នុងទីណា ក៏នាំគ្នាជាប់តាមទៅក្នុងទីនោះៗ ចូលគាល់ព្រះសាស្តាហើយថ្វាយបង្គំ បូជាដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម អង្គុយក្នុងទីសមគួរ ស្តាប់ព្រះធម្មទេសនាហើយក្រាបទូលនិមន្តដើម្បីទ្រង់សោយក្នុងថ្ងៃស្អែក ហើយនាំគ្នាក្រោកចាកទីអង្គុយចៀសចេញទៅ ។ ក្នុងថ្ងៃស្អែកឡើង នាំគ្នាត្រៀមមហាទានប្រដាប់តាក់តែងនគរ ធ្វើផ្លូវដើម្បីការយាងមករបស់ព្រះទសពល ក្នុងទី

ដែលមានទឹកច្រោះដាច់និងទីដែលពុំរាបស្មើ រោយខ្សាច់ដែលមានពណ៌ដូចផែនប្រាក់មួយអន្លើដោយផ្កា ដោតទង់ជ័យនិងទង់ផ្កាលា មានពណ៌ផ្សេងៗ តម្កល់ដើមចេកនិងក្អមដែលពេញដោយទឹក តម្រៀបគ្នាជាជួរ ។ ក្នុងកាលនោះ សុមេធតាបសហោះមកអំពីអាស្រមរបស់ខ្លួនតាមផ្លូវអាកាស ខាងលើពួកមនុស្សទាំងនោះ ឃើញពួកមនុស្សទាំងនោះត្រេកអររីករាយ ក៏គិតថា មានហេតុអ្វីហ្ន៎ ទើបចុះអំពីអាកាសមក ឈរក្នុងទីសមគួរមួយកន្លែង សួរជនទាំងនោះថា នៃអ្នកដ៏ចម្រើនទាំងឡាយ ពួកអ្នកនាំគ្នាតាក់តែងផ្លូវនេះ ដើម្បីអ្នកណា ? ព្រោះហេតុនោះ ទើបលោកពោលថា

បច្ចន្តទេសវិសយេ និមន្តេត្វា តថាគតំ
តស្ស អាគមនំ មគ្គំ សោធេន្តិ តុដ្ឋមានសា ។

ពួកមហាជនក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះតថាគត បាននាំគ្នាជម្រះផ្លូវជាទីមក នៃព្រះតថាគតនោះ ។

អហន្តេន សមយេន និក្ខមិត្វា សកស្សមា
ធុនន្តោ វាកចីរានិ គច្ឆាមិ អម្ពរេ តទា ។
វេទជាតំ ជនំ ទិស្វា តុដ្ឋហដ្ឋំ បមោទិតំ
ឱរោហិត្វាន គគនា មនុស្សេ បុច្ឆិ តាវទេ ។
តុដ្ឋហដ្ឋោ បមុទិតោ វេទជាតោ មហាជនោ

កស្ស សោធិយតី មគ្គោ អញ្ជសំ វដុមាយនំ ។

*សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាល រលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញ ជនកំពុងតែពេញចិត្តត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះ អំពីអាកាសហើយសួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយ រីករាយ ពេញចិត្ត ជម្រះ ផ្លូវ គន្ទង ប្រឡាយ ដើម្បីអ្នកណា ដូច្នេះ ។*

*ពួកមនុស្សទាំងនោះ ឆ្លើយថា បពិត្រសុមេធដ៏ចម្រើន លោកមិន ជ្រាបទេឬ ព្រះពុទ្ធទីបង្ករ ព្រះអង្គសម្រេចសម្ពោធិញ្ញាណហើយ ទ្រង់ ប្រកាសព្រះធម្មចក្រដ៏ប្រសើរ ទ្រង់ចារិកមកដល់នគររបស់ពួកយើង ហើយ ទ្រង់ស្នាក់នៅត្រង់សុទស្សនមហាវិហារ ពួកយើងនិមន្តព្រះបរម សាស្តាអង្គនោះមក ទើបតាក់តែងផ្លូវនេះ ដែលជាទីយាងមករបស់ព្រះ អង្គ ។ សុមេធតាបសគិតថា ត្រឹមតែពាក្យប្រកាសថា ពុទ្ធោ ពុទ្ធោ ក៏ រកបានដោយក្រក្នុងលោក នឹងពោលទៅថ្វីដល់ការកើតឡើងនៃព្រះពុទ្ធ ឯអាត្មាអញក៏គួររួមចំណែកជាមួយពួកមនុស្សទាំងនេះ ដើម្បីធ្វើផ្លូវថ្វាយ ព្រះទសពលផងដែរ ទើបពោលនឹងពួកមនុស្សទាំងនោះថា នែអ្នកដ៏ ចម្រើនទាំងឡាយ បើពួកអ្នកតាក់តែងផ្លូវនេះដើម្បីព្រះសម្ពុទ្ធ ចូរឲ្យឱកាស មួយចំណែកដល់ខ្ញុំចុះ ខ្ញុំនឹងធ្វើផ្លូវនេះថ្វាយព្រះទសពលជាមួយនឹងពួក*

អ្នកដែរ ។ ពួកមនុស្សទាំងនោះទទួលថា សាធុ ដឹងថា សុមេធបណ្ឌិត មានឫទ្ធិច្រើន ទើបឲ្យផ្លូវដែលទឹកច្រោះដោយពោលថា សូមលោកធ្វើក្នុងទីនេះចុះ ហើយប្រគល់ឲ្យ ។ សុមេធតាបសកាន់យកព្រះពុទ្ធជាអារម្មណ៍ប្រកបដោយបីតិ គិតថា អាត្មាអញអាចតាក់តែងផ្លូវនេះ ដោយឫទ្ធិបាន តែកាលអាត្មាអញធ្វើដូច្នោះ ចិត្តមិនត្រេកអរ ថ្ងៃនេះ អញគួរធ្វើការងារនេះដោយកម្លាំងកាយ ដូច្នោះហើយ ជញ្ជូនដីមកចាក់ក្នុងទីនោះ កាលទីនោះមិនទាន់ស្រេច ព្រះទសពលទីបង្ករ មានព្រះខីណាស្រពអ្នកបានអភិញ្ញា ៦ មានអានុភាពច្រើន ៤ សែនរូបចោមរោម ទ្រង់យាងមកដោយពុទ្ធលីលាមិនមានប្រមាណ តាមផ្លូវដែលមហាជនតាក់តែងហើយនោះ ដូចរាជសីហ៍យាត្រាលើផ្ទាំងមនោសិលាដូច្នោះ ។ ពួកទេវតាក៏បូជាដោយផ្កាកម្រង និងគ្រឿងក្រអូបដ៏ជាទិព្វ តូរ្យតន្ត្រីក៏បន្លឺឡើង ពួកមនុស្សក៏បូជាដោយផ្កាកម្រងជាដើម ។ កាលព្រះទសពលទីបង្ករកំពុងយាងមកនោះ សុមេធបណ្ឌិតបើកភ្នែកទាំងគូ សម្លឹងមើលព្រះវរកាយរបស់ទ្រង់ដែលដល់នូវលម្អដ៏លើស ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ លម្អដោយអនុព្យញ្ជនៈ ៨០ ប្រការ ចោមរោមដោយព្រះរស្មីប្រមាណ ១ ព្យាម ទ្រង់បញ្ចេញឆព្វណ្ណរង្សីទាំង ៦ ពណ៌ ដូចផ្លេកបន្ទោរក្នុងលំហមេឃ មានពណ៌ដូចកែវមណី ធ្លៀលធ្លាត់ទៅមកជាគូៗ ទើបគិតថា ថ្ងៃនេះ អញគួរធ្វើការបរិច្ចាគជីវិតដល់ព្រះទសពល ព្រោះ

ដូច្នោះ សូមព្រះដ៏មានព្រះភាគ ទ្រង់កុំបីជាន់ភក់ សូមទ្រង់ជាន់លើខ្នង របស់អាត្មាអញ យាងទៅមួយអន្ទើដោយព្រះខីណាស្រព ៤ សែនអង្គ ដូចជាន់ស្ពានកែវមណីចុះ សេចក្ដីនេះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្ដីសុខដល់អាត្មាអញអស់កាលយូរ ។ គិតដូច្នេះហើយ ស្រាយផ្នួងសក់ចេញ លាតសំពត់ស្បែកខ្លា ដោះជដានិងសំពត់សម្បកឈើដាក់លើភក់ដែលមានពណ៌ខ្មៅ ដេកលើភក់ដូចស្ពានកែវមណី ព្រោះហេតុនោះ ទើបលោកពោលថា

តេ មេ បុដ្ឋា វិយាកំសុ ពុទ្ធោ លោកេ អនុត្តរោ
ទីបង្ករោ នាម ជិនោ ឧប្បជ្ជិ លោកនាយកោ
តស្ស សោធិយតេ មគ្គោ អញ្ជសំ វដុមាយនំ ។

ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ ជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្លង ប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។

ពុទ្ធោតិ មម សុត្វាន បីតិ ឧប្បជ្ជិ តាវទេ
ពុទ្ធោ ពុទ្ធោតិ កថយន្តោ សោមនស្សំ បវេទយឹ ។
តត្ថ ឋត្វា វិចិន្តេសឹ តុដ្ឋោ សំវិគ្គមានសោ
ឥធ វីជានិ រោបិស្សំ ខណោ វេ មា ឧបច្ចគា ។

*បីតិកើតឡើងដល់តថាគត ក្នុងខណៈនោះ ព្រោះតែឮពាក្យថាព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ហើយក៏បាននូវសោមនស្ស ។ តថាគតឋិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្ដុះពូជកុសលក្នុងបុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។*

**យទិ ពុទ្ធស្ស សោតេច ឯកោកាសំ ទទាថ មេ**
**អហំបិ សោធយិស្សាមិ អញ្ជសំ វដុមាយនំ ។**
**អទំសុ តេ មមោកាសេ សោធេតុំ អញ្ជសំ តទា**
**ពុទ្ធោ ពុទ្ធោតិ ចិន្តេន្តោ មគ្គំ សោធេមហន្តទា ។**

*(លុះគិតដូច្នេះហើយ ក៏និយាយទៅរកមហាជនថា) បើអ្នកទាំងឡាយជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មានឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជនទាំងនោះ ក៏ឲ្យឱកាសមួយ ដល់តថាគតដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្ដើរក្នុងឱកាសនោះ ។*

**អនិដ្ឋិតេ មមោកាសេ ទីបង្ករោ មហាមុនិ**
**ចតូហិ សតសហស្សេហិ ឆឡភិញ្ញេហិ តាទិហិ**
**ខីណាសវេហិ វិមលេហិ បដិបជ្ជិ អញ្ជសំ ជិនោ ។**

កាលដែលឱកាស (ផ្លូវ) របស់តថាគត ធ្វើមិនទាន់សម្រេច នៅឡើយ ស្រាប់តែព្រះជិនស្រីជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្ដេចយាងមកតាមផ្លូវជាមួយនឹងព្រះខីណាស្រព ៤ សែនរូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាកមន្ទិល ។

**បច្ចុគ្គមនា វត្តន្តិ　　វជ្ជន្តិ ភេរិយោ ពហូ**
**អាមោទិតា នរមរូ　　សាធុការំ បវត្តយុំ ។**
**ទេវា មនុស្សេ បស្សន្តិ　　មនុស្សា បស្សន្តិ ទេវតា**
**ឧភោបិ តេ បញ្ចូលិកា[១]　　អនុយន្តិ តថាគតំ ។**

ការក្រោកទទួល (ព្រះសាស្ដា) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយ ជាច្រើន ក៏លាន់ឮឡើងគគ្រឹកគគ្រេង ពួកមនុស្សនិងទេវតា ក៏ ត្រេកអរ ញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅ ។ ពួកទេវតាឃើញពួក មនុស្ស ឯពួកមនុស្សក៏ឃើញពួកទេវតា ទេវតានិងមនុស្ស ទាំងពីរពួកនេះ បានផ្គងអញ្ជលី ដើរដង្ហែព្រះតថាគត ។

**ទេវា ទិព្វេហិ តុរិយេហិ　　មនុស្សា មានុសកេហិ ច**
**ឧភោបិ តេ វជ្ជយន្តា　　អនុយន្តិ តថាគតំ ។**
**ទិព្វំ មន្ទារវំ បុប្ផំ　　បទុមំ ចារិឆត្តកំ**

---

១- ឆដ្ឋសង្គាយនាថា បញ្ជលិកា ។

**ទិសោទិសំ ឱតិរន្តិ អាកាសេ ឯកតា មរូ ។**

*ពួកទេវតាប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្សក៏ប្រគំតូរ្យ-តន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទាររវបុស្ស ផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាសអំពីទិសតូចទិសធំ ។*

**ទិព្វំ ចន្ទនចុណ្ណញ្ច វរគន្ធញ្ច កេវលំ**
**ទិសោទិសំ ឱតិរន្តិ អាកាសេ ឯកតា មរូ ។**
**ចម្បកំ សលឡំ នីបំ នាគបុន្នាគកេតកំ**
**ទិសោទិសំ ឱតិរន្តិ ភូមិតលគតា នរា ។**

*ពួកទេវតាដែលឋិតនៅឰដ៏អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្យផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។ ពួកមនុស្សដែលឋិតនៅលើផែនដី ក៏រោយរាយផ្កាចម្បា ផ្កាស្រល់ ផ្កាក្ទម្ព ផ្កាខ្ទឹង ផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូចទិសធំ ។*

**កោសេ មុញ្ចិត្វាហំ តត្ថ វាកចីរំ ច ចម្មកំ**
**កលលេ បត្ថរិត្វាន អវកុជ្ជោ និបជ្ជហំ ។**
**អក្កមិត្វាន មំ ពុទ្ធោ សហ សិស្សេហិ គច្ឆតុ**

**មា នំ កលលំ អក្កមិត្ថ ហិតាយ មេ ភវិស្សតិ ។**

*តថាគត រំសាយសក់ ត្រង់ប្រទេសនោះ ហើយក្រាលចីវរ សម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ (អធិដ្ឋានថា) សូមព្រះពុទ្ធព្រមទាំងពួកសិស្ស ជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ដូច្នេះ ។*

*សុមេធតាបសដេកលើភក់នោះឯង បើកភ្នែកទាំងគូសម្លឹងព្រះពុទ្ធសិរីរបស់ព្រះទសពលទីបង្ករ ហើយគិតថា បើអាត្មាអញប្រាថ្នាដុតនូវកិលេសទាំងពួងឲ្យអស់ ហើយជាសង្ឃនវកចូលកាន់រម្មនគរក៏បាន តែអាត្មាអញមិនមានកិច្ចដោយការដុតកិលេស ក្នុងភេទដែលបុគ្គលណាមួយមិនស្គាល់ហើយបរិនិព្វានឡើយ បើដូច្នោះ អាត្មាអញគប្បីដូចគ្នានឹងព្រះទសពលទីបង្ករ សម្រេចសម្ពោធិញ្ញាណដ៏ឧត្តមហើយ ឡើងកាន់ធម្មនាវា ឲ្យមហាជនឆ្លងសំសារសាគរបានហើយ សឹមបរិនិព្វានឯក្រោយសេចក្ដីនេះ សមគួរដល់អាត្មាអញ ដូច្នេះ ។ បន្ទាប់អំពីនោះ ក៏ធ្វើសមោធានធម៌ ៨ ប្រការ គឺសេចក្ដីប្រាថ្នាដ៏ធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ហើយក្រាបចុះ ព្រោះហេតុនោះ ទើបលោកពោលថា*

**បបរិយំ និបន្នស្ស ឯវំ មេ អាសិ ចេតសោ**
**ឥច្ឆមានោ អហំ អជ្ជ កិលេសេ ឈាបយេ មម ។**

**កឹំ មេ អញ្ញាតវេសេន ធម្មំ សច្ឆិកតេនិធ**
**សព្វញ្ញុតំ បាបុណិត្វា មុត្តោ មោចេ សទេវកេ ។**

*កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្តយ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយរបស់អញ ក្នុងថ្ងៃនេះក៏បាន ។ តែថាប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញគប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាងលោកព្រមទាំងទេវលោក ឲ្យរួចរដោះ ( ចាកសង្សារ ) ។*

**កឹំ មេ ឯកេន តិណ្ណេន បុរិសេន ថាមទស្សិនា**
**សព្វញ្ញុតំ បាបុណិត្វា សន្តារេស្សំ សទេវកេ ។**
**ឥមិនា មេ អធិការេន កតេន បុរិសុត្តមេ**
**សព្វញ្ញុតំ បាបុណាមិ តារេមិ ជនតំ ពហុំ ។**

*ប្រយោជន៍អ្វី អាត្មាអញជាបុរស សម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុតញ្ញាណ ចម្លងមនុស្សលោកព្រមទាំងទេវលោក ។ អាត្មាអញនឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។*

**សំសារសោតំ ឆិន្ទិត្វា វិទ្ធំសេត្វា តយោ ភវេ**
**ធម្មនាវំ សមារុយ្ហ សន្តារេស្សំ សទេវកេ ។**

*តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់ភពទាំង ៣ ឡើងជិះលើនាវាគឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោកដូច្នេះ ។*

*កាលបុគ្គលប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នាដែលធំក្រៃលែង (អាច) សម្រេចបាន ព្រោះសមោធានធម៌ ៨ ប្រការ គឺ ភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ ១ ហេតុ ១ ការឃើញព្រះសាស្ដា ១ ការបួស ១ ការបរិបូរណ៍ដោយគុណ ១ ការធ្វើដ៏ធំក្រៃលែង ១ ឆន្ទៈ ១ ។*

*ពិតហើយ កាលបុគ្គលតាំងនៅក្នុងភាវៈនៃភាពជាមនុស្សនោះឯង ប្រាថ្នាភាពជាព្រះពុទ្ធ ការប្រាថ្នារមែងសម្រេច ការប្រាថ្នារបស់នាគ គ្រុឌ ឬទេវតា មិនសម្រេចឡើយ ។ ក្នុងភាវៈនៃភាពជាមនុស្ស កាលបុគ្គលនោះតាំងនៅក្នុងភេទជាបុរសប៉ុណ្ណោះ ទើបសេចក្ដីប្រាថ្នាសម្រេច ការប្រាថ្នាក្នុងភាពជាស្ត្រីក្ដី ខ្ទើយក្ដី ឧភតោព្យញ្ជនកៈក្ដី មិនសម្រេចឡើយ ។ សូម្បីសម្រាប់បុរស ការប្រាថ្នារបស់បុគ្គលដែលបរិបូណ៌ដោយហេតុ គឺអាចសម្រេចអរហត្តក្នុងអត្តភាពនោះបាន ទើបសម្រេច ក្រៅអំពីនេះ មិនសម្រេចឡើយ ។ សូម្បីសម្រាប់បុគ្គលដែលបរិបូណ៌ដោយហេតុ កាលប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធប៉ុណ្ណោះ ទើបការប្រាថ្នាសម្រេចបាន*

កាលព្រះពុទ្ធបរិនិព្វានហើយ ទោះប្រាថ្នាត្រង់ព្រះចេតិយក្ដី ត្រង់គល់ពោធិព្រឹក្សក្ដី មិនសម្រេចឡើយ ។ ទោះបីប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ ការប្រាថ្នារបស់បុគ្គលដែលតាំងនៅក្នុងភេទបព្វជិតប៉ុណ្ណោះ ទើបសម្រេចបាន បើនៅក្នុងភាពជាគ្រហស្ថមិនសម្រេចឡើយ ។ សូម្បីជាបព្វជិតហើយ ការប្រាថ្នារបស់បុគ្គលដែលបានអភិញ្ញា ៥ និងសមាបត្តិ ៨ ប៉ុណ្ណោះ ទើបសម្រេចបាន បុគ្គលដែលវៀរចាកគុណនេះ មិនសម្រេចឡើយ ។ បុគ្គលដែលបរិបូណ៌ដោយគុណហើយក៏ដោយ ការប្រាថ្នារបស់បុគ្គលដែលធ្វើការបរិច្ចាគជីវិតរបស់ខ្លួនដល់ព្រះពុទ្ធ ដែលជាបុគ្គលបរិបូណ៌ដោយការធ្វើដ៏ក្រៃលែងនេះប៉ុណ្ណោះ ទើបសម្រេច របស់បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។ សូម្បីបុគ្គលដែលបរិបូណ៌ដោយការធ្វើដ៏ក្រៃលែងហើយ ត្រូវមានឆន្ទៈដ៏ធំមួយអន្លើដោយឧស្សាហៈ និងការព្យាយាមដ៏ធំ ដើម្បីប្រយោជន៍ដល់ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ ទើបការប្រាថ្នាសម្រេចបាន បុគ្គលដទៃក្រៅអំពីនេះ មិនសម្រេចឡើយ ។

ក្នុងបទថា **ឆន្ទៈ** នេះ មានឧបមាដូចតទៅនេះថា បើមានបុគ្គលពោលយ៉ាងនេះថា អ្នកណាអាចប្រើកម្លាំងដើមដៃរបស់ខ្លួន ហែលឆ្លងចក្រវាលទាំងមូល ដែលពោរពេញដោយទឹកដល់ត្រើយបាន បុគ្គលនោះរមែងបានសម្រេចជាព្រះពុទ្ធ ឬថា បុគ្គលណាដើរដោយជើង ហើយឆ្លងល្វែងចក្រវាលទាំងមូលដែលពេញដោយគុម្ពឫស្សី ដល់កណ្ដាប់ចក្រវាល

បាន ទើបបុគ្គលនោះ សម្រេចជាព្រះពុទ្ធបាន ឬថា បុគ្គលដោតដាវពេញ
ល្វែងចក្រវាល ហើយដើរជាន់ដាវទាំងនោះ ឆ្លងល្វែងចក្រវាលនេះបាន
បុគ្គលនោះនឹងបានជាព្រះពុទ្ធ ឬថា បុគ្គលណាយកជើងជាន់ចក្រវាល
ទាំងមូលដែលពេញដោយរងើកភ្លើងសន្ធោសន្ធៅ ហើយដើរដល់កណ្ដាប់
ចក្រវាលបាន បុគ្គលនោះនឹងបានត្រាស់ជាព្រះពុទ្ធ បុគ្គលណាមិន
សម្គាល់ហេតុទាំងនេះ សូម្បីតែមួយថា ខ្លួនធ្វើបានដោយលំបាក តែគិត
ថា ខ្ញុំនឹងឆ្លងរហូតដល់កណ្ដាប់ចក្រវាល ដូច្នេះ បុគ្គលនោះរាប់ថាជាអ្នក
ប្រកបដោយឆន្ទៈ ឧស្សាហៈ និងសេចក្ដីព្យាយាមដ៏ធំ សេចក្ដីប្រាថ្នារបស់
បុគ្គលនោះ រមែងសម្រេច បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។
សុមេធតាបសសមោធានធម៌ទាំង ៨ ប្រការនេះបានហើយ ធ្វើសេចក្ដី
ប្រាថ្នាដ៏ធំក្រៃលែងដើម្បីភាពជាព្រះពុទ្ធ ហើយក្រាបចុះ ។ ចំណែកព្រះ
មានព្រះភាគទីបង្ករ ទ្រង់ប្រថាប់ឈរខាងមុខសីសៈរបស់សុមេធតាបស
ទ្រង់បើកព្រះនេត្រទាំងគូ ដែលបរិបូណ៌ដោយបសាទមានពណ៌ ៥ ដូច
បើកសីហបញ្ជរកែវមណី ទតសុមេធតាបសដែលដេកលើភក់ ទ្រង់ព្រះ
តម្រិះថា តាបសនេះ ធ្វើសេចក្ដីប្រាថ្នាធំក្រៃលែងដើម្បីភាពជាព្រះពុទ្ធ
ការប្រាថ្នារបស់តាបសនេះសម្រេចដែរឬហ្ន៎ ព្រះបរមសាស្ដា ទ្រង់បញ្ជូន
អនាគតង្សញ្ញាណពិចារណា ទ្រង់ជ្រាបថា កន្លងទៅ ៤ អសង្ខេយ្យ និង
១ សែនកប្បទៀត តាបសនេះនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមថា

គោតម ខណៈប្រថាប់ឈរនោះឯង ទ្រង់ក៏ព្យាករដោយព្រះតម្រាស់ថា អ្នកទាំងឡាយ ចូរមើលតាបសដែលមានតបៈដ៏ឧត្តមនេះ កំពុងដេកលើភក់ ។

ភិក្ខុទាំងឡាយក្រាបទូលថា ឃើញហើយព្រះអង្គ ។

ព្រះលោកនាយក ទ្រង់ត្រាស់បន្តថា តាបសនេះធ្វើសេចក្តីប្រាថ្នាដ៏ធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ដេកហើយ ការប្រាថ្នារបស់តាបសនេះ នឹងសម្រេចក្នុងទីបំផុតនៃ ៤ អសង្ខេយ្យ និង ១ សែនកប្បទៀត តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធព្រះនាមថា គោតម ក្នុងអត្តភាពនោះ នគរមានឈ្មោះថា កបិលពស្តុជាទីអាស្រ័យនៅ ព្រះទេវីព្រះនាមថា មាយា ជាព្រះរាជមាតា ព្រះរាជាព្រះនាមថា សុទ្ធោទនៈ ជាព្រះរាជបិតា ព្រះថេរៈឈ្មោះថា ឧបតិស្សៈ ជាអគ្គសាវ័ក ព្រះថេរៈឈ្មោះថា កោលិតៈ ជាទុតិយសាវ័ក ពុទ្ធុបដ្ឋាកឈ្មោះថា អានន្ទ ព្រះថេរីឈ្មោះថា ខេមា ជាអគ្គសាវិកា ព្រះថេរីឈ្មោះថា ឧប្បលវណ្ណា ជាទុតិយសាវិកា តាបសនេះ មានញាណចាស់ក្លាហើយ ចេញមហាភិនិស្រ្កមណ៍ តាំងសេចក្តីព្យាយាមយ៉ាងធំ ទទួលមធុបាយាសត្រង់គល់ជ្រៃ សោយត្រង់ឆ្នេរស្ទឹងនេរញ្ជរា ឡើងកាន់ពោធិមណ្ឌល នឹងត្រាស់ដឹងក្រោមដើមអស្សត្ថព្រឹក្ស ព្រោះហេតុនោះ ទើបលោកពោលថា

**ឌីបង្ករោ លោកាវិទូ អាហុតីនំ បដិគ្គហោ**

ឧស្សីសកេ មំ បត្វាន ឥទំ វចនមព្រវិ ។
បស្សថ ឥមំ តាបសំ ជដិលំ ឧគ្គតាបនំ
អបរិមេយ្យេ ឥតោ កប្បេ ពុទ្ធោ លោកេ ភវិស្សតិ ។

*ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈ របស់តថាគត ត្រាស់ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបាន អំពីកប្បនេះទៅ ។*

អហុ កបិលវ្ហយា រម្មា និក្ខមិត្វា តថាគតោ
បធានំ បទហិត្វាន កត្វា ទុក្ករការិកំ ។
អជបាលរុក្ខមូលស្មឹ និសីទិត្វា តថាគតោ
តត្ថ បាយាសំ បគ្គយ្ហ នេរញ្ជរមុបេហិតិ ។

*សត្វនេះ នឹងចេញចាកក្រុងឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាម ធ្វើទុក្ករកិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។*

នេរញ្ជរាយ តីរម្ហិ បាយាសំ អទ សោ ជិនោ

បដិយត្តវរមគ្គេន ពោធិមូលម្ហិ ឯហិតិ ។
តតោ បទក្ខិណំ កត្វា ពោធិមណ្ឌំ អនុត្តរំ
អស្សត្ថរុក្ខមូលម្ហិ ពុជ្ឈិស្សតិ មហាយសោ ។

*ព្រះជិនស្រីនោះ បានទទួលបាយាសទៀបឆ្នេរស្ទឹងនេរញ្ជរា ហើយ នឹងត្រឡប់មកតាមផ្លូវដែលគេតាក់តែងយ៉ាងប្រសើរ (អង្គុយ) ទៀបគល់ពោធិព្រឹក្ស លំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិមណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។*

ឥមស្ស ជនិកា មាតា មាយា នាម ភវិស្សតិ
បិតា សុទ្ធោទនោ នាម អយំ ហេស្សតិ គោតមោ ។
កោលិតោ ឧបតិស្សោ ច អគ្គា ហេស្សន្តិ សាវកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា
អានន្ទោ នាមុបដ្ឋាកោ ឧបដ្ឋិស្សតិមំ ជិនំ ។

*ព្រះជនិកាមាតា របស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថា ព្រះគោតម អគ្គសាវ័កទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ*

នឹងបម្រើព្រះជិនស្រីនេះ ។

ខេមា ឧប្បលវណ្ណា ច អគ្គា ហេស្សន្តិ សាវិកា
អនាសវា វីតរាគា សន្តចិត្តា សមាហិតា ។
ពោធិ តស្ស ភគវតោ អស្សត្ថោតិ បវុច្ចតិ
ចិត្តោ ច ហត្ថាឡវកោ អគ្គា ហេស្សន្តុបដ្ឋកា ។

អគ្គសាវិកាពីររូបគឺ នាងខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈ ប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹងរបស់ព្រះមានព្រះភាគនោះ ហៅថា អស្សត្ថព្រឹក្ស ឯឧបាសកជាឧបដ្ឋាកដ៏ប្រសើរពីររូប គឺ ចិត្តៈ ១ ហត្ថាឡវកៈ ១ ដូច្នេះ ។

សុមេធតាបសកើតសោមនស្សថា បានឮថា សេចក្ដីប្រាថ្នារបស់អាត្មាអញនឹងសម្រេច ដូច្នេះ ។ មហាជនបានស្ដាប់ព្រះតម្រាស់របស់ព្រះទសពលទីបង្ករហើយ នាំគ្នាត្រេកអរពោលថា បានឮថា សុមេធតាបសជាសពេជ្ជតាញាណ គឺជាពន្លកបស់ព្រះពុទ្ធ ពួកយើងមានគំនិតយ៉ាងនេះថា ធម្មតាបុរស កាលឆ្លងស្ទឹង មិនអាចឆ្លងដោយកំពង់ត្រង់បាន រមែងឆ្លងដោយកំពង់ខាងក្រោមយ៉ាងណា សូម្បីពួកយើងក៏ដូច្នោះ បើមិនបានមគ្គផលក្នុងសាសនារបស់ព្រះទសពលទីបង្ករ ក្នុងកាលអនាគតតាបសនេះបានជាព្រះពុទ្ធ ក្នុងកាលនោះ ពួកយើងអាចធ្វើឲ្យជាក់ច្បាស់

នូវមគ្គនិងផលក្នុងទីចំពោះមុខរបស់លោក ហើយនាំគ្នាតាំងសេចក្ដីប្រាថ្នាទុក ។ ព្រះទសពលទីបង្ករ ទ្រង់សរសើរព្រះបរមពោធិសត្វហើយ បូជាដោយផ្កា ៨ ក្ដាប់ ធ្វើប្រទក្សិណចៀសចេញទៅ ឯព្រះខីណាស្រពទាំង ៤ សែន ក៏នាំគ្នាបូជាព្រះមហាសត្វដោយផ្កាកម្រងនិងគ្រឿងក្រអូប ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ព្រះបរមពោធិសត្វក្រោកឡើងក្នុងវេលាដែលជនទាំងពួងចៀសចេញទៅ គិតថា អញនឹងពិចារណាបារមីទាំងឡាយ ដូច្នេះ ទើបអង្គុយពត់ភ្នែនលើគំនរផ្កា ។ កាលព្រះមហាសត្វអង្គុយហើយយ៉ាងនេះ ទេវតាក្នុងម៉ឺនចក្រវាលបានឲ្យសាធុការថា បពិត្រសុមេធតាបសដ៏ចម្រើន ក្នុងវេលាដែលព្រះពោធិសត្វអំពីបុរាណទាំងឡាយអង្គុយពត់ភ្នែនដោយគិតថា អញនឹងស្រាវជ្រាវនូវបារមីទាំងឡាយឈ្មោះថា បុព្វនិមិត្តពួកណានឹងប្រាកដ បុព្វនិមិត្តទាំងនោះ ប្រាកដច្បាស់ហើយក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ពួកខ្ញុំដឹងសេចក្ដីនោះ និមិត្តទាំងនេះ ប្រាកដដល់បុគ្គលណា បុគ្គលនោះ នឹងបានត្រាស់ជាព្រះពុទ្ធដោយចំណែកមួយ សូមលោកផ្គងសេចក្ដីព្យាយាមរបស់ខ្លួនឲ្យមាំទាំ ដូច្នេះហើយ ពោលសរសើរព្រះពោធិសត្វដោយពាក្យសរសើរច្រើនប្រការ ព្រោះហេតុនោះ ទើបលោកពោលថា

ឥទំ សុត្វាន វចនំ អសមស្ស មហេសិនោ
អាមោទិតា នរមរូ ពុទ្ធវីជង្កុរោ អយំ ។

ពួកមនុស្សនិងទេវតា លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា សុមេធតាបសនេះ ជាពូជពន្លក នៃព្រះពុទ្ធ ។

ឧក្កុដិសទ្ទា [១] វត្តន្តិ អប្ផោដេន្តិ ហសន្តិ ច
កតញ្ជលី នមស្សន្តិ ទសសហស្សី សទេវកា ។
យទិមស្ស លោកនាថស្ស វិរជ្ឈិស្សាម សាសនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

សំឡេងហ៊ោទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើងឃ្លាងមគ្គផលក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រ នៃព្រះគោតមនេះ ។

យថា មនុស្សា នទឹ តរន្តា បដិតិត្ថំ វិរជ្ឈិយ
ហេដ្ឋាតិត្ថេ គហេត្វាន ឧត្តរន្តិ មហានទឹ ។
ឯវមេវ មយំ សព្វេ យទិ មុញ្ចាមិមំ ជិនំ
អនាគតម្ហិ អទ្ធានេ ហេស្សាម សម្មុខា ឥមំ ។

---

១- ឆដ្ឋសង្គាយនាថា ឧក្កុដ្ឋិសទ្ទា ។

ពួកមនុស្សកាលធ្វងស្ទឹង បើឃ្វាងកំពង់ចំពោះមុខហើយ តែង កាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថាធ្វងស្ទឹងធំដែរ យ៉ាង ណាមិញ ពួកយើងទាំងអស់គ្នា បើឃ្វាងព្រះជិនស្រីនេះហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះ ភក្ត្រ នៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។

ទីបង្ករោ លោកវិទូ អាហុតីនំ បដិគ្គហោ
មម កម្មំ បកិត្តេត្វា ទក្ខិណាថាទមុទ្ទរិ ។
យេ តត្ថ អាសុំ ជិនបុត្តា សព្វេ បទក្ខិណមកំសុ មំ
ទេវា មនុស្សា អសុរា យក្ខា អភិវាទេត្វាន បក្កមុំ ។

ព្រះពុទ្ធទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាង ស្តាំ ។ សាវ័កទាំងឡាយណា ជាបុត្តនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវ័កទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួក មនុស្ស ពួកអសុរ ពួកយក្ស ក៏ក្រាបថ្វាយបង្គំតថាគត ហើយ ចៀសចេញទៅ ។

ទស្សនំ មេ អតិក្កន្តេ សសង្ឃេ លោកនាយកេ
សយនា វុដ្ឋហិត្វាន បល្លង្កំ អាភុជឹ តទា ។
សុខេន សុខិតោ ហោមិ បាមោជ្ជេន បមោទិតោ

បីតិយា ច អភិស្សន្នោ     បល្លង្កំ អាភុជឹ តទា ។

*កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញ របស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែន ក្នុងកាលនោះ ។ តថាគតជាអ្នកមានសេចក្ដីសុខ ដោយសេចក្ដីសុខ រីករាយដោយបាមោជ្ជៈ ផ្សព្វផ្សាយដោយបីតិ អង្គុយ ពែនភ្នែនក្នុងកាលនោះ ។*

បល្លង្កេន និសីទិត្វា     ឯវំ ចិន្តេសិហំ តទា
វសីភូតោ អហំ ឈានេ     អភិញ្ញាចារមិង្គតោ ។
សហស្សិយម្ហិ លោកម្ហិ     ឥសយោ នត្ថិ មេ សមា
អសមោ ឥទ្ធិធម្មេសុ     អលភឹ ឦទិសំ សុខំ ។

*តថាគតអង្គុយពែនភ្នែន គិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសី ស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើ ក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្ដីសុខបែបនេះ ។*

បល្លង្កាភុជនេ មយ្ហំ     ទសសហស្សាធិវាសិនោ
មហានាទំ បវត្តេសុំ     ធុវំ ពុទ្ធោ ភវិស្សសិ ។
យា បុព្វេ ពោធិសត្តានំ     បល្លង្កវរមាភុជេ

**និមិត្តានិ បទិស្សន្តិ តានិ អជ្ជ បទិស្សរេ ។**

*ក្នុងកាលដែលតថាគត អង្គុយពែនភ្នែនគិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញុំាងសំឡេងខ្លាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែន នៃពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។*

**សីតំ ព្យាបគតំ ហោតិ ឧណ្ហាញ្ច ឧបសម្មតិ**
**តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**
**ទសសហស្សី លោកធាតុ និស្សទ្ទា ហោតិ និរាកុលា**
**តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

*ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

**មហាវាតា ន វាយន្តិ ន សន្ទន្តិ សវន្តិយោ**
**តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

**ថលជា ជលជា បុប្ផា សព្វេ បុប្ផន្តិ តាវទេ**
**តេបជ្ជ បុប្ផិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។**

*ខ្យល់ធំទាំងឡាយក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួង ដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

**លតា វា យទិ វា រុក្ខា ផលំ ធារេន្តិ តាវទេ**
**តេបជ្ជ ផលិតា សព្វេ ធុវំ ពុទ្ធោ ភវិស្សសិ ។**
**អាកាសដ្ឋា ច ភុម្មដ្ឋា រតនា ជោតន្តិ តាវទេ**
**តេបជ្ជ រតនា ជោតន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

*វល្លិទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែ ក្នុងខណៈនោះ វល្លិនិងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយដែលឋិតនៅឰដ៏អាកាសក្តី ឋិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

**មានុស្សិកា ច ទិព្វា ច តុរិយា វជ្ជន្តិ តាវទេ**

តេបជ្ជុកោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
វិចិត្តបុប្ផា គគណា អភិវស្សន្តិ តាវទេ
តេបិ អជ្ជ បវស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។

*គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្យ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រទាំងឡាយ រុះរោយចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

មហាសមុទ្ទោ អាភុជតិ ទសសហស្សី បកម្បតិ
តេបជ្ជុកោ អភិរវន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
និរយេ ទសសហស្សា អគ្គី និព្វន្តិ តាវទេ
តេបជ្ជ និព្វុតា អគ្គី ធុវំ ពុទ្ធោ ភវិស្សសិ ។

*មហាសមុទ្ទ ក៏ស្រុកចុះ លោកធាតុទាំងមួយម៉ឺន ក៏ញាប់ញ័រក្នុងខណៈនោះ មហាសមុទ្ទនិងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះ ក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់*

*ជាព្រះពុទ្ធប្រាកដ ។*

វិមលោ ហោតិ សុរិយោ សព្វា ធិស្សន្តិ តារកា
តេបិ អជ្ជ បធិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។
អធោវុដ្ឋេន ឧទកំ មហិយា ឧព្ភិជ្ជិ តាវទេ
តំបជ្ជុព្ភិជ្ជតេ មហិយា ធុវំ ពុទ្ធោ ភវិស្សសិ ។

*ព្រះអាទិត្យ ប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យនិងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

តារាគណា វិរោចន្តិ នក្ខត្តា គគនមណ្ឌលេ
វិសាខា ចន្ទិមាយុត្តា ធុវំ ពុទ្ធោ ភវិស្សសិ ។
វិលាសយា ទរីសយា និក្ខមន្តិ សកាសយា
តេបជ្ជ អាសយា ធុត្វា ធុវំ ពុទ្ធោ ភវិស្សសិ ។

*ពួកផ្កាយទាំងឡាយក៏រុងរឿង ផ្កាយនក្ខត្តឫក្សទាំងឡាយប្រកបដោយព្រះចន្ទខែវិសាខ (ក៏រុងរឿង) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាក*

*លំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោលក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

ន ហោតិ អរតិ សត្តានំ  សន្តុដ្ឋា ហោន្តិ តាវទេ
តេបជ្ជ សព្វេ សន្តុដ្ឋា  ធុវំ ពុទ្ធោ ភវិស្សសិ ។
រោគា តទុបសម្មន្តិ  ជិឃច្ឆា ច វិនស្សតិ
តានិបជ្ជ បទិស្សន្តិ  ធុវំ ពុទ្ធោ ភវិស្សសិ ។

*សេចក្តីអផ្សុកមិនមានដល់សត្វទាំងឡាយ សត្វទាំងឡាយជាអ្នកត្រេកអរ ក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយ ដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

រាគោ តទា តនុ ហោតិ  ទោសោ មោហោ វិនស្សតិ
តេបជ្ជ វិគតា សព្វេ  ធុវំ ពុទ្ធោ ភវិស្សសិ ។
ភយំ តទា ន ភវតិ  អជ្ជបេតំ បទិស្សតិ
តេន លិង្គេន ជានាម  ធុវំ ពុទ្ធោ ភវិស្សសិ ។

*រាគៈក៏ស្រាកស្រាន្តទៅ ទោសៈ មោហៈ ក៏បាត់បង់ទៅ ក្នុង*

កាលនោះ រោគនិងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមាន ក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

រជោ ឩទ្ធំសតិ ឧទ្ធំ　　អជ្ជេបតំ បទិស្សតិ
តេន លិង្គេន ជានាម　　ធុវំ ពុទ្ធោ ភវិស្សសិ ។
អនិដ្ឋគន្ធោ បក្កមតិ　　ទិព្វគន្ធោ បវាយតិ
សោបជ្ជ វាយតិ គន្ធោ　　ធុវំ ពុទ្ធោ ភវិស្សសិ ។

ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលី ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយ ក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

សព្វេ ទេវា បទិស្សន្តិ　　ឋបេត្វា ច អរូបិនោ
តេបជ្ជ សព្វេ ទិស្សន្តិ　　ធុវំ ពុទ្ធោ ភវិស្សសិ ។
យាវតា និរយា នាម　　សព្វេ ទិស្សន្តិ តាវទេ
តេបជ្ជ សព្វេ ទិស្សន្តិ　　ធុវំ ពុទ្ធោ ភវិស្សសិ ។

ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរក ទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**កុជា[១] ករាជា សេលា ច ន ហោន្តាវរណា តទា**

**អាកាសភូតា តេបជ្ជ ធុវំ ពុទ្ធោ ភវិស្សសិ ។**

**ចុតិ ច ឧបបត្តិ ច ខណោ តស្មឹ ន វិជ្ជតិ**

**តានិ អជ្ជ បទិស្សន្តិ ធុវំ ពុទ្ធោ ភវិស្សសិ ។**

ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារនិងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអាកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិនិងឧបបត្តិ មិនមាន ក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

**( ឥមេ និមិត្តា ទិស្សន្តិ** សម្ពោជគ្គាយ ចាណំ **)**

---

១- គួរតែ **កុឌ្ឌា** វិញ ព្រោះសព្ទនេះ ទើបប្រែថា ជញ្ជាំង ។

**ឧឡ្ហំ បគ្គយ្ហ[១] វិរិយំ មា និវត្ត អភិក្កម**
**មយំបេតំ វិជានាម ធុវំ ពុទ្ធោ ភវិស្សសិ ។**

( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ) ( ពួកសត្វពោលថា បពិត្រសុមេធតាបស ) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុ៎ះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ដូច្នេះ ។

ព្រះបរមពោធិសត្វ បានស្តាប់ព្រះតម្រាស់របស់ព្រះទសពលទីបង្ករ និងពាក្យរបស់ទេវតាក្នុង ១ ម៉ឺនចក្រវាល កើតនូវឧស្សាហៈដ៏ក្រៃលែង ទើបគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះតម្រាស់មិនទទេឡើយ ពាក្យរបស់ព្រះពុទ្ធទាំងឡាយ មិនប្រែទៅជាដទៃ ដូចដុំដីបោះទៅក្នុងអាកាសត្រូវតែធ្លាក់មក សត្វដែលកើតហើយត្រូវស្លាប់ កាលអរុណប្រាកដហើយ ព្រះអាទិត្យក៏នឹងរះឡើង រាជសីហ៍ដែលចេញអំពីគុហា ក៏ត្រូវបន្លឺសីហនាទ ស្ត្រីដែលមានគភ៌ ក៏ត្រូវដាក់ចុះនូវភារៈដោយពិតប្រាកដ យ៉ាងណា ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ តែងពិតប្រាកដ មិនទទេ ក៏យ៉ាងនោះដែរ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ

---

១- គួរតែ **បគ្គណ្ហ** សព្ទនេះ ទើបប្រែថា ចូរផ្គង ឬធ្វើ ។

*ដោយពិត ព្រោះហេតុនោះ ទើបលោកពោលថា*

ពុទ្ធស្ស វចនំ សុត្វា ទសសហស្សីទ ចូភយំ
តុដ្ឋហដ្ឋោ បមោទិតោ ឯវំ ចិន្តេសិហន្តទា ។
អទ្វេជ្ឈវចនា ពុទ្ធា អមោឃវចនា ជិនា
វិតថំ នត្ថិ ពុទ្ធានំ ធុវំ ពុទ្ធោ ភវាមិហំ ។

*តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និងទេវតាទាំងមួយម៉ឺនចក្រវាលហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះ យ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាបែកជាពីរទេ ព្រះជិនស្រីទាំងឡាយ មិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីការបស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។*

យថា ខិត្តំ នភេ លេឌ្ឌុំ ធុវំ បតតិ ភូមិយំ
តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។
វិតថំ នត្ថិ ពុទ្ធានំ ធុវំ ពុទ្ធោ ភវាមិហំ
យថាបិ សព្វសត្តានំ មរណំ ធុវសស្សតំ
តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

*ដុំដីដែលគេចោលទៅ ឰដ៏អាកាស ទៀងតែធ្លាក់មកលើ*

*ផែនដីវិញ យ៉ាងណា ពាក្យរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តីស្លាប់របស់សព្វសត្វ ទៀងទាត់ប្រាកដ យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ប្រាកដ ដូច្នោះដែរ ។*

យថា រត្តិក្ខយេ បត្តេ សុរិយុគ្គមនំ ធុវំ
តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។
យថា និក្ខន្តសយនស្ស សីហស្ស នទនំ ធុវំ
តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

*កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។ សីហៈដែលចេញអំពីដំណេកតែងបន្លឺសំឡេងយ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ។*

យថា អាបន្នសត្តានំ ភារមោរោបនំ ធុវំ
តថេវ ពុទ្ធសេដ្ឋានំ វចនំ ធុវសស្សតំ ។

*ការសម្រាលគភ៌ នៃស្ត្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់*

យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាងនោះដែរ ដូច្នេះ ។

សុមេធតាបសនោះ ធ្វើការដាក់ចិត្តយ៉ាងនេះថា អាត្មាអញនឹងបានជាព្រះពុទ្ធពិតប្រាកដ ដើម្បីពិចារណាដល់ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ កាលពិនិត្យពិចារណាមើលធម្មធាតុទាំងមូល ដោយលំដាប់ថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធមាននៅក្នុងទីណាហ្ន៎ ខាងលើឬខាងក្រោម ក្នុងទិសធំឬទិសតូច ដូច្នេះហើយ បានឃើញទានបារមីប្រការទី ១ ដែលព្រះពោធិសត្វអំពីបុរាណទាំងឡាយ បដិបត្តិជាប្រចាំ ទើបពោលទូន្មានខ្លួនយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងអំពីនេះទៅ អ្នកគប្បីបំពេញទានបារមីទី ១ ឲ្យពេញបរិបូណ៌ ដូចជាក្អមទឹកដែលគេផ្កាប់ហើយ រមែងហូរចេញនូវទឹកមិនមានសេសសល់ មិននាំទឹកត្រឡប់ចូលទៅវិញ យ៉ាងណា អ្នកក៏កុំសម្លឹងមើលទ្រព្យ យស បុត្ត ភរិយា ឬអវយវៈតូចធំ ឲ្យវត្ថុដែលគេត្រូវការទាំងអស់ដល់អ្នកសូមដែលមកដល់ ធ្វើមិនឲ្យមានចំណែកសេសសល់ ក៏យ៉ាងនោះ អ្នកនឹងបានអង្គុយត្រង់មណ្ឌលពោធិព្រឹក្សត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតបានអធិដ្ឋានទានបារមី ទី ១ ធ្វើឲ្យមាំទាំហើយ ព្រោះដូច្នោះ ទើបលោកពោលថា

ហន្ទ ពុទ្ធករេ ធម្មេ　　វិចិនាមិ ឥតោ ចិតោ
ឧទ្ធំ អធោ ទសទិសា　　យាវតា ធម្មធាតុយា ។

*បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះពីខាងនោះ  គឺខាងលើ  ខាងក្រោម  ទិសទាំងដប់ ដរាបដល់ធម្មធាតុ ។*

**វិចិនន្តោ តទា ទក្ខឹ   បឋមំ ទានបារមឹ**
**បុព្វកេហិ មហេសីហិ   អនុចិណ្ណំ មហាបថំ ។**
**ឥមំ ត្វំ បឋមំ តាវ   ទឡ្ហំ កត្វា សមាទិយ**
**ទានបារមិតំ គច្ឆ   យទិ ពោធឹ បត្តុមិច្ឆសិ ។**

*កាលនោះ តថាគត កំពុងជ្រើសរើស ក៏បានឃើញទានបារមី ជាដំបូង  ជាគន្លងធំ  ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា  ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន  ធ្វើនូវទានបារមី ជាដំបូងនេះ ឲ្យមាំមួន បើ អ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។*

**យថាបិ កុម្ភោ សម្បុណ្ណោ   យស្ស កស្សចិ អធោកតោ**
**វមតេ ឧទកំ និស្សេសំ   ន តត្ថ បរិរក្ខតិ ។**
**តថេវ យាចកេ ទិស្វា   ហីនមុក្កដ្ឋមជ្ឈិមេ**
**ទទាហិ ទានំ និស្សេសំ   កុម្ភោ វិយ អធោកតោ ។**

*ក្អមដែលមានទឹកពេញ បុគ្គលណាមួយ ផ្កាប់ចុះ ចាក់មិនឲ្យ សល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញ*

ពួកស្នូមមក ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទាន កុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ដូច្នោះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាឲ្យក្រៃលែងឡើងទៀត ដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនគប្បីមានត្រឹមតែប៉ុណ្ណោះទេ ក៏បានឃើញសីលបារមីទី ២ មានគំនិតយ៉ាងនេះថា នៃសុមេធបណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកគប្បីបំពេញសីលបារមីឲ្យបរិបូណ៌ ធម្មតាសត្វចាមរី មិនស្រណោះអាឡោះអាល័យសូម្បីក្នុងជីវិត រក្សារោមកន្ទុយរបស់ខ្លួនយ៉ាងណា ចាប់តាំងអំពីពេលនេះទៅ អ្នកក៏មិនត្រូវសោកស្តាយសូម្បីតែជីវិត រក្សាសីលតែម្យ៉ាង ក៏យ៉ាងនោះដែរ អ្នកនឹងបានជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋានសីលបារមីទី ២ ធ្វើឲ្យមាំទាំហើយ ព្រោះដូច្នោះ ទើបលោកពោលថា

**ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ**
**អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។**

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

**វិចិនន្តោ តទា ទក្ខិំ ទុតិយំ សីលបារមឹ**
**បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។**

**ឥមំ ត្វំ ទុតិយំ តាវ ទឡ្ហំ កត្វា សមាទិយ**
**សីលបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។**

*កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមី ទី ២ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។*

**យថាបិ ចាមរី វាលំ កិស្មិញ្ចិ បដិលគ្គិតំ**
**ឧបេតិ មរណំ តត្ថ ន វិកោបេតិ វាលធឹ ។**
**តថេវ ចតូសុ ភូមីសុ សីលានិ បរិបូរយ**
**បរិរក្ខ សព្វទា សីលំ ចាមរី វិយ វាលធឹ ។**

*សត្វចាមរី ( កាលឃើញ ) រោមកន្ទុយចំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរី រក្សាកន្ទុយ យ៉ាងនោះចុះ ដូច្នេះ ។*

*លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាឲ្យក្រៃលែងឡើងទៅទៀតដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនគប្បីមានត្រឹមតែ*

ប៉ុណ្ណោះឡើយ ក៏បានឃើញនេក្ខម្មបារមីទី ៣ ទើបមានគំនិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងពីពេលនេះតទៅ អ្នកគប្បីបំពេញនេក្ខម្មបារមីឲ្យពេញបរិបូណ៌ ដូចជាបុរសដែលនៅក្នុងគុក មិនមានសេចក្តីប្រាថ្នានឹងនៅក្នុងគុកនោះឡើយ ដោយពិត បុរសនោះរមែងកន្ទក់កន្ទេញតែម្យ៉ាង និងមិនចង់នៅឡើយយ៉ាងណា សូម្បីអ្នកក៏ចូរធ្វើកពទាំងពួងឲ្យដូចគ្នានឹងគុក ប្រាថ្នានឹងរួចផុតចាកកពទាំងពួង បែរមុខចំពោះការចេញបួសក៏ដូច្នោះ ដូចគ្នា អ្នកនឹងបានត្រាស់ជាព្រះពុទ្ធដោយអាការយ៉ាងនេះដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋាននេក្ខម្មបារមីទី ៣ នោះ ធ្វើឲ្យមាំទាំហើយព្រោះហេតុនោះ ទើបលោកពោលថា

ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិ-ញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខិំ តតិយំ នេក្ខម្មបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ តតិយំ តាវ ទឡ្ហំ កត្វា សមាទិយ
នេក្ខម្មបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមី ទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះ ឲ្យមាំមួន បើអ្នកចង់លុះ នូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។

**យថា អន្ទុឃរេ បុរិសោ ចិរំ វុដ្ឋោ ទុក្ខដ្ដិតោ**
**ន តត្ថ រាគំ ជនេតិ មុត្តឹយេវ គវេសតិ ។**
**តថេវ ត្វំ សព្វភវេ បស្ស អន្ទុឃរេ វិយ**
**នេក្ខម្មាភិមុខោ ហោហិ ភវតោ បរិមុត្តិយា ។**

បុរសដែលជាប់នៅក្នុងគុក អស់កាលយូរ ត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញុំាងសេចក្តីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញ នូវភពទាំងអស់ ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈ ដើម្បីរួចចាកភព យ៉ាងនោះដែរ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើងទៅទៀត ដោយគិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ មិនគប្បីមានត្រឹមតែប៉ុណ្ណោះទេ ក៏បានឃើញបញ្ញាបារមីទី ៤ ទើបមានគំនិតគិតថា ម្នាលសុមេធបណ្ឌិត ចាប់តាំងពីពេលនេះទៅ អ្នកគប្បីបំពេញបញ្ញាបារមីឲ្យ

បរិបូណ៌ អ្នកកុំបីវៀរបុគ្គលណាមួយឡើយ ទោះបីជាមនុស្សថោកទាប មនុស្សកណ្តាល និងមនុស្សជាន់ខ្ពស់ គប្បីចូលទៅរកបណ្ឌិតទាំងអស់ ហើយសួរបញ្ហា ដូចជាភិក្ខុអ្នកត្រាច់បិណ្ឌបាត មិនបានវៀរត្រកូលណាមួយឡើយ ក្នុងបណ្តាត្រកូលផ្សេងៗ មានត្រកូលថោកទាបជាដើម ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ រមែងបានអាហារល្មមញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅយ៉ាងណា សូម្បីអ្នកក៏ត្រូវចូលទៅរកបណ្ឌិតហើយសាកសួរ ក៏យ៉ាងនោះដូចគ្នា អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋានបញ្ញាបារមីទី ៤ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិចាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិ-ញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ចតុត្ថំ បញ្ញាចារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ ចតុត្ថំ តាវ ទឡ្ហំ កត្វា សមាទិយ
បញ្ញាចារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមី

ទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញាបារមីទី ៤ នេះ ឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។

**យថាបិ ភិក្ខុ ភិក្ខន្តោ   ហីនមុក្កដ្ឋមជ្ឈិមេ**
**កុលានិ ន វិវជ្ជេន្តោ   ឯវំ លភតិ យាបនំ ។**
**តថេវ ត្វំ សព្វកាលំ   បរិបុច្ឆន្តោ ពុធំ ជនំ**
**បញ្ញាបារមិតំ គន្ត្វា   សម្ពោធឹ បាបុណិស្សសិ ។**

ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញ សព្វកាល នឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើងទៅទៀត ដោយគិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ មិនគប្បីមានត្រឹមតែប៉ុណ្ណោះឡើយ ក៏បានឃើញវិរិយបារមីទី ៥ ទើបមានគំនិតថា នែសុមេធបណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកគប្បីបំពេញវិរិយបារមីឲ្យពេញបរិបូណ៌ ដូចជាសីហមិគរាជ ជាសត្វមានសេចក្តីព្យាយាមមាំក្នុង

គ្រប់ឥរិយាបថ យ៉ាងណា ឯអ្នកក៏ត្រូវមានសេចក្តីព្យាយាមមាំទាំ មានសេចក្តីព្យាយាមមិនធូរថយ ក៏យ៉ាងនោះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋានវីរិយបារមីទី ៥ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ បញ្ចមំ វីរិយបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ បញ្ចមំ តាវ ទឡ្ហំ កត្វា សមាទិយ
វីរិយបារមិតំ គច្ឆ យទិ ពោធឹ បត្តុមិច្ឆសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។

**យថាបិ សីហោ មិគរាជា និសជ្ជដ្ឋានចង្កមេ**
**អលីនវីរិយោ ហោតិ បគ្គហិតមនោ សទា ។**
**តថេវ ត្វំ សព្វភវេ បគ្គយ្ហ វីរិយំ ទឡ្ហំ**
**វីរិយបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។**

*សត្វសីហៈជាស្តេចនៃម្រឹគ មានព្យាយាម មិនរួញរា មានចិត្តផ្គងផ្គងសព្វកាល ក្នុងការអង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គងផ្គងព្យាយាមឲ្យមាំមួន ក្នុងភពទាំងពួង យ៉ាងនោះចុះ លុះដល់នូវវីរិយបារមីហើយ នឹងបានសម្រេចពោធិញ្ញាណ មិនខានឡើយ ដូច្នេះ ។*

*លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាក្រៃលែងឡើងទៅ ដោយគិតថា ធម្មតាធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមតែប៉ុណ្ណោះឡើយ ក៏បានឃើញខន្តិបារមីទី ៦ ទើបមានគំនិតថា នែសុមេធបណ្ឌិតចាប់តាំងអំពីពេលនេះតទៅ អ្នកគប្បីបំពេញខន្តិបារមីឲ្យពេញបរិបូណ៌ គប្បីជាអ្នកអត់ធន់ទាំងក្នុងការរាប់អាន ទាំងក្នុងការមើលងាយ ដូចជាបុគ្គលទាំងឡាយ ចោលរបស់ស្អាតខ្លះ មិនស្អាតខ្លះលើផែនដី ផែនដីរមែងមិនធ្វើនូវការមិនពេញចិត្ត មិនថ្នាំងថ្នាក់អាក់អន់ មានតែអត់ធន់ប៉ុណ្ណោះ យ៉ាងណា សូម្បីអ្នកក៏គួរអត់ធន់ក្នុងការរាប់អានក្តី ក្នុងការមើលងាយក្តី ក៏យ៉ាងនោះដែរ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។*

សុមេធបណ្ឌិតអធិដ្ឋានខន្តិបារមីទី ៦ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះទើបលោកពោលថា

ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ ឆដ្ឋមំ ខន្តិបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ ឆដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ អទ្វេជ្ឈមានសោ សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណមិនខានឡើយ ។

យថាបិ បឋវី នាម សុចឹបិ អសុចឹបិ ច

សព្វំ សហតិ និក្ខេបំ ន ករោតិ បដិឃទយំ ។
តថេវ ត្វំបិ សព្វេសំ សម្មានាវមានក្ខមោ
ខន្តិបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

ធម្មតាផែនដី រមែងអត់ទ្រាំ ចំពោះវត្ថុទាំងពួង ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាងណា ។ អ្នកក៏គួរអត់ទ្រាំ នូវការរាប់អាន និងការមើលងាយ របស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។

លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាឲ្យក្រៃលែងឡើងទៅដោយគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមតែប៉ុណ្ណោះឡើយ ក៏បានឃើញសច្ចបារមីទី ៧ មានគំនិតគិតយ៉ាងនេះថា នៃសុមេធ-បណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកគប្បីបំពេញសច្ចបារមីឲ្យពេញបរិបូណ៌ ទោះអសនីបាតធ្លាក់ចុះលើអំបែងក្បាលរបស់អ្នកក៏ដោយ ក៏អ្នកមិនត្រូវធ្វើនូវការនិយាយកុហកទាំងដឹងខ្លួន ព្រោះហេតុតែទ្រព្យជាដើមឡើយ ធម្មតាផ្កាយព្រឹក ក្នុងរដូវទាំងឡាយមិនវៀរគោចររបស់ខ្លួនឡើយ មិនគោចរទៅក្នុងផ្លូវដទៃ គោចរចំពោះតែក្នុងគន្លងរបស់ខ្លួនប៉ុណ្ណោះយ៉ាងណា អ្នកក៏មិនត្រូវលះសច្ចៈ មិនត្រូវធ្វើនូវការនិយាយកុហកជា

ដាច់ខាត ក៏យ៉ាងនោះដែរ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋានសច្ចបារមីទី ៧ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។

វិចិនន្តោ តទា ទក្ខឹ សត្តមំ សច្ចបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ សត្តមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ អទ្វេជ្ឈវចនោ សម្ពោធឹ បាបុណិស្សសិ ។

កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើសច្ចបារមីទី ៧ នេះ ឲ្យមាំមួន កុំមានពាក្យបែកជាពីរ ក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

**យថាបិ ឱសធិ[១] នាម តុលាភូតា សទេវកេ**
**សមយេ ឧតុវស្សេ វា ន វោក្កមតិ វីថិតោ ។**
**តថេវ ត្វំបិ សច្ចេសុ មា វោក្កមសិ វីថិតោ**
**សច្ចបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។**

*ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវីថី ក្នុងរដូវភ្លៀង ឬហេមន្តរដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវីថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ដូច្នេះ ។*

*លំដាប់នោះ កាលសុមេធបណ្ឌិត ពិចារណាក្រៃលែងឡើងតទៅទៀត ដោយគិតថា ធម្មតាធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ ក៏បានឃើញអធិដ្ឋានបារមីទី ៨ ក៏មានគំនិតយ៉ាងនេះថា នៃសុមេធបណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកចូរបំពេញអធិដ្ឋានបារមី អធិដ្ឋានវត្ថុណាទុក គប្បីជាអ្នកមិនញាប់ញ័រក្នុងអធិដ្ឋាននោះ ដូចជាធម្មតាភ្នំ កាលខ្យល់គ្រប់ទិសបក់បោកមក រមែងមិនញាប់ញ័រ មិនកក្រើករំពើក គង់នៅក្នុងទីដើមរបស់ខ្លួនយ៉ាងណា សូម្បីអ្នកក៏គប្បីជា*

---

*១- គួរតែ* **ឱសធី** *ដាក់ស្រៈឦ ដើម្បីបង្គ្រប់មាត្រា ។*

បុគ្គលមិនញាប់ញ័រ ក្នុងការតាំងចិត្តមាំរបស់ខ្លួន ក៏យ៉ាងនោះដែរ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតអធិដ្ឋានបារមីទី ៨ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។*

វិចិនន្តោ តទា ទក្ខិំ អដ្ឋមំ អធិដ្ឋានបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ អដ្ឋមំ តាវ ទឡ្ហំ កត្វា សមាទិយ
តត្ថ ត្វំ និច្ចលោ ហុត្វា សម្ពោធឹ បាបុណិស្សសិ ។

*កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយ អំពីបុរាណ ធ្លាប់សេពធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធ-បណ្ឌិត) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះ ឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។*

យថាបិ បព្វតោ សេលោ អចលោ សុបតិដ្ឋិតោ
ន កម្បតិ ភូសវាតេហិ សកដ្ឋានេវ តិដ្ឋតិ ។
តថេវ ត្វំ អធិដ្ឋានេ សព្វទា អចលោ ភវ
អធិដ្ឋានបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។

*ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយ ដោយខ្យល់ដ៏ខ្លាំងក្លា រមែងតាំងនៅ ក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមី សព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។*

*លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាឲ្យក្រៃលែងឡើងទៅទៀតដោយគិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ ក៏បានឃើញមេត្តាបារមីទី ៩ ក៏មានគំនិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកគប្បីបំពេញមេត្តាបារមីឲ្យពេញបរិបូណ៌ ក្នុងវត្ថុដែលជាប្រយោជន៍និងមិនជាប្រយោជន៍ គប្បីមានចិត្តតែមួយ ដូចជាធម្មតា ទឹករមែងធ្វើឲ្យត្រជាក់ផ្សាយទូទៅដល់មនុស្សអាក្រក់និងមនុស្សល្អ យ៉ាងណា សូម្បីអ្នកក៏ចូរជាបុគ្គលមានចិត្តតែមួយដោយមេត្តាក្នុងសត្វទាំងឡាយ ក៏យ៉ាងនោះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតបានអធិដ្ឋានមេត្តាបារមីទី ៩ ធ្វើឲ្យ*

*មាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា*

ន ហេតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ
អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិ-ញ្ញាណឲ្យសម្រេច ។*

វិចិនន្តោ តទា ទក្ខឹ នវមំ មេត្តាបារមឹ
បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។
ឥមំ ត្វំ នវមំ តាវ ទឡ្ហំ កត្វា សមាទិយ
មេត្តាយ អសមោ ហោហិ យទិ ពោធឹ បត្តុមិច្ឆសិ ។

*កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។*

យថាបិ ឧទកំ នាម កល្យាណេ បាបកេ ជនេ
សមំ ផរតិ សីតេន បវាហេតិ រជោមលំ ។
តថេវ ត្វំ ហិតាហិតេ សមំ មេត្តាយ ភាវយ

**មេត្តាចារមិតំ គន្ត្វា សម្ពោធឹ ចាបុណិស្សសិ ។**

*ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលីនិងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើ ចំពោះមិត្តនិងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ដូច្នេះ ។*

*លំដាប់នោះ កាលសុមេធបណ្ឌិតពិចារណាឲ្យក្រៃលែងឡើងទៅទៀតដោយគិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ មិនមែនមានត្រឹមតែប៉ុណ្ណេះឡើយ ទើបបានឃើញឧបេក្ខាបារមីទី ១០ ក៏មានការគិតយ៉ាងនេះថា នៃសុមេធបណ្ឌិត ចាប់តាំងអំពីពេលនេះទៅ អ្នកគប្បីបំពេញឧបេក្ខាបារមី គប្បីដាក់ចិត្តជាកណ្តាលក្នុងសុខនិងទុក្ខ ដូចជាផែនដី កាលមនុស្សចោលរបស់ស្អាតក្តី មិនស្អាតក្តី ផែនដីរមែងដាក់ចិត្តជាកណ្តាលយ៉ាងណា សូម្បីអ្នកក៏ដូច្នោះ ចូរដាក់ចិត្តជាកណ្តាលក្នុងសុខនិងទុក្ខ ក៏យ៉ាងនោះដែរ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ។ សុមេធបណ្ឌិតបានអធិដ្ឋានឧបេក្ខាបារមីទី ១០ ធ្វើឲ្យមាំទាំហើយ ព្រោះហេតុនោះ ទើបលោកពោលថា*

**ន ហោតេ ឯត្តកាយេវ ពុទ្ធធម្មា ភវិស្សរេ**
**អញ្ញេបិ វិចិនិស្សាមិ យេ ធម្មា ពោធិបាចនា ។**

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។*

**វិចិនន្តោ តទា ទក្ខឹ ទសមំ ឧបេក្ខាបារមឹ**
**បុព្វកេហិ មហេសីហិ អាសេវិតំ និសេវិតំ ។**
**ឥមំ ត្វំ ទសមំ តាវ ទឡ្ហំ កត្វា សមាទិយ**
**តុលាភូតោ ទឡ្ហោ ហុត្វា សម្ពោធឹ បាបុណិស្សសិ ។**

*កាលនោះ តថាគត កំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមី ទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះ ឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។*

**យថាបិ បឋវី នាម និក្ខិត្តំ អសុចឹ សុចឹ**
**ឧបេក្ខតិ ឧភោបេតេ កោបានុនយវជ្ជិតា ។**
**តថេវ ត្វំ សុខទុក្ខេ តុលាភូតោ សទា ភវ**
**ឧបេក្ខាបារមិតំ គន្ត្វា សម្ពោធឹ បាបុណិស្សសិ ។**

*ធម្មតាផែនដីតែងព្រងើយកន្តើយ ចំពោះវត្ថុមិនស្អាតក្តី ស្អាត*

ក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និង សេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីង ចំពោះសុខនិងទុក្ខ សព្វកាល យ៉ាងនោះដែរ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ដូច្នេះ ។

លំដាប់នោះ សុមេធបណ្ឌិតគិតថា ពុទ្ធការកធម៌ដែលជាគ្រឿងអប់រំបន្ទំពោធិញាណ មានត្រឹមតែប៉ុណ្ណោះឯង វៀរលែងបារមី ១០ ចេញធម៌ដទៃមិនមានទេ បារមី ១០ នេះ សូម្បីខាងលើ ក្នុងអាកាសក៏មិនមាន សូម្បីខាងក្រោមផែនដីក៏មិនមាន ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើមក្តី ក៏មិនមាន ឯបារមីទាំងនេះមាននៅខាងក្នុងហទយៈរបស់អញនេះឯង ដូច្នេះ ។ កាលឃើញថា បារមីទាំងនោះតាំងនៅក្នុងហទយៈហើយ ទើបអធិដ្ឋានបារមីទាំងអស់ធ្វើឲ្យមាំទាំ ពិចារណាហើយពិចារណាទៀត ត្រឡប់ទៅត្រឡប់មក ទាញយកខាងចុងឲ្យមកចប់ខាងដើម ទាញយកខាងដើមឲ្យមកចប់ខាងចុង ទាញយកត្រង់កណ្តាលឲ្យមកចប់ក្នុងខាងដើមនិងខាងចុង ទាញយកទីបំផុតទាំងពីរឲ្យមកចប់ត្រង់កណ្តាល ទាញយកបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ គឺការបរិច្ចាគវត្ថុខាងក្រៅជាទានបារមី ការបរិច្ចាគអវយវៈជាទានឧបបារមី ការបរិច្ចាគជីវិតជាទានបរមត្ថបារមី ហើយពិចារណាត្រឡប់ចុះត្រឡប់ឡើង ដូច

បុគ្គលបង្វិលនូវគ្រឿងយន្ត កូរប្រេងទៅមក និងពិចារណាឲ្យលាយចូលគ្នានឹងគ្នា ដូចបុគ្គលយកកំពូលភ្នំសិនេរុកូរក្នុងមហាសមុទ្ទ ក្នុងផ្ទៃចក្រវាល ដូច្នោះ ។ កាលពិចារណាបារមីទាំង ១០ ដោយតេជះនៃធម៌ មហាប្រឹថពីដែលមានកម្រាស់ ២ សែនយោជន៍ ក្រៃលែងដោយ ៤ ហនុត ( ២៤០.០០០ យោជន៍ ) ហាក់បីដូចជាបាច់នៃដើមបបុសត្រូវដំរីជាន់ហើយ និងដូចគ្រឿងយន្តដែលគេកំពុងគាបអំពៅ លាន់ឮសំឡេងកក្រើកខ្ទរខ្ទារទាំងអស់ មិនខុសអ្វីអំពីក្ដារប៉ែនរបស់នាយស្មូនផ្ទាំង និងគ្រឿងយន្តដែលគេបង្វិលគាបប្រេងដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា

ឯត្តកាយេវ តេ លោកេ យេ ធម្មា ពោធិបាចនា
តតុទ្ធំ នត្ថិ អញ្ញត្រ ធម្មំ តត្ថ បតិដ្ឋហិ ។

ធម៌ទាំងឡាយណា ជាគ្រឿងញ៉ាំងពោធិញ្ញាណឲ្យសម្រេច
ធម៌ទាំងនោះ មានក្នុងលោក ត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌
ដទៃ ក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុង
បារមីធម៌ទាំង ១០ នោះ ឲ្យមាំមួនចុះ ។

ឥមេ ធម្មេ សម្មសតោ សភាវសរសលក្ខណេ
ធម្មតេជេន វសុធា ទសសហស្សី បកម្បថ ។
ចលតិ រវតិ បឋវី ឧច្ឆុយន្តំវ បីឡិតំ
តេលយន្តំ យថា ចក្កំ ឯវំ កម្បតិ មេទនី ។

*កាលតថាគតពិចារណា នូវបារមីធម៌ទាំងនេះ ដោយសភាវៈ-សរសលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រ ដោយតេជះនៃធម៌ ៗ ផែនដីកម្រើកបន្ទឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាប ឬចក្កយន្តប្រេង ត្រូវគេគាបហើយ ( រមែង វិលញ័រ ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ដូច្នេះ ។*

*កាលមហាប្រឹថពីកម្រើករំពើកនោះឯង មនុស្សម្នាដែលអាស្រ័យនៅក្នុងរម្មនគរ ក៏មិនអាចទប់ខ្លួនឈរនៅបាន ហាក់ដូចជាសាលាធំដែលត្រូវខ្យល់កំបុតត្បូងបក់បោក នាំគ្នាដួលចុះ ភាជនៈរបស់ស្មូនឆ្នាំង មានឆ្នាំងជាដើម ដែលកំពុងធ្វើ ក៏ប៉ះទង្គិចគ្នា បែកជាលម្អិតតូចធំ មហាជនមានការតក់ស្លុត ទើបចូលទៅគាល់ព្រះសាស្តា ហើយក្រាបទូលសួរថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គមិនជ្រាបសេចក្តីនោះយ៉ាងដូចម្តេចទេ នេះជាឫទ្ធិរបស់នាគបណ្តាលឡើង ឬថា ពួកភូត យក្ស និងទេវតាណាមួយ ធ្វើឲ្យកក្រើករំពើក ។ ម្យ៉ាងទៀត មហាជនទាំងអស់ត្រូវធ្វើឲ្យក្តៅក្រហាយ ឧបទ្រព ឬសួស្តី នឹងមានដល់លោកនេះ សូមទ្រង់ត្រាស់ប្រាប់ហេតុនោះ ដល់ពួកខ្ញុំព្រះអង្គចុះ ។*

*ព្រះបរមសាស្តា ទ្រង់ស្តាប់ពាក្យរបស់អ្នកស្រុកទាំងនោះហើយ ក៏ត្រាស់ថា អ្នកទាំងឡាយ កុំភ័យខ្លាចឡើយ កុំគិតថ្វីឡើយ ភ័យអំពីហេតុនេះ មិនមានដល់ពួកអ្នកទាំងឡាយទេ ថ្ងៃនេះ សុមេធបណ្ឌិត តថាគត*

ព្យាករហើយថា នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងអនាគត ឥឡូវនេះ សុមេធបណ្ឌិតនោះពិចារណានូវបារមីទាំងឡាយ កាលសុមេធបណ្ឌិតនោះកំពុងពិចារណានូវបារមី ព្រោះតេជះនៃធម៌ លោកធាតុទាំង ១ ម៉ឺន ក៏កក្រើករំពើកទូទៅក្នុងអម្បាញ់មិញនេះ ដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា

យាវតា បរិសា អាសិ ពុទ្ធស្ស បរិវេសនេ
បវេធមានា សា តត្ថ មុច្ឆិតា សេតិ ភូមិយំ ។
ឃដានេកសហស្សានិ កុម្ភីនញ្ច សតា ពហូ
សញ្ចុណ្ណមថិតា តត្ថ អញ្ញមញ្ញំ បឃដ្ដិតា ។

បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាស បរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដី ក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។

ឧព្ពិគ្គា[១] តសិតា ភីតា ភន្តា ព្យថិតមានសា
មហាជនា សមាគម្ម ទីបង្ករមុបាគមុំ ។
កឹ ភវិស្សតិ លោកស្ស កល្យាណំ អថ បាបកំ

---

១- ឆដ្ឋសង្គាយនាមានរូបជា ឧព្វិគ្គា ។

**សព្វោ ឧបទ្ទុតោ លោកោ តំ វិនោទេហិ ចក្ខុមា ។**

*ពួកមហាជនមានចិត្តរន្ធត់តក់ស្លុត ភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្ដេច នឹងមានដល់មនុស្សលោក លោកទាំងមូលត្រូវសេចក្ដីអន្តរាយបៀតបៀនហើយ សូមព្រះអង្គ ទ្រង់មេត្តាប្រោស បន្ទោបង់សេចក្ដីអន្តរាយនោះចេញ ។*

**តេសំ តទា សញ្ញាបេសិ ទីបង្ករោ មហាមុនិ**
**វិសដ្ឋា ហោថ មា ភាថ ឥមស្មឹ បឋវិកម្បនេ ។**
**យមហំ អជ្ជ ព្យាកាសឹ ពុទ្ធោ លោកេ ភវិស្សតិ**
**ឯសោ សម្មសតី ធម្មំ បុព្វកំ ជិនសេវិតំ ។**

*គ្រានោះ ព្រះមហាមុនីទីបង្ករ ទ្រង់ញុំាងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយ ចូរកុំមានសេចក្ដីរង្កៀស កុំខ្លាចចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថាគតបានព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែលព្រះជិនស្រីអំពីបុរាណធ្លាប់សេពមក ។*

**តស្ស សម្មសតោ ធម្មំ ពុទ្ធភូមិមសេសតោ**
**តេជាយំ កម្បតី បឋវី ទសសហស្សី សទេវកេ ។**

*កាលសុមេធបណ្ឌិតពិចារណាធម៌គឺពុទ្ធភូមិ ដោយឥតសេសសល់ ព្រោះហេតុនោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុក្នុងលោកព្រមទាំងទេវលោក ញាប់ញ័រ ដូច្នេះ ។*

*មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគ ត្រេកអររីករាយហើយ នាំគ្នាកាន់យកផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបជាដើម ចេញអំពីរម្មនគរចូលទៅរកព្រះមហាសត្វ បូជាដោយផ្កាកម្រងជាដើម ថ្វាយបង្គំ ធ្វើប្រទក្សិណ ហើយចូលទៅកាន់រម្មនគរវិញ ។ ចំណែកព្រះបរមពោធិសត្វពិចារណាបារមីទាំង ១០ ធ្វើសេចក្តីព្យាយាមឲ្យមាំទាំអធិដ្ឋានហើយក្រោកចាកអាសនៈ ព្រោះហេតុនោះ ទើបលោកពោលថា*

**ពុទ្ធស្ស វចនំ សុត្វា មនោ និព្វាតិ តាវទេ**
**សព្វេ មំ ឧបសង្កម្ម បុនបិ អភិវន្ទិសុ ។**
**សមាទយិត្វា ពុទ្ធគុណំ ទឡ្ហំ កត្វាន មានសំ**
**ទីបង្ករំ នមស្សិត្វា អាសនា វុដ្ឋហឹ តទា ។**

*ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ ក្នុងខណៈនោះភ្លាម ព្រោះបានស្តាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា ក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្តងទៀត ។ គ្រានោះ*

តថាគត សមាទាននូវពុទ្ធគុណ ធ្វើចិត្តឲ្យមាំមួន ក្រាបថ្វាយ
បង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ដូច្នេះ ។

លំដាប់នោះ ទេវតាក្នុងម៉ឺនចក្រវាលក៏មកប្រជុំគ្នា ហើយបូជាព្រះពោធិសត្វដែលក្រោកអំពីអាសនៈ ដោយផ្កានិងគ្រឿងក្រអូបដ៏ជាទិព្វ ស្រែកប្រកាសនូវពាក្យសរសើរដែលជាមង្គលថា បពិត្រសុមេធតាបសដ៏ចម្រើន ថ្ងៃនេះ លោកតាំងសេចក្ដីប្រាថ្នាយ៉ាងធំ ទៀបបាទមូលរបស់ព្រះទសពលទីបង្ករ សូមសេចក្ដីប្រាថ្នារបស់លោកសម្រេច កុំបីមានអន្តរាយឡើយ ការខ្លាចឬការតក់ស្លុត កុំបីមានដល់លោក ឯរោគាព្យាធិ សូម្បីតែបន្តិចបន្តួច កុំបីកើតក្នុងរាងកាយ សូមលោកបំពេញបារមីឲ្យពេញឆាប់រួសរាន់ ហើយសម្រេចសម្មាសម្ពោធិញ្ញាណ ដើមឈើដែលចេញផ្កាចេញផ្លែ តាមរដូវតាមកាល យ៉ាងណា សូម្បីលោក ក៏ចូរបានពាល់ត្រូវព្រះសម្ពោធិញ្ញាណដ៏ឧត្តម ដោយឆាប់រួសរាន់ កុំបីកន្លងសម័យនោះ យ៉ាងនោះដូចគ្នា ។ ទេវតាទាំងឡាយ កាលស្រែកប្រកាសយ៉ាងនេះហើយ បានត្រឡប់ទៅកាន់ទេវស្ថានរៀងៗ ខ្លួន ។ ចំណែកព្រះពោធិសត្វដែលពួកទេវតាសរសើរហើយ គិតថា អញនឹងបំពេញបារមី ១០ ឲ្យបរិបូណ៌ ហើយក្នុងទីបំផុត ៤ អសង្ខេយ្យនិង ១ សែនកប្បបន្ទាប់អំពីនេះ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះ ហើយអធិដ្ឋានធ្វើនូវសេចក្ដីព្យាយាមឲ្យមាំ ហោះឡើងទៅកាន់អាកាស មានមុខទៅកាន់ព្រៃហិមពាន្តមួយរំពេច

*ព្រោះហេតុនោះ ទើបលោកពោលទុកថា*

ទិព្វំ មានុស្សិកំ បុប្ផំ ទេវា មានុសកា ឧភោ
សមោកិរន្តិ បុប្ផេហិ វុដ្ឋហន្តស្ស អាសនា ។
វេទយន្តិ ច តេ សោត្ថឹ ទេវា មានុសកា ឧភោ
មហន្តំ បត្ថិតំ តុយ្ហំ តំ លភស្សុ យថិច្ឆិតំ ។

*ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្ស ចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតានិងពួកមនុស្ស ទាំងពីរពួកនោះ បាននូវសួស្ដី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាន នូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។*

សព្វីតិយោ វិវជ្ជន្តុ សោកោ រោគោ វិវជ្ជតុ
មា តេ ភវត្វន្តរាយោ ផុស្ស ខិប្បំ ពោធិមុត្តមំ ។
យថា សមយេ សម្បត្តេ បុប្ផន្តិ បុប្ផិនោ ទុមា
តថេវ ត្វំ មហាវីរ ពុទ្ធញ្ញាណេន បុប្ផសិ ។

*ចង្រៃទាំងពួង ចូរបវៀសចៀសចេញទៅ សេចក្ដីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្ដីអន្តរាយ កុំបីមានដល់លោកឡើយ សូមលោកបានលុះ នូវសព្វញ្ញុតញ្ញាណដ៏ខ្ពង់ខ្ពស់ឆាប់ៗ ចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែង*

*បញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណ យ៉ាងនោះដែរ ។*

យថា យេ កេចិ សម្ពុទ្ធា   បូរយុំ ទសបារមី
តថេវ ត្វំ មហាវីរ   បូរយ ទសបារមី ។
យថា យេ កេចិ សម្ពុទ្ធា   ពោធិមណ្ឌម្ហិ ពុជ្ឈរេ
តថេវ ត្វំ មហាវីរ   ពុជ្ឈស្សុ ជិនពោធិយំ ។

*ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយ នូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹង ទៀបគល់ពោធិមណ្ឌៈ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹង ទៀបគល់ពោធិមណ្ឌៈ នៃព្រះជិនស្រី យ៉ាងនោះ ។*

យថា យេ កេចិ សម្ពុទ្ធា   ធម្មចក្កំ បវត្តយុំ
តថេវ ត្វំ មហាវីរ   ធម្មចក្កំ បវត្តយ ។
បុណ្ណមាយំ យថា ចន្ទោ   បរិបុណ្ណោ វិរោចតិ
តថេវ ត្វំ បុណ្ណមនោ   វិរោច ទសសហស្សិយំ ។

*ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញុំាងធម្មចក្រ ឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរញុំាង*

ធម្មចក្រឲ្យប្រព្រឹត្តទៅ យ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុ ទាំងមួយម៉ឺន យ៉ាងនោះ ។

**រាហុមុត្តោ យថា សុរិយោ តាបេន អតិរោចតិ**
**តថេវ លោកា មុញ្ចិត្វា វិរោច សិរិយា តុវំ ។**
**យថា យា កាចិ នទិយោ ឱសរន្តិ មហោទធឹ**
**ឯវំ សទេវកា លោកា ឱសរន្តិ តវន្តិកេ ។**

ព្រះអាទិត្យដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធ-សិរី យ៉ាងនោះដែរ ។ ស្ទឹងទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោកព្រមទាំងទេវ-លោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ ។

**តេហិ ថុតិប្បសត្ថោ សោ ទសធម្មេ សមាទិយ**
**តេ ធម្មេ បរិបូរេន្តោ បវនំ បាវិសី តទា ។**

គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតានិងមនុស្សទាំងនោះ សើ្ញចសរសើរហើយ ក៏សមាទានន្ធូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូលទៅកាន់ព្រៃធំ ដូច្នេះ ។

ចប់ សុមេធកថា ។

ចំណែកអ្នកនគរម្មៈឯណោះវិញ បានចូលទៅកាន់នគរហើយ ថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះបរមសាស្ដា ទ្រង់សម្ដែងធម៌ដល់ពួកមហាជន ឲ្យតាំងនៅក្នុងសរណៈជាដើមហើយ ទ្រង់ចេញអំពីរម្មនគរទៅ បន្ទាប់អំពីនោះ ព្រះអង្គទ្រង់តាំងនៅដរាបដល់អស់ព្រះជន្មាយុ ទ្រង់ធ្វើពុទ្ធកិច្ចគ្រប់យ៉ាងហើយ ទ្រង់រំលត់ខន្ធបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុដោយលំដាប់ ពាក្យដែលគួរពោលក្នុងទីទាំងពួង គប្បីជ្រាបតាមន័យដែលពោលទុកហើយក្នុងគម្ពីរពុទ្ធវំសៈឯណោះចុះ ពិតហើយ លោកពោលទុកក្នុងគម្ពីរពុទ្ធវំសៈនោះថា

**តទា តេ ភោជយិត្វាន សសង្ឃំ លោកនាយកំ**
**ឧបគញ្ឆុំ សរណំ តស្ស ទីបង្ករស្ស សត្ថុនោ ។**
**សរណាគមនេ កញ្ចិ និវេសេសិ តថាគតោ**
**កញ្ចិ បញ្ចសុ សីលេសុ សីលេ ទសវិធេ បរំ ។**

គ្រានោះ ពួកឧបាសកឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្ដាទីបង្ករនោះ ជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះ ឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះ ឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។

**កស្សចិ ទេតិ សាមញ្ញំ ចតុរោ ផលមុត្តមេ**

កស្សចិ អសមេ ធម្មេ ទេតិ សោ បដិសម្ភិទា ។
កស្សចិ វរសមាបត្តិយោ អដ្ឋ ទេតិ នាសកោ
តិស្សោ កស្សចិ វិជ្ជាយោ ឆឡភិញ្ញា បវេច្ឆតិ ។

*ព្រះអង្គទ្រង់ប្រទានមគ្គ ដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើ ដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរ ដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។*

តេន យោគេន ជនកាយំ ឱវទតិ មហាមុនិ
តេន វិត្ថារិកំ អាសិ លោកនាថស្ស សាសនំ ។
មហាហនូសភក្ខន្ធោ ទីបង្ករសនាមកោ
ពហូ ជនេ តារយតិ បរិមោចេតិ ទុគ្គតឹ ។

*ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះហេតុនោះ បានជាសាសនានៃព្រះលោកនាថ ជាគុណជាតដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូចព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានដងខ្លួនមូលក្លំដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។*

ពោធនេយ្យជនំ ទិស្វា សតសហស្សេបិ យោជនេ

ខណេន ឧបគន្ត្វាន ពោធេតិ តំ មហាមុនិ ។
បឋមាភិសមយេ ពុទ្ធោ កោដិសតមពោធយិ
ទុតិយាភិសមយេ ធាថោ នវុតិកោដិមពោធយិ ។

*ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ឋិតនៅក្នុងទីមួយសែនយោជន៍ ទ្រង់ចូលទៅជិតហើយញ៉ាំងពួកជននោះឲ្យត្រាស់ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ញ៉ាំងពួកទេវតា ១០០ កោដិ ឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញ៉ាំងពួកទេវតានិងមនុស្ស ៩០ កោដិ ឲ្យត្រាស់ដឹង ។*

យទា ច ទេវភវនម្ហិ ពុទ្ធោ ធម្មមទេសយិ
នវុតិកោដិសហស្សានំ តតិយាភិសមយោ អហុ ។
សន្និបាតា តយោ អាសុំ ទីបង្ករស្ស សត្ថុនោ
កោដិសតសហស្សានំ បឋមោ អាសិ សមាគមោ ។

*កាលណា ព្រះពុទ្ធទ្រង់សម្តែងធម៌ក្នុងភពនៃទេវតា កាលនោះពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មានសាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក គឺ សន្និបាតលើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។*

បុន នារទភូជម្ហិ បរិវេការតេ ជិនេ
ខីណាសវា វីតមលា សមឹសុ សតកោដិយោ ។
យម្ហិ កាលេ មហាវីរោ សុទស្សនសិលុច្ចយេ
នវុតិកោដិសហស្សេហិ បវារេសិ មហាមុនិ ។

*កាលដែលព្រះជិនស្រី ទ្រង់យាងទៅក្នុងទីស្ងាត់លើកំពូលភ្នំនារទៈ ពួកព្រះខីណាស្រព ប្រាសចាកមន្ទិលចំនួន ១០០ កោដិ មកប្រជុំគ្នា (នេះជាសន្និបាតលើកទី ២) ។ កាលព្រះមហាមុនី មានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ឰដ៏ភ្នំសុទស្សនៈ (នេះជាសន្និបាតលើកទី ៣) ។*

អហំ តេន សមយេន ជដិលោ ឧគ្គតាបនោ
អន្តលិក្ខម្ហិ ចរណោ បញ្ចាភិញ្ញាសុ ចារគូ ។
ទសវីសសហស្សានំ ធម្មាភិសមយោ អហុ
ឯកទ្វិន្នំ អភិសមយោ គណនាតោ អសង្ខិយោ ។

*សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅឰដ៏អាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។*

វិត្ថារិកំ ពហុជញ្ញំ ឥទ្ធំ ផីតំ អហុ តទា
ទីបង្ករស្ស ភគវតោ សាសនំ សុវិសោធិតំ ។
ចត្តារិ សតសហស្សានិ ឆឡភិញ្ញា មហិទ្ធិកា
ទីបង្ករំ លោកវិទុំ បរិវារេន្តិ សព្វទា ។

*សាសនារបស់ព្រះទីបង្ករ មានព្រះភាគ ជាគុណជាតធំទូលាយ មានជនច្រើន ស្ដុកស្ដម្ភ សាយភាយ គឺព្រះអង្គទ្រង់ជម្រះល្អ ហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រព ចំនួន ៤ សែន រូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធ ទីបង្ករ ដែលទ្រង់ជ្រាបច្បាស់នូវលោកសព្វកាល ។*

យេ កេចិ តេន សមយេន ជហន្តិ មានុសម្ភវំ
អប្បត្តមានសា សេក្ខា គរហិតា ភវន្តិ តេ ។
សុបុប្ផិតំ ចាវចនំ អរហន្តេហិ តាទិហិ
ខីណាសវេហិ វិមលេហិ ឧបសោភតិ សព្វទា ។

*ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនា (របស់ព្រះពុទ្ធទីបង្ករនោះ) រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្តខីណាស្រព ជាតាទិបុគ្គល ប្រាសចាកមន្ទិល សព្វកាល ។*

នគរំ រម្មវតី នាម សុទេវោ នាម ខត្តិយោ
សុមេធា នាម ជនិកា ទីបង្ករស្ស សត្ថុនោ ។
ទស វស្សសហស្សានិ អគារំ អជ្ឈាវសី ជិនោ
ហំសា កោញ្ចា មយុរា ច តយោ បាសាទមុត្តមា ។

*នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មវតី ក្សត្រិយ៍ព្រះនាមសុទេវៈ (ជាព្រះបិតា) ព្រះជនិកាព្រះនាមសុមេធា ។ ព្រះជិនស្រី នៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់ មាន ៣ ខ្នង គឺហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មយុរប្រាសាទ ១ ។*

តីណិ សតសហស្សានិ នារិយោ សមលង្កតា
បទុមា នាម សា នារី ឧសភក្ខន្ធោ នាម អត្រជោ ។
និមិត្តេ ចតុរោ ទិស្វា ហត្ថិយានេន និក្ខមិ
អនូនទសមាសានិ បធានំ បទហី ជិនោ ។

*ពួកនារី ៣ សែននាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ (ជាមហេសី) ព្រះឱរស ព្រះនាមឧសភក្ខន្ធ ។ ព្រះជិនស្រីឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ (បួស) ដោយយានដំរី ទ្រង់ផ្គងព្យាយាម អស់ ១០ ខែឥតខ្វះ ។*

បធានចារំ ចរិត្វាន អពុជ្ឈិ មានសា មុនិ

ព្រហ្មុនា យាចិតោ សន្តោ ទីបង្ករោ មហាមុនិ ។
វត្តចក្កោ មហាវីរោ នន្ទារាមេ វសី ជិនោ
និសិន្នោ សិរិសមូលម្ហិ អកាសិ តិត្ថិយមទ្ទនំ ។

*លុះព្រះមុនីមានព្រះទ័យប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ ព្រះមហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រីមានព្យាយាមធំ ទ្រង់ញុំាងធម្មចក្រឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទៈ ទ្រង់គង់ទៀបគល់ព្រេស ធ្វើនូវការញាំញីតិរ្ថិយ ។*

សុមង្គលោ ច តិស្សោ ច អហេសុំ អគ្គសាវកា
សាគតោ នាមុបដ្ឋាកោ ទីបង្ករស្ស សត្ថុនោ ។
នន្ទា ចេវ សុនន្ទា ច អហេសុំ អគ្គសាវិកា
ពោធិ តស្ស ភគវតោ បិប្ផលីតិ បវុច្ចតិ ។

*ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវ័ក ព្រះសាគតៈ ជាឧបដ្ឋាករបស់ព្រះសាស្តាទីបង្ករ ។ នាងនន្ទានិងនាងសុនន្ទាជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថាដើមល្វៀប ។*

តបុស្សភល្លិកា នាម អហេសុំ អគ្គុបដ្ឋកា
សិរិមា សោណា ឧបដ្ឋិកា ទីបង្ករស្ស សត្ថុនោ ។
អសីតិហត្ថមុព្វេធោ ទីបង្ករោ មហាមុនិ

សោភតិ ទីបង្ករោ  សាលរាជាវ ផុល្លិតោ ។

ឧបាសកឈ្មោះតបុស្សៈនិងភល្លិកៈ ជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមានិងនាងសោណា ជាឧបដ្ឋាយិការបស់ព្រះសាស្តាទីបង្ករ ។ ព្រះមហាមុនីទីបង្ករ មានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្គុះស្គាយ ។

បភា និទ្ធាវតី តស្ស  សមន្តា ទសយោជនេ
សតសហស្សវស្សានិ  អាយុ តស្ស មហេសិនោ ។
តាវតា តិដ្ឋមានោ សោ  តារេសិ ជនតំ ពហុំ
ជោតយិត្វាន សទ្ធម្មំ  មន្តារេត្វា មហាជនំ ។

រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ ១០ យោជន៍ជុំវិញ ព្រះមហេសីនោះ មានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញុំាងព្រះសទ្ធម្មឲ្យរុងរឿង ចម្លងមហាជន ញុំាងប្រជុំជនច្រើនឲ្យឆ្លងចាកសង្សារវដ្ត ។

ជលិត្វា អគ្គិក្ខន្ធោវ  និព្វុតោ សោ សសាវកោ
សា ច ឥទ្ធិ សោ ច យសោ  តានិ ច ចាទេសុ ចក្ករតនានិ ។
សព្វំ សមន្តរហិតំ  ននុ រិត្តា សព្វសង្ខារាតិ
ទីបង្ករោ ជិនោ សត្ថា  នន្ទារាមម្ហិ និព្វុតោ ។

ព្រះទីបង្ករនោះ ព្រមទាំងសាវ័កនិព្វានទៅ ដូចគំនរភ្លើងដែល

រុងរឿងរលត់ទៅដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈ ឰដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ក៏អន្តរធានទៅ ឱហ្ន៎! សង្ខារទាំងពួងជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។

**តត្ថេវ តស្ស ជិនថូបោ ឆត្តឹសុព្វេធយោជនោ**
**បត្តចីវរំ បរិក្ខារំ បរិភោគញ្ច សត្ថុនោ**
**ពោធិមូលេ តទា ថូបោ តិយោជនសមុគ្គតោ ។**

ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់ ៣៦ យោជន៍ ( គេកសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស ( សម្រាប់បញ្ចុះ ) បាត្រ និង ចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់ របស់ព្រះសាស្តា ដូច្នេះ ។

ខាងក្រោយអំពីព្រះទសពលទីបង្ករ កន្លងមកបាន ១ អសង្ខេយ្យ ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមកោណ្ឌញ្ញៈ ទ្រង់កើតឡើងហើយ សូម្បីការប្រជុំសាវករបស់ព្រះអង្គ ក៏មាន ៣ លើក ។ ក្នុងការប្រជុំលើកទី ១ មានសាវ័ក ១ សែនកោដិ លើកទី ២ មាន ១ ពាន់កោដិ លើកទី ៣ មាន ៩០ កោដិ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើង យោនយកកំណើតជា

ស្តេចចក្រពត្តិព្រះនាមថា វិជិតាវី បានថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ចំនួន ១ សែនកោដិអង្គ ។ ព្រះបរមសាស្តា ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ហើយទ្រង់សម្តែងធម៌ ព្រះពោធិសត្វស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ លះបង់រាជសម្បត្តិ ចេញបួស រៀនព្រះត្រៃបិដក ធ្វើសមាបត្តិ ៨ និង អភិញ្ញា ៥ ឲ្យកើតឡើងហើយ មានឈានមិនសាបសូន្យក៏ទៅកាន់ព្រហ្មលោក ។

សម្រាប់ព្រះកោណ្ឌញ្ញសម្ពុទ្ធ មាននគរឈ្មោះថា រម្មវតី ក្សត្រព្រះនាមថា សុនន្ទៈ ជាព្រះរាជបិតា ព្រះទេវីព្រះនាមថា សុជាតា ជាព្រះរាជមាតា ។ ព្រះភទ្ទៈនិងព្រះសុភទ្ទៈ ជាព្រះអគ្គសាវ័ក ពុទ្ធុបដ្ឋាកព្រះនាមថា អនុរុទ្ធ ។ ព្រះនាងតិស្សាថេរី និងឧបតិស្សាថេរី ជាអគ្គសាវិកា ដើមឈើត្រាស់ដឹងរបស់ព្រះមានព្រះភាគអង្គនេះ មានឈ្មោះថា សាលកល្យាណិ ( ដើមក្ទៅនាង ) ។ ព្រះវរកាយ មានកម្ពស់ ៨៨ ហត្ថ ប្រមាណព្រះជន្មាយុ ១ សែនឆ្នាំ ដូច្នេះ ។

**ទីបង្ករស្ស អបរេន កោណ្ឌញ្ញោ នាម នាយកោ**
**អនន្តតេជោមិតយសោ [(១)] អប្បមេយ្យោ ទុរាសទោ ។**

សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោកនាយក

---

១- ច្បាប់ឆដ្ឋសង្គាយនាមានរូបជា អនន្តតេជោមិតយសោ ។

ព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជះរកទីបំផុតគ្មាន មានយស
រាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយបុគ្គលគ្រប
សង្កត់បាន ។

ក្នុងកាលតអំពីព្រះសម្មាសម្ពុទ្ធអង្គនោះមក ១ អសង្ខេយ្យ ក្នុងកប្បមួយនោះ មានព្រះពុទ្ធកើតឡើង ៤ ព្រះអង្គ គឺព្រះមង្គលៈ ១ ព្រះអង្គ ព្រះសុមនៈ ១ ព្រះអង្គ ព្រះរេវតៈ ១ ព្រះអង្គ ព្រះសោភិតៈ ១ ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថា មង្គលៈ មានការប្រជុំសាវក ៣ លើក ។ ក្នុងការប្រជុំលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ ក៏ ១ សែនកោដិ លើកទី ៣ មានភិក្ខុ ៩០ កោដិ ។ បានឮថា ព្រះភាតាមាតាដទៃរបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា អានន្ទកុមារ បានយាងមកកាន់សម្នាក់របស់ទ្រង់ ដើម្បីស្តាប់ធម៌មួយអន្លើដោយបរិស័ទ ៩០ កោដិ ។ ព្រះទសពលត្រាស់អនុបុព្វីកថាដល់ព្រះភាតានោះ ព្រះរាជកុមារជាមួយនឹងបរិស័ទ សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ព្រះសាស្តា ទ្រង់សម្លឹងមើលបុព្វចរិយារបស់កុលបុត្តទាំងនោះ ទ្រង់ទតឃើញឧបនិស្ស័យនៃបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ទើបទ្រង់លាព្រះហស្តខាងស្តាំចេញមក ហើយត្រាស់ថា **ឯថ ភិក្ខវោ** ពួកអ្នកចូរមកជាភិក្ខុចុះ ។ ខណៈនោះឯង ជនទាំងអម្បាលនោះ ក៏ទ្រទ្រង់នូវបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ បរិបូណ៌ដោយអាកប្បកិរិយា ដូចព្រះថេរៈមានវស្សា

៦០ ចោមរោមថ្វាយបង្គំព្រះសាស្តាហើយ នេះជាការប្រជុំសាវកលើកទី ៣ របស់ព្រះអង្គ ។ ព្រះរស្មីចេញអំពីព្រះសរីរៈរបស់ព្រះពុទ្ធអង្គដទៃ មានប្រមាណ ៨០ ហត្ថប៉ុណ្ណោះ ដោយជុំវិញ [១] យ៉ាងណា តែព្រះរស្មីរបស់ព្រះមង្គលៈ មិនដូច្នោះទេ ឡើយ ចំណែកព្រះរស្មីចេញអំពីព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគអង្គនោះ ផ្សាយទៅរហូត ១ ម៉ឺនចក្រវាល តាំងនៅអស់កាលជានិច្ច ដើមឈើ ផែនដី ភ្នំ និងសមុទ្រជាដើម ដោយហោចសូម្បីឆ្នាំងបាយជាដើម ក៏មានពន្លឺគ្របដណ្តប់ហាក់ដូចជាមាស ។ ម្យ៉ាងទៀត ប្រមាណព្រះជន្មាយុរបស់ព្រះអង្គបាន ៩ ម៉ឺនឆ្នាំ អស់កាលមានប្រមាណប៉ុណ្ណោះ ព្រះអាទិត្យនិងព្រះចន្ទរមែងមិនប្រាកដ ព្រោះមិនអាចបញ្ចេញរស្មីរបស់ខ្លួន កាលកំណត់ពេលយប់និងពេលថ្ងៃ ក៏មិនប្រាកដក្នុងពេលថ្ងៃ ពួកសត្វត្រាច់ទៅដោយពន្លឺរបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ដូចគ្នានឹងពន្លឺរបស់ព្រះអាទិត្យ សត្វលោកដឹងកំណត់កាលពេលយប់និងពេលថ្ងៃ ដោយអំណាចនៃផ្កាដែលរីកក្នុងវេលាល្ងាច និងបក្សីជាដើមចេញអំពីសម្បុកក្នុងវេលាព្រឹក ។

---

១-ជាធម្មតា ពន្លឺដែលផ្សាយចេញអំពីព្រះវរកាយ របស់ព្រះមានព្រះភាគទាំងឡាយ ១ ព្យាមខ្លះ ៨០ ហត្ថខ្លះ ច្រើនជាងនោះខ្លះ តែក្នុងទីនេះ លោកពោលត្រឹមតែ ៨០ ហត្ថប៉ុណ្ណោះ យើងមិនដឹងបំណងរបស់ព្រះអដ្ឋកថាចារ្យ សេចក្តីនេះ បណ្ឌិតគប្បីពិចារណា ។

សួរថា ព្រះពុទ្ធទាំងឡាយអង្គដទៃ មិនមានអានុភាពយ៉ាងនេះឬ ?

ឆ្លើយថា មិនមែនមិនមានទេ ពិតហើយ ព្រះពុទ្ធអង្គទាំងនោះ កាលទ្រង់បំណង គប្បីផ្សាយព្រះរស្មីទៅបានអស់លោកធាតុ ១ ម៉ឺន ឬច្រើនជាងនោះ ឯព្រះរស្មីដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសម្ពុទ្ធមង្គលៈ ផ្សាយទៅអស់លោកធាតុ ១ ម៉ឺនជានិច្ចកាលនោះឯង ដូចព្រះរស្មី ១ ព្យាមរបស់ព្រះពុទ្ធអង្គដទៃៗ ដោយអំណាចសេចក្តីប្រាថ្នាក្នុងកាលមុន ។

បានឮថា ក្នុងកាលដែលទ្រង់អន្ទោលទៅជាព្រះពោធិសត្វ តាំងនៅក្នុងអត្តភាពដូចគ្នានឹងព្រះវេស្សន្តរ មួយអន្លើដោយបុត្តនិងភរិយាចេញទៅកាន់ភ្នំ ដូចគ្នានឹងភ្នំវង្កតបព៌តដូច្នោះ ។ កាលនោះ មានយក្សមួយឈ្មោះថា ខរទាឋិក បានឮថា ព្រះមហាបុរសមានអធ្យាស្រ័យពេញចិត្តក្នុងទាន ទើបចូលទៅរកដោយកាឡាខ្លួនជាព្រាហ្មណ៍ ហើយសូមទារកទាំងពីរអំពីព្រះមហាសត្វ ។ ព្រះពោធិសត្វពោលថា នែព្រាហ្មណ៍ យើងនឹងឲ្យកូន ដូច្នេះ ទ្រង់ត្រេកអរ រីករាយធ្វើនូវផែនដីដែលមានទឹកជាទីបំផុតឲ្យញាប់ញ័រ បានឲ្យទារកទាំងពីរហើយ យក្សឈរផ្អែកភ្ជាក់ដៃក្នុងទីបំផុតនៃទីចង្រ្កម កាលព្រះមហាសត្វកំពុងឃើញនោះឯង ក៏ទំពាស៊ីទារកទាំងពីរដូចស៊ីឫសឈើ ការទោមនស្សសូម្បីប៉ុនចុងសក់ ក៏មិនកើតឡើងដល់ព្រះមហាបុរស ព្រោះសម្លឹងមើលយក្ស សូម្បីឃើញមាត់យក្ស

កំពុងមានឈាមហូរធ្លាក់ចុះមក ហាក់បីដូចជាអណ្តាតភ្លើងក្នុងមាត់ដែលហាឡើង កាលព្រះពោធិសត្វគិតថា **សុចិណ្ណំ វត មេ ទានំ** ទានដែលអញឲ្យល្អហើយហ្ន៎ បីតិនិងសោមនស្សដ៏ក្រៃលែង បានកើតឡើងពេញសរីរៈ ព្រះបរមពោធិសត្វធ្វើសេចក្តីប្រាថ្នាថា ដោយផលនៃទានរបស់អាត្មាអញនេះ ក្នុងអនាគតសូមរស្មីផ្សាយចេញដោយទំនងនេះឯង ព្រោះអាស្រ័យសេចក្តីប្រាថ្នារបស់ព្រះមហាសត្វ ទើបរស្មីផ្សាយចេញអំពីព្រះវរកាយរបស់ព្រះអង្គ អស់កាលត្រឹមប្រមាណប៉ុណ្ណេះ ។ បុព្វចរិយាដទៃទៀតរបស់ព្រះអង្គក៏នៅមាន បានឮថា ក្នុងកាលនោះ ព្រះបរមពោធិសត្វឃើញចេតិយរបស់ព្រះពុទ្ធមួយព្រះអង្គគិតថា អញគួរបរិច្ចាគជីវិតដល់ព្រះពុទ្ធអង្គនេះ ទើបយកសំពត់មករុំសរីរៈទាំងអស់ ដោយទំនងដូចគេរុំប្រទីបដែលមានដង យកសប្បិដាក់ពេញថាសមាស ដែលមានតម្លៃ ១ សែន កម្ពស់ ១ ហត្ថ ធ្វើប្រឆេះចង្កៀងចំនួន ១ ពាន់ដាក់ក្នុងភាជនៈនោះ យកសិរសាទូលថាសនោះ ហើយដុតប្រឆេះចង្កៀង ព្រមទាំងខ្លួនរបស់ព្រះអង្គ ធ្វើប្រទក្សិណព្រះចេតិយ ឲ្យកាលវេលាកន្លងទៅអស់ ១ រាត្រី កាលព្រះពោធិសត្វកំពុងព្យាយាមនោះ ថ្ងៃក៏រះឡើង កម្តៅមិនមានសូម្បីតែត្រឹមចុងរោម ហាក់បីដូចជាចូលទៅក្នុងល្វែងនៃផ្កាឈូកក្រហមដូច្នោះពិតហើយ ធម្មតាធម៌ រមែងរក្សានូវបុគ្គលដែលប្រព្រឹត្តធម៌ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ថា

ធម្មោ ហវេ រក្ខតិ ធម្មចារឹ
ធម្មោ សុចិណ្ណោ សុខមាវហាតិ
ឯសានិសំសោ ធម្មេ សុចិណ្ណេ
ន ទុគ្គតឹ គច្ឆតិ ធម្មចារី ។

*ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ [១] ។*

*ព្រោះផលនៃកម្មនេះ ទើបពន្លឺចេញអំពីព្រះសរីរៈរបស់ព្រះសាស្ដាអង្គនោះ ផ្សាយទៅ តាំងនៅ អស់ម៉ឺនលោកធាតុ ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើង កើតជាព្រាហ្មណ៍ឈ្មោះថា សុរុចិ គិតថា អញនឹងនិមន្តព្រះសាស្ដា ទើបចូលទៅគាល់ ស្ដាប់ព្រះធម្មកថាដ៏ពីរោះហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្អែកនេះសូមទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះអង្គចុះ ។*

*ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកមានសេចក្ដីត្រូវការដោយភិក្ខុមានប្រមាណប៉ុនណា ?*

---

*១-បិ.៥៦ , ទំ. ២១០ ។*

ព្រះពោធិសត្វពោលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាបរិវាររបស់ព្រះអង្គមានប្រមាណប៉ុនណា ?

កាលនោះ ព្រះបរមសាស្តា ទ្រង់មានការប្រជុំសាវកលើកទី ១ ល្មមព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា មានប្រមាណ ១ សែនកោដិ ។

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មួយអន្ទើដោយភិក្ខុសង្ឃទាំងអស់ ទទួលភិក្ខារបស់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាទ្រង់ទទួលហើយ ។

ព្រះពោធិសត្វ កាលនិមន្តដើម្បីឲ្យព្រះសាស្តាទ្រង់សោយក្នុងថ្ងៃស្អែករួចហើយ ទៅផ្ទះគិតថា អញអាចប្រគេនបបរ ភត្ត និងសំពត់ដល់ភិក្ខុសង្ឃមានប្រមាណប៉ុណ្ណោះបាន តែទីអង្គុយគឺសេនាសនៈ នឹងមានមកអំពីណា ការគិតរបស់ព្រះពោធិសត្វនោះ ក៏ធ្វើឲ្យក្តៅដល់ថ្មបណ្ឌុកម្ពលសិលាសនៈរបស់សក្កទេវរាជ ដែលទ្រង់កំពុងប្រថាប់ឈរក្នុងទីបំផុតនៃទី ៨៤.០០០ យោជន៍ ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា នរណាហ្ន៎ ត្រូវការឲ្យអាត្មាអញឃ្លាតចាកអាសនៈនេះ ទ្រង់ប្រមើលមើលដោយទិព្វចក្ខុ ក៏ឃើញព្រះមហាបុរស ទ្រង់ព្រះតម្រិះថា សុរុចិព្រាហ្មណ៍នេះ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ( ដើម្បីឆាន់ក្នុងថ្ងៃស្អែក ) គិតដើម្បីរកទីអង្គុយគួរតែអាត្មាអញទៅក្នុងទីនោះ កាន់យកចំណែកបុណ្យនឹងគេខ្លះ ទើបនិម្មិតរាងកាយជាជាងឈើ មានដៃកាន់កាំបិតនិងប៉ូវថៅ បានប្រាកដខ្លួន

ខាងមុខព្រះមហាបុរស ហើយពោលថា អ្នកណាមានការងារដែលខ្ញុំអាចធ្វើបានដែរឬទេ ?

ព្រះមហាបុរសឃើញហើយទើបសួរថា អ្នកចេះធ្វើការអ្វីខ្លះ?

ឥន្ទនិមិត្តឆ្លើយថា សិល្បៈណាមួយដែលខ្ញុំមិនចេះ មិនមានទេ អ្នកណាឲ្យខ្ញុំធ្វើការងារណា ទោះជាការងារផ្ទះក្តី មណ្ឌបក្តី ខ្ញុំនឹងធ្វើការងារនោះៗ ដល់បុគ្គលនោះ ។

ព្រះមហាបុរសពោលថា បើដូច្នោះ ខ្ញុំមានការងារមួយ ។

ព្រះឥន្ទសួរថា តើការងារអ្វីទៅលោកម្ចាស់?

ព្រះពោធិសត្វពោលថា ភិក្ខុ ១ សែនកោដិ ខ្ញុំបាននិមន្តដើម្បីឲ្យលោកឆាន់ក្នុងថ្ងៃស្អែក តើអ្នកអាចធ្វើមណ្ឌប និងទីអង្គុយរបស់ភិក្ខុទាំងនោះ បានដែរឬទេ ?

ព្រះឥន្ទពោលថា ខ្ញុំអាចធ្វើបាន ឲ្យតែថ្លៃឈ្នួលដល់ ។

ព្រះពោធិសត្វពោលថា អើធ្វើចុះ ខ្ញុំអាច ។

ព្រះឥន្ទក៏ទទួលថា សាធុ ខ្ញុំនឹងធ្វើ ទើបទៅពិនិត្យមើលទីទំនេរមួយកន្លែង ដែលមានបរិមណ្ឌលប្រមាណ ១២ - ១៣ យោជន៍ មានផ្ទៃដីរាបស្មើដូចជាមណ្ឌលនៃកសិណ ។ ព្រះឥន្ទក៏គិតថា សូមមណ្ឌបដែលសម្រេចដោយកែវ ៧ ប្រការ ប្រាកដឡើងមក ក្នុងទីមានប្រមាណប៉ុណ្ណោះក្នុងរំពេចនោះឯង មណ្ឌបក៏ជ្រែកផែនដីផុសឡើងមក ត្រង់សសរសម្រេច

ដោយមាស មានក្អមទឹកសម្រេចដោយប្រាក់តាំងនៅ ត្រង់សសរសម្រេចដោយប្រាក់ មានក្អមទឹកសម្រេចដោយមាស ត្រង់សសរសម្រេចដោយកែវមណី មានក្អមទឹកសម្រេចដោយកែវប្រពាល ត្រង់សសរដែលសម្រេចដោយកែវប្រពាល មានក្អមទឹកសម្រេចដោយកែវមណី ត្រង់សសរដែលសម្រេចដោយកែវ ៧ ប្រការ មានក្អមទឹកសម្រេចដោយកែវ ៧ ប្រការដូចគ្នា ។ បន្ទាប់អំពីនោះ ព្រះឥន្ទក៏សម្លឹងមើលដោយគិតថា សូមបណ្តាញកណ្តឹងសំយុងចុះ នៅតាមចន្លោះៗ នៃមណ្ឌប ដំណាលគ្នានឹងការគិតនោះឯង បណ្តាញកណ្តឹងក៏សំយុងចុះ ហើយមានសំឡេងល្ងងល្ងើយកាលត្រូវខ្យល់បក់ក៏បន្លឺសំឡេងចេញមកដ៏ពីរោះ ដូចតូរ្យតន្ត្រីដែលប្រកបដោយអង្គ ៥ កាលសម្លឹងមើល មិនខុសអ្វីអំពីតូរ្យតន្ត្រីទិព្វកំពុងបន្លឺ ទើបព្រះឥន្ទគិតថា ក្នុងចន្លោះៗនេះ សូមមានកម្រងផ្កានិងកម្រងគ្រឿងក្រអូបសំយុងចុះមក កម្រងផ្កានិងកម្រងគ្រឿងក្រអូប ក៏សំយុងចុះមកហើយ ព្រះឥន្ទគិតថា អាសនៈនិងតាំងសម្រាប់អង្គុយ សម្រាប់ភិក្ខុដែលមានចំនួន ១ សែនកោដិ សូមជ្រែកផែនដីផុសឡើងមក ក្នុងរំពេចនោះឯង វត្ថុទាំងនោះក៏ជ្រែកផែនដីផុសឡើងមក ។ ព្រះឥន្ទគិតថា គ្រប់ៗ ជ្រុង សូមឲ្យមានក្អមទឹកជ្រែកផែនដីផុសឡើងមក ក្នុងមួយជ្រុងមួយក្អម ក្អមទឹកក៏ជ្រែកផែនដីផុសឡើងមក ព្រះឥន្ទនិម្មិតវត្ថុផ្សេងៗ មានប្រមាណប៉ុណ្ណោះស្រេចហើយ ក៏ទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ហើយពោលថា នៃ

លោក សូមលោកពិនិត្យមើលមណ្ឌប ហើយឲ្យថ្លៃឈ្នួលដល់ខ្ញុំ ។ ព្រះមហាបុរសទៅមើលមណ្ឌបហើយ កាលកំពុងពិនិត្យមើលនោះឯង សរីរៈទាំងមូលប្រកបដោយបីតិ ៥ ប្រការ ខណៈដែលព្រះពោធិសត្វសម្លឹងមើលមណ្ឌប ក៏មានគំនិតយ៉ាងនេះថា មណ្ឌបនេះ មនុស្សធ្វើមិនបានទេ តែព្រោះអធ្យាស្រ័យរបស់អញ គុណរបស់អញ ភពរបស់សក្កទេវរាជក្ដៅពិតប្រាកដ បន្ទាប់អំពីនោះ សក្កទេវរាជក៏មកសាងមណ្ឌបនេះឡើងដូច្នេះ ។ ព្រះបរមពោធិសត្វគិតថា ការថ្វាយទានត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ក្នុងមណ្ឌបដែលមានសភាពបែបនេះ មិនសមគួរដល់អញឡើយ អញនឹងថ្វាយអស់កាល ៧ ថ្ងៃ ។ ពិតហើយ ទានខាងក្រៅ សូម្បីមានប្រមាណប៉ុនណា ក៏មិនអាចធ្វើសេចក្ដីត្រេកអរឲ្យដល់ព្រះពោធិសត្វបានទេ តែក្នុងវេលាដែលព្រះមហាសត្វកាត់ក្បាល ដែលប្រដាប់តាក់តែងហើយ ខ្វេះភ្នែកទាំងគូ ដែលបន្ដក់ថ្នាំល្អហើយ វះយកសាច់បេះដូងចេញ ហើយឲ្យទៅ ( ជាទាន ) ទើបព្រះពោធិសត្វត្រេកអរក្រៃលែង ព្រោះការបរិច្ចាគនោះ ។ កាលព្រះពោធិសត្វរបស់ពួកយើង លះបង់កហាបណៈ ៥ សែនរាល់ៗ ថ្ងៃ ឲ្យទានត្រង់ទ្វារទាំង ៤ និងត្រង់កណ្ដាលនគរ ក្នុង **សិវិជាតក** ទាននោះ ក៏មិនអាចឲ្យកើតសេចក្ដីត្រេកអរក្នុងការបរិច្ចាគឡើយ តែក្នុងកាលណា សក្កទេវរាជកាឡាខ្លួនជាព្រាហ្មណ៍មកសុំកែវភ្នែកទាំងគូ ក្នុងកាលនោះ ព្រះពោធិសត្វខ្វេះកែវភ្នែកទាំងនោះ ឲ្យទៅជាទាននោះឯង

សេចក្តីត្រេកអរក្រៃលែងក៏កើតឡើង ចិត្តមិនបានប្រែប្រួលទៅជាដទៃ សូម្បីប៉ុនចុងសក់ ឈ្មោះថា ការឆ្អែតព្រោះអាស្រ័យទានដែលឲ្យហើយ ដោយអាការយ៉ាងនេះ មិនមានដល់ព្រះពោធិសត្វឡើយ ព្រោះដូច្នោះ ព្រះមហាបុរសនោះ ក៏គិតថា អញគួរថ្វាយទានដល់ភិក្ខុទាំងឡាយ មាន ប្រមាណ ១ សែនកោដិ អស់កាល ៧ ថ្ងៃ ទើបគួរ ហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ប្រថាប់គង់ក្នុងមណ្ឌបនោះ បានថ្វាយទានឈ្មោះ គវបានៈអស់កាល ៧ ថ្ងៃ ។ ដែលហៅថា គវបានៈនោះ បានដល់ភោជន ដែលគេដាក់ទឹកដោះរហូតពេញខ្ទះ ហើយលើកឡើងដាក់លើជើងក្រាន ដាក់អង្ករបន្តិចបន្តួចក្នុងទឹកដោះដែលពុះហើយ ក្នុងខ្ទះនោះ ស្ងោររម្ងាស់ ដាក់ដោយរសទាំងឡាយ មានទឹកឃ្មុំ ស្ករផែននិងសប្បិដែលចម្អិនហើយ ។ ឯមនុស្សនេះឯង មិនអាចនឹងអង្គាសភិក្ខុទាំងឡាយបាន សូម្បីតែទេវតា ក៏ត្រូវតែផ្លាស់ប្តូរគ្នាទើបអាចអង្គាសបាន ទីមានប្រមាណ ១២ - ១៣ យោជន៍ ក៏មិនគ្រប់គ្រាន់សម្រាប់ដាក់ភិក្ខុទាំងឡាយបានឡើយ តែភិក្ខុ ទាំងនោះ អង្គុយបានដោយអានុភាពរបស់ខ្លួននោះឯង ។

ក្នុងថ្ងៃទី ៧ ព្រះបរមពោធិសត្វលាងបាត្ររបស់ភិក្ខុគ្រប់រូបហើយ ដាក់សប្បិ នវនីត ទឹកឃ្មុំ និងទឹកអំពៅជាដើម រហូតពេញបាត្រ ដើម្បីជា ភេសជ្ជៈ មួយអន្លើដោយត្រៃចីវរ សំពត់សាដកដែលជាចីវរ ដែលភិក្ខុនវក ក្នុងភិក្ខុសង្ឃបានទទួលទៅមានតម្លៃដល់ទៅ ១ សែន ។ ព្រះបរមសាស្តា

កាលទ្រង់ធ្វើអនុមោទនា ទ្រង់ពិចារណាថា បុរសនេះថ្វាយទាន មានសភាពបែបនេះ គេនឹងបានជាអ្វីហ្ន៎ កាលទ្រង់ទតឃើញថា នឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមថា គោតម ក្នុងទីបំផុតនៃ ២ អសង្ខេយ្យនិង ១ សែនកប្បក្នុងអនាគត ដូច្នេះ ទើបទ្រង់ត្រាស់ហៅព្រះមហាបុរសមក ហើយព្យាករថា អំណឹះកាលមានប្រមាណប៉ុណ្ណេះហើយ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ព្រះនាមថា គោតម ។

ព្រះមហាបុរស លុះឮពាក្យព្យាករណ៍របស់ព្រះពុទ្ធហើយ គិតថា បានឮថា អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ ប្រយោជន៍អ្វីដោយការនៅគ្រប់គ្រងផ្ទះ អញនឹងចេញបួស ទើបលះបង់សម្បត្តិដ៏មហោឡារនោះ ហាក់ដូចជាដុំទឹកមាត់ ហើយចេញបួសក្នុងសម្នាក់របស់ព្រះបរមសាស្តា កាលបួសហើយ រៀនទូវពុទ្ធវចនៈ ឲ្យអភិញ្ញានិងសមាបត្តិកើតឡើងហើយ ក្នុងវេលាអស់អាយុ ក៏បានទៅកើតក្នុងព្រហ្មលោក ។

ឯនគររបស់ព្រះមានព្រះភាគព្រះនាមថា ព្រះមង្គលៈ មានឈ្មោះថា ឧត្តរៈ ព្រះរាជបិតា ព្រះនាមថា ឧត្តរៈ ព្រះរាជមាតា ព្រះនាមថា ឧត្តរា ។ អគ្គសាវ័កទាំងពីររបស់ព្រះអង្គ ព្រះនាមថា សុទេវៈ ១ ធម្មសេនៈ ១ ឧបដ្ឋាកព្រះនាមថា បាលិតៈ ។ អគ្គសាវិកាទាំងពីរអង្គ ព្រះនាមថា សីវលា ១ ព្រះនាមថា អសោកា ១ ដើមឈើត្រាស់ដឹង មានឈ្មោះថា នាគព្រឹក្ស ( ដើមខ្លឹង ) ។ ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះអង្គ

ទ្រង់តាំងព្រះជន្មនៅបាន ៩ ម៉ឺនឆ្នាំក៏បរិនិព្វាន កាលព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់បរិនិព្វានហើយ ចក្រវាល ១ ម៉ឺនក៏ងងឹតតែមួយដំណាលគ្នានោះឯង ពួកមនុស្សទាំងឡាយក្នុងចក្រវាលទាំងអស់ ក៏នាំគ្នាស្រែកយំកន្ទក់កន្ទេញហើយ ដូច្នេះ ។

**កោណ្ឌញ្ញស្ស អបរេន មង្គលោ នាម នាយកោ**
**តមំ លោកេ និហន្ត្វាន ធម្មោក្កមភិធារយិ ។**

កាលខាងក្រោយ អំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះលោក-
នាយកព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹតក្នុងលោក ព្រះ
អង្គទ្រទ្រង់នូវគប់ភ្លើងគឺព្រះធម៌ ។

ខាងក្រោយព្រះមានព្រះភាគអង្គនោះ ទ្រង់បរិនិព្វាន ធ្វើម៉ឺនលោកធាតុឲ្យងងឹតយ៉ាងនេះហើយ ព្រះបរមសាស្តា ព្រះនាមថា សុមនៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ ត្រង់កញ្ចនបព៌តមានភិក្ខុ ៩០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៨០ ពាន់កោដិ ។

ក្នុងកាលនោះ ព្រះមហាសត្វនៃយើង កើតជានាគរាជឈ្មោះថាអតុលៈ មានឫទ្ធិច្រើន មានអានុភាពច្រើន ។ ស្តេចនាគនោះ បានឮថាព្រះពុទ្ធកើតឡើងហើយ មានពួកញាតិចោមរោម ចេញអំពីនាគពិភពហើយធ្វើការបន្ទីនូវទិព្វតន្ត្រី ថ្វាយដល់ព្រះដ៏មានព្រះភាគ ដែលមានភិក្ខុ

សង្ឃ ១ សែនកោដិជាបរិវារ ថ្វាយគូនៃសំពត់ចំពោះព្រះអង្គហើយតាំង នៅក្នុងសរណៈ ព្រះសាស្តាអង្គនោះ ក៏ទ្រង់ព្យាករនាគរាជនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលអនាគត ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ មានឈ្មោះថា មេខលៈ ព្រះរាជា ទ្រង់ព្រះនាមថា សុទត្តៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សិរិមា ។ អគ្គសាវ័ករបស់ព្រះអង្គ ព្រះនាមថា សរណៈ ១ ព្រះនាមថា ភាវិតត្តៈ ១ ឧបដ្ឋាកព្រះនាមថា ឧទេន ។ អគ្គសាវិកាពីរព្រះអង្គ ព្រះនាមថា សោណា ១ ព្រះនាមថា ឧបសោណា ១ ឯដើមពោធិព្រឹក្សរបស់ព្រះអង្គមានឈ្មោះថា នាគព្រឹក្ស ។ ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៩០ ហត្ថ ប្រមាណព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដោយប្រការដូច្នេះ ។

**មង្គលស្ស អបរេន សុមនោ នាម នាយកោ**
**សព្វធម្មេហិ អសមោ សព្វសត្តានមុត្តមោ ។**

កាលខាងក្រោយ អំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក
ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មានដោយធម៌ទាំងពួង ព្រះអង្គ
ឧត្តមជាងសព្វសត្វ ។

ខាងក្រោយនៃព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្តា ទ្រង់ព្រះនាមថា រេវតៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ នោះ មានភិក្ខុរាប់មិនបាន

សន្និបាតលើកទី ២ មានព្រះអរហន្ត ១ សែនកោដិ សន្និបាតលើកទី ៣ ក៏ដូចគ្នា ( ១ សែនកោដិ ) ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើង កើតជាព្រាហ្មណ៍ ឈ្មោះអតិទេវៈ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ តាំងនៅក្នុងសរណៈ ផ្គងអញ្ជលីលើសិរសា បានស្តាប់ព្រះគុណក្នុងការលះកិលេសរបស់ព្រះសាស្តានោះ បានធ្វើការបូជាដោយសំពត់ដណ្តប់ ព្រះអង្គក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានជាព្រះពុទ្ធ ។

ឯនគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា សុធញ្ញកៈ ព្រះរាជបិតាជាក្សត្រ ព្រះនាមថា វិបុលៈ ព្រះរាជមាតា ព្រះនាមថា វិបុលា ។ ព្រះអគ្គសាវ័កទាំងពីរព្រះអង្គ ព្រះនាមថា វរុណៈ ១ ព្រះនាមថា ព្រហ្មទេវៈ ១ ឧបដ្ឋាក ព្រះនាមថា សម្ភវៈ ។ ព្រះអគ្គសាវិកាពីរព្រះអង្គ ព្រះនាមថា ភទ្ទា ១ ព្រះនាមថា សុភទ្ទា ១ ឯដើមនាគព្រឹក្សជាឈើត្រាស់ដឹង ។ ព្រះសរីរៈកម្ពស់ប្រមាណ ៨០ ហត្ថ ប្រមាណនៃព្រះជន្មាយុបាន ៦ ម៉ឺនឆ្នាំ ដោយប្រការដូច្នេះ ។

សុមនស្ស អបរេន   រេវតោ នាម នាយកោ
អនុបមោ អសទិសោ   អតុលោ ឧត្តមោ ជិនោ ។

កាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមសុមនៈមក មាន
ព្រះលោកនាយក ព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិន

មានបុគ្គលស្មើ មិនមានបុគ្គលប្ញឹងបាន ព្រះអង្គឧត្តម ទ្រង់ឈ្នះពួកមារ ។

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះមហាមុនី ទ្រង់ព្រះនាមថា សោភិតៈ បានកើតឡើងក្នុងលោក សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិ ក្នុងសន្និបាតលើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាព្រាហ្មណ៍ឈ្មោះថា សុជាតៈ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយតាំងនៅក្នុងសរណៈ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឯព្រះសាស្តាក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ មានឈ្មោះថា សុធម្មៈ ព្រះរាជា ព្រះនាមថា សុធម្មៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុធម្មា ។ អគ្គសាវ័ក ព្រះនាមថា អសមៈ ១ ព្រះនាមថា សុនេត្តៈ ១ ឧបដ្ឋាក ព្រះនាមថា អនោមៈ ។ អគ្គសាវិកា ព្រះនាមថា នកុលា ១ ព្រះនាមថា សុជាតា ១ ដើមនាគព្រឹក្សជាឈើត្រាស់ដឹង ។ ឯព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ប្រមាណព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដោយប្រការដូច្នេះ ។

**បរេតស្ស អបរេន សោភិតោ នាម នាយកោ**
**សមាហិតោ សន្តចិត្តោ អសមោ អប្បដិបុគ្គលោ ។**

*កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មាន*
*ព្រះលោកនាយក ព្រះនាមសោភិតៈ មានព្រះហឫទ័យ*
*តម្កល់ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិន*
*មានបុគ្គលប្រៀបផ្ទឹម ។*

*ខាងក្រោយអំពីព្រះសាស្តាអង្គនោះ កន្លងទៅបាន ១ អសង្ខេយ្យ ក្នុងកប្បតែមួយនោះ មានព្រះពុទ្ធ ៣ ព្រះអង្គ ទ្រង់កើតឡើង គឺ ព្រះអនោមទស្សី ១ ព្រះអង្គ ព្រះបទុមៈ ១ ព្រះអង្គ ព្រះនារទៈ ១ ព្រះអង្គ ។ សម្រាប់ព្រះមានព្រះភាគ ព្រះនាមថា អនោមទស្សី មានសាវកសន្និបាត ៣ លើក ។ លើកទី ១ មានភិក្ខុ ៨ សែនអង្គ លើកទី ២ មានភិក្ខុ ៧ សែនអង្គ លើកទី ៣ មានភិក្ខុ ៦ សែនអង្គ ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងបានជាសេនាបតីយក្ស មានឫទ្ធិច្រើន មានអានុភាពច្រើន ជាអធិបតីនៃយក្ស ១ សែនកោដិ ។ បានឮថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ទើបធ្វើដំណើរមក បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសាស្តាក៏ទ្រង់ព្យាករសេនាបតីយក្សនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។*

*ឯនគររបស់ព្រះដ៏មានព្រះភាគអនោមទស្សី ឈ្មោះថា ចន្ទវតី ព្រះរាជា ទ្រង់ព្រះនាមថា យសវា ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា យសោធរា ។ ព្រះអគ្គសាវក ព្រះនាមថា និសភៈ ១ ព្រះនាម*

ថា អនោមៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា វរុណៈ ។ ព្រះអគ្គសាវិកា ព្រះនាមថា សុន្ទរា ១ ព្រះនាមថា សុមនា ១ អជ្ជុនព្រឹក្ស ( ដើមអង្រ្គង ) ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ដូច្នេះ ។

**សោភិតស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ**
**អនោមទស្សី អមិតយសោ តេជស្សី ទុរតិក្កមោ ។**

*កាលជាខាងក្រោយ អំពីព្រះសោភិតសម្ពុទ្ធមក មានព្រះសម្ពុទ្ធ ព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្របុគ្គលកន្លងបាន ។*

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្ដា ទ្រង់ព្រះនាមថា បុទុមៈ កើតឡើងហើយក្នុងលោក សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៣ សែន លើកទី ៣ មានភិក្ខុដែលនៅក្នុងដងព្រៃមហាវ័ន ដែលមិនមែនជាស្រុកចំនួន ២ សែន ។

ក្នុងកាលនោះ ព្រះបរមសាស្ដា ទ្រង់ប្រថាប់នៅក្នុងដងព្រៃនោះ ព្រះពោធិសត្វនៃយើងយោនយកកំណើតជារាជសីហ៍ ឃើញព្រះសាស្ដាចូលនិរោធសមាបត្តិ មានចិត្តជ្រះថ្លា ថ្វាយបង្គំ ធ្វើប្រទក្សិណ កើតបីតិ

*សោមនស្សបន្លឺសីហនាទ ៣ ដង អស់ ៧ ថ្ងៃ មិនលះបីតិ មានព្រះពុទ្ធជាអារម្មណ៍ ព្រោះសុខដែលកើតអំពីបីតិនោះឯង មិនចេញទៅរកស៊ី ធ្វើការបរិច្ចាគជីវិត បានចូលទៅគាល់ព្រះសាស្តាហើយឈរក្នុងទីនោះ ។ ព្រះសាស្តាទ្រង់ចេញអំពីនិរោធសមាបត្តិ ក្នុងកាល ៧ ថ្ងៃកន្លងទៅ ទ្រង់ទតឃើញរាជសីហ៍ ទ្រង់ព្រះតម្រិះថា សីហៈនេះនឹងមានចិត្តជ្រះថ្លាក្នុងភិក្ខុសង្ឃ ហើយថ្វាយបង្គំភិក្ខុសង្ឃ ទើបទ្រង់ព្រះតម្រិះថា ភិក្ខុសង្ឃទាំងឡាយ ចូរមក រំពេចនោះឯង ភិក្ខុទាំងឡាយក៏មក រាជសីហ៍មានចិត្តជ្រះថ្លាហើយក្នុងព្រះសង្ឃ ។ ព្រះសាស្តា ទ្រង់ប្រមើលមើលចិត្តរបស់សីហៈ ហើយទ្រង់ព្យាករថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។*

*ឯនគររបស់ព្រះមានព្រះភាគបទុមៈ ឈ្មោះថា ចម្បកៈ ព្រះរាជាទ្រង់ព្រះនាមថា អសមៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា អសមា ។ អគ្គសាវ័ក ព្រះនាមថា សាលៈ ១ ព្រះនាមថា ឧបសាលៈ ១ ឧបដ្ឋាក ព្រះនាមថា វរុណៈ ។ អគ្គសាវិកា ព្រះនាមថា រាធា ១ ព្រះនាមថា សុរាធា ១ មហាសោណព្រឹក្ស (ដើមម្រុំ) ជាឈើត្រាស់ដឹង ។ ព្រះសរីរៈកម្ពស់ប្រមាណ ៥៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ដូច្នេះ ។*

អនោមទស្សិស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
បទុមោ នាម នាមេន អសមោ អប្បដិបុគ្គលោ ។

*ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សី*

មក មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្តមជាងសត្វជើង ពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្តា ព្រះនាមថា នារទៈ ទ្រង់កើតឡើងហើយ សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៩០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៨០ សែន ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងបួសជាឥសី ជាអ្នកបដិបត្តិរហូតជំនាញក្នុងអភិញ្ញា ៥ ក្នុងសមាបត្តិ ៨ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បានធ្វើការបូជាដោយខ្លឹមចន្ទន៍ក្រហម ព្រះសាស្តាក៏ទ្រង់ព្យាករឥសីនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ មានឈ្មោះថា ធញ្ញវតី ក្សត្រព្រះនាមថា សុទេវៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា អនោមា ។ អគ្គសាវ័ក ព្រះនាមថា ភទ្ទសាលៈ ១ ព្រះនាមថា ជិតមិត្តៈ ១ ឧបដ្ឋាក ព្រះនាមថា វាសេដ្ឋៈ ។ ព្រះអគ្គសាវិកា ព្រះនាមថា ឧត្តរា ១ ព្រះនាមថា ផគ្គុនី ១ ដើមមហាសោណព្រឹក្សជាឈើត្រាស់ដឹង ឯព្រះសរីរៈកម្ពស់ ៨៨ ហត្ថក្រពុំ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំគត់ ដូច្នេះ ។

**បទុមស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ**

ជាវតោ ជាម ជាមេន  អសមោ អប្បដិបុគ្គលោ ។

*ក្នុងកាលជាខាងក្រោយ  នៃព្រះពុទ្ធព្រះនាមបទុមៈមក*
*មានព្រះសម្ពុទ្ធព្រះនាមនារទៈ  ទ្រង់ឧត្តមជាងសត្វជើង*
*ពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ។*

*ខាងក្រោយអំពីព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមនារទៈមក បាន ១ អសង្ខេយ្យ ក្នុងកប្បទី ១ សែន រាប់ថយក្រោយអំពីកប្បនេះ មានព្រះពុទ្ធ ១ ព្រះអង្គព្រះនាមថា បទុមុត្តរៈ ទ្រង់កើតឡើងហើយ សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក ។ ក្នុងលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ ត្រង់ភ្នំវេភារបព៌ត មានភិក្ខុ ៩០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៨០ ពាន់កោដិ ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាជដិល ឈ្មោះថា មហារដ្ឋិយៈ បានថ្វាយចីវរទានដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូម្បីព្រះអង្គក៏ទ្រង់ព្យាករជដិលនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលអនាគត ។*

*ក្នុងកាលនៃព្រះទសពល ព្រះនាមបទុមុត្តរៈ ពួកតិរ្ថិយមិនប្រាកដ គឺមិនមានពួកតិរ្ថិយឡើយ ពួកទេវតានិងមនុស្សទាំងពួង បានដល់ព្រះពុទ្ធប៉ុណ្ណោះ ជាសរណៈ ។ ឯនគររបស់ព្រះអង្គឈ្មោះថា ហង្សវតី ក្សត្រព្រះនាមថា អានន្ទៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុជាតា ។*

អគ្គសាវ័ក ព្រះនាមថា ទេវិល ១ ព្រះនាមថា សុជាតៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា សុមនៈ ។ អគ្គសាវិកាព្រះនាមថា អមិតា ១ ព្រះនាមថា អសមា ១ ដើមសលឡព្រឹក្ស ( ដើមស្រល់ ) ជាឈើត្រាស់ដឹង ។ ឯព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៥៨ ហត្ថក្រពុំ ព្រះរស្មីផ្សាយចេញអំពីព្រះសរីរៈក្នុងទីប្រមាណ ១២ យោជន៍ដោយជុំវិញ ព្រះជន្មាយុបាន ១ សែនឆ្នាំដូច្នេះ ។

**ឆារទស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ**
**បទុមុត្តរោ ឆាម ជិនោ អក្ខោភ្ពោ សាគរូបមោ ។**

ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ។

ខាងក្រោយអំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈបរិនិព្វានទៅ ក្នុងកប្ប ១ រាប់ថយក្រោយអំពីកប្បនេះទៅ ៣ ម៉ឺនកប្ប មានព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះសុមេធៈនិងព្រះសុជាតៈ ទ្រង់កើតឡើងហើយ ។ សាវកសន្និបាតរបស់ព្រះសម្ពុទ្ធព្រះនាមសុមេធៈ ក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ ក្នុងសុទស្សននគរ មានព្រះខីណាស្រព ១០០ កោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាមាណព ឈ្មោះឧត្តរៈ

លះបង់ទ្រព្យ ៨០ កោដិ ដែលកប់ទុកទាំងអស់ ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌ហើយតាំងនៅក្នុងសរណៈ ហើយចេញបួស ។ ព្រះសាស្តា ក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ។

ឯនគររបស់ព្រះមានព្រះភាគ ព្រះនាមថា សុមេធៈនោះ ឈ្មោះថា សុទស្សនៈ ព្រះរាជា ទ្រង់ព្រះនាមថា សុទត្តៈ ជាព្រះរាជបិតា ព្រះរាជមាតាបង្កើត ព្រះនាមថា សុទត្តា ។ អគ្គសាវកពីរអង្គ ព្រះនាមថា សរណៈ ១ ព្រះនាមថា សព្វកាមៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា សាគរៈ ។ អគ្គសាវិកាពីរព្រះអង្គ ព្រះនាមថា រាមា ១ ព្រះនាមថា សុរាមា ១ និម្ពព្រឹក្ស ( ដើមស្តៅ ) ជាឈើត្រាស់ដឹង ។ ព្រះសរីរៈកម្ពស់ ៨៨ ហត្ថក្រពុំ ព្រះជន្មាយុបាន ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

**បទុមុត្តរស្ស អបរេន សុមេធោ នាម នាយកោ**
**ទុរាសទោ ឧគ្គតេជោ សព្វលោកុត្តមោ ជិនោ ។**

ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈមក មានព្រះពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្របសង្កត់បានដោយក្រ ទ្រង់មានព្រះតេជៈដ៏ខ្ពង់ខ្ពស់ ជាព្រះជិនស្រី ដ៏ប្រសើរឧត្តមជាងលោកទាំងមូល ។

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្តា ទ្រង់

ព្រះនាមថា សុជាតៈ កើតឡើងក្នុងលោក សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៦០ សែនរូប លើកទី ២ មានភិក្ខុ ៥០ សែនរូប លើកទី ៣ មានភិក្ខុ ៤ សែនរូប ។

ក្នុងកាលនោះ ព្រះមហាសត្វនៃយើងជាស្តេចចក្រពត្តិ បានឮថាព្រះពុទ្ធកើតឡើងហើយ ទើបចូលទៅគាល់ ស្តាប់ព្រះធម្មទេសនា ហើយថ្វាយរាជសម្បត្តិក្នុងទ្វីបទាំង ៤ មួយអន្លើដោយរតនៈ ៧ ប្រការដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ហើយបួសក្នុងសម្នាក់ព្រះសាស្តា អ្នកដែនទាំងអស់កាន់យកប្រាក់ដែលកើតឡើងក្នុងរដ្ឋ ទទួលនាទីជាអារាមិកជនបានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានជានិច្ចកាល ។ ព្រះបរមសាស្តាក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ។

ឯនគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា សុមង្គលៈ ព្រះរាជា ទ្រង់ព្រះនាមថា ឧគ្គតៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា បភាវតី ។ អគ្គសាវក មាននាមថា សុទស្សនៈ ១ មាននាមថា សុទេវៈ ១ ឧបដ្ឋាក មាននាមថា នារទៈ ។ អគ្គសាវិកាមាននាមថា នាគា ១ មាននាមថា នាគសមានា ១ មហាវេឡុព្រឹក្ស ( ដើមឫស្សីធំ ) ជាឈើត្រាស់ដឹង ។ បានឮថា ដើមឫស្សីនោះ មិនមានប្រហោង ជាឫស្សីមានដើមរឹងមានមែកធំៗ ដុះឡើងល្អពន់ពេក ឯស្លឹកហាក់បីដូចជាកន្ទុយក្ងោក ។

ព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគអង្គនោះ កម្ពស់ ៥០ ហត្ថក្រពុំ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

**តត្ថេវ មណ្ឌកប្បម្ហិ[១] សុជាតោ នាម នាយកោ**
**សីហហនុ ឧសភក្ខន្ធោ អប្បមេយ្យោ ទុរាសទោ ។**

ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធជានាយក ព្រះនាមសុជាតៈ ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហៈ ទ្រង់មានព្រះស្វារង ដូចជា-កនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ។

ខាងក្រោយអំពីព្រះសុជាតសម្ពុទ្ធបរិនិព្វានទៅ ក្នុងកប្ប ១ រាប់អំពីកប្បនេះ ថយក្រោយទៅ ១.៨០០ កប្ប មានព្រះពុទ្ធកើតឡើង ៣ ព្រះអង្គ គឺ ព្រះបិយទស្សី ១ ព្រះអង្គ ព្រះអត្ថទស្សី ១ ព្រះអង្គ ព្រះធម្មទស្សី ១ ព្រះអង្គ ។ សាវកសន្និបាតរបស់ព្រះបិយទស្សីក៏មាន ៣ លើក ។ លើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

---

១-កប្បណា មានព្រះពុទ្ធត្រាស់ដឹង ១ ព្រះអង្គ ហៅថា សារកប្ប មានព្រះពុទ្ធត្រាស់ដឹង ២ ព្រះអង្គ ហៅថា មណ្ឌកប្ប មានព្រះពុទ្ធត្រាស់ដឹង ៣ ព្រះអង្គ ហៅថា សារមណ្ឌកប្ប មានព្រះពុទ្ធត្រាស់ដឹង ៤ ព្រះអង្គ ហៅថា វរកប្ប មានព្រះពុទ្ធត្រាស់ដឹង ៥ ព្រះអង្គ ហៅថា ភទ្ទកប្ប ។ កប្បណា ដែលមិនមានព្រះពុទ្ធត្រាស់ដឹង ហៅថា សុញ្ញកប្ប ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាមាណព ឈ្មោះថា កស្សបៈ រៀនចប់ត្រៃវេទ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានបរិច្ចាគទ្រព្យ ១ សែនកោដិ សាងសង្ឃារាម តាំងនៅក្នុងសរណៈនិងសីល ពេលនោះ ព្រះសាស្តា ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលកន្លងទៅ ១.៨០០ កប្ប ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ មានឈ្មោះថា សុធញ្ញៈ ព្រះរាជាទ្រង់ព្រះនាមថា សុទត្តៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុចន្ទា ។ ព្រះអគ្គសាវ័ក ព្រះនាមថា បាលិតៈ ១ ព្រះនាមថា សព្វទស្សី ១ ឧបដ្ឋាក ព្រះនាមថា សោភិតៈ ។ ព្រះអគ្គសាវិកា ព្រះនាមថា សុជាតា ១ ព្រះនាមថា ធម្មទិន្នា ១ កកុធព្រឹក្ស (ដើមថ្ងាន់) ជាឈើត្រាស់ដឹង ។ ឯព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

**សុជាតស្ស អបរេន សយម្ភូ លោកនាយកោ**
**ទុរាសទោ អសមសមោ បិយទស្សី មហាយសោ ។**

ក្នុងកាលជាខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសុជាតៈ មកមានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាព្រះសយម្ភូ ជាលោកនាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ ព្រះអង្គស្មើដោយព្រះពុទ្ធដែលឥតមានបុគ្គលស្មើ ។

*ខាងក្រោយអំពីព្រះលោកនាយកអង្គនេះ ព្រះមានព្រះភាគ ព្រះនាមថា អត្ថទស្សី ទ្រង់កើតឡើងក្នុងលោក ឯសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៩៨ ពាន់អង្គ លើកទី ២ មានភិក្ខុ ៨៨ ពាន់អង្គ លើកទី ៣ ក៏មានភិក្ខុ ៧៨ ពាន់អង្គ ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាតាបសមានឫទ្ធិច្រើនឈ្មោះថា សុសិមៈ បាននាំឆ័ត្រផ្កាមន្ទារវៈមកអំពីទេវលោក បូជាព្រះបរមសាស្តា ឯព្រះសាស្តាក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលជាអនាគត ។*

*ឯនគររបស់ព្រះមានព្រះភាគអត្ថទស្សីនោះ ឈ្មោះថា សោភណៈ ព្រះរាជា ទ្រង់ព្រះនាមថា សាគរ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុទស្សនា ។ អគ្គសាវ័ក ព្រះនាមថា សន្តៈ ១ ព្រះនាមថា ឧបសន្តៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា អភយៈ ។ អគ្គសាវិកាព្រះនាមថា ធម្មា ១ ព្រះនាមថា សុធម្មា ១ ចម្បកព្រឹក្ស ( ដើមចម្ប៉ា ) ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គមានកម្ពស់ ៨០ ហត្ថ ព្រះរស្មីចេញអំពីព្រះវរកាយផ្សាយទៅប្រមាណ ១ យោជន៍ តាំងនៅសព្វកាល ព្រះជន្មាយុ ១ សែនឆ្នាំ ដូច្នេះ ។*

តត្ថេវ មណ្ឌកប្បម្ហិ អត្ថទស្សី មហាយសោ
មហាតមំ និហន្ត្វាន បត្តោ សម្ពោធិមុត្តមំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី
មានយសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោ-
ធិញ្ញាណដ៏ឧត្តម ។

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្តា ទ្រង់ព្រះនាមធម្មទស្សី ទ្រង់កើតឡើងហើយក្នុងលោក សូម្បីសាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ ពាន់កោដិ លើកទី ២ មានភិក្ខុ ១០០ កោដិ លើកទី ៣ មានភិក្ខុ ៨០កោដិ ។

ក្នុងកាលនោះ ព្រះមហាសត្វនៃយើងជាសក្កទេវរាជ បានធ្វើការបូជាព្រះទសពលដោយផ្កាដែលមានក្លិនដ៏ជាទិព្វ និងគ្រឿងតូរ្យតន្ត្រីដ៏ជាទិព្វ ឯព្រះបរមសាស្តា ទ្រង់ក៏ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ។

ឯនគររបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា សរណៈ ព្រះរាជា ទ្រង់ព្រះនាមថា សរណៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុនន្ទា ។ អគ្គសាវក ព្រះនាមថា បទុមៈ ១ ព្រះនាមថា បុស្សទេវៈ ១ ឧបដ្ឋាក ព្រះនាមថា សុទត្ត ។ អគ្គសាវិកា ព្រះនាមថាខេមា ១ ព្រះនាមថា សច្ចនាមា ១ ដើមតិម្ពជាលព្រឹក្ស ( ដើមទន្ទាប់ ) ជាឈើត្រាស់ដឹង ឯព្រះសរីរៈរបស់ព្រះអង្គមានកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុបាន ១ សែនឆ្នាំ ដូច្នេះ ។

តត្ថេវ មណ្ឌកប្បម្ហិ ធម្មទស្សី មហាយសោ
តមន្ធការំ វិធមិត្វា អតិរោចតិ សទេវកេ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធ ព្រះនាមធម្មទស្សី មាន យសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញុំាងមនុស្ស-លោក ព្រមទាំងទេវលោក ឲ្យរុងរឿង ។

ខាងក្រោយអំពីព្រះបរមសាស្ដាអង្គនេះ ក្នុងកប្ប ១ គឺ ក្នុងកប្បទី ៩៤ រាប់ថយអំពីកប្បនេះ មានព្រះពុទ្ធ ១ ព្រះអង្គ ទ្រង់ព្រះនាមថា សិទ្ធត្ថៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុង សន្និបាតទាំង ៣ លើកនោះ លើកទី ១ មានភិក្ខុ ១០០ កោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

ក្នុងកាលនោះ ព្រះមហាសត្វនៃយើងជាតាបសព្រះនាមថា មង្គលៈ មានតេជះខ្លាំងក្លា សម្បូរដោយអភិញ្ញាពលៈ បាននាំផ្លែព្រីងធំ មកថ្វាយ ដល់ព្រះតថាគត ព្រះសាស្ដាសោយផ្លែឈើនោះហើយ ទ្រង់ព្យាករព្រះ ពោធិសត្វថា ក្នុងទីបំផុតនៃកប្បទី ៩៤ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា វេភារៈ ព្រះ រាជា ទ្រង់ព្រះនាមថា ឧទេនៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សុផស្សា ។ ព្រះអគ្គសាវ័ក ព្រះនាមថា សម្ពលៈ ១ ព្រះនាមថា សុមិត្តៈ ១ ឧបដ្ឋាក ព្រះនាមថា រេវតៈ ។ ព្រះអគ្គសាវិកា ព្រះនាមថា សីវលា ១

ព្រះនាមថា សុភមា ១ កណ្ណិការព្រឹក្ស ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គ កម្ពស់ ៦០ ហត្ថ ព្រះជន្មាយុបាន ១ សែនឆ្នាំ ដូច្នេះ ។

ធម្មទស្សិស្ស អបរេន សិទ្ធត្ថោ លោកនាយកោ
និហន្ត្វាន តមំ សព្វំ សុរិយោ អព្ភុគ្គតោ យថា ។

ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាមសិទ្ធត្ថៈ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង ។

ខាងក្រោយអំពីព្រះមានព្រះភាគអង្គនេះ រាប់ថយក្រោយអំពីកប្បនេះទៅ ៩២ កប្ប មានព្រះពុទ្ធទ្រង់កើតឡើង ២ ព្រះអង្គ ក្នុងកប្បតែមួយ គឺ ព្រះនាមថា តិស្សៈ ១ ព្រះអង្គ ព្រះនាមថា បុស្សៈ ១ ព្រះអង្គ ។ សម្រាប់ព្រះមានព្រះភាគទ្រង់ព្រះនាមថា តិស្សៈ មានសាវកសន្និបាត ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែនអង្គ លើកទី ២ មានភិក្ខុ ៩០ សែនអង្គ លើកទី ៣ មានភិក្ខុ ៨០ សែនអង្គ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាក្សត្រ មានភោគសម្បត្តិច្រើន មានយសធំ ព្រះនាមថា សុជាតៈ ទ្រង់សាងព្រះផ្នួសជាឥសីដល់នូវភាពជាអ្នកមានឫទ្ធិច្រើន បានឮដំណឹងថា ព្រះពុទ្ធទ្រង់កើតឡើងហើយ កាន់យកផ្កាមន្ទារវបុស្ស ផ្កាឈូកក្រហម និងផ្កាបារិច្ឆត្តកៈដែលជាទិព្វ មកបូជាព្រះសាស្តាដែលគង់ប្រថាប់ត្រង់កណ្តាលបរិស័ទ ៤ បានធ្វើពិដានផ្កាឈើទុកក្នុងអាកាស ។ ព្រះតថាគតអង្គនោះ ក៏ទ្រង់ព្យាករព្រះ

ពោធិសត្វថា ក្នុងកប្បទី ៩២ បន្ទាប់អំពីនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា ខេមកៈ ក្សត្រ ព្រះនាមថា ជនសន្ធៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា បទុមា ។ អគ្គសាវ័ក ព្រះនាមថា ព្រហ្មទេវៈ ១ ព្រះនាមថា ឧទយៈ ១ ឧបដ្ឋាក ព្រះនាមថា សមគៈ ។ អគ្គសាវិកា ព្រះនាមថា ផុស្សា ១ ព្រះនាមថា សុទត្តា ១ អសនព្រឹក្ស ( ដើមធ្នង់ ) ជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុបាន ១ សែនឆ្នាំ ដូច្នេះ ។

សិទ្ធត្ថស្ស អបរេន អសមោ អប្បដិបុគ្គលោ
អនន្តសីលោ អមិតយសោ តិស្សោ លោកគ្គនាយកោ ។

ក្រោយពីព្រះពុទ្ធ ព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធ ព្រះនាម តិស្សៈ ជានាយកដ៏ប្រសើរ ក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មានយសរាប់ពុំបាន ។

ខាងក្រោយអំពីព្រះដ៏មានព្រះភាគអង្គនេះ ព្រះបរមសាស្តា ទ្រង់ព្រះនាមថា បុស្សៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៦០ សែនអង្គ លើកទី ២ មានភិក្ខុ ៥០ សែនអង្គ លើកទី ៣ មានភិក្ខុ ៤០ សែនអង្គ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាក្សត្រ ព្រះនាមថា

វិជិតៈ ទ្រង់លះរាជសម្បត្តិធំ ហើយបួសក្នុងសម្នាក់របស់ព្រះសាស្ដា រៀន ព្រះត្រៃបិដកហើយ ទ្រង់សម្ដែងធម្មកថាដល់មហាជន ទ្រង់បំពេញសីល-បារមី សូម្បីព្រះពុទ្ធបុស្សៈ ក៏ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកាលជាអនាគត ។

ឯនគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា កាសិកៈ ព្រះរាជា ព្រះនាមថា ជយសេន ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា សិរិមា ។ អគ្គសាវ័ក ព្រះនាមថា សុរក្ខិតៈ ១ ព្រះនាមថា ធម្មសេនៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា សភិយ្យៈ ។ អគ្គសាវិកា ព្រះនាមថា ចាលា ១ ព្រះនាមថា ឧបចាលា ១ អាមលកព្រឹក្ស ( ដើមកន្ទួតព្រៃ ) ជាឈើត្រាស់ដឹង ព្រះសរីរៈមានកម្ពស់ ៥៨ ហត្ថ ព្រះជន្មាយុបាន ៩ ម៉ឺនឆ្នាំ ដូច្នេះ ។

**តត្ថេវ មណ្ឌកប្បម្ហិ អាហុ សត្ថា អនុត្តរោ**
**អនុបមោ អសមសមោ បុស្សោ លោកគ្គនាយកោ ។**

ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្ដា ព្រះនាមបុស្សៈ ទ្រង់
មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន
ស្មើដោយព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ជានាយកប្រសើរ
ក្នុងលោក ។

ខាងក្រោយអំពីព្រះសម្ពុទ្ធអង្គនេះ ក្នុងកប្បទី ៩១ រាប់ថយក្រោយ អំពីកប្បនេះ ព្រះមានព្រះភាគព្រះនាមថា វិបស្សី ទ្រង់កើតឡើងហើយ

សាវកសន្និបាតរបស់ព្រះអង្គក៏មាន ៣ លើក ។ ក្នុងសន្និបាតលើក ទី ១ មានភិក្ខុ ៦៨ សែនអង្គ ក្នុងលើកទី ២ មានភិក្ខុ ១ សែនអង្គ ក្នុងលើកទី ៣ មានភិក្ខុ ៨ ម៉ឺនអង្គ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាស្តេចនាគ ឈ្មោះថា អតុលៈ មានឫទ្ធិច្រើន មានអានុភាពច្រើន បានថ្វាយតាំងធំធ្វើដោយមាសរំលេចដោយកែវ ៧ ប្រការដល់ព្រះមានព្រះភាគ ព្រះអង្គក៏ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងកប្បទី ៩១ អំពីកប្បនេះ នាគនេះនឹងបានត្រាស់ជាព្រះពុទ្ធ ។

ឯនគររបស់ព្រះបរមសាស្ដាអង្គនោះ ឈ្មោះថា ពន្ធុមតី ព្រះរាជាព្រះនាមថា ពន្ធុមៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា ពន្ធុមតី ។ អគ្គសាវក ព្រះនាមថា ខន្ធៈ ១ ព្រះនាមថា តិស្សៈ ១ ពុទ្ធុបដ្ឋាកៈ ព្រះនាមថា អសោក ។ អគ្គសាវិកា ព្រះនាមថា ចន្ទា ១ ព្រះនាមថា ចន្ទមិត្តា ១ ដើមបាដលិព្រឹក្ស ( ដើមប្រនៀង ) ជាឈើត្រាស់ដឹង ព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៨០ ហត្ថ ព្រះរស្មីផ្សាយចេញអំពីព្រះសរីរៈប្រមាណ ៧ យោជន៍ ព្រះជន្មាយុបាន ៨ ម៉ឺនឆ្នាំ ដូច្នេះ ។

**ផុស្សស្ស[១] អបរេន សម្ពុទ្ធោ ទិបទុត្តមោ**

១- ច្បាប់ឆដ្ឋសង្គាយនាជា ផុស្សស្ស ច អបរេន ។

**វិបស្សី ជាម ជាមេជ លោកេ ឧប្បជ្ជិ ចក្ខុមា ។**

*ក្រោយអំពីព្រះពុទ្ធ ព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធ ព្រះនាមវិបស្សី ដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុ កើតឡើង ក្នុងលោក ។*

*ខាងក្រោយអំពីព្រះបរមសាស្តាអង្គនេះ ក្នុងកប្បទី ៣១ រាប់ថយក្រោយអំពីកប្បនេះ មានព្រះពុទ្ធពីរព្រះអង្គ គឺ ព្រះសិខីនិងព្រះវេស្សភូ ទ្រង់កើតឡើងហើយ ។ សាវកសន្និបាតរបស់ព្រះសិខីសម្ពុទ្ធ ក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ១ សែន លើកទី ២ មានភិក្ខុ ៨ ម៉ឺន លើកទី ៣ មានភិក្ខុ ៧ ម៉ឺន ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាព្រះរាជា ព្រះនាមថា អរិន្ទមៈ បានថ្វាយមហាទានមួយអន្លើដោយចីវរដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយដំរីកែវដែលតាក់តែងដោយកែវ ៧ ប្រការ ថ្វាយកប្បិយភ័ណ្ឌធ្វើឲ្យមានទំហំប៉ុនខ្លួនដំរី ។ ឯព្រះមានព្រះភាគក៏បានព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងកប្បទី ៣១ បន្ទាប់អំពីកប្បនេះ ។*

*ឯនគររបស់ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា អរុណវតី ក្សត្រព្រះនាមថា អរុណៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា បភាវតី ។ អគ្គសាវក ព្រះនាមថា អភិភូ ១ ព្រះនាមថា សម្ភវៈ ១ ឧបដ្ឋាកព្រះនាម*

ថា ខេមង្ករៈ ។ អគ្គសាវិកា ព្រះនាមថា មខិលា ១ ព្រះនាមថា បទុមា ១ បុណ្ឌរីកព្រឹក្ស ( ដើមស្វាយស ) ជាឈើត្រាស់ដឹង ។ ឯព្រះសរីរៈរបស់ព្រះអង្គមានកម្ពស់ ៧០ ហត្ថ ព្រះរស្មីចេញអំពីព្រះវរកាយផ្សាយទៅ ៣ យោជន៍ ព្រះជន្មាយុបាន ៧ ម៉ឺនឆ្នាំ ដូច្នេះ ។

វិបស្សិស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
សិខិវ្ហយោ អាសិ ជិនោ អសមោ អប្បដិបុគ្គលោ ។

ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹមបាន ។

ខាងក្រោយអំពីព្រះមានព្រះភាគអង្គនេះ ព្រះសាស្ដា ព្រះនាមថា វេស្សភូ ទ្រង់កើតឡើងហើយ សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មាន ៣ លើក ។ ក្នុងសន្និបាតលើកទី ១ មានភិក្ខុ ៨០ ពាន់កោដិ លើកទី ២ មានភិក្ខុ ៧០ ពាន់កោដិ លើកទី ៣ មានភិក្ខុ ៦០ ពាន់កោដិ [១] ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាព្រះរាជា ព្រះនាមថា សុទស្សនៈ បានថ្វាយមហាទានមួយអន្លើដោយចីវរ ដល់ព្រះសង្ឃមាន

---

១-ច្បាប់ឆដ្ឋសង្គាយនា និងច្បាប់មហាចុឡា មិនមានពាក្យថាកោដិនេះទេ មានត្រឹមតែ ៨០ ពាន់ ៧០ពាន់ ៦០ ពាន់ប៉ុណ្ណោះ ។

ព្រះពុទ្ធជាប្រធាន ហើយទ្រង់បួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ ជាអ្នកសម្បូរដោយអាចារគុណ ច្រើនទៅដោយការកោតក្រែងនិងបីតិក្នុងព្រះពុទ្ធរតនៈ ព្រះសាស្តាក៏ទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងកប្បទី ៣១ បន្ទាប់អំពីកប្បនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

ឯនគររបស់ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា អនោមៈ ព្រះរាជា ព្រះនាមថា សុប្បតិតៈ ជាព្រះរាជបិតា ព្រះរាជមាតា ព្រះនាមថា យសវតី ។ អគ្គសាវក ព្រះនាមថា សោណៈ ១ ព្រះនាមថា ឧត្តរៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា ឧបសន្តៈ ។ អគ្គសាវិកា ព្រះនាមថា រាមា ១ ព្រះនាមថា សមានា ១ មហាសាលព្រឹក្សជាឈើត្រាស់ដឹង ឯព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៦០ ហត្ថ ព្រះជន្មាយុបាន ៦ ម៉ឺនឆ្នាំ ដូច្នេះ ។

**តត្ថេវ មណ្ឌកប្បម្ហិ អសមោ អប្បដិបុគ្គលោ**
**វេស្សភូ នាម នាមេន លោកេ ឧប្បជ្ជិ សោ ជិនោ ។**

ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រី ព្រះនាមវេស្សភូ ព្រះអង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់កើតឡើងក្នុងលោក ។

ខាងក្រោយអំពីព្រះមានព្រះភាគអង្គនេះ ក្នុងកប្បនេះ មានព្រះពុទ្ធកើតឡើង ៤ ព្រះអង្គ គឺ ព្រះកកុសន្ធៈ ១ ព្រះអង្គ ព្រះកោនាគមនៈ ១ ព្រះអង្គ ព្រះកស្សបៈ ១ ព្រះអង្គ និងព្រះដ៏មានព្រះភាគនៃយើង ១

ព្រះអង្គ ។ សម្រាប់ព្រះមានព្រះភាគ ព្រះនាមថា កកុសន្ធៈ មានសាវកសន្និបាតតែម្តង ក្នុងសាវកសន្និបាតនោះ មានភិក្ខុ ៤ ម៉ឺនអង្គ ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាព្រះរាជា ព្រះនាមថា ខេមៈ បានថ្វាយមហាទានមួយអន្លើដោយចីវរនិងភេសជ្ជៈ មានថ្នាំបន្តក់ភ្នែកជាដើម ដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ទ្រង់ក៏បួស ព្រះទសពលអង្គនោះ ក៏ទ្រង់ព្យាករព្រះពោធិសត្វហើយ ។

ឯនគររបស់ព្រះដ៏មានព្រះភាគ ព្រះនាមថា កកុសន្ធៈ នោះ ឈ្មោះថា ខេមៈ ព្រាហ្មណ៍ឈ្មោះថា អគ្គិទត្តៈ ជាព្រះបិតា ព្រាហ្មណីឈ្មោះថា វិសាខា ជាព្រះមាតា ។ អគ្គសាវក ព្រះនាមថា វិធុរៈ ១ ព្រះនាមថា សញ្ជីវៈ ១ ឧបដ្ឋាកៈរបស់ព្រះអង្គ ព្រះនាមថា ពុទ្ធិជៈ ។ អគ្គសាវិកា ព្រះនាមថា សាមា ១ ព្រះនាមថា ចម្បា ១ សិរិសព្រឹក្ស ( ដើមច្រេស ) ជាឈើត្រាស់ដឹង ។ ព្រះសរីរៈរបស់ព្រះអង្គកម្ពស់ ៤០ ហត្ថ ព្រះជន្មាយុបាន ៤ ម៉ឺនឆ្នាំ ដូច្នេះ ។

**វេស្សភុស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ**
**កកុសន្ធោ នាម នាមេន អប្បមេយ្យោ ទុរាសទោ ។**

ក្នុងកាលជាក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធ ព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មានគុណ

រាប់មិនបាន គេគ្រប់សង្កត់បានដោយកម្រ ។

ខាងក្រោយអំពីព្រះលោកនាយកអង្គនេះ ព្រះបរមសាស្ដា ទ្រង់ព្រះនាមថា កោនាគមនៈ ទ្រង់កើតឡើងហើយ សូម្បីសាវកសន្និបាតរបស់ព្រះអង្គ ក៏មានតែមួយដងប៉ុណ្ណោះ ក្នុងសាវកសន្និបាតនោះ មានភិក្ខុ ៣ ម៉ឺនរូប ។

ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងជាព្រះរាជា ទ្រង់ព្រះនាមថា បព្វតៈ មានពួកអាមាត្យចោមរោម យាងទៅកាន់សម្នាក់របស់ព្រះបរមសាស្ដា ស្ដាប់ព្រះធម្មទេសនាហើយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានហើយ ។ ព្រះពោធិសត្វបានថ្វាយវត្ថុ ៤ មុខ គឺ សំពត់ចិនប្រទេស ១ សំពត់សូត្រ ១ សំពត់កម្ពល ១ និងស្បែកជើងមាស ១ ចំពោះព្រះសាស្ដា ព្រមទាំងសាវ័ក ហើយទ្រង់បួសក្នុងសម្នាក់របស់ព្រះបរមសាស្ដា ព្រះអង្គក៏ទ្រង់ព្យាករព្រះពោធិសត្វហើយ ។

ឯនគររបស់ព្រះមហាមុនីអង្គនោះ ឈ្មោះថា សោភវតី ព្រាហ្មណ៍ឈ្មោះថា យញ្ញទត្ត ជាព្រះបិតា ព្រាហ្មណីឈ្មោះថា ឧត្តរា ជាព្រះមាតា ។ អគ្គសាវ័ក ព្រះនាមថា ភិយ្យោសៈ ១ ព្រះនាមថា ឧត្តរៈ ១ ពុទ្ធុបដ្ឋាក ព្រះនាមថា សោត្ថិជៈ ។ អគ្គសាវិកា ព្រះនាមថា សមុទ្ទា ១ ព្រះនាមថា ឧត្តរា ១ ឧទុម្ពរព្រឹក្ស ( ដើមល្វា ) ជាឈើត្រាស់ដឹង ឯព្រះសរីរៈរបស់ព្រះអង្គ មានកម្ពស់ ៣០ ហត្ថ ព្រះជន្មាយុបាន ៣ ម៉ឺនឆ្នាំ ដូច្នេះ ។

កកុសន្ធស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ
កោនាគមនោ នាម ជិនោ លោកជេដ្ឋោ នរាសភោ ។

*កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រី សម្ពុទ្ធ ព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ។*

*ខាងក្រោយអំពីព្រះមានព្រះភាគអង្គនេះ ព្រះបរមសាស្តា ទ្រង់ព្រះនាមថា កស្សបៈ ទ្រង់កើតឡើងហើយ សាវកសន្និបាតរបស់ព្រះអង្គក៏មានតែមួយដងប៉ុណ្ណោះ ក្នុងសន្និបាតនោះ មានភិក្ខុ ២ ម៉ឺនអង្គ ។*

*ក្នុងកាលនោះ ព្រះបរមពោធិសត្វនៃយើងកើតជាមាណពឈ្មោះថា ជោតិបាលៈ រៀនចប់ត្រៃវេទ ជាអ្នកមានកេរ្តិ៍ឈ្មោះលើផែនដី និងលើអាកាស បានជាមិត្តរបស់ស្មូនឆ្នាំងឈ្មោះ ឃដិការ ។ ព្រះពោធិសត្វមួយអន្លើដោយស្មូនឆ្នាំងនោះ ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម្មកថាហើយបួស បំពេញសេចក្តីព្យាយាម រៀនព្រះត្រៃបិដកជាអ្នករុងរឿងក្នុងព្រះពុទ្ធសាសនា ព្រោះដល់ព្រមដោយវត្តបដិបត្តិ ព្រះបរមសាស្តា ក៏ទ្រង់ព្យាករព្រះពោធិសត្វទុកហើយ ។*

*ឯនគរដែលជាទីប្រសូតិរបស់ព្រះដ៏មានព្រះភាគអង្គនោះ ឈ្មោះថា ពារាណសី ព្រាហ្មណ៍ឈ្មោះថា ព្រហ្មទត្ត ជាព្រះបិតា ព្រាហ្មណីឈ្មោះថា ធនវតី ជាព្រះមាតា ។ អគ្គសាវ័ក ព្រះនាមថា តិស្សៈ ១*

ព្រះនាមថា ភារទ្វាជៈ ១ ឧបដ្ឋាកព្រះនាមថា សព្វមិត្ត ។ អគ្គសាវិកា ព្រះនាមថា អនុលា ១ ព្រះនាមថា ឧរុវេលា ១ ដើមនិគ្រោធព្រឹក្ស ( ដើមជ្រៃ ) ជាឈើត្រាស់ដឹង ។ ព្រះសរីរៈរបស់ព្រះអង្គមានកម្ពស់ ២០ ហត្ថ ព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ដូច្នេះ ។

**កោណាគមនស្ស អបរេន សម្ពុទ្ធោ ទិបទុត្តមោ**
**កស្សបោ នាម នាមេន ធម្មរាជា បភង្ករោ ។**

កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនៈមក
មានព្រះសម្ពុទ្ធ ព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ
ជាធម្មរាជ ទ្រង់ធ្វើពន្លឺ ។

ក្នុងកប្បដែលព្រះទសពលទីបង្ករ ទ្រង់កើតឡើង សូម្បីមានព្រះពុទ្ធដល់ទៅ ៣ ព្រះអង្គ ( កើតរួមជាមួយព្រះអង្គ ) ព្រះពោធិសត្វមិនបានទទួលការព្យាករណ៍ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងនោះ ព្រោះដូច្នោះទើបព្រះពុទ្ធទាំងនោះ មិនបានសម្ដែងទុកក្នុងទីនេះ ប៉ុន្តែក្នុងអដ្ឋកថាដើម្បីសម្ដែងព្រះពុទ្ធទាំងអស់ ចាប់តាំងអំពីកប្បនោះ ទើបលោកពោលពាក្យជាដើមថា

ព្រះសម្មាសម្ពុទ្ធទាំងនេះ គឺ ព្រះតណ្ហង្ករៈ ព្រះមេធង្ករៈ
ព្រះសរណង្ករៈ ព្រះទីបង្ករសម្ពុទ្ធ ព្រះកោណ្ឌញ្ញៈដ៏ឧត្តម
ជាងនរៈ ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ

*ដ៏ជាមុនី ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សីទ្រង់មានយសធំ ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថៈដ៏ជាលោកនាយក ព្រះតិស្សៈ ព្រះបុស្សៈដ៏ជាសម្ពុទ្ធ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះលោកនាយកកស្សបៈ សុទ្ធតែទ្រង់មានរាគៈទៅប្រាសហើយ មានព្រះហឫទ័យតាំងមាំ ទ្រង់កម្ចាត់ងងឹតយ៉ាងធំបាន ដូចព្រះអាទិត្យរះឡើងហើយ រុងរឿងដូចគំនរភ្លើងទ្រង់បរិនិព្វានហើយ មួយអន្លើដោយសាវ័ក ដូច្នេះ ។*

*ក្នុងរឿងនោះ ព្រះពោធិសត្វនៃយើងសាងគុណ គឺសេចក្តីល្អ ក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ ព្រះអង្គ មានព្រះពុទ្ធទីបង្ករជាដើម រហូតអស់ ៤ អសង្ខេយ្យនិង ១ សែនកប្ប ។ បន្ទាប់អំពីព្រះមានព្រះភាគ ទ្រង់ព្រះនាមថា កស្សបៈ វៀរព្រះសម្មាសម្ពុទ្ធអង្គនេះ មិនមានព្រះសម្ពុទ្ធអង្គដទៃព្យាករព្រះពោធិសត្វទៀតឡើយ ។ ព្រះពោធិសត្វបានទទួលពាក្យព្យាករក្នុងសម្នាក់របស់ព្រះមានព្រះភាគ ២៤ អង្គ មានព្រះពុទ្ធទីបង្ករជាដើម ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា*

មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំ
បព្វជ្ជា គុណសម្បត្តិ អធិការោ ច ឆន្ទតា

**អដ្ឋធម្មសមោធានា អភិនីហារោ សមិជ្ឈតីតិ ។**

*ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ភាពដែលសម្បូរដោយភេទ ដោយហេតុ ការបានជួបព្រះសាស្តា ការបានទូវបព្វជ្ជា ការដល់ព្រមដោយគុណ ការធ្វើវត្ថុក្រៃលែងធំ ការពេញចិត្ត ការប្រាថ្នាតាំងចិត្តពិត រមែងសម្រេចបាន ។*

*ព្រះមហាសត្វ ទ្រង់បានធ្វើសេចក្តីប្រាថ្នាតាំងចិត្តទុកទៀបបាទមូលរបស់ព្រះសម្ពុទ្ធព្រះនាមទីបង្ករ សមោធានធម៌ទាំងឡាយ ៨ ប្រការ មកហើយ ធ្វើឧស្សាហៈថា* ***ណ្ហើយចុះ អញនឹងជ្រើសរើសធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ អំពីទីនោះខ្លះ អំពីទីនេះខ្លះ*** *បានឃើញពុទ្ធការកធម៌មានទានជាដើម ទើបពោលថា* ***ក្នុងកាលដែលតថាគតកំពុងជ្រើសរើសក៏បានឃើញទានបារមីជាខាងដើម*** *ដូច្នេះ ។*

*ព្រះបរមពោធិសត្វបំពេញធម៌ទាំងនោះមក ដរាបដល់អត្តភាពជាព្រះវេស្សន្តរ ។ កាល ( ធម៌ទាំងនោះ ) មកដល់ ក៏បានសម្រេចអានិសង្សសម្រាប់ព្រះពោធិសត្វដែលបានធ្វើសេចក្តីប្រាថ្នាតាំងចិត្តទុក ដូចពណ៌នាមកយ៉ាងច្រើនថា*

*នរជនដែលសម្បូណ៌ដោយអង្គនៃគុណគ្រប់ប្រការ ជាបុគ្គល*
*ទៀងចំពោះពោធិញ្ញាណ អស់សង្សារ មានកាលដ៏វែងឆ្ងាយ*
*រាប់ដោយរយកោដិកប្ប មិនកើតក្នុងអវិចីនរក មិនកើតក្នុង*

លោកន្តរនរក កាលកើតក្នុងទុគ្គតិ ក៏មិនកើតជានិជ្ឈាមតណ្ហិក-ប្រេត ខុប្បិបាសកប្រេត កាឡកញ្ជិកាសុរ និងមិនកើតជាសត្វតូចៗ កាលកើតក្នុងមនុស្សក៏មិនកើតជាមនុស្សខ្វាក់អំពីកំណើត មិនជាមនុស្សថ្លង់អំពីកំណើត មិនជាមនុស្សគ មិនកើតជាស្រី មិនកើតជាឧភតោព្យញ្ជនកៈ គឺមនុស្សមានភេទពីរ មិនកើតជាខ្ទើយ នរជនដែលទៀងចំពោះពោធិញ្ញាណ មិនមានចិត្តជាប់ចំពាក់ក្នុងវត្ថុណាមួយឡើយ ផុតចាកអន្តរិយកម្ម ៥ ជាបុគ្គលមានគោចរស្អាតក្នុងទីទាំងពួង មិនសេពមិច្ឆាទិដ្ឋិ ព្រោះឃើញផលក្នុងការធ្វើកម្ម សូម្បីកើតក្នុងឋានសួគ៌ទាំងឡាយ ក៏មិនកើតក្នុងអសញ្ញីសត្វ ក្នុងពួកសត្វដែលនៅក្នុងសុទ្ធាវាស ក៏មិនមានហេតុទៅកើត ជាសប្បុរស បង្អោនចិត្តទៅក្នុងនេក្ខម្មៈ ដោះនូវភពតូច ភពធំចេញ ប្រព្រឹត្តតែប្រយោជន៍ដល់សត្វលោក បំណងបំពេញបារមីគ្រប់ប្រការ ត្រាច់ទៅ ដូច្នេះ ។

ព្រះមហាបុរស កាលទ្រង់បំពេញបារមីនោះ អត្តភាពដែលបំពេញទានបារមី គឺក្នុងកាលជាព្រាហ្មណ៍ឈ្មោះ អកិត្តិ ក្នុងកាលជាព្រាហ្មណ៍ឈ្មោះសង្ខៈ ក្នុងកាលជាព្រះរាជា ព្រះនាមថា ធនញ្ជយៈ ក្នុងកាលជាព្រះបាទមហាសុទស្សនៈ ក្នុងកាលជាមហាគោវិន្ទ ក្នុងកាលជាព្រះបាទនេមិមហារាជ ក្នុងកាលជាចន្ទកុមារ ក្នុងកាលជាវិសយ្ហសេដ្ឋី ក្នុងកាល

ជាព្រះបាទសិវិរាជ ក្នុងកាលជាព្រះវេស្សន្តរ ហួសនឹងរាប់បាន តែទាន-
បារមីរបស់ព្រះពោធិសត្វដែលធ្វើការបរិច្ចាគខ្លួនក្នុង **សសបណ្ឌិតជាតក**
យ៉ាងនេះថា

**ភិក្ខាយ ឧបគតំ ទិស្វា សកត្តានំ បរិច្ចជឹ**
**ទានេន មេ សមោ នត្ថិ ឯសា មេ ទានបារមីតិ ។**

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួន
ជារបស់ខ្លួន បុគ្គលអ្នកឲ្យទាន ស្មើដោយទានរបស់តថាគត
មិនមានឡើយ នេះជាទានបារមី របស់តថាគត [១] ដូច្នេះ ។
នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។

ដូចគ្នានោះដែរ ក្នុងអត្តភាពដែលទ្រង់បំពេញនូវសីលបារមី គឺក្នុង
កាលជាសីលវនាគរាជ [២] ក្នុងកាលដែលជាចម្បេយ្យនាគរាជ ក្នុងកាល
ដែលជាភូរិទត្តនាគរាជ ក្នុងកាលដែលជាស្តេចដំរីឈ្មោះឆទ្ទន្ត ក្នុងកាល
ដែលជាជយទិសរាជបុត្ត ក្នុងកាលដែលជាអលីនសត្តុកុមារ ដ៏សេសហួស
នឹងរាប់បាន តែសីលបារមីរបស់ព្រះពោធិសត្វ ដែលធ្វើការបរិច្ចាគខ្លួន
ក្នុង **សង្ខបាលជាតក** យ៉ាងនេះថា

**សូលេហិ វិជ្ឈយន្តេបិ កោដ្ដយន្តេបិ សត្តិភិ**

---

១-បិ.៧៧ , ទំ.២៦៧ ។ ២ - ស្តេចដំរីមានសីល ក្នុងសីលវនាគជាតក ឯកនិបាត ។

**កោជបុត្តេ ន កុប្បាមិ ឯសា មេ សីលបារមីតិ ។**

(ប៉ុន្តែ) តថាគត មិនខឹងនឹងកូនព្រានព្រៃទាំងឡាយ ដែលចោះដោយដែកស្រួច និងចាក់ដោយលំពែងទាំងឡាយឡើយ នេះជាសីលបារមីរបស់តថាគត [១] ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។

ដូចគ្នានេះដែរ អត្តភាពដែលព្រះពោធិសត្វលះរាជសម្បត្តិយ៉ាងធំ បំពេញនេក្ខម្មបារមី គឺក្នុងកាលដែលជាសោមនស្សកុមារ ក្នុងកាលដែលជាហត្ថិបាលកុមារ ក្នុងកាលដែលជាអយោឃរបណ្ឌិត ដ៏សេសហួសនឹងរាប់បាន តែនេក្ខម្មបារមីរបស់ព្រះពោធិសត្វដែលលះរាជសម្បត្តិចេញបួស ព្រោះប្រាសចាកគ្រឿងជាប់ចំពាក់ក្នុង **ចុល្លសុតសោមជាតក** យ៉ាងនេះថា

**មហារជ្ជំ ហត្ថគតំ ខេឡបិណ្ឌំវ ឆឌ្ឌយឹ**
**ចជតោ ន ហោតិ លគ្គំ ឯសា មេ នេក្ខម្មបារមីតិ ។**

តថាគតលះបង់រាជសម្បត្តិយ៉ាងធំ ដែលមាននៅក្នុងកណ្តាប់ដៃ ដូចជាដុំទឹកមាត់ កាលតថាគតលះហើយមិនមានការជាប់ចំពាក់ឡើយ នេះជានេក្ខម្មបារមីរបស់តថាគត ដូច្នេះ ។ នេះ

---

១-បិ.៧៧ , ទំ. ២៨៣ ។

ចាត់ជាបរមត្ថបារមីដោយពិតប្រាកដ ។

ដូចគ្នានោះដែរ ក្នុងអត្តភាពដែលទ្រង់បំពេញបញ្ញាបារមី គឺក្នុងកាលដែលជាវិធូរបណ្ឌិត ក្នុងកាលដែលជាមហាគោវិន្ទបណ្ឌិត ក្នុងកាលដែលជាកុទ្ទាលបណ្ឌិត ក្នុងកាលដែលជាអរកបណ្ឌិត ក្នុងកាលដែលជាពោធិបរិព្វាជក ក្នុងកាលដែលជាមហោសធបណ្ឌិត ក្នុងកាលដ៏សេសរាប់មិនបាន តែបញ្ញាបារមីរបស់ព្រះបរមពោធិសត្វបង្ហាញពស់ ដែលនៅខាងក្នុងថង់ ក្នុងកាលដែលជាសេនកបណ្ឌិត ក្នុង **សត្តុភត្តជាតក** យ៉ាងនេះថា

**បញ្ញាយ វិចិនន្តោហំ ព្រាហ្មណំ មោចយឹ ទុខា**
**បញ្ញាយ មេ សមោ នត្ថិ ឯសា មេ បញ្ញាបារមីតិ ។**

តថាគតកាលពិចារណាដោយបញ្ញា ដោះនូវព្រាហ្មណ៍ ឲ្យផុតចាកទុក្ខបាន បុគ្គលដែលស្មើដោយបញ្ញារបស់តថាគតមិនមាន នេះជាបញ្ញាបារមីរបស់តថាគត ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។

ដូចគ្នានោះដែរ ក្នុងអត្តភាពដែលទ្រង់បំពេញវីរិយបារមីជាដើមដ៏សេសហួសនឹងរាប់ តែវីរិយបារមីរបស់ព្រះបរមពោធិសត្វ ដែលឆ្លងមហាសមុទ្រក្នុង **មហាជនកជាតក** យ៉ាងនេះថា

**អតីរទស្សី ជលមជ្ឈេ ហតា សព្វេវ មានុសា**

**ចិត្តស្ស អញ្ញថា នត្ថិ ឯសា មេវីរិយបារមីតិ ។**

*ក្នុងកណ្ដាលទឹក តថាគតមើលមិនឃើញត្រើយ ពួកមនុស្ស ត្រូវស្លាប់អស់ ភាពជាដទៃនៃចិត្តមិនមានឡើយ នេះជាវីរិយ-បារមីរបស់តថាគត ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។*

*ខន្តិបារមីរបស់ព្រះពោធិសត្វ ដែលអត់សង្កត់នូវទុក្ខដ៏ខ្លាំងក្លា ដូចជាបុគ្គលមិនមានចិត្តក្នុង* **ខន្តិវាទិជាតក** *យ៉ាងនេះថា*

**អចេតនំវ កោដ្ដេន្តេ តិណ្ហេន ផរសុនា មមំ**
**កាសិរាជេ ន កុប្បាមិ ឯសា មេ ខន្តិបារមីតិ ។**

*តថាគត មិនក្រោធក្នុងព្រះបាទកាសិករាជ ដែលកាប់តថាគត ដូចជាបុគ្គលមិនមានចិត្ត ដោយប៉ូវថៅដ៏មុត នេះជាខន្តិបារមីរបស់តថាគត ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។*

*សច្ចបារមីរបស់ព្រះពោធិសត្វដែលលះបង់ជីវិត តាមរក្សាសច្ចធម៌ក្នុង* **មហាសុតសោមជាតក** *យ៉ាងនេះថា*

**សច្ចវាចំ អនុរក្ខន្តោ ចជិត្វា មម ជីវិតំ**
**មោចេសឹ ឯកសតំ ខត្តិយេ ឯសា មេ សច្ចបារមីតិ ។**

*កាលតថាគត តាមរក្សានូវសច្ចវាចា លះបង់ជីវិតរបស់តថាគត ដោះក្សត្រ ទាំង ១០១ អង្គបានហើយ នេះជាសច្ចបារមីរបស់*

*តថាគត ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។*

*អធិដ្ឋានបារមីរបស់ព្រះពោធិសត្វដែលសុខចិត្តលះជីវិត អធិដ្ឋានវត្តក្នុង* **មូគផក្ខជាតក** [១] *យ៉ាងនេះថា*

**មាតា បិតា ន មេ ទេស្សា អត្តា មេ ន ច ទេស្សិយោ**

**សព្វញ្ញុតំ បិយំ មយ្ហំ តស្មា វ តមធិដ្ឋហឹ ។**

*មាតាបិតាមិនមែនជាទីស្អប់របស់តថាគតទេ ទាំងខ្លួនក៏មិនមែនជាទីស្អប់របស់តថាគតដែរ តែសព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគតតម្កល់នូវអធិដ្ឋាននោះ* [២] *។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។*

*មេត្តាបារមីរបស់ព្រះពោធិសត្វដែលមិនក្រឡេកមើល គឺមិនសោកស្តាយ សូម្បីតែជីវិត ( ទោះជនដទៃបៀតបៀន ) ក៏នៅតែមានមេត្តាក្នុង* **ឯករាជជាតក** [៣] *យ៉ាងនេះថា*

**ន មំ កោចិ ឧត្តសតិ នបិហំ ភាយាមិ កស្សចិ**

**មេត្តាពលេនុបត្ថទ្ធោ រមាមិ បវនេ តទាតិ ។**

*សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគត ក៏*

---

*១- បិដកខ្មែរជា តេមិយជាតក ។ ២-បិ. ៧៧ , ទំ. ២៩៦ ។ ៣-គាថានេះ មិនមានក្នុងឯករាជជាតក ( ឯករាជចរិយា ) តែមានក្នុងសុវណ្ណសាមចរិយា បិ.៧៧ ,ទំ.៣០៦ ។*

មិនខ្វាចសត្វណាមួយឡើយ កាលណោះ កម្លាំងមេត្តាឧបត្ថម្ភតថាគត ឲ្យតថាគតនៅក្នុងព្រៃដោយសួស្តី ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។

ឧបេក្ខាបារមីរបស់ព្រះពោធិសត្វ ដែលជាអ្នកមិនប្រព្រឹត្តកន្លងឧបេក្ខា កាលពួកក្មេងអ្នកស្រុកបង្កឲ្យកើតទុក្ខនិងសុខ ដោយការស្តោះទឹកមាត់ និងការបន្ទោបង់លាមកដាក់ជាដើម ដោយការនាំផ្កានិងគ្រឿងក្រអូបមកឲ្យជាដើម ក្នុង **លោមហំសជាតក** យ៉ាងនេះថា

**សុសានេ សេយ្យំ កប្បេមិ ឆវដ្ឋិកំ ឧបនិធាយ**
**គាមមណ្ឌលា ឧបាគន្ត្វា រូបំ ទស្សេន្តិ នប្បកំ ។**

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត (តថាគត) ហើយសម្តែងនូវប្រការដ៏ប្លែក ច្រើនយ៉ាង[១] ដូច្នេះ ។ នេះចាត់ជាបរមត្ថបារមីពិតប្រាកដ ។

សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណោះ ចំណែកដោយពិស្តារ គប្បីកាន់យកអត្ថទាំងនោះ អំពីចរិយាបិដក ព្រះបរមពោធិសត្វបំពេញបារមីយ៉ាងនេះហើយ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ធ្វើ

---

១-បិ.៧៧ , ទំ. ៣០៧ ។

*បុណ្យធំដែលជាហេតុឲ្យផែនដីកម្រើក ដូចលោកពោលទុកយ៉ាងនេះថា*

**អចេតនាយំ បថវី អវិញ្ញាយ សុខំ ទុក្ខំ**

**សាបិ ទានពលា មយ្ហំ សត្តក្ខត្តុមកម្បថាតិ ។**

*ប្រឹថពី មិនមានចេតនាទេ មិនដឹងសុខនិងទុក្ខទេ តែមហាប្រឹថពីនោះ បានកម្រើកញាប់ញ័រ អស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត [១] ដូច្នេះ ។*

*ក្នុងវេលាអស់អាយុចុតិអំពីនោះហើយ បានទៅកើតក្នុងតុសិតពិភព ។ ចាប់តាំងអំពីបាទមូលរបស់ព្រះពុទ្ធ ព្រះនាមទីបង្ករ រហូតមកដល់ព្រះពោធិសត្វកើតនៅក្នុងតុសិតបុរី សេចក្ដីនេះ គប្បីជ្រាបថា ឈ្មោះថា* **ទូរេនិទាន** *ដោយប្រការដូច្នេះ [២] ។*

ចប់ ទូរេនិទាន ។

---

*១-បិ. ៧៧ , ទំ. ២៦២ ។ ២- ក្នុងទូរេនិទាននេះ នគរក្ដី ព្រះបិតាក្ដី ព្រះមាតាក្ដី អគ្គសាវ័កជាដើមក្ដី របស់ព្រះពុទ្ធទាំងឡាយ សេចក្ដីពិស្ដារមានហើយ ក្នុងបិដកលេខ ៧៧ ឯណោះ បណ្ឌិតអ្នកត្រូវការសេចក្ដីពិស្ដារ សូមកាន់យកសេចក្ដីក្នុងទីនោះហោង ។*

# អចិន្តេយ្យនិទាន

*កាលព្រះបរមពោធិសត្វនៅក្នុងតុសិតបុរីនោះឯង កោលាហល រឿងព្រះពុទ្ធបានកើតឡើងហើយ ។ ពិតហើយ ក្នុងលោករមែងមាន កោលាហល ៣ យ៉ាងកើតឡើង គឺកោលាហលរឿងកប្ប ១ កោលាហល រឿងព្រះពុទ្ធ ១ កោលាហលរឿងស្តេចចក្រពត្តិ ១ ។*

*ទេវតាជាន់កាមាវចរដែលឈ្មោះថា លោកព្យូហា ដឹងថា ការអស់ ទៅនៃកប្បនឹងមាន ក្នុងកាលកន្លងទៅ ១ សែនឆ្នាំទៀតដូច្នេះ ក៏មានសក់ សើម រំសាយសក់ មានមុខជោកដោយទឹកភ្នែក ដៃទាំងពីរជូតទឹកភ្នែក ស្លៀកសំពត់ក្រហម មានរូបរាងចម្លែក ត្រាច់ទៅពោលក្នុងឋានមនុស្សថា នៃអ្នកនិរទុក្ខទាំងឡាយ ដោយកាលកន្លងទៅ ១ សែនឆ្នាំ បន្ទាប់អំពីឆ្នាំ នេះ ហេតុដែលកើតឡើង គឺការអស់ទៅនៃកប្បនឹងមានឡើង លោកនេះ នឹងវិនាសទៅ សូម្បីមហាសមុទ្រក៏នឹងវិនាស ផែនដីធំនិងស្តេចនៃភ្នំឈ្មោះ សិនេរុ ក៏ត្រូវភ្លើងឆេះនឹងវិនាសទៅ សេចក្តីវិនាសនឹងមានរហូតដល់ព្រហ្ម លោក នៃអ្នកនិរទុក្ខទាំងឡាយ សូមអ្នកទាំងឡាយចម្រើន មេត្តា ករុណា មុទិតា ឧបេក្ខា បម្រើមាតាបិតា ចូរជាអ្នកឱនលំទោនចំពោះបុគ្គលដែល ជាធំក្នុងត្រកូល ដូច្នេះ ។ នេះឈ្មោះថា កប្បកោលាហល ។*

*ទេវតាឈ្មោះថា លោកបាល ជ្រាបថា ក្នុងកាលកន្លងទៅ ១ ពាន់ ឆ្នាំទៀត ព្រះសព្វញ្ញូពុទ្ធទ្រង់នឹងកើតឡើងក្នុងលោក ដូច្នេះហើយ នាំគ្នា*

ត្រាច់ទៅ ស្រែកប្រកាសថា នែអ្នកនិរទុក្ខទាំងឡាយ ១ ពាន់ឆ្នាំទៀត ព្រះពុទ្ធនឹងកើតឡើងក្នុងលោក ដូច្នេះ ។ នេះឈ្មោះថា ពុទ្ធកោលាហល ។

ទេវតាពួកនោះឯងដឹងថា ក្នុងកាលកន្លងទៅ ១០០ ឆ្នាំ នឹងមានស្តេចចក្រពត្តិកើតឡើង ក៏នាំគ្នាត្រាច់ប្រកាសថា នែអ្នកនិរទុក្ខទាំងឡាយ ដោយកន្លងទៅ ១០០ ឆ្នាំ បន្ទាប់អំពីឆ្នាំនេះ ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក ដូច្នេះ ។ នេះឈ្មោះថា ចក្កវត្តិកោលាហល ។

កោលាហលទាំង ៣ ប្រការនេះ រាប់ថាជារបស់ធំ បណ្តាកោលាហលទាំង ៣ នោះ ទេវតាក្នុងម៉ឺនចក្រវាលបានស្តាប់សំឡេងកោលាហលរឿងព្រះពុទ្ធហើយ ទើបប្រជុំគ្នា ជ្រាបថា សត្វឈ្មោះនោះនឹងបានត្រាស់ជាព្រះពុទ្ធ ក៏ចូលទៅរក ហើយក៏អារាធនា កាលអារាធនា ក៏អារាធនាក្នុងកាលបុព្វនិមិត្តកើតឡើងហើយ ក្នុងកាលនោះ ទេវតាទាំងឡាយមួយអន្លើដោយចាតុម្មហារាជ សក្កទេវរាជ សុយាមទេវរាជ សន្តុសិតទេវរាជ និម្មានរតីទេវរាជ បរនិម្មិតវសវត្តីទេវរាជ មហាព្រហ្មក្នុងចក្រវាលនីមួយៗ មកប្រជុំគ្នាក្នុងចក្រវាលនេះ ហើយនាំគ្នាទៅកាន់សម្នាក់របស់ព្រះពោធិសត្វក្នុងឋានតុសិតអង្វរថា បពិត្រលោកអ្នកនិរទុក្ខ លោកកាលបំពេញបារមី ១០ ក៏មិនបានប្រាថ្នាសម្បត្តិរបស់សក្កទេវរាជ សម្បត្តិរបស់មារ សម្បត្តិរបស់ស្តេចចក្រពត្តិ សម្បត្តិរបស់ព្រហ្ម តែលោកបំពេញប្រាថ្នាសព្វញ្ញុតញ្ញាណ ដើម្បីនឹងជញ្ជូនសត្វចេញចាកលោក បពិត្រលោកអ្នក

និរទុក្ខ ឥឡូវនេះ ជាកាលដែលលោកគួរជាព្រះពុទ្ធហើយ ដល់សម័យដែលលោកជាព្រះពុទ្ធហើយ ។

លំដាប់នោះ ព្រះមហាសត្វមិនទាន់ឲ្យប្ដេជ្ញាដល់ទេវតាទាំងឡាយ ទ្រង់ប្រមើលមើលមហាវិលោកនៈ គឺទីដែលត្រូវជ្រើសរើសធំ ៥ ប្រការ គឺ កាល ១ ទ្វីប ១ ប្រទេស ១ ត្រកូល ១ និងកំណត់អាយុរបស់មាតា ១ ។ ក្នុងមហាវិលោកនៈ ៥ ប្រការនោះ ព្រះពោធិសត្វពិចារណាមើលកាលជាមុនថា ជាកាលគួរឬមិនគួរ ក្នុងសេចក្ដីនោះ កាលនៃអាយុចម្រើនឡើងដល់លើស ១ សែនឆ្នាំ ចាត់ជាកាលមិនគួរ ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះក្នុងកាលនោះ ជាតិ ជរា និងមរណៈ មិនប្រាកដដល់សត្វទាំងឡាយ និងព្រោះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយដែលផុតទៅអំពីត្រៃលក្ខណ៍មិនមាន កាលព្រះអង្គត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** ពួកសត្វក៏នឹងគិតថា ទ្រង់ត្រាស់សេចក្ដីនោះធ្វើអ្វី ហើយក៏មិនសម្គាល់ថាគួរស្ដាប់ គួរជឿ បន្ទាប់អំពីនោះ ក៏មិនមានការត្រាស់ដឹង កាលមិនមានការត្រាស់ដឹង សាសនាក៏មិនជាវត្ថុនាំសត្វចេញចាកទុក្ខ ព្រោះដូច្នោះទើបជាកាលដែលមិនគួរ ក្នុងកាលនៃអាយុតិចជាង ១០០ ឆ្នាំ ក៏ចាត់ជាកាលដែលមិនគួរ ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ហើយឱវាទដែលឲ្យដល់បុគ្គលដែលមានកិលេសក្រាស់ មិនតាំងនៅជាឱវាទ ឱវាទនោះក៏សាបរលាបទៅដោយឆាប់រួសរាន់ ដូចស្នាមគំនូសដែលគូសក្នុងទឹកដូច្នោះ ព្រោះហេតុនោះ កាលនោះ ក៏ចាត់ថាជាកាលមិនគួរ កាលនៃអាយុត្រឹម ១ សែនឆ្នាំចុះមក ១០០ ឆ្នាំឡើងទៅ ចាត់ជាកាលដែលគួរ ។ ឯក្នុងកាលនោះ ក៏ជាកាលនៃមនុស្សអាយុ ១០០ ឆ្នាំ ពេលនោះ ទើបព្រះមហាសត្វសម្គាល់កាលដែលគួរកើតឡើងបានហើយ ។

បន្ទាប់អំពីនោះ កាលប្រមើលមើលទ្វីប ក៏មើលក្នុងទ្វីបទាំង ៤ ឃើញថា ក្នុងទ្វីបទាំង ៣ ព្រះពុទ្ធទាំងឡាយទ្រង់មិនកើតឡើង ទ្រង់កើតឡើងតែក្នុងជម្ពូទ្វីបនេះប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ក៏ប្រមើលមើលប្រទេសថា ធម្មតាជម្ពូទ្វីបធំទូលាយពេក មានប្រមាណរហូតដល់ ១ ម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយ ទ្រង់កើតឡើងក្នុងប្រទេសណាហ្ន៎ ទើបសម្លឹងឃើញមជ្ឈិមប្រទេស ឈ្មោះថាមជ្ឈិមប្រទេស គឺប្រទេសដែលលោកពោលទុកក្នុងព្រះវិន័យយ៉ាងនេះថា

បណ្តាជនបទទាំងនោះ ជនបទទាំងឡាយនេះដែលជាបច្ចន្តិមជនបទគឺ ក្នុងទិសខាងកើតមាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។ ក្នុង

ទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ [១] ។

មជ្ឈិមប្រទេសនោះ វាស់ដោយបណ្តោយបាន ៣០០ យោជន៍ វាស់ដោយទទឹងបាន ២៥០ យោជន៍ វាស់ដោយរង្វង់ជុំវិញបាន ៩០០ យោជន៍ ក្នុងប្រទេសនោះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ អគ្គសាវក ស្តេចចក្រពត្តិ និងខត្តិយមហាសាល ព្រាហ្មណមហាសាល គហបតីមហាសាល ដែលមានសក្តិធំដទៃ រមែងកើតឡើង ឯនគរឈ្មោះថាកបិលពស្តុនេះ ក៏តាំងនៅក្នុងមជ្ឈិមប្រទេសនោះ ព្រះពោធិសត្វក៏សម្រេចចិត្តថា អាត្មាអញគួរទៅកើតក្នុងនគរនោះ ។

បន្ទាប់អំពីនោះ ព្រះពោធិសត្វកាលពិចារណាដល់ត្រកូល ក៏ឃើញ

---

១-បិ. ៧ , ទំ. ២១៤ ។

ថា ពុទ្ធមាតាទាំងឡាយ រមែងមិនកើតក្នុងត្រកូលវេស្សៈ ឬត្រកូលសូទ្រៈ តែកើតក្នុងត្រកូលពីរប៉ុណ្ណោះ គឺ ត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ដែលសត្វលោកគោរពរាប់អាន ឥឡូវនេះ មានត្រកូលក្សត្រដែលសត្វលោកលើកតម្កើងហើយ អាត្មាអញនឹងកើតក្នុងត្រកូលនោះ ព្រះបាទសុទ្ធោទនមហារាជ នឹងជាព្រះបិតារបស់អាត្មាអញ ដូច្នេះ ។

បន្ទាប់អំពីនោះ កាលជ្រើសរើសមាតាក៏ឃើញថា ពុទ្ធមាតារមែងមិនមែនជាស្រីឡេះឡោះក្នុងបុរស មិនមែនជាអ្នកលេងស្រា តែជាអ្នកបំពេញបារមីមកអស់ ១ សែនកប្ប ចាប់តាំងអំពីកើតមកក៏មានសីល ៥ មិនដាច់ ឯព្រះទេវីព្រះនាមថា មហាមាយានេះ ព្រះនាងមានសភាពដូច្នេះ ព្រះនាងនឹងជាព្រះរាជមាតារបស់អាត្មាអញ ដូច្នេះ ។ កាលប្រមើលមើលថា តើព្រះនាងមានព្រះជន្មាយុប៉ុនណា ? ក៏ឃើញថា អាចរស់នៅបានមិនលើស ១០ ខែនិង ៧ ថ្ងៃ ។

ព្រះបរមពោធិសត្វ ប្រមើលមើលមហាវិលោកនៈ ៥ ប្រការនេះយ៉ាងនេះហើយគិតថា អ្នកនិរទុក្ខ ដល់កាលគួរហើយ ខ្ញុំនឹងជាព្រះពុទ្ធកាលនឹងធ្វើសេចក្តីអនុគ្រោះដល់ទេវតាទាំងឡាយ ទើបឲ្យប្តេជ្ញាហើយពោលថា សូមពួកអ្នកទៅចុះ បញ្ជូនទេវតាទាំងនោះត្រឡប់ទៅ មានទេវតាជាន់តុសិតចោមរោមហើយ ក៏ទៅកាន់នន្ទនវ័នក្នុងតុសិតបុរី ។ ពិតហើយ នន្ទនវ័ននោះ មានគ្រប់ទេវលោកនោះឯង ទេវតាក្នុងនន្ទនវ័ន

ក្នុងទេវលោកនោះពោលថា បពិត្រលោកនិរទុក្ខ សូមលោកចុតិអំពីនន្ទនវ័ននេះ ទៅកាន់សុគតិចុះ ដាស់តឿនក្រើនរំលឹកព្រះមហាសត្វ ឲ្យរឭកដល់ឱកាសនៃកុសលកម្មដែលធ្លាប់ធ្វើទុកក្នុងកាលមុន ។ ព្រះពោធិសត្វដែលពួកទេវតាជួយដាស់តឿនឲ្យរឭកដល់កុសលកម្ម ចោមរោមហើយយ៉ាងនេះ ត្រាច់ទៅក្នុងទេវលោកនោះ ចុតិហើយបដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវី ។ ដើម្បីឲ្យជាក់ច្បាស់ដល់វិធីដែលព្រះពោធិសត្វបដិសន្ធិ សូមនាំពាក្យដែលជាបរិយាយតាមលំដាប់ដូចតទៅនេះថា

បានឮថា ក្នុងកាលនោះ ក្នុងនគរកបិលពស្តុ មានបុណ្យនក្ខត្តឫក្សខែអាសាឍ យ៉ាងគគ្រឹកគគ្រេង មហាជននាំគ្នាលេងនក្ខត្តឫក្ស ។ ចំណែកព្រះនាងមហាមាយាទេវី ក្នុងកាល ៧ ថ្ងៃទៀត ដល់ថ្ងៃពេញបូណ៌មី ព្រះនាងក៏លេងនក្ខត្តឫក្ស តែមិនមានការផឹកសុរា មានតែចាត់ចែងផ្កាកម្រងគ្រឿងក្រអូប និងគ្រឿងអលង្ការ ។ ក្នុងថ្ងៃទី ៧ ព្រះនាងតើនឡើងអំពីព្រលឹម ព្រះនាងស្រពស្រង់ដោយទឹកក្រអូប លះបង់រាជទ្រព្យ ៤ សែនឲ្យទៅជាទានហើយ ព្រះនាងតាក់តែងព្រះកាយដោយគ្រឿងអលង្ការសព្វយ៉ាង សោយព្រះក្រយាហារយ៉ាងល្អ អធិដ្ឋានអង្គនៃឧបោសថ ព្រះនាងក៏ចូលកាន់បន្ទប់ដ៏មានសិរី ផ្ទំលើព្រះសិរីសេយ្យាសនៈ ឈានចុះកាន់និទ្រា ព្រះនាងបានឃើញសុបិនយ៉ាងនេះថា មហារាជទាំង ៤ លើកព្រះនាងមួយអន្ទើដោយទែនព្រះបន្ទំនោះ ទៅកាន់ព្រៃហិមពាន្ត ហើយដាក់

លើផ្ទាំងថ្មមានទំហំប្រមាណ ៦០ យោជន៍ ខាងក្រោមដើមសាលព្រឹក្សធំដែលមានកម្ពស់ ៧ យោជន៍ ហើយឈរក្នុងទីសមគួរនាចំណែកម្ខាង ។ ពេលនោះ ព្រះទេវីរបស់មហារាជទាំង ៤ នោះ នាំគ្នាមកនាំព្រះនាងទៅកាន់អនោតត្តស្រះ ឲ្យស្រពស្រង់ដើម្បីលាងជម្រះនូវមន្ទិលរបស់មនុស្សចេញ ហើយឲ្យស្លៀកសំពត់ទិព្វ លាបស្រឡាបដោយគ្រឿងក្រអូបដ៏ជាទិព្វ ប្រដាប់ដោយផ្កាទិព្វ ។ ក្នុងទីមិនឆ្ងាយអំពីទីនោះ មានភ្នំប្រាក់មួយ ខាងលើភ្នំប្រាក់នោះ មានវិមានមាស ពួកជនទាំងនោះក៏រៀបចំព្រះទែនដ៏ជាទិព្វដាក់ព្រះសិរសាទៅកាន់ទិសខាងកើត ទូលឲ្យព្រះនាងផ្ទំក្នុងវិមានមាសនោះ ។ គ្រានោះ ព្រះពោធិសត្វជាស្ដេចដំរីដ៏ប្រសើរ មានពណ៌សសុទ្ធ ធ្វើដំណើរអំពីភ្នំមាស ១ ក្នុងទីមិនឆ្ងាយអំពីទីនោះ ដើរចុះអំពីភ្នំមាសនោះ ឡើងទៅកាន់ភ្នំប្រាក់តាមផ្លូវទិសឧត្តរ យកប្រមោយដែលមានពណ៌សដូចកម្រងប្រាក់ ចាប់ផ្កាឈូកមានពណ៌ស បន្លឺកោញ្ចនាទចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណទែនព្រះបន្ទំព្រះរាជមាតា ៣ ជុំ ហើយប្រាកដហាក់ដូចជាចូលទៅក្នុងផ្ទៃងជំនីរខាងស្ដាំ ក្នុងព្រះឧទររបស់ព្រះនាង ព្រះពោធិសត្វបដិសន្ធិក្នុងថ្ងៃនក្ខត្តឫក្ស ខែអាសាឍ ដោយប្រការដូច្នេះ ។

ស្អែកឡើង ព្រះទេវីទ្រង់តើនអំពីក្រឡាព្រះបន្ទំហើយ ក្រាបទូលព្រះសុបិននោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យអញ្ជើញព្រាហ្មណ៍ដែលជាធំ ៦៤ នាក់ចូលគាល់ ឲ្យរៀបចំក្រាលអាសនៈដែលមានតម្លៃ

ច្រើន លើទីដែលគេបូកលាបដោយគោម័យស្រស់ ( អាចម៍គោស្រស់ ) មានគ្រឿងសក្ការៈដែលជាមង្គលធ្វើដោយលាជជាដើម ឲ្យដាក់បាយាសដ៏ប្រសើរ ដែលចម្អិនដោយសប្បិ ទឹកឃ្មុំ និងស្ករផែន រហូតពេញថាសមាសនិងថាសប្រាក់ ឲ្យយកថាសមាសនិងថាសប្រាក់គ្រប ហើយឲ្យដល់ពួកព្រាហ្មណ៍ទាំងនោះ ញុំាងពួកព្រាហ្មណ៍ទាំងនោះឲ្យឆ្អែតស្កប់ស្កល់ហើយ ឲ្យនូវសំពត់ថ្មីនិងមេគោក្រហមជាដើម ។ ពេលនោះ កាលពួកព្រាហ្មណ៍ទាំងនោះ ឆ្អែតស្កប់ស្កល់ដោយរបស់ដែលត្រូវការគ្រប់យ៉ាងហើយ ទើបប្រាប់ព្រះសុបិនហើយត្រាស់សួរថា តើមានរឿងហេតុអ្វីកើតឡើង?

ព្រាហ្មណ៍ក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំវិតក្កអ្វីឡើយ ព្រះទេវីតាំងព្រះគភ៌ហើយ ឯព្រះគភ៌ដែលតាំងឡើងនោះ ជាគភ៌របស់បុរសមិនមែនជាគភ៌របស់ស្ត្រី ព្រះនាងនឹងមានព្រះរាជបុត្ត បើព្រះរាជបុត្តនោះនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើចេញចាកផ្ទះបួស នឹងបានត្រាស់ជាព្រះពុទ្ធ ជាអ្នកដែលមានកិលេសដូចជាដំបូលបើកហើយ ក្នុងលោក ។

ក្នុងខណៈដែលព្រះពោធិសត្វបដិសន្ធិក្នុងគព្ភោទរៈ របស់ព្រះមាតានោះឯង មុឺនលោកធាតុក៏ញាប់ញ័រព្រមគ្នា បុព្វនិមិត្ត ៣២ ប្រការ ប្រាកដឡើងហើយ ។ ក្នុងមុឺនចក្រវាល មានពន្លឺភ្លឺស្វាងប្រមាណមិនបានផ្សាយ

ទៅ ពួកមនុស្សភ្នែកខ្វាក់ក៏មានភ្នែកល្អឡើងវិញ ហាក់បីដូចជាមានបំណង នឹងមើលព្រះសិរីរបស់ព្រះពោធិសត្វដូច្នោះ ពួកមនុស្សដែលមានត្រចៀកថ្លង់ក៏ស្តាប់សំឡេងបាន ពួកមនុស្សគក៏និយាយចរចាបាន ពួកមនុស្សគម ក៏មានខ្នងត្រង់ឡើង ឯមនុស្សខ្វិនក៏មានជើងដើរបាន សត្វទាំងពួងដែលត្រូវចង ក៏របូតចំណងមានខ្នោះឃ្នាងជាដើម ក្នុងនរកគ្រប់កន្លែងភ្លើងក៏រលត់ ក្នុងបេត្តិវិស័យការស្រេកឃ្លានក៏ស្ងប់ទៅ ពួកសត្វតិរច្ឆានក៏មិនមានការភិតភ័យតក់ស្លុត រោគនិងភ្លើងកិលេសមានរាគៈជាដើម របស់សត្វទាំងពួងក៏ស្ងប់រម្ងាប់ សត្វទាំងពួងមានវាចាគួរជាទីស្រឡាញ់ដល់គ្នានឹងគ្នា ពួកសេះទាំងឡាយក៏កញ្ជ្រៀវ ដំរីទាំងឡាយក៏កង្ហួចដោយអាការដ៏ពីរោះ បណ្តាតន្ត្រីគ្រប់ប្រភេទក៏បន្លឺរងំរៀងៗខ្លួន ដោយខ្លួនឯង មិនចាំបាច់មានអ្នកណាវាយដំប្រគំកូតឡើយ គ្រឿងអាភរណៈដែលពាក់ត្រង់ដៃរបស់មនុស្សទាំងឡាយក៏ទង្គិចគ្នា សំឡេងក៏លាន់ឮឡើង គ្រប់ទិសានុទិសក៏ភ្លឺច្បាស់ ខ្យល់ត្រជាក់ទាំងឡាយ ក៏បក់ផាត់មក កើតសេចក្តីសុខដល់សត្វទាំងឡាយ ភ្លៀងពុំជួកាលក៏ធ្លាក់ចុះមក សូម្បីផែនដីទឹកក៏ខ្លួរចេញមក ឯពួកបក្សី ក៏មិនហើរទៅក្នុងអាកាស ខ្សែទឹកក៏នៅស្ងៀមមិនហូរ ទឹកក្នុងមហាសមុទ្រក៏មានរសឆ្ងាញ់ តាមមាត់ច្រាំងគ្រប់កន្លែង ក៏ដេរដាសដោយផ្កាឈូកមានពណ៌ ៥ ផ្កាគ្រប់ប្រភេទដែលកើតលើគោកនិងក្នុងទឹក ក៏រីកស្គុសស្គាយទូទៅ ត្រង់ដើមឈើ ឈូកដើមក៏ចេញផ្កាអំពីដើម ឯឈូកមែកក៏ចេញ

ផ្កាអំពីមេឃ ឯឈូកវល្លិក៏ចេញផ្កាអំពីវល្លិ ត្រង់ផែនដីមានផ្កាឈូកជ្រែកផែនថ្មផុសឡើង មួយកន្ទេងប្រាំពីរផ្កាៗ ក្នុងអាកាសក៏មានឈូកអាកាសកើតឡើងសំយុងចុះ ភ្លៀងផ្កាក៏ធ្លាក់រោយរាយចុះមកដោយជុំវិញ ទិព្វតន្ត្រីក៏បន្លឺក្នុងអាកាស ក្នុងម៉ឺនលោកធាតុពេញដោយទង់ជ័យ និងកម្រងផ្កាជាប់គ្នាតែមួយ រសាត់ទៅ ហាក់បីដូចកម្រងផ្កាដែលគេប្រមូលចងជាបាច់រួមគ្នា ឬដូចគ្នានឹងដំណេកផ្កាដែលប្រដាប់តាក់តែងហើយ មានផ្កាជាកម្រងតែមួយ ( ក្នុងម៉ឺនចក្រវាល ) ហាក់បីដូចផ្ចិតវាលវិជនីកំពុងបក់ផ្សាយនូវក្លិនគ្រឿងក្រអូប មួយអន្លើដោយក្លិនផ្សេងក្រអូប ជាលោកធាតុដែលដល់នូវលម្អដ៏ស្រស់ត្រកាលហើយ ។

ចាប់តាំងអំពីព្រះបរមពោធិសត្វបដិសន្ធិហើយយ៉ាងនេះ កាលនឹងការពារមិនឲ្យកើតអន្តរាយដល់ព្រះពោធិសត្វ និងព្រះរាជមាតារបស់ទ្រង់ទេវរាជ ៤ អង្គ មានដៃកាន់ដាវរង់ចាំធ្វើការរក្សា ។ ការគិតទាក់ទងដោយរាគៈក្នុងបុរសទាំងឡាយ មិនកើតដល់ព្រះរាជមាតារបស់ព្រះមហាបុរសឡើយ ព្រះនាងមានតែដល់នូវការប្រសើរដោយលាភ និងការប្រសើរដោយយស មានសេចក្តីសុខ មានព្រះវរកាយមិនលំបាក ហើយអាចទតឃើញព្រះមហាសត្វដែលនៅក្នុងព្រះឧទរ ហាក់បីដូចអំបោះពណ៌សដែលដោតក្នុងកែវមណីដ៏ថ្លា ធម្មតាព្រះឧទរដែលព្រះពោធិសត្វអាស្រ័យនៅ ដូចគ្នានឹងបន្ទប់នៃចេតិយ សត្វទាំងឡាយដទៃមិនអាចនឹងបរិភោគ

ព្រោះដូច្នោះ ទើបព្រះរាជមាតារបស់ព្រះពោធិសត្វ សោយព្រះទិវង្គត ហើយទៅកាន់តុសិតបុរី ក្នុងកាលព្រះពោធិសត្វប្រសូតបាន ៧ ថ្ងៃ ។ ស្ត្រីដទៃមិនដល់ ១០ ខែខ្លះ ហួស ១០ ខែខ្លះ អង្គុយប្រសូតខ្លះ ដេកប្រសូតខ្លះ យ៉ាងណា ព្រះរាជមាតារបស់ព្រះពោធិសត្វមិនដូច្នោះឡើយ ព្រះនាងថែរក្សាព្រះពោធិសត្វទុកក្នុងព្រះគភ៌អស់ ១០ ខែ ហើយប្រថាប់ឈរប្រសូត ឯសេចក្តីនេះ ជាធម្មតារបស់ព្រះមាតានៃព្រះពោធិសត្វ ។ ព្រះនាងមហាមាយាទេវី ថែរក្សាព្រះពោធិសត្វក្នុងព្រះឧទរអស់ ១០ ខែ ហាក់បីដូចថែរក្សាប្រេងដែលទុកក្នុងបាត្រដូច្នោះ ។ លុះព្រះនាងមានព្រះគភ៌ចាស់ពេញបរិបូណ៌ហើយ មានព្រះរាជបំណងនឹងយាងទៅកាន់ត្រកូលព្រះញាតិ ទើបក្រាបទូលព្រះបាទសុទ្ធោទនមហារាជថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នានឹងទៅកាន់នគរទេវទហៈ ដែលជានគរនៃត្រកូល ។ ព្រះបាទសុទ្ធោទនៈទ្រង់ទទួលថា ប្រពៃហើយ ទើបត្រាស់ឲ្យធ្វើផ្លូវ តាំងអំពីនគរកបិលពស្តុរហូតដល់នគរទេវទហៈ ប្រដាប់ដោយដើមចេក តម្កល់ក្អមដែលមានទឹកពេញ លើកទង់ជ័យនិងទង់ផ្កាលា ឲ្យព្រះទេវីគង់ក្នុងវិមាស ឲ្យអាមាត្យ ១ ពាន់នាក់សែងទៅ ទ្រង់បញ្ជូនទៅមួយអន្លើដោយបរិវារជាច្រើន ។ អ្នកនគរទាំងពីរ មានសាលវ័នដែលជាមង្គលឈ្មោះថា លុម្ពិនី ដែលនៅចន្លោះនគរទាំងពីរ ។ សម័យនោះ សាលវ័នទាំងមូលមានផ្ការីកស្គុសស្គាយដូចគ្នាតែមួយ តាំងអំពីគល់រហូត

ដល់ចុង ត្រង់ចន្លោះមែកនិងចន្លោះផ្កា មានហ្វូងបក្សីមានពណ៌ ៥ និង មានពណ៌ដូចសត្វកន្ទង់ ត្រាច់ហើរ យំបញ្ចេញសំឡេងរងំ ក្នុងលុម្ពិនីវ័ន ទាំងមូល ហាក់បីដូចជាចិត្តលតាវ័ន មណ្ឌលនៃផែនដីហាក់ដូចជាប្រជុំគ្នា ក្នុងទីនោះ ។ ព្រោះព្រះនាងទតឃើញលុម្ពិនីវ័ន ព្រះទេវីក៏មានព្រះរាជ បំណងនឹងក្រសាលកីឡាក្នុងសាលវ័ននោះ ពួកអាមាត្យ ក៏នាំព្រះទេវីចូល ទៅកាន់សាលវ័ន ព្រះនាងមានព្រះរាជបំណងយាងចូលទៅកាន់គល់ សាលព្រឹក្សមួយដើមដែលជាមង្គល ហើយព្រះនាងប្រាថ្នានឹងចាប់ត្រង់ មែកសាលព្រឹក្ស មែកសាលព្រឹក្សក៏ទោរទន់ចុះមក ហាក់បីដូចដើមផ្តៅ ដែលគេពោលឲ្យក្តៅហើយទោរទន់មកដូច្នោះ គឺល្មមដល់ព្រះហស្តរបស់ ព្រះនាងអាចចាប់បាន ព្រះនាងក៏លាព្រះហស្តចេញមក ចាប់មែកសាល-ព្រឹក្សនោះ ។

ក្នុងខណៈនោះ ខ្យល់កម្មជ្ជវាតរបស់ព្រះនាងក៏កើតឡើង រំពេច នោះ មហាជនក៏បាំងវាំងននថ្វាយដល់ព្រះនាង ហើយក៏ចៀសចេញទៅ កាលព្រះនាងចាប់មែកសាលព្រឹក្សប្រថាប់ឈរ ព្រះនាងក៏ប្រសូតហើយ ក្នុងខណៈនោះឯង ។ មហាព្រហ្មដែលមានចិត្តបរិសុទ្ធ ៤ អង្គក៏មកដល់ មួយអន្លើដោយបណ្តាញមាសមកផង យកបណ្តាញមាសនោះ ទទួល ព្រះពោធិសត្វ ដាក់ត្រង់ព្រះភក្ត្ររបស់ព្រះរាជមាតាបណ្តើរ ក្រាបទូល បណ្តើរថា បពិត្រព្រះទេវី សូមព្រះនាងត្រេកអរចុះ ព្រះរាជបុត្តរបស់

ព្រះនាងមានសក្តិធំកើតឡើងហើយ ។ ធម្មតាសត្វដទៃ កាលប្រសូតចាកឧទរមាតា ក៏រមែងប្រឡាក់ប្រឡូសដោយវត្ថុបដិកូលមិនស្អាត យ៉ាងណា ព្រះពោធិសត្វមិនដូច្នោះឡើយ ឯព្រះពោធិសត្វនោះលាដៃនិងជើងទាំងពីរ ប្រថាប់ឈរត្រង់ ដូចធម្មកថិកចុះអំពីធម្មាសនៈ និងដូចបុរសចុះអំពីជណ្តើរ មិនបានប្រឡាក់ប្រឡូសដោយរបស់មិនស្អាតណាមួយ ដែលមាននៅក្នុងគភ៌មាតា ជាអ្នកស្អាតបរិសុទ្ធរុងរឿងដូចកែវមណី ដែលគេដាក់លើសំពត់កាសិកពស្ត្រ ប្រសូតចេញមកអំពីគភ៌ព្រះមាតា តែទោះបីជាដូច្នោះ ក៏ធ្លារទឹក ២ ខ្សែ ( ធ្លារទឹកក្តៅនិងធ្លារទឹកត្រជាក់ ) ហូរមកអំពីអាកាស ស្រោចស្រពលើព្រះសរីរៈរបស់ព្រះពោធិសត្វនិងព្រះមាតា ធ្វើឲ្យក្តៅសប្បាយ ដើម្បីជាគ្រឿងសក្ការដល់ព្រះពោធិសត្វនិងព្រះមាតា ។ បន្ទាប់អំពីនោះ មហារាជ ៤ អង្គ បានទទួលព្រះមហាបុរសអំពីដៃរបស់ព្រហ្ម ដែលឈរយកបណ្តាញមាសទទួល ដោយកម្រាលដែលធ្វើដោយស្បែកខ្លាមានសម្ផស្សទន់ដែលសត្វលោកសន្មតគ្នាថាជាមង្គល ពួកមនុស្សក៏យកសំពត់ទុកូលពស្ត្រទទួលអំពីដៃរបស់មហារាជទាំងនោះ លុះផុតអំពីដៃរបស់ពួកមនុស្ស ព្រះបរមពោធិសត្វក៏ប្រថាប់ឈរលើផែនដី ទតមើលទិសខាងកើតនិងចក្រវាលទាំងឡាយ ១ ពាន់ ទេវតានិងមនុស្សក្នុងទីនោះ ក៏នាំគ្នាបូជាដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម ហើយនាំគ្នាក្រាបទូលថា បពិត្រលោកនិរទុក្ខ បុរសដទៃក្នុងទីនេះ ដូចជាលោកមិន

មាន បុគ្គលដែលក្រៃលែងជាងលោក នឹងមានមកអំពីណា ។ ព្រះពោធិ-សត្វសម្លឹងមើលលោកធាតុ ក្នុងទិសតូចទិសធំទាំង ១០ គឺទិសធំ ៤ និងទិសតូច ៤ ទិសខាងលើនិងទិសខាងក្រោម មិនឃើញមានបុគ្គលណាស្មើនឹងព្រះអង្គ ទើបត្រិះរិះថា នេះជាទិសខាងជើង ហើយទ្រង់បានយាងទៅដោយជំហាន ៧ មានមហាព្រហ្មបាំងស្វេតច្ឆត្រ ស្តេចសុយាមកាន់ផ្លិតវាលវិជនី ឯទេវតាដទៃមានដៃកាន់គ្រឿងរាជកកុធភណ្ឌដ៏សេស ដើរតាមទៅ ។ បន្ទាប់អំពីនោះ ព្រះមហាបុរសទ្រង់ក៏ប្រថាប់ឈរត្រង់ជំហានទី ៧ បន្លឺអសភិវាចាជាដើមថា **អគ្គោហមស្មិ លោកស្ស** យើងជាកំពូលនៃលោក ហើយទ្រង់បន្លឺសីហនាទ ។

ពិតហើយ ព្រះបរមពោធិសត្វគ្រាន់តែប្រសូតអំពីព្រះគភ៌របស់ព្រះមាតាប៉ុណ្ណោះ ក៏បន្លឺវាចាបាន ៣ អត្តភាព គឺក្នុងអត្តភាពជាព្រះមហោ-សធ ក្នុងអត្តភាពជាព្រះវេស្សន្តរ និងក្នុងអត្តភាពនេះ ។ បានឮថា ក្នុងអត្តភាពជាព្រះមហោសធ ក្នុងពេលព្រះពោធិសត្វប្រសូតអំពីព្រះគភ៌របស់ព្រះមាតា សក្កទេវរាជក៏យាងមក ទ្រង់ដាក់ខ្លឹមចន្ទន៍ដែលជាឱសថត្រង់ដៃហើយ ស្តេចយាងត្រឡប់ទៅវិញ ។ ព្រះមហាបុរសក្តាប់ខ្លឹមចន្ទន៍នោះក្នុងដៃប្រសូតចេញមក រំពេចនោះមាតាក៏សួរថា នែបា កូនកាន់អ្វី ? ព្រះមហោសធក៏ឆ្លើយថា **ឱសធំ អម្ម** បពិត្រអ្នកម៉ែ ថ្នាំ ព្រោះហេតុដែលកាន់យកថ្នាំមក ទើបមនុស្សទាំងឡាយដាក់ឈ្មោះដល់កុមារនោះថា

ឱសថទារក ជនទាំងឡាយក៏កាន់យកថ្នាំនោះដាក់ក្នុងពាង ឱសថនោះបានជាថ្នាំរក្សារោគសព្វយ៉ាង សូម្បីដល់មនុស្សភ្នែកខ្វាក់ មនុស្សត្រចៀកថ្លង់ជាដើម មនុស្សទាំងនោះក៏នាំគ្នាមកជាបន្តៗ ព្រោះកាន់យកពាក្យដែលពោលតគ្នាថា ឱសថនេះមានគុណច្រើន ឱសថនេះមានគុណច្រើន ទើបកុមារនោះ មានឈ្មោះមួយទៀតថា មហោសធ ។ ចំណែកក្នុងអត្តភាពជាព្រះវេស្សន្តរ ព្រះពោធិសត្វ កាលប្រសូតអំពីព្រះគភ៌របស់ព្រះមាតា ក៏លាដៃចេញមកពោលថា **អត្ថិ នុ ខោ អម្ម កិញ្ចិ គេហស្មឹ ធានំ ទស្សាមិ** បពិត្រអ្នកម៉ែ ក្នុងផ្ទះមានទ្រព្យខ្លះដែរឬទេ ខ្ញុំនឹងឲ្យទាន ។ រំពេចនោះ ព្រះមាតារបស់ព្រះពោធិសត្វពោលថា នែបា កូនកើតក្នុងត្រកូលដែលមានទ្រព្យ ពោលហើយព្រះនាងក៏ដាក់ថង់ប្រាក់ ១ ពាន់ ( ក្នុងដៃព្រះពោធិសត្វ ) ហើយក៏ដាក់ដៃរបស់ព្រះពោធិសត្វលើដៃរបស់ព្រះនាង ។ ក្នុងអត្តភាពជាព្រះពោធិសត្វ ( បាន ) បន្លឺសីហនាទទាំងនេះ ដោយប្រការដូច្នេះ ។

ព្រះពោធិសត្វគ្រាន់តែប្រសូតចាកគភ៌មាតាប៉ុណ្ណោះ ក៏បន្លឺវាចាបានក្នុង ៣ អត្តភាព ដោយប្រការដូច្នេះ ។

ក្នុងខណៈបដិសន្ធិយ៉ាងណា សូម្បីក្នុងខណៈប្រសូតក៏ដូច្នោះ បុព្វនិមិត្ត ៣២ ប្រការ ក៏បានប្រាកដឡើង ក្នុងសម័យដែលព្រះពោធិសត្វនៃយើងប្រសូតហើយក្នុងលុម្ពិនីវ័ន ។ ក្នុងសម័យនោះឯង ព្រះទេវីដែល

ជាព្រះមាតារបស់ព្រះរាហុល ឆន្នអាមាត្យ កាឡុទាយី រាជកុមារអានន្ទ សេះកណ្ឋកៈ មហាពោធិព្រឹក្ស កំណប់ទ្រព្យ ៤ រណ្តៅ ក៏កើតឡើងព្រមគ្នា ។ បណ្តាកំណប់ទ្រព្យទាំងនោះ កំណប់ទ្រព្យទី ១ មាន ( វង្វង់មាត់ ) ប្រមាណ ១ គាវុត កំណប់ទ្រព្យទី ២ មានប្រមាណកន្លះយោជន៍ កំណប់ទ្រព្យទី ៣ មានប្រមាណ ៣ គាវុត កំណប់ទ្រព្យទី ៤ មានប្រមាណ ១ យោជន៍ ព្រោះដូច្នោះ ទើបរួមជាសហជាតវត្ថុ ៧ យ៉ាង ។ ពួកអ្នកនគរទាំងពីរ ក៏បាននាំព្រះពោធិសត្វត្រឡប់ទៅកាន់នគរកបិលពស្តុវិញ ។ ក្នុងថ្ងៃនោះ ពួកទេវតាក្នុងតាវត្តិង្សពិភពក៏នាំគ្នាត្រេកអរថា ព្រះឱរសរបស់ព្រះបាទសុទ្ធោទនមហារាជប្រសូតហើយ ក្នុងនគរកបិលពស្តុ ព្រះរាជកុមារនេះ នឹងប្រថាប់គង់ត្រង់មណ្ឌលមហាពោធិព្រឹក្ស ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះហើយ នាំគ្នាគ្រវីសំពត់ សម្តែងនូវការត្រេកអរលេងយ៉ាងសប្បាយ ។

ក្នុងសម័យនោះ មានតាបសមួយរូបឈ្មោះកាឡទេវិល ដែលជាអ្នកស្និទ្ធស្នាលក្នុងត្រកូលរបស់ព្រះបាទសុទ្ធោទនមហារាជ បានសម្រេចសមាបត្តិ ៨ ឆាន់ស្រេចហើយ ក៏ហោះទៅកាន់តាវត្តិង្សពិភព ដើម្បីសម្រាកក្នុងវេលាថ្ងៃ អង្គុយសម្រាកក្នុងពេលថ្ងៃក្នុងទីនោះ ឃើញទេវតាទាំងនោះក៏សួរថា ព្រោះហេតុអ្វី ទើបពួកអ្នកត្រេកអររីករាយម្ល៉េះ សូមប្រាប់ហេតុនោះ ដល់អាត្មាផង ។

ពួកទេវតាបានប្រាប់ហេតុនោះថា បពិត្រលោកនិរទុក្ខ ព្រះរាជឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ ប្រសូតហើយ ព្រះអង្គនឹងប្រថាប់គង់ត្រង់មណ្ឌលពោធិព្រឹក្ស ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ប្រកាសព្រះធម្មចក្ក ពួកខ្ញុំត្រេកអររីករាយព្រោះហេតុនេះថា ពួកយើងនឹងបានឃើញពុទ្ធលីលា ដែលមិនមានទីបំផុត នឹងបានស្តាប់ព្រះធម៌របស់ព្រះអង្គ ។ តាបសនោះស្តាប់ពាក្យរបស់ពួកទេវតាហើយ ចុះអំពីទេវលោកមួយរំពេចទៅកាន់ព្រះរាជនិវេសន៍ អង្គុយលើអាសនៈដែលគេក្រាលទុកហើយទូលថា បពិត្រមហារាជ បានឮថា ព្រះរាជឱរសរបស់ព្រះអង្គប្រសូតហើយ អាត្មាមកចង់ឃើញ ។ ព្រះរាជាត្រាស់ឲ្យប្រដាប់តាក់តែងព្រះរាជកុមារហើយនាំមក ទ្រង់ពទៅដើម្បីឲ្យនមស្ការតាបស ( ក្នុងខណៈនោះ ) ព្រះបាទទាំងគូរបស់ព្រះមហាសត្វ ក៏ត្រឡប់ប្រតិស្ឋានលើជដារបស់តាបស ។ ពិតហើយ បុគ្គលដទៃដែលឈ្មោះថា ព្រះមហាបុរសគប្បីថ្វាយបង្គំក្នុងអត្តភាពនោះ មិនមានឡើយ ប្រសិនបើបុគ្គលមិនដឹង គប្បីដាក់ព្រះសិរសារបស់ព្រះមហាបុរសទៀបបាទមូលរបស់តាបស ក្បាលរបស់តាបសនោះ គប្បីបែកជា ៧ ភាគ ។ តាបសគិតថា ការធ្វើខ្លួនអញឲ្យវិនាស មិនគួរ ទើបក្រោកចាកអាសនៈហើយផ្គងអញ្ជលីដល់ព្រះពោធិសត្វ ។ ព្រះរាជា ទ្រង់ទតឃើញហេតុអស្ចារ្យនោះ ទ្រង់ក៏ថ្វាយបង្គំបុត្តរបស់ព្រះអង្គដូចគ្នា តាបសរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីត ៤០ កប្ប ក្នុងអនាគត

៤០ កប្ប ឃើញលក្ខណសម្បត្តិរបស់ព្រះពោធិសត្វហើយពិចារណាថា កុមារនេះនឹងបានជាព្រះពុទ្ធឬទេហ្ន៎ ក៏ដឹងថា នឹងបានត្រាស់ជាព្រះពុទ្ធ ដោយឥតសង្ស័យ គិតថា ព្រះរាជបុត្តនេះជាអច្ឆរិយបុរស ទើបបានធ្វើនូវការញញឹមឲ្យប្រាកដ លុះកាលពិចារណាថា អញនឹងបានទាន់ បានឃើញព្រះពុទ្ធអង្គនេះកើតឡើងដែរឬហ្ន៎ ក៏បានឃើញថា អាត្មាអញមិនអាចនៅទាន់ឡើយ នឹងស្លាប់ក្នុងចន្លោះនោះឯង ហើយនឹងទៅកើតក្នុងអរូបភព ដែលព្រះពុទ្ធរាប់រយរាប់ពាន់ព្រះអង្គ ក៏មិនអាចយាងទៅដើម្បីឲ្យត្រាស់ដឹងបាន ។ តាបសគិតថា អាត្មាអញមិនបានឃើញអច្ឆរិយបុរសដែលជាព្រះសម្ពុទ្ធបែបនេះ អញមានការវិនាសធំហ្ន៎ ដូច្នេះហើយ ក៏ទ្រហោយំ ។ ពួកមនុស្សឃើញតាបសទ្រហោយំ ក៏សួរថា បពិត្រលោកម្ចាស់ អម្បាញ់មិញនេះ លោកម្ចាស់សើចហើយត្រឡប់ជាយំវិញ បពិត្រលោកម្ចាស់ដ៏ចម្រើន អន្តរាយអ្វីនឹងកើតដល់ព្រះអយ្យបុត្តរបស់យើងឬ ?

តាបសឆ្លើយថា ទ្រង់មិនមានអន្តរាយអ្វីឡើយ ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ។

ពួកមនុស្សសួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបលោកម្ចាស់យំ ?

តាបសឆ្លើយថា អាត្មាសោយសោកដល់ខ្លួនថា អញមិនបានទាន់ មិនបានឃើញព្រះមហាបុរស ដែលជាព្រះពុទ្ធមានសភាពបែបនេះ ការ

វិនាសធំមានដល់អាត្មា ដូច្នេះហើយ ទើបអាត្មាយំ ។

បន្ទាប់អំពីនោះ តាបសពិចារណាមើលថា ក្នុងញាតិរបស់ពួកអញ មានអ្នកណាខ្លះ នឹងបានឃើញភាពជាព្រះពុទ្ធរបស់ព្រះរាជកុមារអង្គនេះ ក៏បានឃើញនាលកទារកដែលជាក្មួយ ទើបចូលទៅកាន់ផ្ទះរបស់ប្អូនស្រី សួរថា នាលកៈ កូនរបស់នាងនៅឯណា ?

ប្អូនស្រីឆ្លើយថា បពិត្រលោកម្ចាស់ កុមារនៅក្នុងផ្ទះ ។

តាបសពោលថា ចូរហៅគេមកចុះ ។ ពួកជនទាំងនោះក៏ឲ្យហៅកុមារមកហើយ តាបសក៏និយាយនឹងកុមារដែលមកកាន់សម្នាក់របស់ខ្លួនថា នែក្មួយ ព្រះរាជឱរសដែលកើតហើយក្នុងត្រកូលរបស់ព្រះបាទសុទ្ធោទនមហារាជ ព្រះអង្គជាពុទ្ធង្កូរ ទ្រង់នឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាល ៣៥ ឆ្នាំទៀត អ្នកនឹងបានឃើញព្រះអង្គ ចូរអ្នកបួសក្នុងថ្ងៃនេះចុះ ។ កុមារកើតក្នុងត្រកូលដែលមានទ្រព្យ ៨៧ កោដិ គិតថា លោកអ៊ំរបស់អញ មិនមែនដឹកនាំអញក្នុងវត្ថុដែលមិនមានប្រយោជន៍ ។ រំពេចនោះឯង ក៏ឲ្យមនុស្សទិញសំពត់កាសាវពស្ត្រនិងបាត្រដីមកអំពីផ្សារ កោរសក់និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាវពស្ត្រ ផ្គងអញ្ជលីបែរមុខទៅរកព្រះពោធិសត្វហើយពោលថា **យោ លោកេ ឧត្តមបុគ្គលោ តំ ឧទ្ទិស្ស មយ្ហំ បព្វជ្ជា** ឧត្តមបុគ្គលក្នុងលោកអង្គណាកើតឡើង ខ្ញុំសូមបួសឧទ្ទិសឧត្តមបុគ្គលនោះ ហើយក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន

យកបាត្រដាក់ក្នុងស្ពាក ស្ពាយត្រង់ចង្កេះស្មា ហើយទៅកាន់ហិមវន្តប្ប-ទេសបំពេញសមណធម៌ ។ លោកចូលទៅគាល់ព្រះសាស្តា ក្នុងបឋមពោធិកាល ទូលសូមឲ្យទ្រង់សម្តែងនាលកបដិបទា ( មោនេយ្យបដិបទា ) ហើយចូលទៅកាន់ព្រៃហិមពាន្តទៀត សម្រេចអរហត្ត បដិបត្តិនូវបដិបទានោះយ៉ាងឧក្រិដ្ឋ រក្សាអាយុមកបាន ៧ ខែ ( ក្រោយពេលបដិបត្តិមោនេយ្យបដិបទា ) ក៏ឈរផ្អែកត្រង់ថ្មភ្នំនោះឯង បរិនិព្វានហើយដោយអនុបាទិសេសនិព្វានធាតុ ។

ក្នុងថ្ងៃទី ៥ ព្រះញាតិទាំងឡាយ នាំគ្នាស្រពស្រង់ព្រះសិរសារបស់ព្រះពោធិសត្វ គិតថា ពួកយើងនឹងថ្វាយព្រះនាមដល់ព្រះអង្គ ដូច្នេះហើយក៏លាបស្រឡាបរាជមន្ទីរដោយគន្ធជាតិ ៤ ប្រភេទ បាចសាចនូវផ្កា មានលាជជាគម្រប់ ៥ ឲ្យចម្អិនបាយាសស្រស់ៗ ហើយអញ្ជើញព្រាហ្មណ៍ដែលចេះចប់ត្រៃវេទចំនួន ១០៨ នាក់ ឲ្យអង្គុយក្នុងព្រះរាជមន្ទីរ ឲ្យឆាន់ភោជនយ៉ាងល្អ ជូនសក្ការៈជាច្រើនហើយសួរថា អ្វីហ្ន៎នឹងមាន ហើយឲ្យពិនិត្យមើលលក្ខណៈ ។

បណ្តាព្រាហ្មណ៍ទាំងនោះ មានដូច្នេះគឺ

រាមោ ធជោ លក្ខណោ ចាបិ មន្តី
ភោជោ សុយាមោ កោណ្ឌញ្ញោ សុទត្តោ
ឯតេ តទា អដ្ឋ អហេសុំ ព្រាហ្មណា

ឆឡង្គវា មន្តំ វិយាករឹសុ ។

*ព្រាហ្មណ៍ ៨ នាក់ គឺព្រាហ្មណ៍ ឈ្មោះរាមៈ ឈ្មោះធជៈ*
*ឈ្មោះលក្ខណៈ ឈ្មោះមន្ត្រី ឈ្មោះភោជៈ ឈ្មោះសុយាមៈ*
*ឈ្មោះកោណ្ឌញ្ញៈ ឈ្មោះសុទត្តៈ ក្នុងកាលនោះ ពួក*
*ព្រាហ្មណ៍ទាំងនោះ ក៏បានជាព្រាហ្មណ៍ ៨ នាក់ ដែល*
*ជាអ្នកចេះចប់ខាងត្រៃវេទទាំង ៦ ព្យាករមន្តហើយ ។*

*ព្រាហ្មណ៍ទាំងនេះ ក៏បានពិនិត្យមើលហើយ ។ ពួកព្រាហ្មណ៍ទាំងនេះឯង ជាអ្នកពិនិត្យមើលលក្ខណៈព្រះសុបិនក្នុងថ្ងៃដែល (ព្រះពោធិសត្វ) បដិសន្ធិផងដែរ ។ បណ្តាព្រាហ្មណ៍ទាំង ៨ នាក់នោះ ព្រាហ្មណ៍ ៧ នាក់ លើកម្រាមដៃពីរ ព្យាករជាពីរផ្លូវថា បុគ្គលដែលប្រកបដោយលក្ខណៈយ៉ាងនេះ កាលនៅគ្រប់គ្រងផ្ទះនឹងបានជាស្តេចចក្រពត្តិ កាលចេញទៅបួសនឹងបានត្រាស់ជាព្រះពុទ្ធ ដូច្នេះហើយ ក៏នាំគ្នាប្រាប់អំពីសម្បត្តិដ៏មានសិរីរបស់ស្តេចចក្រពត្តិ ។ ឯមាណពឈ្មោះកោណ្ឌញ្ញៈដោយគោត្រក្មេងជាងព្រាហ្មណ៍ទាំងនោះ ពិចារណាមើលភាពសម្បូរនៃលក្ខណៈរបស់ព្រះពោធិសត្វ លើកម្រាមដៃមួយប៉ុណ្ណោះ ហើយព្យាករតែមួយផ្លូវថា ព្រះពោធិសត្វអង្គនេះ មិនមានហេតុដែលតាំងនៅក្នុងកណ្តាលផ្ទះ នឹងចេញបួស បានត្រាស់ជាព្រះពុទ្ធ ប្រាសចាកកិលេសដូចដំបូល ដោយចំណែកមួយប៉ុណ្ណោះ ។ ពិតហើយ កោណ្ឌញ្ញព្រាហ្មណ៍នេះឯង ជាអ្នកសាងនូវ*

សេចក្តីល្អក្រៃលែងមកហើយ ជាសត្វដែលកើតក្នុងភពចុងក្រោយ មានបញ្ញាក្រៃលែងជាងព្រាហ្មណ៍ទាំង ៧ នាក់ បានឃើញគតិមួយប៉ុណ្ណោះថា សម្រាប់បុគ្គលដែលប្រកបដោយលក្ខណៈទាំងនេះ មិនមានឋានៈដែលតាំងនៅក្នុងកណ្តាលផ្ទះ នឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ព្រោះដូច្នោះ ទើបលើកម្រាមមួយឡើងហើយព្យាករតែម្យ៉ាង ។ ក្រោយមកពួកព្រាហ្មណ៍ទាំងនោះ ត្រឡប់ទៅកាន់ផ្ទះរៀងៗ ខ្លួន ហើយហៅកូនរបស់ខ្លួនមកថា នែបាទាំងឡាយ ឪពុកចាស់ហើយ មិនដឹងជាបានទាន់បានឃើញព្រះរាជបុត្ររបស់ព្រះបាទសុទ្ធោទនមហារាជ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណឬក៏អត់នោះទេ ពួកអ្នក កាលព្រះរាជកុមារអង្គនេះ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ គប្បីបួសក្នុងសាសនារបស់ព្រះអង្គចុះ ។ ជនទាំង ៧ នាក់នោះ តាំងនៅជរាបដល់អស់អាយុក្ខ័យ ហើយក៏ទៅតាមយថាកម្ម ។ កោណ្ឌញ្ញមាណពប៉ុណ្ណោះ មិនមានរោគភ័យ មិនមានជំងឺជម្ងាត់ ក៏មានជីវិតរស់នៅរហូតមក ។ កាលព្រះមហាសត្វទ្រង់ធំចម្រើនវ័យហើយ ទ្រង់ចេញមហាភិនិស្ក្រមណ៍ ទ្រង់យាងទៅកាន់ឧរុវេលាប្រទេសតាមលំដាប់ ទ្រង់កើតព្រះតម្រិះថា ភូមិភាគនេះ គួរជាទីត្រេកអរពិតហ្ន៎ ស្ថានទីនេះឯង សមគួរជាទីកន្លែងសម្រាប់បំពេញព្យាយាមរបស់កុលបុត្រដែលត្រូវការសេចក្តីព្យាយាម ដូច្នេះហើយ ទ្រង់ក៏ចាំវស្សាក្នុងទីនោះ ។ កោណ្ឌញ្ញព្រាហ្មណ៍បានដំណឹងថា ព្រះមហាសត្វទ្រង់

បួសហើយ ក៏ចូលទៅរកកូនរបស់ព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះថា បានឮថា ព្រះសិទ្ធត្ថកុមារទ្រង់ចេញបួសហើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ បើលោកពុករបស់អ្នកទាំងឡាយនៅមានជីវិត ពួកគាត់គប្បីចេញបួសក្នុងថ្ងៃនេះឯង បើពួកអ្នកត្រូវការបែបនោះ មកយើងនឹងបួសតាមព្រះមហាបុរសនោះ ។ ពួកជនទាំងនោះ មិនអាចយើញដោយឯកច្ឆន្ទ ចំណែកបុគ្គលខ្លះបួស បុគ្គលខ្លះមិនបួស កូនព្រាហ្មណ៍ ៣ នាក់មិនបួស កូនព្រាហ្មណ៍ ៤ នាក់ក៏បួស មានកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន ជនទាំង ៥ នាក់នោះក៏មានឈ្មោះថា បញ្ចវគ្គិយត្ថេរ ។

ក្នុងកាលនោះ ព្រះរាជាត្រាស់សួរថា កូនរបស់យើងឃើញអ្វី ទើបបួស ?

ពួកអាមាត្យក៏ក្រាបទូលថា ព្រោះឃើញបុព្វនិមិត្ត ៤ ប្រការ ។

ព្រះរាជាក៏ត្រាស់សួរថា បុព្វនិមិត្ត ៤ ប្រការ នោះគឺអ្វីខ្លះ ?

ពួកអាមាត្យក្រាបទូលថា គឺ មនុស្សចាស់ជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ និងភេទអ្នកបួស ១ ។

ព្រះរាជាត្រាស់ថា ចាប់តាំងអំពីថ្ងៃនេះទៅ ពួកអ្នកកុំឲ្យនិមិត្តបែបនេះ ចូលមកក្នុងសម្នាក់របស់កូនយើង យើងមិនត្រូវការឲ្យកូនរបស់យើងត្រាស់ជាព្រះពុទ្ធទេ យើងត្រូវការឃើញកូនរបស់យើងគ្រប់គ្រងរាជសម្បត្តិដែលជាធំ ក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២ ពាន់ជាបរិវារ ចោមរោម

ទៅដោយបរិស័ទ មានបរិមណ្ឌលប្រមាណ ៣៦ យោជន៍ ត្រាច់ទៅក្នុងអាកាស ។ កាលព្រះរាជាត្រាស់យ៉ាងនេះហើយ ទ្រង់បញ្ជាឲ្យគេរក្សាក្នុងទីគ្រប់ៗ មួយគាវុត ក្នុងទិសទាំង ៤ ដើម្បីហាមមិនឲ្យបរិស័ទ ៤ ប្រការនោះ ចូលមកកាន់គន្លងចក្ខុរបស់ព្រះរាជកុមារ ។ ក្នុងថ្ងៃនោះ កាលត្រកូលញាតិ ៨ ម៉ឺនប្រជុំគ្នាក្នុងមង្គលស្ថាន ព្រះញាតិនីមួយៗ ត្រេកអរក៏លើកបុត្តឲ្យមួយអង្គៗ ថា ព្រះរាជកុមារសិទ្ធត្ថនេះ បានត្រាស់ជាព្រះពុទ្ធក្តី បានជាស្តេចក្តី ពួកយើងនឹងថ្វាយបុត្តម្នាក់មួយៗ បើបានត្រាស់ជាព្រះពុទ្ធ ក៏នឹងមានសមណក្សត្រឲ្យកិត្តិយសហែហមព្រះអង្គទៅ បើបានជាព្រះរាជាក៏នឹងមានខត្តិយកុមារហែហមត្រាច់ទៅ ។ ចំណែកព្រះរាជាទ្រង់តាំងស្នំសុទ្ធតែមានរូបរាងស្រស់បស់ ប្រាសចាកទោសសព្វប្រការដល់ព្រះពោធិសត្វ ។ ព្រះមហាសត្វ ទ្រង់ចម្រើនវ័យដោយបរិវារជាច្រើនសុទ្ធតែល្អៗ ក្រៃលែង ដូច្នេះ ។

ថ្ងៃមួយ ព្រះរាជាមានព្រះរាជពិធីវប្បមង្គល ( ពិធីច្រត់ព្រះនង្គ័ល ) ថ្ងៃនោះ ពួកអ្នកនគរនាំគ្នាប្រដាប់តាក់តែងនគរគ្រប់អន្លើ ហាក់ដូចជាទេវវិមាន ពួកទាសៈនិងពួកកម្មករទាំងអស់នាំគ្នាស្លៀកសំពត់ថ្មី ប្រដាប់ដោយផ្កាកម្រង និងគ្រឿងក្រអូប ប្រជុំគ្នាក្នុងរាជត្រកូល ។ ក្នុងរាជពិធីនោះ មានការទឹមនង្គ័ល ១ ពាន់ ក្នុងថ្ងៃនោះ នង្គ័ល ១០៨ ខ្វះមួយ ( ១០៧ ) ស្រោបដោយប្រាក់ មួយអន្លើដោយគោឈ្មោល ខ្សែទាមនិង

ខ្សែបរ ចំណែកចន្ទោលនង្គ័លរបស់ព្រះរាជាស្រោបដោយមាស ស្នែង
របស់គោ ខ្សែទាម ខ្សែបរ និងជន្ទួញ ស្រោបដោយមាសទាំងអស់ ។
ព្រះរាជាមួយអន្លើដោយបរិវារជាច្រើនយាងចេញអំពីនគរ ទ្រង់នាំព្រះ
រាជឱរសទៅផងដែរ ។ ក្នុងទីប្រកបព្រះរាជពិធីនោះ មានដើមព្រីងមួយ
ដើម មានស្លឹកត្រសាយត្រសុំបរិបូណ៌ដោយម្លប់ ខាងក្រោមដើមព្រីងនោះ
ព្រះរាជា ទ្រង់ត្រាស់ឲ្យក្រាលទែនព្រះបន្ទំរបស់ព្រះរាជឱរស ខាងលើឲ្យ
ចងពិដានព្យួរដោយផ្កាយមាស ឲ្យចងរាំងននព័ទ្ធជុំវិញ ធ្វើនូវការរក្សា
ចំណែកព្រះអង្គ ទ្រង់ប្រដាប់ដោយគ្រឿងអលង្ការគ្រប់សព្វ មានពួកអា-
មាត្យចោមរោម យាងទៅកាន់ទីច្រត់ព្រះនង្គ័ល ។ ក្នុងទីនោះ ព្រះរាជា
ទ្រង់កាន់នង្គ័លដែលស្រោបដោយមាស ពួកអាមាត្យកាន់នង្គ័លប្រាក់
១០៧ ពួកអ្នកស្រែក៏នាំគ្នាកាន់នង្គ័លដ៏សេស ជនទាំងនោះ កាន់នង្គ័ល
ភ្ជួរទៅខាងនោះខ្លះ ខាងនេះខ្លះ តែព្រះរាជា ទ្រង់ភ្ជួរក្នុងគន្លងខាងក្រៅ
ចេញអំពីគន្លងខាងក្រៅ ក៏ចូលកាន់គន្លងខាងក្នុង ក្នុងពេលនោះ មាន
មហាសម្បត្តិ ។ ស្រីស្នំអង្គុយចោមរោមព្រះពោធិសត្វ ក៏នាំគ្នាចេញមក
ខាងក្រៅអំពីខាងក្នុងរាំងនន ដោយគិតថា ពួកយើងនឹងមើលសម្បត្តិ
របស់ព្រះរាជា ។ ព្រះពោធិសត្វទតក្នុងទីផ្សេងៗ មិនឃើញមានបុគ្គល
ណាមួយ ក៏ក្រោកឡើងដោយរហ័ស ទ្រង់គង់ពត់ភ្នែនកំណត់ខ្យល់ដង្ហើម
ចេញចូល ធ្វើបឋមជ្ឈានឲ្យកើតឡើងហើយ ។ ពួកស្រីស្នំនាំគ្នាត្រាច់ទៅ

ក្នុងវាងកាលបរិភោគអាហារយើតយូរបន្តិច ។ ស្រមោលរបស់ដើមឈើដ៏សេសជ្រេទៅ ចំណែកស្រមោលរបស់ដើមព្រីងនោះ តាំងនៅជាបរិ-មណ្ឌលដដែល ។ ពួកស្រីស្នំរឭកបានថា ព្រះអយ្យបុត្តប្រថាប់នៅមួយអន្លើឯង ក៏ប្រញាប់បើកវាំងននចូលទៅខាងក្នុង ឃើញព្រះបរមពោធិសត្វគង់ពត់ភ្នែនលើទៃនព្រះបន្ទំនិងបាដិហារិយ៍នោះ ទើបទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារប្រថាប់គង់យ៉ាងនេះ ស្រមោលរបស់ដើមឈើដទៃជ្រេទៅ ស្រមោលរបស់ដើមព្រីងតាំងនៅជាបរិមណ្ឌលដដែល ។ ព្រះរាជាប្រញាប់ស្រូតមក ទ្រង់ទតឃើញបាដិ-ហារិយ៍នោះ ទើបត្រាស់ថា នែបា នេះជាការថ្វាយបង្គំលើកទី ២ របស់ខ្ញុំចំពោះអយ្យបុត្ត ។

ចំណេរតមក ព្រះមហាបុរសមានព្រះជន្មាយុបាន ១៦ ព្រះវស្សាដោយលំដាប់ ព្រះរាជា ទ្រង់ត្រាស់ឲ្យសាងប្រាសាទ ៣ ខ្នង ឲ្យសមតាមរដូវ គឺប្រាសាទមួយខ្នងមាន ៩ ជាន់ ប្រាសាទមួយខ្នងមាន ៧ ជាន់ ប្រាសាទមួយខ្នងមាន ៥ ជាន់ និងឲ្យស្ត្រីរបាំចំនួន ៤ ម៉ឺននាក់ចាំបម្រើ ។ ព្រះពោធិសត្វមានស្ត្រីរបាំដែលតែងខ្លួនស្រស់ស្អាតចោមរោម ហាក់បីដូចជាទេវបុត្តដែលចោមរោមដោយស្រីទេពអប្សរដូច្នោះ ព្រះពោធិសត្វត្រូវគេបម្រើដោយតូរ្យតន្ត្រី មិនមានបុរសឡើយ ទ្រង់សោយសម្បត្តិធំ ប្រថាប់គង់ក្នុងប្រាសាទទាំងនោះតាមកាលនៃរដូវ ចំណែករាហុលមាតាបានជា

អគ្គមហេសីរបស់ព្រះអង្គ ។ ថ្ងៃមួយ កាលព្រះពោធិសត្វកំពុងសោយមហាសម្បត្តិ មានពាក្យនិយាយឡើងក្នុងរវាងព្រះញាតិយ៉ាងនេះថា ព្រះសិទ្ធត្ថ ទ្រង់ខ្វល់ខ្វាយតែនឹងការលេងប៉ុណ្ណោះ មិនបានសិក្សាសិប្បៈណាមួយ កាលបើកើតសង្គ្រាមឡើងនឹងធ្វើដូចម្តេច ? ព្រះរាជាទ្រង់ត្រាស់ឲ្យហៅព្រះពោធិសត្វមក ហើយត្រាស់ថា នែបា ពួកញាតិរបស់កូននាំគ្នាពោលថា ព្រះសិទ្ធត្ថមិនបានសិក្សាសិប្បៈណាសោះ ខ្វល់ខ្វាយតែនឹងការលេងដូច្នេះ កូនឃើញថាដល់ការដែលគួរហើយឬនៅ ?

ព្រះបរមពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមានកិច្ចដែលត្រូវសិក្សាសិប្បៈ សូមទ្រង់ឲ្យវាយស្គរប្រកាសទៅក្នុងនគរ ដើម្បីឲ្យមហាជនមកមើលការសម្តែងសិប្បៈរបស់ទូលបង្គំចុះ បន្ទាប់អំពីថ្ងៃនេះទៅ ៧ ថ្ងៃទៀត ទូលបង្គំនឹងសម្តែងសិប្បៈដល់ញាតិទាំងឡាយ ព្រះរាជាទ្រង់បានធ្វើតាមនោះ ។ លុះ ៧ ថ្ងៃកន្លងទៅ អ្នកនគរមួយអន្លើដោយព្រះញាតិ មកប្រជុំគ្នាហើយក្នុងលានព្រះរាជវាំងដោយគិតថា ពួកយើងនឹងមើលការសម្តែងសិល្បសាស្ត្រ ។

ព្រះរាជាត្រាស់ថា នែសិទ្ធត្ថ ចូរកូនសម្តែងសិប្បៈចុះ ។

ព្រះសិទ្ធត្ថកុមារក្រាបទូលថា បពិត្រព្រះសម្មតិទេព បណ្តានាយខ្មាន់ធ្នូរបស់ព្រះអង្គ សូមទ្រង់ឲ្យនាយខ្មាន់ធ្នូ ៤ នាក់ គឺអ្នកដែលបាញ់ដូចផ្ទេកបន្ទោរ ១ អ្នកបាញ់មិនខុស សូម្បីតែរោមទ្រាយក៏បាញ់បាន ១ អ្នក

បាញ់បានតាមសំឡេង ១ និងអ្នកបាញ់បំបាក់ព្រួញដែលបាញ់មក ១ ។ ព្រះរាជា ទ្រង់ឲ្យហៅជនទាំង ៤ នោះមក ។ ព្រះបរមពោធិសត្វ ទ្រង់សម្ដែងសិប្បៈ ១២ យ៉ាង ដែលនាយខ្មាន់ធ្នូដទៃមិនអាចធ្វើបាន ដល់ព្រះញាតិទាំងឡាយក្នុងកណ្ដាលមហាជន សេចក្ដីនេះ គប្បីជ្រាបតាមន័យក្នុង **សរភង្គជាតក** ថា

ព្រះមហាសត្វឲ្យរៀបចំមណ្ឌបខាងក្នុងទីកំណត់ ៤ ជ្រុង ក្នុងលានព្រះរាជវាំង ឲ្យនាយខ្មាន់ធ្នូទាំង ៤ ឈរក្នុងទិសទាំង ៤ ហើយឲ្យព្រួញម្នាក់ ៣ ម៉ឺនព្រួញ ដល់ខ្មាន់ធ្នូនីមួយៗ ឲ្យអ្នកឈរចាំហុចព្រួញម្នាក់មួយឈរក្បែរខ្មាន់ធ្នូនោះ ហើយព្រះបរមពោធិសត្វកាន់ព្រួញដែលមានចុងដូចពេជ្រ ឈរត្រង់កណ្ដាលមណ្ឌប ក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ខ្មាន់ធ្នូទាំង ៤ នេះ ចូរបាញ់ទូលបង្គំព្រមគ្នាចុះ ទូលបង្គំនឹងឃាត់ព្រួញដែលជនទាំងនេះបាញ់មក ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរធ្វើយ៉ាងនេះ ។

ពួកនាយខ្មាន់ធ្នូទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំជានាយខ្មាន់ធ្នូ បាញ់រហ័សដូចផ្លេកបន្ទោរ បាញ់មិនខុស សូម្បីត្រឹមតែរោមទ្រាយបាញ់តាមសំឡេងដែលបានឮ បាញ់បំបាក់ព្រួញដែលគេបាញ់មក ព្រះសិទ្ធត្ថជាកំលោះ ទូលបង្គំមិនហ៊ានបាញ់ឡើយ ។

ព្រះមហាសត្វពោលថា បើពួកលោកអាច អញ្ជើញបាញ់ខ្ញុំចុះ ។

ខ្មាន់ធ្នូទាំងនោះទទួលថា សាធុ ទើបលែងព្រួញទាំងនោះព្រមគ្នា ។ ព្រះមហាសត្វយកព្រួញចុងពេជ្រ វាយព្រួញទាំងនោះ ឲ្យធ្លាក់ចុះក្នុងទិសទាំង ៤ ដូចធ្វើរបងព័ទ្ធគល់ពោធិព្រឹក្ស ឲ្យគល់ព្រួញទៅតាមគល់ព្រួញ ខ្នងព្រួញទៅតាមខ្នងព្រួញ ចុងព្រួញទៅតាមចុងព្រួញ មិនឲ្យបញ្រ្ចាសទិសគ្នា បានធ្វើដូចជាបន្ទប់ព្រួញ រហូតព្រួញរបស់នាយខ្មាន់ធ្នូបាញ់មកអស់ ។ ព្រះមហាបុរសដឹងថា ព្រួញរបស់នាយខ្មាន់ធ្នូអស់ហើយ មិនញាំងបន្ទប់ព្រួញឲ្យបែកធ្លាយ លោតឡើងទៅឈរគាល់ក្បែរព្រះរាជា មហាជននាំគ្នាហ៊ោកញ្ជ្រៀវទះដៃកងរំពង ផ្ទាត់ម្រាមដៃ ធ្វើកោលាហល បោះសំពត់និងគ្រឿងអករណៈឡើងទៅលើ រហូតមានទ្រព្យ ១៨ កោដិកើតមកជាគំនរយ៉ាងនេះ ។ សម័យនោះ ព្រះរាជាត្រាស់សួរព្រះសិទ្ធត្ថកុមារថា នែ បាសិទ្ធត្ថ នេះគេហៅសិប្បៈអ្វី ?

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះឈ្មោះថា សរបដិពាហនៈ គឺគ្រឿងឃាត់កូនសរ ។

ព្រះរាជាត្រាស់សួរថា អ្នកដទៃដែលធ្វើបានយ៉ាងនេះ មានឬ ?

ព្រះមហាបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បើវៀរទូលបង្គំចេញហើយ អ្នកដទៃក្នុងជម្ពូទ្វីបទាំងមូល មិនមានឡើយ ។

ព្រះរាជាត្រាស់សួរថា បុត្តនឹងសម្ដែងសិប្បៈអ្វីទៀត ?

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព បើនាយខ្មាន់ធ្នូ

ទាំង ៤ ឈរក្នុងទិសទាំង ៤ មិនអាចបាញ់ទូលបង្គំបានសោត បពិត្រព្រះអង្គ ទូលបង្គំនឹងបាញ់ជនទាំង ៤ ដែលឈរក្នុងទិសទាំង ៤ ដោយព្រួញមួយប៉ុណ្ណោះ ។ នាយខ្មាន់ធ្នូទាំងនោះ មិនហ៊ានឈរក្នុងទិសទាំង ៤ ឡើយ ។

ព្រះមហាសត្វ ទ្រង់ឲ្យយកដើមចេកដាក់តាមជ្រុងទាំង ៤ ហើយយកអំបោះពណ៌ក្រហមចងព្រួញ បាញ់ដើមចេក ១ ព្រួញធ្លុះហើយត្រូវដើមចេក ១ ដើមទៀត ហើយបត់ទៅរកដើមចេកទី ៣ វិលមកត្រូវដើមចេកទី ៤ ហើយវិលមកធ្លុះដើមចេកទី ១ ព្រួញក៏មកតាំងនៅក្នុងដៃព្រះអង្គវិញ ដើមចេកទាំងឡាយត្រូវអំបោះដោតហើយតាំងនៅបាន មហាជនបន្លឺសំឡេងកញ្រ្កើករំពើករាប់ពាន់ ។ ព្រះរាជាត្រាស់សួរថា នេះគេហៅសិប្បៈអ្វី ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះឈ្មោះថា ចក្កវិទ្ធសិប្បៈ គឺបាញ់ឲ្យព្រួញរត់ជារង្វង់ដូចចក្រ ។

ព្រះរាជាត្រាស់ថា ចូរកូនសម្ដែងសិប្បៈដទៃទៀតចុះ ។

ព្រះមហាសត្វក៏សម្ដែងសិប្បៈឈ្មោះ សរលដ្ឋិ គឺសិប្បៈឈើច្រត់ ( បាញ់ព្រួញជាច្រើនទៅលើអាកាស ឲ្យឃើញជារូបឈើច្រត់ ) សិប្បៈឈ្មោះសររជ្ជុ គឺសិប្បៈជារូបខ្សែ សិប្បៈឈ្មោះសរវេធិ គឺសិប្បៈផ្ទួងសក់ សិប្បៈឈ្មោះសរបាសាទៈ គឺសិប្បៈរូបប្រាសាទ សិប្បៈឈ្មោះសរមណ្ឌប

គឺសិប្បៈរូបមណ្ឌប សិប្បៈឈ្មោះសរសោបាន គឺសិប្បៈរូបជណ្ដើរ សិប្បៈឈ្មោះសរបាការ គឺសិប្បៈរូបកំពែង សិប្បៈឈ្មោះសរវន គឺសិប្បៈរូបព្រៃ សិប្បៈឈ្មោះសរបោក្ខរណី គឺសិប្បៈរូបស្រះបោក្ខរណី សិប្បៈឈ្មោះសរ-បទុម គឺសិប្បៈរូបផ្កាឈូក ឬសិប្បៈរូបផ្កាឈើ សិប្បៈឈ្មោះសរវស្ស គឺសិប្បៈភ្លៀងព្រួញ ។ កាលព្រះមហាបុរសសម្ដែងសិប្បៈ ១២ យ៉ាង មិនទូទៅដល់មហាជនយ៉ាងនេះហើយ ទម្លាយនូវប្រជុំធំ ៧ ដង ដែលមិនទូទៅដល់ជនដទៃ ។ ព្រះមហាសត្វបាញ់ឈើល្វាកម្រាស់ ៨ ធ្នាប់ បាញ់ឈើធ្នង់កម្រាស់ ៤ ធ្នាប់ បាញ់ទង់ដែងកម្រាស់ ២ ធ្នាប់ បាញ់បន្ទះដែកកម្រាស់ ១ ធ្នាប់ បាញ់បន្ទះក្ដារ ១០០ ឲ្យដោតជាប់គ្នាដោយព្រួញតែមួយ បាញ់ព្រួញអំពីខាងមុខរទេះដែលដាក់ស្មឹកឈើ រទេះដែលដាក់ខ្សាច់ និងរទេះដែលដាក់បន្ទះក្ដារ ឲ្យធ្លុះចេញទៅខាងក្រោយ បាញ់ពីក្រោយឲ្យធ្លុះទៅខាងមុខ បាញ់ទៅក្នុងទឹកចម្ងាយ ៤ ឧសភ បាញ់ទៅលើគោកចម្ងាយ ៨ ឧសភ បាញ់រោមទ្រាយក្នុងចម្ងាយ ១ យោជន៍ ដោយដាក់ផ្ទៃត្រប់ជាសញ្ញា[១] និងទីបំផុត ទ្រង់ឲ្យយកធ្នូសហស្សថាម ជាធ្នូ

---

១- ស្រង់ចាកសរភង្គជាតក តែក្នុងសរភង្គជាតកនោះ ព្រះពោធិសត្វបាញ់រោមទ្រាយត្រឹមចម្ងាយ ១ ឧសភប៉ុណ្ណោះ តែក្នុងជាតិជាព្រះសិទ្ធត្ថបាញ់ក្នុងទីចម្ងាយ ១ យោជន៍ ( អដ្ឋកថា សុខុមាលសូត្រ ) ។

តម្កល់ទុកអំពីបុរាណ ដ្បិតធ្នូនេះ ទាល់តែកម្លាំងបុរស ១ ពាន់នាក់ ទើបអាចលើកឡើងហើយបាញ់បាន ។ ជាធម្មតាកម្លាំងរបស់ព្រះពោធិសត្វស្មើនឹងកម្លាំងដំរីឆទ្ទន្ត ១០ ។ បានឮថា កម្លាំងបុរស ១០ នាក់ ស្មើនឹងដំរីត្រកូលកាឡាវកៈ ១ កម្លាំងដំរីត្រកូលកាឡាវកៈ ១០ ស្មើនឹងដំរីត្រកូលគង្គេយ្យៈ ១ កម្លាំងដំរីត្រកូលគង្គេយ្យៈ ១០ ស្មើនឹងដំរីត្រកូលបណ្ឌរៈ ១ កម្លាំងដំរីត្រកូលបណ្ឌរៈ ១០ ស្មើនឹងដំរីត្រកូលតម្ពៈ ១ កម្លាំងដំរីត្រកូលតម្ពៈ ១០ ស្មើនឹងដំរីត្រកូលបិង្គលៈ ១ កម្លាំងដំរីត្រកូលបិង្គលៈ ១០ ស្មើនឹងដំរីត្រកូលគន្ធៈ ១ កម្លាំងដំរីត្រកូលគន្ធៈ ១០ ស្មើនឹងដំរីត្រកូលមង្គលៈ ១ កម្លាំងដំរីត្រកូលមង្គលៈ ១០ ស្មើនឹងដំរីត្រកូលហេមៈ ១ កម្លាំងដំរីត្រកូលហេមៈ ១០ ស្មើនឹងដំរីត្រកូលឧបោសថ ១ កម្លាំងដំរីត្រកូលឧបោសថ ១០ ស្មើនឹងដំរីត្រកូលឆទ្ទន្តៈ ១ កម្លាំងដំរីត្រកូលឆទ្ទន្តៈ ១០ ទើបស្មើនឹងកម្លាំងព្រះពោធិសត្វ ១ អង្គ [១] ។ ព្រះរាជាឲ្យមនុស្ស ១ ពាន់នាក់សែងធ្នូសហស្សថាមមក ព្រះបរមពោធិសត្វយកដើងធ្នឹះធ្នូឡើង ចាប់ដោយព្រះហស្តឆ្វេង យឹតដោយព្រះហស្តស្តាំ បាញ់ហើយ ។ ស្នូរបន្ទោះធ្នូដែលព្រះពោធិសត្វយឹតហើយ រត់ទៅរកសភាពដើមវិញ លាន់ឮកក្រើកនគរកបិលពស្តុ [២] ។ ក្នុងកាលនោះ ពួកព្រះញាតិរបស់ព្រះអង្គក៏អស់

១- ស្រង់ចាកអដ្ឋកថា មហាសីហនាទសូត្រ ។ ២- ស្រង់ចាកអដ្ឋកថា សុខុមាលសូត្រ ។

សេចក្ដីសង្ស័យហើយ ។

ថ្ងៃមួយ ព្រះពោធិសត្វមានបំណងនឹងយាងទៅកាន់ភូមិភាគក្នុងឧទ្យាន ទើបហៅនាយសារថីមកហើយត្រាស់ថា ចូរទឹមរថ ។ នាយសារថីពោលថា សាធុ ហើយប្រដាប់រថដែលល្អបំផុត មានតម្លៃច្រើន ដោយគ្រឿងអលង្ការគ្រប់ប្រភេទ ទឹមដោយសេះសិន្ធពដ៏ជាមង្គល ៤ ដែលមានពណ៌ដូចផ្កាកុមុទស្រេចហើយ ក៏ទៅក្រាបទូលដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វទ្រង់ឡើងរថ ដូចគ្នានឹងទេវវិមាន បែរព្រះភក្ត្រទៅកាន់ព្រះរាជឧទ្យាន ទេវតាទាំងឡាយគិតថា កាលនៃការត្រាស់ដឹងរបស់ព្រះសិទ្ធត្ថរាជកុមារជិតចូលមកដល់ហើយ ពួកយើងនឹងសម្ដែងបុព្វនិមិត្ត ហើយឲ្យទេវបុត្តមួយអង្គ កាឡាខ្លួនធ្វើជាមនុស្សចាស់ជរា មានធ្មេញបាក់ សក់ស្កូវ ខ្នងកោងដូចបង្កង់ផ្ទះ មានខ្លួនឱនចុះ មានដៃកាន់ឈើច្រត់ ដើរទ្រើកៗ ព្រះមហាបុរសនិងសារថីបានទតឃើញសភាពបែបនោះ ។ ពេលនោះ ព្រះពោធិសត្វត្រាស់សួរតាមន័យដែលមានមកហើយក្នុង **គម្ពីរអបទាន** នោះថា នែសារថីសម្លាញ់ បុរសនេះ ឈ្មោះអ្វី សូម្បីតែសក់របស់គេក៏មិនដូចសក់របស់ពួកជនដទៃ ដូច្នេះ ទ្រង់ស្ដាប់ពាក្យរបស់នាយសារថីហើយ ទ្រង់មានព្រះទ័យសង្វេគ ត្រាស់ថា នែសម្លាញ់ គួរតិះដៀលការកើតនេះណាស់ហ្ន៎ ការចាស់នឹងត្រូវប្រាកដដល់សត្វដែលកើតហើយយ៉ាងពិតប្រាកដ ដូច្នេះហើយ ទ្រង់ត្រឡប់អំពីព្រះរាជឧទ្យានឡើងកាន់

ប្រាសាទវិញ ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វីទើបកូនរបស់យើងឆាប់ត្រឡប់ម៉្លេះ ?

ពួកអាមាត្យក្រាបទូលថា ព្រោះទ្រង់ទតឃើញមនុស្សចាស់ ។

ព្រះរាជាត្រាស់ថា ពួកអ្នកពោលថា កូនរបស់យើងឃើញមនុស្សចាស់ហើយបួស ចុះហេតុអ្វីទើបមកទម្លាយយើងដូច្នេះ ចូរប្រញាប់រកអ្នករបាំមកសម្តែងដល់កូនរបស់យើង កូនយើងសោយសម្បត្តិនឹងមិននឹកនាដល់ការចេញបួស ហើយឲ្យបន្ថែមការរក្សាទ្វេឡើង គ្រប់ៗ កន្ទះយោជន៍និងក្នុងគ្រប់ទិសទាំងឡាយ ។ ស្អែកឡើង ព្រះពោធិសត្វទ្រង់យាងទៅកាន់ព្រះរាជឧទ្យានដូចមុននោះទៀត ទតឃើញមនុស្សឈឺដែលពួកទេវតានិម្មិត ទើបត្រាស់សួរដោយន័យមុននោះ ទ្រង់មានព្រះទ័យសង្វេគហើយត្រឡប់ឡើងកាន់ប្រាសាទ ។ ចំណែកព្រះរាជាក៏ត្រាស់សួរហើយទ្រង់ចាត់ចែងតាមន័យដែលពោលហើយខាងដើមនោះឯង ទ្រង់ដាក់ការរក្សាបន្ថែមឡើងទៀត ក្នុងទីប្រមាណ ៣ គាវុតដោយជុំវិញ ។ លុះថ្ងៃបន្ទាប់មកទៀត ព្រះពោធិសត្វយាងទៅកាន់ព្រះរាជឧទ្យាន ទតឃើញមនុស្សស្លាប់ដែលទេវតានិម្មិតឡើង ត្រាស់សួរដោយន័យមុននោះទៀតមានព្រះទ័យសង្វេគហើយ ទ្រង់យាងត្រឡប់ឡើងកាន់ប្រាសាទដូចមុន ។ ចំណែកព្រះរាជា ទ្រង់ត្រាស់សួរហើយ ក៏ចាត់ចែងតាមន័យដែលបានពោលហើយខាងដើមនោះឯង ទ្រង់ឲ្យធ្វើការរក្សាបន្ថែមឡើងទៀតក្នុងទី

ប្រមាណមួយយោជន៍ដោយជុំវិញ ។ ក្នុងថ្ងៃតមកទៀត ព្រះពោធិសត្វ យាងទៅកាន់ព្រះរាជឧទ្យាន បានទតឃើញបព្វជិតស្លៀកដណ្ដប់រៀបរយ ដែលទេវតានិម្មិតឡើងដូចមុននោះទៀត ទើបត្រាស់សួរនាយសារថីថា នៃសារថីសម្លាញ់ បុរសនេះ ឈ្មោះអ្វី ? សារថីមិនជ្រាបដល់ភាពជាបព្វជិត ឬអ្នកដែលជាបព្វជិតឡើយ ព្រោះមិនមានការកើតឡើងនៃព្រះពុទ្ធក៏ពិត តែដោយអានុភាពរបស់ទេវតា ទើបក្រាបទូលថា មនុស្សនេះគេហៅថា បព្វជិត ព្រះអង្គ ហើយពណ៌នាគុណនៃការចេញបួស ( ធ្វើឲ្យ ) ព្រះពោធិសត្វកើតនូវការពេញព្រះទ័យក្នុងការចេញបព្វជ្ជា ទ្រង់បានយាងទៅកាន់ព្រះរាជឧទ្យានក្នុងថ្ងៃនោះ តែលោកពោលក្នុង **គម្ពីរទីឃនិកាយ** ថា ព្រះពោធិសត្វបានទតឃើញនិមិត្តទាំង ៤ ក្នុងថ្ងៃមួយប៉ុណ្ណោះ ។ ព្រះមហាបុរសយាងក្រសាលក្នុងឧទ្យានពេញមួយថ្ងៃ ទ្រង់ស្រង់ទឹកក្នុងស្រះបោក្ខរណីដែលជាមង្គល កាលព្រះអាទិត្យអស្តង្គតហើយ ទ្រង់ប្រថាប់គង់លើផ្ទាំងថ្មដ៏ជាមង្គល មានបំណងនឹងប្រដាប់ព្រះកាយ ។ ពេលនោះ ពួកបរិចារិកៈរបស់ព្រះអង្គ នាំគ្នាកាន់យកសំពត់មានពណ៌ផ្សេងៗ និងគ្រឿងអាភរណៈជាច្រើន មានផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបមកឈរចោមរោមដោយជុំវិញ ។ ក្នុងខណៈនោះ អាសនៈដែលជាទីប្រថាប់គង់របស់សក្កទេវរាជបានក្ដៅឡើង ទ្រង់ពិចារណាមើលថា អ្នកណាហ្ន៎ មានបំណងនឹងឲ្យអញឃ្លាតចាកអាសនៈនេះ ក៏ទតឃើញកាល

ដែលនឹងត្រូវប្រដាប់ ( ចុងក្រោយ ) របស់ព្រះមហាបុរស ទើបត្រាស់ហៅវិស្សុកម្មទេវបុត្តមកថា នែវិស្សុកម្មសម្លាញ់ ថ្ងៃនេះ ព្រះសិទ្ធត្ថរាជកុមារនឹងចេញមហាភិនិក្ខមណ៍ក្នុងកណ្ដាលអធ្រាត្រ នេះជាគ្រឿងប្រដាប់ចុងក្រោយរបស់ទ្រង់ ចូរអ្នកទៅកាន់ព្រះរាជឧទ្យាន ជួបព្រះមហាបុរសហើយចូរប្រដាប់នូវគ្រឿងប្រដាប់គ្រប់ប្រភេទទាំងនេះ ។ វិស្សុកម្មទេវបុត្តទទួលព្រះតម្រាស់ថា សាធុ ហើយក៏ចូលទៅក្នុងខណៈនោះ ដោយទេវានុភាព ដំណែងខ្លួនជាអ្នកកោរកាត់របស់ព្រះអង្គ ហើយទទួលយកសំពត់ជូតក្បាលពីដៃរបស់ជាងកោរកាត់ មកព័ទ្ធព័ន្ធព្រះសិរសារបស់ព្រះពោធិសត្វ ។ ព្រះមហាបុរស ទ្រង់ជ្រាបដោយសម្ផស្សនៃដៃប៉ុណ្ណោះថា បុរសនេះមិនមែនជាមនុស្ស ជាទេវបុត្តដោយពិត គ្រាន់តែសំពត់ជូតក្បាលបានពាល់ត្រូវព្រះសិរសា សំពត់នោះក៏វិលខ្ពស់ឡើងដោយអាការដូចកែវមណីត្រង់ព្រះមោលីលើព្រះសិរសា កាលព័ទ្ធព័ន្ធ ១ ជុំទៀត ក៏ជាសំពត់ ១ ពាន់ព័ទ្ធព័ន្ធ ១០ ដង ក៏ជាសំពត់ ១ ម៉ឺន ។ មិនគួរគិតថា ព្រះសិរសាតូចសំពត់មានច្រើន តើនឹងរុំខ្ពស់ឡើងបានដូចម្ដេច បណ្ដាសំពត់ទាំងនោះសំពត់ដែលធំបំផុត មានប្រមាណប៉ុនផ្កានៃវល្លិអាមលតា សំពត់ដែលសេសសល់ក្រៅអំពីនេះ ប្រមាណប៉ុនផ្កាកុសុម្ភកៈ ព្រះសិរសារបស់ព្រះពោធិសត្វពោរពេញដោយសក់ ដែលមានពណ៌ដូចផ្កាសារភី ក្រាស់ទៅដោយកេសរ ។ បន្ទាប់មក កាលពួកភ្នាក់ងារតូរ្យតន្ត្រីសម្ដែងបដិភាណ

*គឺភាពវៃឆ្លាតរៀងៗខ្លួន កាលពួកព្រាហ្មណ៍ពោលសរសើរដោយពាក្យជាដើមថា បពិត្រព្រះអង្គជាធំជាងជន សូមទ្រង់មានជ័យជម្នះចុះ កាលពួកសារថី និងពួកអ្នកពោលមង្គលជាដើម ពោលសរសើរដោយពាក្យសម្ដីដែលជាមង្គល ពាក្យសរសើរ និងពាក្យប្រកាសជាអនេកប្បការដល់ព្រះបរមពោធិសត្វ ដែលប្រដាប់តាក់តែងហើយដោយគ្រឿងប្រដាប់សព្វយ៉ាង ទើបទ្រង់ឡើងកាន់រាជរថដ៏ប្រសើរ ដែលប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ។*

*សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានឮថា ព្រះរាជមាតារបស់ព្រះរាហុលប្រសូតព្រះឱរសហើយ ទើបទ្រង់បញ្ជូនដំណឹងទៅដោយព្រះតម្រាស់ថា ពួកអ្នក ចូរប្រាប់ការត្រេកអររបស់យើងដល់អយ្យបុត្ត ។ ព្រះពោធិសត្វទ្រង់ស្ដាប់ដំណឹងនោះហើយ ត្រាស់ថា* **រាហុ ជាតោ ពន្ធនំ ជាតំ** *រាហុលកើតហើយ ចំណងកើតហើយ ។ ព្រះរាជាត្រាស់សួរថា អយ្យបុត្តរបស់យើងពោលដូចម្ដេចខ្លះ ? កាលទ្រង់បានស្ដាប់ពាក្យនោះហើយ ទើបត្រាស់ថា ចាប់តាំងអំពីពេលនេះទៅ ចៅរបស់យើង ចូរមានឈ្មោះថា រាហុលកុមារចុះ ។ ចំណែកព្រះបរមពោធិសត្វទ្រង់ឡើងកាន់ព្រះរាជរថដ៏ប្រសើរ ទ្រង់យាងចេញអំពីនគរប្រកបដោយយសធំ មួយអន្លើដោយសិរីដ៏ប្រសើរ ដែលគួរជាទីត្រេកអរក្រៃលែង ។ ក្នុងសម័យនោះ ព្រះនាងកិសាគោតមីខត្តិយកញ្ញា ប្រថាប់លើផ្ទៃប្រាសាទ*

ជាន់ខាងលើ ទតឃើញព្រះរូបដ៏ប្រកបដោយសិរីរបស់ព្រះបរមពោធិសត្វ ដែលទ្រង់ធ្វើប្រទក្សិណនគរ ព្រះនាងក៏កើតបីតិសោមនស្ស ហើយពោលនូវឧទាននេះថា

**និព្វុតា នូន សា មាតា និព្វុតោ នូន សោ បិតា**
**និព្វុតា នូន សា នារី យស្សាយំ ឦទិសោ បតីតិ ។**

ស្រីណាជាមាតារបស់ព្រះរាជកុមារនេះ ស្រីនោះ នឹងរលត់ទុក្ខបាន បុរសណាជាបិតារបស់ព្រះរាជកុមារនេះ បុរសនោះ នឹងរលត់ទុក្ខបាន ព្រះរាជកុមារនេះ ជាស្វាមីរបស់ស្រីណា ស្រីនោះរលត់ទុក្ខបានពិត ។

ព្រះពោធិសត្វស្តាប់គាថានោះហើយ ទ្រង់ព្រះតម្រិះថា ព្រះនាងកិសាគោតមីនេះ ត្រាស់យ៉ាងនេះថា ហទយៈរបស់មាតា ហទយៈរបស់បិតា ហទយៈរបស់ភរិយា ដែលឃើញអត្តភាពបែបនេះ រមែងរលត់ទុក្ខបាន កាលណាហ្ន៎ ទើបហទយៈ ឈ្មោះថា រលត់ទុក្ខបាន ។ ពេលនោះព្រះមហាសត្វមានទឹកព្រះទ័យប្រាសចាកតម្រេកហើយ ក្នុងកិលេសទាំងឡាយ ទ្រង់មានព្រះតម្រិះថា កាលភ្លើងគឺរាគៈរលត់ ឈ្មោះថាការរលត់ទុក្ខនឹងមាន កាលភ្លើងគឺទោសៈរលត់ ឈ្មោះថា ការរលត់ទុក្ខនឹងមាន កាលបើភ្លើងគឺមោហៈរលត់ ឈ្មោះថា ការរលត់ទុក្ខក៏មាន កាលកម្តៅក្នុងកិលេសទាំងឡាយ មានមានះនិងទិដ្ឋិជាដើម រលត់ហើយ ឈ្មោះថា ការ

រលត់ទុក្ខនឹងមាន ព្រះនាងឲ្យអញស្ដាប់ពាក្យដែលល្អ សេចក្ដីពិតអញកំពុងស្វែងរកព្រះនិព្វាន អញគួរលះបង់ឃរាវាស ចេញបួសហើយស្វែងរកព្រះនិព្វានក្នុងថ្ងៃនេះឯង ទ្រង់ដោះកម្រងកែវមុក្ដាដែលមានតម្លៃ ១ សែនអំពីព្រះសូរង បញ្ជូនទៅឲ្យដល់ព្រះនាងកិសាគោតមី ដោយទ្រង់ព្រះតម្រិះថា នេះចូរជាអាចរិយភាគៈ ( ជាចំណែកដែលបូជាអាចារ្យ ) សម្រាប់ព្រះនាងចុះ ។ ព្រះនាងកើតបីតិសោមនស្សថា ព្រះសិទ្ធត្ថរាជកុមារនេះមានចិត្តស្រឡាញ់ក្នុងអញ ទើបបញ្ជូនគ្រឿងបណ្ណាការមកឲ្យ ។

ចំណែកព្រះបរមពោធិសត្វ ទ្រង់ឡើងកាន់ប្រាសាទរបស់ព្រះអង្គដោយសិរីដ៏ប្រសើរ ទ្រង់ផ្ទំលើសិរីសេយ្យាសនៈ ។ ក្នុងរំពេចនោះឯង ពួកស្ត្រីដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ដែលបានសិក្សាមកល្អហើយ ក្នុងការរាំច្រៀងនិងការប្រគំជាដើម ទាំងមានរូបឆោមលោមពណ៌ល្អក្រៃលែងដូចទេវកញ្ញា កាន់យកតូរ្យតន្ត្រីច្រើនប្រភេទដ៏គួរជាទីត្រេកអរមកប្រគំបម្រើព្រះពោធិសត្វ នាំគ្នាសម្ដែងអាការរាំ ច្រៀង និងការប្រគំ ។ ព្រះពោធិសត្វ ព្រោះហេតុដែលទ្រង់មានព្រះទ័យប្រាសចាកតម្រេកហើយក្នុងកិលេសទាំងឡាយ ទើបទ្រង់មិនត្រេកអរក្នុងការច្រៀងរាំជាដើម មួយសន្ទុះប៉ុណ្ណោះ ទ្រង់ក៏ចូលកាន់ព្រះនិទ្រា ។ ពួកស្ត្រីទាំងនោះគិតថា ពួកយើងសម្ដែងរបាំជាដើម ដើម្បីប្រយោជន៍ដល់ព្រះរាជកុមារណា ព្រះរាជកុមារនោះ ទ្រង់ចូលកាន់និទ្រាហើយ ឥឡូវនេះនឹងលំបាកធ្វើអ្វី ហើយនាំ

គ្នាដាក់គ្រឿងតូរ្យតន្ត្រីរៀងៗ ខ្លួន ដេកលក់ទៅ ។ ផ្ទាំងប្រទីបក៏នៅឆេះសន្ធោសន្ធៅនៅឡើយ ព្រះពោធិសត្វទ្រង់តើនអំពីព្រះបន្ទំប្រថាប់គង់ពត់ភ្នែនលើទែនបន្ទំ បានទតឃើញស្រីទាំងនោះ ដេកលក់សង្កត់លើគ្រឿងតូរ្យតន្ត្រី ស្រីខ្លះមានទឹកមាត់ហូរ មានខ្លួនប្រឡាក់ប្រឡូសដោយទឹកមាត់ ស្រីខ្លះសង្កៀតធ្មេញ ស្រីខ្លះស្រម៉ុក ស្រីខ្លះដេកមមើរ ស្រីខ្លះហាមាត់ ស្រីខ្លះមានសំពត់របូត ប្រាកដឲ្យឃើញអវយវភេទដែលគួរខ្ពើម ។ ព្រះមហាបុរសទតឃើញអាការខុសប្រក្រតីរបស់ស្រីទាំងនោះ មានព្រះទ័យប្រាសចាកតម្រេកក្នុងកាមទាំងឡាយក្រៃលែង ផ្ទៃប្រាសាទដ៏ធំល្វឹងល្វើយប្រដាប់តាក់តែងហើយដូចគ្នានឹងពិភពរបស់សក្កទេវរាជ ប្រាកដដល់ព្រះពោធិសត្វហាក់បីដូចជាព្រៃស្មសាន ដែលពោរពេញទៅដោយសាកសពផ្សេងៗ ដែលគេយកទៅចោល ភពបីប្រាកដហាក់បីដូចជាផ្ទះដែលត្រូវភ្លើងឆេះ ព្រះឧទានក៏មានឡើងថា **ឧបទ្ទុតំ វត ភោ ឧបស្សដ្ឋំ វត ភោ** ទីនេះច្របូកច្របល់ណាស់ហ្ន៎ ទីនេះរឹកររណាស់ហ្ន៎ ទ្រង់មានព្រះទ័យបង្អោនទៅកាន់បព្វជ្ជាតែម្យ៉ាងប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វ ទ្រង់ព្រះតម្រិះថា អាត្មាអញគួរចេញមហាភិនិក្ខមណ៍ក្នុងកាលឥឡូវនេះ ទើបក្រោកឡើងចាកទីបន្ទំ ទៅក្បែរទ្វារត្រាស់សួរថា អ្នកណានៅក្នុងទីនេះ ? លំដាប់នោះ ឆន្នអាមាត្យដែលដេកយកក្បាលកើយធរណីទ្វារទូលតបថា បពិត្រអយ្យបុត្ត គឺទូលបង្គំ ឆន្នៈ ។

ព្រះពោធិសត្វត្រាស់ថា នែឆន្នៈសម្លាញ់ ថ្ងៃនេះ ខ្ញុំមានបំណងនឹងចេញមហាភិនិស្ក្រមណ៍ ចូររៀបសេះមួយឲ្យខ្ញុំ ។

ឆន្នអាមាត្យទូលថា ករុណាថ្ងៃវិសេស ហើយនាំយកគ្រឿងសេះទៅកាន់រោងសេះ ។ កាលផ្ចាំងប្រទីបកំពុងឆេះសន្ធោសន្ធៅ ឃើញស្ដេចសេះកណ្ឋកៈឈរលើភូមិភាគគួរជាទីរីករាយ ខាងក្រោមពិដានដែលចងសន្ទឹងទុកដោយជុំវិញ ទើបគិតថា ថ្ងៃនេះអញគួររៀបចំសេះកណ្ឋកៈនេះថ្វាយ ហើយរៀបចំសេះកណ្ឋកៈថ្វាយ ។ សេះកណ្ឋកៈនោះ កាលគេកំពុងរៀបចំប្រដាប់តាក់តែង បានដឹងថា ការរៀបចំអាត្មាអញក្នុងថ្ងៃនេះខ្ជាប់ខ្ជួនពិតប្រាកដ មិនមែនជាការត្រៀមចេញដំណើរទៅលេងក្នុងព្រះរាជឧទ្យានដូចថ្ងៃដទៃឡើយ ថ្ងៃនេះ ព្រះអយ្យបុត្តរបស់អញ គង់នឹងមានបំណងចេញមហាភិនិស្ក្រមណ៍ដោយពិត ។ លំដាប់នោះ ក៏មានចិត្តត្រេកអរហើយស្រែកដោយសំឡេងខ្លាំង សំឡេងនោះ ជាធម្មតារមែងខ្ទរខ្ទារពេញនគរទាំងមូល តែទេវតានាំគ្នាទប់នូវសំឡេងនោះៗ មិនឲ្យមានបុគ្គលណាបានឮឡើយ ។ ចំណែកព្រះពោធិសត្វ ទ្រង់ប្រើឆន្នអាមាត្យទៅហើយ ទ្រង់ព្រះតម្រិះថា អញនឹងមើលកូនបន្តិចសិន ទើបក្រោកឡើងអំពីទីប្រថាប់ទៅកាន់ទីបន្ទំរបស់រាហុលមាតា កាលបើកទ្វារបន្ទប់ហើយ ក្នុងខណៈនោះ ប្រទីបផ្ចាំងប្រេងក៏នៅឆេះសន្ធោសន្ធៅនៅឡើយ ឯរាហុលមាតា ក៏ផ្ទំដាក់ព្រះហស្ថអំពីខាងលើព្រះសិរសារបស់ព្រះឱរស ផ្ទំ

លើព្រះបន្ទំដែលដេរដាសដោយផ្កាម្ទិះលាននិងម្ទិះរួតជាដើម ផ្កាទាំងឡាយនោះ មានប្រមាណមួយអម្ពណៈ ( ១១ នាឡិ ) ។ ព្រះមហាបុរសប្រថាប់ឈរដាក់ព្រះបាទលើធរណីទ្វារនោះ ទតហើយមានព្រះតម្រិះថា បើអញចាប់ដៃព្រះទេវីចេញ ហើយចាប់កូនរបស់អញ ព្រះទេវីនឹងភ្ញាក់ កាលបើដូច្នេះ អន្តរាយនៃការចេញទៅនឹងមានប្រាកដដល់អញ ណ្ហើយចុះកាលអញបានត្រាស់ជាព្រះពុទ្ធហើយ សឹមមកសួរសុខទុក្ខកូន ដូច្នេះហើយ ទ្រង់ក៏ចុះអំពីប្រាសាទជាន់ខាងលើ ។ មានពាក្យដែលពោលទុកក្នុងអដ្ឋកថាជាតកថា គ្រានោះ ព្រះរាហុលកុមារប្រសូតបាន ៧ ថ្ងៃ មិនមានក្នុងអដ្ឋកថាដ៏សេសទេ ព្រោះដូច្នោះ គប្បីកាន់យកពាក្យនេះឯងជាប្រមាណ ។

ព្រះមហាបុរសចុះអំពីផ្ទៃប្រាសាទ ដោយប្រការដូច្នេះហើយ យាងទៅជិតសេះហើយត្រាស់ថា នៃកណ្ឋកៈ ថ្ងៃនេះ ចូរអ្នកនាំយើងឆ្លងត្រើយត្រឹម ១ យប់ចុះ យើងអាស្រ័យអ្នកបានជាព្រះពុទ្ធហើយនឹងឲ្យសត្វលោកឆ្លងដែរ ។ រំពេចនោះ ព្រះមហាសត្វក៏ទ្រង់ឡើងផែលលើខ្នងសេះកណ្ឋកៈ សេះកណ្ឋកៈនោះ មានបណ្តោយខ្លួន ១៨ ហត្ថ គឺវាស់អំពីកទៅ ចំណែកកម្ពស់ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា សម្បូរដោយកម្លាំងនិងសន្ទុះ មានពណ៌សសុទ្ធដូចស័ង្ខដែលគេខាត់ល្អហើយ បើស្តេចសេះកណ្ឋកៈនោះគប្បីស្រែកឬក៏ទន្ទ្រាំជើង សំឡេងក៏នឹងលាន់ឮពេញនគរ ( កបិលពស្តុ ) ព្រោះ

ហេតុនោះ ទើបទេវតានាំគ្នាទប់ស្កាត់នូវសំឡេងស្រែក និងសំឡេងជើងរបស់សេះកណ្ឋកៈនោះ ដោយអាការដែលមិនមានបុគ្គលណាបានឮដោយអានុភាពរបស់ខ្លួន ។ ព្រះពោធិសត្វ ទ្រង់ឡើងផែលលើខ្នងសេះដ៏ប្រសើរ ទ្រង់ឲ្យឆន្នអាមាត្យចាប់កន្ទុយសេះអំពីក្រោយ ទ្រង់យាងដល់ខ្លោងទ្វារធំក្នុងកណ្ដាលអធ្រាត្រនោះឯង ។ ក្នុងកាលនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រះពោធិសត្វនឹងមិនអាចបើកទ្វារនគរចេញបាន ទោះក្នុងកាលណាក៏ដោយ ទើបត្រាស់ក៏ឲ្យគេធ្វើសន្ទះទ្វារម្ខាងៗ ល្មមបុរស ១ ពាន់នាក់ទើបអាចបើកបានដោយប្រការដូច្នេះ ។ ព្រះមហាបុរសសម្បូរដោយកម្លាំងដ៏ក្រៃលែង ទ្រង់មានព្រះកម្លាំង កាលប្រៀបធៀបនឹងកម្លាំងរបស់ដំរីធម្មតាក៏រាប់បាន ១ ពាន់កោដិ កាលប្រៀបធៀបនឹងកម្លាំងរបស់បុរសក៏រាប់បាន ១០ ពាន់កោដិ ព្រោះដូច្នោះ ទើបទ្រង់ព្រះតម្រិះថា បើទ្វារមិនបើក ថ្ងៃនេះ អញនឹងអង្គុយលើខ្នងសេះកណ្ឋកៈ ហើយនឹងយកជើងឲ្យសញ្ញាដល់សេះកណ្ឋកៈ ឲ្យលោតឆ្លងកំពែងដែលមានកម្ពស់ ១៨ ហត្ថនេះចេញទៅ ។ ចំណែកឆន្នអាមាត្យគិតថា បើទ្វារមិនបើក អញនឹងឲ្យព្រះអយ្យបុត្តប្រថាប់គង់លើករបស់អញ ហើយយកដៃខាងស្ដាំឱបសេះកណ្ឋកៈត្រង់ពោះធ្វើឲ្យនៅក្នុងចន្លោះក្លៀក ហើយឲ្យសេះលោតឆ្លងកំពែងទៅ ។ ចំណែកសេះកណ្ឋកៈគិតថា បើទ្វារមិនបើក អញនឹងលើកម្ចាស់របស់អញដែលនៅលើខ្នង មួយអន្លើដោយឆន្នអាមាត្យដែលតោងកន្ទុយនេះ ឲ្យឆ្លង

កំពែងទៅ ។ បណ្ដាជនទាំងនោះ បុគ្គលម្នាក់ៗ គង់នឹងធ្វើតាមគំនិតរៀងៗ ខ្លួននោះឯង តែទេវតាដែលអាស្រ័យនៅត្រង់ទ្វារនោះ ក៏បើកឲ្យ ។

ក្នុងខណៈនោះឯង មារមានចិត្តបាបគិតថា អញនឹងឲ្យព្រះសិទ្ធត្ថត្រឡប់ ហើយឈរក្នុងអាកាសពោលថា បពិត្រអ្នកនិរទុក្ខ លោកកុំចេញទៅ ( បួស ) ឡើយ ដ្បិតអំពី ៧ ថ្ងៃទៀត រាប់អំពីថ្ងៃនេះទៅ រតនៈនឹងកើតដល់លោកហើយ លោកនឹងគ្រប់គ្រងរាជសម្បត្តិក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ បពិត្រលោកនិរទុក្ខ ចូរលោកត្រឡប់ចុះ ។

ព្រះពោធិសត្វត្រាស់សួរថា តើអ្នកជាអ្នកណា ?

មារឆ្លើយថា ខ្ញុំជាវសវត្តីមារ ។

ព្រះពោធិសត្វត្រាស់ថា នែមារ យើងជ្រាបថា ចក្ករតនៈនឹងកើតប្រាកដដល់យើង យើងមិនមានសេចក្ដីត្រូវការដោយរាជសម្បត្តិនោះ យើងនឹងឲ្យម៉ឺនលោកធាតុញាប់ញ័រ ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ។

មារពោលថា រាប់តាំងអំពីពេលនេះជាដើមទៅ ក្នុងវេលាដែលទ្រង់ព្រះតម្រិះដល់កាមវិតក្កក្តី ព្យាបាទវិតក្កក្តី វិហឹសាវិតក្កក្តី ខ្ញុំនឹងដឹង ដូច្នេះហើយ ឃ្លាំចាំចាប់ទោសរបស់ព្រះមហាសត្វ ជាប់តាមទ្រង់ទៅហាក់បីដូចជាស្រមោលអន្ទោលតាមប្រាណ ។

ចំណែកព្រះបរមពោធិសត្វ មិនមានអាឡោះអាល័យនឹងចក្រពត្តិរាជសម្បត្តិ ដែលនៅក្នុងកណ្ដាប់ព្រះហស្ត ហាក់បីដូចជាគេស្ដោះទឹកមាត់

ចោលដូច្នោះ ហើយចេញអំពីនគរដោយសក្ការៈដ៏ធំ ។ ក្នុងថ្ងៃនោះ ជាថ្ងៃពេញបូណ៌មី ខែអាសាឍ កាលនក្ខត្តឫក្សឧត្តរាសាឡ្ហៈកំពុងប្រព្រឹត្តទៅ កាលទ្រង់យាងចេញអំពីនគរហើយ មានព្រះបំណងនឹងសម្លឹងមើលនគរ កាលព្រះពោធិសត្វមានគំនិតកើតឡើងប៉ុណ្ណោះ ប្រឹថពីហាក់បីដូចជាទូលព្រះពោធិសត្វថា បពិត្រមហាបុរស ទ្រង់កុំចាំបាច់បែរក្រោយឡើយ ទើបក្នុងទីដីដែលសេះកណ្ឋកៈកំពុងទៅនោះ ក៏វិលដូចជាប៉ែនរបស់ស្មូនឆ្នាំងដែលគេបង្វិលដូច្នោះ ព្រះពោធិសត្វក៏បែរព្រះភក្ត្រទៅក្រោយ ទតមើលនគរ ហើយទ្រង់សម្តែងចេតិយដ្ឋាន ក្នុងទីដែលសេះកណ្ឋកៈត្រឡប់ខ្លួនវិលទៅក្រោយនោះ ទ្រង់ធ្វើសេះកណ្ឋកៈឲ្យបែរមុខទៅតាមផ្លូវដែលទ្រង់បំណងនឹងទៅ ទ្រង់យាងទៅដោយសក្ការៈដ៏ធំ ដោយភាពស្រស់ស្អាតដ៏ឧឡារ ។ បានឮថា ក្នុងកាលនោះ ទេវតាទាំងឡាយឈួលគប់ភ្លើងខាងមុខព្រះពោធិសត្វ ៦ ម៉ឺនដើម ខាងក្រោយ ៦ ម៉ឺនដើម ខាងស្តាំ ៦ ម៉ឺនដើម ខាងឆ្វេង ៦ ម៉ឺនដើម ទេវតាមួយពួកទៀត ឈួលគប់ភ្លើងប្រមាណមិនបានត្រង់ក្នុំកណ្តាប់ចក្រវាល ទេវតាមួយអន្លើដោយនាគគ្រុឌជាដើម ពួកមួយដើរបូជាដោយផ្កាកម្រង គ្រឿងក្រអូប លម្អិត និងផ្សែងក្រអូបដ៏ជាទិព្វ ផ្ទៃដីនិងផ្ទៃមេឃជាប់តគ្នាទៅមិនមានចន្លោះ ដោយផ្កាបារិច្ឆត្តកៈ និងផ្កាមន្ទារវៈ ដូចភ្លៀងផ្កាធ្លាក់ចុះមកដូច្នោះ ទិព្វសង្គីតៈ ( តូរ្យតន្ត្រីទិព្វ ) ក៏បានប្រព្រឹត្តទៅហើយ គ្រឿងតន្ត្រី ៦៨.០០០ ប្រភេទ បន្លឺហើយដោយទូទៅ

កាលរមែងប្រព្រឹត្តទៅ ដូចវេលាដែលមេឃគំរាមផ្ទៃមហាសមុទ្រ និងដូចវេលាដែលសាគរមានសំឡេងគគ្រឹកគគ្រេង ត្រង់ចន្លោះភ្នំយុគន្ធរដូច្នោះ ។

ព្រះពោធិសត្វ កាលទ្រង់យាងទៅដោយសិរីដ៏ប្រសើរនេះ កន្លងរំលងរាជអាណាចក្រទាំង ៣ ក្នុងមួយរាត្រីប៉ុណ្ណោះ ទ្រង់យាងដល់ឆ្នេរស្ទឹងអនោមានទី ក្នុងទីបំផុតនៃផ្លូវ ៣០ យោជន៍ ។

សួរថា សេះកណ្ឋកៈអាចរត់ទៅបានឆ្ងាយជាងនោះ មិនមែនឬ ?

ឆ្លើយថា អាចទៅបាន ព្រោះសេះនោះ អាចត្រាច់ទៅចុងចក្រវាលមិនមានព្រំដែនយ៉ាងនេះ ដូចគេជាន់កង់រទេះត្រង់ដុំហើយត្រឡប់មកទាន់ក្នុងអាហារពេលព្រឹក បរិភោគអាហារដែលគេរៀបចំទុកសម្រាប់ខ្លួន តែក្នុងកាលនោះ រាងកាយរបស់សេះក៏លិចក្នុងគំនរផ្កានិងគ្រឿងក្រអូបដែលពួកទេវតា នាគ គ្រុឌ ឈរនៅក្នុងអាកាសបាចសាចចុះមក រហូតស្មើភ្លៅសេះកណ្ឋកៈនោះលុយផ្កានិងគ្រឿងក្រអូបទាំងនោះទៅ ទើបមានសភាពយឺតយូរដូច្នេះ ព្រោះហេតុនោះ ទើបបានត្រឹមតែ ៣០ យោជន៍ប៉ុណ្ណោះ ។

ព្រះមហាបុរសប្រថាប់ឈរលើឆ្នេរស្ទឹង ហើយត្រាស់សួរឆន្នៈថា ស្ទឹងនេះ ឈ្មោះស្ទឹងអ្វី ?

ឆន្នៈក្រាបទូលថា ស្ទឹងនេះ ឈ្មោះអនោមានទី ព្រះអង្គ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា បព្វជ្ជារបស់អាត្មាអញនឹងមិនថោកថយ ទើបទ្រង់ឡើងផែលលើខ្នងសេះ យកកែងព្រះបាទឲ្យសញ្ញាដល់សេះ សេះ

បានលោតចូលផ្ទៃស្ទឹងទៅម្ខាងទៀត ប្រមាណ ៨ ឧសភ ទៅឈរត្រង់ត្រើយនាយ ។ ព្រះពោធិសត្វចុះអំពីខ្នងសេះ ប្រថាប់ឈរលើផ្នូក-ខ្សាច់ដែលមានពណ៌ដូចផែនប្រាក់ ហើយត្រាស់ហៅនាយឆន្នៈមកថា នែឆន្នៈសម្លាញ់ ចូរអ្នកនាំយកអាភរណៈនិងសេះរបស់យើងទៅ យើងនឹងបួសក្នុងទីនេះឯង ។

នាយឆន្នៈក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំក៏នឹងបួសជាមួយព្រះអង្គដែរ ។ ព្រះពោធិសត្វត្រាស់អស់វារៈ ៣ ដងថា អ្នកបួសមិនបានទេ អ្នកត្រូវតែត្រឡប់ទៅវិញ ហើយទ្រង់ប្រគល់គ្រឿងអាភរណៈ និងសេះកណ្ឋកៈឲ្យនាយឆន្នៈ ។ នាយឆន្នៈទទួលហើយ ។ ព្រះមហាបុរសទ្រង់ព្រះតម្រិះថា សក់របស់អញនេះ មិនគួរដល់សមណៈទេ តែបុគ្គលដទៃសមគួរនឹងកោរសក់របស់អាត្មាអញមិនមាន ព្រោះហេតុនោះ អញនឹងកាត់ដោយព្រះខ័នខ្លួនឯង ទើបយកព្រះហស្តស្តាំចាប់ព្រះខ័ន យកព្រះហស្តឆ្វេងចាប់ចុងព្រះចូឡា មួយអន្លើដោយព្រះមោលី ( ផ្នួងសក់ ) ហើយទើបកាត់ចេញ សរសៃសក់សល់ប្រមាណពីរធ្នាប់ កាលដុះក៏ដុះវិលជុំវិញព្រះសិរសានោះឯង ព្រះកេសាមានប្រមាណប៉ុណ្ណោះ រហូតដល់អស់ព្រះជន្មនិងព្រះមស្សុ ( ពុកមាត់ ) ក៏មានល្មមសមគួរដល់ព្រះកេសានោះ ឈ្មោះថា កិច្ចដោយការកោរសក់និងកោរពុកមាត់ មិនមានសម្រាប់ព្រះពោធិសត្វទៀតឡើយ ។ ព្រះបរមពោធិសត្វ ចាប់ចុងព្រះចូឡាមួយ

អន្ទើដោយព្រះមោលី ទ្រង់អធិដ្ឋានថា **សចាហំ ពុទ្ធោ ភវិស្សាមិ អាកាសេ តិដ្ឋតុ នោ ចេ ភូមិយំ បតតុ** បើអាត្មាអញបានត្រាស់ជាព្រះពុទ្ធសោត ព្រះមោលីចូរតាំងនៅក្នុងអាកាស បើមិនបានត្រាស់ជាព្រះពុទ្ធទេ ក៏ចូរធ្លាក់ចុះមកលើផែនដី ហើយទ្រង់បោះឡើងទៅក្នុងអាកាស ផ្នួងសក់នោះក៏ហោះទៅក្នុងទីប្រមាណ ១ យោជន៍ ហើយតាំងនៅលើអាកាស ។ សក្កទេវរាជប្រមើលមើលដោយទិព្វចក្ខុ ទើបយកប្រអប់កែវដែលមានទំហំប្រមាណ ១ យោជន៍មកទទួលទុក ហើយនាំទៅប្រតិស្ឋានទុកនៅក្នុងព្រះចេតិយឈ្មោះថា ចូឡាមណីចេតិយ ក្នុងភពតាវត្តិង្ស ឯណោះ សមដូចលោកពោលទុកថា

**ឆេត្វាន មោឡឹ វរគន្ធវាសិតំ**
**វេហាសយំ ឧក្ខិបិ អគ្គបុគ្គលោ**
**សហស្សនេត្តោ សិរសា បដិគ្គហិ**
**សុវណ្ណចង្កោដវរេន វាសវោតិ ។**

អគ្គបុរសដ៏ប្រសើរ បានកាត់ព្រះមោលី ដែលអប់ដោយក្លិនក្រអូបដ៏ប្រសើរហើយ បោះទៅក្នុងអាកាស ស្តេចវាសវៈមានព្រះនេត្រ ១ ពាន់ យកប្រអប់មាសដ៏ប្រសើរ ទទួលទូលដោយសិរសាហើយ ។

ព្រះមហាបុរស ទ្រង់ព្រះតម្រិះទៀតថា សំពត់កាសិកពស្ត្រទាំងនេះ

មិនសមគួរដល់សមណៈដូចជាអាត្មាអញឡើយ ។ លំដាប់នោះ ឃដិការមហាព្រហ្មដែលជាសម្លាញ់ របស់ព្រះពោធិសត្វអំពីបុរាណ ក្នុងសាសនាព្រះពុទ្ធកស្សបៈ មានភាពជាមិត្តជិតស្និទ្ធ សូម្បីអស់មួយពុទ្ធន្តរ ក៏គិតថាថ្ងៃនេះ សម្លាញ់របស់អញចេញមហាភិនិស្ក្រមណ៍ អញនឹងយកសមណ-បរិក្ខាររបស់សម្លាញ់អញទៅ ទើបនាំយកបរិក្ខារទាំង ៨ គឺ

**តិចីវរញ្ច បត្តោ ច វាសិ សូចិ ច ពន្ធនំ**
**បរិស្សាវនេន អដ្ឋេតេ យុត្តយោគស្ស ភិក្ខុនោតិ ។**

បរិក្ខារទាំងនេះ គឺ ត្រៃចីវរ បាត្រ កាំបិតកោរ ម្ជុល វត្ថពន្ធចង្កេះ ជាគម្រប់ ៨ មួយអន្លើដោយតម្រងទឹក រមែងគួរដល់ភិក្ខុដែលប្រកបព្យាយាម ។

មកថ្វាយព្រះមហាបុរស ទ្រង់ស្លៀកដណ្ដប់ទង់ជ័យនៃព្រះអរហត្តហើយ កាន់យកបព្វជ្ជាភេទដ៏ឧត្តម ទើបបញ្ជូននាយឆន្នៈទៅដោយព្រះតម្រាស់ថា នែឆន្នៈ អ្នកចូរក្រាបទូលដល់ការមិនមានរោគ និងការមិនមានជំងឺដម្កាត់ ដល់ព្រះជនកនិងព្រះជននី តាមពាក្យរបស់យើងផងចុះ ឆន្នៈថ្វាយបង្គំព្រះបរមពោធិសត្វ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ចំណែកសេះកណ្ឋកៈឈរត្រង់ឆ្នេរស្ទឹង ស្ដាប់ឮពាក្យរបស់ព្រះពោធិសត្វដែលត្រាស់នឹងនាយឆន្នៈ គិតថា ឥឡូវនេះ អញលែងបានឃើញម្ចាស់របស់អញតទៅទៀតហើយ កាលផុតគន្លងចក្ខុទៅ មិនអាចអត់សង្កត់នូវ

សេចក្តីសោកបាន ហឫទ័យក៏បែកធ្លាយ ស្លាប់ទៅកើតជាកណ្ឌកទេវបុត្ត ក្នុងឋានតាវត្តិង្ស ។ ពីដំបូងឆន្នអាមាត្យមានសេចក្តីសោកត្រឹមតែមួយ តែកាលសេះកណ្ឌកៈស្លាប់ទៅ ឆន្នអាមាត្យត្រូវសេចក្តីសោកទ្វេដងបៀត-បៀន បានទ្រហោយំហើយដើរទៅ ។

ចំណែកព្រះមហាបុរសកាលបព្វជ្ជាហើយ បានសម្រាកនៅដោយសេចក្តីសុខដែលកើតអំពីបព្វជ្ជាអស់មួយសប្តាហ៍ ក្នុងអនុបិយអម្ពវ័នដែលមាននៅក្នុងប្រទេសនោះ ហើយទ្រង់យាងទៅដោយព្រះបាទទទេ អស់ចម្ងាយផ្លូវ ៣០ យោជន៍ ក្នុងមួយថ្ងៃប៉ុណ្ណោះ ទ្រង់យាងចូលទៅកាន់នគររាជគ្រឹះ កាលចូលទៅដល់ហើយ ទ្រង់ចារិកបិណ្ឌបាតទៅតាមលំដាប់ច្រកពួកអ្នកនគរទាំងមូលដល់នូវការភ្ញាក់ផ្អើល ព្រោះបានឃើញព្រះរូបដ៏ល្អឯករបស់ព្រះពោធិសត្វ ដូចដំរីធនបាលចូលទៅកាន់ក្រុងរាជគ្រឹះ និងដូចទេវនគរត្រូវស្តេចអសុរចូលទៅដូច្នោះ ។ លំដាប់នោះ រាជបុរសទាំងឡាយមកក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព បុគ្គលមានសភាពបែបនេះត្រាច់បិណ្ឌបាតក្នុងនគរ ទូលបង្គំទាំងឡាយមិនដឹងថា បុគ្គលនេះឈ្មោះអ្វី ជាទេវតា មនុស្ស នាគ ឬគ្រុឌនោះឡើយ ។ ព្រះរាជាប្រថាប់ឈរលើផ្ទៃប្រាសាទ ទតឃើញព្រះមហាបុរស កើតអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់ឃើញ ទ្រង់បញ្ជារាជបុរសថា នែនាយ អ្នកទាំងឡាយចូរទៅសង្កេតមើលថា បើជាអមនុស្ស កាលចេញអំពីនគរហើយ ក៏នឹងអន្តរធាន

ទៅ បើជាទេវតាក៏នឹងហោះទៅក្នុងអាកាស បើជានាគក៏នឹងមុជចូលទៅក្នុងផែនដី បើជាមនុស្សនឹងបរិភោគអាហារតាមដែលខ្លួនបាន ។ ចំណែកព្រះមហាបុរសប្រមូលភត្តចូលគ្នាហើយ ដឹងថា ភត្តមានប្រមាណប៉ុណ្ណោះល្មមសម្រាប់អាត្មាអញ ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានហើយ ទើបយាងចេញអំពីនគរតាមទ្វារដែលទ្រង់ចូលមកនោះឯង បែរព្រះភក្ត្រទៅកាន់ទិសខាងកើត ប្រថាប់គង់ត្រង់ម្លប់របស់ភ្នំបណ្ឌវបព៌ត ផ្ដើមសោយនូវព្រះក្រយាហារ ។ លំដាប់នោះព្រះអន្តំ (ពោះវៀនធំ) របស់ទ្រង់ដល់នូវអាការហាក់ដូចចេញអំពីព្រះឱស្ឋ ខណៈនោះ ព្រះមហាបុរស ទ្រង់អត់សង្កត់ព្រះទ័យដោយអាហារបដិកូល ព្រោះអត្តភាពនោះ ទ្រង់មិនធ្លាប់ឃើញអាហារបែបនោះ សូម្បីដោយព្រះនេត្រឡើយ ទើបទ្រង់ទូន្មានខ្លួនដោយព្រះអង្គឯងថា នៃសិទ្ធត្ថ អ្នកកើតមកក្នុងទីដែលមានភោជនប្រសើរផ្សេងៗ ដោយភោជននៃស្រូវសាលីដែលមានក្លិនក្រអូប ដែលគេរក្សាទុកអស់ ៣ ឆ្នាំ ក្នុងត្រកូលមានបាយនិងទឹករកបានងាយ បានឃើញបព្វជិតអ្នកទ្រទ្រង់សំពត់បង្សុកូលមួយរូបហើយ គិតថា កាលណាហ្ន៎ ទើបអញនឹងបានជាបុគ្គលមានសភាពដូច្នោះ ត្រាច់បិណ្ឌបាតបរិភោគ កាលណាហ្ន៎ កាលនោះ នឹងមានសម្រាប់អញ ទើបចេញបួស ឥឡូវនេះ អ្នកធ្វើសេចក្ដីនោះដូចម្ដេច ? កាលទ្រង់ទូន្មានព្រះអង្គយ៉ាងនេះហើយ ទ្រង់មិនមានអាការខុសប្រក្រតី ទ្រង់ក៏សោយព្រះក្រយាហារ ។ រាជបុរស

ទាំងឡាយឃើញការប្រព្រឹត្តទៅយ៉ាងនោះហើយ ទើបទៅក្រាបទូលឲ្យព្រះរាជាទ្រង់ជ្រាប ។ ព្រះរាជាបានស្តាប់ពាក្យរបស់ទូតប៉ុណ្ណោះ ទ្រង់ប្រញាប់ចុះអំពីប្រាសាទ យាងចេញអំពីនគរទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ទ្រង់ជ្រះថ្លាចំពោះឥរិយាបថប៉ុណ្ណោះ ទ្រង់ក៏ប្រគល់រាជជាធំដល់ព្រះពោធិសត្វ ។ ព្រះមហាបុរសត្រាស់ថា មហាបពិត្រ អាត្មាមិនមានសេចក្តីត្រូវការដោយវត្ថុកាមឬកិលេសកាមទាំងឡាយទេ អាត្មាប្រាថ្នាបរមាភិសម្ពោធិញ្ញាណ ទើបចេញបួស ។ ព្រះរាជា កាលទ្រង់អារាធនាដោយអនេកប្បការ ក៏មិនបានទឹកព្រះទ័យអំពីព្រះពោធិសត្វ ទើបត្រាស់ថា បើទ្រង់បានត្រាស់ជាព្រះពុទ្ធហើយ គប្បីមកកាន់ដែនរបស់ញោមមុនគេ ដូច្នេះ ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ចំណែកសេចក្តីពិស្តារគប្បីមើលសព្វក្នុងបព្វជ្ជាសូត្រយ៉ាងនេះថា

**បព្វជ្ជំ កិត្តយិស្សាមិ យថា បព្វជ្ជិ ចក្ខុមា**
**យថា វិមំសមានោ សោ បព្វជ្ជំ សមារោចយិ ។**

ខ្ញុំនឹងសម្តែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ បានទ្រង់ព្រះផ្នួសហើយ ដោយប្រការយ៉ាងណា ទ្រង់ពិចារណាឃើញយ៉ាងណា ទើបទ្រង់ពេញព្រះហឫទ័យនឹងបព្វជ្ជា (១) ។

---

១-បិ. ៥៤ , ទំ. ១៣១ ។

មួយអន្លើដោយអដ្ឋកថា ហើយគប្បីជ្រាបចុះ ។

ចំណែកព្រះបរមពោធិសត្វទ្រង់ឲ្យប្ដេជ្ញាដល់ព្រះរាជាហើយ ទ្រង់យាងចារិកទៅដោយលំដាប់ ចូលទៅកាន់សម្នាក់របស់អាឡារតាបសកាលាមគោត្រ និងឧទកតាបសរាមបុត្ត ធ្វើសមាបត្តិឲ្យកើតហើយ ទ្រង់ព្រះតម្រិះថា នេះមិនមែនជាផ្លូវនៃការត្រាស់ដឹង ទើបមិនទាន់ពេញព្រះទ័យក្នុងសមាបត្តិភាវនានោះ ទ្រង់មានបំណងនឹងផ្ដើមតាំងមហាបធាន ដើម្បីសម្ដែងកម្លាំងនិងសេចក្ដីព្យាយាមរបស់ព្រះអង្គ ដល់សត្វលោកមួយអន្លើដោយទេវលោក ទើបយាងទៅកាន់តំបន់ឧរុវេលា ទ្រង់មានព្រះតម្រាស់ថា ភូមិភាគនេះគួរជាទីរីករាយហ្ន៎ ទើបយាងចូលទៅកាន់តំបន់ឧរុវេលានោះ ទ្រង់ផ្ដើមតាំងមហាបធាន គឺការព្យាយាមធំ ។ បព្វជិត ៥ រូប មានកោណ្ឌញ្ញៈជាប្រធាននោះឯង នាំគ្នាត្រាច់ភិក្ខាចារក្នុងគាម និគម រាជធានីទៅទាន់ព្រះបរមពោធិសត្វក្នុងតំបន់ឧរុវេលានោះ ។ លំដាប់នោះ បព្វជិតទាំង ៥ រូបនោះ ឧបដ្ឋាកព្រះពោធិសត្វដែលផ្ដើមតាំងមហាបធាន អស់កាល ៦ វស្សាដោយការបដិបត្តិ មានការបោសបរិវេណជាដើម ដោយបំណងថា ព្រះមហាបុរសនឹងបានជាព្រះពុទ្ធក្នុងកាលឥឡូវនេះ ហើយបាននៅក្នុងសម្នាក់របស់ព្រះមហាបុរសនោះឯង ។

ចំណែកព្រះពោធិសត្វ ទ្រង់ព្រះតម្រិះថា នឹងធ្វើទុក្ករកិរិយាឲ្យដល់ទីបំផុត ទើបទ្រង់ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយអង្ករប្រមាណប៉ុនគ្រាប់ល្ង

មួយជាដើម ទ្រង់បានធ្វើនូវការកាត់បន្ថយអាហារដោយប្រការទាំងពួង ។ ចំណែកទេវតា នាំឱជាទិព្វដាក់ចូលទៅក្នុងរណ្ដៅរោមទាំងឡាយ កាលព្រះបរមពោធិសត្វ មានព្រះវរកាយដល់នូវភាពទន់ខ្សោយយ៉ាងក្រៃលែង ព្រោះភាពជាអ្នកមិនមានអាហារយ៉ាងនោះ ព្រះវរកាយដែលមានឆវីវណ្ណដូចមាស ក៏មានពណ៌សម្បុរខ្មៅអាប់ឱនទៅ ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការក៏ត្រូវបិទបាំង មិនប្រាកដ ។ ក្នុងកាលខ្លះ កាលទ្រង់សម្ងំអប្បាណកជ្ឈាន ត្រូវវេទនាធំគ្របសង្កត់ ទ្រង់ក៏វិសញ្ញី ( សន្លប់ក្នុងទីចង្ក្រម ) ។ លំដាប់នោះ ទេវតាពួកខ្លះពោលដល់ព្រះពោធិសត្វថា ព្រះសមណគោតមធ្វើកាលកិរិយាទៅហើយ ទេវតាពួកខ្លះពោលថា នេះជាវិហារធម៌របស់ព្រះអរហន្តទេតើ ។ បណ្ដាទេវតាទាំងនោះ ពួកទេវតាដែលនិយាយថា ព្រះសមណគោតមបានធ្វើកាលកិរិយាទៅហើយនោះ ក៏នាំគ្នាទៅក្រាបទូលដល់ព្រះបាទសុទ្ធោទនមហារាជថា ព្រះរាជឱរសរបស់ព្រះអង្គ ទ្រង់សោយទិវង្គតហើយ ។

ព្រះបាទសុទ្ធោទនមហារាជត្រាស់ថា កូនរបស់យើង បើមិនបានត្រាស់ជាព្រះពុទ្ធ មិនស្លាប់ទេ ។

ទេវតាទាំងនោះក្រាបទូលថា ព្រះរាជឱរសរបស់ព្រះអង្គ មិនអាចជាព្រះពុទ្ធបានទេ ទ្រង់ដួលលើផែនដីក្នុងទីចង្ក្រម សោយទិវង្គតហើយ ។

ព្រះរាជា ទ្រង់ស្ដាប់ពាក្យនោះហើយ ទើបត្រាស់តបថា យើងមិន

ជឿទេ កាលកូនរបស់យើងមិនទាន់បានសម្រេចពោធិញាណ ហើយធ្វើកាលកិរិយា មិនមានឡើយ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះរាជា ទ្រង់មិនជឿ?

ឆ្លើយថា ព្រោះព្រះអង្គបានឃើញបាដិហារិយ៍ទាំងឡាយ ក្នុងថ្ងៃដែលកាឡទេវិលតាបសនិមន្តមកសួរសុខទុក្ខ និងត្រង់មណ្ឌលដើមព្រីងក្នុងថ្ងៃវប្បមង្គល ។ ឯព្រះពោធិសត្វត្រឡប់បាននូវសញ្ញាក្រោកឡើងសាជាថ្មីទៀត កាលព្រះមហាបុរសក្រោកឡើងហើយ ពួកទេវតាទាំងនោះ ក៏មកក្រាបទូលព្រះរាជាថា បពិត្រមហារាជ ព្រះរាជឱរសរបស់ព្រះអង្គមិនមានរោគទេ ។

ព្រះរាជាត្រាស់ថា យើងដឹងថា បុត្តរបស់យើងមិនស្លាប់ទេ ។

កាលព្រះមហាបុរស ទ្រង់បំពេញទុក្ករកិរិយាអស់ ៦ វស្សា កាលវេលាហាក់បីដូចជាក្បួចកំណួចក្នុងអាកាស ។ ព្រះពោធិសត្វ ទ្រង់ព្រះតម្រិះថា ឈ្មោះថាការធ្វើទុក្ករកិរិយានេះមិនមែនជាផ្លូវនាំឲ្យសម្រេច ទើបទ្រង់ចារិកទៅបិណ្ឌបាតក្នុងគាមនិងនិគមទាំងឡាយ ដើម្បីអាហារគ្រោតគ្រាត ហើយទ្រង់នាំយកអាហារមក ។ គ្រានោះ មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ព្រះពោធិសត្វបានត្រឡប់ជាប្រក្រតី ព្រះកាយមានព្រះឆវីវណ្ណដូចមាស បញ្ចវគ្គិយភិក្ខុនាំគ្នាគិតថា ព្រះមហាបុរសនេះ សូម្បីធ្វើទុក្ករកិរិយាដល់ទៅ ៦ ឆ្នាំ ក៏មិនអាចសម្រេចសព្វញ្ញុតញ្ញាណបាន

ឥឡូវនេះ ត្រាច់បិណ្ឌបាតទៅក្នុងស្រុកជាដើម នាំអាហារគ្រោតគ្រាតមក នឹងអាចសម្រេចបានដូចម្ដេច ព្រះមហាបុរសនេះ ក្លាយជាបុគ្គលល្មោភ លះបង់សេចក្ដីព្យាយាម ឈ្មោះថា ការត្រិះរិះដល់គុណវិសេសអំពីសម្នាក់របស់ព្រះមហាបុរសនៃពួកយើង ក៏ដូចជាបុគ្គលដែលកក់សក់ត្រិះរិះយកដំណក់ទឹកសន្សើមដូច្នោះ ពួកយើងនឹងប្រយោជន៍អ្វីដោយព្រះមហាបុរសនេះ ទើបនាំគ្នាលះបង់ព្រះមហាសត្វ កាន់បាត្រនិងចីវររៀងៗខ្លួន ធ្វើដំណើរទៅកាន់ទីប្រមាណ ១៨ យោជន៍ ចូលទៅកាន់ព្រៃឥសិបតនៈ ។

សម័យនោះ ទារិកាឈ្មោះ សុជាតា កើតក្នុងផ្ទះរបស់សេនាកុដុម្ពិកៈ ក្នុងតំបន់ឧរុវេលាសេនានិគម លុះចម្រើនវ័យហើយ បានធ្វើសេចក្ដីប្រាថ្នាត្រង់ដើមជ្រៃ ១ ដើមថា បើខ្ញុំបានទៅកាន់ផ្ទះត្រកូលដែលមានជាតិស្មើគ្នា ហើយបានកូនប្រុសក្នុងផ្ទៃជាលើកដំបូង ខ្ញុំនឹងធ្វើពលិកម្មដោយបរិច្ចាគទ្រព្យ ១ សែនរាល់ៗ ឆ្នាំ សេចក្ដីប្រាថ្នារបស់នាងក៏សម្រេចហើយ ។ កាលព្រះមហាសត្វធ្វើទុក្ករកិរិយា លុះគ្រប់ឆ្នាំទី ៦ បរិបូណ៌ នាងសុជាតានោះបំណងធ្វើពលិកម្មក្នុងថ្ងៃ ១៥ កើត ខែពិសាខ ។ បុរេតរំ ធេនុសហស្សំ លដ្ឋិមធុកវនេ ចរាបេត្វា តាសំ ខីរំ បញ្ច ធេនុសតានិ ចាយេត្វា តាសំ ខីរំ អឌ្ឍតិយានីតិ ឯវំ យាវ សោឡសន្នំ ធេនូនំ ខីរំ អដ្ឋ ធេនុយោ បិវន្តិ តាវ ខីរស្ស ពហលតញ្ច មធុរតញ្ច ឱជវន្តញ្ច បត្ថយមានា ខីរបរិវត្តនំ នាម អកាសិ ។

ដំបូង ( នាង ) បានលែងមេគោទឹកដោះ ១ ពាន់ ឲ្យត្រាច់ទៅ ( ស៊ី ) ក្នុងព្រៃឈើអែម ឲ្យគោ ៥០០ ផឹកទឹកដោះរបស់មេគោ ១ ពាន់នោះ ហើយឲ្យមេគោ ២៥០ ផឹកទឹកដោះរបស់មេគោ ៥០០ នោះ នាងប្រាថ្នាទឹកដោះខាប់ដែលមានឱជៈ ទើបឲ្យមេគោផឹកទឹកដោះតគ្នារហូត ចុងក្រោយឲ្យមេគោ ៨ ផឹកទឹកដោះរបស់មេគោ ១៦ ដោយប្រការដូច្នេះ ។ ក្នុងព្រលឹមថ្ងៃវិសាខបុណ្ណមី នាងសុជាតាក្រោកឡើងអំពីព្រលឹមនៃរាត្រី ឲ្យរីតទឹកដោះមេគោទាំង ៨ នោះ កូនគោទាំងឡាយមិនទាន់បានបៅដោះនោះនៅឡើយ លុះភាជនៈថ្មីចូលទៅជិតកន្សោមដោះប៉ុណ្ណោះ ផ្ការទឹក-ដោះក៏ហូរតាមធម្មតារបស់ខ្លួន នាងសុជាតាបានឃើញភាពអស្ចារ្យនោះទើបត្រងទឹកដោះនោះដោយដៃរបស់ខ្លួនឯង ដាក់ក្នុងភាជនៈថ្មី ហើយបង្កាត់ភ្លើងដោយដៃខ្លួនឯង ផ្ដើមនឹងចម្អិន ។ កាលកំពុងចម្អិនបាយាសនោះ ពពុះធំៗ តាំងឡើងវិលជាទក្ខិណាវដ្ដ សូម្បីដំណក់ទឹកត្រឹមតែមួយដំណក់ក៏មិនខ្ទាតចេញមកខាងក្រៅ ផ្សែងមានប្រមាណតិចតួចក៏មិនតាំងឡើងអំពីជើងក្រាន ។ សម័យនោះ ស្ដេចចតុលោកបាលធ្វើការរក្សាត្រង់ជើងក្រាន មហាព្រហ្មបាំងស្វេតច្ឆត្រ សក្កទេវរាជនាំយកឧសអំពីព្រៃមកដុត ។ ពិតហើយ ទេវតាទាំងឡាយប្រមូល **ឧបការប្បឧឱជ** គឺឱជៈដែលចូលទៅសម្រេចដល់ទេវតានិងមនុស្សទាំងឡាយ ក្នុងទ្វីបធំទាំង ៤ ដែលមានទ្វីបតូច ២ ពាន់ជាបរិវារ ដាក់ចូលក្នុងឆ្នាំងបាយាសនោះដោយ

ទេវានុភាពរៀងៗ ខ្លួន ដូចបុគ្គលច្របាច់ទឹកឃ្មុំដែលជាប់លើបង្គង់ ហើយកាន់យកតែទឹកផ្អែមដូច្នោះ ។

ពិតហើយ ក្នុងវេលាដទៃៗ ទេវតាទាំងឡាយដាក់ឱជៈក្នុងពំនូតបាយ តែក្នុងថ្ងៃត្រាស់ដឹងនិងថ្ងៃបរិនិព្វាន ដាក់ឱជៈក្នុងឆ្នាំងនោះឯង ។

នាងសុជាតាបានឃើញភាពអស្ចារ្យមិនមែនតិច ដែលប្រាកដដល់ខ្លួនក្នុងទីនោះ ក្នុងមួយថ្ងៃប៉ុណ្ណោះ ទើបហៅនាងបុណ្ណាទាសីមកពោលថា នែបុណ្ណា ថ្ងៃនេះ ទេវតារបស់ពួកយើងទាំងឡាយ គួរជ្រះថ្លាពន់ពេកក្នុងកាលមានប្រមាណប៉ុណ្ណោះ យើងមិនធ្លាប់ឃើញភាពអស្ចារ្យបែបនេះឡើយ ចូរនាងប្រញាប់ទៅមើលទេវស្ថានដោយឆាប់រហ័សចុះ ។ នាងបុណ្ណាទាសីនោះ ទទួលពាក្យនាងសុជាតាថា សាធុ ហើយក៏ប្រញាប់ទៅកាន់គល់ជ្រៃ ។ ចំណែកព្រះបរមពោធិសត្វ ទ្រង់ឃើញមហាសុបិន ៥ ប្រការនារាត្រី ទ្រង់ពិចារណា ទើបទ្រង់ធ្វើការសន្និដ្ឋានថា ថ្ងៃនេះ អញនឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ។ លុះរាត្រីកន្លងទៅ ទ្រង់ធ្វើការបដិបត្តិសរីរៈ រង់ចាំពេលភិក្ខាចារ ។ លុះដល់វេលាភិក្ខាចារ ទើបទ្រង់យាងមកគង់ត្រង់គល់ជ្រៃនោះ ធ្វើគល់ជ្រៃទាំងអស់ឲ្យភ្លឺស្វាងដោយរស្មីរបស់ព្រះអង្គ ។

លំដាប់នោះ នាងបុណ្ណាទាសីនោះមក បានឃើញព្រះមហាបុរសគង់ត្រង់គល់ឈើ ទតលោកធាតុទិសខាងកើត និងព្រោះបានឃើញដើម

ឈើទាំងមូលមានរស្មីពណ៌ដូចមាស ដោយព្រះរស្មីដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះមហាបុរស ទើបនាងគិតដូច្នេះថា ថ្ងៃនេះ ទេវតារបស់យើងទាំងឡាយ ប្រហែលជាចុះមកអំពីដើមជ្រៃ អង្គុយទទួលពលិកម្មដោយដៃរបស់ខ្លួនឯង ទើបជាអ្នកដល់នូវសេចក្តីត្រេកអរ ប្រញាប់ប្រាប់រឿងនោះដល់នាងសុជាតា ។ នាងសុជាតាស្តាប់ពាក្យនាងបុណ្ណាទាសីនោះហើយ ក៏មានចិត្តត្រេកអរពោលថា ចាប់អំពីថ្ងៃនេះទៅ នាងចូរតាំងនៅក្នុងឋានៈជាកូនស្រីច្បងរបស់យើង ហើយបានឲ្យគ្រឿងប្រដាប់ទាំងពួងដែលសមគួរដល់ធីតា ។ ព្រោះហេតុក្នុងថ្ងៃដែលបានសម្រេចភាពជាព្រះពុទ្ធ ការបានថាសមាសដែលមានតម្លៃ ១ សែនទើបគួរ ព្រោះដូច្នោះ ទើបនាងសុជាតានោះ ធ្វើការគិតឲ្យកើតឡើងថា នឹងដាក់បាយាសក្នុងថាសមាស ទើបឲ្យអ្នកបម្រើនាំថាសមាសដែលមានតម្លៃ ១ សែនចេញមក បំណងនឹងដាក់បាយាសក្នុងថាសនោះ ទើបពិចារណាដល់ភោជនដែលឆ្អិនហើយ បាយាសទាំងអស់ក៏រមៀលចូលទៅប្រតិស្ឋានក្នុងថាសមាសនោះ ដូចទឹកធ្លាក់ចុះអំពីស្លឹកឈូកដូច្នោះ បាយាសនោះ មានប្រ-មាណពេញថាសមួយល្មម ទើបនាងយកថាសមួយដទៃគ្របថាសនោះ ហើយយកសំពត់សខ្ចប់ ប្រដាប់តាក់តែងរាងកាយដោយគ្រឿងអលង្ការទាំងពួង យកថាសនោះទូលលើក្បាលរបស់ខ្លួន ដើរទៅកាន់គល់ជ្រៃនោះដោយអានុភាពធំ ។ លុះទៅដល់ហើយ សម្លឹងមើលព្រះពោធិសត្វ កើត

សោមនស្សជាកម្លាំង សម្គាល់ថាជារុក្ខទេវតា ខណៈបានឃើញនោះឯង ក៏បង្អោនកាយដើរចូលទៅ ដាក់ថាសមាសអំពីលើក្បាល ហើយបើកយកសុវណ្ណភិង្ការដាក់ទឹកដែលអប់ដោយផ្កាឈើ ហើយចូលទៅឈរជិតព្រះពោធិសត្វ បាត្រដីដែលឃដិការមហាព្រហ្មថ្វាយ មិនឃ្លាតឆ្ងាយអំពីព្រះពោធិសត្វអស់កាលមានប្រមាណប៉ុណ្ណោះ ក៏បាត់ទៅក្នុងខណៈនោះឯង ។ ព្រះមហាបុរស កាលសម្លឹងមិនឃើញបាត្រ ទើបលាព្រះហស្តស្តាំចេញមកទទួល នាងសុជាតាក៏ដាក់ថាសបាយាសនោះ លើព្រះហស្តរបស់ព្រះមហាបុរស ទ្រង់ក៏ទតនាងសុជាតា ។ នាងសុជាតាកំណត់អាការហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គ សូមទ្រង់កាន់យកវត្ថុដែលខ្ញុំបរិច្ចាគនេះចុះ ថ្វាយបង្គំហើយទូលថា មនោរថគឺសេចក្តីប្រាថ្នា ចូរសម្រេចដល់ទ្រង់ដូចសម្រេចដល់ខ្ញុំចុះ ។ នាងមិនអាឡោះអាល័យក្នុងថាសមាសដែលមានតម្លៃ ១ សែន ហាក់ដូចជាភាជនៈដីចាស់ ចៀសចេញទៅហើយ ។

ចំណែកព្រះមហាបុរស ទ្រង់ក្រោកឡើងអំពីអាសនៈ ធ្វើប្រទក្សិណដើមឈើនោះហើយ កាន់ថាសយាងទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ។ ក្នុងថ្ងៃដែលព្រះពោធិសត្វទាំងឡាយត្រាស់ដឹង មានកំពង់ (មួយ) ឈ្មោះសុប្បតិដ្ឋិតៈ ជាស្ថានទីដែលទ្រង់ចុះស្រង់ ។ ព្រះពោធិសត្វដាក់ថាសលើច្រាំងនៃកំពង់ឈ្មោះសុប្បតិដ្ឋិតៈនោះ ទ្រង់ចុះស្រង់ស្រេចហើយ ទើបស្លៀកសំពត់ដែលជាទង់ជ័យនៃព្រះអរហត្ត ដែលជាគ្រឿងដណ្តប់របស់

ព្រះពុទ្ធទាំងឡាយ ទ្រង់បែរព្រះភក្ត្រទៅកាន់ទិសខាងកើត ទ្រង់ពូតពំនូត បាយជា ៤៩ ពំនូត ប្រមាណប៉ុនគ្រាប់ត្នោតនីមួយៗ ហើយទ្រង់សោយមធុបាយាសមានទឹកតិចនោះទាំងអស់ បាយាសនោះ បានជាអាហារតាំងនៅអស់ ៧ សប្តាហ៍ សម្រាប់ព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធប្រថាប់នៅត្រង់ពោធិមណ្ឌលប្រទេស ដែលជាទីផូរផង់នៃបញ្ញាជាគ្រឿងត្រាស់ដឹង ។ ក្នុងកាលមានប្រមាណប៉ុណ្ណោះ មិនមានអាហារដទៃ មិនមានការស្រង់ទឹក មិនមានការខ្ពុរព្រះឱស្ឋ មិនមានការបន្ទោបង់ព្រះឧច្ចារៈព្រះបស្សាវៈ ទ្រង់សម្ងំនៅដោយឈានសុខនិងផលសុខប៉ុណ្ណោះ ។ ព្រះមហាបុរស កាលទ្រង់សោយបាយាសនោះហើយ ចាប់ថាសមាសធ្វើការអធិដ្ឋានថា **សចាហំ អជ្ជ ពុទ្ធោ ភវិតុំ សក្ខិស្សាមិ អយំ ចាតិ បដិសោតំ គច្ឆតុ នោ ចេ សក្ខិស្សាមិ អនុសោតំ គច្ឆតុ** បើអាត្មាអញបានត្រាស់ជាព្រះពុទ្ធក្នុងថ្ងៃនេះសោត ថាសមាសនេះ ចូរអណ្តែតច្រាសខ្សែទឹក បើមិនបានត្រាស់ទេ ចូរអណ្តែតទៅតាមខ្សែទឹក ។ កាលអធិដ្ឋានដូច្នេះហើយ ក៏លែងថាសទៅ ថាសនោះ ក៏អណ្តែតច្រាសខ្សែទឹកទៅអស់ទីប្រមាណ ៨០ ហត្ថ ប្រៀបដូចសេះដែលដល់ព្រមដោយថ្វីជើងដ៏រហ័សដូច្នោះ ហើយក៏លិចក្នុងអន្លង់មួយទៅដល់ពិភពកាឡនាគ ប៉ះនឹងថាសដែលជាគ្រឿងបរិភោគរបស់ព្រះពុទ្ធ ៣ ព្រះអង្គ ទង្គិចគ្នាមានសំឡេងក្រិកៗ ហើយបានចូលទៅអំពីខាងក្រោមថាសទាំង ៣ នោះ ។

*កាឡនាគរាជបានស្តាប់សំឡេងនោះហើយ ពោលថា* **ហិយ្យោ ឯកោ ពុទ្ធោ និព្វត្តោ បុន អជ្ជ ឯកោ និព្វត្តោតិ** *ម្សិលមិញនេះ ព្រះពុទ្ធកើតឡើងមួយអង្គ ថ្ងៃនេះ កើតឡើងមួយអង្គទៀត ទើបបានឈរនមស្ការដោយគាថាទាំងឡាយ ច្រើនរយបទ ។ បានឮថា វេលាដែលមហាប្រឹថពីដុះឡើង ក្នុងអាកាសប្រមាណ ១ យោជន៍ និង ៣ គាវុត ហាក់ដូចជាថ្ងៃនេះ និងថ្ងៃស្អែកដល់កាឡនាគរាជនោះ ។*

*ចំណែកព្រះបរមពោធិសត្វ ទ្រង់សម្រាកពេលថ្ងៃក្នុងសាលវ័នដែលមានផ្ការីកស្គុសស្គាយក្បែរឆ្នេរស្ទឹងនោះ លុះវេលាល្ងាច ក្នុងកាលដែលផ្កាឈើទាំងឡាយជ្រុះចាកទង ទ្រង់បែរព្រះភក្ត្រទៅកាន់ពោធិព្រឹក្សតាមផ្លូវដែលមានទទឹងប្រមាណ ៨ ឧសភ ដែលទេវតាទាំងឡាយតាក់តែងទុកដូចសីហៈយាត្រាដូច្នោះ ។ នាគ យក្ស និងគ្រុឌជាដើម បានបូជាដោយគ្រឿងក្រអូបនិងផ្កាជាដើមដ៏ជាទិព្វ ម៉ឺនលោកធាតុមានក្លិនក្រអូបដូចគ្នាមានរបៀបនៃកម្រងផ្កាតែ ១ និងមានសំឡេងសាធុការតែ ១ ។ សម័យនោះ ព្រាហ្មណ៍ឈ្មោះសោត្ថិយៈ ជាអ្នកច្រូតស្មៅ រែកស្មៅដើរច្រាសផ្លូវមក ដឹងអាការរបស់ព្រះមហាបុរសក៏ថ្វាយស្មៅ ៨ ក្តាប់ ព្រះពោធិសត្វទទួលស្មៅហើយឡើងកាន់ពោធិមណ្ឌល ប្រថាប់ឈរក្នុងទិសខាងត្បូងបែរព្រះភក្ត្រទៅទិសខាងជើង ខណៈនោះ ចក្រវាលទិសខាងត្បូងក៏ស្រុតចុះ ហាក់បីដូចជាទល់គ្នានឹងអវិចីខាងក្រោម ចក្រវាលទិសខាងជើងក៏*

អណ្តែតឡើង ហាក់បីដូចជាទល់គ្នានឹងភវគ្គព្រហ្មខាងលើ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ទីនេះ មិនមែនជាទីដែលឲ្យសម្រេចសម្ពោធិញ្ញាណទេ ទើបធ្វើប្រទក្សិណាយាងទៅកាន់ទិសខាងលិច ប្រថាប់ឈរបែរព្រះភក្ត្រទៅកាន់ទិសខាងកើត លំដាប់នោះ ចក្រវាលទិសខាងលិចក៏ស្រុតចុះ ហាក់បីដូចជាទល់គ្នានឹងអវិចី ចក្រវាលទិសខាងកើតក៏អណ្តែតឡើង ហាក់បីដូចជាទល់គ្នានឹងភវគ្គព្រហ្ម បានឮថា ក្នុងទីដែលព្រះមហាបុរសនោះប្រថាប់ឈរហើយ មហាប្រឹថពីក៏បានស្រុតចុះនិងបះឡើង ដូចកង់រទេះធំដែលដាក់ដុំបញ្ឈរត្រង់ផែនដី កាលបុគ្គលជាន់ម្ខាងហើយ ម្ខាងទៀតក៏បះឡើងដូច្នោះ ព្រះបរមពោធិសត្វ ទ្រង់ព្រះតម្រិះថា ស្ថានទីនេះ ប្រហែលជាមិនមែនស្ថានទីដែលសម្រាប់សម្រេចសម្ពោធិញ្ញាណ ទើបធ្វើប្រទក្សិណាយាងទៅកាន់ទិសខាងជើង ប្រថាប់ឈរបែរព្រះភក្ត្រទៅទិសខាងត្បូង លំដាប់នោះ ចក្រវាលទិសខាងជើងក៏ស្រុតចុះ ហាក់បីដូចជាទល់គ្នានឹងអវិចី ចក្រវាលទិសខាងត្បូងក៏អណ្តែតឡើង ហាក់បីដូចជាទល់គ្នានឹងភវគ្គព្រហ្ម ព្រះបរមពោធិសត្វទ្រង់ព្រះតម្រិះថា ស្ថានទីនេះ ក៏ប្រហែលជាមិនមែនស្ថានទីដែលត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ទើបទ្រង់ធ្វើប្រទក្សិណាយាងទៅកាន់ទិសខាងកើត ប្រថាប់ឈរបែរព្រះភក្ត្រទៅទិសខាងលិច ។ ស្ថានទីកើតបល្ល័ង្ករបស់ព្រះពុទ្ធទាំងឡាយមាននៅក្នុងទិសខាងកើត ទើបទីនោះមិនញាប់ញ័រ មិនកក្រើករំពើក ព្រះមហាសត្វ ទ្រង់ជ្រាបថា ស្ថានទីនេះ

ជាស្ថានទីព្រះពុទ្ធទាំងឡាយ ទ្រង់មិនលះបង់ ជាស្ថានទីមិនញាប់ញ័រ ជាស្ថានទីកម្ចាត់ទ្រុងគឺកិលេស ទើបទ្រង់ចាប់ចុងស្មៅ ហើយរលាស់ រំពេចនោះឯង ក៏មានបល្ល័ង្កកម្ពស់ ១៤ ហត្ថផុសឡើង ស្មៅទាំងនោះក៏តាំងនៅដោយការក្រាលបែបនោះ ឈ្មោះថាជាងគំនូររចនា បូកលាប សូម្បីជាអ្នកឈ្លាសក្រៃលែង ក៏មិនអាចនឹងគូរ នឹងបូកលាបបាន ។

ព្រះមហាបុរសបែរព្រះភក្ត្រទៅទិសខាងកើត ឲ្យដើមពោធិនៅអំពីខាងក្រោយព្រះបិដ្ឋិ ជាអ្នកមានព្រះទ័យមាំទាំ ទ្រង់គង់លើអបរាជិតបល្ល័ង្កដែលសូម្បីរន្ទះ ១ រយដងក៏មិនអាចទម្លាយ ដោយទ្រង់អធិដ្ឋានថា

**កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ មេ សរីរេ អវសុស្សតុ មំសលោហិតំ ។ ន ត្វេវាហំ សម្មាសម្ពោធឹ អប្បត្វា ឥមំ បល្លង្កំ ន ភិន្ទិស្សាមិ ។** សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ [១] ។ កាលអាត្មាអញមិនសម្រេចសម្មាសម្ពោធិញ្ញាណលើបល្ល័ង្កនេះ ក៏នឹងមិនទម្លាយភ្នែននេះ ។

សម័យនោះ ទេវបុត្តមារគិតថា សិទ្ធត្ថកុមារបំណងនឹងឈានកន្លងអំណាចរបស់អញ ឥឡូវនេះ អញនឹងមិនឲ្យសិទ្ធត្ថកុមារនោះ កន្លងផុត

---

១- បិ.២៣ , ទំ. ៤០៥ ។

ទៅបាន ទើបទៅកាន់សម្នាក់របស់ពលមារប្រាប់សេចក្ដីនោះ ឲ្យពលមារស្រែកហ៊ោកញ្ជ្រៀវហើយនាំចេញទៅ ។ ឯសេនាមារនោះ ខាងមុខមានកម្រាស់ ១២ យោជន៍ ខាងស្ដាំនិងខាងឆ្វេង ១២ យោជន៍ ខាងក្រោយទល់គ្នានឹងភ្នំកណ្ដាប់ចក្រវាល ខាងលើ ៩ យោជន៍ ដែលបន្ទឺសំឡេងហាក់ដូចជាផែនដីស្រុត តាំងអំពីទីប្រមាណ ១ ពាន់យោជន៍ លំដាប់នោះ ទេវបុត្ត-មារឡើងជិះដំរីឈ្មោះ គិរិមេខល កម្ពស់ ១៥០ យោជន៍ និម្មិតដៃ ១ ពាន់កាន់អាវុធច្រើនប្រការ ។ ចំណែកបរិស័ទមារក្រៅពីនេះ មារពីរនាក់កាន់អាវុធដូចគ្នាមិនមាន ជាអ្នកមានពណ៌សម្បុរផ្សេងៗ ជាអ្នកមានមុខផ្សេងៗនាំគ្នាមក ហាក់បីដូចជាជោរជន់លិចព្រះមហាសត្វ ។ ឯទេវតាក្នុងម៉ឺនចក្រវាលបានឈរពោលសរសើរព្រះមហាសត្វ ចំណែកសក្កទេវរាជបានឈរផ្លុំស័ង្ខឈ្មោះវិជយុត្តរៈ បានឮថា ស័ង្ខនោះមានប្រវែង ១២០ ហត្ថកាលផ្លុំខ្យល់ចូលទៅតែម្ដងហើយ មានសំឡេងតាំងនៅអស់ ៤ ខែ ទើបសំឡេងនោះអស់ទៅ ។ មហាកាឡនាគរាជបានឈរពោលសរសើរគុណជាង ១០០ គាថា មហាព្រហ្មបានឈរបាំងស្វេតច្ឆត្រ តែកាលពលមារចូលមកជិតពោធិបល្ល័ង្ក បណ្ដាទេវតាជាដើមនោះ សូម្បីតែម្នាក់ក៏មិនអាចតាំងនៅបាន នាំគ្នាគេចទៅក្នុងទីចំពោះមុខរៀងៗ ខ្លួន ។ មហាកាឡនាគរាជជ្រែកដីទៅកាន់នាគពិភព ដែលមានមណ្ឌលប្រមាណ ៥០០ យោជន៍ ដេកយកដៃទាំងពីរខ្ទប់មុខ សក្កទេវរាជយកស័ង្ខវិជយុត្តរៈទុក

អំពីខាងក្រោយ បានឈរត្រង់ក្តិកណ្តាប់ចក្រវាល មហាព្រហ្មចាប់ចុង ស្វេតច្ឆត្រទៅកាន់ព្រហ្មលោកមួយរំពេច ទេវតាសូម្បីតែមួយអង្គដែល អាចតាំងនៅបាន មិនមាន ព្រះមហាបុរសមួយអង្គឯងប៉ុណ្ណោះ ប្រថាប់ គង់ក្នុងទីនោះ ។

ចំណែកមារក៏ពោលនឹងបរិស័ទរបស់ខ្លួនថា នែបាទាំងឡាយ ឈ្មោះ ថា បុរសដទៃដូចគ្នានឹងសិទ្ធត្ថឱរសរបស់ព្រះបាទសុទ្ធោទនមហារាជ រមែង មិនមាន ពួកយើងមិនអាចធ្វើនូវចម្បាំងក្នុងទីចំពោះមុខ ពួកយើងនឹងចូល ចាប់អំពីខាងក្រោយ ។ ព្រះមហាបុរសសម្លឹងមើលក្នុងទិសទាំង ៣ ឃើញ តែភាពទទេ ព្រោះទេវតាទាំងពួងនាំគ្នាគេចទៅអស់ ទ្រង់ឃើញពលមារ ពពាក់ពពូននៅអំពីខាងលើ ទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះ បំណងមករកអាត្មាអញតែម្នាក់ ដែលធ្វើសេចក្តីព្យាយាមយ៉ាងធំក្នុងទីនេះ មិនមានមាតាបិតា បុត្តធីតា បងប្អូនប្រុសស្រី ឬញាតិណាដទៃ មានតែបារមី ១០ នេះប៉ុណ្ណោះ ដែលដូចជាបុត្តនិងបរិវាររបស់អញ នៅអស់កាលយូរ ព្រោះដូច្នោះ អញនឹងធ្វើបារមីនេះឲ្យជាខែល ហើយប្រហារដោយសាស្ត្រា គឺបារមីនោះឯង កម្ចាត់ពលមារនេះ ទើបគួរ ទើបទ្រង់រឭកដល់បារមីទាំង ១០ ។ លំដាប់នោះ ទេវបុត្តមារបានបណ្តាលមណ្ឌលប្រទេសនៃខ្យល់ឲ្យ តាំងឡើង ដោយគិតថា អញនឹងឲ្យសិទ្ធត្ថនេះគេចទៅដោយខ្យល់នេះឯង ខណៈនោះ មណ្ឌលខ្យល់ មានខ្យល់បក់មកអំពីទិសខាងកើតជាដើម បាន

តាំងឡើងហើយ សូម្បីអាចទម្លាយកំពូលភ្នំដែលមានទំហំកន្ទះយោជន៍ ១ យោជន៍ ២ យោជន៍ ៣ យោជន៍ ដកឫសឈើ គុម្ពឈើនិងដើមឈើជាដើម និងធ្វើគាមនិគមជុំវិញឲ្យខ្ទេចខ្ទី ជាលម្អិតតូចធំ ក៏ត្រូវតេជានុភាពនៃបុណ្យរបស់ព្រះមហាបុរសកម្ចាត់ហើយ លុះមកដល់ព្រះពោធិសត្វ ក៏មិនអាចធ្វើសូម្បីតែជាយចីវរឲ្យកម្រើក ។ លំដាប់នោះ ទេវបុត្តមារបានបណ្តាលឲ្យកើតជាភ្លៀងធំតាំងឡើង ដោយបំណងថា នឹងឲ្យទឹកជន់លិចស្លាប់ ដោយអានុភាពរបស់ទេវបុត្តមារនោះ ពពក ១ រយស្រទាប់និង ១ ពាន់ស្រទាប់ ក៏តាំងឡើងខាងលើហើយធ្លាក់ចុះមក ផែនដីក៏ដាច់ធ្លុះជាចន្លោះៗ ទៅដោយកម្លាំងនៃធ្លារទឹកភ្លៀង មហាមេឃក៏អណ្តែតមកអំពីខាងលើដើមឈើនិងព្រៃ ក៏មិនអាចធ្វើឲ្យដំណក់ទឹកត្រឹមតែមួយតំណក់ សើមជាយចីវររបស់ព្រះមហាសត្វបានឡើយ ។ បន្ទាប់អំពីនោះ ក៏បណ្តាលឲ្យភ្លៀងថ្មតាំងឡើង កំពូលភ្នំធំៗ ទង្គិចគ្នាហុយជាផ្សែង បែកជាអណ្តាតភ្លើង ធ្លាក់ចុះមកអំពីអាកាស លុះមកដល់ព្រះបរមពោធិសត្វ ក៏ត្រឡប់ក្លាយជាផ្កាឈើទិព្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលឲ្យភ្លៀងគ្រឿងប្រហារតាំងឡើង សស្ត្រាវុធមានដាវ លំពែង និងព្រួញជាដើម ដែលមានមុខម្ខាងខ្លះ មានមុខសងខាងខ្លះធ្លាក់មកទង្គិចគ្នា ហុយជាផ្សែងឆេះជាភ្លើង អណ្តែតមកតាមអាកាស លុះមកដល់ព្រះពោធិសត្វក៏ក្លាយជាផ្កាឈើទិព្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលឲ្យមានភ្លៀង ជាភ្លៀងរងើកភ្លើងតាំងឡើង រងើក

ភ្លើងទាំងឡាយមានពណ៌ដូចផ្កាចារ អណ្តែតមកតាមអាកាស ក្លាយជាផ្កាទិព្វ បាចសាចរោយរាយចុះមកទៀបបាទមូលរបស់ព្រះមហាសត្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលឲ្យមានភ្លៀងផេះតាំងឡើង ភ្លៀងផេះក្តៅខ្លាំងមានពណ៌ដូចភ្លើងអណ្តែតមកតាមអាកាស ក៏ក្លាយជាលម្អិតនៃខ្លឹមចន្ទន៍ធ្លាក់ចុះទៀបបាទមូលរបស់ព្រះមហាសត្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលឲ្យភ្លៀងខ្សាច់តាំងឡើង ខ្សាច់ទាំងឡាយល្អិតធ្លាក់មកប៉ះគ្នាក្លាយជាផ្សែងនិងអណ្តាតភ្លើង អណ្តែតមកពីអាកាសក៏ក្លាយជាផ្កាឈើទិព្វ ធ្លាក់ចុះទៀបបាទមូលរបស់ព្រះពោធិសត្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលភ្លៀងភក់ឲ្យតាំងឡើង ភក់នោះជាភក់ក្តៅ ប្រកបដោយផ្សែងនិងភ្លើងអណ្តែតចុះមកអំពីអាកាស ក្លាយជាគ្រឿងលាបស្រលាបដ៏ជាទិព្វ ធ្លាក់ចុះមកទៀបបាទមូលរបស់ព្រះមហាសត្វ ។ បន្ទាប់អំពីនោះ ក៏បណ្តាលងងឹតឲ្យតាំងឡើងដោយគិតថា អញនឹងធ្វើឲ្យភ័យខ្លាចដោយភាពងងឹតនេះ ហើយឲ្យសិទ្ធត្ថនេះរត់ទៅ ។ ងងឹតនោះជាងងឹតប្រកបដោយអង្គ ៤ ( គឺថ្ងៃ ១៤ រោច ព្រៃស្តុក មេឃខ្មៅ និងកណ្តាលយប់ ) លុះមកដល់ព្រះមហាសត្វក៏អន្តរធានទៅ ដូចងងឹតដែលត្រូវកម្ចាត់ដោយពន្លឺព្រះអាទិត្យ ។ មារមិនអាចឲ្យព្រះពោធិសត្វគេចទៅបានដោយខ្យល់ ភ្លៀង ភ្លៀងដុំថ្ម ភ្លៀងគ្រឿងប្រហារ ភ្លៀងរងើកភ្លើង ភ្លៀងផេះ ភ្លៀងខ្សាច់ ភ្លៀងភក់ និងភាពងងឹតរួមជា ៩ យ៉ាងនេះ ដោយប្រការដូច្នេះ ទើបបញ្ជាបរិស័ទនោះ

ថា នែអ្នកទាំងឡាយ ពួកអ្នកឈប់បង្អង់ធ្វើអ្វី ចូរចាប់សិទ្ធត្ថកុមារនេះ ចូរសម្លាប់ ចូរធ្វើឲ្យគេចទៅ ចំណែកខ្លួនឯងអង្គុយលើកដំរីគិរិមេខល កាន់ចក្រាវុធចូលទៅជិតព្រះមហាបុរស ហើយពោលថា នែសិទ្ធត្ថ អ្នកចូរក្រោកឡើងអំពីបល្ល័ង្កនេះ បល្ល័ង្កនេះមិនមែនសម្រាប់អ្នកទេ បល្ល័ង្កនេះគួរដល់យើង ។

ព្រះបរមពោធិសត្វបានស្តាប់ពាក្យរបស់មារនោះហើយ ត្រាស់ថា នែមារ អ្នកមិនបានបំពេញបារមី ១០ ឧបបារមី ១០ និងបរមត្ថបារមី ១០ ផង មិនបានបំពេញមហាបរិច្ចាគ ៥ ផង មិនបានបំពេញញាតត្ថ-ចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយាផង បល្ល័ង្កនេះមិនមែនកើតឡើងសម្រាប់អ្នកទេ បល្ល័ង្កនេះ កើតឡើងដល់យើងតែប៉ុណ្ណោះ ។ មារក្រោធអត់សង្កត់នឹងសេចក្តីក្រោធមិនបាន ទើបគ្រវែងចក្រាវុធមកលើព្រះពោធិ-សត្វ ។ កាលព្រះមហាសត្វរំពឹងដល់បារមី ១០ ចក្រាវុធនោះ ក៏ក្លាយជាពិដានផ្កាតាំងនៅអំពីខាងលើ បានឮថា ចក្រាវុធនោះមុតក្រៃពេក បើមារនោះក្រោធហើយ គ្រវែងទៅក្នុងទីដទៃៗ អាចកាត់សសរថ្មដ៏ក្រាស់តែម្តងប៉ុណ្ណោះឲ្យដាច់ទៅ ដូចកាត់ទំពាំងដូច្នោះ តែឥឡូវនេះ កាលចក្រាវុធនោះ ក្លាយជាពិដានផ្កាតាំងនៅ បរិស័ទមារក្រៅអំពីនេះ គិតថា សិទ្ធត្ថកុមារនឹងក្រោកចាកអំពីបល្ល័ង្ក បេញទៅក្នុងកាលឥឡូវនេះ ទើបនាំគ្នាលែងនូវកំពូលភ្នំថ្មធំៗ ចុះមក ។ កាលព្រះមហាបុរស ទ្រង់ពិចារណាដល់

បារមី ១០ កំពូលភ្នំធំៗ ទាំងនោះ ដល់នូវភាវៈជាដុំផ្កា ធ្លាក់ចុះមកកាន់ផែនដី ។ ទេវតាទាំងឡាយដែលឈរត្រង់ភ្នំកណ្តាប់ចក្រវាល អើតកមើលដោយគិតថា លោកដ៏ចម្រើនទាំងឡាយ អត្តភាពដែលល្អដល់ម៉្លេះរបស់សិទ្ធត្ថកុមារ វិនាសហើយហ្ន៎ សិទ្ធត្ថកុមារនឹងធ្វើអ្វីហ្ន៎ ។

លំដាប់នោះ ព្រះមហាបុរសត្រាស់ ( នឹងមារ ) ថា បល្ល័ង្កនេះ កើតឡើងដល់យើង ក្នុងថ្ងៃដែលព្រះពោធិសត្វទាំងឡាយបំពេញបារមីហើយត្រាស់ដឹងក្រៃលែង ដូច្នេះ ។ ហើយទ្រង់ត្រាស់នឹងមារដែលឈរបន្តទៀតថា ម្នាលមារ អ្នកណាជាសាក្សីក្នុងភាពដែលអ្នកឲ្យទានហើយ ?

មារលាដៃទៅត្រង់ទីចំពោះមុខពលមារ ដោយពោលថា ជនមានប្រមាណប៉ុណ្ណេះជាសាក្សី ខណៈនោះ សំឡេងបរិស័ទរបស់មារក៏លាន់ឮតែមួយថា យើងជាសាក្សី យើងជាសាក្សី ដូច្នេះ ហាក់បីដូចជាសំឡេងផែនដីស្រុត ។ លំដាប់នោះ មារក៏ពោលនឹងព្រះមហាបុរសថា នែសិទ្ធត្ថក្នុងភាវៈដែលអ្នកឲ្យទាន អ្នកណាជាសាក្សី អ្នកណាជាបន្ទាល់ ?

ព្រះមហាបុរសត្រាស់ថា មុនដំបូងក្នុងភាវៈដែលអ្នកឲ្យទាន ពលមារទាំងឡាយជាអ្នកមានចិត្តជាសាក្សី តែសម្រាប់យើង បុគ្គលដែលមានចិត្តឈ្មោះថាជាសាក្សី រមែងមិនមានក្នុងទីនេះ ក្នុងស្ថានទីដែលយើងឲ្យហើយក្នុងអត្តភាពដទៃៗ ចូរលើកទុកចុះ ក្នុងភាវៈដែលយើងតាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ បានឲ្យសត្តសតកមហាទាន គឺឲ្យវត្ថុមួយមុខ ៧

រយៗ មហាប្រឹថពីដ៏ក្រាស់នេះ សូម្បីមិនមានចិត្ត មិនមានវិញ្ញាណ ក៏ជាសាក្សី ( ត្រាស់ហើយ ) ទើបទ្រង់យកព្រះហស្តស្តាំចេញមកអំពីស្រទាប់ចីវរ ហើយទ្រង់លាចុះទៅកាន់ផែនដី មួយអន្ទើដោយព្រះតម្រាស់ថា ក្នុងកាលដែលយើងតាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ហើយឲ្យសត្តសតកមហាទាន អ្នកជាសាក្សីឬក៏មិនមែន ? មហាប្រឹថពីបានកក្រើករំពើកហាក់បីដូចជាលិចលង់ដល់ពលមារ ដោយសំឡេង ១ ពាន់ថា ក្នុងកាលនោះ ខ្ញុំជាសាក្សី បន្ទាប់អំពីនោះ មហាប្រឹថពីហាក់ដូចជាពោលថា បពិត្រព្រះសិទ្ធត្ថ ទានដែលទ្រង់ឲ្យហើយ ជាមហាទាន ជាឧត្តមទាន ។ កាលព្រះមហាបុរសពិចារណាទៅដល់ទានដែលបានឲ្យហើយ ក្នុងអត្តភាពជាព្រះវេស្សន្តរ ដំរីគិរិមេខលកម្ពស់ ១៥០ យោជន៍ក៏លុតជង្គង់ចុះ បរិស័ទរបស់មារក៏នាំគ្នាកៀសផាយទៅកាន់ទិសានុទិស ឈ្មោះថា មារពីរនាក់ទៅផ្លូវតែមួយមិនមាន មារទាំងនោះ លះបង់គ្រឿងប្រដាប់ក្បាល និងសំពត់ស្លៀកសំពត់ដណ្តប់ គេចទៅក្នុងទីទាំងឡាយរៀងៗខ្លួន ត្រង់ផ្លូវដែលមានក្នុងទីចំពោះមុខ ។ លំដាប់នោះ ពួកទេវតាទាំងឡាយឃើញពលមាររត់ទៅហើយ ក៏ពោលថា មារបរាជ័យហើយ ព្រះសិទ្ធត្ថកុមារមានជ័យជម្នះហើយ ពួកយើងមកធ្វើការបូជានូវជ័យជម្នះចុះ ដូច្នេះ ។ ពួកនាគក៏ប្រកាសដល់ពួកនាគ ពួកគ្រុឌក៏ប្រកាសដល់ពួកគ្រុឌ ពួកទេវតាក៏ប្រកាសដល់ពួកទេវតា ពួកព្រហ្មក៏ប្រកាសដល់ពួកព្រហ្ម មានដៃកាន់នូវផ្កាកម្រង

និងគ្រឿងក្រអូបជាដើម មកកាន់ពោធិបល្ល័ង្ករបស់ព្រះមហាបុរស កាលមារនិងពលមារទាំងនោះ ចៀសចេញទៅយ៉ាងនេះហើយ ( ទើបនាគជាដើម មកថ្វាយសាធុការដូច្នេះថា )

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

ក្នុងកាលនោះ ពួកនាគ មានចិត្តត្រេកអរ ប្រកាសនូវជ័យជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធដ៏មានសិរី ទ្រង់មានជ័យជម្នះ ចំណែកមារមានចិត្តបាបចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
សុបណ្ណសំឃាបិ ជយំ មហេសិនោ ។

ក្នុងកាលនោះ ពួកគ្រុឌ ក៏មានចិត្តត្រេកអរ ប្រកាសនូវជ័យជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធដ៏មានសិរី ទ្រង់មានជ័យជម្នះ ចំណែកមារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ

មារស្ស ច បាបិមតោ បរាជយោ
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា នាគគណា មហេសិនោ ។

ក្នុងកាលនោះ ពួកទេវតា មានចិត្តត្រេកអរ ប្រកាសនូវជ័យជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធដ៏មានសិរី ទ្រង់មានជ័យជម្នះ ចំណែកមារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

ជយោ ហិ ពុទ្ធស្ស សិរីមតោ អយំ
មារស្ស ច បាបិមតោ បរាជយោ
ឧគ្ឃោសយុំ ពោធិមណ្ឌេ បមោទិតា
ជយំ តទា ព្រហ្មគណាបិ តាទិនោតិ ។

ក្នុងកាលនោះ សូម្បីពួកព្រហ្ម ក៏មានចិត្តត្រេកអរ ប្រកាសនូវជ័យជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធដ៏មានសិរី ទ្រង់មានជ័យជម្នះ ចំណែកមារមានចិត្តបាប ចាញ់ព្រះអង្គហើយ ដូច្នេះ ។

ទេវតាក្នុងម៉ឺនចក្រវាលដ៏សេស បូជាដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបជាដើម បានឈរពោលសរសើរមានប្រការផ្សេងៗ ។ កាលព្រះអាទិត្យអស្តង្គតហើយ ព្រះមហាបុរសទ្រង់កម្ចាត់មារ និងសេនាបានហើយ ត្រួយពោធិព្រឹក្សក៏ធ្លាក់ចុះលើចីវរ ហាក់បីដូចជាត្របកនៃកែវ

ប្រពាលក្រហម ដើម្បីជាការបូជា ។ ព្រះមហាបុរស ទ្រង់រឭកបាននូវបុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ទ្រង់ញ៉ាំងញាណឲ្យឈមចុះក្នុងបដិច្ចសមុប្បាទក្នុងបច្ឆិមយាម កាលព្រះមហាបុរសពិចារណាបច្ចយាការដែលប្រកបដោយអង្គ ១២ ដោយអនុលោមនិងបដិលោម ដោយអំណាចវដ្តនិងវិវដ្ត ម៉ឺនលោកធាតុញាប់ញ័រអស់ ១២ ដង ទល់គ្នានឹងទឹកទ្រផែនដី ។ ព្រះមហាបុរស ញ៉ាំងម៉ឺនលោកធាតុឲ្យញាប់ញ័រហើយ ទ្រង់បានត្រាស់ដឹងនូវព្រះសព្វញ្ញុតញ្ញាណ ក្នុងវេលាអរុណរះ ។ កាលព្រះមហាបុរស ទ្រង់បានសម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ម៉ឺនលោកធាតុទាំងមូលហាក់ដូចជាប្រដាប់តាក់តែងហើយ មានរស្មីនៃទង់ជ័យនិងទង់ផ្កាលា លើកឡើងត្រង់ភ្នំកណ្តាប់ចក្រវាលទិសខាងកើត ទល់គ្នានឹងភ្នំកណ្តាប់ចក្រវាលទិសខាងលិច លើកឡើងត្រង់ភ្នំកណ្តាប់ចក្រវាលទិសខាងលិច ទល់គ្នានឹងភ្នំកណ្តាប់ចក្រវាលទិសខាងកើត លើកឡើងត្រង់ភ្នំកណ្តាប់ចក្រវាលទិសខាងជើង ទល់គ្នានឹងភ្នំកណ្តាប់ចក្រ-វាលទិសខាងត្បូង លើកឡើងត្រង់ភ្នំកណ្តាប់ចក្រវាលទិសខាងត្បូង ទល់គ្នានឹងភ្នំកណ្តាប់ចក្រវាលទិសខាងជើង សុទ្ធតែមានរស្មីនៃទង់ជ័យនិងទង់ផ្កាលា លើកឡើងលើប្រឹថពីបានតាំងនៅរហូតដល់ព្រហ្មលោក រស្មីដែលតាំងនៅក្នុងព្រហ្មលោក ក៏ហាក់ដូចជាមកទល់គ្នានឹងផែនដី ដើមឈើក្នុងម៉ឺនចក្រវាលក៏ចេញផ្កា ដើមឈើណាដែលមានផ្លែក៏ចេញផ្លែ ផ្កាឈូក

គ្រប់ប្រភេទ ត្រង់ដើមឈើឈូកដើមក៏ចេញផ្កាអំពីដើម ឈូកមែកក៏ចេញផ្កាអំពីមែក ឈូកវល្លិក៏ចេញផ្កាអំពីវល្លិ ឈូកអាកាសក៏មានផ្កាសំយុងចុះមកអំពីអាកាស ឈូកស្រទាប់ក៏ទម្លុះផែនថ្មដុះឡើង ត្រួតគ្នាជាជាន់ៗមួយកន្ទេងប្រាំពីរផ្កាៗ ម៉ឺនលោកធាតុវិលទៅដូចដុំអំបោះដែលគេបោះទៅនិងដូចគ្រឿងកម្រាលដែលគេក្រាលទុកល្អហើយដូច្នោះ ។ លោកន្តរនរកដែលមានទទឹង ៥០០ យោជន៍ ក្នុងចន្លោះនៃចក្រវាលទាំងឡាយដែលមិនធ្លាប់បានស្គាល់នូវពន្លឺ ក៏ភ្លឺដូចព្រះអាទិត្យ ៧ ដួង មហាសមុទ្រដែលមានជម្រៅ ៨៤.០០០ យោជន៍ ក៏ក្លាយជាទឹកផ្អែម ស្ទឹងទាំងឡាយមិនហូរ មនុស្សខ្វាក់អំពីកំណើតឃើញរូប មនុស្សថ្លង់អំពីកំណើតក៏បានឮសំឡេង មនុស្សខ្វិនអំពីកំណើតក៏ដើរបាន កម្មករណៈទាំងឡាយ មានចំណងនិងខ្នោះជាដើម ក៏បានដាច់បាក់បែកទៅ ។ ព្រះមហាបុរសត្រូវពួកទេវតានិងមនុស្សទាំងឡាយ បូជាដោយសម្បត្តិដែលប្រកបដោយសិរី មិនមានប្រមាណដោយប្រការដូច្នេះ កាលអច្ឆរិយធម៌ដែលគួរអស្ចារ្យទាំងឡាយមានប្រការផ្សេងៗ ប្រាកដហើយ ព្រះមហាបុរសទ្រង់បានចាក់ធ្លុះនូវព្រះសព្វញ្ញុតញ្ញាណ ទើបទ្រង់បន្លឺឧទាន ដែលព្រះពុទ្ធទាំងឡាយមិនដែលលះបង់ដូច្នេះថា

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្វិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។

**គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ**
**សព្វា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ**
**វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

*នៃជាងផ្ទះ អ្នកឯងធ្វើផ្ទះគឺអត្តភាព តថាគតឃើញហើយ អ្នកនឹងធ្វើផ្ទះ (របស់តថាគត) ទៀត មិនបានឡើយ ឆ្អឹងជំនីរគឺកិលេសរបស់អ្នកទាំងអស់តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះគឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគត ដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគត បានដល់ធម៌ជាគ្រឿងក្ស័យតណ្ហាទាំងឡាយហើយ* [១] ។

*ឋានៈមានប្រមាណប៉ុណ្ណេះ ផ្ដើមតាំងអំពីតុសិតបុរី រហូតមកទល់គ្នានឹងសម្រេចព្រះសព្វញ្ញុតញ្ញាណ ត្រង់មណ្ឌលពោធិព្រឹក្សនេះ គប្បីជ្រាបឈ្មោះថា* **អវិទូរេនិទាន** *ដោយប្រការដូច្នេះ ។*

ចប់ អវិទូរេនិទាន ។

---

*១- បិ.៥២ , ទំ. ៥៤ ។*

# សន្តិកេនិទាន

ក្នុង **សន្តិកេនិទាន** លោកពោលថា ព្រះមានព្រះភាគ កាលប្រថាប់នៅក្នុងទីនោះៗ យ៉ាងនេះថា ព្រះសាស្ដា ទ្រង់គង់នៅក្នុងវិហារជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី និងពោលថា ទ្រង់គង់ក្នុងកូដាគារសាលានាព្រៃមហាវ័ន ក្បែរក្រុងវេសាលីដូច្នេះជាដើម ។ **សន្តិកេនិទាន** រមែងមានក្នុងទីនោះៗ ឯង លោកពោលទុកយ៉ាងនេះក៏ពិត តែទោះជាដូច្នោះ **សន្តិកេនិទាន** នោះ គប្បីជ្រាបយ៉ាងនេះ ចាប់តាំងអំពីដើមតទៅថា

ព្រះមានព្រះភាគ ទ្រង់ប្រថាប់គង់នៅលើបល្ល័ង្កជ័យ បន្ទីឧទាននេះហើយមានព្រះតម្រិះថា តថាគតស្ទុះទៅ អន្ទោលទៅ អស់ ៤ អសង្ខេយ្យនិង ១ សែនកប្ប ក៏ព្រោះហេតុនៃបល្ល័ង្កនេះ តថាគតកាត់ក្បាលដែលប្រដាប់តាក់តែងហើយឲ្យទៅជាទាន អស់កាលមានប្រមាណប៉ុណ្ណោះ ក៏ព្រោះហេតុនៃបល្ល័ង្កនេះ តថាគតខ្វេះភ្នែកដែលបន្តក់ល្អហើយ ពុះទ្រូងរូងយកបេះដូងឲ្យទៅជាទាន ឲ្យនូវបុត្តដូចគ្នានឹងជាលីកុមារ ឲ្យនូវធីតាដូចគ្នានឹងកណ្ហាជិនាកុមារី និងឲ្យភរិយាដូចគ្នានឹងព្រះនាងមទ្រីទេវីដើម្បីជាទាសៈរបស់អ្នកដទៃៗ ព្រោះហេតុនៃបល្ល័ង្កនេះ បល្ល័ង្កនេះ ជាបល្ល័ង្កជ័យ ជាបល្ល័ង្កប្រសើររបស់តថាគត កាលការត្រិះរិះរបស់តថាគតដែលអង្គុយលើបល្ល័ង្កនេះ មិនបរិបូណ៌ដរាបណា តថាគតនឹងមិនក្រោក

ឡើងចាកបល្ល័ង្កនេះ ដរាបនោះ ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់គង់ចូលសមាបត្តិច្រើនសែនកោដិលើបល្ល័ង្កនោះ ដរាបអស់ ១ សប្តាហ៍ ដូចលោកពោលទុកថា

ក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់គង់សោយវិមុត្តិសុខ ដោយភ្នែនតែមួយ ដរាបអស់មួយសប្តាហ៍ គ្រានោះ ទេវតាពួកខ្លះកើតបរិវិតក្កឡើងថា ថ្ងៃនេះ ព្រះសិទ្ធត្ថនៅមានកិច្ចដែលត្រូវធ្វើឬហ្ន៎ ព្រោះមិនទាន់លះនូវអាល័យក្នុងបល្ល័ង្ក ។ ព្រះបរមសាស្តា ទ្រង់ជ្រាបការត្រិះរិះរបស់ទេវតាទាំងឡាយ ដើម្បីរម្ងាប់នូវបរិវិតក្ករបស់ទេវតាទាំងនោះ ទើបទ្រង់ហោះឡើងទៅកាន់អាកាស ទ្រង់សម្តែងយមកប្បាដិហារិយ៍ ពិតហើយយមកប្បាដិហារិយ៍ដែលទ្រង់ធ្វើនៅត្រង់មហាពោធិមណ្ឌលក្តី បាដិ-ហារិយ៍ដែលទ្រង់ធ្វើក្នុងសមាគមព្រះញាតិក្តី បាដិហារិយ៍ដែលទ្រង់ធ្វើក្នុងសមាគមអ្នកបាថិកបុត្តក្តី ទាំងអស់ជាយមកប្បាដិហារិយ៍ ដូចគ្នានឹងបាដិហារិយ៍ត្រង់មណ្ឌលគណ្ឌម្ពព្រឹក្ស (គល់ស្វាយ) នោះឯង ។

ព្រះបរមសាស្តា កាលទ្រង់រម្ងាប់នូវបរិវិតក្ករបស់ទេវតាទាំងឡាយដោយបាដិហារិយ៍នេះហើយ ទើបទ្រង់ប្រថាប់ឈរត្រង់ទិសខាងជើងបញ្ចិតទៅទិសខាងកើតបន្តិច ទ្រង់ព្រះតម្រិះថា តថាគតដឹងច្បាស់នូវសព្វញ្ញុតញ្ញាណលើបល្ល័ង្កនេះហ្ន៎ ទើបទ្រង់ទតមិនប៉ប្រិចព្រះនេត្រ ទតបល្ល័ង្កដែលជាស្ថានទីសម្រេចផលនៃបារមី ដែលទ្រង់បំពេញមកអស់

៤ អសង្ខេយ្យនិង ១ សែនមហាកប្ប ទ្រង់ទតក្នុងទីនោះអស់មួយសប្តាហ៍ ស្ថានទីនោះ ទើបមានឈ្មោះថា អនិមិសចេតិយ ។

លំដាប់នោះ ទ្រង់និម្មិតទីចង្ក្រមក្នុងរវាងបល្ល័ង្ក និងទីដែលទ្រង់ប្រថាប់ឈរ ហើយទ្រង់ចង្ក្រមក្នុងរតនចង្ក្រម ដែលលាតសន្ធឹងអំពីទិសខាងកើតទៅទិសខាងលិច ទ្រង់សម្ងំនៅមួយសប្តាហ៍ ទើបស្ថានទីនោះមានឈ្មោះថា រតនចង្កមចេតិយ ។

ក្នុងសប្តាហ៍ ទី ៤ ទេវតាទាំងឡាយ និម្មិតផ្ទះកែវក្នុងទិសពាយព្យនៃពោធិបល្ល័ង្ក ទ្រង់ប្រថាប់គង់ក្នុងផ្ទះកែវនោះ ទ្រង់ពិចារណាព្រះអភិធម្មបិដកនិងសមន្តប្បដ្ឋានអនន្តន័យ ក្នុងផ្ទះកែវនេះដោយវិសេស ទ្រង់សម្ងំនៅមួយសប្តាហ៍ ចំណែកអ្នកអភិធម្មពោលថា ផ្ទះដែលសម្រេចដោយកែវឈ្មោះថា រតនឃរ ស្ថានទីដែលទ្រង់ពិចារណាបករណ៍ទាំង ៧ គម្ពីរ ក៏ឈ្មោះថា រតនឃរ ព្រោះហេតុដែលបរិយាយទាំងពីរនេះរមែងប្រើបានក្នុងទីនេះ ដូច្នោះពាក្យទាំងពីរគួរកាន់យកនោះឯង ចាប់តាំងអំពីពេលនោះមក ស្ថានទីនោះក៏មានឈ្មោះថា រតនឃរចេតិយ ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ងំនៅក្បែរពោធិព្រឹក្សនោះឯងអស់ ៤ សប្តាហ៍ដោយអាការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ ទើបទ្រង់យាងចេញអំពីមណ្ឌលពោធិព្រឹក្ស ទៅកាន់ដើមអជបាលនិគ្រោធ ទ្រង់ពិចារណាព្រះធម៌ និងទ្រង់សោយវិមុត្តិសុខត្រង់ដើមអជបាលនិគ្រោធនោះ ។

សម័យនោះ ទេវបុត្តមារដែលជាប់តាមមកអស់កាលមានប្រមាណប៉ុណ្ណោះ មិនអាចសម្លឹងរកឱកាសបាន មិនបានឃើញការភ្លាំងភ្លាត់ ឬការខុសឆ្គងណានីមួយរបស់ព្រះសិទ្ធត្ថអង្គនេះ ក៏ដល់នូវទោមនស្សថា ឥឡូវនេះ ព្រះសិទ្ធត្ថនេះ កន្លងផុតវិស័យរបស់អញហើយ ទើបអង្គុយត្រង់ផ្លូវធំមានមុំ ៤ គិតដល់ហេតុ ១៦ ប្រការ គូសនូវគំនូស ១៦ លើផែនដី គឺគិតថា អញមិនបានបំពេញទានបារមីដូចព្រះសិទ្ធត្ថនេះ គូសលើផែនដី ១ ។ គិតថា អញមិនបានបំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី ឧបេក្ខាបារមីដូចព្រះសិទ្ធត្ថនេះ ដោយហេតុនោះ ទើបអាត្មាអញមិនដូចព្រះសិទ្ធត្ថនេះ ហើយគូសគំនូសទី ២ ដល់ទី ១០ ។ ទេវបុត្តមារនោះគិតបន្តទៀតថា អញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យដល់ការត្រាស់ដឹងអាសយានុសយញ្ញាណ ឥន្ទ្រិយបរោបរិយត្តញ្ញាណ មហាករុណាសមាបត្តិញ្ញាណ យមកប្បាដិហារិយញ្ញាណ អនាវរណញ្ញាណ និងសព្វញ្ញុតញ្ញាណដែលមិនទូទៅដល់បុគ្គលដទៃ ដូចព្រះសិទ្ធត្ថនេះ ដោយហេតុនោះ ទើបអញមិនដូចព្រះសិទ្ធត្ថនេះ ហើយគូសគំនូសទី ១១ ដល់ទី ១៦ ។ កាលទេវបុត្តមារនោះ អង្គុយគូសផែនដីត្រង់ផ្លូវធំ ដោយប្រការដូច្នេះហើយ សម័យនោះ ធីតារបស់មារ ៣ នាក់គឺ នាងតណ្ហា នាងអរតី និងនាងរាគា ពោលថា បិតារបស់ពួកយើងមិនប្រាកដ ឥឡូវ

នេះ ទ្រង់នៅទីណាហ្ន៎ ទើបសម្លឹងមើលបានឃើញទេវបុត្តមារនោះ ទទួលនូវទោមនស្សអង្គុយគូសផែនដី ក៏គិតគ្នាថា យើងនឹងទៅកាន់សម្នាក់របស់ព្រះបិតា ។ ( លុះទៅដល់ហើយ ) សួរថា បពិត្រព្រះបិតា ព្រោះហេតុអ្វីទើបទ្រង់មកអង្គុយជាទុក្ខសៅហ្មងបែបនេះ ?

ទេវបុត្តមារនោះពោលថា នែកូន មហាសមណៈនេះ កន្លង់ផុតអំណាចរបស់អញហើយ ឪពុកធ្លាប់ឃ្លាំមើលអស់កាលមានប្រមាណប៉ុណ្ណេះ មិនអាចឃើញឱកាសរបស់មហាសមណៈនេះ ដោយហេតុនោះទើបឪពុកជាទុក្ខសុបសៅយ៉ាងនេះ ។

មារធីតាពោលថា កាលបើដូច្នោះ សូមព្រះបិតាកុំទោមនស្ស ពួកខ្ញុំនឹងធ្វើឲ្យមហាសមណៈនោះ នៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក ។

ទេវបុត្តមារពោលថា នែកូន បុគ្គលណាមួយ ក៏មិនអាចធ្វើមហាសមណៈនេះ ឲ្យនៅក្នុងអំណាចបានដែរ បុរសនេះតាំងនៅក្នុងសទ្ធាមិនញាប់ញ័រ ។

មារធីតាពោលថា បពិត្រព្រះបិតា ពួកខ្ញុំម្ចាស់ជាមាតុគ្រាម ពួកខ្ញុំម្ចាស់នឹងយកអន្ទាក់ គឺរាគៈជាដើម ចងមហាសមណៈឲ្យមាំ ហើយនាំមកក្នុងកាលឥឡូវនេះ សូមព្រះបិតាកុំគិតថ្វីឡើយ ។ ពោលហើយមារធីតាទាំង ៣ នោះ ក៏ចេញអំពីទីនោះ ហើយចូលទៅរកព្រះមានព្រះភាគក្រាបទូលថា បពិត្រសមណៈ ពួកខ្ញុំម្ចាស់នឹងបម្រើបាទារបស់ព្រះអង្គ ។

ព្រះបរមសាស្តា ទ្រង់មិនបានបើកព្រះនេត្រមើល មានព្រះទ័យបង្អោនទៅក្នុងធម៌ជាគ្រឿងអស់ទៅនូវឧបធិដ៏កំពូល ទ្រង់ប្រថាប់គង់សោយវិមុត្តិសុខដែលកើតអំពីវិវេកប៉ុណ្ណោះ ។ មារធីតាគិតថា បំណងរបស់កូនប្រុសមិនដូចគ្នា កូនប្រុសខ្លះស្រឡាញ់ស្រីក្មេងវ័យជំទង់ កូនប្រុសខ្លះស្រឡាញ់ស្រីក្នុងបឋមវ័យ កូនប្រុសខ្លះស្រឡាញ់ស្រីដែលតាំងនៅក្នុងមជ្ឈិមវ័យ កូនប្រុសខ្លះស្រឡាញ់ស្រីដែលតាំងនៅក្នុងបច្ឆិមវ័យ បើដូច្នោះ ពួកយើងនឹងប្រលោមលួងលោមដោយរូបច្រើនប្រការ ទើបមារធីតានីមួយៗ និម្មិតអត្តភាពមួយរយៗ ជារូបស្រីដែលមានវ័យក្មេង ជាស្រីមិនទាន់ប្រសូត ជាស្រីប្រសូតម្តង ជាស្រីប្រសូតពីរដង ជាស្រីវ័យកណ្តាល និងជាស្រីវ័យចំណាស់ ចូលទៅរកព្រះមានព្រះភាគអស់វារៈ ៦ ដង ហើយពោលថា បពិត្រព្រះសមណៈ ពួកខ្ញុំម្ចាស់នឹងបម្រើបាទារបស់ព្រះអង្គ ។ ព្រះបរមសាស្តា ទ្រង់មិនដាក់ព្រះទ័យក្នុងសេចក្តីនោះ ដោយប្រការដែលទ្រង់បង្អោនទៅក្នុងធម៌ ដែលជាគ្រឿងអស់ទៅនូវឧបធិដ៏កំពូល ។ ចំណែកអាចារ្យពួកខ្លះពោលថា ព្រះបរមសាស្តា កាលទ្រង់ឃើញមារធីតាទាំងនោះចូលមករកដោយភាវៈជាស្រី ទើបទ្រង់អធិដ្ឋានថា ស្រីទាំងនេះ ចូរមានធ្មេញបាក់ សក់ស្កូវ យ៉ាងនេះ យ៉ាងនេះ ពាក្យរបស់កេចិអាចារ្យនោះ មិនគួរកាន់យក ព្រោះព្រះសាស្តាទ្រង់មិនធ្វើការអធិដ្ឋានបែបនោះឡើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកនាង

ចូរចៀសចេញទៅ ហេតុអ្វីទើបពួកនាងមកព្យាយាមយ៉ាងនេះ ឈ្មោះថា កម្មមានសភាពបែបនេះ គួរធ្វើក្នុងទីចំពោះមុខបុរសដែលមិនទាន់ប្រាសចាករាគៈជាដើម តែតថាគតលះរាគៈ ទោសៈ និងមោហៈបានហើយ ទ្រង់ប្រារព្ធដល់ការលះកិលេសរបស់ព្រះអង្គ ទើបទ្រង់សម្ដែងធម៌ ត្រាស់គាថាពីរក្នុង **ធម្មបទ ពុទ្ធវគ្គ** ដូច្នេះថា

យស្ស ជិតំ នាវជីយតិ
ជិតមស្ស នោយាតិ កោចិ លោកេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេសណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះ របស់ព្រះពុទ្ធអង្គនោះ នាងទាំងឡាយនឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមានគោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយកិលេសដូចស្នាមជើង ម្ដេចកើត ។

យស្ស ជាលិនី វិសត្តិកា
តណ្ហា នត្ថិ កុហិញ្ចិ នេតវេ
តំ ពុទ្ធំ អនន្តគោចរំ
អបទំ កេន បទេន នេស្សថ ។

តណ្ហាដែលមានបណ្ដាញផ្សាយទៅ ក្នុងអារម្មណ៍ផ្សេងៗ មិន
មានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅ ក្នុងភពណាមួយ
នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមាន
គោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយ
កិលេសដូចស្នាមជើង ម្ដេចកើត [១] ។

មារធីតាទាំងនោះពោលពាក្យថា បានឮថា បិតារបស់ពួកយើង និយាយពិត ព្រះអរហន្តសុគត មិនមែនជាបុគ្គលដែលគេនាំទៅបាន ដោយងាយក្នុងលោក ដោយរាគៈជាដើមឡើយ ហើយក៏នាំគ្នាទៅកាន់សម្នាក់របស់បិតាខ្លួន ។

ចំណែកព្រះមានព្រះភាគ ទ្រង់សម្ងំនៅក្នុងអជបាលនិគ្រោធនោះ មួយសប្ដាហ៍ ហើយទ្រង់យាងទៅត្រង់គល់មុច្ចលិន្ទ ( រាំងអន្ទក់ ) ក្នុងទីនោះ ភ្លៀងរលឹមក៏កើតឡើង ៧ ថ្ងៃ ព្រះបរមសាស្ដាដែលស្ដេចមុច្ចលិន្ទនាគរាជព័ទ្ធរង្វេល ៧ ជុំ ជុំវិញហើយ ដើម្បីការពារនូវភាពរងាជាដើម សោយវិមុត្តិសុខ ហាក់បីដូចប្រថាប់នៅក្នុងព្រះគន្ធកុដិ ដែលមិនចង្អៀត ទ្រង់សម្ងំនៅត្រង់ទីនោះមួយសប្ដាហ៍ហើយ ទើបទ្រង់យាងទៅកាន់ដើមរាជាយតនៈ គង់សោយវិមុត្តិសុខត្រង់ដើមរាជាយតនៈនោះ ១ សប្ដាហ៍

១- បិ.៥២ , ទំ. ៥៩ ។

ដោយលំដាប់ កាលមានប្រមាណប៉ុណ្ណោះ សប្ដាហ៍ទាំងឡាយ ៧ ក៏គ្រប់បរិបូណ៌ ។

ក្នុងចន្លោះនេះ ព្រះមានព្រះភាគមិនមានការលុបព្រះភក្ត្រ មិនមានការបដិបត្តិសរីរៈ មិនមានកិច្ចដោយព្រះក្រយាហារ ទ្រង់សម្រំនៅដោយឈានសុខ និងផលសុខ ។ ក្នុងថ្ងៃទី ៤៩ ដែលជាថ្ងៃចុងក្រោយនៃសប្ដាហ៍ទី ៧ នោះ ព្រះមានព្រះភាគអង្គនោះ ទ្រង់ប្រថាប់ត្រង់ដើមរាជាយតនៈនោះ កើតព្រះតម្រិះឡើងថា តថាគតនឹងលុបព្រះភក្ត្រ ។ លំដាប់នោះ សក្កទេវរាជ បាននាំយកឈើស្ទន់ឈ្មោះនាគលតា ( ម្ទេស ) និងទឹកលុបព្រះភក្ត្រថ្វាយដល់ព្រះលោកនាថ ។ ព្រះមានព្រះភាគ ទ្រង់ទំពាឈើស្ទន់ លុបព្រះភក្ត្រដោយទឹកដែលព្រះឥន្ទនាំមកអំពីអនោតត្តស្រះ ។ សក្កទេវរាជស្ដេចទេវតាបាននាំយកផ្លែសម៉ទិព្វ មកថ្វាយដោយព្រះអង្គឯង ព្រះទសពលសោយផ្លែសម៉នោះ ដោយហេតុនោះ ទើបមានការបន្ទោបង់ព្រះឧច្ចារៈ ហើយទ្រង់ប្រថាប់ត្រង់គល់រាជាយតនៈនោះឯង ។

សម័យនោះ ពាណិជពីរនាក់បងប្អូន ឈ្មោះតបុស្សៈ និងភល្លិកៈ ចេញអំពីឧក្កលាជនបទទៅកាន់មជ្ឈិមប្រទេស ដោយរទេះ ៥០០ ត្រូវទេវតាដែលជាញាតិសាលោហិតរបស់ខ្លួនក្នុងជាតិមុន ធ្វើមិនឲ្យកង់រទេះវិលទៅមុខ ដើម្បីឲ្យបានថ្វាយភិក្ខាដល់ព្រះលោកនាយក ទើបពាណិជកាន់យកសដូវដុំនិងសដូវផង់ ហើយចូលទៅរកព្រះសាស្ដាក្រាបទូលថា

បពិត្រព្រះមានព្រះភាគ សូមទ្រង់អនុគ្រោះទទួលអាហារនេះចុះ ហើយឈរ ព្រោះបាត្របាត់ទៅក្នុងថ្ងៃដែលទ្រង់ទទួលមធុបាយាសនោះ ព្រះទសពល ទ្រង់ព្រះតម្រិះថា ព្រះតថាគតទាំងឡាយ រមែងមិនទទួលដោយដៃ តថាគតនឹងទទួលដូចម្តេចហ្ន៎ ។

លំដាប់នោះ មហារាជទាំង ៤ មកអំពីទិសទាំង ៤ ដឹងព្រះតម្រិះរបស់ព្រះមានព្រះភាគអង្គនោះ ក៏បង្អោនបាត្រដែលសម្រេចដោយកែវឥន្ទនីលចូលទៅថ្វាយ ព្រះមានព្រះភាគ ទ្រង់បដិសេធបាត្រទាំងនោះ ទើបមហារាជទាំងនោះ បង្អោនបាត្រ ៤ ដែលសម្រេចដោយថ្មពណ៌ដូចសណ្តែកបាយចូលទៅថ្វាយ កាលទ្រង់អនុគ្រោះទេវបុត្តទាំង ៤ អង្គ ទើបទ្រង់ទទួលបាត្រទាំង ៤ នោះ ហើយដាក់ត្រួតលើគ្នាអធិដ្ឋានថា **ឯកោ ហោតុ** ចូរជាបាត្រតែមួយចុះ បាត្រទាំង ៤ ក៏មិនមានស្នាមប្រាកដត្រង់កណ្តាប់មាត់បាត្រ គឺក្លាយជាបាត្រមួយប៉ុណ្ណោះ ដោយប្រមាណគឺបាត្រខ្នាតកណ្តាល ។ ព្រះមានព្រះភាគ ទ្រង់ទទួលអាហារដោយបាត្រថ្ម ឲ្យពាណិជឃើញប្រចក្សហើយសោយ ទ្រង់ធ្វើអនុមោទនា ពាណិជពីរនាក់បងប្អូនដល់នូវព្រះពុទ្ធនិងព្រះធម៌ជាសរណៈ បានជាទ្វេវាចិកឧបាសកបន្ទឺវាចាដល់សរណៈពីរដង ។ លំដាប់នោះ កាលពាណិជទាំងពីរនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានឋានៈដែលគប្បីប្រតិបត្តិណាមួយដល់ខ្ញុំព្រះអង្គទាំងពីរ ទើបព្រះមានព្រះភាគ ទ្រង់យក

ព្រះហស្តស្ទាំស្ទាបព្រះសីសៈរបស់ព្រះអង្គ ហើយទ្រង់ប្រទានព្រះកេស-ធាតុទាំងឡាយ ឲ្យទៅពាណិជទាំងពីរនោះ ។ ពាណិជក៏ឲ្យសាងព្រះចេតិយបញ្ចុះព្រះកេសធាតុទុកក្នុងនគររបស់ខ្លួន [១] ។

ចាប់តាំងអំពីពេលនោះ ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់ដើមអជបាលនិគ្រោធទៀត ទ្រង់ប្រថាប់ត្រង់គល់និគ្រោធនោះ ។ លំដាប់នោះ ព្រះសម្មាសម្ពុទ្ធ គ្រាន់តែទ្រង់ប្រថាប់ត្រង់គល់និគ្រោធនោះប៉ុណ្ណោះ ទ្រង់ក៏ពិចារណាដល់ធម៌ដែលទ្រង់សម្រេចហើយ ថាជាធម៌ដ៏ជ្រាលជ្រៅ ទ្រង់ព្រះតម្រិះថា ធម៌នេះព្រះពុទ្ធទាំងពួងប្រព្រឹត្តសន្សំទុក តថាគតបានសម្រេចហើយ ទើបកើតនូវសេចក្តីត្រិះរិះដល់អាការ គឺការមិនប្រាថ្នានឹងសម្តែងធម៌ដល់ជនដទៃ ។ លំដាប់នោះ សហម្បតីព្រហ្មក៏ពោលថា **នស្សតិ វត ភោ លោកោ វិនស្សតិ វត ភោ លោកោ** លោកដ៏ចម្រើនទាំងឡាយ លោកនឹងវិនាសហើយហ្ន៎ លោកដ៏ចម្រើនទាំងឡាយ លោកនឹងវិនាសហើយហ្ន៎ ហើយនាំសក្កទេវរាជ សុយាមទេវរាជ សន្តុសិតទេវរាជ និម្មានរតីទេវរាជ វសវត្តីទេវរាជ និងមហាព្រហ្មក្នុង ១ ម៉ឺនចក្រវាល ចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលអារាធនា

---

១- ពាណិជទាំងពីរ ពាណិជឈ្មោះ ភល្លិកៈ ថ្ងៃក្រោយមកចេញបួសបានជាព្រះអរហន្ត តែក្នុងបិដកខ្មែរ ថេរគាថា ដូរឈ្មោះជា ព្រះភល្លិយត្ថេរ ទៅវិញ ។

ឲ្យទ្រង់សម្ដែងធម៌ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់សម្ដែងព្រះធម៌ ។ ព្រះទសពល ទ្រង់ឲ្យប្ដេជ្ញាដល់សហម្បតីព្រហ្មនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្ដែងធម៌លើកទី ១ ដល់នរណាហ្ន៎ ទ្រង់ញុំាងព្រះតម្រិះឲ្យកើតឡើងថា អាឡារតាបសជាបណ្ឌិត អាឡារតាបសនោះ នឹងដឹងទូទៅដល់ធម៌នេះ ដោយឆាប់រហ័ស ហើយទ្រង់ប្រមើលមើលទៀត ទើបទ្រង់បានជ្រាបថា អាឡារតាបសនោះ ធ្វើកាលកិរិយា ៧ ថ្ងៃ ហើយ ទើបទ្រង់នឹកដល់ឧទកតាបស ទ្រង់ក៏បានជ្រាបថា សូម្បីឧទកតាបសនោះ ក៏បានធ្វើកាលកិរិយាទៅហើយ កាលពីព្រលប់ម្សិលមិញនេះ ទើបទ្រង់មនសិការប្រារព្ធដល់បញ្ចវគ្គីយ៍ថា បញ្ចវគ្គិយភិក្ខុមានឧបការៈច្រើនដល់តថាគត ទ្រង់ពិចារណាថា ឥឡូវនេះបញ្ចវគ្គិយភិក្ខុនោះនៅក្នុងទីណាហ្ន៎ ទ្រង់បានជ្រាបថា នៅត្រង់ព្រៃឥសិបតនមិគទាយវ័ន ក្នុងនគរពារាណសី ទើបទ្រង់ព្រះតម្រិះថា តថាគតនឹងទៅកាន់ព្រៃឥសិបតនមិគទាយវ័ននោះ ហើយសម្ដែងធម្មចក្ក ( កាលទ្រង់ព្រះតម្រិះដូច្នេះហើយ ) ព្រះសាស្ដា ទ្រង់យាងទៅបិណ្ឌបាតក្បែរៗពោធិមណ្ឌលប៉ុណ្ណោះ អស់ពីរ-បីថ្ងៃ ទ្រង់ព្រះតម្រិះថា តថាគតនឹងទៅកាន់នគរពារាណសី ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ។ ក្នុងវេលា បច្ចូសសម័យថ្ងៃជិតរះ កាលរាត្រីចាតុទ្ទសីអស់ហើយ ទ្រង់កាន់បាត្រនិងចីវរយាងទៅអស់ចម្ងាយផ្លូវ ១៨ យោជន៍ ទ្រង់ជួបឧបកាជីវកក្នុងចន្លោះផ្លូវ

ទើបត្រាស់ប្រាប់ដល់ភាពដែលព្រះអង្គជាព្រះពុទ្ធ ដល់ឧបកាជីវកនោះ ហើយទ្រង់យាងដល់ព្រៃឥសិបតនមិគទាយវ័ន ក្នុងវេលាល្ងាចនោះឯង ។

បញ្ចវគ្គិយភិក្ខុ ឃើញព្រះសាស្តាយាងមកអំពីចម្ងាយ ក៏ធ្វើកតិកាគ្នាថា នែអាវុសោទាំងឡាយ ព្រះសមណគោតមនេះ វិលមកដើម្បីភាពជាអ្នកល្មោភក្នុងបច្ច័យ មានកាយបរិបូណ៌ មានឥន្ទ្រិយផូរផង់ មានពណ៌សម្បុរដូចមាសកំពុងមកហើយ ពួកយើងកុំធ្វើសាមីចិកម្ម អភិវាទនកម្មជាដើម ដល់ព្រះសមណគោតមនេះឡើយ តែលោកជាបុគ្គលប្រសូតក្នុងត្រកូលធំ រមែងគួររៀបចំអាសនៈទុក ដោយហេតុនោះ ពួកយើងចូរក្រាលត្រឹមតែអាសនៈទុកដើម្បីលោកចុះ ។ ព្រះដ៏មានព្រះភាគ ទ្រង់ពិចារណាថា បញ្ចវគ្គិយភិក្ខុនេះគិតដូចម្តេចហ្ន៎ ទ្រង់ក៏បានជ្រាបការគិតដោយព្រះញាណដែលអាចដឹងវារៈចិត្ត របស់លោកព្រមទាំងទេវលោកលំដាប់នោះ ទើបទ្រង់យកមេត្តាចិត្តដែលអាចផ្សាយទៅដោយមិនចំពោះក្នុងពពួកទេវតា និងពួកមនុស្សទាំងពួង ហើយទ្រង់ផ្សាយមេត្តាចិត្តនោះទៅកាន់បញ្ចវគ្គិយភិក្ខុទាំងនោះដោយចំពោះ បញ្ចវគ្គិយភិក្ខុទាំងនោះកាលព្រះមានព្រះភាគ ទ្រង់ឲ្យពាល់ត្រូវដោយមេត្តាចិត្តហើយ កាលទ្រង់យាងចូលទៅជិត ក៏មិនអាចតាំងនៅក្នុងកតិការបស់ខ្លួនបាន នាំគ្នាធ្វើកិច្ចទាំងពួង មានការអភិវាទ និងការក្រោកទទួលជាដើម តែមិនទាន់ដឹងថា ព្រះមានព្រះភាគជាព្រះសព្វញ្ញុពុទ្ធនៅឡើយ ទើបប្រើវាចាហៅ

ដោយឈ្មោះ និងដោយពាក្យថា អាវុសោ អាវុសោ ។ លំដាប់នោះ ព្រះបរមសាស្តា ទ្រង់ញ៉ាំងបញ្ចវគ្គិយភិក្ខុទាំងនោះឲ្យដឹងថា ព្រះអង្គបាន ត្រាស់ជាព្រះពុទ្ធហើយ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នក ទាំងឡាយ កុំហៅតថាគតដោយឈ្មោះនិងដោយវាទៈថា អាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ហើយ ទ្រង់ប្រថាប់គង់លើបវរពុទ្ធាសនៈដែលគេតាក់តែងទុក កាលក្រុមផ្កាយ នក្ខត្តឫក្ស ខែឧត្តរាសាឡ្ហៈ គឺខែអាសាឍកំពុងគោចរទៅ ទ្រង់ហែហម ដោយពួកព្រហ្ម ១៨ កោដិ ត្រាស់ហៅបញ្ចវគ្គិយភិក្ខុមក ទ្រង់សម្តែង ព្រះធម្មចក្កប្បវត្តនសូត្រ ។ បណ្តាបញ្ចវគ្គិយភិក្ខុទាំងនោះ ព្រះអញ្ញា-កោណ្ឌញ្ញត្ថេរបញ្ជូនញាណទៅតាមក្រសែនៃព្រះធម្មទេសនា ក្នុងកាល ចប់ព្រះសូត្រ បានតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ព្រះបរមសាស្តា ទ្រង់ចាំវស្សាក្នុងព្រៃឥសិបតនមិគទាយវ័ននោះ ។ ស្អែកឡើង ទ្រង់ប្រថាប់គង់ទូន្មានព្រះវប្បត្ថេរក្នុងទីនោះឯង ព្រះថេរៈ ដែលសល់ ៤ រូបទៀតត្រាច់ទៅបិណ្ឌបាត ព្រះវប្បត្ថេរបានសម្រេច សោតាបត្តិផលក្នុងវេលាព្រឹកនោះ ដោយឧបាយនេះ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងព្រះភទ្ទិយត្ថេរ ឲ្យតាំងនៅក្នុងសោតាបត្តិផលក្នុងថ្ងៃស្អែកឡើង ព្រះមហានាមត្ថេរក្នុងថ្ងៃស្អែកបន្ទមកទៀត ព្រះអស្សជិត្ថេរក្នុងថ្ងៃស្អែក បន្ទមកទៀត រួមសេចក្តីថា ទ្រង់ធ្វើព្រះថេរៈទាំងពួងឲ្យតាំងនៅក្នុង

សោតាបត្តិផលហើយ ក្នុងតិថីទី ៥ នៃបក្ខ ព្រះសាស្ដា ទ្រង់បានឃើញព្រះថេរៈទាំង ៥ អង្គប្រជុំគ្នាហើយ ទ្រង់សម្ដែងអនត្តលក្ខណសូត្រ ក្នុងវេលាចប់ទេសនា ព្រះថេរៈទាំង ៥ អង្គបានតាំងនៅក្នុងអរហត្តហើយ ។

គ្រានោះ ព្រះទសពល ទ្រង់ឃើញឧបនិស្ស័យរបស់យសកុលបុត្ត យសកុលបុត្តនោះនឿយណាយក្នុងផ្ទះ ហើយចេញទៅទាំងរាត្រី ទើបទ្រង់ត្រាស់ហៅថា មកចុះយស ហើយឲ្យតាំងនៅក្នុងសោតាបត្តិផលទាំងមិនទាន់ភ្លឺនោះឯង ថ្ងៃស្អែកឡើង បានឲ្យតាំងនៅក្នុងអរហត្ត ទ្រង់ញុំាងជនដទៃ ៥៤ នាក់ទៀត ដែលជាសម្លាញ់របស់ព្រះយសនោះ ឲ្យបព្វជ្ជាដោយឯហិភិក្ខុបព្វជ្ជា ហើយឲ្យសម្រេចអរហត្ត កាលព្រះអរហន្ត ៦១ អង្គ កើតឡើងក្នុងលោកដោយប្រការយ៉ាងនេះហើយ ព្រះសាស្ដា កាលចេញវស្សាបវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ អង្គទៅកាន់ទិសទាំងឡាយដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ចារិកទៅ ចំណែកព្រះអង្គ ទ្រង់យាងទៅកាន់ឧរុវេលាប្រទេស ក្នុងរវាងផ្លូវទ្រង់បានទូន្មានភទ្ទវគ្គិយកុមារ ៣០ នាក់ក្នុងព្រៃកប្បាស បណ្ដាភទ្ទវគ្គិយកុមារទាំងនោះ បុគ្គលយ៉ាងទាបត្រឹមសោតាបន្ន បុគ្គលយ៉ាងខ្ពស់ជាព្រះអនាគាមី ។ ព្រះបរមសាស្ដា ទ្រង់ឲ្យភទ្ទវគ្គិយកុមារទាំងអស់នោះ បព្វជ្ជាដោយឯហិភិក្ខុដូចគ្នា ហើយទ្រង់បញ្ជូនទៅកាន់ទិសទាំងឡាយ ឯព្រះអង្គយាងទៅកាន់តំបន់ឧរុវេលា ទ្រង់សម្ដែងបាដិហារិយ៍

៣.៥០០ ទូន្មានជដិល ៣ នាក់បងប្អូន មានឧរុវេលកស្សបជាដើម មានបរិវារ ១ ពាន់ ឲ្យបព្វជ្ជាដោយភាពជាឯហិភិក្ខុដូចគ្នា ហើយឲ្យអង្គុយត្រង់គយាសីសប្រទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ។ ព្រះដ៏មានព្រះភាគ មានព្រះអរហន្ត ១ ពាន់រូបចោមរោមទ្រង់ព្រះតម្រិះនឹងដោះនូវប្តេជ្ញា ដែលទ្រង់ឲ្យដល់ព្រះបាទពិម្ពិសារ ទើបទ្រង់យាងទៅកាន់លដ្ឋិវនឧទ្យាន គឺឧទ្យានត្នោតជំទង់ក្នុងនគររាជគ្រឹះ ។ ព្រះរាជា ទ្រង់បានដំណឹងអំពីឧទ្យានបាលថា ព្រះមានព្រះភាគ ស្តេចយាងមកហើយ ទើបទ្រង់ចោមរោមដោយព្រាហ្មណ៍ និងគហបតី ១២ នហុតៈ ( ១២ម៉ឺន ) ចូលទៅគាល់ព្រះបរមសាស្តា កាលផ្ទៃព្រះបាទដែលវិចិត្រដោយចក្រ កំពុងបញ្ចេញពន្លឺហាក់ដូចជាពិដានមាស ព្រះរាជាទ្រង់ឱនសិរសាទៀបព្រះបាទារបស់ព្រះសម្មាសម្ពុទ្ធ ហើយប្រថាប់គង់ក្នុងចំណែកម្ខាងមួយអន្លើដោយបរិស័ទ ។ លំដាប់នោះ ពួកព្រាហ្មណ៍និងគហបតីទាំងនោះ ក៏មានគំនិតគិតដូច្នេះថា ព្រះមហាសមណៈប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់ឧរុវេលកស្សបៈ ឬក៏ឧរុវេលកស្សបៈប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់របស់ព្រះមហាសមណៈ ? ព្រះបរមសាស្តា ទ្រង់ជ្រាបបរិវិតក្ករបស់ព្រាហ្មណ៍និងគហបតីទាំងនោះ ទើបត្រាស់នឹងព្រះថេរៈដោយព្រះគាថានេះថា

**កិមេវ ទិស្វា ឧរុវេលវាសិ**

**បហាសិ អគ្គឹ កិសកោវទានោ ។**

**បុច្ឆាមិ តំ កស្សប ឯតមត្ថំ**

**កថំ បហីនំ តវ អគ្គិហុត្តំ ។**

*អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស តើអ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោលចេញ ។ ម្នាលកស្សបៈ តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើង ដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី ។*

*ចំណែកព្រះថេរៈដឹងព្រះបំណងរបស់ព្រះសាស្តា ទើបពោលគាថានេះថា*

**រូបេ ច សទ្ទេ ច អថោ រសេ ច**

**កាមិត្ថិយោ ចាភិវទន្តិ យញ្ញា**

**ឯតំ មលន្តិ ឧបធីសុ ញត្វា**

**តស្មា ន យិដ្ឋេ ន ហុតេ អរញ្ជឹ ។**

*ជនទាំងឡាយ តែងពោលសរសើរចំពោះនូវកាមទាំងឡាយ គឺ រូប សំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយផង ព្រោះការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណមានរូបជាដើមនេះ ជាគ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះហេតុដូច្នោះ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងបូជាតូច ( គឺការ*

គោរពភ្លើងរាល់ថ្ងៃ) ។

ឯត្ថ ច តេ មនោ ន រមិត្ថ កស្សចាតិ ភគវា
រូបេសុ សទ្ទេសុ អថោ រសេសុ
អថ កោចរហិ ទេវមនុស្សលោកេ
រតោ មនោ កស្សប ព្រូហិ មេតំ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលកស្សប ចិត្តរបស់អ្នកមិនត្រេកអរហើយ ក្នុងកាមគុណទាំងឡាយនោះ គឺរូប សំឡេង ព្រមទាំងរស ម្នាលកស្សប ម្យ៉ាងទៀត ចិត្តរបស់អ្នកត្រេកអរក្នុងមនុស្សលោក និងទេវលោកខ្លះដែរឬ ចូរអ្នកពោលហេតុនេះមក តថាគតមើល ។

ព្រះឧរុវេលកស្សបក្រាបទូលថា

ទិស្វា បទំ សន្តមនូបធីកំ
អកិញ្ចនំ កាមភវេ អសត្តំ
អនញ្ញថាភាវិមនញ្ញនេយ្យំ
តស្មា ន យិដ្ឋេ ន ហុតេ អរញ្ជិន្តិ ។

ខ្ញុំព្រះអង្គឃើញនូវព្រះនិព្វានជារបស់ល្អិត ឥតមានឧបធិ ឥតមានសេចក្តីខ្វល់ មិនជាប់ចំពាក់នៅក្នុងកាមភព ជាធម្មជាតពិត មិនប្រែប្រួល ជាធម្មជាត

*គឺបុគ្គលមិនគប្បីបានដោយហេតុដទៃ ( ក្រៅពីមគ្គ )*
*ព្រោះហេតុដូច្នោះ បានជាខ្ញុំព្រះអង្គមិនត្រេកអរក្នុង*
*ការបូជាធំនិងបូជាតូច* [១] ។

*ដើម្បីប្រកាសភាពដែលខ្លួនជាសាវក ទើបឱនសិរសាលើខ្នងព្រះបាទារបស់ព្រះសាស្តាហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ដូច្នេះហើយហោះឡើងទៅកាន់អាកាស ៧ ដង លើកទី ១ មួយដួរដើមត្នោត លើកទី ២ ពីរដួរដើមត្នោត រហូតដល់ ៧ ដួរដើមត្នោត ហើយចុះមកថ្វាយបង្គំព្រះតថាគត អង្គុយក្នុងចំណែកម្ខាង ។ មហាជនបានឃើញបាដិហារិយ៍នោះហើយ នាំគ្នាពណ៌នាព្រះគុណរបស់ព្រះសាស្តាថា គួរអស្ចារ្យហ្ន៎ ព្រះពុទ្ធទ្រង់មានអានុភាពច្រើន សូម្បីឧរុវេលាកស្សបៈ ឈ្មោះថា ជាអ្នកមានទិដ្ឋិរឹងត្អឹងយ៉ាងនេះ សម្គាល់ថាខ្លួនជាព្រះអរហន្ត ក៏ត្រូវព្រះតថាគតទ្រង់ទម្លាយសំណាញ់គឺទិដ្ឋិ ទ្រង់ទូន្មានបានហើយ ។ ព្រះបរមសាស្តាត្រាស់ថា តថាគតទូន្មានឧរុវេលកស្សបតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងអតីតកាល ឧរុវេលកស្សបៈនេះ ក៏ត្រូវតថាគតទូន្មានហើយដូចគ្នា ហើយទ្រង់ត្រាស់* **មហានារទកស្សបជាតក** *ព្រោះហេតុ*

---

*១-បិ. ៦ , ទំ. ១០៩ ។*

កើតរឿងនេះឡើង ហើយទ្រង់ប្រកាសសច្ចៈទាំង ៤ ព្រះបាទមគធរាជ ទ្រង់តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយបរិវារ ១១ នហុតៈ មួយចំណែក គឺ ១ នហុតៈទៀត បានដល់នូវភាពជាឧបាសក ព្រះរាជាទ្រង់ប្រថាប់នៅក្នុងសម្នាក់របស់ព្រះបរមសាស្ដា ទ្រង់ប្រកាសហេតុដែលនាំមកនូវការសប្បាយព្រះទ័យ ៥ ប្រការ ហើយទ្រង់ដល់នូវសរណៈ ទ្រង់និមន្តឲ្យព្រះសាស្ដាទ្រង់សោយក្នុងថ្ងៃស្អែក ទ្រង់ក្រោកចាកអាសនៈ ធ្វើប្រទក្សិណព្រះមានព្រះភាគ ហើយចៀសចេញទៅ ។ ស្អែកឡើង ពួកអ្នកនគររាជគ្រឹះទាំងមូល ប្រមាណ ១៨ កោដិ ទាំងដែលធ្លាប់ឃើញព្រះទសពល និងដែលមិនធ្លាប់ឃើញ មានបំណងនឹងឃើញព្រះតថាគត ទើបបានចេញអំពីក្រុងរាជគ្រឹះ ទៅកាន់លដ្ឋិវនអំពីព្រហាម ផ្លូវ ៣ គាវុត មិនគ្រប់គ្រាន់ លដ្ឋិវនឧទ្យានទាំងមូលណែនណាន់ខ្នាន់ខ្នាប់ទាំងអស់ ។ មហាជនសម្លឹងមើលព្រះអត្តភាព ដែលដល់នូវលម្អដោយព្រះរូបឆោមរបស់ព្រះសម្មាសម្ពុទ្ធ មិនអាចធ្វើឲ្យឆ្អែតបានក្នុងឋានៈទាំងឡាយបែបនេះ ។ ការពណ៌នាលម្អនៃព្រះរូបកាយទាំងមូល ដែលមានប្រភេទជាព្រះលក្ខណៈ និងព្រះអនុព្យញ្ជនៈរបស់ព្រះតថាគត ឈ្មោះថា វណ្ណរូប ( ការពណ៌នារូប ) ។ មហាជនសម្លឹងមើលព្រះសរីរៈរបស់ព្រះទសពល ដែលដល់នូវលម្អដោយព្រះរូបឆោមដ៏ត្រកាល ដោយអាការយ៉ាងនេះ ទើបមិនមានឱកាស សូម្បីតែភិក្ខុមួយរូបអាចចេញអំពីឧទ្យាននោះទៅ

ដោយផ្លូវថ្មើរជើងបាន ។ បានឮថា ក្នុងថ្ងៃនោះ ព្រះសាស្តា ទ្រង់នឹងត្រូវដាច់ព្រះក្រយាហារ តែការដាច់ព្រះក្រយាហារនោះមិនមានឡើយ ព្រោះហេតុនោះ អាសនៈរបស់សក្កទេវរាជក៏សម្តែងអាការក្តៅ សក្កទេវរាជ ទ្រង់ពិចារណាហេតុ ក៏បានជ្រាបហេតុការណ៍នោះ ទ្រង់ក៏និម្មិតភេទជាមាណពជំទង់ ពោលពាក្យសរសើរ និងពាក្យដែលបដិសំយុត្តដោយពុទ្ធគុណ ធម្មគុណ និងសង្ឃគុណ ទ្រង់យាងទៅក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះទសពល បានឱកាសដោយទេវានុភាព ទ្រង់យាងនាំផ្លូវអំពីខាងមុខ ហើយពោលគុណរបស់ព្រះសាស្តាដោយគាថាទាំងនេះថា

**ទន្តោ ទន្តេហិ សហ បុរាណជដិលេហិ**
**វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ**
**រាជគហំ បាវិសិ ភគវា ។**

ព្រះដ៏មានព្រះភាគ ព្រះអង្គទូន្មានហើយ (នូវឥន្ទ្រិយ) មានព្រះហឫទ័យផុតស្រឡះហើយ (ចាកអាសវធម៌) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះមួយអន្លើ ដោយពួកបុរាណជដិលដែលជាអ្នកទូន្មានហើយ ( នូវឥន្ទ្រិយ ) ដែរ ជាអ្នកមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

**មុត្តោ មុត្តេហិ សហ បុរាណជដិលេហិ**

**វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ**
**រាជគហំ បាវិសិ ភគវា ។**

*ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យផុតហើយ ( ចាកសេចក្តីសៅហ្មង ) និងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះមួយអន្លើ ដោយពួកបុរាណជដិល ដែលមានចិត្តផុតហើយ ( ចាកសេចក្តីសៅ-ហ្មង ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។*

**តិណ្ណោ តិណ្ណេហិ សហ បុរាណជដិលេហិ**
**វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ**
**រាជគហំ បាវិសិ ភគវា ។**

*ព្រះដ៏មានព្រះភាគ ទ្រង់ឆ្លង ( ចាកលោក ) ហើយ ទាំងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល ដែលឆ្លងហើយ ( ចាកលោក ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។*

**សន្តោ សន្តេហិ សហ បុរាណជដិលេហិ**

**វិប្បមុត្តោ វិប្បមុត្តេហិ សិង្គីនិក្ខសុវណ្ណោ**

**រាជគហំ បាវិសិ ភគវា ។**

ព្រះដ៏មានព្រះភាគមានព្រះហឫទ័យ រម្ងាប់ហើយ ( ចាក អកុសលធម៌ ) ទាំងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះ សិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះមួយអន្លើ ដោយ ពួកបុរាណជដិល ដែលមានចិត្តរម្ងាប់ហើយ ( ចាកអកុសល-ធម៌ ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

**ទសវាសោ ទសពលោ ទសធម្មវិទូ ទសភិ**

**ចុបេតោ សោ ទសសតបរិវារោ រាជគហំ**

**បាវិសិ ភគវាតិ ។**

ព្រះដ៏មានព្រះភាគនោះ ទ្រង់មានអរិយវាស ១០ យ៉ាង ទ្រង់ មានកម្លាំង ១០ ព្រះអង្គជ្រាបច្បាស់នូវធម៌ ( គឺកម្មបថ ) ១០ ប្រការ ទ្រង់ប្រកបដោយអង្គជារបស់នៃអសេក្ខបុគ្គល ១០ យ៉ាង មានភិក្ខុសង្ឃ ១ ពាន់ជាបរិវារ ទ្រង់យាងចូល ទៅកាន់ក្រុងរាជគ្រឹះ (១) ។

---

១- បិ.៦ , ទំ.១១៥ ។

មហាជនបានឃើញលម្អនៃរូបរបស់មាណពជំទង់នោះ គិតថា មាណពតូចនេះមានរូបស្អាតពន់ពេក ឯមាណពនេះអញមិនធ្លាប់ឃើញសោះ ទើបពោលថា នៃមាណពអ្នកឯងមកអំពីណា ជាមាណពរបស់អ្នកណា? មាណពនោះស្តាប់ដូច្នោះហើយ ក៏ពោលនូវគាថានេះថា

**យោ ធីរោ សព្វធិ ទន្តោ សុទ្ធោ អប្បដិបុគ្គលោ**
**អរហំ សុគតោ លោកេ តស្សាហំ បរិចារកោតិ ។**

អ្នកប្រាជ្ញណាទូន្មានឥន្ទ្រិយទាំងអស់បានហើយ មានព្រះហឫទ័យស្អាត រកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវពោលគឺកិលេស មានដំណើរល្អក្នុងលោក ខ្ញុំឯងជាអ្នកបម្រើអ្នកប្រាជ្ញនោះ (១) ។

ព្រះសាស្តា ទ្រង់យាងទៅតាមផ្លូវដែលសក្កទេវរាជធ្វើឱកាសហើយនោះឯង ទ្រង់ចោមរោមដោយភិក្ខុ ១ ពាន់ យាងទៅកាន់នគររាជគ្រឹះ ។ ព្រះរាជា ទ្រង់ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចប្រព្រឹត្តទៅដោយវៀរព្រះរតនៈទាំងបី ខ្ញុំព្រះអង្គនឹងចូលគាល់ព្រះមានព្រះភាគក្នុងវេលាមិនមែនជាកាលខ្លះ ជាកាលខ្លះ ឈ្មោះថា លដ្ឋិវនឧទ្យាននៅឆ្ងាយពេក

១- បិ.៦ , ទំ. ១១៨ ។

តែឧទ្យានឈ្មោះវេឡុវ័នរបស់ខ្ញុំព្រះអង្គនេះ មិនជិតមិនឆ្ងាយ ជាសេនាសនៈសម្បូរដោយផ្លូវទៅមក សមគួរដល់ព្រះអង្គ សូមទ្រង់ទទួលវេឡុវ័ននេះចុះ ហើយទ្រង់យកសុវណ្ណភិង្គារគឺកុណ្ឌីមាស ដែលមានពណ៌ដូចកែវមណី ដែលអប់ដោយផ្កា និងគ្រឿងក្រអូបមក កាលទ្រង់បរិច្ចាគឧទ្យានវេឡុវ័ន ទើបទ្រង់ច្រួចទឹកដាក់លើព្រះហស្តរបស់ព្រះសាស្តា ក្នុងខណៈដែលព្រះសម្មាសម្ពុទ្ធទ្រង់ទទួលអារាម មហាប្រឹថពីក៏បានកក្រើករំពើក ជាហេតុឲ្យដឹងថា ឫសកែវរបស់ព្រះពុទ្ធសាសនាបានឈមចុះហើយ ពិតហើយ ក្នុងជម្ពូទ្វីប វៀរវត្តវេឡុវ័នចេញហើយ ឈ្មោះថាសេនាសនៈដទៃដែលទ្រង់ទទួលហើយ ផែនដីញាប់ញ័រ មិនមានឡើយ ចំណែកក្នុងតម្ពបណ្ណិទ្វីប ( កោះលង្កា ) មិនមានសេនាសនៈដទៃដែល ( ព្រះថេរៈទាំងឡាយ ) ទទួលហើយផែនដីកម្រើកនោះទេ មានតែមហាវិហារប៉ុណ្ណោះ ។ ព្រះមានព្រះភាគ កាលទ្រង់ទទួលវត្តវេឡុវនារាមហើយ ទ្រង់ធ្វើអនុមោទនាដល់ព្រះរាជា ហើយទ្រង់ក្រោកចាកអាសនៈចោមរោមដោយភិក្ខុសង្ឃ បានយាងទៅកាន់វេឡុវ័ននោះ ។

សម័យនោះ បរិព្វាជកពីរនាក់គឺ សារីបុត្តនិងមោគ្គល្លាន អាស្រ័យក្រុងរាជគ្រឹះហើយស្វែងរកអមតធម៌ បណ្តាបរិព្វាជកទាំងពីរនោះ សារីបុត្តឃើញព្រះអស្សជិត្ថេរចូលទៅបិណ្ឌបាត មានចិត្តជ្រះថ្លា ក៏ចូលទៅជិត បានស្តាប់គាថាថា **យេ ធម្មា ហេតុប្បភវា** ប្រែថា ធម៌ពួកណា

មានហេតុជាដែនកើត ដូច្នេះជាដើម បានតាំងនៅក្នុងសោតាបត្តិផល បានពោលគាថានោះ ដល់មោគ្គល្លានបរិព្វាជកដែលជាសម្លាញ់របស់ខ្លួន ។ ចំណែកមោគ្គល្លានបរិព្វាជក ក៏បានតាំងនៅក្នុងសោតាបត្តិផល សម្លាញ់ទាំងពីរនោះ លាសញ្ជយបរិព្វាជកហើយ បួសក្នុងសម្នាក់របស់ព្រះដ៏មានព្រះភាគ មួយអន្លើដោយបរិវាររបស់ខ្លួន ។ បណ្ដាសម្លាញ់ទាំងពីរនាក់នោះ ព្រះមោគ្គល្លានត្ថេរបានសម្រេចអរហត្ត ក្នុងកាល ៧ ថ្ងៃ ព្រះសារីបុត្តត្ថេរសម្រេចអរហត្ត ក្នុងកាលកន្លងទៅកន្លះខែ ។ ព្រះមានព្រះភាគ ទ្រង់ស្ថាបនាព្រះថេរៈទាំងពីរក្នុងតំណែងអគ្គសាវក ក្នុងថ្ងៃដែលព្រះសារីបុត្តត្ថេរសម្រេចអរហត្តនោះ ហើយទ្រង់បានធ្វើសាវកសន្និបាត ប្រជុំពួកសាវកទាំងឡាយ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងឧទ្យានវេឡុវ័ននោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់បានដំណឹងថា បានឮថា បុត្តរបស់យើងប្រព្រឹត្តទុក្ករកិរិយាអស់ ៦ ឆ្នាំ បានសម្រេចបរមាភិសម្ពោធិញ្ញាណ ហើយប្រកាសធម្មចក្កដ៏បវរ ឥឡូវនេះ អាស្រ័យវត្តវេឡុវ័ន ក្នុងនគររាជគ្រឹះ ទើបត្រាស់ហៅអាមាត្យម្នាក់មកត្រាស់ថា នៃអ្នក ចូរអ្នកមានបុរស ១ ពាន់ជាបរិវារ ធ្វើដំណើរទៅកាន់ក្រុងរាជគ្រឹះ ពោលតាមពាក្យរបស់យើងថា ព្រះបាទសុទ្ធោទនមហារាជជាបិតារបស់ព្រះអង្គ មានបំណងនឹងជួប ហើយសូមនាំបុត្តរបស់យើងមក ។ អាមាត្យនោះទទួលព្រះ

តម្រាស់របស់ព្រះរាជាដោយសិរសោគីត្បូងថា ករុណាថ្ងៃវិសេស មាន បុរស ១ ពាន់ជាបរិវារ ប្រញាប់ធ្វើដំណើរទៅអស់ផ្លូវប្រមាណ ៦០ យោជន៍ ចូលទៅកាន់វិហារ អង្គុយក្នុងកណ្តាលបរិស័ទ ៤ នៃព្រះទសពល ក្នុងវេលាសម្តែងធម៌ ។ អាមាត្យនោះគិតថា ព្រះរាជសាសន៍របស់ព្រះរាជាបញ្ជូនមក ចូរស្ទេះទុកសិនចុះ ហើយឈរក្នុងទីបំផុតនៃបរិស័ទ ស្តាប់ព្រះធម្មទេសនាក្នុងសម្នាក់ព្រះសាស្តា ក្នុងខណៈដែលឈរនោះ ក៏សម្រេចអរហត្តមួយអន្លើដោយបុរសជាបរិវារ ១ ពាន់នាក់ ទើបទូលសូមបព្វជ្ជា ព្រះសាស្តា ទ្រង់លាព្រះហស្តស្តាំចេញមក ហើយត្រាស់ថា **ឯថ ភិក្ខវោ** ពួកអ្នកចូរមកជាភិក្ខុចុះ ខណៈនោះ ជនទាំងអម្បាលនោះ ក៏ទ្រទ្រង់នូវបាត្រនិងចីវរដែលសម្រេចដោយឫទ្ធិ ហាក់បីដូចជាព្រះថេរៈដែលមានវស្សា ៦០ ដូច្នោះ ធម្មតាព្រះអរិយៈទាំងឡាយ រមែងមានខ្លួនជាកណ្តាល ចាប់តាំងអំពីពេលដែលបានសម្រេចអរហត្ត ព្រោះដូច្នោះ ទើបមិនបានក្រាបទូលរាជសាសន៍ដែលព្រះរាជាបញ្ជូនមក ។ ព្រះរាជាត្រាស់ថា អាមាត្យដែលបញ្ជូនទៅហើយមិនឃើញមកសោះ រាជសាសន៍ក៏មិនបានស្តាប់ ណ្ហើយចុះអ្នក អ្នកចូរទៅ ហើយទ្រង់បញ្ជូនអាមាត្យដទៃទៅតាមទំនងនោះឯង ។ អាមាត្យនោះទៅហើយ ក៏បានសម្រេចអរហត្តមួយអន្លើដោយបរិស័ទ ដោយន័យមុននោះឯង ( អាមាត្យនោះ ) ក៏បាននៅស្ងៀមទៀត ព្រះរាជាទ្រង់បានបញ្ជូនអាមាត្យ ៩ នាក់ ដែល

មានបរិវារម្នាក់ ១ ពាន់ ដោយទំនងនោះទៅ ។ អាមាត្យគ្រប់គ្នាញុំាង កិច្ចរបស់ខ្លួនឲ្យសម្រេចហើយ ក៏ជាអ្នកនៅស្ងៀមក្នុងក្រុងរាជគ្រឹះនោះ ។ ព្រះរាជាមិនបានអាមាត្យ សូម្បីតែម្នាក់មកប្រាប់ដំណឹង ទើបទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះ មិននាំដំណឹងត្រឡប់មក ព្រោះមិនមានសេចក្ដីស្រឡាញ់ក្នុងអញ អ្នកណាហ្ន៎ អាចធ្វើតាមពាក្យរបស់អញបាន កាលទ្រង់ពិចារណាពលទាំងអស់ហើយ ក៏បានឃើញកាឡុទាយីអាមាត្យ ។ បានឮថា កាឡុទាយីអាមាត្យនោះ ជាអាមាត្យដែលចាត់-ចែងរាជកិច្ចទាំងពួងឲ្យសម្រេច ជាមនុស្សខាងក្នុង ជាអ្នកស្និទ្ធស្នាលក្រៃលែង កើតថ្ងៃតែមួយ ជាមួយនឹងព្រះមហាបុរស ជាសម្លាញ់លេងដីជាមួយគ្នាមក ។ លំដាប់នោះ ព្រះរាជាឲ្យហៅកាឡុទាយីអាមាត្យនោះមក ហើយត្រាស់ថា បាឧទាយី យើងប្រាថ្នានឹងឃើញបុត្តរបស់យើង ទើបបញ្ជូនបុរស ៩ ពាន់ទៅ បុរសសូម្បីតែម្នាក់ មកប្រាប់យើងដោយដំណឹងក៏មិនមាន ឯអន្តរាយនៃជីវិតរបស់យើង ដឹងបានដោយលំបាកពេកណាស់ យើងកាលមានជីវិតនៅ ប្រាថ្នានឹងឃើញបុត្ត តើអ្នកអាចនាំបុត្តរបស់យើងមកបានដែរឬទេហ្ន៎ ?

កាឡុទាយីអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំអាច បើទូលបង្គំបានបួស ។

ព្រះរាជាត្រាស់ថា អើបា បើអ្នកបួសឬមិនបួស ក៏តាមតែចិត្តអ្នក

ទៅចុះ តែចូរបង្ហាញបុត្តដល់យើង ។ កាឡុទាយីអាមាត្យនោះ ទទួលព្រះរាជតម្រាស់ថា សាធុ ហើយកាន់យកព្រះរាជសាសន៍ទៅកាន់នគររាជគ្រឹះ ឈរខាងចុងបរិស័ទ ក្នុងកាលព្រះដ៏មានព្រះភាគទ្រង់សម្ដែងព្រះធម្មទេសនា បានស្ដាប់ធម៌ហើយ មួយអន្លើដោយបរិវារក៏សម្រេចអរហត្តផល តាំងនៅក្នុងភាពជាឯហិភិក្ខុ ។

ចំណែកព្រះសាស្ដា ទ្រង់បានត្រាស់ជាព្រះពុទ្ធហើយ ទ្រង់ប្រថាប់នៅក្នុងឥសិបតនមិគទាយវ័ន ក្នុងវស្សាទី ១ លុះចេញវស្សាបវារណាហើយ ទ្រង់យាងមកកាន់ឧរុវេលា ប្រថាប់នៅត្រង់តំបន់ឧរុវេលានោះអស់ ៣ ខែ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូន មានភិក្ខុ ១ ពាន់ជាបរិវារក្នុងថ្ងៃ ១៥ កើត ខែបុស្ស ទ្រង់យាងទៅកាន់នគររាជគ្រឹះ ប្រថាប់នៅពីរខែដោយលំដាប់ កាលមានប្រមាណប៉ុណ្ណោះ វេលា ៥ ខែ សម្រាប់ព្រះបរមសាស្ដាដែលយាងចេញអំពីនគរពារាណសី ហេមន្តរដូវក៏កន្លងទៅហើយ ចាប់តាំងអំពីថ្ងៃដែលព្រះឧទាយិត្ថេរមកហើយ វេលាបានកន្លងទៅ ៧ - ៨ ថ្ងៃ ក្នុងថ្ងៃ ១៥ កើត ខែផល្គុន ព្រះឧទាយិត្ថេរនោះគិតថាហេមន្តរដូវក៏កន្លងទៅហើយ វស្សានរដូវកំពុងឈានចូលមក ពួកមនុស្សដកសន្ទូងហើយ ផ្លូវក្នុងទីចំពោះមុខ ដេរដាសទៅដោយស្មៅពណ៌ខៀវស្រស់ ដងព្រៃមានផ្ការីកស្គុសស្គាយ ផ្លូវសមគួរដល់ការធ្វើដំណើរ កាលនេះជាកាលគួរព្រះមានព្រះភាគ ទ្រង់ធ្វើការសង្គ្រោះដល់ព្រះញាតិ ។

លំដាប់នោះ ព្រះឧទាយិត្ថេរចូលទៅគាល់ព្រះដ៏មានព្រះភាគ ពណ៌នាអំពីផ្លូវ ដើម្បីឲ្យព្រះទសពលយាងទៅកាន់នគររបស់រាជត្រកូល ដោយគាថាប្រមាណ៦០ ដូច្នេះថា

អង្គារិនោទានិ ទុមា ភទន្តេ
ផលេសិនោ ឆទនំ វិប្បហាយ
តេ អច្ចិមន្តោវ បភាសយន្តិ
សមយោ មហាវិរ ភគី រសានំ ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើមានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ រុងរឿងដូចជាអណ្ដាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះជាកាលគួរបានចំណែកធម្មរសហើយ ។

ទុមានិ ផុល្លានិ មនោរមានិ
សមន្តតោ សព្វទិសា បវន្តិ
បត្តំ បហាយ ផលមាសសានា
កាលោ ឥតោ បក្កមនាយ វិរ ។

ឈើទាំងឡាយ ជាទីរីករាយនៃចិត្ត មានផ្លែ ផ្សាយក្លិនសព្វទិសដោយជុំវិញ ជម្រុះស្លឹកចាស់ចោល ប្រុងនឹងចេញផ្លែថ្មីទៀត បពិត្រព្រះអង្គមានព្យាយាម កាលនេះជាកាលគួរ

*ដើម្បីចេញទៅអំពីទីនេះ ។*

ឆេវាតិសីតំ ឆ បជាតិឧណ្ហំ
សខា ឧតុ អទ្ធនិយា ភទន្តេ
បស្សន្តុ តំ សាកិយា កោឡិយា ច
បច្ឆាមុខំ រោហិណិយំ តរន្តំ ។

*បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ពួកសក្យៈនិងពួកកោឡិយៈ សូមជួបព្រះអង្គ ដែលមានព្រះភក្ត្របែរត្រឡប់មកខាងក្រោយ កំពុងឆ្លងស្ទឹងរោហិណី ។*

អាសាយ កសតេ ខេត្តំ ពីជំ អាសាយ វប្បតិ
អាសាយ វាណិជា យន្តិ សមុទ្ទំ ធនហារកា ។
យាយ អាសាយ តិដ្ឋាមិ សា មេ អាសា សមិជ្ឈតុ ។

*អ្នកស្រែភ្ជួរស្រែ ដោយសេចក្តីប្រាថ្នា ក៏ព្រោះពូជ ដោយសេចក្តីប្រាថ្នា ពួកឈ្មួញ អ្នករកទ្រព្យឆ្លងសមុទ្ទ ដោយសេចក្តីប្រាថ្នា ។ ខ្ញុំព្រះអង្គ ឋិតនៅ ដោយសេចក្តីប្រាថ្នាណា សេចក្តីប្រាថ្នា របស់ខ្ញុំព្រះអង្គនោះ សូមឲ្យសម្រេច*[១]

១-បិ.៥៧ , ទំ. ១៤ ។

ដូច្នេះជាដើម ។

លំដាប់នោះ ព្រះសាស្តា ត្រាស់នឹងព្រះឧទាយិត្ថេរថា ម្នាលឧទាយី ព្រោះហេតុអ្វី ទើបអ្នកពណ៌នាការទៅដោយសំឡេងដ៏ពីរោះម្ល៉េះ ?

ព្រះឧទាយិត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជ ព្រះជនករបស់ព្រះអង្គ មានបំណងនឹងឃើញព្រះអង្គ សូមទ្រង់ធ្វើការសង្គ្រោះដល់ព្រះញាតិទាំងឡាយផងចុះ ។

ព្រះសាស្តាត្រាស់ថា សាធុ ឧទាយី តថាគតនឹងធ្វើការសង្គ្រោះដល់ព្រះញាតិ អ្នកចូរប្រាប់ដល់ភិក្ខុសង្ឃ ភិក្ខុទាំងឡាយនឹងបំពេញគមិកវត្ត ( វត្តសម្រាប់អ្នកធ្វើដំណើរ ) ។ ព្រះឧទាយិត្ថេរទទួលព្រះតម្រាស់ថា សាធុ ព្រះអង្គ ហើយទើបទៅប្រាប់ភិក្ខុសង្ឃ ។

ព្រះមានព្រះភាគ ទ្រង់ចោមរោមដោយពួកភិក្ខុខីណាស្រព ទាំងអស់ ២ ម៉ឺនអង្គ គឺភិក្ខុដែលជាកុលបុត្តអ្នកដែនអង្គៈនិងអ្នកមគធៈ ១ ម៉ឺនអង្គ ភិក្ខុដែលជាកុលបុត្តអ្នកក្រុងកបិលពស្តុ ១ ម៉ឺនអង្គ ទ្រង់ចេញអំពីនគររាជគ្រឹះ យាងទៅមួយថ្ងៃមួយយោជន៍ ។ ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា នឹងយាងចេញអំពីក្រុងរាជគ្រឹះដល់ក្រុងកបិលពស្តុ ដែលមានចម្ងាយផ្លូវ ៦០ យោជន៍ ដោយថេរវេលា ២ ខែ ទើបទ្រង់ចារិកទៅដោយមិនប្រញាប់ប្រញាល់ ។ ចំណែកព្រះថេរៈគិតថា នឹងក្រាបទូលភាពដែលព្រះមានព្រះភាគយាងមកហើយ ទើបហោះទៅតាមអាកាស

ប្រាកដក្នុងព្រះរាជនិវេសន៍របស់ព្រះរាជា ។ ព្រះរាជាទតឃើញព្រះថេរៈហើយ ត្រេកអរ និមន្តឲ្យគង់លើបល្ល័ង្កដែលមានតម្លៃច្រើន ហើយទ្រង់នាំបាត្រមក ឲ្យពេញដោយភោជនមានរសដ៏ប្រសើរផ្សេងៗ ដែលគេត្រៀមទុកដើម្បីព្រះអង្គហើយប្រគេនទៅ ព្រះថេរៈក្រោកឡើងសម្តែងអាការនឹងទៅ ព្រះរាជាត្រាស់ថា សូមលោកម្ចាស់ឆាន់ចុះ ។

ព្រះថេរៈពោលថា មហាបពិត្រ អាត្មានឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយសឹមឆាន់ ។

ព្រះរាជាត្រាស់សួរថា ព្រះសាស្តាគង់នៅឯណា ?

ព្រះឧទាយិត្ថេរពោលថា មហាបពិត្រ ព្រះសាស្តាមានភិក្ខុ ២ ម៉ឺនជាបរិវារ ទ្រង់យាងចេញចារិកដើម្បីឃើញព្រះអង្គ ។

ព្រះរាជាទ្រង់សប្បាយព្រះទ័យត្រាស់ថា លោកម្ចាស់ឆាន់ភត្តាហារនេះហើយ សឹមនាំបិណ្ឌបាតអំពីព្រះរាជនិវេសន៍នេះ ទៅថ្វាយព្រះឱរស រហូតព្រះឱរសរបស់ខ្ញុំមកដល់នគរនេះ ។ ព្រះថេរៈទទួលហើយ ព្រះរាជាអង្គាសព្រះថេរៈ អប់បាត្រដោយលម្អិតក្រអូប ដាក់ពេញដោយភោជនដ៏ឧត្តម ហើយទុកក្នុងដៃរបស់ព្រះថេរៈ ដោយត្រាស់ថា សូមលោកម្ចាស់ថ្វាយព្រះសាស្តា ។ ព្រះថេរៈ កាលអ្នករាជវាំងកំពុងឃើញនោះឯង បោះបាត្រទៅលើអាកាស បាត្រក៏អណ្តែតទៅ ចំណែកខ្លួនលោកក៏ហោះឡើងទៅកាន់អាកាស នាំបិណ្ឌបាតទៅចុះក្នុងទីចំពោះ

ព្រះភក្ត្របស់ព្រះទសពល ។ ព្រះបរមសាស្តា ទ្រង់សោយបិណ្ឌបាតនោះ ។ ព្រះថេរៈបាននាំបិណ្ឌបាតមករាល់ៗថ្ងៃ ដោយឧបាយនេះឯង ព្រះបរមសាស្តា ទ្រង់សោយចំពោះតែបិណ្ឌបាតរបស់ព្រះរាជាប៉ុណ្ណោះ ក្នុងរវាងដំណើរផ្លូវ ។ ក្នុងកាលស្រេចភត្តកិច្ចរាល់ៗថ្ងៃ ព្រះថេរៈពោលថា ថ្ងៃនេះ ព្រះដ៏មានព្រះភាគ ទ្រង់យាងមកអស់រយៈផ្លូវមានប្រមាណប៉ុណ្ណោះ ថ្ងៃនេះ ទ្រង់យាងមកអស់រយៈផ្លូវមានចម្ងាយប៉ុណ្ណោះ បានធ្វើរាជត្រកូលទាំងមូលឲ្យជ្រះថ្លាក្នុងព្រះទសពល ដោយវៀរការបានឃើញព្រះអង្គ ដោយធម្មីកថាដែលសម្បយុត្តដោយព្រះពុទ្ធគុណ ដោយហេតុនោះ ព្រះបរមសាស្តា ទ្រង់ស្ថាបនាព្រះឧទាយិត្ថេរនោះ ទុកក្នុងតំណែងកំពូលជាងភិក្ខុទាំងឡាយថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ**

**កុលប្បសាទកានំ យទិទំ កាឡុទាយិ ។**

ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញ៉ាំងត្រកូលឲ្យជ្រះថ្លា ដែលជាសាវករបស់តថាគត ស្រេចនឹងកាឡុទាយិ [១] ។

ចំណែកស្តេចសក្យទាំងឡាយ កាលព្រះមានព្រះភាគ ទ្រង់យាងដល់ដោយលំដាប់ហើយ បានប្រឹក្សាគ្នាថា ពួកយើងនឹងឃើញព្រះញាតិ

---

១-បិ.៤០ , ទំ. ៥៥ ។

ដ៏ប្រសើររបស់ពួកយើង ទើបប្រជុំគ្នា ពិចារណាស្ថានទីដែលជាទីប្រថាប់គង់របស់ព្រះទសពល កំណត់គ្នាថា អារាមរបស់ព្រះបាទនិគ្រោធសក្យគួរជាទីត្រេកអរ ហើយឲ្យធ្វើការជួសជុលគ្រប់យ៉ាងក្នុងអារាមនោះ កាន់ផ្កាកម្រងនិងគ្រឿងក្រអូបដើម្បីធ្វើការទទួល ( ព្រះសាស្ដា ) បញ្ជូនក្មេងអ្នកស្រុកដែលប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាងទៅមុន បន្ទាប់អំពីនោះ ( ស្ដេចសក្យទាំងនោះ ) ក៏បញ្ជូនព្រះរាជកុមារនិងព្រះរាជកុមារីទៅ ខ្លួនឯងបូជាដោយផ្កាកម្រងនិងគ្រឿងក្រអូប មួយអន្លើដោយលម្អិត (ខ្ទឹមចន្ទន៍) ជាដើម ហើយនៅក្នុងចន្លោះរាជកុមារនិងរាជកុមារីទាំងនោះ បាននាំព្រះបរមសាស្ដាទៅកាន់និគ្រោធារាម ។ ក្នុងនិគ្រោធារាមនោះ ព្រះមានព្រះភាគចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ទ្រង់ប្រថាប់លើបវរពុទ្ធាសនៈដែលគេក្រាលទុកហើយ ។ ធម្មតាស្ដេចសក្យទាំងឡាយ ជាអ្នកមានជាតិមានះគឺប្រកាន់ខ្លួនខ្លាំង ស្ដេចសក្យទាំងនោះទ្រង់ព្រះតម្រិះថា សិទ្ធត្ថកុមារក្មេងជាងយើងទាំងឡាយ ជាប្អូនប្រុស ជាក្មួយ ជាព្រះឱរស ជាចៅនៃយើងទាំងឡាយ ទើបត្រាស់នឹងព្រះរាជកុមារទាំងឡាយដែលក្មេងៗ ថា អ្នកទាំងឡាយ ចូរថ្វាយបង្គំព្រះមានព្រះភាគ ពួកយើងនឹងអង្គុយខាងក្រោយអ្នកទាំងឡាយ ។

កាលសក្យទាំងនោះមិនថ្វាយបង្គំ ប្រថាប់គង់ហើយយ៉ាងនេះ ព្រះបរមសាស្ដា ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ស្ដេចសក្យទាំងនោះ

ហើយទ្រង់ព្រះតម្រិះថា ព្រះញាតិទាំងឡាយមិនថ្វាយបង្គំតថាគត ណ្ហើយចុះ តថាគតនឹងឲ្យញាតិទាំងនោះថ្វាយបង្គំ ទើបទ្រង់ចូលចតុត្ថ-ជ្ឈានមានអភិញ្ញាជាបាទ ចេញអំពីឈានហើយហោះឡើងទៅកាន់អា-កាស រោយធូលីព្រះបាទលើសិរសាស្តេចសក្យទាំងនោះ ទ្រង់បានធ្វើបាដិហារិយ៍ ដូចគ្នានឹងយមកប្បាដិហារិយ៍ត្រង់មណ្ឌលគណ្ឌាម្ពព្រឹក្សនោះឯង ។ ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ ក្នុងថ្ងៃដែលព្រះអង្គប្រសូត ខ្ញុំព្រះអង្គបានឃើញព្រះបាទារបស់ព្រះអង្គ ដែលខ្ញុំព្រះអង្គនាំទៅឲ្យថ្វាយបង្គំកាឡទេវិលតាបសត្រឡប់ជាប្រតិស្ឋានលើផ្នួងសក់របស់ព្រាហ្មណ៍ ខ្ញុំក៏បានថ្វាយបង្គំព្រះអង្គ នេះជាការថ្វាយបង្គំលើកទី ១ របស់ខ្ញុំព្រះអង្គ ។ ក្នុងថ្ងៃវប្បមង្គល (ថ្ងៃច្រត់ព្រះនង្គ័ល) ក៏បានឃើញការមិនប្រែប្រួលនៃស្រមោលដើមព្រីង ក្នុងពេលដែលទ្រង់ផ្ទំលើទីបន្ទំដែលប្រកបដោយសិរី ក្រោមម្លប់ព្រីងនោះ ខ្ញុំព្រះអង្គក៏បានថ្វាយបង្គំព្រះបាទា នេះជាការថ្វាយបង្គំលើកទី ២ ឥឡូវនេះ បានឃើញបាដិហារិយ៍នេះ ដែលមិនធ្លាប់ឃើញ ទើបថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ នេះជាការថ្វាយបង្គំលើកទី ៣ របស់ខ្ញុំព្រះអង្គ ។ កាលព្រះរាជាថ្វាយបង្គំហើយ ស្តេចសក្យសូម្បីតែមួយអង្គ ដែលអាចមិនថ្វាយបង្គំព្រះសាស្តាហើយតាំងនៅបាន មិនមានឡើយ ស្តេចសក្យទាំងពួងនាំគ្នាថ្វាយបង្គំទាំងអស់ ព្រះសាស្តា ទ្រង់ឲ្យព្រះញាតិទាំងឡាយ

ថ្វាយបង្គំដោយប្រការដូច្នេះហើយ ទើបទ្រង់ចុះអំពីអាកាសប្រថាប់លើអាសនៈដែលគេក្រាលទុក ។ កាលព្រះមានព្រះភាគ ទ្រង់គង់ហើយ សមាគមព្រះញាតិដែលដល់ទីបំផុត (ប្រជុំគ្នាទាំងអស់) ក៏មានឡើង ស្តេចសក្យទាំងពួងជាអ្នកមានឯកគ្គតាចិត្ត ប្រថាប់គង់ហើយ ។ លំដាប់នោះ មហាមេឃបានញុំាងភ្លៀងបោក្ខរព័ស៌ឲ្យធ្លាក់ចុះមក ទឹកភ្លៀងនោះមានពណ៌ក្រហមស្រក់ចុះមក ហើយបុគ្គលដែលបំណងនឹងសើម ទើបសើម ភ្លៀងបោក្ខរព័ស៌មិនធ្លាក់ សូម្បីត្រឹមតែមួយដំណក់ លើរាងកាយបុគ្គលដែលមិនប្រាថ្នាឲ្យសើម ស្តេចសក្យទាំងពួងឃើញដូច្នោះ កើតអស្ចារ្យមិនធ្លាប់ឃើញ ទើបសន្ទនាគ្នាឡើងថា ឱ គួរអស្ចារ្យ ឱ មិនធ្លាប់មាន ។ ព្រះសាស្តាត្រាស់ថា ភ្លៀងបោក្ខរព័ស៌ធ្លាក់ចុះមកក្នុងសមាគមនៃព្រះញាតិរបស់តថាគត តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងអតីតក៏ធ្លាក់មកហើយដែរ ហើយទើបត្រាស់ **វេស្សន្តរជាតក** ព្រោះហេតុកើតរឿងនេះ ។ ស្តេចសក្យទាំងពួង ស្តាប់ព្រះធម្មទេសនាហើយ ក្រោកឡើងថ្វាយបង្គំព្រះបរមសាស្តា ហើយចៀសចេញទៅ ។ ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជា សូម្បីតែមួយអង្គ ឈ្មោះថា ក្រាប-ទូលថា សូមព្រះអង្គទទួលភិក្ខារបស់ខ្ញុំព្រះអង្គទាំងឡាយក្នុងថ្ងៃស្អែកដូច្នេះ មិនមាន ហើយនាំគ្នាចៀសចេញទៅ ។

ស្អែកឡើង ព្រះសម្មាសម្ពុទ្ធ ទ្រង់ចោមរោមដោយភិក្ខុ ២ ម៉ឺនអង្គ

ស្តេចយាងចូលទៅបិណ្ឌបាតក្នុងនគរកបិលពស្តុ មិនមានបុគ្គលណាមួយទៅនិមន្ត ឬទទួលបាត្រឡើយ ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់ឈរត្រង់សសរខឿន ទ្រង់ពិចារណាថា ព្រះពុទ្ធទាំងឡាយក្នុងកាលមុនត្រាច់បិណ្ឌបាតក្នុងនគររបស់ត្រកូលដូចម្តេចហ្ន៎ ទ្រង់យាងទៅកាន់ផ្ទះរបស់ឥស្សរជន ដោយរំលងលំដាប់ ឬត្រាច់ចារិកទៅតាមលំដាប់ ។ បន្ទាប់អំពីនោះ ទ្រង់មិនបានឃើញ សូម្បីតែព្រះពុទ្ធមួយព្រះអង្គ ដែលយាងទៅរំលងលំដាប់ ហើយទ្រង់ព្រះតម្រិះថា នេះប៉ុណ្ណោះជាវង្សរបស់ព្រះពុទ្ធទាំងឡាយ នេះជាបវេណីរបស់តថាគត សូម្បីតថាគតក៏គួរនឹងរៀរ (ការត្រាច់ទៅរំលងលំដាប់) ក្នុងកាលឥឡូវនេះ សាវកទាំងឡាយរបស់តថាគត នឹងសិក្សាតាមតថាគត នឹងបំពេញបិណ្ឌបាតចារិកវត្តតទៅ ទើបទ្រង់ត្រាច់ចារិកបិណ្ឌបាតទៅតាមលំដាប់ តាំងអំពីផ្ទះដែលតាំងនៅក្នុងទីបំផុត ។ មហាជនបន្ទីឡើងថា បានឮថា ព្រះសិទ្ធត្ថកុមារជាស្តេច ត្រាច់បិណ្ឌបាតដើម្បីដុំបាយ ហើយក៏បើកបង្អួចប្រាសាទជាន់ទី ២ និងជាន់ទី ៣ ជាដើម បានជាអ្នកខ្វល់ខ្វាយដើម្បីមើល ។

ចំណែកព្រះទេវីមាតារបស់ព្រះរាហុល ព្រះនាងព្រះតម្រិះថា បានឮថា ព្រះអយ្យបុត្តត្រាច់ទៅដោយវមាសជាដើម ដោយរាជានុភាពធំក្រៃលែងក្នុងនគរនេះឯង តែឥឡូវនេះ កោរសក់ និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាវៈ កាន់អំបែងត្រាច់ទៅដើម្បីដុំបាយ

តើស្រស់ស្អាតដែរឬហ្ន៎ ? ទើបព្រះនាងបើកសីហបញ្ជរទតមើល ក៏បានឃើញព្រះទសពលទ្រង់ញុាំងផ្លូវក្នុងនគរឲ្យភ្លឺស្វាង ដោយព្រះរស្មីនៃព្រះសរីរៈដ៏រុងរឿងដោយពុទ្ធសិរីមិនមានប្រមាណ ប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ លម្អដោយអនុព្យញ្ជនៈ ៨០ ដែលតាមហែហមចោមរោមដោយព្រះរស្មីប្រមាណមួយព្យាម ទើបព្រះនាងសរសើរតាំងអំពីព្រះឧណ្ហីស ( ថ្ងាស ) រហូតដល់ផ្ទៃព្រះបាទដោយគាថា ឈ្មោះថា នរសីហៈ ១០ គាថា មានសេចក្ដីដូច្នេះថា

សិនិទ្ធនីលមុទុកុញ្ចិតកេសោ សុរិយនិម្មលតលាភិនលាដោ
យុត្តតុង្គមុទុកាយតនាសោ រំសិជាលវិតតោ នរសីហោ ។

ព្រះនរសីហៈ មានកេសារលកទន់ខ្មៅរលោង មានថ្ងាសទូលាយប្រាសចាកមន្ទិលដូចព្រះអាទិត្យ មានព្រះនាសាវែងខ្ពស់ ទន់សម មានបណ្ដាញរស្មីផ្សាយចេញអំពីកាយ ។

ចក្កវរង្កិតរត្តសុបាទោ លក្ខណមណ្ឌិតអាយតបណ្ហិ
ចាមរឆត្តវិភូសិតបាទោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានផ្ទៃព្រះបាទក្រហមកំណត់ដោយចក្រដ៏ល្អ មានព្រះបណ្ហិ ( កែង ) វែង ប្រដាប់ដោយលក្ខណៈ មានព្រះបាទប្រដាប់ដោយចាមរនិងឆត្រ ។

សក្យកុមារោ វរោ សុខុមាលោ លក្ខណវិចិត្តបសន្នសរីរោ

លោកហិតាយ អាគតោ នរីពេ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង ជាសក្យកុមារដ៏ប្រសើរ ជាស្តេចសុខុមាលជាតិ មានសរីរៈស្អាត វិចិត្រដោយលក្ខណៈ ជាមហាវីរៈ ទ្រង់ស្តេចយាងមកដើម្បីប្រយោជន៍សត្វលោក ។*

អាយតយុត្តសុសណ្ឋិតសោតោ គោបខុមោ អភីនីលនេត្តោ
ឥន្ទធនុអភីនីលភមុកោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានទងព្រះកាណ៌វែងសក្តិសម មានដួងព្រះនេត្រ ដូចជាភ្នែកនៃ (កូន) គោ មានពណ៌ខៀវស្រស់ មានរោមចិញ្ចើមខ្មៅកោង ដូចឥន្ទធនូ ។*

បុណ្ណចន្ទនិភោ មុខវណ្ណោ ទេវនរានំ បិយោ នរនាគោ
មត្តគជិន្ទវិលាសិតគាមី ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះសោត មានព្រះភក្ត្រដូចចន្ទពេញវង់ ជាទីស្រឡាញ់នៃពួកទេវតានិងមនុស្ស ជានរៈប្រសើរ ទ្រង់មានដំណើរយាងយាស ដូចស្តេចដំរី ។*

សិនិទ្ធសុគម្ភីរមញ្ជុសឃោសោ ហិង្គុលវណ្ណរត្តសុជិវ្ហោ
វីសតិវីសតិសេតសុទន្តោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានព្រះសូរសៀងមូលជ្រៅ មានព្រះជិវ្ហាក្រហមល្អ សម្បុរដូចហិង្គុលជាតិ មានព្រះទន្តសបរិសុទ្ធ ចំនួន ៤០ គត់ ។*

ខត្តិយសម្ភវអគ្គកុលិន្ទោ ទេវមនុស្សនមស្សិតចាទោ
សីលសមាធិបតិដ្ឋិតចិត្តោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះ មានជាតិជាក្សត្រ ជាកំពូលនៃត្រកូល ដែលទេវតានិងមនុស្សតែងនមស្ការព្រះបាទា ទ្រង់មានព្រះទ័យតាំងមាំ ក្នុងសីល សមាធិ ។*

វដ្ដសុវដ្ដសុសណ្ឋិតគីវោ សីហហនុមិគរាជសរីរោ
កញ្ចនសុច្ឆវិឧត្តមវណ្ណោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានព្រះសូរង់មូលក្រំ មានចង្កាដូចសីហៈ មានសរីរៈដូចស្តេចម្រឹគ មានសម្បុរស្បែកល្អដូចមាស ។*

អញ្ជនសមវណ្ណសុនីលកេសោ កញ្ចនបដ្ដវិសុទ្ធនលាដោ
ឱសធិបណ្ឌរសុទ្ធសុឧណ្ណោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង មានព្រះកេសាខ្មៅដូចផ្កាអញ្ចាន មានថ្ងាសបរិសុទ្ធដូចដំបារមាស មានរោមប្រជុំចិញ្ចើមសសុទ្ធ ដូចផ្កាយព្រឹក ។*

គច្ឆតិនីលនភេវ ចន្ទោ តារាគណាបរិវេឋិតរូបោ
សាវកមជ្ឈគតោ សមណិន្ទោ ឯស ហិ តុយ្ហំ បិតា នរសីហោ ។

*ព្រះនរសីហៈ ជាបិតារបស់អ្នកនោះឯង ជាធំជាងសមណៈ*

ស្ដេចយាងត្រង់កណ្ដាលសាវ័ក ដូចព្រះចន្ទចោមរោមដោយ
ហ្វូងផ្កាយ គោចរក្នុងវិថីដូច្នោះ [១] ។

( ព្រះនាងពោលសរសើរដូច្នេះហើយ ) ទើបក្រាបទូលព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គយាងទៅដើម្បីដុំបាយ ។ ព្រះរាជា ទ្រង់សង្វេគ ទ្រង់ស្លៀកសំពត់សាដកដោយព្រះហស្តខ្លួនឯង ប្រញាប់ប្រញាល់ចេញទៅដោយរហ័ស ប្រថាប់ឈរក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដាហើយត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វីទើបទ្រង់ធ្វើឲ្យខ្ញុំព្រះអង្គខ្មាសគេ ហេតុអ្វីទើបទ្រង់ត្រាច់ទៅដើម្បីដុំបាយ ហេតុអ្វីទើបទ្រង់ធ្វើនូវការសម្គាល់ថា ភិក្ខុមានប្រមាណប៉ុណ្ណោះ មិនអាចបានភត្តាហារ ?

ព្រះបរមសាស្ដាត្រាស់តបថា មហាបពិត្រ នេះជាវង្ស នេះជាចរិតរបស់តថាគត ។

ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយមានវង្សជាខត្តិយៈ គឺជាវង្សរបស់ព្រះមហាសម្មតិរាជ មិនមែនឬ ? ក្នុងវង្សក្សត្រមហាសម្មតិរាជនោះ ក្សត្រសូម្បីតែមួយអង្គឈ្មោះថា ត្រាច់សុំដុំបាយ មិនមានទេ ។

---

១- ព្រះនរសីហគាថានេះ ប្រែសម្រួលដោយព្រះមហាសីលបញ្ញោ ។

ព្រះសាស្តាត្រាស់តបថា មហាបពិត្រ ឈ្មោះថាវង្សនេះ ជាវង្សរបស់ព្រះអង្គទេតើ តែឈ្មោះថា ពុទ្ធវង្ស គឺ ព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ ។ បេ ។ ព្រះកស្សបៈ ជាវង្សរបស់តថាគត ឯព្រះពុទ្ធអង្គដទៃៗ រាប់បានច្រើនពាន់អង្គ បានសម្រេចការចិញ្ចឹមជីវិតដោយភិក្ខាចារប៉ុណ្ណោះ ។ ព្រះបរមសាស្តា ទ្រង់ប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង ត្រាស់គាថានេះថា

**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ ធម្មំ សុចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង [១] ។

ក្នុងវេលាដែលចប់គាថានោះ ព្រះរាជាបានតាំងនៅក្នុងសោតាបត្តិផល និងបានស្តាប់គាថានេះថា

**ធម្មំ ចរេ សុចរិតំ ន តំ ទុច្ចរិតំ ចរេ**
**ធម្មចារី សុខំ សេតិ អស្មឹ លោកេ បរម្ហិ ច ។**

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះ ឲ្យ

---

១,២ - បិ.៥២ , ទំ.៥៧ ។

*ទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង* (២) ។

*(ព្រះរាជាក៏បាន) តាំងនៅក្នុងសកទាគាមិផល ទ្រង់បានស្តាប់* **ធម្មបាលជាតក** *ក៏តាំងនៅក្នុងអនាគាមិផល ។ ក្នុងសម័យជិតសោយទិវង្គត ផ្ទំលើទីបន្ទំដែលប្រកបដោយសិរីក្រោមស្វេតច្ឆត្រ បានសម្រេចអរហត្ត កិច្ចក្នុងការតាមប្រកបព្យាយាមដោយការនៅព្រៃ មិនមានដល់ព្រះរាជា ។ កាលទ្រង់ធ្វើឲ្យជាក់ច្បាស់ចំពោះនូវសោតាបត្តិផលប៉ុណ្ណោះ ព្រះរាជា ទ្រង់ក៏ទទួលបាត្រព្រះមានព្រះភាគ និមន្តព្រះសាស្តាមួយអន្លើដោយភិក្ខុសង្ឃឡើងកាន់មហាប្រាសាទ ទ្រង់អង្គាសដោយខាទនីយភោជនីយាហារដ៏ឧត្តម ។ ក្នុងវេលាស្រេចភត្តកិច្ច ស្នំទាំងពួងវៀរតែរាហុលមាតា នាំគ្នាមកថ្វាយបង្គំព្រះសាស្តា ឯព្រះមាតារបស់រាហុលកុមារនោះសូម្បីជនជាបរិវារពោលថា សូមព្រះនាងយាងទៅថ្វាយបង្គំព្រះអយ្យបុត្តចុះ ក៏មានព្រះសវនីយ៍ថា បើគុណគឺសេចក្តីល្អរបស់ខ្ញុំមានសោត ព្រះអយ្យបុត្តនឹងយាងមកកាន់សម្នាក់ខ្ញុំដោយព្រះអង្គឯង ខ្ញុំនឹងថ្វាយបង្គំព្រះអយ្យបុត្តនោះ ដែលយាងមកប៉ុណ្ណោះ កាលត្រាស់ដូច្នេះហើយ ក៏មិនបានយាងទៅ ។ ព្រះបរមសាស្តា ទ្រង់ឲ្យព្រះរាជាកាន់បាត្រហើយទ្រង់យាងទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជធីតា មួយអន្លើដោយអគ្គសាវកទាំងគូ ហើយត្រាស់ (ហាម) ថា បើព្រះរាជធីតាថ្វាយបង្គំ ចូរឲ្យ*

ព្រះនាងថ្វាយបង្គំតថាគតតាមគាប់ចិត្តចុះ មិនគប្បីពោលពាក្យណាមួយឡើយ ហើយប្រថាប់គង់លើអាសនៈដែលគេក្រាលទុក ព្រះរាជធីតាយាងចេញមកដោយឆាប់រហ័ស ចាប់ត្រង់កព្រះបាទា ដាក់ព្រះសិរសាលើខ្នងព្រះបាទ ថ្វាយបង្គំតាមព្រះអធ្យាស្រ័យ ។ ព្រះរាជាត្រាស់គុណសម្បត្តិ មានការស្រឡាញ់ និងការរាប់អានច្រើន ចំពោះព្រះមានព្រះ-ភាគរបស់ព្រះរាជធីតាថា បពិត្រព្រះអង្គដ៏ចម្រើន ធីតារបស់ខ្ញុំព្រះអង្គបានឮដំណឹងថា ព្រះអង្គទ្រង់ស្លៀកដណ្ដប់សំពត់កាសាវៈ តាំងអំពីនោះមក ព្រះនាងក៏ស្លៀកដណ្ដប់សំពត់កាសាវៈដែរ បានឮដំណឹងថា ទ្រង់មានភត្តតែមួយពេល ព្រះនាងក៏មានភត្តតែមួយពេលដែរ ព្រះនាងបានឮថា ទ្រង់លះបង់ទីអង្គុយ ទីដេកធំ ព្រះនាងក៏ផ្ទំចំពោះលើគ្រែតូចដែលសន្ធឹងដោយផ្ទាំងសំពត់ ព្រះនាងជ្រាបថា ទ្រង់វៀរចាកគ្រឿងក្រអូប មានផ្កាជាដើម ព្រះនាងក៏វៀរបង់នូវគ្រឿងក្រអូប មានផ្កាជាដើមដែរ កាលព្រះញាតិបញ្ជូនដំណឹងមកថា យើងទាំងឡាយនឹងបដិបត្តិក្នុងញាតិទាំងឡាយរបស់ខ្លួន ( ចូលស្ដីដណ្ដឹង ) ក៏ព្រះនាងមិនសម្ញឹងមើល សូម្បីតែព្រះញាតិមួយអង្គ បពិត្រព្រះមានព្រះភាគ ព្រះរាជធីតារបស់ខ្ញុំព្រះអង្គដល់ព្រមដោយគុណយ៉ាងនេះ យ៉ាងនេះ ។

ព្រះបរមសាស្ដាត្រាស់ថា មហាបពិត្រ ការដែលព្រះរាជធីតាដែលព្រះអង្គរក្សាគ្រប់គ្រង ក្នុងកាលឥឡូវនេះ គប្បីរក្សាគ្រប់គ្រងខ្លួន

ក្នុងកាលញាណចាស់ក្លាហើយនោះ មិនជាអស្ចារ្យទេ សូម្បីក្នុងកាលមុន ព្រះរាជធីតានេះ មិនមានការរក្សា ត្រាច់ទៅតាមជើងភ្នំ ក៏រក្សាខ្លួនបាន ក្នុងកាលញាណមិនទាន់ចាស់ក្លា ដូច្នេះហើយ ទ្រង់បន្ទោបង់នូវសេចក្តីសោករបស់ព្រះរាជធីតានោះ ត្រាស់ **ចន្ទកិន្នរីជាតក** ទ្រង់ឲ្យសោតាបត្តិផល ហើយក្រោកចាកអាសនៈ ស្តេចយាងចៀសចេញទៅ ។ ក្នុងថ្ងៃទី ២ កាលវិវាហមង្គលទាក់ទងក្នុងការយាងចូលព្រះដំណាក់អភិសេករបស់នន្ទរាជកុមារកំពុងប្រព្រឹត្តទៅ ព្រះបរមសាស្តា ទ្រង់យាងទៅកាន់ដំណាក់របស់នន្ទរាជកុមារនោះ ទ្រង់ឲ្យនន្ទរាជកុមារកាន់បាត្រ មានព្រះបំណងឲ្យបួស ទើបត្រាស់មង្គលកថា ហើយទ្រង់ក្រោកឡើងចាកអាសនៈចៀសចេញទៅ ។ ឯនាងជនបទកល្យាណីនោះ ឃើញព្រះរាជកុមារកំពុងយាងទៅ ទើបទូលថា **តុវដំ ខោ អយ្យបុត្ត អាគច្ឆេយ្យាសិ** បពិត្រអយ្យបុត្ត សូមទ្រង់ប្រញាប់ត្រឡប់មកវិញផង ហើយព្រះនាងអើតកមើលតាមបង្អួច ។ ព្រះរាជកុមារមិនអាចទូលព្រះសាស្តាថា សូមទ្រង់ទទួលយកបាត្ររបស់ព្រះអង្គវិញចុះ ក៏យាងទៅកាន់វិហារនោះឯង នន្ទកុមារនោះ មិនប្រាថ្នានឹងបួសឡើយ ព្រះមានព្រះភាគទ្រង់ឲ្យបួសហើយ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់កបិលពស្តុបុរី ទ្រង់ឲ្យនន្ទកុមារបួស ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ រាហុលមាតាប្រដាប់តាក់តែងព្រះកុមារហើយ បញ្ជូន

ទៅគាល់ព្រះដ៏មានព្រះភាគដោយព្រះសវនីយ៍ថា នែកូន ចូរបាមើល សមណៈដែលមានរូបដូចព្រហ្ម មានពណ៌សម្បុរដូចមាស ចោមរោម ដោយសមណៈ ២ ម៉ឺនអង្គនុ៎ះ ព្រះសមណៈនេះជាបិតារបស់បុត្ត ព្រះ សមណៈនេះមានកំណប់ទ្រព្យធំ ចាប់តាំងអំពីព្រះសមណៈនោះចេញ បួសហើយ ម្តាយមិនបានឃើញកំណប់ទ្រព្យនោះឡើយ ចូរបាទៅសូម មរតកជាមួយសមណៈនោះថា បពិត្រព្រះបិតា ខ្ញុំព្រះអង្គជាកុមារ បាន ទទួលអភិសេកហើយនឹងបានជាស្តេចចក្រពត្តិ ខ្ញុំព្រះអង្គត្រូវការទ្រព្យ សូមព្រះអង្គប្រទានទ្រព្យដល់ខ្ញុំ ព្រោះធម្មតាបុត្ត រមែងជាម្ចាស់ទ្រព្យ ដែលជាដំណែលរបស់បិតា ។ ព្រះរាហុលកុមារនោះទៅកាន់សម្នាក់ ព្រះសាស្តា ត្រឡប់បាននូវការស្រឡាញ់ចំពោះព្រះបិតា មានចិត្តត្រេកអរ ក្រាបទូលថា **សុខា តេ សមណ ឆាយា** បពិត្រព្រះសមណៈ ម្លប់ ព្រះអង្គត្រជាក់ សុខហ្ន៎ ហើយបានឈរត្រាស់ពាក្យដទៃៗ ដែលសមគួរ ដល់ព្រះអង្គជាច្រើន ។ ព្រះបរមសាស្តា ទ្រង់ធ្វើភត្តកិច្ចហើយ ទ្រង់ធ្វើ អនុមោទនា ហើយក្រោកចាកអាសនៈចៀសចេញទៅ ។ ឯរាហុល កុមារក៏ដើរតាមព្រះមានព្រះភាគទៅ ហើយក្រាបទូលថា បពិត្រព្រះ សមណៈ សូមទ្រង់ប្រទានមរតកដល់ខ្ញុំព្រះអង្គចុះ បពិត្រព្រះសមណៈ សូមទ្រង់ប្រទានមរតកដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគ ទ្រង់មិន ឲ្យព្រះរាជកុមារត្រឡប់ បរិវារជនមិនអាចញុំាងព្រះរាជកុមារឲ្យត្រឡប់

វិញបាន ។ ព្រះរាជកុមារនោះ យាងទៅដល់អារាមជាមួយព្រះមាន-ព្រះភាគដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់យាងទៅ ទ្រង់ព្រះតម្រិះថា កុមារនេះ ប្រាថ្នាទ្រព្យដែលជារបស់បិតា ប្រព្រឹត្តទៅតាមវដ្តៈ ដែលមានការចង្អៀតចង្អល់ច្រើន ណ្ហើយចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះត្រង់មណ្ឌលពោធិព្រឹក្សដល់កុមារនេះ តថាគតនឹងធ្វើ ( កុមារនេះ ) ឲ្យជាម្ចាស់មរតកដែលជាលោ-កុត្តរ ហើយទ្រង់ត្រាស់ហៅព្រះសារីបុត្តមកថា ម្នាលសារីបុត្ត ចូរអ្នកឲ្យរាហុលកុមារបួស ។ កាលព្រះរាហុលកុមារបួសហើយ ទុក្ខមានប្រមាណក្រៃលែងមានដល់ព្រះរាជា កាលមិនអាចអត់សង្កត់នូវសេចក្តីទុក្ខនោះបាន ទើបទ្រង់ក្រាបទូលព្រះសាស្តាឲ្យទ្រង់ជ្រាប ហើយត្រាស់សូមពរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមឱកាស លោកម្ចាស់ទាំងឡាយ មិនគប្បីបំបួសកូនដែលឪពុកម្តាយគេមិនបានអនុញ្ញាត ។ ព្រះមានព្រះភាគ ទ្រង់ទទួលព្រះរាជតម្រាស់របស់ព្រះរាជានោះ ។ ស្អែកឡើង សោយព្រះក្រយាហារព្រឹកក្នុងព្រះរាជនិវេសន៍ហើយ កាលព្រះរាជាប្រថាប់គង់ក្នុងចំណែកម្ខាង ទ្រង់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះអង្គបំពេញទុក្ករកិរិយា ទេវតាមួយអង្គចូលមករកខ្ញុំព្រះអង្គ ហើយពោលថា ព្រះឱរសរបស់ព្រះអង្គធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គមិនជឿពាក្យរបស់ទេវតានោះទេ ខ្ញុំព្រះអង្គប្រាប់ទេវតានោះ

ថា កូនរបស់ខ្ញុំ បើមិនសម្រេចសម្ពោធិញ្ញាណ មិនធ្វើកាលកិរិយាជាដាច់ខាត ។ ព្រះបរមសាស្តាត្រាស់ថា ឥឡូវនេះ ព្រះអង្គនឹងជឿបានដូចម្តេច សូម្បីក្នុងកាលមុន កាលមនុស្សយកឆ្អឹងក្ងែងក្ងាយមកបង្ហាញហើយពោលថា កូនរបស់អ្នកស្លាប់ហើយ ក៏មហារាជមិនជឿ ហើយព្រះសាស្តាទ្រង់ត្រាស់ **មហាធម្មបាលជាតក** ព្រោះហេតុកើតរឿងនេះឡើង ក្នុងវេលាចប់ព្រះជាតក ព្រះរាជាតាំងនៅក្នុងអនាគាមិផល ។ ព្រះមានព្រះភាគ ទ្រង់ញ៉ាំងឲ្យព្រះបិតាតាំងនៅក្នុងផលទាំង ៣ ដោយប្រការដូច្នេះហើយ កាលភិក្ខុសង្ឃចោមរោមហើយ ទ្រង់យាងទៅកាន់នគររាជគ្រឹះវិញ ទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ។

សម័យនោះ អនាថបិណ្ឌិកគហបតីយករទេះ ៥០០ ដាក់ទ្រព្យពេញ ទៅកាន់ផ្ទះសេដ្ឋីដែលជាសម្លាញ់ (១) របស់ខ្លួនក្នុងក្រុងរាជគ្រឹះ ។ សេដ្ឋីនោះ បានឮថា ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ទ្រង់កើតឡើងហើយឥឡូវនេះ ទ្រង់គង់នៅក្នុងក្រុងរាជគ្រឹះ ។ ក្នុងវេលាទៀបភ្លឺ បានចូលទៅគាល់ព្រះបរមសាស្តា តាមទ្វារដែលបើកដោយអានុភាពរបស់ទេវតាស្តាប់ធម៌ហើយ បានតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃទី ២ បានថ្វាយមហាទានដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រធាន បានសូមឲ្យព្រះសាស្តា

---

១-ក្នុងវិន័យបិដក សេនាសនក្ខន្ធកៈថា ទៅកាន់ផ្ទះរបស់រាជគហសេដ្ឋីដែលជាបងថ្លៃ ។

ទ្រង់ទទួលប្ដេជ្ញាយាងមកកាន់នគរសាវត្ថី ។ ក្នុងចន្លោះផ្លូវ ៤៥ យោជន៍ បានឲ្យទ្រព្យ ១ សែនសាងវិហារ គឺធ្វើវិហារតគ្នា ១ យោជន៍ ១ កន្លែង ហើយទិញឧទ្យានរបស់ព្រះបាទជេតៈដោយប្រាក់ ១៨ កោដិ ដោយការក្រាលកហាបណៈរាប់កោដិលើផែនដី ធ្វើការកសាងស្រេចហើយ គឺឲ្យសាងព្រះគន្ធកុដិដើម្បីព្រះទសពលនៅត្រង់កណ្ដាល និងឲ្យសាងវិហារ ( ទីសម្រាប់នៅ ) ដែលគួរជាទីត្រេកអរជុំវិញព្រះគន្ធកុដិនោះ ក្នុងភូមិភាគដែលគួរជាទីរីករាយ ដោយការបរិច្ចាគប្រាក់ ១៨ កោដិ គឺឲ្យសាងសេនាសនៈដូចជា កុដិ ១ ខ្នង កុដិ ២ ខ្នង កុដិមានសណ្ឋានដូចជាសត្វហង្ស សាលាវែង និងមណ្ឌបជាដើម មួយអន្លើដោយស្រះបោក្ខរណី ទីចង្ក្រម ទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ និងអាវាសសម្រាប់អាស្រ័យនៅចំពោះមួយអង្គឯង តាមលំដាប់ៗ ដើម្បីព្រះថេរៈដែលជាធំ ៨០ អង្គ ហើយនិងជនទូទៅ ។ កាលសាងវិហាររួចស្រេចហើយ ទើបបញ្ជូនទូតទៅនិមន្តព្រះទសពលឲ្យស្ដេចយាងមក ។ ព្រះទសពល ទ្រង់ស្ដាប់ពាក្យរបស់ទូតហើយ មានភិក្ខុសង្ឃជាច្រើនជាបរិវារ យាងចេញអំពីនគររាជគ្រឹះ ដល់នគរសាវត្ថីដោយលំដាប់ ។ ចំណែកមហាសេដ្ឋីត្រៀមការឆ្លងវិហារ ក្នុងថ្ងៃដែលព្រះសម្មាសម្ពុទ្ធ ទ្រង់យាងចូលមកក្នុងវត្តជេតពន បានតាក់តែងប្រដាប់បុត្តដោយអលង្ការទាំងពួង បញ្ជូនទៅមួយអន្លើដោយកុមារ ៥០០ នាក់ដែលតាក់តែងហើយ បុត្តសេដ្ឋីនោះ

មួយអន្ទើដោយបរិវារកាន់ទង់ ៥០០ ដែលរុងរឿងដោយសំពត់ ៥ ពណ៌ បានទៅក្នុងទីចំពោះព្រះកត្រ្តរបស់ព្រះដ៏មានព្រះភាគ ។ ខាងក្រោយកុមារទាំងនោះ មានធីតារបស់សេដ្ឋីពីរនាក់គឺ នាងមហាសុភទ្ទា និងនាងចុល្លសុភទ្ទា មួយអន្ទើដោយកុមារី ៥០០ នាក់ កាន់ក្អមពេញដោយទឹកចេញទៅ ។ ខាងក្រោយកុមារីទាំងនោះ ភរិយារបស់សេដ្ឋីប្រដាប់ដោយគ្រឿងអលង្ការទាំងពួង មួយអន្ទើដោយមាតុគ្រាម ៥០០ នាក់ កាន់ថាសពេញដោយអាហារ ចេញទៅអំពីខាងក្រោយជនទាំងនោះ ។ ឯមហាសេដ្ឋីស្លៀកសំពត់ថ្មី មួយអន្ទើដោយសេដ្ឋី ៥០០ នាក់ ដែលសុទ្ធតែស្លៀកសំពត់ថ្មីៗ មានមុខឆ្ពោះទៅរកព្រះមានព្រះភាគ ។ ព្រះសាស្តាទ្រង់ធ្វើឧបាសកបរិស័ទនេះទុកខាងមុខ ចោមរោមដោយមហាភិក្ខុសង្ឃ ទ្រង់ធ្វើចន្លោះព្រៃឲ្យមានពណ៌ក្រហម ដូចស្រោចដោយរសនៃទឹកមាស ដោយព្រះរស្មីនៃព្រះសរីរៈរបស់ព្រះអង្គ ទ្រង់យាងចូលទៅក្នុងវត្តជេតពនមហាវិហារដោយពុទ្ធលីលាជាប់តគ្នា និងដោយពុទ្ធសិរីមិនមានប្រមាណ ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋី ក្រាបទូលសួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីបដិបត្តិក្នុងវិហារនេះ ដូចម្តេច ?

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី ចូរអ្នកថ្វាយដល់ភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ ចុះ ។ ចំណែកមហាសេដ្ឋីទទួលព្រះពុទ្ធដីកាថា សាធុ ព្រះអង្គ ហើយកាន់កុណ្ឌីមាសច្រូចទឹកលើព្រះហស្ត

របស់ព្រះដ៏មានព្រះភាគ ហើយថ្វាយដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពនមហាវិហារនេះ ចំពោះភិក្ខុសង្ឃមកអំពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ។ ព្រះបរមសាស្ដា ទ្រង់ទទួលវិហារហើយ កាលទ្រង់ធ្វើអនុមោទនា ទ្រង់បានត្រាស់អានិសង្សនៃការថ្វាយវិហារថា

**សីតំ ឧណ្ហំ បដិហន្តិ ততো វាឡមិគានិ ច**

**សិរឹសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ**

**តតោ វាតាតបោ ឃោរោ សញ្ជាតោ បដិហញ្ញតិ ។**

( វិហារ គឺទីអាវាស ឬសេនាសនៈ ជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពាររងាផង ក្ដៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកម្ដៅថ្ងៃ ដ៏ខ្លាំងក្លា ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។

**លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុញ្ច វិបស្សិតុំ**

**វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ ។**

វិហារទាន គឺការឲ្យលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃសម្រាប់ជ្រកកោនផង សម្រាប់នៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំង

*ឡាយ តែងត្រាស់សរសើរថាជាអគ្គទាន ( ទានដ៏ប្រសើរ ) ។*

**តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ**

**វិហារេ ការយេ រម្មេ វាសយេត្ថ ពហុស្សុតេ ។**

*ព្រោះហេតុនោះឯង បុរស ( ស្ត្រី ) ជាបណ្ឌិត កាលបើបាន ឃើញច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ គប្បីកសាងវិហារ គឺ អាវាសឬសេនាសនៈទាំងឡាយ ដ៏ជាទីគួររីករាយ ហើយ គប្បីនិមន្តលោកដែលជាពហុស្សូត គឺ លោកអ្នកចេះដឹងច្រើន ទាំងឡាយ ឲ្យនៅក្នុងទីនោះ ។*

**តេសំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច**

**ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។**

*គប្បីមានចិត្តជ្រះថ្លាចំពោះលោកទាំងឡាយ ដែលមានកាយ និងចិត្តត្រង់ ហើយឲ្យម្ហូបចំណីផង ទឹកផង សំពត់និងសេនា-សនៈទាំងឡាយផង ដល់លោកទាំងនោះចុះ ។*

**តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខា បនូទនំ**

**យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតិ អនាសវោតិ ។**

*លោកទាំងនោះ រមែងសម្តែងធម៌ជាគ្រឿងបន្ទោបង់សេចក្តី ទុក្ខ គ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ*

រមែងបរិនិព្វាន [១] ។

ចាប់តាំងអំពីថ្ងៃទី ២ ទៅ អនាថបិណ្ឌិកសេដ្ឋីក៏ផ្ដើមការធ្វើវិហារ ។ ការធ្វើវិហាររបស់នាងវិសាខា ៤ ខែ ទើបស្រេច ចំណែកការធ្វើវិហាររបស់អនាថបិណ្ឌិកសេដ្ឋីដល់ទៅ ៩ ខែ ទើបស្រេច អស់ទ្រព្យប្រមាណ ១៨ កោដិ អនាថបិណ្ឌិកសេដ្ឋីបរិច្ចាគទ្រព្យប្រមាណ ៥៤ កោដិ ចំពោះវិហារមួយប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ក្នុងអតីតកាល ក្នុងសម័យព្រះមានព្រះភាគព្រះនាមថា វិបស្សី សេដ្ឋីឈ្មោះថា បុនព្វសុមិត្តៈ ទិញដីត្រង់នោះ ដោយការក្រាលឥដ្ឋមាស ហើយឲ្យសាងសង្ឃារាមប្រមាណមួយយោជន៍ក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះមានព្រះភាគព្រះនាមថា សិខី សេដ្ឋីឈ្មោះថា សិរិវឌ្ឍៈ ទិញដីត្រង់នោះ ដោយការក្រាលផាលមាស ហើយឲ្យសាងសង្ឃារាមប្រមាណ ៣ គាវុតក្នុងទីនោះឯង ។ ក្នុងសម័យព្រះមានព្រះភាគ ព្រះនាមថា វេស្សភូ សេដ្ឋីឈ្មោះថា សោត្ថិយៈ [២] ទិញដីត្រង់នោះ ដោយការក្រាលជើងដំរីមាស ហើយឲ្យសាងសង្ឃារាមប្រមាណកន្លះយោជន៍ក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ សេដ្ឋីឈ្មោះថា អច្ចុតៈ ទិញដីត្រង់នោះ ដោយការក្រាលឥដ្ឋមាសដូច

---

១- បិ. ១០ , ទំ. ៣២១ ។ ២- ក្នុងទីខ្លះ ជាសោត្ថិជៈ ។

គ្នា ហើយឲ្យសាងសង្ឃារាមប្រមាណ ១ គាវុតក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះមានព្រះភាគព្រះនាមថា កោនាគមនៈ សេដ្ឋីឈ្មោះថា ឧគ្គៈ ទិញដីត្រង់នោះ ដោយការក្រាលអណ្ដើកមាស ហើយឲ្យសាងសង្ឃារាមប្រមាណកន្លះគាវុតក្នុងទីនោះឯង ។ ក្នុងសម័យនៃព្រះមានព្រះភាគព្រះនាមថា កស្សបៈ សេដ្ឋីឈ្មោះថា សុមង្គលៈ ទិញដីត្រង់នោះ ដោយការក្រាលអណ្ដើកមាស ហើយឲ្យសាងសង្ឃារាមប្រមាណ ១៦ ករីសក្នុងទីនោះឯង ។ តែក្នុងសម័យនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ សេដ្ឋីឈ្មោះថា អនាថបិណ្ឌិក ទិញដីត្រង់នោះ ដោយការក្រាលកហាបណៈរាប់កោដិ ហើយឲ្យសាងសង្ឃារាមប្រមាណ ៨ ករីសក្នុងទីនោះ ។ បានឮថា ទីនោះ ជាស្ថានទីដែលព្រះពុទ្ធទាំងពួង ទ្រង់មិនបានលះបង់ឡើយ ។

តាំងអំពីទ្រង់សម្រេចសព្វញ្ញុតញ្ញាណត្រង់ពោធិមណ្ឌល រហូតដល់គ្រែដែលជាទីបរិនិព្វាន ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងទីណាទីនោះៗ ឈ្មោះថា **សន្តិកេនិទាន** ដោយប្រការដូច្នេះ ។ ខ្ញុំនឹងពណ៌នាជាតកទាំងពួង ដោយអំណាចសន្តិកេនិទាននោះឯង ។

ចប់ និទានកថា ដោយប្រការដូច្នេះ ។

# អដ្ឋកថា អបណ្ណកជាតក ទី ១

ព្រះដ៏មានព្រះភាគ កាលទ្រង់អាស្រ័យក្នុងនគរសាវត្ថី ទ្រង់គង់នៅក្នុងវត្តជេតពន ត្រាស់អបណ្ណកធម្មទេសនានេះ មុនគេបង្អស់ [១] ។

សួរថា រឿងនេះកើតឡើងព្រោះប្រារព្ធអ្នកណា ?

ឆ្លើយថា ព្រោះប្រារព្ធសាវករបស់តិរ្ថិយ ជាសម្លាញ់របស់អនាថ-បិណ្ឌិកសេដ្ឋី ។

សេចក្តីពិស្តារថា ថ្ងៃមួយ អនាថបិណ្ឌិកសេដ្ឋី បបួលពួកសាវករបស់តិរ្ថិយប្រមាណ ៥០០ នាក់ ដែលជាសម្លាញ់របស់ខ្លួន ឲ្យកាន់យកផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបជាច្រើន មួយអន្លើដោយប្រេង ទឹកឃ្មុំ ទឹកអំពៅ និងសំពត់ទៅជាមួយផង អនាថបិណ្ឌិកសេដ្ឋីនាំជនទាំងនោះ ទៅកាន់វត្តជេតពនថ្វាយបង្គំព្រះមានព្រះភាគ បូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម លះភេសជ្ជៈប្រគេនដល់ភិក្ខុសង្ឃហើយអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ដោយវៀរទោសនៃការអង្គុយ ៦ ប្រការ

---

១-ពាក្យថាមុនគេបង្អស់ក្នុងទីនេះ គឺ មុនគេក្នុងវត្តជេតពនផង និងសម្រាប់ឯកនិបាតជាតកផង ។ តែកាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ក្នុងសមាគមព្រះបាទពិម្ពិសារប្រារព្ធជដិលទាំងបី គឺទ្រង់សម្តែងនារទជាតកមុនជាតកនេះទៅទៀត តែព្រោះជាតកនោះ មុនសម្រាប់វត្តវេឡុវ័នផង និងជាមហានិបាតផង ទើបមិនរាប់ដំបូងបង្អស់ ។

សាវករបស់តិរ្ថិយទាំងនោះ ថ្វាយបង្គំព្រះតថាគតហើយ សម្លឹងមើលព្រះភក្ត្រដ៏ស្រស់ផូរផង់របស់ព្រះតថាគត ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត សម្លឹងមើលព្រះវរកាយដូចកាយព្រហ្ម ដែលប្រដាប់ដោយព្រះលក្ខណៈ និងអនុព្យញ្ជនៈ ចោមរោមដោយព្រះរស្មីប្រមាណមួយព្យាម និងសម្លឹងមើលពុទ្ធរង្សីដែលឆ្វៀលឆ្វាត់ជារង្វង់ៗ ជាគូៗ ទើបអង្គុយជិតអនាថបិណ្ឌិកសេដ្ឋី ។ លំដាប់នោះ ព្រះបរមសាស្តាត្រាស់ធម្មកថាដ៏ពីរោះវិចិត្រដោយន័យផ្សេងៗ ដោយព្រះសូរសៀងដូចសំឡេងព្រហ្ម គួរស្តាប់ប្រកបដោយអង្គ ៨ ប្រការ ដល់សាវករបស់តិរ្ថិយទាំងនោះ ហាក់បីដូចរាជសីហ៍ដំទង់ បន្លឺសីហនាទលើផ្ទាំងមនោសិលា និងដូចផ្គរគ្រហឹម ឬដូចសំឡេងអាកាសគង្គា [១] ដែលហូរធ្លាក់មក និងដូចកម្រងកែវដូច្នោះ សាវករបស់តិរ្ថិយទាំងនោះ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ មានចិត្តជ្រះថ្លា ក្រោកឡើងថ្វាយបង្គំព្រះមានព្រះភាគ ទម្លាយសរណៈរបស់តិរ្ថិយហើយ បានដល់ព្រះពុទ្ធជាសរណៈ ។ ចាប់តាំងអំពីពេល

---

១- ខ្សែទឹក ១ ខ្សែ ដែលហូរមកអំពីអនោតត្តស្រះ ឆ្ពោះទៅទិសខាងត្បូងប៉ះនឹងភ្នំ ១ ក៏ទម្លុះភ្នំនោះ ផ្ចារទឹកទំហំប្រមាណ ៣០ គាវុត ក៏បាញ់ទៅលើអាកាសអស់ចម្ងាយ ៦០ យោជន៍ ទើបធ្លាក់មកកាន់ផែនដី ពួកយក្សនិងពួកទេវតា យកទឹកនេះជាកីឡាហោះធ្វេងទៅមក លេងយ៉ាងសប្បាយ ព្រោះហេតុនោះ ទើបផ្ចារទឹកនេះ ឈ្មោះថាអាកាសគង្គា ( អដ្ឋកថា បោតលិសូត្រ ) ។

នោះមក ពួកតិរ្ថិយទាំងនោះ មានដៃកាន់ផ្កាកម្រង និងគ្រឿងក្រអូបជាដើមទៅកាន់ព្រះវិហារ ស្តាប់ធម៌ ធ្វើទាន រក្សាសីល ធ្វើឧបោសថកម្មព្រមជាមួយអនាថបិណ្ឌិកសេដ្ឋីជានិច្ចកាល ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់យាងចេញអំពីនគរសាវត្ថីទៅកាន់នគររាជគ្រឹះ ក្នុងវេលាដែលព្រះបរមសាស្តាទ្រង់យាងទៅហើយសាវកតិរ្ថិយទាំងនោះ ក៏បានទម្លាយសរណៈនោះចោល ត្រឡប់កាន់យកអញ្ញតិត្ថិយជាសរណៈវិញ តាំងនៅក្នុងឋានៈដើមរបស់ខ្លួននោះឯង ។ ចំណែកព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់នៅអស់កាល ៧-៨ ខែហើយទ្រង់ក៏ត្រឡប់មកកាន់វត្តជេតពនវិញ អនាថបិណ្ឌិកសេដ្ឋីក៏នាំពួកតិរ្ថិយទាំងនោះ ទៅគាល់ព្រះសម្មាសម្ពុទ្ធទៀត បូជាព្រះបរមសាស្តាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ពួកសាវកតិរ្ថិយទាំងនោះក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនាចំណែកម្ខាងដែរ ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលព្រះបរមសាស្តា នូវភាពដែលពួកសាវកតិរ្ថិយទាំងនោះ កាលព្រះសាស្តាចៀសចេញទៅហើយ បានទម្លាយសរណៈដែលខ្លួនទទួល ហើយកាន់យកតិរ្ថិយជាសរណៈ តាំងនៅក្នុងឋានៈដើមរបស់ខ្លួននោះឯង ។ ព្រះសម្មាសម្ពុទ្ធទ្រង់បើកមណ្ឌលព្រះឱស្ឋ ដូចបើកប្រអប់កែវដែលពេញដោយគ្រឿងក្រអូបផ្សេងៗដ៏ជាទិព្វ ដោយអានុភាពរបស់វចីសុចរិត ដែលទ្រង់ឲ្យប្រព្រឹត្ត

ទៅមិនដាច់ អស់កោដិនៃកប្បរាប់មិនអស់ កាលទ្រង់បន្ទឺព្រះសូរសៀង ដ៏ពីរោះ ទ្រង់ត្រាស់សួរថា បានឮថា ពួកអ្នកជាឧបាសក ទម្លាយសរណៈ ៣ ចេញហើយដល់នូវតិរ្ថិយជាសរណៈ ពិតមែនឬ? លំដាប់នោះ កាល ពួកសាវកតិរ្ថិយទាំងនោះមិនអាចបិទបាំងបាន ក៏នាំគ្នាក្រាបទូលថា ពិត ហើយព្រះអង្គ ទើបព្រះបរមសាស្តាត្រាស់ថា ម្នាលឧបាសកទាំងឡាយ ក្នុងលោកធាតុខាងក្រោមទល់គ្នានឹងអវិចីមហានរក ខាងលើទល់គ្នានឹង ភវគ្គព្រហ្ម និងទទឹងប្រមាណមិនបាន ឈ្មោះថា បុគ្គលដូចគ្នានឹងតថាគត ដោយគុណទាំងឡាយ មានសីលជាដើម រមែងមិនមាន បុគ្គលដែលក្រៃ-លែងជាងតថាគត នឹងមានអំពីណា ហើយទ្រង់ប្រកាសគុណរបស់ព្រះ រតនត្រ័យ ដែលទ្រង់ប្រកាសទុកដោយព្រះសូត្រទាំងឡាយយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមាន ជើងក្តី មានជើងពីរក្តី មានជើងបួនក្តី មានជើងច្រើនក្តី មានរូបក្តី មិន មានរូបក្តី មានសញ្ញាក្តី មិនមានសញ្ញាក្តី មានសញ្ញាក៏មិនមែន មិនមាន សញ្ញាក៏មិនមែន គឺមានសញ្ញាយ៉ាងល្អិតក្តី ព្រះតថាគតជាអរហន្តសម្មា-សម្ពុទ្ធ ប្រាកដជាប្រសើរ ជាងពួកសត្វទាំងនោះ [១] ។ និងសូត្រមួយ ទៀតថា

---

១- បិ.៥៣ , ទំ. ១១៦ ។

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា
សគ្គេសុ វា យំ រតនំ បណីតំ
ន នោ សមំ អត្ថិ តថាគតេន
ឥទម្បិ ពុទ្ធេ រតនំ បណីតំ ។

*ទ្រព្យណាមួយ ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី រតនវត្ថុដ៏ឧត្តមណា ក្នុងឋានសួគ៌ក្តី ទ្រព្យនិងរតនវត្ថុទាំងនោះឯងស្មើដោយព្រះតថាគត មិនមានឡើយ រតនៈគឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម[១] ។ និងសូត្រមួយទៀតថា*

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។

*បុណ្យគឺ អាយុដ៏ប្រសើរផង សម្បុរកាយដ៏ប្រសើរផង យសសក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សុខដ៏ប្រសើរផង កម្លាំង*

---

*១- បិ.៥២ , ទំ.៧ ។*

ដ៏ប្រសើរផង រមែងចម្រើនដល់ពួកបុគ្គល អ្នកជ្រះថ្លានឹងវត្ថុដ៏ប្រសើរ ដឹងច្បាស់នូវធម៌ដ៏ប្រសើរ ជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរ ជាទក្ខិណេយ្យបុគ្គល រកបុគ្គលដទៃក្រៃលែងជាងគ្មាន ជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាករាគៈ ជាធម៌ស្ងប់រម្ងាប់ នាំមកនូវសេចក្ដីសុខ ជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាបុញ្ញក្ខេត្ត រកខេត្តដទៃក្រៃលែងជាងគ្មាន ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ ។

**អគ្គស្ស ទាតា មេធាវី  អគ្គធម្មសមាហិតោ**
**ទេវភូតោ មនុស្សោ វា  អគ្គប្បត្តោ បមោទតីតិ ។**

បុគ្គលអ្នកមានប្រាជ្ញា មានចិត្តតម្កល់ក្នុងធម៌ដ៏ប្រសើរ ជាអ្នកឲ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ តែងបានទៅកើតជាទេវតា ឬមនុស្សដល់នូវសេចក្ដីប្រសើរ រមែងរីករាយ [១] ។

ហើយទើបត្រាស់ថា បុគ្គលជាឧបាសកក្ដី ជាឧបាសិកាក្ដី ដែលដល់ព្រះរតនត្រ័យប្រកបដោយឧត្តមគុណយ៉ាងនេះ ឈ្មោះថា ជាអ្នកកើតក្នុងនរកជាដើមមិនមាន ម្យ៉ាងទៀត ផុតចាកការកើតក្នុងអបាយហើយ កើតក្នុងទេវលោកបានសោយនូវសម្បត្តិទិព្វ ព្រោះហេតុអ្វីទើប

១-បិ.៤៤ , ទំ. ៧១ ។

*ពួកអ្នកនាំគ្នាទម្លាយនូវសរណៈបែបនេះ ហើយកាន់យកតិរ្ថិយជាសរណៈ ធ្វើកម្មដែលមិនគួរដូច្នេះ ?*

*ក្នុងពេលនេះ ដើម្បីសម្តែងដល់ភាពដែលបុគ្គលដល់ព្រមដោយ ព្រះរតនត្រ័យជាសរណៈ ដោយអំណាចនៃការរួចផុត និងដោយអំណាច ជារតនៈដ៏ឧត្តម និងមិនមានការកើតក្នុងអបាយទាំងឡាយ បណ្ឌិតគប្បី សម្តែងសូត្រទាំងនេះថា*

យេ កេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

*ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹង ទីរលឹកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់ រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃ ទេវតាមិនខាន* [១] ។

យេ កេចិ ធម្មំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ

---

*១- បិ. ១៧ , ទំ. ១៧១ ។*

បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

*ពួកជនណាមួយ បានដល់នូវព្រះធម៌ជាទីពឹង ទីរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន ។*

យេ កេចិ សង្ឃំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តីតិ ។

*ពួកជនណាមួយ បានដល់នូវព្រះសង្ឃជាទីពឹង ទីរឭកហើយ ពួកជននោះឯង នឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅហើយ នឹងទៅបំពេញពពួកនៃទេវតាមិនខាន (១) ។*

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច

---

*១- គាថាទាំងពីរនេះ គឺ គាថាពោលសរសើរគុណព្រះធម៌ និងព្រះសង្ឃ ជាពាក្យរបស់ព្រះអដ្ឋកថាជាតក ឯកនិបាត ភាគ ១ នេះ មិនទាន់ជួបក្នុងព្រះត្រៃបិដកទេ ។*

អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា
នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ
នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

*មនុស្សទាំងឡាយ ច្រើននាក់ ត្រូវភ័យគំរាមហើយ តែងយកភ្នំ អារាមនិងរុក្ខចេតិយ ជាទីពឹង ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងបែបនេះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលអាស្រ័យនូវទីពឹងនេះហើយ រមែងមិនរួចស្រឡះចាកទុក្ខទាំងពួងឡើយ ។*

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ
ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

*លុះតែបុគ្គលណា យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹង ឃើញច្បាស់នូវអរិយសច្ចទាំង ៤ គឺទុក្ខសច្ច ១ ទុក្ខសមុទយ-សច្ច ១ និរោធសច្ច កន្លងទុក្ខ ១ អរិយមគ្គប្រកបដោយអង្គ ៨ ជាដំណើរទៅកាន់ព្រះនិព្វានដែលជាទីរម្ងាប់ទុក្ខ ១ ដោយ*

ប្រាជ្ញាដ៏ប្រពៃ នេះឯង ជាទីពឹងដ៏ក្សេម នេះឯង ជាទីពឹង ដ៏ឧត្តម បុគ្គលអាស្រ័យទីពឹងនេះ រមែងរួចស្រឡះចាកទុក្ខ ទាំងពួងបាន (១) ។

ព្រះបរមសាស្តា កាលទ្រង់សម្តែងធម៌មានប្រមាណប៉ុណ្ណោះ ដល់ពួកសាវកតិរ្ថិយទាំងនោះ ក៏មិនទាន់សមល្មមនៅឡើយ ម្យ៉ាងទៀត ទ្រង់បានសម្តែងធម៌ដោយន័យជាដើមយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយ ឈ្មោះថា ពុទ្ធានុស្សតិកម្មដ្ឋាន ធម្មានុស្សតិកម្មដ្ឋាន សង្ឃានុស្សតិកម្មដ្ឋាន រមែងឲ្យសោតាបត្តិមគ្គ រមែងឲ្យសោតាបត្តិផល រមែងឲ្យសកទាគាមិមគ្គ រមែងឲ្យសកទាគាមិផល រមែងឲ្យអនាគាមិមគ្គ រមែងឲ្យអនាគាមិផល រមែងឲ្យអរហត្តមគ្គ រមែងឲ្យអរហត្តផល ។

កាលទ្រង់សម្តែងធម៌ហើយទើបត្រាស់ថា ពួកអ្នកទម្លាយសរណៈដែលមានសភាពបែបនេះ ធ្វើកម្មមិនសមគួរឡើយ ។ ម្យ៉ាងទៀត ពុទ្ធានុស្សតិកម្មដ្ឋានជាដើម ដែលជាផ្លូវឲ្យដល់នូវសោតាបត្តិមគ្គ ជាដើមនេះ គប្បីសម្តែងដោយព្រះសូត្រទាំងឡាយមានយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ ធម៌មួយដែលបុគ្គលចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ តែងប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដើម្បីប្រាសចាក

---

១-បិ.៥២ , ទំ.៦១ ។

តម្រេក ដើម្បីរលត់ ដើម្បីរម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹងដើម្បីនិព្វាន ដោយពិត ។ ធម៌មួយគឺអ្វី ។ គឺពុទ្ធានុស្សតិ [១] ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានឧបាសកទាំងឡាយដោយប្រការផ្សេងៗហើយ ទើបទ្រង់ត្រាស់ថា ម្នាលឧបាសកទាំងឡាយ ក្នុងកាលមុន មនុស្សទាំងឡាយកាន់យកវត្ថុដែលមិនមែនជាសរណៈ ថាជាសរណៈ ដោយការកាន់យក ដោយការគិតស្មាន ដោយការកាន់យកខុស បានធ្លាក់ទៅជាចំណីរបស់យក្ស ក្នុងផ្លូវកន្តារដែលអមនុស្សហួងហែងហើយ ដល់នូវការវិនាសយ៉ាងធំ ចំណែកមនុស្សពួកណា កាន់យកនូវផ្លូវដ៏ប្រពៃ គឺកាន់យកនូវភាពពិតប្រាកដ មិនកាន់យកខុស បានដល់នូវសួស្តីក្នុងផ្លូវកន្តារនោះឯង កាលត្រាស់ហើយ ទ្រង់ក៏នៅស្ងៀម ។ លំដាប់នោះ អនាថបិណ្ឌិកគហបតីក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ សរសើរហើយ ផ្គងអញ្ជលីលើសិរសា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលដែលពួកឧបាសកទាំងនេះ ទម្លាយសរណៈដ៏ឧត្តមហើយ កាន់យកសរណៈដោយការគិតស្មាន គឺកាន់យកខុស ប្រាកដដល់ខ្ញុំព្រះអង្គ ចំណែកក្នុងកាលមុន ពួកមនុស្សកាន់យកដោយការគិតខុស ដល់នូវសេចក្តីវិនាស និងពួកមនុស្ស

---

១- បិ.៤០ , ទំ.៦៨ ។

ដែលកាន់យកត្រូវដោយធម៌ មានសួស្តីក្នុងផ្លូវកន្តារដែលអមនុស្សហួងហែង នៅកំបាំងសម្រាប់ខ្ញុំព្រះអង្គនៅឡើយ មិនប្រាកដដល់ខ្ញុំព្រះអង្គសោះ ខ្ញុំព្រះអង្គសូមឱកាស សូមព្រះមានព្រះភាគទ្រង់ធ្វើហេតុនេះឲ្យប្រាកដ ដូចញ៉ាំងព្រះចន្ទពេញវង់ ឲ្យអណ្តែតឡើងក្នុងអាកាសដូច្នោះ ។

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី តថាគតបំពេញបារមី ១០ អស់កាលប្រមាណមិនបាន ឥឡូវបានសម្រេចសព្វញ្ញុតញ្ញាណ ក៏ដើម្បីនឹងកាត់សង្ស័យរបស់សត្វលោកនោះឯង ចូរអ្នកផ្ទៀងសោតៈស្តាប់ដោយគោរព ដូចបុគ្គលយកថាសមាសដាក់ពេញដោយខ្លាញ់របស់រាជសីហ៍ដូច្នោះ (១) ហើយទ្រង់ញ៉ាំងស្មារតីឲ្យកើតឡើងដល់សេដ្ឋី នាំហេតុការណ៍ដែលអន្តរភពបិទបាំងទុកឲ្យប្រាកដ ដូចទម្លាយដុំពពកនាំព្រះចន្ទពេញវង់ចេញមកដូច្នេះថា

ក្នុងអតីតកាល មានព្រះរាជាព្រះនាមថា ព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសិករដ្ឋ ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញរទេះ អាស្រ័យគភ៌របស់មាតា ១០ខែ ហើយទើបប្រសូតមក ដល់នូវការចម្រើនវ័យដោយលំដាប់ បានត្រាច់

---

១- បានឮថា មានតែភាជន៍មាសប៉ុណ្ណោះ ទើបដាក់ខ្លាញ់រាជសីហ៍បាន ភាជនៈដទៃក្រៅពីមាសមិនអាចដាក់ជាប់ឡើយ នឹងជ្រាបអស់ឥតសេសសល់ ។

ធ្វើការស្វែងរកការជួញដូរដោយរទេះ ៥០០ ។ ព្រះពោធិសត្វនោះ ជួនកាលចេញអំពីស្រុកកំណើតរបស់ខ្លួនទៅកាន់ជាយដែន ជួនកាលចេញអំពីជាយដែនមកកាន់ស្រុកកំណើតរបស់ខ្លួន ។ ក្នុងនគរពារាណសីនោះ មានកូនឈ្មួញរទេះម្នាក់ទៀត ឈ្មួញរទេះនោះ ជាបុគ្គលល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា មិនជាអ្នកឈ្លាសក្នុងឧបាយ ។ ក្នុងកាលនោះ ព្រះពោធិសត្វផ្ទុកទំនិញមានតម្លៃច្រើនអំពីនគរពារាណសី ពេញក្នុងរទេះ ៥០០ ត្រៀមដំណើរនឹងចេញទៅជួញ ចំណែកឈ្មួញរទេះល្ងង់ខ្លៅនោះ ក៏ផ្ទុកទំនិញពេញរទេះ ៥០០ យ៉ាងនោះដូចគ្នា ហើយត្រៀមនឹងចេញដំណើរដូចព្រះពោធិសត្វដែរ ។ ព្រះពោធិសត្វគិតថា បើឈ្មួញរទេះល្ងង់ខ្លៅនេះទៅព្រមជាមួយអញសោត កាលរទេះ ១ ពាន់ទៅព្រមគ្នា ផ្លូវក៏មិនគ្រប់គ្រាន់ ឧសនិងទឹកជាដើមរបស់ពួកមនុស្សក្តី ស្មៅរបស់ពួកគោក្តី ក៏រកបានដោយលំបាក ឈ្មួញរទេះល្ងង់ខ្លៅនេះ ឬក៏អាត្មាអញគួរទៅមុនហ្ន៎ ។ ព្រះពោធិសត្វក៏ហៅឈ្មួញរទេះនោះមក ហើយប្រាប់សេចក្តីនោះថា យើងទាំងពីរមិនអាចរួមដំណើរគ្នាទៅតែម្តងបាន បណ្តាអ្នកនិងខ្ញុំ អ្នកណាទៅមុន អ្នកណាទៅក្រោយ ។ ឈ្មួញរទេះល្ងង់ខ្លៅនោះគិតថា បើអញទៅមុន នឹងមានអានិសង្សច្រើន អញនឹងទៅដោយផ្លូវដែលមិនទាន់បែក ពួកគោនឹងទំពាស៊ីស្មៅដែលមិនទាន់មានអ្នកជាន់ទេប៉ះពាល់ ពួកមនុស្សនឹងមានបន្លែធ្វើជាសម្ល មិនចាំបាច់កង្វល់ចិត្ត ហើយនឹងបាន

ប្រើប្រាស់ទឹកថា អញនឹងទៅតាមគាប់ចិត្ត ហើយនឹងលក់នូវទំនិញទាំងឡាយបាន ឈ្មួញរទេះនោះ ក៏ពោលនឹងព្រះពោធិសត្វថា **អហំ សម្ម បុរតោ គមិស្សាមិ** នែសម្លាញ់ ខ្ញុំនឹងទៅមុន ។ ព្រះពោធិសត្វបានឃើញការទៅតាមក្រោយថា មានអានិសង្សច្រើន ព្រោះព្រះពោធិសត្វគិតថា ជនទាំងនេះកាលទៅមុននឹងធ្វើផ្លូវដែលពុំរាបស្មើឲ្យរាបស្មើ អញនឹងដើរតាមផ្លូវដែលជនទាំងនេះទៅហើយ កាលគោបម្រើដែលចេញដំណើរទៅមុន ស៊ីស្មៅដែលចាស់ៗ រឹងៗ គោទាំងឡាយរបស់អញដែលទៅតាមក្រោយ នឹងបានស្មៅខ្ចីដែលទើបតែលាស់ មនុស្សទៅមុនក៏បាននូវបន្លែដែលចាស់ៗ ឯអញទៅតាមក្រោយ នឹងបានបន្លែខ្ចីដែលមានរសជាតឆ្ងាញ់ ក្នុងទីដែលមិនមានទឹក មនុស្សទាំងនេះ នឹងជីកអណ្តូងឲ្យកើតឡើង អញនឹងផឹកទឹកក្នុងអណ្តូងដែលជនទាំងនេះជីកទុក ឈ្មោះថាការកំណត់តម្លៃមុនគេ ដូចជាការផ្តាច់ជីវិតមនុស្ស កាលបើដូច្នោះ អញនឹងទៅតាមក្រោយ លក់តាមតម្លៃដែលឈ្មួញនេះតាំងទុកនោះឯង ព្រះបរមពោធិសត្វឃើញអានិសង្សមានប្រមាណប៉ុណ្ណោះ ក៏ពោលថា

**សម្ម ត្វំ បុរតោ គច្ឆាហិ** នែសម្លាញ់ ចូរអ្នកទៅមុនចុះ ។

ឈ្មួញរទេះល្ងង់ខ្លៅនោះទទួលពាក្យថា អើ សម្លាញ់ ហើយក៏ទឹមគោទាំងឡាយ ធ្វើដំណើរចេញអំពីមាតុភូមិរបស់ខ្លួន ទៅតាមផ្លូវកន្តារដោយលំដាប់ ។

ឈ្មោះថាកន្តារមាន ៥ យ៉ាងគឺ កន្តារព្រោះចោរ ១ កន្តារព្រោះសត្វសាហាវ ១ កន្តារព្រោះមិនមានទឹក ១ កន្តារព្រោះអមនុស្ស ១ កន្តារព្រោះមិនមានអាហារ ១ ។ ក្នុងបណ្ដាកន្តារ ៥ យ៉ាងនោះ កន្តារដែលមានពួកចោរចាំស្កាត់តាមផ្លូវ ឈ្មោះថា កន្តារព្រោះចោរ ផ្លូវដែលមានសត្វសីហៈជាដើមហួងហែង ឈ្មោះថា កន្តារព្រោះសត្វសាហាវអាស្រ័យនៅ ផ្លូវណាដែលមិនមានទឹកងូតឬទឹកផឹកនោះ ឈ្មោះថា កន្តារព្រោះមិនមានទឹក ផ្លូវដែលមានអមនុស្សអាស្រ័យនៅ ឈ្មោះថា កន្តារព្រោះមានអមនុស្សអាស្រ័យនៅ ស្ថានទីដែលមិនមានអាហារ សូម្បីតែមើមដំឡូងជាដើម ឈ្មោះថា កន្តារព្រោះមិនមានអាហារ ។ ក្នុងកន្តារ ៥ យ៉ាងនេះ ក្នុងទីនេះ ជាកន្តារដែលមិនមានទឹក និងជាកន្តារដែលមានអមនុស្សហួងហែងរក្សា ព្រោះដូច្នោះ ឈ្មួញរទេះលួងខ្លៅនោះក៏តម្កល់ពាងធំៗ ដាក់លើរទេះទាំងឡាយ ផ្ទុកពេញដោយទឹក ហើយធ្វើដំណើរទៅ ឆ្លងកាត់ផ្លូវកន្តារដែលមានចម្ងាយ ៦០ យោជន៍ ។ កាលឈ្មួញរទេះលួងខ្លៅនោះទៅដល់ពាក់កណ្ដាលផ្លូវ យក្សដែលអាស្រ័យនៅត្រង់ផ្លូវកន្តារនោះ គិតថា អញនឹងឲ្យពួកមនុស្សទាំងនេះ ចាក់ទឹកដែលផ្ទុកមកចោល ធ្វើឲ្យអស់កម្លាំងហើយនឹងស៊ីទាំងអស់ ទើបនិម្មិតយានតូចគួរជាទីត្រេកអរ ទឹមដោយគោពណ៌ស ចោមរោមដោយអមនុស្ស ១២ នាក់ មានសក់និងសម្លៀកបំពាក់ជោកដោយទឹកនិងភក់ កាន់អាវុធព្រមទាំង

ខែលជាដើម ប្រដាប់ផ្កាឧប្បលនិងផ្កាកុមុទ មានសក់សើម សំពត់សើម អង្គុយលើយានតូចនោះ ហាក់បីដូចជាអ្នកធំអង្គុយលើយាន ដែលកង់យានប្រឡាក់សុទ្ធតែភក់ធ្វើដំណើរមក ចំណែកពួកអមនុស្សដែលជាបរិវាររបស់យក្សនោះ ធ្វើដំណើរខាងមុខនិងខាងក្រោយ មានសក់សើម មានសំពត់សើម ប្រដាប់ផ្កាឧប្បល និងផ្កាកុមុទ កាន់បាច់ផ្កាឈូក និងផ្កាបុណ្ឌរីក ទំពាស៊ីក្រឡឹឈូក មានដំណក់ទឹកនិងភក់ស្រក់ចុះ បាននាំគ្នាធ្វើដំណើរទៅ ។ ធម្មតាប្រធានឈ្មួញរទេះទាំងឡាយ ក្នុងកាលណាខ្យល់បក់មកអំពីខាងមុខ ក្នុងកាលនោះក៏អង្គុយក្នុងយានតូច ចោមរោមដោយឧបដ្ឋាកដើម្បីគេចធូលី ហើយក៏បររទេះទៅខាងមុខ ក្នុងកាលណាខ្យល់បក់ពីក្រោយ ក្នុងកាលនោះក៏គេចអំពីខាងមុខ មកបរក្រោយគេបង្អស់ ដូច្នេះ ឯក្នុងកាលនោះ ខ្យល់ក៏បក់មកអំពីមុខ ព្រោះដូច្នោះ ឈ្មួញរទេះល្ងង់ខ្លៅនោះ ក៏បររទេះទៅខាងមុខ ។ យក្សឃើញឈ្មួញរទេះល្ងង់ខ្លៅនោះកំពុងមក ក៏ឲ្យយានតូចរបស់ខ្លួនចៀសចេញទៅម្ខាងផ្លូវ ហើយសួរឈ្មួញរទេះនោះថា តើលោកទាំងឡាយទៅណា? ឈ្មួញរទេះនោះក៏ចុះចាកយានតូចរបស់ខ្លួន ឲ្យឱកាសដល់រទេះទាំងឡាយទៅ ហើយឈរក្នុងចំណែកម្ខាងពោលនឹងយក្សថា លោកដ៏ចម្រើន ពួកខ្ញុំមកពីនគរពារាណសី ឯលោកទាំងឡាយប្រដាប់ដោយផ្កាឧប្បល និងផ្កាកុមុទ កាន់ផ្កាឈូកក្រហមនិងផ្កាឈូកសជាដើម ទំពាស៊ីនូវក្រឡឹឈូក

ប្រឡាក់ដោយភក់ មានដំណក់ទឹកហូរចុះ តាមផ្លូវដែលលោកទាំងឡាយមក ភ្លៀងធ្លាក់ខ្លាំងឬ មានស្រះទឹកប្រកបដោយផ្កាឧប្បលជាដើមឬ ?

យក្សបានស្តាប់ពាក្យរបស់ឈ្មួញរទេះនោះហើយ ក៏ពោលថា នែសម្លាញ់ អ្នកនិយាយអ្វី ទីនោះមានដងព្រៃពណ៌ខៀវស្រងាត់ ចាប់ពីទីនោះទៅ ព្រៃទាំងមូលពោរពេញទៅដោយទឹក ភ្លៀងធ្លាក់ជាប្រចាំ តាមថ្លុក តាមត្រពាំងជាដើម ពោរពេញដោយទឹក ក្នុងទីនោះៗ មានស្រះដេរដាសដោយផ្កាឈូក ។ កាលរទេះទាំងឡាយធ្វងទៅដោយលំដាប់ ទើបពួកយក្សទាំងឡាយសួរថា តើពួកលោកទៅណា ?

ឈ្មួញរទេះល្ងង់ខ្លៅឆ្លើយថា ខ្ញុំទៅកាន់ជនបទ ឈ្មោះឯណោះ ។

យក្សសួរថា ក្នុងរទេះនេះ ដឹកអ្វី ?

ឈ្មួញរទេះល្ងង់ខ្លៅឆ្លើយថា រទេះនេះ ដឹករបស់ឈ្មោះនេះ រទេះនេះ ដឹករបស់ឈ្មោះនេះ ។

យក្សសួរថា រទេះដែលមកខាងក្រោយជារទេះធ្ងន់ រទេះនោះដឹកអ្វី ?

ឈ្មួញរទេះល្ងង់ខ្លៅឆ្លើយថា រទេះនោះ ដឹកទឹក ។

យក្សពោលថា អ្នកទាំងឡាយនាំទឹកមក នាំតែយឺតយូរ ចាប់ពីទីនេះទៅ កិច្ចដោយទឹករមែងមិនមាន ខាងមុខមានទឹកច្រើន អ្នកទាំងឡាយ ចូរបំបែកពាង ចាក់ទឹកចោល ចូរធ្វើរទេះឲ្យស្រាលហើយទៅចុះ ។

កាលពោលយ៉ាងនេះហើយ ទើបពោលថា អ្នកទាំងឡាយ ចូរទៅចុះ ការយឺតយូរកុំបីមានដល់ពួកអ្នកឡើយ ហើយធ្វើដំណើរទៅបានបន្តិច ក្នុងកាលដែលមនុស្សទាំងនោះមើលមិនឃើញ ក៏ទៅកាន់នគរយក្សរបស់ខ្លួននោះឯង ។ ចំណែកឈ្មួញរទេះនោះ ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ ក៏ជឿពាក្យរបស់យក្សនោះ ហើយឲ្យវាយបំបែកពាងទាំងអស់ មិនមានសេសសល់ទឹក សូម្បីត្រឹមមួយទូកដៃ ហើយបររទេះទៅ ។ ក្នុងទីខាងមុខ ឈ្មោះថាមានទឹក សូម្បីប្រមាណតិចតួចមិនមានឡើយ មនុស្សទាំងឡាយ កាលមិនបានទឹកផឹកដល់នូវសេចក្តីលំបាកហើយ ។ មនុស្សទាំងនោះ ក៏នាំគ្នាធ្វើដំណើរទៅរហូតដល់ព្រះអាទិត្យអស្តង្គត ទើបបញ្ឈប់រទេះ ហើយព័ទ្ធរទេះជារង្វង់ចងគោទាំងឡាយទុក ។ ទឹកមិនមានដល់ពួកគោ បបរនិងភត្ត ក៏មិនមានដល់ពួកមនុស្សដែរ ពួកមនុស្សក៏មានកម្លាំងថមថយ មិនដាក់ចិត្ត ( ក្នុងរឿងផ្សេងៗ ) ហើយក៏នាំគ្នាដេកលក់ក្នុងទីនោះៗ ។ លំដាប់នោះ ជាចំណែកនៃរាត្រី យក្សទាំងឡាយក៏មកអំពីនគរយក្ស ញុំាងគោនិងមនុស្សទាំងឡាយនោះឯង ឲ្យដល់នូវសេចក្តីស្លាប់ ហើយស៊ីសាច់គោនិងមនុស្សទាំងនោះ ឲ្យសេសសល់ត្រឹមតែឆ្អឹង ហើយនាំគ្នាទៅ ។ មនុស្សទាំងអស់នោះ ដល់នូវសេចក្តីវិនាសព្រោះអាស្រ័យឈ្មួញរទេះល្ងង់ខ្លៅម្នាក់នោះ ដោយប្រការយ៉ាងនេះ ។ ឆ្អឹងទាំងឡាយ មានឆ្អឹងដៃជាដើម ក៏ខ្ចាត់ខ្ចាយទៅក្នុងទិសតូចនិងទិសធំ

រទេះទាំង ៥០០ តាំងនៅដដែលនោះឯង ។ ចំណែកព្រះបរមពោធិសត្វ ចាប់តាំងពីថ្ងៃដែលឈ្មួញរទេះល្ងង់ខ្លៅនោះចេញទៅហើយ ក៏សម្រាក ប្រមាណកន្លះខែ ទើបនាំគ្នាចេញអំពីនគរ មួយអន្លើដោយរទេះ ៥០០ ដល់មាត់ផ្លូវកន្តារដោយលំដាប់ ។ ព្រះពោធិសត្វក៏ឲ្យដងទឹកដាក់ពាង ធំៗ ឲ្យលើកដាក់លើរទេះ ដើម្បីធ្វើដំណើរឆ្លងកាត់ផ្លូវកន្តារនោះ ហើយ ប្រកាសឲ្យពួកអ្នករទេះជ្រាបយ៉ាងនេះថា នែអ្នកដ៏ចម្រើនទាំងឡាយ ពួក អ្នកបើមិនបានអនុញ្ញាតអំពីខ្ញុំ កុំចាក់ទឹកសូម្បីមួយទូកដៃឡើយ ក្នុងផ្លូវ កន្តារនេះ មានដើមឈើមានជាតពុល ផ្កា ស្លឹក ឬផ្លៃឈើណា ដែល អ្នកទាំងឡាយមិនធ្លាប់បរិភោគក្នុងកាលមុន បើមិនទាន់សួរខ្ញុំជាមុន កុំ បរិភោគឡើយ ។ ឈ្មួញពោធិសត្វឲ្យឱវាទដល់មនុស្សទាំងឡាយយ៉ាង នេះហើយ ក៏ធ្វើដំណើរឆ្លងផ្លូវកន្តារនោះដោយរទេះ ៥០០ ។ កាលព្រះ ពោធិសត្វធ្វើដំណើរដល់កណ្តាលផ្លូវកន្តារ យក្សនោះក៏បានបង្ហាញខ្លួន ក្នុងចំណែកច្រាសផ្លូវគ្នា ដល់ព្រះពោធិសត្វដោយន័យមុននោះឯង ។ ព្រះពោធិសត្វគ្រាន់តែឃើញយក្សប៉ុណ្ណោះ ក៏ដឹងបានថា ក្នុងផ្លូវកន្តារ នេះ មិនមានទឹក នេះឈ្មោះថា ផ្លូវកន្តារព្រោះមិនមានទឹក ម្យ៉ាងទៀត បុគ្គលនេះ មានអាកប្បកិរិយាមិនខ្លាចក្រែងដល់អ្នកណាសោះ មានភ្នែក ក្រហម ស្រមោលក៏មិនប្រាកដ ឈ្មួញរទេះល្ងង់ខ្លៅនោះ ប្រាកដជាចាក់ ទឹកចោល ដល់នូវសេចក្តីលំបាកមួយអន្លើដោយបរិស័ទ ត្រូវយក្សនេះស៊ី

ដោយឥតសង្ស័យ តែយក្សនេះ មិនដឹងថាអញជាបណ្ឌិត និងភាពដែលអញជាអ្នកឈ្លាសក្នុងឧបាយឡើយ ។ លំដាប់នោះ ព្រះបរមពោធិសត្វពោលនឹងយក្សនោះថា សូមពួកអ្នកទៅចុះ ខ្ញុំជាឈ្មួញ បើមិនឃើញទឹក មិនអាចចាក់ទឹកដែលដឹកមកបានឡើយ ខ្ញុំនឹងចាក់ទឹកចោលក្នុងទីណាដែលខ្ញុំបានឃើញទឹកហើយ ធ្វើរទេះទាំងឡាយឲ្យស្រាលហើយទៅ ។ ចំណែកយក្សទៅបានបន្តិច ដល់ទីដែលមនុស្សមើលមិនឃើញក៏ត្រឡប់ទៅកាន់នគររបស់ខ្លួននោះឯង ។ កាលយក្សនោះទៅហើយមនុស្សទាំងឡាយក៏ចូលទៅរកព្រះពោធិសត្វ ហើយពោលថា បពិត្រលោកម្ចាស់ ជនអម្បាញ់មិញ ជាអ្នកពាក់នូវកម្រងផ្កាឧប្បល និងផ្កាកុមុទមានដៃកាន់ផ្កាឈូកក្រហម និងផ្កាឈូកស ទំពាស៊ីនូវក្រឳឈូក មានសំពត់សើម មានសក់សើម មានដំណក់ទឹក និងភក់ហូរចុះមក ពោលថា នុ៎ះជាដងព្រៃខៀវស្រងាត់ ចាប់អំពីនោះទៅ ភ្លៀងធ្លាក់ជានិច្ច ពួកយើងចាក់ទឹកចោល មានរទេះស្រាលហើយនឹងទៅបានដោយរហ័ស ។ ព្រះពោធិសត្វបានស្តាប់ពាក្យរបស់មនុស្សទាំងនោះហើយ ក៏ឲ្យបញ្ឈប់រទេះ ឲ្យមនុស្សទាំងឡាយប្រជុំគ្នាហើយសួរថា ពួកលោកធ្លាប់បានស្តាប់មកអំពីណាថា ក្នុងផ្លូវកន្តារនេះ មានស្រះទឹក ឬស្រះបោក្ខរណី ?

ជនទាំងឡាយពោលថា បពិត្រលោកម្ចាស់ មិនធ្លាប់បានឮទេ ។

ព្រះពោធិសត្វពោលថា នេះឈ្មោះថា កន្តារមិនមានទឹក ឥឡូវ

នេះ ពួកជនអម្បាញ់មិញពោលថា ខាងមុខ ចាប់តាំងអំពីដងព្រៃពណ៌ខៀវនោះទៅ មានភ្លៀងធ្លាក់ ធម្មតាកាលភ្លៀងធ្លាក់ តើខ្យល់ត្រជាក់មានចម្ងាយប្រមាណប៉ុនណា ?

ជនទាំងឡាយឆ្លើយថា កាលមេឃមានភ្លៀងធ្លាក់ ខ្យល់ត្រជាក់នឹងផាត់ចំហាយមក ១ យោជន៍ ។

ព្រះពោធិសត្វសួរថា ឥឡូវនេះ ខ្យល់ត្រជាក់នោះ ប៉ះពាល់កាយរបស់អ្នកទាំងឡាយ សូម្បីតែម្នាក់ហើយឬ ?

មនុស្សទាំងនោះឆ្លើយថា មិនមានទេលោកម្ចាស់ ។

ព្រះបរមពោធិសត្វសួរថា ធម្មតាដុំពពកខ្មៅ រមែងប្រាកដក្នុងទីប្រមាណប៉ុនណា ?

មនុស្សទាំងឡាយឆ្លើយថា ក្នុងទីប្រមាណ ៣ យោជន៍ ។

ព្រះមហាសត្វសួរថា បណ្ដាអ្នកទាំងឡាយ តើមានអ្នកណាឃើញដុំពពកខ្មៅដែលបញ្ជាក់ថា មានភ្លៀងដែរឬទេ ?

មនុស្សទាំងឡាយឆ្លើយថា មិនឃើញទេ លោកម្ចាស់ ។

ព្រះមហាសត្វសួរថា ធម្មតាផ្លេកបន្ទោរ ប្រាកដក្នុងទីមានប្រមាណប៉ុនណា ?

មនុស្សទាំងឡាយឆ្លើយថា មានប្រមាណ ៤ ទៅ ៥ យោជន៍ ។

ព្រះពោធិសត្វសួរថា បណ្ដាអ្នកទាំងឡាយ មានអ្នកណាមួយ

បានឃើញពន្លឺផ្លេកបន្ទោរដែរឬ?

មនុស្សទាំងឡាយឆ្លើយថា មិនបានឃើញទេ លោកម្ចាស់ ។

ព្រះបរមពោធិសត្វសួរថា ជម្ពាសំឡេងផ្គរ ឮក្នុងទីមានប្រមាណប៉ុនណា?

មនុស្សទាំងឡាយឆ្លើយថា សំឡេងផ្គរលាន់ឮក្នុងចម្ងាយ ១ ឬ ២ យោជន៍ ។

ព្រះពោធិសត្វសួរថា បណ្ដាអ្នកទាំងឡាយ តើមានអ្នកណាបានឮសំឡេងផ្គរខ្លះ ?

មនុស្សទាំងឡាយឆ្លើយថា មិនមានអ្នកណាបានឮទេ ។

ព្រះពោធិសត្វសួរថា អ្នកទាំងឡាយដឹងថា ជនអម្បាញ់មិញនេះជាអ្វីដែរឬទេ ?

មនុស្សទាំងឡាយឆ្លើយថា ពួកខ្ញុំមិនដឹងទេ ។

ព្រះពោធិសត្វពោលថា ជនទាំងនេះ មិនមែនជាមនុស្សទេ ជនទាំងនេះជាយក្ស ពួកវាមកបញ្ឆោតដើម្បីឲ្យពួកយើងចាក់ទឹកចោល ធ្វើយើងឲ្យខ្សោយកម្លាំងហើយនឹងទំពាស៊ី ។ ឈ្មួញរទេះលួងខ្លៅដែលទៅមុននោះ ជាអ្នកមិនឈ្លាសក្នុងឧបាយ ពិតជាត្រូវយក្សនេះធ្វើឲ្យលំបាកហើយទំពាស៊ីដោយឥតសង្ស័យ រទេះ ៥០០ នឹងនៅដដែលនោះឯង ថ្ងៃនេះ ពួកយើងនឹងឃើញរទេះទាំងនោះ អ្នកទាំងឡាយកុំចាក់ទឹកចោល

សូម្បីត្រឹមតែមួយទុកដៃឡើយ ចូរប្រញាប់បររទេះទៅចុះ ។ ព្រះបរមពោធិសត្វធ្វើដំណើរទៅជាមួយរទេះ ៥០០ ដែលផ្ទុកទំនិញពេញនោះឯង ឃើញផ្លូវរបស់មនុស្សទាំងឡាយនិងផ្លូវរបស់គោ ខ្ទាត់ខ្ទាយរាត់រាយក្នុងទិសតូចនិងទិសធំ ទើបប្រាប់ឲ្យដោះរទេះ ឲ្យបោះជំរំ ឲ្យយករទេះព័ទ្ធធ្វើជារង្វង់ចង់គោ ក្នុងពេលថ្ងៃមិនទាន់លិចឲ្យពួកមនុស្សបរិភោគអាហារល្ងាច ឲ្យគោទាំងឡាយដេកត្រង់កណ្ដាល ឲ្យមនុស្សទាំងឡាយដែលមានកម្លាំងខ្លាំងកាន់ដាវធ្វើនូវការរក្សា អស់យាម ៣ ក្នុងរាត្រីរហូតដល់អរុណោរះ ។ ស្អែកឡើង ព្រះមហាសត្វធ្វើកិច្ចទាំងពួងអំពីព្រលឹមឲ្យគោទាំងឡាយស៊ីស្មៅហើយ ឲ្យចោលរទេះដែលមិនរឹងមាំ ឲ្យកាន់យករទេះដែលរឹងមាំ ឲ្យចោលវត្ថុដែលមានតម្លៃតិច ឲ្យជញ្ជូនវត្ថុដែលមានតម្លៃច្រើន ( ដាក់លើរទេះ ) ហើយធ្វើដំណើរទៅកាន់ទីដែលខ្លួនប្រាថ្នា លក់ដូរនូវទំនិញទាំងឡាយបានចំណេញទ្វេគុណ ត្រីគុណ នាំពួកបរិស័ទទាំងអស់ត្រឡប់មកកាន់នគររបស់ខ្លួនវិញ ។

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់ព្រះធម្មទេសនានេះហើយ ទើបត្រាស់ថា ម្នាលគហបតី ក្នុងកាលមុន បុគ្គលមានប្រក្រតីកាន់យកដោយការគិតខុស ដល់នូវសេចក្ដីវិនាសធំ ដោយប្រការដូច្នេះ ចំណែកបុគ្គលមានប្រក្រតីកាន់យកតាមសេចក្ដីពិត ផុតចាកកណ្ដាប់ដៃរបស់ពួកអមនុស្ស ទៅដល់ទីដែលខ្លួនប្រាថ្នាដោយសួស្ដី ហើយត្រឡប់មកកាន់

ទីលំនៅរបស់ខ្លួននោះឯង ។ កាលទ្រង់ត្រាស់ដឹងក្រៃលែងឯង ទ្រង់បន្ត អនុសន្ធិក្នុងអបណ្ណកធម្មទេសនានេះ ទើបត្រាស់ព្រះគាថានេះថា

**អបណ្ណកំ ឋានមេកេ ទុតិយំ អាហុ តក្កិកា**

**ឯតទញ្ញាយ មេធាវី តំ គណ្ហេ យទបណ្ណកន្តិ ។**

បុគ្គលពួកខ្លះ ជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស

បុគ្គលពួកខ្លះ ត្រិះរិះយកឯង រមែងប្រកាន់ហេតុទី ២ ( ហេតុ

ខុស) មេធាវីបុគ្គល បានដឹងនូវហេតុដែលខុសនិងហេតុដែល

មិនខុសនេះហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ។

បណ្តាបទទាំងនោះ បទថា **អបណ្ណកំ** បានដល់ ប្រព្រឹត្តទៅយ៉ាងពិតប្រាកដ មិនខុស ជាគ្រឿងនាំចេញចាកទុក្ខ ។ បទថា **ឋានំ** បានដល់ហេតុ ។ ពិតហើយក្នុងហេតុនោះ ព្រោះផលតាំងនៅ ព្រោះមានការប្រព្រឹត្តទៅទាក់ទងជាមួយហេតុនោះ ព្រោះដូច្នោះ ទើបលោកហៅហេតុនោះថា ឋានៈ និងគប្បីជ្រាបប្រយោគរបស់បទថា **ឋានំ** នោះក្នុងប្រយោគជាដើមថា **ឋានញ្ច ឋានតោ អឋានញ្ច អឋានតោ** ប្រែថា ស្គាល់ឋានៈ ថាជាឋានៈ និងមិនមែនឋានៈ ថាជាមិនមែនឋានៈ ដូច្នេះ ។ ដោយបទទាំងពីរ បទថា **អបណ្ណកំ ឋានំ** សម្តែងថា ហេតុណានាំមកនូវសេចក្តីសុខដោយចំណែកមួយ ហេតុនោះ បណ្ឌិតទាំងឡាយបដិបត្តិហើយ ហេតុដែលប្រព្រឹត្តទៅយ៉ាងពិតប្រាកដ ហេតុ

ដែលប្រពៃ ឈ្មោះថា **អបណ្ណកា** គឺបដិបត្តិមិនខុស នេះជាហេតុដែលមិនខុស ជាហេតុគឺគ្រឿងនាំចេញចាកទុក្ខ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ តែកាលពោលដោយប្រភេទ សរណគមន៍ ៣ សីល ៥ សីល ៨ សីល ១០ បាតិមោក្ខសំវរ ឥន្ទ្រិយសំវរ អាជីវបារិសុទ្ធិសីល បច្ចយបដិសេវន គឺការសេពបច្ច័យ ចតុប្បារិសុទ្ធិសីលទាំងអស់ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ការដឹងប្រមាណក្នុងភោជន ជាគរិយានុយោគ គឺការប្រកបនូវការភ្ញាក់រឭក ឈាន វិបស្សនា អភិញ្ញាសមាបត្តិ អរិយមគ្គ អរិយផល ទាំងអស់នេះ ជាឋានៈដែលមិនខុស អធិប្បាយថា បដិបទាមិនខុស បដិបទាដែលជាគ្រឿងនាំចេញចាកទុក្ខ ព្រោះហេតុដែលឋានៈមិនខុសនេះ ជាឈ្មោះរបស់បដិបទាជាគ្រឿងនាំសត្វចេញចាកទុក្ខ ព្រោះដូច្នោះឯង ទើបព្រះមានព្រះភាគ ទ្រង់សម្តែងបដិបទាដែលមិនខុសនោះ ហើយត្រាស់ព្រះសូត្រនេះថា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថា អ្នកប្រតិបត្តិនូវសេចក្តីប្រតិបត្តិមិនខុស ទាំងហេតុក៏ឈ្មោះថា លោកបានផ្គងដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកគ្រប់គ្រងទ្វារ

ក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ តែជាអ្នកមិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ បានឮសំឡេងដោយត្រចៀកហើយ ។ បេ ។ បានធុំក្លិនដោយច្រមុះហើយ ។ បេ ។ បានជញ្ជក់ជញ្ជាបរសដោយអណ្តាតហើយ ។ បេ ។ បានពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយហើយ ។ បេ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែជាអ្នកមិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែ មិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានពិចារណាដោយឧបាយនៃប្រាជ្ញា បរិភោគនូវអាហារ

ដោយគិតថា មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថ ៤ ក្តី ការមិនមានទោស គឺមិនខ្ជិលច្រអូសក្តី ការនៅជាសុខក្តី នឹងមានដល់អាត្មាអញដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ( ធម៌ជាគ្រឿងរាំង ) ដោយការចង្រ្កម ដោយការអង្គុយអស់ ១ ថ្ងៃ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចនូវសីហសេយ្យាសន៍ ផ្អៀងទៅខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងលើជើង ប្រកបដោយសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវសេចក្តីសម្គាល់ថា នឹងក្រោក ហើយក៏ក្រោក ក្នុងបច្ឆិមយាមនៃរាត្រី ធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ

ប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថា អ្នកប្រតិបត្តិនូវសេចក្តីប្រតិបត្តិមិនខុស ទាំងហេតុក៏ឈ្មោះថា លោកបានផ្តងដើម្បីឲ្យអស់អាសវៈទាំងឡាយ [១] ។

ក្នុងព្រះសូត្រនេះ ទ្រង់ត្រាស់ធម៌ ៣ ប្រការ អបណ្ណកបដិបទា គឺបដិបទាមិនខុសនេះ រមែងប្រើបានរហូតដល់អរហត្តផលនោះឯង ។ ក្នុងអបណ្ណកបដិបទានេះ អរហត្តផលក៏ឈ្មោះថា ជាបដិបទាឲ្យដល់ផលសមាបត្តិវិហារ និងដល់អនុបាទាបរិនិព្វាន ។ បទថា **ឯកេ** បានដល់បុគ្គលដែលជាបណ្ឌិតពួកមួយ ក្នុងបទថា **ឯកេ** នេះ មិនមានការកំណត់យ៉ាងពិតប្រាកដថា បុគ្គលឈ្មោះនោះ ពិតហើយ តែទោះដូច្នោះពាក្យថា **ឯកេ** ប្រែថា ពួកមួយនេះ គប្បីជ្រាបថា ព្រះសាស្តាត្រាស់សំដៅយកចំពោះព្រះពោធិសត្វព្រមទាំងបរិស័ទ ។

បទថា **ទុតិយំ** ប្រែថា ទី ២ ក្នុងបទថា **ទុតិយំ អាហុ តក្កិកា** បានដល់ ហេតុនៃការកាន់យកដោយការត្រិះរិះ គឺហេតុដែលមិនជាគ្រឿងនាំចេញចាកទុក្ខថាជាទី ២ ក្រៅអំពីឋានៈទី ១ ដែលជាហេតុនាំចេញចាកទុក្ខ ។

ក្នុងបទថា **អាហុ តក្កិកា** នេះ មានការប្រកបសេចក្តីជាមួយ

---

១- បិ. ៤១ , ទំ. ៣០ ។

បទដំបូងដូចតទៅនេះថា បុគ្គលដែលជាបណ្ឌិតពួកមួយ មានព្រះពោធិ-សត្វជាប្រធាន កាន់យកឋានៈដែលមិនខុស គឺហេតុដែលប្រព្រឹត្តទៅយ៉ាងពិតប្រាកដ បានដល់ហេតុដែលមិនខុស ហេតុដែលជាគ្រឿងនាំចេញចាកទុក្ខ ចំណែកបុគ្គលដែលកាន់យកដោយការគិតខុស មានឈ្មួញរទេះលូងខ្មៅជាប្រធាននោះ ពោលគឺបានកាន់យកឋានៈដែលប្រព្រឹត្តទៅដោយមិនពិតប្រាកដ គឺហេតុដែលខុស បានដល់ហេតុដែលមិនជាគ្រឿងនាំចេញចាកទុក្ខ ដែលមានទោស ថាជាទី ២ ។ បណ្តាជនទាំងពីរពួកនោះ ជនដែលកាន់យកឋានៈមិនខុស ជាអ្នកបដិបត្តិបដិបទាសចំណែកជនដែលកាន់យកហេតុ ដែលមិនជាគ្រឿងនាំចេញចាកទុក្ខពោលគឺប្រកាន់ដោយគិតខុសថា ខាងមុខមានទឹក ថាជាទី ២ នោះ ជាអ្នកបដិបត្តិបដិបទាខ្មៅ បដិបទាទាំងពីរនោះ បដិបទាសជាបដិបទាមិនសាបសូន្យ ចំណែកបដិបទាខ្មៅជាបដិបទាសាបសូន្យ ព្រោះដូច្នោះបុគ្គលបដិបត្តិបដិបទាស ជាអ្នកមិនវិនាសដល់នូវសួស្តី ចំណែកបុគ្គលអ្នកបដិបត្តិបដិបទាខ្មៅ ជាអ្នកវិនាសដល់នូវការវិនាសអន្តរាយ ។ ព្រះសាស្តា ត្រាស់ដល់អនាថបិណ្ឌិកគហបតី ដោយអត្ថន័យដូចពណ៌នាមកនេះហើយ ត្រាស់ព្រះតម្រាស់នេះឲ្យក្រៃលែងឡើងថា បុគ្គលមានបញ្ញាដឹងនូវឋានៈ និងអឋានៈនេះហើយ គួរកាន់យកឋានៈដែលមិនខុស ។

បណ្តាបទទាំងនោះ បទថា **ឯតទញ្ញាយ មេធាវី** សេចក្តីថា

កុលបុត្តប្រកបដោយបញ្ញាដ៏បរិសុទ្ធឧត្តម ដែលបានឈ្មោះថា **មេធា** ដឹងនូវគុណនិងទោស សេចក្តីចម្រើននិងសេចក្តីវិនាស ប្រយោជន៍និងមិនមែនប្រយោជន៍ ឋានៈនិងមិនមែនឋានៈ ។ ក្នុងឋានៈទាំងឡាយ គឺក្នុងឋានៈដែលមិនខុសនិងឋានៈដែលខុសនេះ ។

បទថា **តំ គណ្ហេយ្យ ឧ បណ្ណកំ** សេចក្តីថា គួរកាន់យកឋានៈដែលមិនខុស គឺដែលប្រព្រឹត្តទៅដោយពិតប្រាកដ ជាបដិបទាសជាហេតុនាំចេញចាកទុក្ខ ពោលគឺបដិបទាដែលមិនវិនាសនោះឯង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាវៈមានការប្រព្រឹត្តទៅពិតប្រាកដជាដើម ចំណែកក្រៅអំពីនេះ មិនគួរកាន់យក ។

សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះភាវៈមានការប្រព្រឹត្តទៅមិនពិតប្រាកដ ពិតហើយឈ្មោះថា អបណ្ណកបដិបទានេះ ជាបដិបទារបស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះពុទ្ធបុត្តទាំងឡាយ ដូច្នេះ ។ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ តាំងនៅចំពោះក្នុងអបណ្ណកបដិបទា បំពេញបារមីទាំងឡាយដោយសេចក្តីព្យាយាមដ៏ខ្លាំងក្លា ទើបត្រាស់ជាព្រះពុទ្ធត្រង់មណ្ឌលពោធិព្រឹក្ស ព្រះបច្ចេកពុទ្ធ ក៏ញុំាងបច្ចេកពោធិញ្ញាណឲ្យកើតឡើង សូម្បីបុត្តរបស់ព្រះពុទ្ធទាំងឡាយ ក៏ត្រាស់ដឹងចំពោះសាវកបារមីញាណ ។ ព្រះសាស្តា

ទ្រង់ប្រទានកុសលសម្បត្តិទាំង ៣ កាមាវចរស្ឋគ៌ ៦ និងសម្បត្តិក្នុងព្រហ្ម លោកដល់ឧបាសកទាំងនោះ ដោយប្រការដូច្នេះ ក្នុងទីបំផុតទ្រង់សម្ដែង អបណ្ណកបដិបទានេះថា ឈ្មោះថា បដិបទាមិនខុស ឲ្យនូវអរហត្តមគ្គ អរហត្តផល ឈ្មោះថា បដិបទាខុស ឲ្យនូវការកើតក្នុងអបាយ ៤ និងក្នុង ត្រកូលថោកទាប ៥ ហើយទ្រង់ប្រកាសអរិយសច្ចៈ ៤ ដោយអាការ ១៦ ឲ្យក្រៃលែងឡើង ក្នុងវេលាចប់អរិយសច្ចៈ ៤ ឧបាសកទាំង ៥០០ នោះ តាំងនៅក្នុងសោតាបត្តិផល ។

ព្រះបរមសាស្ដា ទ្រង់សម្ដែងព្រះធម្មទេសនានេះហើយ ទ្រង់ធ្វើរឿង ទាំងពីរឲ្យជាប់គ្នា ហើយទ្រង់ប្រជុំជាតក បញ្ចប់ព្រះធម្មទេសនាថា បុត្ត ឈ្មួញរទេះល្ងង់ខ្លៅក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ បរិស័ទរបស់ឈ្មួញរទេះល្ងង់ខ្លៅនោះ បានមកជាបរិស័ទរបស់ទេវទត្ត ក្នុង កាលឥឡូវនេះដូចគ្នា បរិស័ទរបស់បុត្តឈ្មួញរទេះដែលជាបណ្ឌិត ក្នុង កាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកបុត្តរបស់ ឈ្មួញរទេះដែលជាបណ្ឌិតក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អបណ្ណកជាតក ទី ១ ។

# អដ្ឋកថា វណ្ណុបថជាតក ទី ២

ព្រះដ៏មានព្រះភាគ កាលទ្រង់គង់នៅក្នុងនគរសាវត្ថី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អកិលាសុនោ** ដូច្នេះជាដើម ។

សួរថា ទ្រង់ប្រារព្ធអ្នកណា ?

ឆ្លើយថា ទ្រង់ប្រារព្ធភិក្ខុលះបង់សេចក្តីព្យាយាមមួយរូប ។

បានឮថា កាលព្រះតថាគតគង់នៅក្នុងនគរសាវត្ថី មានកុលបុត្តអ្នកនគរសាវត្ថីមួយរូបទៅកាន់វត្តជេតពនមហាវិហារ ស្តាប់ព្រះធម្មទេសនាក្នុងសម្នាក់ព្រះបរមសាស្តា ហើយមានចិត្តជ្រះថ្លា ឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងការចេញចាកកាម ទើបបួស ឧបសម្បទាបាន ៥ វស្សា រៀនមាតិកាបាន ២ សិក្សាប្រព្រឹត្តវិបស្សនា ទទួលកម្មដ្ឋានតាមការចូលចិត្តរបស់ខ្លួននៅក្នុងសម្នាក់របស់ព្រះសាស្តា ហើយចូលទៅកាន់ព្រៃមួយកន្លែងចាំវស្សា ព្យាយាមអស់ត្រៃមាស មិនអាចធ្វើត្រឹមតែឱភាស ឬនិមិត្តឲ្យកើតឡើងបាន ។ លំដាប់នោះ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ព្រះសាស្តាត្រាស់បុគ្គលទុកមួយពួក ក្នុងបុគ្គល ៤ ពួកនោះ អញប្រហែលជាបទបរមបុគ្គល [១] ហើយ អញប្រហែលជាមិនមានមគ្គឬផល

---

១- បុគ្គលដែលមានបទដ៏ក្រៃលែង គឺសូម្បីស្តាប់ធម៌ ឬព្យាយាមយ៉ាងណា ក៏មិនអាចសម្រេចមគ្គផលបាន ។

ក្នុងអត្តភាពនេះទេ អញនឹងធ្វើអ្វីដោយការនៅព្រៃ អញនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា សម្លឹងមើលព្រះរូបរបស់ទ្រង់ដែលដល់នូវលម្អដ៏លើស ស្តាប់ព្រះធម្មទេសនាដ៏ពីរោះល្អជាង កាលគិតយ៉ាងនេះហើយក៏ត្រឡប់មកកាន់វត្តជេតពនមហាវិហារវិញ ។ លំដាប់នោះ ភិក្ខុទាំងឡាយដែលជាសម្លាញ់របស់ភិក្ខុនោះ ពោលនឹងភិក្ខុនោះថា នៃអាវុសោលោករៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តា ហើយទៅដោយបំណងថា នឹងធ្វើសមណធម៌ តែឥឡូវនេះ មកត្រេកអរដោយការច្រឡូកច្រឡំកិច្ចនៃបព្វជិតរបស់លោកដល់ទីបំផុតហើយឬ លោកជាអ្នកមិនមានបដិសន្ធិទៀតទេឬ?

ភិក្ខុនោះពោលថា នៃអាវុសោទាំងឡាយ ខ្ញុំមិនបានមគ្គឬផលអ្វីឡើយ ទើបគិតថា ប្រហែលខ្ញុំនេះជាអភព្វបុគ្គល ទើបលះបង់សេចក្តីព្យាយាមហើយមក ។

ភិក្ខុទាំងនោះពោលថា នៃអាវុសោ លោកបួសក្នុងសាសនារបស់ព្រះសម្ពុទ្ធដែលមានសេចក្តីព្យាយាមដ៏ខ្លាំងក្លា ហើយលះសេចក្តីព្យាយាម ធ្វើវត្តុដែលមិនមែនហេតុ មកពួកយើងនឹងបង្ហាញលោកដល់ព្រះតថាគត កាលពោលហើយ ភិក្ខុទាំងនោះ ក៏នាំភិក្ខុនោះទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ព្រះបរមសាស្តា កាលទ្រង់ឃើញភិក្ខុនោះ ទើបត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកនាំភិក្ខុអ្នកមិនប្រាថ្នារូប

នេះ មកធ្វើអ្វី ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខមានសភាពបែបនេះ មិនអាចធ្វើសមណធម៌ លះបង់សេចក្ដីព្យាយាម មកហើយ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកលះបង់សេចក្ដីព្យាយាមពិតឬ ?

ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខមានសភាពបែបនេះ ហេតុអ្វីមិនឲ្យគេស្គាល់ខ្លួនយ៉ាងនេះថា ជាអ្នកប្រាថ្នាតិចក្ដី ជាអ្នកសន្ដោសក្ដី ជាអ្នកស្ងប់ស្ងាត់ក្ដី ជាអ្នកប្រារព្ធសេចក្ដីព្យាយាមក្ដី បែរជាឲ្យគេដឹងថាជាភិក្ខុលះបង់សេចក្ដីព្យាយាម ក្នុងកាលមុន អ្នកជាបុគ្គលមានព្យាយាម មិនមែនឬ ? កាលវេះ ៥០០ ទៅក្នុងផ្លូវកន្ដារព្រោះខ្សាច់ ពួកមនុស្សនិងគោទាំងឡាយបានទឹក មានសេចក្ដីសុខ ព្រោះអាស្រ័យសេចក្ដីព្យាយាមរបស់អ្នកតែម្នាក់ប៉ុណ្ណោះ ព្រោះហេតុអ្វី ឥឡូវនេះ ទើបអ្នកលះបង់សេចក្ដីព្យាយាមចោល ? ភិក្ខុនោះ បានកម្លាំងចិត្តដោយហេតុមានប្រមាណប៉ុណ្ណោះ ។ ចំណែកភិក្ខុទាំងឡាយ បានស្ដាប់ព្រះតម្រាស់នោះហើយ ទើបអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភាពដែលភិក្ខុនេះលះបង់

សេចក្ដីព្យាយាមហើយ ប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយ ក្នុងកាលឥឡូវនេះ តែក្នុងកាលមុន ភាពដែលគោនិងមនុស្សទាំងឡាយបានទឹកផឹក មានសេចក្ដីសុខក្នុងផ្លូវកន្ដារព្រោះខ្សាច់ ព្រោះអាស្រ័យសេចក្ដីព្យាយាមដែលភិក្ខុនេះធ្វើ ជាអាថ៌កំបាំងសម្រាប់ខ្ញុំព្រះអង្គទាំងឡាយ ប្រាកដដល់ទ្រង់ដែលសម្រេចសព្វញ្ញុតញ្ញាណប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ត្រាស់ហេតុនេះ ដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ។ ព្រះមានព្រះ-ភាគ ទ្រង់ញុំាងការកើតសតិឲ្យកើតដល់ភិក្ខុទាំងឡាយនោះ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើយ៉ាងនោះ អ្នកទាំងឡាយចូរស្ដាប់ចុះ ហើយទ្រង់ធ្វើហេតុការណ៍ដែលអន្តរភពបិទបាំងទុកឲ្យប្រាកដដូច្នេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលឈ្មួញរទេះ ។ ព្រះពោធិសត្វនោះ ចម្រើនវ័យហើយ ត្រាច់ធ្វើការជួញដូរដោយរទេះ ៥០០ ធ្វើដំណើរឆ្លងផ្លូវកន្ដារព្រោះខ្សាច់ ដែលមានចម្ងាយប្រមាណ ៦០ យោជន៍ ក្នុងផ្លូវកន្ដារដែលប្រកបដោយខ្សាច់នោះ មានខ្សាច់ល្អិត ចាប់តាំងអំពីពេលដែលព្រះអាទិត្យរះឡើង ក៏មានសភាពក្ដៅដូចរងើកភ្លើង មិនអាចដើរឆ្លងទៅបាន ព្រោះដូច្នោះ ព្រះពោធិសត្វ កាលធ្វើដំណើរឆ្លងផ្លូវកន្ដារនោះ ក៏យករទេះដាក់ឧស ទឹក ប្រេង និងអង្ករជាដើម ធ្វើដំណើរតែក្នុងពេលយប់ប៉ុណ្ណោះ ក្នុងពេលអរុណរះ ក៏ធ្វើរទេះឲ្យជា

វង្វង់ ចងបារាំទុកខាងលើ ធ្វើកិច្ចក្នុងរឿងអាហារស្រេចពីព្រលឹម ហើយអង្គុយជ្រកម្លប់អស់មួយថ្ងៃ កាលព្រះអាទិត្យអស្តង្គតហើយ បរិភោគអាហារល្ងាច កាលផែនដីមានសភាពត្រជាក់ ទើបទឹមរទេះធ្វើដំណើរទៅ ការទៅដូចគ្នានឹងការទៅក្នុងសមុទ្រខ្សាច់នោះឯង រមែងមានក្នុងផ្លូវកន្តារនោះ ធម្មតាបុគ្គលកំណត់បទ ( អ្នកនាំផ្លូវ ) គួរនឹងមាន ព្រោះហេតុនោះ ទើបព្រះបរមពោធិសត្វឲ្យធ្វើការប្រកបការទៅរបស់ពួករទេះតាមសញ្ញារបស់ផ្កាយ ។ ក្នុងកាលនោះ ឈ្មួញរទេះទាំងនោះ កាលទៅកាន់ផ្លូវកន្តារនោះ តាមទំនងនោះឯង ទើបទៅបាន ៥៩ យោជន៍ ក៏គិតថា ឥឡូវនេះ ដោយរាត្រីមួយប៉ុណ្ណោះ នឹងចេញផុតអំពីផ្លូវកន្តារព្រោះខ្សាច់ ទើបបរិភោគអាហារល្ងាច ប្រើឧសនិងទឹកទាំងពួងឲ្យអស់ ហើយទឹមរទេះទៅ បុរសអ្នកនាំផ្លូវឲ្យក្រាលអាសនៈក្នុងរទេះទី ១ ដេកមើលផ្កាយនៅក្នុងលំហមេឃប្រាប់ថា ចូរបរទៅទិសនេះ ចូរបរទៅទិសនេះ អ្នកនាំផ្លូវនោះហត់នឿយព្រោះមិនបានដេកអស់កាលយូរ ក៏ដេកលក់ទៅ កាលគោទាំងឡាយនាំគ្នាត្រឡប់ក្រោយ ក៏នៅតែមិនដឹងខ្លួន គោទាំងឡាយដើរទៅមួយយប់ទល់ភ្លឺ បុរសអ្នកនាំផ្លូវភ្ញាក់ឡើងក្នុងពេលអរុណោះ សម្លឹងមើលផ្កាយនក្ខត្តឫក្សហើយពោលថា **សកាជានិ និវត្តេថ សកាជានិ និវត្តេថ** ចូរឲ្យរទេះត្រឡប់ ចូរឲ្យរទេះត្រឡប់ ។ កាលមនុស្សទាំងឡាយនាំគ្នាត្រឡប់រទេះតាមលំដាប់ៗ នោះឯង ព្រះអាទិត្យ

ក៏រះឡើង មនុស្សទាំងឡាយនាំគ្នាពោលថា នេះជាទីតាំងដែលពួកយើងបោះជំរំ កាលពីម្សិលមិញ ឧសនិងទឹករបស់ពួកយើងក៏អស់ហើយ ឥឡូវនេះ ពួកយើងវិនាសហើយ ទើបដោះគោដាក់រទេះជារង្វង់ ហើយធ្វើបារាំទុកអំពីខាងលើ ដេកសុបសៅក្រោមរទេះរៀងៗ ខ្លួន ។ ព្រះបរមពោធិសត្វគិតថា កាលអញលះបង់សេចក្ដីព្យាយាម មនុស្សទាំងអស់នឹងដល់នូវសេចក្ដីវិនាស ទើបត្រាច់ទៅក្នុងវេលាដែលថ្ងៃមិនទាន់ក្ដៅ ឃើញស្មៅមួយគុម្ព ទើបគិតថា ស្មៅនេះអាចដុះឡើងបាន ព្រោះភាពត្រជាក់របស់ទឹកខាងក្រោម ទើបឲ្យមនុស្សកាន់ចបមកហើយឲ្យជីកត្រង់ទីនោះ មនុស្សទាំងនោះនាំគ្នាជីកបានជម្រៅ ៦០ ហត្ថ កាលមនុស្សទាំងឡាយជីកដីមានប្រមាណប៉ុណ្ណោះ ចបក៏ប៉ះនឹងផ្ទាំងថ្មខាងក្រោម លុះចបប៉ះនឹងផ្ទាំងថ្ម មនុស្សទាំងនោះក៏នាំគ្នាលះបង់សេចក្ដីព្យាយាម ។ ចំណែកព្រះបរមពោធិសត្វគិតថា ខាងក្រោមផ្ទាំងថ្មនេះ ពិតជាមានទឹក ទើបចុះទៅឈរលើផ្ទាំងថ្មហើយឱនផ្ទៀងត្រចៀកស្ដាប់ ក៏បានឮសំឡេងក្រសែទឹកនៅខាងក្រោមនោះ ទើបឡើងមកប្រាប់អ្នកបម្រើថា នែបាកាលបើអ្នកលះបង់សេចក្ដីព្យាយាម ពួកយើងនឹងវិនាស អ្នកកុំលះបង់សេចក្ដីព្យាយាមឡើយ ចូរកាន់យកញញួរដែកចុះទៅក្នុងរណ្ដៅនេះវាយបំបែកថ្មនេះចុះ ។ អ្នកបម្រើនោះ ទទួលពាក្យរបស់ព្រះពោធិសត្វហើយ មិនលះបង់សេចក្ដីព្យាយាម ក្នុងកាលដែលមនុស្សទាំងពួង

លះបង់សេចក្ដីព្យាយាម ឈរក្នុងអណ្ដូងនោះវាយថ្ម ថ្មក៏បែកជាពីរចំ-ណែក ធ្លារទឹកមានទំហំប្រមាណប៉ុនដើមត្នោតនៅខាងក្រោមផ្ទាំងថ្មក៏បាញ់ឡើង មនុស្សទាំងឡាយនាំគ្នាផឹកទឹក ងូត ពុះដុំរទេះ នឹមរទេះជាដើមដែលសេសសល់ ដាំបបរនិងកត្តបរិភោគ និងឲ្យគោផឹក កាលព្រះអាទិត្យអស្តង្គត ទើបចងទង់ក្បែរអណ្ដូងទឹក ហើយបាននាំគ្នាទៅកាន់ទីដែលខ្លួនប្រាថ្នា ។ មនុស្សទាំងនោះលក់ដូរទំនិញក្នុងទីនោះហើយ បានចំណេញទ្វេគុណ ត្រីគុណ ចតុគុណ ទើបនាំគ្នាមកកាន់លំនៅរៀងៗខ្លួន ។ មនុស្សទាំងនោះតាំងនៅក្នុងអត្តភាពនោះ លុះអស់អាយុហើយក៏ទៅតាមយថាកម្ម ចំណែកព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើមបានទៅតាមយថាកម្មដូចគ្នា ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់ត្រាស់ដឹងក្រៃលែងឯងហើយ ទើបត្រាស់ព្រះគាថានេះថា

**អកិលាសុនោ វណ្ណុបថេ ខណន្តា**
**ឧទង្គណេ តត្ថ បបំ អវិន្ទុំ**
**ឯវំ មុនិ វីរិយពលូបបន្នោ**
**អកិលាសុ វិន្ទេ ហទយស្ស សន្តិន្តិ ។**

ពួកជនមិនខ្ជិលច្រអូស កាលជីក ( ផែនដី ) ត្រង់ផ្លូវខ្សាច់ ឬក្នុងទីទួល បាននូវទឹកត្រង់ផ្លូវនោះ ( យ៉ាងណា ) អ្នកប្រាជ្ញ

បរិបូណ៌ដោយព្យាយាមនិងកម្លាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវសេចក្ដីស្ងប់រម្ងាប់នៃហឫទ័យយ៉ាងនោះដែរ ។

បណ្ដាបទទាំងនោះ បទថា **អកិលាសុនោ** បានដល់ មិនខ្ជិលច្រអូស គឺប្រារព្ធសេចក្ដីព្យាយាម ។ បទថា **វណ្ណុបថេ** សេចក្ដីថា ខ្សាច់លោកហៅថា **វណ្ណុ** ។ ក្នុងផ្លូវខ្សាច់នោះ ។ បទថា **ខណន្តា** ប្រែថា ជីកផែនដី ។

សព្ទថា **ឧទ** ក្នុងបទថា **ឧទង្គណេ** នេះ ត្រឹមតែជានិបាត អធិប្បាយថា ក្នុងទីកណ្ដាលវាល សេចក្ដីថា ក្នុងទីដែលសញ្ចារទៅរបស់ពួកមនុស្ស គឺក្នុងភូមិភាគដែលមិនបិទបាំង ។ បទថា **តត្ថ** សេចក្ដីថា ក្នុងផ្លូវខ្សាច់នោះ ។ បទថា **បបំ អវិន្ទុំ** ប្រែថា បានទឹក ពិតហើយទឹកលោកហៅថា **បបា** ព្រោះជាគ្រឿងផឹក ម្យ៉ាងទៀត ទឹកដែលហូរចូលទៅ ឈ្មោះថា **បបា** អធិប្បាយថា ទឹកច្រើន ។

បទថា **ឯវំ** ជាបទធ្វើនូវការឧបមាឲ្យសម្រេច ។ បទថា **មុនិ** សេចក្ដីថា ញាណលោកហៅថា មោនៈ ម្យ៉ាងទៀត មោនេយ្យៈ ឯណានីមួយ ក្នុងកាយមោនេយ្យជាដើម លោកហៅថា មោនៈ បុគ្គលដែលហៅថា មុនី ព្រោះប្រកបដោយមោនៈនោះ មុនីនេះ មានច្រើនយ៉ាង គឺ អាគារិយមុនី អនាគារិយមុនី សេក្ខមុនី អសេក្ខមុនី បច្ចេកពុទ្ធមុនី និង មុនិមុនី ។ បណ្ដាមុនីទាំងនោះ គ្រហស្ថដែលសម្រេចផលដឹងច្បាស់

នូវសាសនា ឈ្មោះថា អាគារិយមុនី បព្វជិតបែបនោះឯង ឈ្មោះថា អនាគារិយមុនី ព្រះសេក្ខ ៧ ពួក ឈ្មោះថា សេក្ខមុនី ព្រះខីណាស្រព ឈ្មោះថា អសេក្ខមុនី ព្រះបច្ចេកពុទ្ធ ឈ្មោះថា បច្ចេកពុទ្ធមុនី ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា មុនិមុនី ។ ក្នុងអត្ថនេះ បើពោលដោយរួមបុគ្គលដែលប្រកបដោយបញ្ញា គឺគប្បីជ្រាបថា ជាមុនីទាំងអស់ ។ បទថា **វិរិយពលូបបន្នោ** បានដល់ បុគ្គលប្រកបសេចក្តីព្យាយាមដោយកម្លាំងកាយ មួយអន្លើដោយកម្លាំងញាណ ។

បទថា **អកិលាសុ** សេចក្តីថា បុគ្គលមិនខ្ជិលច្រអូស គឺឈ្មោះថា បុគ្គលមិនខ្ជិលច្រអូស ព្រោះប្រកបដោយសេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ដែលលោកពោលទុកយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ មេ សរីរេ អវសុស្សតុ មំសលោហិតំ ។** សូមឲ្យស្បែក សរសៃ និងឆ្អឹង សល់នៅចុះ ឯសាច់ឈាមក្នុងសរីរៈរបស់អាត្មាអញ ចង់រីងស្ងួត ក៏រីងស្ងួតទៅចុះ [១] ដូច្នេះ ។

បទថា **វិន្ទេ ហទយស្ស សន្តឹ** សេចក្តីថា រមែងជួប គឺបានចំពោះនូវអរិយធម៌ ពោលគឺ ឈាន វិបស្សនា អភិញ្ញា និងអរហត្តមគ្គញ្ញាណ ដែលដល់នូវការរាប់ថា **សន្តិ** ព្រោះធ្វើការត្រជាក់ចិត្តផង

---

១-បិ.២៣ , ទំ. ៤០៥ ។

ត្រជាក់ហទយរូបផង ពិតហើយ ព្រះមានព្រះភាគ ទ្រង់ពណ៌នាការនៅជាទុក្ខរបស់បុគ្គលខ្ជិលច្រអូស និងការនៅជាសុខរបស់បុគ្គលដែលប្រារព្ធសេចក្ដីព្យាយាម ដោយព្រះសូត្រទាំងឡាយមិនមែនតិចយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្ជិលច្រអូស រមែងច្រឡូកច្រឡំដោយអកុសលធម៌ដ៏លាមក នៅជាទុក្ខ ថែមទាំងញុំាងប្រយោជន៍នៃខ្លួនដ៏ធំឲ្យសាបសូន្យទៅ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលដែលមានព្យាយាមតឹងរ៉ឹងរមែងស្ងប់ស្ងាត់ចាកអកុសលធម៌ដ៏លាមក នៅជាសុខ ថែមទាំងញុំាងប្រយោជន៍នៃខ្លួនដ៏ធំឲ្យបរិបូណ៌ [១] ដូច្នេះ ។

លោកពោលអធិប្បាយពាក្យនេះទុកថា ឈ្មួញទាំងនោះ មិនខ្ជិលច្រអូស ជីកដីក្នុងផ្លូវកន្ដារដែលប្រកបដោយខ្សាច់ រមែងបានទឹកយ៉ាងណា ភិក្ខុក្នុងសាសនានេះ ក៏យ៉ាងនោះ ជាអ្នកឈ្លាស មិនខ្ជិលច្រអូសប្រកបព្យាយាម រមែងបាននូវការស្ងប់ចិត្ត មានបឋមជ្ឈានជាដើម ។

ព្រះមានព្រះភាគ កាលទ្រង់នាំអតីតនិទាននេះមកហើយ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន អ្នកធ្វើសេចក្ដីព្យាយាមដើម្បីត្រូវការទឹក ឥឡូវនេះ ព្រោះហេតុអ្វីទើបអ្នកលះបង់សេចក្ដីព្យាយាមក្នុងសាសនា

---

១- បិ. ៣១ , ទំ. ៦២ ។

ដែលជាគ្រឿងនាំចេញចាកទុក្ខ ( និងជាសាសនា ) ឲ្យនូវប្រយោជន៍ដល់មគ្គនិងផលដែលមានសភាពបែបនេះ ។

ព្រះបរមសាស្តា កាលទ្រង់សម្តែងព្រះធម្មទេសនានេះ យ៉ាងនេះហើយ ទើបទ្រង់ប្រកាសសច្ចៈ ៤ ក្នុងវេលាចប់អរិយសច្ចៈ ភិក្ខុដែលលះបង់សេចក្តីព្យាយាម ក៏តាំងនៅក្នុងអរហត្តដែលជាអគ្គផល ។

ព្រះសាស្តា ទ្រង់ត្រាស់រឿងទាំងពីរឲ្យជាប់គ្នា ទ្រង់បន្តអនុសន្ធិហើយប្រជុំជាតកថា អ្នកបម្រើមិនលះបង់សេចក្តីព្យាយាម វាយបំបែកថ្មឲ្យទឹកដល់មហាជនក្នុងកាលនោះ បានមកជាភិក្ខុដែលលះបង់សេចក្តីព្យាយាមក្នុងកាលឥឡូវនេះ បរិស័ទដ៏សេសក្នុងសម័យនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកប្រធានឈ្មួញរទេះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វណ្ណុបថជាតក ទី ២ ។

# អដ្ឋកថា សេរិវវាណិជជាតក ទី ៣

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធភិក្ខុមួយរូប ដែលលះបង់សេចក្ដីព្យាយាមដូចគ្នា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ឥធ ចេ នំ វិរាធេសិ** ដូច្នេះជាដើម ។

ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយនាំមកដោយន័យមុននោះ ទើបត្រាស់ថា ម្នាលភិក្ខុ អ្នកបួសក្នុងសាសនាដែលឲ្យនូវមគ្គផលយ៉ាងនេះ កាលលះសេចក្ដីព្យាយាម អ្នកនឹងសោយសោកអស់កាលយូរ ដូចសេរិវវាណិជវិនាសចាកថាសមាសដែលមានតម្លៃ ១ សែនដូច្នោះ ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះសាស្ដា ដើម្បីទ្រង់ត្រាស់រឿងនោះឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់បានធ្វើហេតុដែលមានភពបិទបាំងទុកឲ្យប្រាកដដូច្នេះថា

ក្នុងអតីតកាល ក្នុងកប្បទី ៥ អំពីភទ្ទកប្បនេះ ព្រះពោធិសត្វកើតជាឈ្មួញរ៉ៃឈ្មោះថា សេរិវៈ ក្នុងដែនសេរិវរដ្ឋ ។ សេរិវពាណិជនោះកាលទៅដើម្បីជួញដូរជាមួយឈ្មួញរ៉ៃទ្បេះទ្បោះម្នាក់ ឈ្មោះថា សេរិវៈ ( ដូចគ្នា ) ឆ្លងស្ទឹងឈ្មោះថា នីលពាហៈ ហើយចូលទៅកាន់នគរឈ្មោះថា អរិដ្ឋបុរៈ ចែកផ្លូវគ្នាក្នុងនគរ ហើយត្រាច់ស្វែងរកទំនិញក្នុងផ្លូវមួយ ។ ចំណែកពាណិជម្នាក់ទៀតកាន់យកផ្លូវមួយ ។ ក្នុងនគរនោះមានត្រកូលសេដ្ឋីមួយជាត្រកូលបុរាណ បុត្ត បងប្អូន និងទ្រព្យសម្បត្តិទាំងពួង បាន

*អស់ទៅ សល់នៅតែទារិកាម្នាក់និងជីដូនប៉ុណ្ណោះ ។ ជីដូននិងចៅទាំងពីរនាក់នោះ ធ្វើការស៊ីឈ្នួលអ្នកដទៃដើម្បីចិញ្ចឹមជីវិត ក្នុងផ្ទះមានថាសមាសដែលមហាសេដ្ឋីធ្លាប់ប្រើប្រាស់បន្សល់ទុក ជនទាំងពីររក្សាទុកជាមួយភាជនៈដទៃៗ កាលមិនបានប្រើប្រាស់យូរ ច្រែះក៏ចាប់ ជីដូននិងចៅនោះក៏មិនដឹងថា ថាសនោះជាថាសមាស ។ សម័យនោះ ពាណិជខ្មេះខ្មោះនោះ ត្រាច់លក់ដូរពពាយនាយថា ចូរកាន់យកគ្រឿងប្រដាប់ ចូរកាន់យកគ្រឿងប្រដាប់ ហើយក៏បានទៅដល់ទ្វារផ្ទះនោះ កុមារិកាឃើញពាណិជនោះ ទើបពោលនឹងជីដូនថា បពិត្រលោកយាយ សូមទិញគ្រឿងប្រដាប់ទាំងនោះឲ្យចៅ ។*

*ជីដូនពោលថា នែចៅ យើងជាមនុស្សក្រីក្រ នឹងយកអ្វីទៅទិញ ?*

*កុមារិកាពោលថា ពួកយើងមានថាស ១ ថាសនេះមិនជាឧបការៈដល់ពួកយើង ចូរឲ្យថាសនេះ ហើយកាន់យកគ្រឿងប្រដាប់ ។ ជីដូនឲ្យហៅនាយពាណិជនោះមក ហើយអញ្ជើញឲ្យអង្គុយលើអាសនៈ ឲ្យថាសនោះហើយពោលថា នែអ្នក ចូរអ្នកកាន់យកថាសនេះ ហើយឲ្យគ្រឿងប្រដាប់ណាមួយក៏បានដល់ក្មួយស្រីរបស់អ្នកចុះ ។ ពាណិជនោះយកដៃចាប់ថាសនោះ គិតថា ប្រហែលជាថាសមាស ទើបត្រឡប់យកដៃកកូតត្រង់បាតថាស ដឹងច្បាស់ថាជាមាស ក៏គិតទៀតថា អញនឹងមិនឲ្យរបស់ណាមួយដល់ជនទាំងនេះ ហើយនឹងនាំយកថាសនេះទៅ*

ទើបពោលថា ថាសនេះមានតម្លៃអ្វី តម្លៃរបស់ថាសនេះ មិនដល់កន្ទះមាសកៈផង ហើយបោះថាសនោះទៅលើផែនដី ក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកព្រះបរមពោធិសត្វគិតថា អ្នកដទៃអាចចូលទៅកាន់ផ្លូវដែលពាណិជនោះចូលទៅមុនហើយចេញទៅ ទើបចូលទៅកាន់ផ្លូវនោះ ពពាយនាយថា ចូរកាន់យកគ្រឿងប្រដាប់ ដូច្នេះ បានទៅដល់ទ្វារផ្ទះនោះ កុមារិកាក៏ពោលនឹងជីដូនដូចមុនទៀត ជីដូនពោលនឹងកុមារិកានោះថា នៃចៅ នាយពាណិជដែលមកកាន់ផ្ទះនេះ បោះថាសនេះលើដីហើយទៅ ឥឡូវនេះ យើងនឹងឲ្យអ្វីដល់ឈ្មួញនេះ ហើយកាន់យកគ្រឿងប្រដាប់នោះ ?

កុមារិកាពោលថា បពិត្រលោកយាយ ពាណិជមុននោះ មានវាចាគ្រោតគ្រាត ចំណែកពាណិជនេះ គួរជាទីស្រឡាញ់ និយាយពាក្យទន់ភ្លន់ គាត់នឹងទទួលយកមិនខាន ។

ជីដូនពោលថា បើដូច្នោះ ចូរនាងហៅគេមកចុះ ។ កុមារិកានោះក៏ហៅព្រះពោធិសត្វចូលមក លំដាប់នោះ ជីដូននិងចៅបានឲ្យថាសនោះ ដល់ព្រះពោធិសត្វដែលចូលទៅកាន់ផ្ទះហើយអង្គុយ ។ ព្រះពោធិសត្វដឹងថា ថាសនោះជាថាសមាស ក៏ពោលថា អ្នកម្ដាយ ថាសនេះមានតម្លៃរាប់សែន តម្លៃក្នុងដៃរបស់ខ្ញុំមិនមានសម្រាប់ថាសនេះឡើយ ។

ដីជូននិងចៅក៏ពោលថា នៃលោក ពាណិជដែលមកមុន ពោលថា ថាសនេះ មានតម្លៃមិនដល់កន្ទះមាសកៈ ហើយបោះថាសនេះទៅលើដី តែថាសនេះក្លាយជាមាស ព្រោះបុណ្យរបស់លោក ពួកយើងឲ្យថាសនេះដល់លោក លោកឲ្យវត្ថុណាមួយដល់ពួកយើងក៏បាន សូមកាន់យកថាសនេះទៅចុះ ។ ខណៈនោះ ព្រះពោធិសត្វក៏ឲ្យកហាបណៈ ៥០០ ដែលមាននៅក្នុងដៃ និងមុខទំនិញដែលមានតម្លៃ ៥០០ កហាបណៈទាំងអស់ ហើយសូមយកត្រឹមតែជញ្ជីង ១ ថង់ ១ និងកហាបណៈ ៨ ប៉ុណ្ណោះ ហើយកាន់យកថាសនោះចៀសចេញទៅ ។ ព្រះពោធិសត្វប្រញាប់ទៅកាន់ឆ្នេរស្ទឹង ឲ្យនាយទូក ៨ កហាបណៈ ហើយឡើងទូកទៅ ។ ចំណែកនាយពាណិជពាលត្រឡប់មកកាន់ផ្ទះនោះវិញ ហើយពោលថា ចូរនាំថាសនោះមក ខ្ញុំនឹងឲ្យរបស់បន្តិចបន្តួច ។

ស្រីនោះ ជេរពាណិជពាលនោះ ហើយពោលថា លោកបានធ្វើថាសមាសដែលមានតម្លៃរាប់សែនរបស់ពួកយើង ឲ្យមានតម្លៃត្រឹមកន្ទះមាសកៈ តែពាណិជដែលជាអ្នកមានធម៌ម្នាក់ ដូចគ្នានឹងលោកនោះឯងបានឲ្យទ្រព្យ ១ ពាន់ដល់ពួកយើង ហើយកាន់យកថាសមាសនោះទៅហើយ ។ ពាណិជពាលបានស្តាប់ដូច្នោះ គិតថា អញវិនាសចាកថាសមាសដែលមានតម្លៃ ១ សែន ពាណិជនេះ ធ្វើនូវសេចក្តីវិនាសយ៉ាងធំឲ្យដល់អញហ្ន៎ កើតសេចក្តីសោកដ៏មានកម្លាំង មិនអាចតម្កល់ស្មារតីបាន

ក៏ដួលសន្ធប់លើផែនដី លុះដឹងខ្លួនឡើង ក៏បាចកហាបណៈដែលមាននៅក្នុងដៃ និងរបស់របរត្រង់ទ្វារផ្ទះនោះ ស្រាតសំពត់ចោល កាន់ជង់ជញ្ជីងធ្វើជាដំបង រត់តាមស្នាមជើងរបស់ព្រះពោធិសត្វទៅ លុះទៅដល់ឆ្នេរស្ទឹងនោះ ឃើញព្រះពោធិសត្វកំពុងទៅ ក៏ពោលថា **អម្ភោ ឆាវិក ឆាវំ និវត្តេហិ** រ៉ឺយនាយទូក ចូរអ្នកត្រឡប់ ។

ព្រះពោធិសត្វពោលថា **តាត មា និវត្តយិ** សូមអ្នកកុំត្រឡប់ឡើយ ។ កាលនាយពាណិជពាល ឃើញព្រះពោធិសត្វកំពុងទៅនោះឯង កើតសេចក្តីសោកដ៏មានកម្លាំង ហទយៈក៏ក្តៅ ឈាមក៏ខ្លួរមកតាមមាត់ ហទយៈក៏បែកដូចភក់ក្នុងបឹងដូច្នោះ ។ ពាណិជពាលនោះ ចងអាឃាតជាមួយនឹងព្រះពោធិសត្វ ដល់នូវការអស់ជីវិតក្នុងទីនោះឯង ។ នេះជាការចងពៀរជាមួយនឹងព្រះមហាសត្វ របស់ទេវទត្តគ្រាដំបូង ។ ព្រះបរមពោធិសត្វធ្វើបុណ្យមានទានជាដើម លុះអស់ជីវិតហើយក៏ទៅតាមយថាកម្ម ។

ព្រះសម្មាសម្ពុទ្ធ កាលត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់ត្រាស់ដឹងព្រមចំពោះហើយ ទើបត្រាស់ព្រះគាថានេះថា

**ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមកំ**
**ចិរំ ត្វំ អនុតប្បេសិ សេរិវាយំវ វាណិជោតិ ។**

បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ

ឲ្យឃ្លាតចាកសាសនានេះហើយ អ្នករមែងក្តៅក្រហាយរឿយៗ អស់កាលយូរ ដូចជាពាណិជឈ្មោះសេរិវៈនេះ ។

បណ្តាបទទាំងនោះ បទថា **ឥធ ចេ ណំ វិរាធេសិ សទ្ធម្មស្ស និយាមតំ** សេចក្តីថា បើអ្នកភ្លាត់សោតាបត្តិមគ្គ ពោលគឺការពិតប្រាកដនៃព្រះសទ្ធម្មយ៉ាងនេះ ក្នុងសាសនានេះ អធិប្បាយថា អ្នកកាលលះបង់សេចក្តីព្យាយាម នឹងមិនសម្រេច ។

បទថា **ចិរំ ត្វំ អនុតប្បេសិ** សេចក្តីថា កាលបើយ៉ាងនោះ អ្នកកាលសោយសោក គឺកន្ទក់កន្ទេញអស់កាលយូរ ឈ្មោះថា នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយសព្វកាល ម្យ៉ាងទៀត ក្នុងបទនេះ មានអធិប្បាយដូច្នេះថា អ្នកនឹងកើតក្នុងនរកជាដើម សោយទុក្ខមានប្រការផ្សេងៗ អស់កាលយូរ ឈ្មោះថា នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ គឺឈ្មោះថា នឹងលំបាក ព្រោះភាពជាអ្នកលះបង់សេចក្តីព្យាយាម គឺព្រោះភាពជាអ្នកភ្លាត់ចាកអរិយមគ្គ ។

សួរថា នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយដូចម្តេច ?

ឆ្លើយថា នឹងក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដូចនាយពាណិជ ឈ្មោះសេរិវៈនេះ អធិប្បាយថា ដូចនាយពាណិជនេះ ដែលមានឈ្មោះយ៉ាងនេះថា សេរិវៈ លោកពោលពាក្យអធិប្បាយទុកថា កាលមុនពាណិជ ឈ្មោះ សេរិវៈ បានថាសមាសដែលមានតម្លៃ ១ សែន មិន

ធ្វើសេចក្ដីព្យាយាមដើម្បីកាន់យកថាសនោះ ទើបវិនាសចាកថាសមាស នោះ ក្ដៅក្រហាយក្នុងកាលជាខាងក្រោយយ៉ាងណា អ្នកក៏ដូច្នោះ ដូច គ្នា កាលមិនបានសម្រេចអរិយមគ្គដែលដូចគ្នានឹងថាសមាស ដែលគេ ត្រៀមទុកឲ្យក្នុងសាសនានេះ ព្រោះលះបង់នូវសេចក្ដីព្យាយាម អ្នកជា បុគ្គលវិនាសជុំវិញចាកអរិយមគ្គនោះ នឹងក្ដៅក្រហាយចិត្តក្នុងកាលជា ក្រោយអស់កាលយូរ បើមិនលះបង់សេចក្ដីព្យាយាមសោត នឹងបាន សម្រេចលោកុត្តរធម៌ទាំង ៩ ក្នុងសាសនារបស់តថាគត ដូចនាយពា-ណិជដែលជាបណ្ឌិត បាននូវថាសមាសដូច្នោះ ។

ព្រះបរមសាស្ដា ទ្រង់កាន់យកកំពូលដោយអរហត្ត ទ្រង់សម្ដែង ព្រះធម្មទេសនានេះ ដល់ភិក្ខុនោះយ៉ាងនេះហើយ ទ្រង់ប្រកាសសច្ចៈ ទាំង ៤ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលលះបង់សេចក្ដីព្យាយាមនោះ តាំង នៅក្នុងអរហត្តដែលជាអគ្គផល ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់រឿងទាំងពីរជាប់តគ្នា ហើយទ្រង់ប្រជុំ ជាតកថា ពាណិជពាលក្នុងកាលនោះ បានមកជាទេវទត្តភិក្ខុក្នុងកាល ឥឡូវនេះ ចំណែកពាណិជដែលជាបណ្ឌិតក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា សេរិវវាណិជជាតក ទី ៣ ។

# អដ្ឋកថា ចុល្លកសេដ្ឋិជាតក ទី ៤

*ព្រះមានព្រះភាគ ទ្រង់អាស្រ័យនគររាជគ្រឹះ គង់នៅក្នុងជីវកម្ពវ័ន ទ្រង់ប្រារព្ធចុល្លបន្ថកត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **អប្បកេន បិ មេធាវី** *ដូច្នេះជាដើម ។*

*ខាងដើម គប្បីពោលការកើតឡើង និងការបាននូវបព្វជ្ជារបស់ចុល្លបន្ថកៈ ក្នុងអម្ពវ័ននោះជាមុន មានកថាតាមលំដាប់ដូចតទៅនេះថា*

*បានឮថា ក្នុងនគររាជគ្រឹះ ធីតារបស់ធនសេដ្ឋី បានធ្វើនូវការជិតស្និទ្ធ គឺស្រឡាញ់ជាមួយទាសៈរបស់ខ្លួន ដោយខ្លាចអ្នកដទៃដឹងកម្មរបស់ខ្លួន ទើបពោលយ៉ាងនេះថា បើមាតាបិតារបស់យើងដឹងទោសនេះ គាត់នឹងធ្វើយើងជាកំណាត់តូចកំណាត់ធំ ពួកយើងនឹងទៅកាន់ប្រទេសដទៃ ទើបកាន់យកទ្រព្យមានតម្លៃដែលអាចកាន់យកទៅបាន ចេញតាមទ្វារសម្ងាត់ ជនទាំងពីរនាក់បាននាំគ្នាទៅហើយដោយគិតថា នឹងទៅកាន់ទីដែលអ្នកដទៃមិនស្គាល់ ហើយនៅក្នុងទីណាមួយ ។ កាលស្វាមីភរិយាទាំងពីរនោះ នៅក្នុងទីនោះហើយ ព្រោះអាស្រ័យការនៅរួមគ្នា សេដ្ឋីធីតាក៏មានគភ៌ ។ សេដ្ឋីធីតានោះ អាស្រ័យគភ៌ចាស់ខែហើយ ទើបប្រឹក្សានឹងស្វាមីថា គភ៌របស់ខ្ញុំគ្រប់ខែហើយ ឈ្មោះថា ការប្រសូតបុត្តក្នុងទីដែលឆ្ងាយអំពីពួកញាតិ រមែងជាទុក្ខសម្រាប់យើងទាំងពីរ ពួកយើងនឹងទៅចំពោះ គឺទៅកាន់ផ្ទះរបស់ត្រកូល ។ ស្វាមីនោះគិតថា បើអញទៅក្នុង*

កាលឥឡូវនេះ ជីវិតរបស់អញនឹងមិនមាន ទើបពន្យាថា នឹងទៅក្នុងថ្ងៃនេះ នឹងទៅក្នុងស្អែកនេះ ។ សេដ្ឋីធីតានោះគិតថា ស្វាមីរបស់អញជាមនុស្សល្ងង់ មិនហ៊ានទៅព្រោះមានកំហុសច្រើន ធម្មតាមាតាបិតាមានឧបការៈដោយចំណែកមួយក្នុងបុត្តធីតា ស្វាមីនេះទៅក្តី មិនទៅក្តីអញគួរតែទៅ ។ កាលស្វាមីនោះ ចេញទៅអំពីផ្ទះដើម្បីប្រកបការងារនាងក៏ទុកដាក់បរិក្ខារក្នុងផ្ទះ ប្រាប់ដល់ភាពដែលខ្លួនទៅផ្ទះរបស់ត្រកូលដល់អ្នកជិតខាងហើយ ក៏ធ្វើដំណើរទៅ ។ លំដាប់នោះ បុរសនោះមកកាន់ផ្ទះមិនឃើញភរិយារបស់ខ្លួន ក៏សួរញាតិជិតខាង បានដំណឹងថានាងទៅកាន់ផ្ទះរបស់ត្រកូល ទើបប្រញាប់ទៅតាម ក៏បានទាន់ក្នុងរវាងផ្លូវ ។ ចំណែកសេដ្ឋីធីតានោះ ក៏បានប្រសូតបុត្តក្នុងរវាងផ្លូវនោះឯងស្វាមីនោះសួរថា នែនាងដ៏ចម្រើន នេះជាអ្វី ?

សេដ្ឋីធីតានោះក៏ពោលថា បុត្តម្នាក់កើតហើយ ។

ស្វាមីពោលថា ឥឡូវនេះ ពួកយើងនឹងធ្វើដូចម្តេច ?

ធីតារបស់សេដ្ឋីពោលថា ពួកយើងទៅកាន់ផ្ទះរបស់ត្រកូល ដើម្បីប្រយោជន៍ដល់កម្មណា កម្មនោះ បានសម្រេចហើយក្នុងរវាងផ្លូវ ពួកយើងទៅទីនោះ ធ្វើអ្វី ? ពួកយើងនាំគ្នាត្រឡប់ចុះ ។ ជនទាំងពីរជាអ្នកមានការគិតតែមួយដូចគ្នាយ៉ាងនេះហើយ ក៏នាំគ្នាត្រឡប់ ព្រោះទារកនោះកើតក្នុងរវាងផ្លូវ ទើបមាតាបិតាដាក់ឈ្មោះថា បន្ថកៈ មិនយូរប៉ុន្មាន

នាងក៏មានគភ៌ទៀត រឿងរ៉ាវទាំងពួងគប្បីឲ្យពិស្តារដោយន័យមុននោះឯង ។ ព្រោះទារកទាំងនោះកើតក្នុងរវាងផ្លូវ ទើបមាតាបិតាដាក់ឈ្មោះបុត្តដែលកើតដំបូងថា **មហាបន្ថកៈ** តាំងឈ្មោះបុត្តទី ២ ថា **ចុល្លបន្ថកៈ** ស្វាមីភរិយានោះ ពទារកទាំងពីរមកកាន់លំនៅរបស់ខ្លួនវិញ ។ កាលស្វាមីភរិយាទាំងពីរនោះ នៅក្នុងទីនោះ មហាបន្ថកទារកបានស្តាប់ក្មេងដទៃៗ និយាយថា ពូ អ៊ំ លោកតា លោកយាយ ទើបសួរមាតាថា

បពិត្រអ្នកម៉ែ ពួកក្មេងដទៃៗ ហៅថា ពូ អ៊ំ លោកតា លោកយាយ ញាតិរបស់យើងមិនមានទេឬ ?

មាតាពោលថា នែបា ក្នុងទីនេះ ញាតិរបស់ពួកយើងមិនមានទេ តែក្នុងនគររាជគ្រឹះ ពួកយើងមានជីតាឈ្មោះថា **មហាធនសេដ្ឋី** ញាតិរបស់ពួកយើងមានច្រើន ក្នុងនគររាជគ្រឹះនោះ ។

មហាបន្ថកៈសួរថា ព្រោះហេតុអ្វី ទើបពួកយើងមិនទៅកាន់នគររាជគ្រឹះ ? នាងមិនប្រាប់ហេតុដែលខ្លួនមកដល់បុត្ត កាលបុត្តទាំងពីររំអុកសួររឿងនេះ ទើបពោលនឹងស្វាមីថា ក្មេងនេះធ្វើឲ្យយើងលំបាកពន់ពេក មាតាបិតាឃើញពួកយើងហើយ នឹងស៊ីសាច់ឬ ? មកពួកយើងនឹងនាំកុមារនេះ ទៅបង្ហាញដល់ត្រកូលជីតា ។

ស្វាមីពោលថា យើងមិនអាចទៅជួបមុខ តែយើងនឹងនាំទៅ ។

ភរិយាពោលថា ប្រពៃហើយ ពួកក្មេងៗ គួរតែឃើញត្រកូលរបស់

ជីតានោះដោយវិធីណាមួយ ។ ជនទាំងពីរនោះ នាំទារកទាំងពីរទៅដល់នគររាជគ្រឹះដោយលំដាប់ ហើយស្នាក់នៅក្នុងសាលាមួយកន្លែងក្បែរទ្វារនគរ ហើយឲ្យប្រាប់មាតាបិតាដល់ការដែលខ្លួននាំទារកទាំងពីរមក ។ ជីដូននិងជីតាបានស្ដាប់ដំណឹងនោះហើយ ពោលថា មនុស្សឈ្មោះថាមិនមែនជាបុត្ត មិនមែនជាធីតា រមែងមិនមានដល់យើងទាំងឡាយក្នុងសង្សារវដ្ដ ជនទាំងនេះ បានធ្វើខុសច្រើនដល់ពួកយើង ពួកគេមិនអាចតាំងនៅក្នុងគន្លងចក្ខុរបស់ពួកយើងបានទេ ជនទាំងពីរចូរកាន់យកទ្រព្យមានប្រមាណប៉ុណ្ណេះ ទៅកាន់ទីផាសុកចិញ្ចឹមជីវិតចុះ តែចូរបញ្ជូនទារកទាំងពីរនោះមកក្នុងទីនេះ ។ សេដ្ឋីធីតាក៏កាន់យកទ្រព្យដែលមាតាបិតាបញ្ជូនមក ហើយទុកទារកទាំងពីរក្នុងដៃពួកជនដែលនាំទ្រព្យមកនោះ ។ ទារកទាំងពីរក៏ចម្រើនធំធាត់ក្នុងត្រកូលរបស់ជីតា ។ បណ្ដាទារកទាំងពីរនោះ ចុល្លបន្ថក:នៅក្មេង ចំណែកមហាបន្ថក:ទៅស្ដាប់ធម្មកថារបស់ព្រះមានព្រះភាគជាមួយជីតា ។ កាលមហាបន្ថក:នោះ ស្ដាប់ធម៌ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដាជានិច្ច ចិត្តក៏បង្អោនទៅដើម្បីបួស ទើបពោលនឹងជីតាថា បពិត្រលោកតា បើលោកតាយល់ព្រម ខ្ញុំនឹងបួស ។

ជីតាពោលថា ចៅនិយាយអ្វី ចៅជាទីស្រឡាញ់របស់តា ការបួសចំពោះរបស់ចៅប៉ុណ្ណោះ ល្អជាងការបួសរបស់មនុស្សក្នុងលោកទាំងមូល បើចៅអាច ក៏ចូរបួសចុះ ។ កាលទទួលពាក្យហើយ ក៏ទៅកាន់សម្នាក់

របស់ព្រះសម្មាសម្ពុទ្ធ ។ ព្រះបរមសាស្តា ទ្រង់ត្រាស់ថា នែលោកសេដ្ឋី លោកមានទារកឬ ?

មហាសេដ្ឋីក្រាបទូលថា ករុណាព្រះអង្គ ទារកនេះ ជាចៅរបស់ខ្ញុំព្រះអង្គទេ ចៅនេះនិយាយថា នឹងបួសក្នុងសម្នាក់របស់ព្រះអង្គ ។

ព្រះបរមសាស្តា ទ្រង់ប្រើភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តមួយរូបថា **ឥមំ ទារកំ បព្វាជេហិ** អ្នកចូរឲ្យទារកនេះបួស ។ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់មហាបន្ថកៈនោះ ហើយឲ្យបួស ។ មហាបន្ថកៈនោះ រៀនពុទ្ធវចនៈជាច្រើន មានវស្សាគ្រប់បរិបូណ៌ហើយបានឧបសម្បទា ធ្វើកម្មដ្ឋានដោយយោនិសោមនសិការ សម្រេចអរហត្តហើយ ។ ព្រះមហាបន្ថកៈនោះ សម្ងំនៅក្នុងឈានសុខ មគ្គសុខ និងផលសុខ ទើបគិតថា អញអាចឬទេហ្ន៎ ដើម្បីធ្វើសេចក្តីសុខនេះដល់ចុល្លបន្ថកៈ ។ លំដាប់នោះ ព្រះមហាបន្ថកៈ ក៏ទៅកាន់សម្នាក់របស់សេដ្ឋីដែលជាជីតា ហើយពោលថា លោកសេដ្ឋី បើលោកយល់ព្រមអាត្មានឹងឲ្យចុល្លបន្ថកៈបួស ។

មហាសេដ្ឋីពោលថា ចូរឲ្យគេបួសចុះ លោកម្ចាស់ ។ ព្រះថេរៈឲ្យចុល្លបន្ថកទារកបួស ហើយឲ្យតាំងនៅក្នុងសីល ១០ ។ សាមណេរចុល្លបន្ថកៈនោះ បួសហើយប៉ុណ្ណោះ ក៏បានជាបុគ្គលល្ងង់ខ្លៅ សមដូចលោកពោលទុកថា អស់កាល ៤ ខែ ក៏មិនអាចរៀនគាថាមួយចាំបាន

*គាថានោះមានសេចក្តីថា*

**បទុមំ យថា កោកនុទំ[១] សុគន្ធំ**
**ចាតោ សិយា ផុល្លមវីតគន្ធំ**
**អង្គីរសំ បស្ស វិរោចមានំ**
**តបន្តមាទិច្ចមិវន្តលិក្ខេតិ ។**

*ផ្កាឈូកឈ្មោះកោកនទៈ មានក្លិនក្រអូប រីកអំពីព្រឹក មានក្លិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើលព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គ ដ៏រុងរឿងដូច ព្រះអាទិត្យដែលរុងរឿង ក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង[២] ។*

*បានឮមកថា ព្រះចុល្លបន្ថកៈនោះ បួសក្នុងសាសនាព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ ជាអ្នកមានបញ្ញាវាងវៃ បានសើចចំអកក្នុងវេលាដែលភិក្ខុល្ងង់ខ្លៅមួយរូបរៀនឧទ្ទេស ភិក្ខុនោះ ខ្មាសព្រោះការសើចចំអកនោះ ក៏លះបង់ គឺឈប់រៀនឧទ្ទេសនោះ មិនធ្វើការស្វាធ្យាយ ព្រោះកម្មនោះ ទើបចុល្លបន្ថកៈនេះ គ្រាន់តែបួសប៉ុណ្ណោះ ក៏ក្លាយទៅជាបុគ្គលល្ងង់ខ្លៅ កាលលោករៀនបទដែលសល់ខាងមុខ បទដែលរៀនហើយ ក៏ភ្លេចអស់ទៅ កាលចុល្លបន្ថកៈនោះ ព្យាយាមរៀនគាថានេះ អស់កាល*

---

*១- ច្បាប់មហាចុឡានិងច្បាប់ឆដ្ឋសង្គាយនាជា* **កោកនទំ** *។ ២- បិ.៤៥, ទំ. ២២៣ ។*

៤ ខែ ក៏ពុំអាចចាំបាន ។ លំដាប់នោះ ព្រះមហាបន្ថកៈ ក៏ចាប់ទាញចុល្លបន្ថកៈនោះចេញអំពីវិហារ ហើយពោលថា នែចុល្លបន្ថកៈ អ្នកជាអភព្វបុគ្គលក្នុងសាសនានេះ ព្រោះអស់កាល ៤ ខែ មិនអាចរៀនគាថាមួយបាន អ្នកនឹងធ្វើកិច្ចរបស់បព្វជិតឲ្យដល់ទីបំផុត បានដូចម្តេច ចូរចេញពីវិហារនេះចុះ ។ ព្រះចុល្លបន្ថកៈនោះ មិនប្រាថ្នាភាពជាគ្រហស្ថ ព្រោះស្រឡាញ់ក្នុងព្រះពុទ្ធសាសនា ។ គ្រានោះ ព្រះមហាបន្ថកៈបានជាភត្តុទ្ទេសកៈ ( អ្នកចែកភត្ត ) ។ ពេទ្យជីវកោមារភច្ចកាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម ដ៏ច្រើនសន្ធឹកសន្ធាប់ទៅកាន់អម្ពវ័នរបស់ខ្លួន បូជាព្រះបរមសាស្តា ស្តាប់ធម៌ហើយក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយចូលទៅរកព្រះមហាបន្ថកៈ សួរថា បពិត្រលោកម្ចាស់ ក្នុងសម្នាក់របស់ព្រះសាស្តា មានភិក្ខុប៉ុន្មានអង្គ ?

ព្រះមហាបន្ថកៈពោលថា មានភិក្ខុប្រមាណ ៥០០ អង្គ ។

ពេទ្យជីវកៈពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ស្អែកនេះ សូមលោកម្ចាស់ឲ្យភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាប្រធាន ដើម្បីទទួលភិក្ខារក្នុងនិវេសន៍របស់ខ្ញុំ ។

ព្រះថេរៈពោលថា ឧបាសក ចុល្លបន្ថកៈជាបុគ្គលល្ងង់ខ្លៅ មានធម៌មិនដុះដាល អាត្មាសូមវៀរចុល្លបន្ថកៈនោះចេញ ។ ព្រះចុល្លបន្ថកៈបានស្តាប់ឮពាក្យនោះហើយ គិតថា បងប្រុសរបស់អញ កាលទទួល

និមន្តន៍ដើម្បីភិក្ខុទាំងឡាយមានប្រមាណប៉ុណ្ណោះ ក៏ទទួលបាន ទុកអញនៅខាងក្រៅមិនរាប់បញ្ចូល បងប្រុសរបស់អញអស់ក្តីស្រឡាញ់ក្នុងអញដោយឥតសង្ស័យ ឥឡូវនេះ ប្រយោជន៍អ្វីដោយការបួសក្នុងសាសនា អញនឹងសឹកទៅជាគ្រហស្ថ ធ្វើបុណ្យមានទានជាដើម ដល់អស់ជីវិតចុះ ។ ស្អែកឡើង ព្រះចុល្លបន្ថកៈនោះក្រោកឡើងអំពីព្រលឹម ដោយគិតថា នឹងសឹកជាគ្រហស្ថ ។ ក្នុងពេលទៀបភ្លឺ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកសន្និវាស ទ្រង់ឃើញហេតុនោះហើយ ទើបយាងទៅមុន ទ្រង់ប្រថាប់ឈរហើយចង្ក្រមក្បែរខ្លោងទ្វារ ជិតផ្លូវដែលចុល្លបន្ថកៈទៅ ចុល្លបន្ថកៈកាលដើរទៅកាន់ផ្ទះ ឃើញព្រះមានព្រះភាគ ទើបចូលទៅគាល់ហើយថ្វាយបង្គំ ។ លំដាប់នោះ ព្រះបរមសាស្តា ត្រាស់នឹងចុល្លបន្ថកៈនោះថា ម្នាលចុល្លបន្ថកៈ តើអ្នកទៅណាក្នុងពេលនេះ ?

ព្រះចុល្លបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសរបស់ខ្ញុំព្រះអង្គអូសខ្ញុំព្រះអង្គចេញ ដោយហេតុនោះ ទើបខ្ញុំព្រះអង្គទៅដោយគិតថានឹងសឹកជាគ្រហស្ថ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលចុល្លបន្ថកៈ ឈ្មោះថា ការបួសរបស់អ្នកក្នុងសម្នាក់របស់តថាគត អ្នកត្រូវបងប្រុសអូសចេញទៅ ព្រោះហេតុអ្វីទើបមិនមកកាន់សម្នាក់របស់តថាគត មកប្រយោជន៍អ្វីដោយភាពជាគ្រហស្ថ អ្នកនៅក្នុងសម្នាក់របស់តថាគតនេះហើយ ។ ទ្រង់នាំ

ព្រះចុល្លបន្ថកៈទៅ ឲ្យព្រះចុល្លបន្ថកៈនោះ អង្គុយត្រង់យ៉មុខព្រះគន្ធកុដិ ហើយត្រាស់ថា ម្នាលចុល្លបន្ថកៈ អ្នកចូរបែរមុខទៅកាន់ទិសខាងកើត ចូរនៅក្នុងទីនេះ អង្អែលកំណាត់សំពត់នេះ ហើយបរិកម្មថា **រជោហរណំ រជោហរណំ** សំពត់ជាគ្រឿងនាំធូលីទៅ សំពត់ជាគ្រឿងនាំធូលីទៅ ហើយទ្រង់ប្រទានសំពត់ស្អាតបរិសុទ្ធ ដែលទ្រង់និម្មិតដោយឫទ្ធិ ។ កាលជនទាំងឡាយក្រាបទូលកត្តកាលឲ្យទ្រង់ជ្រាប ទើបទ្រង់ចោមរោម ដោយភិក្ខុសង្ឃ យាងទៅកាន់និវេសន៍របស់ពេទ្យជីវកៈ គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ ចំណែកព្រះចុល្លបន្ថកៈសម្លឹងមើលព្រះអាទិត្យ អង្អែលកំណាត់សំពត់នោះ បរិកម្មថា **រជោហរណំ រជោហរណំ** ។ កាលព្រះចុល្លបន្ថកៈអង្អែលសំពត់នោះ សំពត់ក៏សៅហ្មងប្រឡាក់ដោយញើសនិងក្អែល បន្ទាប់អំពីនោះ ព្រះចុល្លបន្ថកៈក៏គិតថា កំណាត់សំពត់នេះ ដើមឡើយបរិសុទ្ធ ជាសំពត់ស្អាតល្អ តែព្រោះអាស្រ័យអត្តភាពនេះ ទើបលះប្រក្រតីហើយសៅហ្មងយ៉ាងនេះ សង្ខារទាំងឡាយមិនទៀងហ្ន៎ ទើបផ្ដើមវិបស្សនា ចម្រើននូវការអស់ទៅសូន្យទៅ ។ ព្រះបរមសាស្ដាទ្រង់ជ្រាបថា ចិត្តរបស់ចុល្លបន្ថកៈឡើងកាន់វិបស្សនាហើយ ទើបត្រាស់ថា ម្នាលចុល្លបន្ថកៈ អ្នកកុំធ្វើសេចក្ដីសម្គាល់ថា សំពត់នោះប៉ុណ្ណោះជារបស់សៅហ្មងដោយធូលី តែធូលីគឺរាគៈជាដើមនេះ មាននៅខាងក្នុង ចូរអ្នកនាំធូលីគឺរាគៈជាដើមនោះចេញទៅ ហើយទ្រង់បញ្ចេញឱភាស

គឺព្រះរូបកាយរបស់ព្រះអង្គឲ្យប្រាកដ ដូចប្រថាប់គង់អំពីខាងមុខ បាន ត្រាស់ព្រះគាថានេះថា

រាគោ រជោ ន ច បន រេណូ វុច្ចតិ
រាគស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។

ធូលី គឺរាគៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីទុំះ ជាឈ្មោះនៃរាគៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

ទោសោ រជោ ន ច បន រេណុ វុច្ចតិ
ទោសស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។

ធូលី គឺទោសៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីទុំះ ជាឈ្មោះនៃទោសៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីទុំះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនានៃព្រះពុទ្ធ ដែលប្រាសចាកធូលី ។

មោហោ រជោ ន ច បន រេណុ វុច្ចតិ
មោហាស្សេតំ អធិវចនំ រជោតិ
ឯតំ រជំ វិប្បជហិត្វ បណ្ឌិតា
វិហរន្តិ តេ វិគតរជស្ស សាសនេ ។

ធូលី គឺ មោហៈ មិនមែនសំដៅយកលំអងទេ ពាក្យថាធូលីនុ៎ះ ជាឈ្មោះនៃមោហៈ បណ្ឌិតទាំងនោះ រមែងលះបង់នូវធូលីនុ៎ះ ហើយសម្រាកសម្រាន្តនៅ ក្នុងសាសនានៃព្រះពុទ្ធដែលប្រាសចាកធូលី[១] ។

ក្នុងវេលាចប់ព្រះគាថា ព្រះចុល្លបន្ថកៈ សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ បិដកទាំង ៣ ក៏មកដល់ព្រម ដល់ព្រះចុល្លបន្ថកៈនោះ មួយអន្លើដោយបដិសម្ភិទាទាំងឡាយនោះឯង ។ បានឮថា ក្នុងកាលមុន ព្រះចុល្លបន្ថកៈនោះជាព្រះរាជាកំពុងប្រទក្សិណនគរ កាលព្រះសេទោហូរចេញមកត្រង់ព្រះនលាដ ទើបយកសំពត់សាដកដែលស្អាតបរិសុទ្ធជូតព្រះនលាដ សំពត់សាដកនោះ ក៏សៅហ្មងទៅ ព្រះរាជានោះ ទ្រង់បាននូវអនិច្ចសញ្ញា គឺការសម្គាល់ថាមិនទៀងដូច្នេះថា សំពត់សាដកបរិសុទ្ធបែបនេះ គង់លះប្រក្រតីដើម សៅហ្មង

១- បិ.៦៦ , ទំ. ៣៣៤ ។

ព្រោះអាស្រ័យកាយនេះ ឱ សង្ខារទាំងឡាយមិនទៀងហ្ន៎ ដោយហេតុនោះ ទើបសំពត់នាំធូលីចេញទៅប៉ុណ្ណោះ កើតជាបច្ច័យដល់ព្រះចុល្ល-បន្ថកៈនោះ ។ ចំណែកពេទ្យជីវកោមារភច្ច នាំទក្ខិណោទកចូលទៅថ្វាយព្រះទសពល ព្រះសាស្ដា ទ្រង់យកព្រះហស្ដបិទបាត្រហើយត្រាស់ថា ម្នាលជីវកៈ ក្នុងវិហារមានភិក្ខុនៅសេសសល់ មិនមែនឬ ?

ព្រះមហាបន្ថកៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងវិហារមិនមានភិក្ខុទេ ?

ព្រះមានព្រះភាគត្រាស់ថា ម្នាលជីវក មាន ។ ពេទ្យជីវកក៏បញ្ជូនមនុស្សទៅដោយប្រាប់ថា នែអ្នក បើយ៉ាងនោះ ចូរអ្នកទៅ ហើយចូរដឹងថា ក្នុងវិហារមានភិក្ខុ ឬមិនមាន ។ ខណៈនោះ ព្រះចុល្លបន្ថកៈគិតថា បងប្រុសរបស់អញពោលថា ក្នុងវិហារមិនមានភិក្ខុ អញនឹងប្រកាសភាពដែលភិក្ខុទាំងឡាយមានក្នុងវិហារ ដល់បងប្រុសរបស់អញ គិតដូច្នេះហើយ ព្រះចុល្លបន្ថកៈក៏ញុំាងអម្ពវ័នទាំងមូល ឲ្យពេញដោយភិក្ខុទាំងឡាយ ភិក្ខុមួយពួកធ្វើចីវរកម្ម ភិក្ខុមួយពួកជ្រលក់ចីវរ ភិក្ខុមួយពួកធ្វើការស្វាធ្យាយ ។ ព្រះថេរៈនិម្មិតភិក្ខុ ១ ពាន់អង្គដូចៗ គ្នាយ៉ាងនេះ បុរសនោះ ឃើញភិក្ខុច្រើនសន្ធឹកសន្ធាប់នៅក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា បពិត្រលោកម្ចាស់ អម្ពវ័នទាំងមូលពេញដោយភិក្ខុទាំងឡាយនោះឯង ។ សមដូចព្រះថេរៈពោលទុកក្នុងថេរគាថាថា

សហស្សក្ខត្តុំ អត្តានំ និម្មិនិត្វាន បន្ថកោ
និសីទិ អម្ពវនេ រម្មេ យាវ កាលប្បវេទនំ ។

*បន្ថកភិក្ខុនិម្មិតខ្លួនជាមួយពាន់ ហើយអង្គុយក្នុងអម្ពវ័ន*
*ជាទីរីករាយ ដរាបដល់ការប្រាប់នូវភត្តកាល [១] ។*

*លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងបុរសនោះថា ចូរអ្នកទៅកាន់វិហារពោលថា ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅភិក្ខុឈ្មោះថា ចុល្ល-បន្ថកៈ ។ កាលបុរសនោះ ទៅពោលយ៉ាងនោះហើយ មាត់ទាំងពាន់ក៏ពោលថា អាត្មាឈ្មោះចុល្លបន្ថកៈ អាត្មាឈ្មោះចុល្លបន្ថកៈ ។ បុរសនោះទៅក្រាបទូលព្រះសាស្តាវិញថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងអស់នោះ សុទ្ធតែឈ្មោះចុល្លបន្ថកៈ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បើយ៉ាងនោះ អ្នកចូរចាប់ដៃភិក្ខុដែលពោលមុនគេថា អាត្មាឈ្មោះចុល្លបន្ថកៈ ភិក្ខុដ៏សេសទាំងអស់នឹងអន្តរធានទៅ ។ បុរសនោះបានធ្វើយ៉ាងនោះហើយ រំពេចនោះឯង ភិក្ខុប្រមាណ ១ ពាន់រូបក៏អន្តរធានទៅ ព្រះថេរៈបានទៅជាមួយបុរសនោះក្នុងពេលស្រេចភត្តកិច្ច ព្រះសាស្តាត្រាស់ហៅពេទ្យជីវកមកថា ជីវក ចូរអ្នកទទួលបាត្ររបស់ចុល្លបន្ថកៈ ចុល្លបន្ថកៈនេះនឹងធ្វើអនុមោទនាដល់*

---

*១- បិ. ៥៧ , ទំ. ២០ ។*

អ្នក ។ ពេទ្យជីវកក៏បានធ្វើតាមនោះ ព្រះថេរៈបន្លឺសីហនាទដូចរាជសីហ៍ ជំទង់ ញ៉ាំងបិដកទាំង ៣ ឲ្យកក្រើក ធ្វើអនុមោទនា ។ ព្រះបរមសាស្ដា ទ្រង់ក្រោកឡើងចាកអាសនៈ មានភិក្ខុសង្ឃជាបរិវារយាងទៅកាន់វិហារ កាលភិក្ខុទាំងឡាយសម្ដែងវត្តហើយ ទ្រង់ក៏ក្រោកចាកអាសនៈ ប្រថាប់ ឈរត្រង់យ៉មុខព្រះគន្ធកុដិ ប្រទានសុគតោវាទដល់ភិក្ខុសង្ឃ ហើយ ត្រាស់ប្រាប់កម្មដ្ឋាន ទ្រង់បញ្ជូនភិក្ខុសង្ឃទៅ ហើយយាងចូលកាន់ព្រះ គន្ធកុដិដែលប្រកបដោយក្លិនក្រអូប ទ្រង់ចូលសីហសេយ្យា ដោយព្រះ បង្អៀងស្ដាំ ។ លុះដល់ពេលល្ងាច ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយដូចបាំងដោយវាំងននសំពត់កម្ពលក្រហម ប្រារព្ធរឿងគុណរបស់ ព្រះដ៏មានព្រះភាគថា នែអាវុសោទាំងឡាយ ព្រះមហាបន្ថកៈមិនដឹង អធ្យាស្រ័យរបស់ព្រះចុល្លបន្ថកៈ មិនអាចឲ្យលោករៀនគាថា ១ អស់ កាល ៤ ខែ អូសលោកចេញអំពីវិហារដោយពោលថា ចុល្លបន្ថកៈនេះ ល្ងង់ខ្លៅ តែព្រះសម្មាសម្ពុទ្ធទ្រង់បានប្រទានអរហត្ត មួយអន្លើដោយបដិ-សម្ភិទាដល់ព្រះចុល្លបន្ថកៈនោះ ក្នុងរវាងភត្តប៉ុណ្ណោះ ព្រោះព្រះអង្គជា ព្រះធម្មរាជាដ៏កំពូល បិដកទាំង ៣ មួយអន្លើដោយបដិសម្ភិទា ក៏ប្រាកដ ដល់ព្រះចុល្លបន្ថកៈ គួរអស្ចារ្យហ្ន៎ ឈ្មោះថា កម្លាំងរបស់ព្រះសម្មាសម្ពុទ្ធ ធំក្រៃលែង ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបការប្រព្រឹត្តទៅ របស់រឿងនេះក្នុងរោងធម្មសភា ទ្រង់ព្រះតម្រិះយ៉ាងនេះថា ថ្ងៃនេះ

តថាគតគួរទៅ ទើបទ្រង់ក្រោកចាកអាសនៈ ទ្រង់ស្លៀកសំពត់ពីរជាន់ពណ៌ក្រហម ចងវត្ថពន្ធចង្កេះដូចផ្លេកបន្ទោរ ទ្រង់ដណ្តប់ព្រះសុគតចីវរដូចគ្នានឹងសំពត់កម្ពលក្រហម ទ្រង់យាងចេញអំពីព្រះគន្ធកុដិទៅកាន់រោងធម្មសភា ដោយលីលាដូចដំរីចុះប្រេងដ៏ប្រសើរ និងដូចរាជសីហ៍ដោយពុទ្ធលីលា មិនមានទីបំផុត ទ្រង់ឡើងកាន់បវរពុទ្ធាសនៈដែលគេក្រាលទុក បញ្ចេញព្រះរស្មីមានពណ៌ ៦ ប្រការ ដូចទ្រង់ញុំាងសមុទ្រឲ្យរញ្ជួយ ក្នុងកាលដែលព្រះអាទិត្យបញ្ចេញរស្មីដ៏ស្រទន់ លើកំពូលភ្នំយុគន្ធរដូច្នោះ ទ្រង់គង់កណ្តាលអាសនៈនោះ កាលព្រះទសពលទ្រង់គង់ស្រេចហើយ ភិក្ខុសង្ឃទាំងឡាយក៏នៅស្ងៀម ។ ព្រះសាស្តា ទ្រង់ទតបរិស័ទដោយមេត្តាចិត្តដ៏ទន់ ទ្រង់ព្រះតម្រិះថា បរិស័ទនេះ ល្អពន់ពេកការឃ្មើសឃ្មងដោយដៃ ជើង ឬសំឡេងក្អក កណ្តាស់ជាដើម របស់ភិក្ខុសូម្បីតែមួយរូបក៏មិនមាន ភិក្ខុទាំងឡាយនេះគោរពក្នុងតថាគតក្រៃលែងត្រូវតែជះតថាគតគំរាម បើតថាគតមិននិយាយអស់កាលមួយកប្ប ភិក្ខុទាំងនេះ ក៏នឹងមិនពោលពាក្យណាមួយឡើយ វត្តក្នុងកាលផ្តើមកថាតថាគតនឹងដឹង ល្មើយចុះ គួរតែតថាគតពោលមុន ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះសូរសៀងដូចសំឡេងព្រហ្មថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី រឿងអ្វីដែលពួកអ្នកសន្ទនាគ្នាក្នុងចន្លោះនេះ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយអង្គុយក្នុងទីនេះ មិនពោលតិរច្ឆានកថាដទៃ តែអង្គុយពណ៌នាអំពីគុណរបស់ទ្រង់ប៉ុណ្ណោះថា នៃអាវុសោទាំងឡាយ ព្រះមហាបន្ថកៈមិនដឹងអាធ្យាស្រ័យរបស់ចុល្លបន្ថកៈ មិនអាចឲ្យលោករៀនគាថាមួយអស់កាល ៤ ខែ ទាញលោកចេញអំពីវិហារហើយពោលថា នៃចុល្លបន្ថកៈ អ្នកល្ងង់ខ្លៅណាស់ តែព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានអរហត្តមួយអន្ទើដោយបដិសម្ភិទាដល់ព្រះចុល្លបន្ថកៈនោះ ក្នុងចន្លោះកត្តតែម្តងប៉ុណ្ណោះ ព្រោះទ្រង់ជាព្រះធម្មរាជដ៏កំពូល គួរអស្ចារ្យហ្ន៎ ឈ្មោះថាកម្លាំងរបស់ព្រះសម្ពុទ្ធទាំងឡាយធំក្រៃលែង ។

ព្រះមានព្រះភាគ ទ្រង់បានស្តាប់ពាក្យរបស់ភិក្ខុទាំងឡាយហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈអាស្រ័យតថាគតសម្រេចភាពជាធំក្នុងធម៌ទាំងឡាយ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនសូម្បីក្នុងកាលមុន ចុល្លបន្ថកៈនេះដល់នូវភាពជាធំក្នុងភោគទាំងឡាយព្រោះអាស្រ័យតថាគតដូចគ្នា ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះសាស្តា ដើម្បីទ្រង់ត្រាស់សម្តែងរឿងនោះឲ្យប្រាកដ ព្រះមានព្រះភាគទ្រង់បានធ្វើហេតុដែលអន្តរភេពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសី ។ ព្រះមហាសត្វ ទ្រង់បដិសន្ធិក្នុងត្រកូលសេដ្ឋី

ចម្រើនវ័យហើយបានទទួលតំណែងសេដ្ឋី មានឈ្មោះថា ចុល្លកសេដ្ឋី ចុល្លកសេដ្ឋីនោះជាបណ្ឌិត ឈ្លាសក្នុងការមើលនិមិត្តទាំងពួង ។ ថ្ងៃមួយ ចុល្លកសេដ្ឋីនោះ ទៅកាន់ទីបម្រើព្រះរាជា ឃើញកណ្ដុរងាប់ក្នុងវាំងផ្លូវ គន់គូរនក្ខត្តឫក្សក្នុងខណៈនោះ ហើយពោលពាក្យនេះថា កុលបុត្តដែលមានភ្នែកគឺបញ្ញា អាចយកកណ្ដុរនេះទៅធ្វើការចិញ្ចឹមបុត្ត ភរិយា និងប្រកបការងារបាន ។ កុលបុត្តទុគ៌តម្នាក់ឈ្មោះថា ចូឡន្តេវាសិក បានស្ដាប់ពាក្យរបស់សេដ្ឋីនោះហើយ គិតថា លោកសេដ្ឋីនេះ បើមិនដឹងពិតជាមិននិយាយឡើយ ទើបយកកណ្ដុរនោះទៅលក់ឯផ្សារ ដើម្បីជាអាហារដល់ឆ្មាបានទ្រព្យ ១ កាកណិកៈ ទើបទិញទឹកអំពៅដោយទ្រព្យ ១ កាកណិកៈនោះ ហើយយកឆ្នាំង ១ ដងទឹកទៅ ទុគ្គតបុរសឃើញអ្នកក្រងផ្កាចេញមកអំពីព្រៃ ទើបឲ្យទឹកអំពៅម្នាក់បន្តិច ហើយជូនទឹកពិសា ពួកអ្នកក្រងផ្កាទាំងនោះ ក៏បានឲ្យផ្កាម្នាក់មួយក្ដាប់ដល់ទុគ្គតបុរសនោះ ។ ស្អែកឡើង គាត់ក៏យកផ្កាទាំងនោះ ទៅដូរទឹកអំពៅនិងទឹកផឹកបាន ១ ក្អម ហើយក៏ទៅកាន់ឧទ្យានផ្កានោះឯង ពួកអ្នកក្រងផ្កាក៏បានឲ្យផ្កាម្នាក់កន្លះបាច់ដល់បុរសនោះ ហើយក៏ទៅ ។ មិនយូរប៉ុន្មាន បុរសនោះក៏សន្សំប្រាក់បាន ៨ កហាបណៈដោយឧបាយនេះ ។ ក្នុងថ្ងៃដែលមានភ្លៀងខ្យល់ខ្លាំង ដើមឈើងាប់ មែកឈើនិងស្លឹកឈើជាច្រើន ក្នុងព្រះរាជឧទ្យានរបស់ព្រះរាជាត្រូវខ្យល់កាច់បំបាក់ធ្លាក់ចុះមក អ្នកយាមឧទ្យាន

មិនឃើញឧបាយ បុរសនោះក៏ទៅកាន់ព្រះរាជឧទ្យាន ហើយពោលនឹងអ្នកយាមឧទ្យាននោះថា បើអ្នកឲ្យឈើនិងស្លឹកឈើទាំងនេះដល់ខ្ញុំ ខ្ញុំនឹងជញ្ជូនចេញ ។ អ្នករក្សាឧទ្យាននោះ ក៏ទទួលថា អើ ចូរអ្នកយកទៅចុះ ។ ចូឡន្តេវាសិកក៏ទៅកាន់ទីលានរបស់ក្មេងៗ ហើយឲ្យទឹកអំពៅដល់ក្មេងទាំងនោះផឹក ហើយសូមឲ្យក្មេងទាំងនោះ ជួយជញ្ជូនឈើនិងស្លឹកឈើ តែមួយសន្ទុះប៉ុណ្ណោះក៏ ( ជញ្ជូន ) អស់ ហើយឲ្យគរទុកត្រង់ទ្វារព្រះរាជឧទ្យាន ។ ក្នុងកាលនោះ ពួកស្មូនឆ្នាំងកំពុងដើររកឧសដើម្បីដុតភាជនៈដីសម្រាប់រាជត្រកូល ឃើញមែកឈើនិងស្លឹកឈើទាំងនោះត្រង់ទ្វារឧទ្យាន ទើបទិញអំពីដៃរបស់ចូឡន្តេវាសិកនោះ ។ ថ្ងៃនោះចូឡន្តេវាសិកបានទ្រព្យ ១៦ កហាបណៈនិងភាជនៈ ៥ មានឆ្នាំងដីជាដើមដោយការលក់ឈើនោះ មកទល់នឹងពេលនេះ ទុគ្គតបុរសនោះ មានទ្រព្យចំនួន ២៤ កហាបណៈ គាត់គិតថា អញមានឧបាយ ហើយក៏តម្កល់ក្អមទាំងនោះ ទុកក្នុងទីមិនឆ្ងាយអំពីទ្វារនគរ ដើម្បីផ្គត់ផ្គង់ដល់អ្នករែកស្មៅ និងអ្នកច្រូតស្មៅប្រមាណ ៥០០ នាក់ ដោយទឹកក្នុងក្អមនោះ អ្នករែកស្មៅទាំងនោះពោលថា នែសម្លាញ់ អ្នកមានឧបការៈច្រើនដល់ពួកយើង ពួកយើងនឹងធ្វើអ្វីដល់អ្នក ។ ចូឡន្តេវាសិកពោលថា កាលមានកិច្ចកើតឡើង សឹមអ្នកទាំងឡាយជួយខ្ញុំចុះ ហើយត្រាច់ទៅក្នុងទីផ្សេងៗ បានធ្វើនូវការស្និទ្ធស្នាលដោយភាពជាមិត្ត ជាមួយអ្នកធ្វើការ

ទាំងផ្លូវគោកនិងផ្លូវទឹក ។ អ្នកធ្វើការផ្លូវគោកប្រាប់ដល់ទុគ្គតបុរសនោះថា ស្អែកនេះ មានឈ្មួញសេះ ៥០០ នាក់មកកាន់នគរនេះ ។ ចូឡន្តេ-វាសិកបានស្តាប់ពាក្យរបស់អ្នកធ្វើការផ្លូវគោកនោះហើយ ទើបពោលនឹងពួកអ្នករែកស្មៅថា ថ្ងៃនេះ ចូរអ្នកឲ្យស្មៅដល់ខ្ញុំម្នាក់មួយបាច់ចុះ បើខ្ញុំមិនទាន់លក់ស្មៅ សូមអ្នកទាំងឡាយកុំលក់ឡើយ អ្នករែកស្មៅទាំងនោះទទួលថា សាធុ ហើយនាំយកស្មៅ ៥០០ បាច់ មកដាក់ត្រង់ទ្វារផ្ទះរបស់ចូឡន្តេវាសិកនោះ ។ ចំណែកឈ្មួញសេះទាំងនោះ កាលមិនបានអា-ហារសម្រាប់សេះក្នុងនគរទាំងមូល ទើបឲ្យទ្រព្យ ១០០ ដល់ចូឡន្តេវា-សិកនោះ ហើយកាន់យកស្មៅនោះទៅ ។ លុះកន្លងទៅបានពីរ-បីថ្ងៃ សម្លាញ់ដែលធ្វើការផ្លូវទឹក ក៏ប្រាប់ចូឡន្តេវាសិកថា មានទូកធំមកចតត្រង់កំពង់ហើយ ។ ចូឡន្តេវាសិកនោះគិតថា អញមានឧបាយ ទើបយកប្រាក់ ៨ កហាបណៈទៅជួលរថ ដែលដល់ព្រមដោយបរិវារទាំងពួង ហើយទៅកាន់កំពង់ទូកដោយយសធំ ឲ្យចិញ្ចៀនមួយវង់ដល់ម្ចាស់ទូក ហើយឲ្យបាំងវាំងននក្នុងទីមិនឆ្ងាយ ប្រាប់បរិវារថា កាលពួកឈ្មួញខាងក្រៅមក ពួកអ្នកចូរប្រាប់ដោយការពន្យារអស់កាល ៣ ដង ។ ឈ្មួញប្រមាណ ១០០ នាក់ មកអំពីនគរពារាណសីបានដំណឹងថា ទូកមកហើយ ទើបទៅកាន់កំពង់ហើយពោលថា ពួកយើងនឹងទិញយកទំនិញទាំងនេះ ។ នាយទូកពោលថា ពួកលោកមិនបានទំនិញទេ ព្រោះ

ឈ្មួញធំក្នុងទីឯណោះ បានកក់ទុកហើយ ។ ឈ្មួញទាំងនោះបានស្តាប់ដូច្នោះ ក៏ទៅកាន់សម្នាក់របស់ចូឡន្តេវាសិកនោះ អ្នកបម្រើដែលយាមខាងក្រៅបានប្រាប់ដល់ឈ្មួញទាំងនោះ មិនឲ្យចូលជួបអស់វារៈ ៣ ដង តាមចូឡន្តេវាសិកប្រាប់នោះឯង ឈ្មួញប្រមាណ ១០០ នាក់នោះ ឲ្យទ្រព្យម្នាក់ ១ ពាន់ ដើម្បីជាភាគហ៊ុនដល់ចូឡន្តេវាសិកនោះ ហើយឲ្យម្នាក់ ១ ពាន់ទៀត ដើម្បីឲ្យចូឡន្តេវាសិកនោះប្រគល់ទំនិញឲ្យ ហើយធ្វើទំនិញទាំងអស់នោះឲ្យជារបស់ខ្លួន ។ ចូឡន្តេវាសិកកាន់យកទ្រព្យ ២ សែនត្រឡប់មកកាន់នគរពារាណសីវិញ គិតថា អញគួរជាបុគ្គលដឹងគុណ ទើបជូនទ្រព្យ ១ សែនដល់ចុល្លកសេដ្ឋី ។ លំដាប់នោះ សេដ្ឋីពោធិសត្វសួរចូឡន្តេវាសិកនោះថា នែបា អ្នកធ្វើអ្វីទើបបានទ្រព្យនេះ ?

ចូឡន្តេវាសិកឆ្លើយថា ខ្ញុំតាំងនៅក្នុងឧបាយដែលលោកប្រាប់ ទើបបានទ្រព្យនេះ ក្នុងកាល ៤ ខែប៉ុណ្ណោះ ហើយក៏ប្រាប់រឿងរ៉ាវទាំងអស់តាំងអំពីរើសកណ្តុរងាប់យកទៅលក់ជាដើមទៅ ។ ចុល្លកមហាសេដ្ឋីបានស្តាប់ពាក្យរបស់ចូឡន្តេវាសិកនោះហើយគិតថា ឥឡូវនេះ អញនឹងធ្វើទារកនេះឲ្យជារបស់អញ ទើបគួរ ទើបឲ្យធីតារបស់ខ្លួនដែលមានវ័យចម្រើនហើយ ធ្វើជនទាំងពីរឲ្យជាម្ចាស់ទ្រព្យ ។ កាលចុល្លកសេដ្ឋីអនិច្ចកម្មទៅ ចូឡន្តេវាសិកក៏បានតំណែងសេដ្ឋីក្នុងនគរនោះ ។ ឯព្រះបរមពោធិសត្វ ក៏បានទៅតាមយថាកម្ម ។

*ព្រះសម្មាសម្ពុទ្ធ កាលទ្រង់ត្រាស់ព្រះធម្មទេសនានេះហើយ ទ្រង់ត្រាស់ដឹងហើយ ទើបទ្រង់ត្រាស់ព្រះគាថានេះថា*

**អប្បកេន បិ មេធាវី ចាភដេន វិចក្ខណោ**

**សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមន្តិ ។**

*អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើម*

*ទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។*

*បណ្តាបទទាំងនោះ បទថា* **អប្បកេន បិ** *ប្រែថា សូម្បីតិចតួច គឺបន្តិចបន្តួច ។ បទថា* **មេធាវី** *ប្រែថា អ្នកមានបញ្ញា ។*

*បទថា* **ចាភដេន** *បានដល់ ដោយដើមទុននៃទំនិញ ។ បទថា* **វិចក្ខណោ** *បានដល់ ដែលឈ្លាសក្នុងវោហារ ។*

*បទថា* **សមុដ្ឋាបេតិ អត្តានំ** *សេចក្តីថា ញុំាងទ្រព្យនិងយសធំឲ្យកើតឡើងហើយដល់ខ្លួន គឺញុំាងខ្លួនឲ្យតាំងនៅក្នុងទ្រព្យនិងយសនោះ ។*

*សួរថា ដូចអ្វី?*

*ឆ្លើយថា ដូចបុគ្គលបង្កាត់ភ្លើងតូចឲ្យជាគំនរធំ អធិប្បាយថា បុរសដែលជាបណ្ឌិត ដាក់គោម័យនិងកម្ទេចឈើតូចៗ ហើយផ្លុំដោយបបូរមាត់ បង្កាត់ភ្លើងតូចមួយឲ្យឆេះឡើង គឺឲ្យចម្រើនឡើង បានដល់ធ្វើឲ្យជាគំនរធំដោយលំដាប់ យ៉ាងណា បណ្ឌិតក៏ដូច្នោះដូចគ្នា បានទ្រព្យដែលជាដើមទុន សូម្បីតិចតួចហើយប្រកបឧបាយផ្សេងៗ រមែងធ្វើទ្រព្យ*

និងយសឲ្យកើតឡើង គឺឲ្យចម្រើនឡើង កាលឲ្យចម្រើនឡើងហើយ ក៏តម្កល់ខ្លួនក្នុងទ្រព្យនិងយសនោះ ឬរមែងតាំងខ្លួនទុក គឺធ្វើឲ្យដឹង គឺឲ្យប្រាកដ ព្រោះភាពជាធំក្នុងទ្រព្យនិងយសនោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងព្រះធម្មទេសនាយ៉ាងនេះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុល្លបន្ថកៈអាស្រ័យតថាគតដល់នូវភាពជាធំក្នុងធម៌នៃធម៌ទាំងឡាយ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន អាស្រ័យតថាគតក៏ដល់នូវភាពជាធំក្នុងភោគៈព្រោះភោគៈទាំងឡាយដែរ ហើយត្រាស់រឿងទាំងពីរ បន្តអនុសន្ធិប្រជុំជាតកថា ចូឡន្តេវាសិក ក្នុងកាលនោះ បានមកជាចុល្លបន្ថកៈក្នុងកាលឥឡូវនេះ ចំណែកចុល្លកមហាសេដ្ឋីក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ចុល្លកសេដ្ឋិជាតក ទី ៤ ។

# អដ្ឋកថា តណ្ឌុលនាឡិជាតក ទី ៥

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះលោឡុទាយិត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កិមគ្ឃតី តណ្ឌុលនាឡិកា ច** ដូច្នេះជាដើម ។

សម័យនោះ ព្រះទព្វមល្លបុត្តបានជាភត្តុទ្ទេសកៈរបស់សង្ឃ កាលព្រះទព្វមល្លបុត្តនោះ សម្តែងសលាកភត្តជាដើម អំពីព្រលឹម ជួនកាលភត្តល្អ ក៏ធ្លាក់ដល់ព្រះលោឡុទាយិត្ថេរ ជួនកាលភត្តអាក្រក់ ក៏ធ្លាក់ដល់លោក ។ ក្នុងថ្ងៃដែលបានភត្តអាក្រក់ ព្រះលោឡុទាយិត្ថេរនោះ ក៏ធ្វើរោងស្លាកឲ្យរឹករវ ហើយពោលថា ព្រះទព្វៈប៉ុណ្ណោះឬ ដែលចេះឲ្យស្លាក យើងមិនចេះឲ្យឬ? កាលព្រះលោឡុទាយីនោះ ធ្វើរោងស្លាកឲ្យរឹករវ ភិក្ខុទាំងឡាយបានឲ្យល្អីស្លាកដោយពាក្យថា ណ្ហើយចុះ អាវុសោ ចូរលោកឲ្យស្លាក ។ ចាប់តាំងអំពីពេលនោះមក ព្រះលោឡុទាយីនោះ ក៏បានឲ្យស្លាកដល់សង្ឃ កាលឲ្យមិនដឹងថា នេះភត្តល្អ ឬភត្តអាក្រក់ ឬមិនដឹងថា ភត្តល្អតម្កល់ទុកក្នុងរោងឆាន់នោះ ភត្តអាក្រក់តម្កល់ទុកក្នុងរោងឆាន់នោះ រមែងមិនកំណត់ថា បញ្ជីសម្តែងចំនួនក្នុងរោងនោះមានសភាពយ៉ាងនេះ ក្នុងវេលាដែលភិក្ខុទាំងឡាយឈរ ក៏គូសចំណាំត្រង់ផែនដី ឬត្រង់ជញ្ជាំង មានការឲ្យដឹងថា ក្នុងទីនេះ បញ្ជីដែលតាំងលំដាប់នេះ ត្រឹមនេះ ក្នុងទីនេះ បញ្ជីដែលតាំងលំដាប់នេះ ត្រឹមនេះ ។

ស្មើកឡើង ក្នុងរោងស្លាកមានភិក្ខុតិចជាងខ្លះ ច្រើនជាងខ្លះ កាលភិក្ខុទាំងឡាយនោះតិចជាង ស្នាមគំនូសក៏ទាប កាលភិក្ខុទាំងឡាយច្រើនជាង ស្នាមគំនូសក៏ខ្ពស់ ព្រះលោឡុទាយីនោះ កាលមិនដឹងបញ្ញើដែលតាំងលំដាប់ ទើបឲ្យស្លាកទៅតាមកំណត់សម្គាល់ដែលគូសចំណាំនោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ពោលនឹងលោកថា នែអាវុសោលោឡុទាយី ធម្មតាស្នាមគំនូសទាបឬខ្ពស់ក៏ដោយចុះ តែភត្តល្អតាំងនៅត្រង់រោងនោះ ភត្តអាក្រក់តាំងនៅត្រង់រោងនោះ ។ ព្រះលោឡុទាយីនោះ កាលឆ្លើយតបនឹងភិក្ខុទាំងឡាយក៏ពោលថា បើយ៉ាងនោះ ព្រោះហេតុអ្វីទើបស្នាមគំនូសតាំងនៅយ៉ាងនេះ យើងជឿពួកលោកបានដូចម្តេច យើងជឿតាមស្នាមគំនូសនេះប៉ុណ្ណោះ ។ លំដាប់នោះ ភិក្ខុកំលោះនិងសាមណេរទាំងឡាយក៏ពោលនឹងលោកថា អាវុសោលោឡុទាយី កាលលោកឲ្យស្លាក ភិក្ខុទាំងឡាយសាបសូន្យចាកលាភ លោកមិនសមគួរជាអ្នកចែកស្លាក ចូរចេញពីរោងស្លាក ហើយក៏អូសលោកចេញអំពីរោងស្លាក ខណៈនោះ ក្នុងរោងស្លាកក៏មានការរឹករវរធំ ។

ព្រះបរមសាស្តា ទ្រង់បានស្តាប់ឮសំឡេងនោះ ទើបត្រាស់សួរព្រះអានន្ទថា ម្នាលអានន្ទ ក្នុងរោងស្លាកមានសំឡេងអ៊ូអរ តើជាសំឡេងអ្វី ? ព្រះថេរៈក៏ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលអានន្ទ លោឡុទាយីធ្វើនូវការវិនាសលាភឲ្យដល់ភិក្ខុដទៃ

ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏បានធ្វើហើយដូចគ្នា ។ កាលព្រះថេរៈក្រាបទូលអារាធនាព្រះមានព្រះភាគ ដើម្បីទ្រង់ត្រាស់សម្តែងរឿងនោះឲ្យជាក់ច្បាស់ ទើបទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសី ។ ក្នុងកាលនោះ ព្រះពោធិសត្វនៃយើងទាំងឡាយ បានជាអាមាត្យអ្នកវាយតម្លៃរបស់ព្រះបាទព្រហ្មទត្តនោះ បានវាយតម្លៃដំរី សេះ កែវមណី មួយអន្ទើដោយមាសជាដើម កាលវាយតម្លៃហើយ ឲ្យមូលតម្លៃតាមសមគួរដល់ភណ្ឌៈនោះ ដល់ម្ចាស់ភណ្ឌៈទាំងឡាយ តែព្រះរាជាទ្រង់ជាបុគ្គលល្មោភ ព្រោះភាពជាអ្នកប្រាថ្នាច្រើន ទើបទ្រង់ត្រិះរិះយ៉ាងនេះថា អាមាត្យអ្នកវាយតម្លៃនេះ វាយតម្លៃយ៉ាងនេះ មិនយូរប៉ុន្មាន ទ្រព្យក្នុងវាំងរបស់អញនឹងដល់នូវការអស់ទៅ អញនឹងតែងតាំងបុគ្គលដទៃឲ្យជាអ្នកវាយតម្លៃជំនួស ។ ព្រះរាជា ទ្រង់បើកសីហបញ្ជរទតមើលលានព្រះរាជវាំង ឃើញបុរសអ្នកស្រុកម្នាក់ដែលជាមនុស្សឡេះឡោះនិងល្ងង់ខ្លៅ ទើបទ្រង់ព្រះតម្រិះថា បុរសនេះអាចធ្វើការងារក្នុងតំណែងជាអ្នកវាយតម្លៃរបស់អញបាន ទើបត្រាស់ឲ្យហៅបុរសនោះចូលមក ហើយត្រាស់ថា នែអ្នក អ្នកអាចធ្វើការក្នុង

តំណែងជាអ្នកវាយតម្លៃរបស់យើង បានដែរឬទេ ?

បុរសនោះក្រាបទូលថា ករុណាថ្លៃវិសេស ទូលបង្គំអាច ។ ព្រះរាជា ទ្រង់តាំងបុរសនោះ ទុកក្នុងតំណែងជាអ្នកវាយតម្លៃដើម្បីរក្សាទ្រព្យរបស់ព្រះអង្គ តាំងអំពីនោះមក បុរសល្ងង់ខ្លៅនោះ កាលវាយតម្លៃដំរីនិងសេះជាដើម ពោលវាយតម្លៃតាមគាប់ចិត្តរបស់ខ្លួន ធ្វើឲ្យខូចតម្លៃព្រោះបុរសនោះតាំងនៅក្នុងតំណែង គាត់ពោលពាក្យណា ពាក្យនោះឯងជាតម្លៃនៃភណ្ឌៈទាំងឡាយ ។ គ្រានោះ មានឈ្មួញសេះម្នាក់ នាំសេះ ៥០០ មកអំពីដែនឧត្តរាបថៈ ព្រះរាជាត្រាស់ឲ្យហៅបុរសនោះមកវាយតម្លៃសេះ បុរសនោះបានតាំងតម្លៃសេះ ៥០០ ដោយអង្ករ ១ នាឡិកាលវាយតម្លៃហើយ ទើបពោលថា អ្នកទាំងឡាយចូរឲ្យអង្ករ ១ នាឡិដល់ឈ្មួញសេះនេះ ហើយឲ្យយកសេះទៅចងទុកក្នុងរោងសេះ ។ ឈ្មួញសេះក៏បានទៅកាន់សម្នាក់អាមាត្យអ្នកវាយតម្លៃចាស់ ប្រាប់រឿង-រ៉ាវនោះហើយសួរថា ឥឡូវនេះ តើខ្ញុំគួរធ្វើដូចម្តេច ?

ព្រះពោធិសត្វដែលជាអ្នកវាយតម្លៃអំពីមុននោះពោលថា អ្នកទាំងឡាយ ចូរឲ្យសំណូកដល់បុរសនោះ ហើយសួរយ៉ាងនេះថា សេះទាំងឡាយរបស់ពួកខ្ញុំមានតម្លៃស្មើនឹងអង្ករ ១ នាឡិ សេចក្តីនេះ ពួកខ្ញុំដឹងហើយ តែខ្ញុំបំណងនឹងដឹងតម្លៃរបស់អង្ករ ១ នាឡិ ព្រោះអាស្រ័យលោក តើលោកអាចឈរក្នុងសម្នាក់របស់ព្រះរាជាហើយពោលថា អង្ករ

១ នាឡិនេះ មានតម្លៃប៉ុណ្ណេះបានឬទេ ? បើបុរសនោះពោលថា អាច ពួកអ្នកចូរនាំគ្នាទៅកាន់សម្នាក់របស់ព្រះរាជា ឯខ្ញុំក៏នឹងទៅទីនោះដែរ ។ ឈ្មួញសេះទទួលពាក្យរបស់ព្រះពោធិសត្វហើយ ក៏ឲ្យសំណូកដល់អ្នកវាយតម្លៃនោះ រួចប្រាប់សេចក្ដីនោះ ។ អ្នកវាយតម្លៃនោះ គ្រាន់តែបានសំណូកប៉ុណ្ណោះ ក៏ពោលថា យើងអាចវាយតម្លៃអង្ករ ១ នាឡិរបស់អ្នកបាន ។ ឈ្មួញសេះពោលថា បើដូច្នោះ ពួកយើងចូរនាំគ្នាទៅកាន់រាជត្រកូល ហើយបាននាំអ្នកវាយតម្លៃនោះទៅកាន់សម្នាក់ព្រះរាជា ព្រះពោធិសត្វក្ដី អាមាត្យដទៃជាច្រើនក្ដី បាននាំគ្នាទៅហើយ ។ ឈ្មួញសេះថ្វាយបង្គំព្រះរាជាហើយទូលសួរថា បពិត្រព្រះសម្មតិទេព ទូលបង្គំជ្រាបថាសេះ ៥០០ មានតម្លៃស្មើគ្នានឹងអង្ករ ១ នាឡិ តែអង្ករ ១ នាឡិនេះមានតម្លៃប៉ុនណាទៅហ្ន៎ បពិត្រព្រះសម្មតិទេព សូមទ្រង់សួរអ្នកវាយតម្លៃរបស់ទ្រង់ចុះ ។ ព្រះរាជាទ្រង់មិនជ្រាបការប្រព្រឹត្តទៅនោះ ទើបត្រាស់សួរថា លោកដ៏ចម្រើន សេះ ៥០០ មានតម្លៃប៉ុន្មាន ?

អ្នកវាយតម្លៃក្រាបទូលថា មានតម្លៃស្មើនឹងអង្ករ ១ នាឡិ ។

ព្រះរាជាត្រាស់ថា ណ្ហើយចុះ សេះទាំងឡាយមានតម្លៃស្មើនឹងអង្ករ ១ នាឡិ (យើងដឹងហើយ) តែអង្ករ ១ នាឡិនេះ មានតម្លៃប៉ុនណា?

បុរសល្ងង់នោះក្រាបទូលថា អង្ករ ១ នាឡិនេះ មានតម្លៃស្មើនឹងនគរពារាណសីទាំងខាងក្នុង និងខាងក្រៅ ។ បានឮថា ក្នុងកាលមុន

បុរសល្ងង់នោះ ធ្វើតាមព្រះរាជា ទើបបានវាយតម្លៃសេះទាំងឡាយដោយអង្ករ ១ នាឡិ លុះបានសំណូកអំពីដៃរបស់ឈ្មួញ ក៏ត្រឡប់ជាវាយតម្លៃនគរពារាណសីទាំងខាងក្នុងនិងខាងក្រៅ ដោយតម្លៃត្រឹមអង្ករ ១ នាឡិប៉ុណ្ណោះ ។ ក្នុងកាលនោះ នគរពារាណសីមានកំពែងព័ទ្ធជុំវិញ ប្រមាណ ១២ យោជន៍ ដែនទាំងខាងក្នុងនិងខាងក្រៅទាំងអស់ទំហំ ៣០០ យោជន៍ បុរសល្ងង់នោះ បានវាយតម្លៃនគរពារាណសីទាំងខាងក្នុងនិងខាងក្រៅដ៏ធំយ៉ាងនេះ ដោយអង្ករ ១ នាឡិប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វបានស្តាប់ពាក្យនោះ កាលនឹងសាកសួរ ទើបពោលគាថានេះថា

**កិមគ្ឃតី តណ្ឌុលនាឡិកា ច**
**ពារាណសីអន្តរពាហិរានិ**
**អស្សបញ្ចសតេតានិ ឯកា តណ្ឌុលនាឡិកាតិ ។**

អង្ករមួយនាឡិ ថ្លៃ ( ស្មើនឹង ) ក្រុងពារាណសី ទាំងខាងក្នុង
ទាំងខាងក្រៅ ឬ (ស្មើនឹង ) សេះ ៥០០ នេះ ថ្លៃត្រឹមតែអង្ករ
១ នាឡិ ទេឬ ។

អាមាត្យទាំងឡាយបានស្តាប់ដូច្នោះ ទើបនាំគ្នាទះដៃសើចចំអកថា កាលមុនពួកយើងមានការសម្គាល់ថា ផែនដីនិងរាជសម្បត្តិមានតម្លៃកាត់ថ្លៃមិនបាន ( ឥឡូវនេះ ) បានឮថា រាជសម្បត្តិក្នុងនគរពារាណសី

*មួយអន្ទើដោយព្រះរាជាដែលជាធំយ៉ាងនេះ មានតម្លៃត្រឹមតែអង្ករ ១ នាឡិ ឱ ការដល់ព្រមរបស់ភ្នាក់ងារវាយតម្លៃ អ្នកជាភ្នាក់ងារវាយតម្លៃតាំងនៅអស់កាលមានប្រមាណប៉ុណ្ណោះក្នុងទីណា អ្នកសមគួរដល់ព្រះរាជារបស់ពួកយើងហើយ ។ គ្រានោះ ព្រះរាជាទ្រង់ខ្មាស ឲ្យអូសបុរសល្ងង់នោះចេញទៅ ហើយព្រះរាជទានតំណែងវាយតម្លៃដល់ព្រះបរមពោធិសត្វដូចមុន ។ ព្រះពោធិសត្វ ( រស់នៅដរាបដល់អស់ជីវិតហើយ ) ក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដា ទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់រឿងពីរបន្តអនុសន្ធិគ្នា ហើយទ្រង់ប្រជុំជាតកថា ភ្នាក់ងារវាយតម្លៃដែលជាអ្នកស្រុកល្ងង់ខ្លៅក្នុងកាលនោះ បានមកជាលោឡុទាយីក្នុងកាលឥឡូវនេះ ចំណែកអ្នកវាយតម្លៃដែលជាបណ្ឌិតក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា តណ្ឌុលនាឡិជាតក ទី ៥ ។

# អដ្ឋកថា ទេវធម្មជាតក ទី ៦

ព្រះមានព្រះភាគ កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលមានភណ្ឌៈច្រើន ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ហិរិឱត្តប្បសម្បន្នា** ដូច្នេះជាដើម ។

បានឮថា កុដុម្ពិកៈអ្នកនគរសាវត្ថីម្នាក់ កាលភរិយាស្លាប់ហើយក៏បួស កុដុម្ពិកៈនោះកាលបួស បានឲ្យធ្វើបរិវេណ រោងភ្លើង និងបន្ទប់សម្រាប់ដាក់ភណ្ឌៈ ធ្វើបន្ទប់សម្រាប់ដាក់របស់របរ ផ្ទុកដោយសប្បិ និងអង្ករជាដើមសម្រាប់ខ្លួនហើយទើបបួស កាលបួសហើយហៅទាសៈរបស់ខ្លួនមក ឲ្យចម្អិនអាហារតាមគាប់ចិត្តហើយបរិភោគ បានជាអ្នកមានបរិក្ខារច្រើន ក្នុងវេលាយប់ មានសំពត់ស្លៀកនិងសំពត់ដណ្ដប់មួយផ្ទាំង ក្នុងវេលាថ្ងៃ មានសំពត់ស្លៀកនិងសំពត់ដណ្ដប់មួយផ្ទាំង អាស្រ័យសេនាសនៈខាងចុងវិហារ ។ ថ្ងៃមួយ កាលភិក្ខុនោះនាំចីវរ និងគ្រឿងកម្រាលជាដើម ចេញមកហាលត្រង់បរិវេណ ភិក្ខុអ្នកជនបទជាច្រើន នាំគ្នាត្រាច់ចារិកទៅតាមសេនាសនៈ ដល់បរិវេណឃើញចីវរជាដើម ទើបសួរថា ចីវរជាដើមនេះ ជារបស់អ្នកណា?

ភិក្ខុនោះឆ្លើយថា ជារបស់ខ្ញុំ អាវុសោ ។

ភិក្ខុទាំងនោះសួរថា ចីវរនេះក្ដី សំពត់ស្លៀកក្ដី កម្រាលនេះក្ដី ទាំងអស់នេះ ជារបស់លោកម្នាក់ឯងប៉ុណ្ណោះឬ ?

ភិក្ខុនោះពោលថា ករុណាលោកម្ចាស់ ជារបស់ខ្ញុំប៉ុណ្ណោះ ។

ភិក្ខុទាំងឡាយពោលថា អាវុសោ ព្រះមានព្រះភាគទ្រង់អនុញ្ញាតចីវរ ៣ មិនមែនឬ ? លោកបួសក្នុងសាសនារបស់ព្រះពុទ្ធដែលជាបុគ្គលប្រាថ្នាតិចយ៉ាងនេះ បែរជាអ្នកមានបរិក្ខារច្រើន មកពួកយើងទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ហើយនាំភិក្ខុនោះទៅកាន់សម្នាក់របស់ព្រះទសពល ។ ព្រះសាស្តា កាលទ្រង់ឃើញភិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំភិក្ខុដែលមិនប្រាថ្នានេះ មកហើយឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា ករុណាព្រះអង្គ ភិក្ខុនេះមានភណ្ឌៈច្រើន មានបរិក្ខារច្រើន ។

ព្រះសាស្តាត្រាស់សួរថា នែភិក្ខុ បានឮថា អ្នកមានភណ្ឌៈច្រើនពិតឬ ?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយ ព្រះអង្គ ។

ព្រះបរមសាស្តាត្រាស់សួរថា ម្នាលភិក្ខុ ព្រោះហេតុអ្វីទើបអ្នកជាបុគ្គលមានភណ្ឌៈច្រើន តថាគតពោលគុណរបស់ការប្រាថ្នាតិច ការសន្តោស ការស្ងប់ស្ងាត់ និងការប្រារព្ធសេចក្តីព្យាយាម មិនមែនឬ ? ភិក្ខុនោះ បានស្តាប់ព្រះតម្រាស់របស់ព្រះសាស្តាក៏ក្រោធខឹង គិតថាឥឡូវនេះ អញនឹងត្រាច់ទៅដោយទំនងនេះ ហើយក៏ដោះសំពត់ដណ្តប់

មានចីវរមួយផ្ទាំង ( ស្បៀកតែស្បង់ ) ឈរក្នុងកណ្តាលបរិស័ទ ។ លំដាប់នោះ ព្រះលោកនាយក កាលទ្រង់ឧបត្ថម្ភភិក្ខុនោះ ទើបត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន កាលអ្នកជាអារក្សទឹក អ្នកបានស្វែងរកហិរិឱត្តប្បៈ កាលអ្នកស្វែងរកហិរិឱត្តប្បៈនោះ អស់ ១២ ឆ្នាំ បើដូច្នោះ ព្រោះហេតុអ្វីទើបឥឡូវនេះ អ្នកបួសក្នុង ( ព្រះពុទ្ធ ) សាសនាដែលជាទីគោរពដ៏ក្រៃលែងយ៉ាងនេះ បែរជាដោះសំពត់ដណ្តប់ក្នុងកណ្តាលបរិស័ទ ហើយលះហិរិឱត្តប្បៈឈរនៅយ៉ាងនេះ ? ភិក្ខុនោះ បានស្តាប់ព្រះតម្រាស់របស់ព្រះមានព្រះភាគហើយ ក៏ញុំាងហិរិឱត្តប្បៈឲ្យតាំងឡើង ដណ្តប់ចីវរនោះវិញ ថ្វាយបង្គំព្រះទសពលហើយអង្គុយក្នុងចំណែកម្ខាង ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះតថាគត ដើម្បីទ្រង់ត្រាស់សម្តែងរឿងនោះឲ្យជាក់ច្បាស់ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល មានព្រះរាជា ១ អង្គព្រះនាមថា ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ដែនកាសី ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វបដិសន្ធិក្នុងព្រះគភ៌អគ្គមហេសី របស់ព្រះបាទព្រហ្មទត្តនោះ កាលគ្រប់ទសមាសព្រះនាងក៏ប្រសូតព្រះឱរស ក្នុងថ្ងៃថ្វាយព្រះនាម ព្រះញាតិទាំងឡាយក៏បានថ្វាយព្រះនាមថា **មហិសាសកុមារ** ក្នុងកាលដែលមហិសាសកុមារនោះ ទ្រង់ចេះរត់លេងបាន ព្រះឱរសអង្គ

ដទៃក៏ប្រសូត ព្រះញាតិទាំងឡាយក៏តាំងព្រះនាមឱរសបន្ទាប់នោះថា **ចន្ទកុមារ** ។ ក្នុងវេលាដែលចន្ទកុមារនោះ ចេះរត់លេងបាន ព្រះមាតារបស់ព្រះពោធិសត្វក៏សោយព្រះទិវង្គត ព្រះរាជា ទ្រង់តែងតាំងស្ត្រីដទៃ ក្នុងតំណែងអគ្គមហេសី ។ អគ្គមហេសីនោះ បានជាទីស្រឡាញ់ ជាទីពេញព្រះរាជហឫទ័យរបស់ព្រះរាជា អគ្គមហេសីនោះអាស្រ័យការនៅរួមជាមួយព្រះរាជាក៏ប្រសូតបានព្រះឱរសមួយអង្គ ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមព្រះរាជឱរសនោះថា **សុរិយកុមារ** ។ ព្រះរាជាទ្រង់ឃើញព្រះឱរសហើយ មានព្រះរាជហឫទ័យត្រេកអរត្រាស់ថា

នែនាងដ៏ចម្រើន យើងឲ្យពរដល់បុត្ររបស់នាង ។

អគ្គមហេសីក្រាបទូលថា ខ្ញុំម្ចាស់នឹងសូម ក្នុងកាលដែលខ្ញុំម្ចាស់ត្រូវការ ។ កាលព្រះឱរសចម្រើនវ័យហើយ ព្រះនាងក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ក្នុងកាលដែលឱរសរបស់ខ្ញុំម្ចាស់ប្រសូត ទ្រង់បានប្រទានពរទុកហើយ មិនមែនឬ ? សូមទ្រង់ព្រះរាជទានរាជសម្បត្តិឲ្យដល់ឱរសរបស់ខ្ញុំម្ចាស់ ។

ព្រះរាជាត្រាស់ថា ព្រះរាជឱរសរបស់យើងទាំងទ្វេ រុងរឿងដូចគំនរភ្លើង យើងមិនអាចឲ្យរាជសម្បត្តិដល់ឱរសរបស់នាងបានទេ ។ កាលព្រះទេវីនោះអង្វររឿយៗ ទ្រង់ព្រះតម្រិះថា ស្ត្រីនេះ គប្បីធ្វើនូវកម្មដ៏លាមកដល់ឱរសទាំងពីររបស់អញក៏បាន ទើបត្រាស់ឲ្យហៅព្រះរាជ

ឱរសទាំងពីរមក ហើយត្រាស់ថា នែបាទាំងទ្វេ ក្នុងកាលដែលសុរិយ-កុមារប្រសូត ឪពុកបានឲ្យពរ ឥឡូវនេះ មាតារបស់សុរិយកុមារនោះទូលសូមរាជសម្បត្តិ ឪពុកមិនមានបំណងឲ្យរាជសម្បត្តិដល់សុរិយកុមារនោះ ធម្មតាមាតុគ្រាមជាបុគ្គលលាមក អាចធ្វើរឿងលាមកដល់បាទាំងពីរ ព្រោះដូច្នោះ ចូរបាទាំងពីរចូលទៅកាន់ព្រៃ អំណឹះតតអំពីបិតាទៅសឹមត្រឡប់មកយករាជសម្បត្តិក្នុងនគរដែលជារបស់ត្រកូល ហើយគ្រប់គ្រងចុះ ។ ព្រះរាជាត្រាស់ហើយ ទ្រង់ព្រះកន្សែងយំរៀបរាប់ ថើបសីសៈបុត្តទាំងពីរ ហើយបញ្ជូនទៅ ។ សុរិយកុមារកំពុងលេងត្រង់លានព្រះរាជវាំង ឃើញព្រះរាជឱរសទាំងពីរនោះថ្វាយបង្គំព្រះរាជបិតាចុះអំពីប្រាសាទ ក៏គិតថា អញក៏នឹងទៅជាមួយបងទាំងពីរ ទើបចេញទៅព្រមជាមួយព្រះរាជឱរសទាំងពីរនោះឯង ។ ព្រះរាជឱរសទាំង ៣ អង្គនោះយាងចូលទៅកាន់ព្រៃហិមពាន្ត ។ ព្រះពោធិសត្វគេចចុះអំពីផ្លូវ គង់ត្រង់គល់ឈើហៅសុរិយកុមារមកថា នែសុរិយៈ ចូរបាទៅកាន់ស្រះនោះងូត ផឹក ហើយយកស្លឹកឈូកខ្ចប់ទឹកផឹកមក ដើម្បីយើងទាំងពីរផង ។ ឯស្រះនោះ ជាស្រះដែលអារក្សទឹកបានបញ្ជាអំពីសម្នាក់ព្រះបាទវេស្ស-វ័ណនោះមកថា ចូរអ្នកស៊ីមនុស្សនិងសត្វដែលចុះកាន់ស្រះនេះ វៀរលែងតែបុគ្គលដែលចេះទេវធម៌ប៉ុណ្ណោះ អ្នកមិនអាចស៊ីបុគ្គលដែលមិនចុះបានឡើយ ។ តាំងអំពីពេលនោះមក អារក្សទឹកនោះ ក៏សួរទេវធម៌

ដល់មនុស្សដែលចុះក្នុងស្រះនោះ ហើយស៊ីមនុស្សដែលមិនចេះទេវធម៌ ។ លំដាប់នោះ សុរិយកុមារទៅកាន់ស្រះនោះ មិនបានពិចារណាក៏ជ្រុលចុះទៅ ។ លំដាប់នោះ អារក្សទឹកក៏ចាប់សុរិយកុមារនោះ ហើយសួរថា

**ទេវធម្មេ ជានាសិ** តើអ្នកចេះទេវធម៌ដែរឬ ?

សុរិយកុមារនោះឆ្លើយថា **អាម ជានាមិ ទេវធម្មា នាម ចន្ទិមសុរិយា** អើ ខ្ញុំចេះ ព្រះចន្ទនិងព្រះអាទិត្យឈ្មោះថា ទេវធម៌ ។ លំដាប់នោះ អារក្សទឹកក៏ពោលនឹងសុរិយកុមារនោះថា អ្នកមិនស្គាល់ទេវធម៌ ហើយក៏ចាប់សុរិយកុមារនោះ នាំទៅកាន់លំនៅរបស់ខ្លួន ។ ចំណែកព្រះមហាសត្វ កាលមិនឃើញសុរិយកុមារនោះត្រឡប់មកវិញ ក៏បញ្ជូនចន្ទកុមារទៅ ។ អារក្សទឹកក៏ចាប់ចន្ទកុមារនោះ ហើយសួរថា

តើអ្នកដឹងទេវធម៌ដែរឬ ?

ចន្ទកុមារពោលថា **អាម ជានាមិ ទេវធម្មា នាម ចតស្សោ ទិសា** អើយើងដឹង ទិសទាំង ៤ ឈ្មោះថា ទេវធម៌ ។

អារក្សទឹកពោលថា អ្នកមិនស្គាល់ទេវធម៌ ហើយក៏នាំចន្ទកុមារនោះទៅទុកក្នុងលំនៅរបស់ខ្លួននោះឯង ។ កាលចន្ទកុមារយឺតយូរ ព្រះពោធិសត្វគិតថា អន្តរាយឯណានីមួយគប្បីមាន ទើបយាងទៅកាន់ស្រះនោះដោយព្រះអង្គឯង ឃើញស្នាមជើងចុះរបស់ព្រះអនុជទាំងពីរ ទើបគិតថា ស្រះនេះ ជាស្រះដែលមានអារក្សទឹកហួងហែង ទើបសៀត

ព្រះខ័នកាន់ធ្នូ ហើយឈរក្នុងទីនោះ ។ អារក្សទឹកឃើញព្រះពោធិសត្វមិនចុះ ទើបកាឡាខ្លួនដូចជាបុរសដែលធ្វើការក្នុងព្រៃ ពោលនឹងព្រះពោធិសត្វថា នែបុរសដ៏ចម្រើន អ្នកហត់នឿយក្នុងរវាងផ្លូវ ព្រោះហេតុអ្វីក៏មិនចុះក្នុងស្រះនេះ ងូត ផឹក បរិភោគក្រឡឹឈូក ប្រដាប់ផ្កាឈូកតាមសប្បាយទៅ ?

ព្រះពោធិសត្វឃើញដូច្នោះ ក៏ដឹងថា បុរសនេះជាយក្ស ទើបសួរថា អ្នកចាប់ប្អូនប្រុសរបស់យើងឬ ?

អារក្សទឹកឆ្លើយថា អើ ខ្ញុំចាប់ ។

ព្រះមហាបុរសសួរថា ព្រោះហេតុអ្វី ?

អារក្សទឹកឆ្លើយថា ខ្ញុំរមែងបានមនុស្សដែលចុះកាន់ស្រះនេះ ។

ព្រះពោធិសត្វសួរថា អ្នករមែងបានមនុស្សទាំងអស់ឬ ?

អារក្សទឹកឆ្លើយថា ខ្ញុំបានទាំងអស់ វៀរលែងតែបុគ្គលដែលចេះទេវធម៌ប៉ុណ្ណោះ ។

ព្រះមហាសត្វសួរថា អ្នកមានសេចក្តីត្រូវការដោយទេវធម៌ឬ?

អារក្សទឹកឆ្លើយថា អើ ខ្ញុំមានសេចក្តីត្រូវការ ។

ព្រះពោធិសត្វត្រាស់ថា បើដូច្នោះ ខ្ញុំនឹងប្រាប់ទេវធម៌ដល់អ្នក ។

យក្សពោលថា បើដូច្នោះ សូមអ្នកប្រាប់មកចុះ ខ្ញុំនឹងចាំស្តាប់ ។

ព្រះពោធិសត្វត្រាស់ថា តែខ្ញុំមានខ្លួនស្មោកគ្រោក ។ យក្សក៏ឲ្យ

ព្រះពោធិសត្វផ្ងូតទឹក ឲ្យផឹក ឲ្យប្រដាប់ផ្កា ឲ្យលាបស្រលាបដោយគ្រឿងក្រអូប ក្រាលបល្ល័ង្កក្នុងកណ្តាលបារាំដែលប្រដាប់តាក់តែងហើយ ព្រះពោធិសត្វគង់លើអាសនៈ ឲ្យយក្សអង្គុយទៀបជើងហើយត្រាស់ថា បើយ៉ាងនោះ ចូរអ្នកផ្ទៀងនូវត្រចៀកស្តាប់ដោយគោរព ហើយត្រាស់ព្រះគាថានេះថា

**ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា**
**សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេតិ ។**

ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិនិងឱតប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថាមានទេវធម៌ក្នុងលោក ។

បណ្តាបទទាំងនោះ បទថា **ហិរិឱត្តប្បសម្បន្នា** ប្រែថា បុគ្គលប្រកបដោយហិរិនិងឱត្តប្បៈ ។ បណ្តាហិរិនិងឱត្តប្បៈទាំងនោះ ដែលឈ្មោះថា ហិរិ ព្រោះខ្មាសចំពោះកាយទុច្ចរិតជាដើម ពាក្យថា ហិរិ នេះជាឈ្មោះនៃការខ្មាស ដែលឈ្មោះថា ឱត្តប្បៈ ព្រោះខ្លាចអំពីកាយទុច្ចរិតជាដើមនោះឯង ពាក្យថា ឱត្តប្បៈ នេះ ជាឈ្មោះនៃការខ្លាចចំពោះបាប ។ បណ្តាហិរិនិងឱត្តប្បៈនេះ ហិរិមានសមុដ្ឋានតាំងឡើងខាងក្នុង ឱត្តប្បៈមានសមុដ្ឋានតាំងឡើងខាងក្រៅ ហិរិមានខ្លួនជាធំ ឱត្តប្បៈមានលោកជាធំ ហិរិតាំងនៅក្នុងសភាវដែលគួរខ្មាស ឱត្តប្បៈតាំងនៅក្នុងសភាវៈ

ដែលគួរខ្មាច ហិរិមានលក្ខណៈកោតក្រែង ឱត្តប្បៈមានលក្ខណៈឃើញទោសនិងឃើញភ័យ ។ បណ្តាហិរិនិងឱត្តប្បៈនោះ បុគ្គលរមែងញ៉ាំងហិរិដែលមានសមុដ្ឋានជាខាងក្នុង ឲ្យតាំងឡើងដោយហេតុ ៤ ប្រការ គឺ ពិចារណាដល់ជាតិកំណើត ១ ពិចារណាដល់វ័យ ១ ពិចារណាដល់ភាពអង់អាច ១ ពិចារណាដល់ភាពជាពហុស្សូត ១ ។

សួរថា ពិចារណាដូចម្តេច ?

ឆ្លើយថា បុគ្គលពិចារណាដល់ជាតិកំណើតយ៉ាងនេះថា ឈ្មោះថាការធ្វើបាបនេះ មិនមែនជាកម្មរបស់បុគ្គលដែលសម្បូរដោយជាតិ ជាកម្មរបស់បុគ្គលដែលមានជាតិថោកថយ មានព្រានសន្ទូចជាដើម គប្បីធ្វើ បុគ្គលដែលសម្បូរដោយជាតិដូចអាត្មាអញ មិនគួរធ្វើនូវកម្មនេះ ហើយមិនធ្វើបាបមានបាណាតិបាតជាដើម ឈ្មោះថា ញ៉ាំងហិរិឲ្យតាំងឡើង ។ ម្យ៉ាងទៀត បុគ្គលពិចារណាដល់វ័យយ៉ាងនេះថា ឈ្មោះថាការធ្វើបាបនេះ ជាកម្មដែលមនុស្សកំលោះៗ គប្បីធ្វើ កម្មនេះ បុគ្គលដែលតាំងនៅក្នុងវ័យដូចអាត្មាអញមិនគួរធ្វើ ហើយមិនធ្វើនូវបាប មានសម្លាប់សត្វជាដើម ឈ្មោះថា ញ៉ាំងហិរិឲ្យតាំងឡើង ។ ម្យ៉ាងទៀត បុគ្គលពិចារណាដល់ភាពជាអ្នកអង់អាចយ៉ាងនេះថា ឈ្មោះថាការធ្វើបាបនេះ ជាកម្មរបស់បុគ្គលដែលមានភាពទន់ខ្សោយ កម្មនេះ បុគ្គលដែលសម្បូរដោយភាពអង់អាច ភាពក្លាហានដូចអាត្មាអញមិនគួរធ្វើ ហើយមិនធ្វើនូវបាប

មានសម្លាប់សត្វជាដើម ឈ្មោះថា ញុំាងហិរិឲ្យតាំងឡើង ។ មួយ៉ាងទៀត បុគ្គលពិចារណាដល់ភាពជាពហុស្សូតយ៉ាងនេះថា ឈ្មោះថា ការធ្វើបាបនេះជាកម្មរបស់ជនអន្ធពាល កម្មនេះបុគ្គលដែលជាពហុស្សូត គឺជាអ្នកចេះដឹងច្រើន ជាបណ្ឌិតដូចអាត្មាអញមិនគួរធ្វើ ហើយមិនធ្វើនូវបាប មានបាណាតិបាតជាដើម ឈ្មោះថា ញុំាងហិរិឲ្យតាំងឡើង បុគ្គលនោះ ឈ្មោះថា ញុំាងហិរិមានសមុដ្ឋានខាងក្នុងឲ្យតាំងឡើងដោយហេតុ ៤ ប្រការយ៉ាងនេះ កាលឲ្យតាំងឡើងហើយ នឹងឲ្យហិរិចូលទៅក្នុងចិត្តមិនធ្វើបាបដោយខ្លួនឯង ហិរិ រមែងឈ្មោះថា មានសមុដ្ឋានខាងក្នុងយ៉ាងនេះ ។

សួរថា ឱត្តប្បៈ មានសមុដ្ឋានខាងក្រៅដូចម្តេច ?

ឆ្លើយថា បុគ្គលពិចារណាថា បើអ្នកធ្វើបាបសោត អ្នកនឹងជាបុគ្គលត្រូវតិះដៀលក្នុងបរិស័ទ ៤ ថា វិញ្ញូជនទាំងឡាយនឹងតិះដៀលអ្នក ដូចអ្នកនគរតិះដៀលនូវរបស់មិនស្អាតថា នៃភិក្ខុ អ្នកជាបុគ្គល ( វៀរចាកបាប ) ដែលបុគ្គលមានសីលទាំងឡាយវៀរឆ្ងាយហើយ តើនឹងធ្វើ (បាប) ដូចម្តេច ដូច្នេះ ។ រមែងមិនធ្វើបាបកម្មព្រោះឱត្តប្បៈតាំងឡើងខាងក្រៅ ឱត្តប្បៈ រមែងឈ្មោះថា មានសមុដ្ឋានខាងក្រៅយ៉ាងនេះ ។

សួរថា ហិរិ ឈ្មោះថា មានខ្លួនជាធំដូចម្តេច ?

ឆ្លើយថា កុលបុត្តពួកខ្លះ ក្នុងលោកនេះ ធ្វើខ្លួនឲ្យជាធំ ឲ្យជាប្រធាន

មិនធ្វើបាបដោយគិតថា បុគ្គលដែលបួសដោយសទ្ធា ជាពហុស្សូត មានវាទៈ គឺប្រៀនប្រដៅក្នុងការកម្ចាត់កិលេសដូចអ្នក មិនគួរធ្វើបាបកម្ម ហិរិរមែងឈ្មោះថា មានខ្លួនជាធំយ៉ាងនេះ ដោយហេតុនោះ ទើបព្រះមាន-ព្រះភាគត្រាស់ថា

ភិក្ខុនេះ ធ្វើខ្លួនឯងឲ្យជាអាធិបតេយ្យហើយ រមែងលះបង់អកុ-សល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អត្តាធិបតេយ្យ [១] ។

សួរថា ឱត្តប្បៈ ឈ្មោះថា មានលោកជាធំ ( នោះ ) តើដូចម្ដេច ?

ឆ្លើយថា កុលបុត្តខ្លះ ក្នុងលោកនេះ ធ្វើលោកឲ្យជាធំ ឲ្យជាប្រធានហើយមិនធ្វើបាបកម្ម សមដូចព្រះតម្រាស់ដែលត្រាស់ទុកថា

លោកសន្និវាសនេះសោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នក

---

១-បិ.៤១ , ទំ.១១៤ ។

មើលកុលបុត្តនេះ ចេញចាកផ្ទះមកបួស ដោយសទ្ធាហើយ នៅតែប្រឫកប្រឫល់ ដោយធម៌ជាអកុសលដ៏លាមក ។ មួយទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្តនេះ ចេញចាកផ្ទះមកបួសដោយសទ្ធាហើយ នៅតែប្រឫកប្រឫល់ ដោយធម៌ជាអកុសលដ៏លាមក ។ ភិក្ខុនោះពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាម មិនឲ្យធូរថយ នឹងប្រុងសតិ មិនឲ្យវង្វេងភ្លេច ឲ្យកាយស្ងប់រម្ងាប់ មិនឲ្យធូរថយ ឲ្យចិត្តតម្កល់មាំ មានអារម្មណ៍តែមួយ ។ លុះភិក្ខុនោះ ប្រារព្ធលោកឲ្យជាអាធិបតេយ្យហើយ តែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា លោកាធិបតេយ្យ [១] ។

ក្នុងពាក្យថា ហិរិ តាំងនៅក្នុងសភាវៈខ្មាស ឱត្តប្បៈ តាំងនៅក្នុងសភាវៈខ្លាចនេះ មានវិនិច្ឆ័យដូចតទៅនេះថា

ការតាំងនៅក្នុងលជ្ជីធម៌ ឈ្មោះថា ហិរិ ហិរិតាំងនៅដោយសភាវៈ

១- បិ.៤១ , ទំ.១១៥ ។

នោះ ការខ្លាចចំពោះអបាយ ឈ្មោះថា ឱត្តប្បៈ ឱត្តប្បៈរមែងតាំងនៅដោយសភាវៈនោះ ហិរិនិងឱត្តប្បៈទាំងពីរនោះ រមែងប្រាកដក្នុងការវៀរចាកបាប ។ ពិតហើយ បុគ្គលខ្លះក្នុងលោកឈានចុះកាន់ធម៌ គឺការខ្មាសជាខាងក្នុងមិនធ្វើបាបកម្ម ដូចកុលបុត្ត កាលបន្ទោបង់ឧច្ចារៈបស្សាវៈជាដើម ឃើញបុគ្គលម្នាក់ដែលគួរខ្មាស គប្បីជាអ្នកដល់នូវការខ្មាស ត្រូវឧច្ចារៈឬបស្សាវៈបៀតបៀនដ៏ខ្លាំងក្លា ក៏មិនអាចបន្ទោបង់ឧច្ចារៈបស្សាវៈនោះបានដូច្នោះ បុគ្គលពួកខ្លះជាអ្នកខ្លាចភ័យក្នុងអបាយ ក៏មិនហ៊ានធ្វើបាបកម្ម ក្នុងសេចក្ដីនោះ មានឧបមាយ៉ាងនេះថា ដូចដុំដែកពីរដុំ មួយដុំត្រជាក់តែប្រឡាក់ទៅដោយលាមក មួយដុំក្ដៅឆេះដោយភ្លើង ក្នុងដុំដែកទាំងពីរនោះ បណ្ឌិតខ្ពើមរអើមមិនចាប់ដុំដែកត្រជាក់ ព្រោះខ្លាចប្រឡាក់លាមក មិនចាប់ដុំដែកក្ដៅព្រោះខ្លាចភ្លើងឆេះ យ៉ាងណា ក្នុងសេចក្ដីដែលពោលអំពីហិរិនិងឱត្តប្បៈនេះ ក៏ដូច្នោះ គប្បីជ្រាបការឈមចុះកាន់លជ្ជីធម៌ដែលជាខាងក្នុង ហើយមិនធ្វើបាបកម្ម ដូចបណ្ឌិតខ្ពើមនូវដុំដែកត្រជាក់ដែលប្រឡាក់លាមក ទើបមិនចាប់ និងគប្បីជ្រាបការមិនធ្វើបាប ព្រោះខ្លាចភ័យក្នុងអបាយ ដូចការដែលបណ្ឌិតមិនចាប់ដុំដែកក្ដៅ ព្រោះខ្លាចឆេះដូច្នោះ ។ បទទាំងពីរនេះ ហិរិ មានលក្ខណៈខ្មាស ឱត្តប្បៈ មានលក្ខណៈខ្លាចទោសនិងឃើញភ័យ ដូច្នេះ រមែងប្រាកដចំពោះក្នុងការវៀរចាកបាបប៉ុណ្ណោះ ពិតហើយ បុគ្គលខ្លះញ៉ាំងហិរិមាន

*លក្ខណៈខ្មាសឲ្យកើតឡើងដោយហេតុ ៤ ប្រការ គឺពិចារណាដល់ភាពជាធំដោយជាតិ ១ ពិចារណាដល់ភាពជាធំនៃព្រះសាស្តា ១ ពិចារណាដល់ភាពជាធំដោយទ្រព្យ គឺមរតក ១ និងពិចារណាដល់ភាពជាធំនៃសព្រហ្មចារី ១ ហើយមិនធ្វើបាប ។ បុគ្គលពួកខ្លះ ញុំាងឱត្តប្បៈដែលមានលក្ខណៈខ្លាចទោស និងឃើញភ័យឲ្យតាំងឡើងដោយហេតុ ៤ ប្រការ គឺភ័យក្នុងការតិះដៀលខ្លួនឯង ១ ភ័យក្នុងការតិះដៀលអំពីអ្នកដទៃ ១ ភ័យគឺអាជ្ញា ១ ភ័យក្នុងទុគ្គតិ ១ ហើយមិនធ្វើបាប ។ ក្នុងហិរិនិងឱត្តប្បៈនេះ គប្បីពោលការពិចារណាដល់ភាពជាធំដោយជាតិជាដើម និងភ័យក្នុងការតិះដៀលជាដើមឲ្យពិស្តារ សេចក្តីពិស្តាររបស់ការពិចារណាភាពជាធំដោយជាតិជាដើមនោះ បានពោលទុកហើយក្នុងអដ្ឋកថា អង្គុត្តរនិកាយឯណោះ ។*

*បទថា* **សុក្កធម្មសមាហិតា** *សេចក្តីថា កុសលធម៌ដែលគួរធ្វើមានហិរិឱត្តប្បៈនេះឯងជាដើម ឈ្មោះថា សុក្កធម៌ គឺធម៌ស កាលពោលដោយន័យរួម គឺកាន់យកដោយសរុប សុក្កធម៌នោះ គឺធម៌ដែលជាលោកិយនិងលោកុត្តរៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដែលប្រកបហើយប្រកបព្រមហើយ ដោយហិរិនិងឱត្តប្បៈទាំងពីរនោះ ។*

*បទថា* **សន្តោ សប្បុរិសា លោកេ** *សេចក្តីថា ឈ្មោះថាជាអ្នកស្ងប់រម្ងាប់ ព្រោះកាយកម្មជាដើមស្ងប់រម្ងាប់ហើយ ឈ្មោះថាជា*

សប្បុរស ព្រោះជាបុរសដែលល្អដោយកតញ្ញូកតវេទី ។ ក្នុងបទថា **លោកេ** នេះ លោកមានច្រើនគឺ សង្ខារលោក សត្វលោក ឱកាសលោក ខន្ធលោក អាយតនលោក និងធាតុលោក ក្នុងលោកទាំងនោះ សង្ខារលោក លោកបានពោលទុកក្នុងប្រយោគនេះថា

លោក ១ បានដល់ពួកសត្វទាំងអស់ដែលតាំងនៅបានដោយអាហារ លោក ២ បានដល់នាម ១ រូប ១ លោក ៣ បានដល់វេទនា ៣ លោក ៤ បានដល់អាហារ ៤ លោក ៥ បានដល់ឧបាទានក្ខន្ធ ៥ លោក ៦ បានដល់អាយតនៈខាងក្នុង ៦ លោក ៧ បានដល់ទីតាំងនៃវិញ្ញាណ ៧ លោក ៨ បានដល់លោកធម៌ ៨ លោក ៩ បានដល់ទីនៅរបស់សត្វ ៩ លោក ១០ បានដល់អាយតនៈទាំង ១០ លោក ១២ បានដល់អាយតនៈ ១២ លោក ១៨ បានដល់ធាតុ ១៨ [១] ។

លោក មានខន្ធលោកជាដើម រួមក្នុងសង្ខារលោកនោះឯង ។ ចំណែកសត្វលោក លោកពោលក្នុងប្រយោគជាដើមថា លោកនេះ លោកខាងមុខ ទេវលោក មនុស្សលោកជាដើម ឱកាសលោក លោកពោលទុកក្នុងប្រយោគនេះថា

**យាវតា ចន្ទិមសុរិយា បរិហរន្តិ**

---

១- បិ.៦៩ , ទំ.២៧៥ ។

ឧិសា ភន្តិ វិរោចនា
តាវ សហស្សធា លោកោ
ឯត្ថ តេ វត្តតី វសោ ។

*ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយ ដើរបំភ្លឺទិសទាំងឡាយ ឲ្យភ្លឺបានត្រឹមណា លោកគឺចក្កវាឡទាំងមួយពាន់ក៏កំណត់ត្រឹមនោះ អំណាចរបស់អ្នកប្រព្រឹត្តទៅបានតែត្រឹមចក្កវាឡមួយពាន់នុ៎ះ* (១) ។

*បណ្ដាលោកទាំងនោះ ក្នុងទីនេះ បំណងយកសត្វលោក ពិតហើយ ក្នុងសត្វលោកប៉ុណ្ណោះ មានសប្បុរសបែបនេះ សប្បុរសទាំងនោះ លោកពោលថា មានទេវធម៌ ។*

*បទថា* **ទេវ** *ក្នុងបទថា* **ទេវធម្មា** *នោះ ទេវៈ មាន ៣ គឺ សម្មតិទេព ១ ឧបបត្តិទេព ១ វិសុទ្ធិទេព ១ ។ បណ្ដាទេវៈទាំងនោះ ព្រះរាជានិងព្រះរាជកុមារជាដើម ឈ្មោះថា សម្មតិទេព ព្រោះសត្វលោកសន្មតថាជាទេវៈ ចាប់តាំងពីកាលព្រះបាទមហាសម្មតិរាជមកម៉្លេះ ។ ទេវតាជាអ្នកកើតឡើងក្នុងទេវលោកឈ្មោះថា ឧបបត្តិទេព ។ ព្រះខីណាស្រពឈ្មោះថា វិសុទ្ធិទេព សមដូចព្រះតម្រាស់ថា*

---

*១-បិ. ២២ , ទំ. ៣៦៨ ។*

ពួកព្រះរាជា ព្រះរាជកុមារ និងព្រះទេពី លោកហៅថា សម្មតិទេព ។ ឧបបត្តិទេព តើដូចម្តេច ។ ពួកទេពឋិតនៅ ក្នុងចាតុម្មហារាជិកា ពួកទេពឋិតនៅក្នុងតាវត្តិង្ស ពួកទេពឋិតនៅក្នុងយាមា ពួកទេពឋិតនៅក្នុងតុសិត ពួកទេពឋិតនៅក្នុងនិម្មានរតី ពួកទេពឋិតនៅក្នុងបរនិម្មិតវសវត្តី និងពួកទេពជាពួកនៃព្រហ្ម ជាពួកទេពដែលឋិតនៅខាងលើពួកទេពទាំងនុ៎ះ លោកហៅថា ឧបបត្តិទេព ។ វិសុទ្ធិទេព តើដូចម្តេច ។ ពួកព្រះអរហន្តខីណាស្រព ជាសាវ័ករបស់ព្រះតថាគត និងពួកព្រះខីណាស្រព ដែលជាព្រះបច្ចេកពុទ្ធ លោកហៅថា វិសុទ្ធិទេព ។ ព្រះមានព្រះភាគ ជាទេពរបស់ពួកសម្មតិទេព ឧបបត្តិទេព និងវិសុទ្ធិទេព ជាទេពដ៏ក្រៃលែងផង ជាទេពធំកន្លងជាងពួកទេពផង ជាសីហៈធំជាងសីហៈផង ជានាគធំជាងនាគផង ជាមេគណៈធំជាងមេគណៈផង ជាមុនីធំជាងមុនីផង ជាព្រះរាជាធំជាងព្រះរាជាផង [១] ដូច្នេះ ។ ធម៌របស់ទេវៈទាំងនេះ ឈ្មោះថា ទេវធម៌ ។

បទថា វុច្ចរេ ប្រែថា រមែងពោល ពិតហើយ កុសលធម៌ទាំងឡាយ មានហិរិឱត្តប្បៈជាមូល ឈ្មោះថា ជាធម៌របស់ទេវៈទាំង ៣ ប្រភេទនោះ ព្រោះអត្ថថា ជាហេតុនៃកុសលសម្បទា ហេតុនៃការកើត

---

១- បិ. ៦៧ , ទំ. ១៨២ ។

ក្នុងទេវលោក និងហេតុនៃការបរិសុទ្ធ ព្រោះហេតុនោះ ទើបឈ្មោះថា ទេវធម៌ បុគ្គលប្រកបដោយទេវធម៌ទាំងនោះ ក៏ជាបុគ្គលមានទេវធម៌នោះឯង ព្រោះដូច្នោះ ព្រះដ៏មានព្រះភាគ កាលទ្រង់សម្ដែងធម៌ទាំងនោះ ដោយទេសនាដែលជាបុគ្គលាធិដ្ឋាន ទើបទ្រង់ត្រាស់ថា សប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ហៅថា ជាអ្នកមានទេវធម៌ក្នុងលោក ។

យក្ស កាលបានស្ដាប់ព្រះធម្មទេសនានេះ មានសេចក្ដីជ្រះថ្លា ទើបពោលនឹងព្រះពោធិសត្វថា នៃបណ្ឌិត ខ្ញុំជ្រះថ្លានឹងលោក ខ្ញុំនឹងឲ្យប្អូនប្រុសម្នាក់ តើលោកយកមួយណា ?

ព្រះបរមពោធិសត្វត្រាស់ថា សូមអ្នកយកប្អូនពៅមកចុះ ។

យក្សពោលថា នៃបណ្ឌិត លោកស្គាល់ទេវធម៌តែម្យ៉ាងប៉ុណ្ណោះ តែមិនប្រព្រឹត្តទេវធម៌ទាំងនោះ ។

ព្រះមហាសត្វត្រាស់សួរថា ព្រោះហេតុអ្វី ?

យក្សពោលថា ព្រោះថា លោកវៀរប្អូនកណ្ដាលចេញហើយ នាំយកប្អូនពៅមក ឈ្មោះថា មិនធ្វើកម្មដែលឱនលំទោនចំពោះបុគ្គលដែលមានសេចក្ដីចម្រើន ។

ព្រះមហាបុរសពោលថា នៃយក្ស ខ្ញុំស្គាល់ទេវធម៌ ហើយប្រព្រឹត្តក្នុងទេវធម៌ទាំងនោះ ព្រោះថា យើងទាំងឡាយចូលព្រៃនេះ ព្រោះអាស្រ័យប្អូនពៅនេះ ព្រោះមាតារបស់ប្អូនពៅនេះ ទូលសូមរាជសម្បត្តិអំពី

ព្រះរាជបិតារបស់យើង ដើម្បីប្រយោជន៍ដល់ប្អូនពៅនេះ តែព្រះបិតារបស់ពួកយើងមិនឲ្យពរនោះ កាលទ្រង់រក្សាពួកយើង ទើបទ្រង់អនុញ្ញាតការនៅព្រៃ កុមារនោះ ក៏រត់តាមមកជាមួយពួកយើង កាលពួកយើងពោលថា យក្សមួយក្នុងព្រៃស៊ីកុមារនោះហើយ បុគ្គលណាមួយនឹងជឿដោយហេតុនោះ យើងខ្លាចភ័យ គឺការតិះដៀល ទើបឲ្យនាំប្អូនប្រុសពៅនោះមកដូច្នេះ ។

យក្សមានចិត្តជ្រះថ្លា ឲ្យសាធុការដល់ព្រះពោធិសត្វថា សាធុ សាធុ បណ្ឌិត លោកចេះទេវធម៌ ព្រមទាំងបដិបត្តិក្នុងទេវធម៌ទាំងនោះដូច្នេះហើយ ទើបនាំប្អូនប្រុសទាំងពីរមកប្រគល់ឲ្យព្រះពោធិសត្វវិញ ។ លំដាប់នោះ ព្រះពោធិសត្វត្រាស់នឹងយក្សនោះថា នែសម្លាញ់ អ្នកកើតជាយក្សនេះអាស្រ័យឈាម សាច់របស់អ្នកដទៃជាអាហារ ព្រោះបាបកម្មដែលខ្លួនធ្វើទុកក្នុងជាតិមុន ឥឡូវនេះ អ្នកនៅធ្វើបាបនោះទៀត ឈ្មោះថា បាបកម្ម មិនឲ្យអ្នកផុតអំពីនរកជាដើមឡើយ ព្រោះហេតុនោះ ចាប់តាំងអំពីពេលនេះទៅ ចូរអ្នកលះបាបកម្ម ហើយធ្វើតែកុសលកម្មចុះ ។ ព្រះពោធិសត្វ កាលទ្រង់ទូន្មានយក្សនោះហើយ យក្សនោះក៏ធ្វើការរក្សា ( ព្រះពោធិសត្វ ) នៅក្នុងទីនោះឯង ។ ថ្ងៃមួយ សម្ដីងមើលនក្ខត្តឫក្សដឹងថាព្រះជនកសោយទិវង្គត ទើបនាំយក្សទៅកាន់នគរពារាណសី កាន់យករាជសម្បត្តិ ហើយប្រទានតំណែងឧបរាជដល់ចន្ទកុមារ ប្រទាន

តំណែងសេនាបតីដល់សុរិយកុមារ ឲ្យសាងលំនៅគួរជាទីត្រេកអរដល់យក្ស ទ្រង់ធ្វើយក្សនោះ ឲ្យជាបុគ្គលដែលមហាជនបូជាដោយផ្កាកម្រង និងគ្រឿងក្រអូប ផ្លែឈើដ៏ប្រសើរផ្សេងៗ និងតម្កល់ភត្តដ៏ប្រសើរជានិច្ច ព្រះពោធិសត្វ ទ្រង់គ្រងរាជសម្បត្តិដោយធម៌ លុះអស់ព្រះជន្មហើយ ក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់រឿងទាំងពីរហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អារក្សទឹកក្នុងកាលនោះ បានមកជាភិក្ខុមានភណ្ឌៈច្រើនក្នុងកាលឥឡូវនេះ សុរិយកុមារ បានមកជាអានន្ទ ចន្ទ-កុមារបានមកជាសារីបុត្ត ចំណែកមហិសាសកុមារដែលជាបុត្តច្បង គឺ**តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ទេវធម្មជាតក ទី ៦ ។

# អដ្ឋកថា កដ្ឋហារិជាតក ទី ៧

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងវាសភខត្តិយា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **បុត្តោ ត្យាហំ មហារាជ** ដូច្នេះជាដើម ។

រឿងរបស់ព្រះនាងវាសភខត្តិយានឹងមានជាក់ច្បាស់ក្នុង **ភទ្ទសាលជាតក ទ្វាទសកនិបាត** ឯណោះ ។

បានឮថា ព្រះនាងវាសភខត្តិយានោះ ជាព្រះរាជធីតារបស់ស្ដេចសក្យមហានាម ប្រសូតចាកគភ៌របស់ទាសីឈ្មោះថា នាគមុណ្ឌា ក្រោយមកក៏បានជាអគ្គមហេសីរបស់ព្រះបាទកោសល ព្រះនាងប្រសូតបានព្រះរាជឱរសមួយអង្គ ។ ក្រោយមក ព្រះរាជាទ្រង់ជ្រាបថា ព្រះនាងជាកូនរបស់ទាសី ទើបទ្រង់ដកមុខតំណែង សូម្បីវិឌូឌភៈដែលជាព្រះឱរសក៏ត្រូវដកមុខតំណែងដូចគ្នា ម្ដាយនិងកូនទាំងពីរនាក់ រស់នៅក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកោសលនោះឯង ។ ព្រះបរមសាស្តា ទ្រង់ជ្រាបហេតុនោះ លុះវេលាល្ងាច ទ្រង់ចោមរោមដោយពួកភិក្ខុ ៥០០ រូប ទ្រង់យាងទៅកាន់ព្រះរាជនិវេសន៍របស់ព្រះរាជា ទ្រង់គង់លើអាសនៈដែលគេក្រាលទុក ហើយមានព្រះតម្រាស់សួរថា ព្រះនាងវាសភខត្តិយាប្រថាប់នៅឯណា ? ព្រះរាជាក៏ក្រាបទូលហេតុនោះ ឲ្យទ្រង់ជ្រាប ។ ព្រះសាស្តាត្រាស់សួរថា មហាបពិត្រ ព្រះនាងវាសភខត្តិយា ជាធីតារបស់អ្នកណា ?

ព្រះរាជាក្រាបទូលថា ជាធីតារបស់ព្រះបាទមហានាម ។

ព្រះមានព្រះភាគត្រាស់សួរថា កាលព្រះនាងវាសភខត្តិយាយាង មក តើយាងមកដើម្បីអ្នកណា ?

ព្រះរាជាក្រាបទូលថា ដើម្បីខ្ញុំព្រះអង្គនេះឯង ។

ព្រះសាស្តាត្រាស់ថា មហាបពិត្រ ព្រះនាងវាសភខត្តិយានេះជា ធីតារបស់ព្រះរាជា ហើយមកក៏ដើម្បីព្រះរាជា ព្រោះអាស្រ័យព្រះរាជា នោះឯង ទើបបានព្រះរាជឱរស ព្រោះហេតុអ្វី ទើបព្រះរាជឱរសនោះ មិនបានរាជសម្បត្តិដែលជារបស់ព្រះរាជបិតា ? ព្រះរាជាទាំងឡាយក្នុង កាលមុន បានព្រះឱរសក្នុងគភ៌របស់ស្ត្រីរកឧសជាករិយាម្តងម្កាល ក៏គង់ ព្រះរាជទានរាជសម្បត្តិដល់ព្រះរាជឱរសនោះ ។ ព្រះរាជា ទ្រង់ក្រាប ទូលអារាធនាព្រះមានព្រះភាគ ដើម្បីទ្រង់ត្រាស់រឿងនោះឲ្យជាក់ច្បាស់ ព្រះសាស្តា ទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូច្នេះថា

ក្នុងអតីតកាល ព្រះរាជាព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជ សម្បត្តិក្នុងនគរពារាណសី ។ ថ្ងៃមួយ ព្រះរាជាយាងទៅក្រសាលក្នុង ឧទ្យានដោយយសធំ ទ្រង់ត្រាច់ទៅក្នុងព្រះរាជឧទ្យាននោះ ព្រោះទ្រង់ ត្រេកអរដោយផ្កានិងផ្លៃឈើ ក៏បានឃើញស្ត្រីម្នាក់ កំពុងច្រៀងបណ្តើរ កាច់ឧសបណ្តើរក្នុងព្រះរាជឧទ្យាននោះ ទ្រង់មានចិត្តប្រតិព័ទ្ធ ទើបទ្រង់ សម្រេចការនៅរួមជាមួយស្ត្រីនោះ ។ ក្នុងខណៈនោះឯង ព្រះពោធិសត្វ

ក៏បដិសន្ធិក្នុងគភ៌របស់ស្ត្រីនោះ រំពេចនោះ គភ៌របស់នាងក៏ធ្ងន់ហាក់ដូចពេញដោយពេជ្រ នាងដឹងថា នាងមានគភ៌ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មានគភ៌ហើយ ។ ព្រះរាជាបានប្រទានព្រះទម្រង់ ១ វង់ហើយត្រាស់ថា បើកូនរបស់នាងជាកូនស្រី ចូរចំណាយចិញ្ចៀននេះ ហើយចិញ្ចឹមបីបាច់រក្សាចុះ បើជាកូនប្រុស ចូរនាំមកកាន់សម្នាក់របស់យើងមួយអន្ទើដោយចិញ្ចៀននេះ កាលត្រាស់ហើយ ទ្រង់ក៏យាងចៀសចេញទៅ ។ ចំណែកស្ត្រីនោះ មានគភ៌គ្រប់ខែហើយ ក៏ប្រសូតព្រះបរមពោធិសត្វ ។ ក្នុងវេលាដែលព្រះពោធិសត្វកំពុងលេងក្នុងទីលានសម្រាប់លេងរបស់កុមារ ( ក៏វាយកុមារទាំងនោះ ) ក្មេងទាំងឡាយពោលថា ពួកយើងត្រូវអាកូនអត់ឪវាយតប់ហើយ ។ ព្រះពោធិសត្វបានស្តាប់ពាក្យនោះ ទើបទៅរកមាតាសួរថា **អម្ម កោ មយ្ហំ បិតា** បពិត្រអ្នកម៉ែ អ្នកណាជាឪពុករបស់កូន ?

មាតាពោលថា **តាត ត្វំ ពារាណសិរញ្ញោ បុត្តោ** នែកូនឯងជាបុត្តរបស់ព្រះបាទពារាណសី ។

ព្រះពោធិសត្វសួរថា តើមានបន្ទាល់ ឬសាក្សីណាមួយដែរឬទេ ?

មាតាពោលថា នែកូន ព្រះរាជា ទ្រង់បានប្រទានចិញ្ចៀននេះទុកហើយត្រាស់ថា បើជាកូនស្រី គប្បីលក់ចិញ្ចៀននេះ ចិញ្ចឹមបីបាច់រក្សាចុះ បើជាកូនប្រុស គប្បីនាំមកមួយអន្ទើដោយចិញ្ចៀននេះ ដូច្នេះហើយ

ទ្រង់ក៏យាងទៅ ។

ព្រះមហាសត្វពោលថា បពិត្រអ្នកម៉ែ បើដូច្នោះ ព្រោះហេតុអ្វីទើបអ្នកម៉ែមិននាំខ្ញុំទៅកាន់សម្នាក់ព្រះបិតា ? នាងដឹងអធ្យាស្រ័យរបស់កូន ទើបនាំកុមារទៅកាន់ព្រះរាជវាំងនោះ ទៅដល់ទ្វារហើយក៏ឲ្យក្រាបទូលដល់ព្រះរាជាដើម្បីឲ្យទ្រង់ជ្រាប កាលព្រះរាជាទ្រង់អនុញ្ញាតហើយទើបចូលទៅថ្វាយបង្គំព្រះរាជា ហើយក្រាបទូលថា **អយំ ទេវ បុត្តោ** បពិត្រព្រះសម្មតិទេព កុមារនេះជាបុត្តរបស់ព្រះអង្គ ។

ព្រះរាជា សូម្បីទ្រង់ជ្រាប តែព្រោះទ្រង់ខ្មាសបរិស័ទ ទើបត្រាស់ថា **ន មយ្ហំ បុត្តោ** មិនមែនជាកូនរបស់យើងទេ ។

មាតាព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះជាព្រះទម្រង់របស់ព្រះអង្គ តើទ្រង់ចាំព្រះទម្រង់នេះបានដែរឬទេ ?

ព្រះរាជាត្រាស់ថា សូម្បីទម្រង់នេះ ក៏មិនមែនជាព្រះទម្រង់របស់យើង ។

មាតាព្រះមហាសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ឥឡូវនេះ វៀរសច្ចៈហើយ អ្នកដទៃជាសាក្សីរបស់ខ្ញុំម្ចាស់មិនមានទេ បើទារកនេះ កើតព្រោះអាស្រ័យព្រះអង្គ កាលខ្ញុំម្ចាស់បោះទារកនេះទៅហើយ ទារកនេះ ចូរតាំងនៅលើអាកាស បើមិនមែនអាស្រ័យព្រះអង្គកើតទេ ចូរធ្លាក់ស្លាប់លើផែនដីចុះ ហើយចាប់ជើងទាំងពីររបស់ព្រះពោធិសត្វ

*បោះទៅក្នុងអាកាស ។ ព្រះពោធិសត្វក៏គង់ពត់ក្អែនក្នុងអាកាស កាលនឹងពោលធម៌ដល់ព្រះបិតាដោយសំឡេងដ៏ពីរោះ ទើបត្រាស់ព្រះគាថានេះថា*

**បុត្តោ ត្យាហំ មហារាជ ត្វំ មំ បោស ជនាធិប**
**អញ្ញេបិ ទេវោ បោសេតិ កិញ្ច ទេវោ សកំ បជន្តិ។**

*បពិត្រមហារាជ ខ្ញុំជាបុត្តរបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្ដេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វដែលជាបុត្តរបស់ព្រះអង្គផង ។*

*បណ្ដាបទទាំងនោះ បទថា* **បុត្តោ ត្យាហំ** *កាត់បទជា* **បុត្តោ តេ អហំ** *ប្រែថា ខ្ញុំព្រះអង្គជាឱរសរបស់ទ្រង់ ។ ឈ្មោះថា បុត្ត មាន ៤ ប្រភេទ គឺបុត្តដែលកើតក្នុងខ្លួន ១ បុត្តដែលកើតក្នុងខេត្ត ១ អន្តេវាសិក ១ និងបុត្តដែលគេឲ្យ ១ ។ បណ្ដាបុត្តទាំង ៤ ប្រភេទនោះ បុគ្គលណាអាស្រ័យខ្លួនកើត ឈ្មោះថា បុត្តកើតក្នុងខ្លួន ។ បុត្តកើតក្នុងទីទាំងឡាយមានកើតត្រង់ទីដេកក្ដី ត្រង់បល្ល័ង្កក្ដី ត្រង់ទ្រូងក្ដី ឈ្មោះថា បុត្តដែលកើតក្នុងខេត្ត ។ បុគ្គលដែលជាកូនសិស្ស រៀនសិល្បសាស្ត្រក្នុងសម្នាក់ ឈ្មោះថា កូនសិស្ស ។ បុត្តដែលគេឲ្យហើយយកមកចិញ្ចឹម ឈ្មោះថា បុត្តដែលគេឲ្យ គឺជាកូនធម៌ តែក្នុងទីនេះ លោកពោលសំដៅយកបុត្ត*

ដែលកើតក្នុងខ្លួន ទើបពោលថា បុត្ត ។ ឈ្មោះថា ព្រះរាជា ព្រោះធ្វើជនឲ្យត្រេកអរដោយសង្គហវត្ថុ ៤ ប្រការ ព្រះរាជាដែលជាធំ ឈ្មោះថា មហារាជា ។ ព្រះបរមពោធិសត្វ កាលត្រាស់ហៅព្រះរាជានោះ ទើបត្រាស់ថា **មហារាជ** បពិត្រមហារាជដ៏ជាធំ ដូច្នេះ ។

បទថា **ត្វំ មំ បោស ជនាធិប** សេចក្តីថា បពិត្រព្រះអង្គដ៏ជាធំក្នុងពពួកជន សូមទ្រង់ចិញ្ចឹម គឺថែរក្សាទូលបង្គំផងចុះ ។

បទថា **អញ្ញេបិ ទេវោ បោសេតិ** សេចក្តីថា ជនជាច្រើនដទៃបានដល់មនុស្សដែលជាអ្នកចិញ្ចឹមដំរីជាដើម និងសត្វតិរច្ឆាន មានដំរីសេះជាដើម ហេតុអ្វីក៏ទ្រង់ចិញ្ចឹមបាន ។

ស័ព្ទថា **កិញ្ច** ក្នុងបទថា **កិញ្ច ទេវោ សកំ បជំ** ជានិបាតប្រើក្នុងអត្ថថា តិះដៀល និងប្រើក្នុងអត្ថថា អនុគ្រោះ ព្រះពោធិសត្វទ្រង់ឲ្យឱវាទថា ប្រជាជនរបស់ព្រះអង្គ គឺទូលបង្គំដែលជាឱរសរបស់ព្រះអង្គទ្រង់មិនចិញ្ចឹមដូច្នេះ ឈ្មោះថា តិះដៀល កាលត្រាស់ថា អ្នកដទៃជាច្រើនទ្រង់ចិញ្ចឹមបានដូច្នេះ ឈ្មោះថា អនុគ្រោះ គឺជួយស្រោចស្រង់ដូច្នោះ ព្រះពោធិសត្វកាលទ្រង់តិះដៀល ទើបត្រាស់ថា ហេតុអ្វីទ្រង់មិនចិញ្ចឹមបុត្តរបស់ព្រះអង្គ ។ កាលព្រះពោធិសត្វគង់ក្នុងអាកាសសម្តែងធម៌យ៉ាងនេះ ព្រះរាជាទ្រង់បានស្តាប់ហើយ ទើបទ្រង់លាព្រះហស្តចេញមក ត្រាស់ថា ចូរបុត្តមកចុះ យើងនឹងចិញ្ចឹមបុត្ត ។ កាលដែរាប់រយពាន់លាចេញមក

*ព្រះពោធិសត្វមិនចុះក្នុងដៃរបស់អ្នកដទៃ ចុះក្នុងព្រះហស្តរបស់ព្រះរាជាប៉ុណ្ណោះ ហើយប្រថាប់គង់លើព្រះឧរុ (ភ្លៅ) របស់ព្រះរាជា ។ ព្រះរាជា ទ្រង់ប្រទានភាពជាឧបរាជដល់ព្រះបរមពោធិសត្វ ហើយទ្រង់តែងតាំងមាតារបស់ព្រះមហាសត្វជាអគ្គមហេសី ។ កាលអំណឹះតតអំពីព្រះបាទពារាណសីទៅ ព្រះបរមពោធិសត្វក៏បានសោយរាជ្យជាព្រះរាជាព្រះនាមថា កដ្ឋវាហន គ្រង់រាជសម្បត្តិដោយធម៌ លុះអស់ព្រះជន្មក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា ទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងដល់ព្រះបាទកោសលហើយ ទ្រង់បន្តអនុសន្ធិ គឺធ្វើរឿងទាំងពីរឲ្យជាប់គ្នា ហើយទ្រង់ប្រជុំជាតកថា ព្រះមាតាក្នុងកាលនោះ បានមកជាព្រះនាងមហាមាយាទេវី ព្រះបិតាក្នុងកាលនោះ បានមកជាព្រះបាទសុទ្ធោទនមហារាជ ចំណែកព្រះបាទកដ្ឋវាហនរាជក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កដ្ឋហារិជាតក ទី ៧ ។

# អដ្ឋកថា គាមណិជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលលះបង់សេចក្តីព្យាយាម ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អបិ អតរមានានំ** ដូច្នេះជាដើម ។

រឿងបច្ចុប្បន្ននិងរឿងអតីត ក្នុងជាតកនេះ នឹងមានជាក់ច្បាស់ក្នុង **សំវរជាតក ឯកាទសកនិបាត** ឯណោះ ក្នុង **សំវរជាតក** នោះ និងជាតកនេះ រឿងដូចគ្នានោះឯង ប្លែកតែគាថាប៉ុណ្ណោះ ដែលមានសេចក្តីសង្ខេបថា គាមណិកុមារតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ សូម្បីជាព្រះកនិដ្ឋារបស់ព្រះភាតាទាំងរយព្រះអង្គ ក៏ជាអ្នកដែលព្រះភាតាទាំងរយព្រះអង្គចោមរោម ប្រថាប់គង់លើបល្ល័ង្កដ៏ប្រសើរ ខាងក្រោមស្វេតច្ឆត្រ ទតមើលយសសម្បត្តិរបស់ព្រះអង្គ ទ្រង់ត្រេកអរក្នុងយសសម្បត្តិរបស់ព្រះអង្គដែលជារបស់អាចារ្យ ទើបទ្រង់បន្លឺព្រះឧទាននេះថា

**អបិ អតរមានានំ ផលាសាវ សមិជ្ឈតិ**
**វិបក្កព្រហ្មចរិយោស្មិ ឯវំ ជានាហិ គាមណីតិ ។**

ការប្រាថ្នានូវផល តែងសម្រេចព្រមដល់ពួកជនអ្នកមិនរួសរាន់ អញជាអ្នកមានព្រហ្មចារ្យចាស់ក្លាហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ ។

បណ្តាបទទាំងនោះ សព្ទថា **អបិ** ត្រឹមតែជានិបាត ។ បទថា

**អតរមាធាធំ** បានដល់ ដែលតាំងនៅក្នុងឱវាទរបស់បណ្ឌិតទាំងឡាយ មិនប្រញាប់ប្រញាល់ ធ្វើការដោយឧបាយ ។

បទថា **ផលាសាវ សមិជ្ឈតិ** សេចក្តីថា ការសង្ឃឹមក្នុងផលដែលប្រាថ្នាទុក ឈ្មោះថា រមែងសម្រេចពិត ព្រោះការសម្រេចផលនោះ ម្យ៉ាងទៀត បទថា **ផលាសា** បានដល់ ផលនៃសេចក្តីប្រាថ្នា គឺផលតាមដែលប្រាថ្នាទុក រមែងសម្រេចនោះឯង ។

បទថា **វិបក្កព្រហ្មចរិយោស្មិ** នេះ សង្គហវត្ថុ ៤ ឈ្មោះថា ព្រហ្មចរិយៈ ព្រោះជាការប្រព្រឹត្តដ៏ប្រសើរ ឯព្រហ្មចរិយៈនោះ ឈ្មោះថា ចាស់ក្លាហើយនោះឯង ព្រោះបានចំពោះនូវយសសម្បត្តិដែលមានសង្គហវត្ថុនោះជាមូល យសដែលសម្រេចដល់គាមណិកុមារនោះ ក៏ឈ្មោះថា ព្រហ្មចរិយៈ ព្រោះអត្ថថា ប្រសើរ ដោយហេតុនោះ ទើបលោកពោលថា ខ្ញុំជាអ្នកមានព្រហ្មចរិយៈចាស់ក្លាហើយ ។

បទថា **ឯវំ ជានាហិ គាមណិ** សេចក្តីថា ក្នុងទីខ្លះបុរសអ្នកស្រុកក្តី ប្រធានរបស់អ្នកស្រុកក្តី ឈ្មោះថា គាមណិ ប្រែថា ជាអ្នកធំ តែក្នុងទីនេះ សំដៅយកខ្លួនឯងដែលជាប្រធាននៃមនុស្សទាំងពួង ទើបពោលថា នៃគាមណិដ៏ចម្រើន អ្នកចូរដឹងហេតុនេះ យ៉ាងនេះថា យើងឈានកន្លងបងប្រុសរបស់ខ្លួនបានដោយរាជសម្បត្តិដ៏ធំនេះ ព្រោះអាស្រ័យអាចារ្យ ដូច្នេះ បន្លឺឧទានហើយ ។

*កាលគាមណិកុមារនោះ បានរាជសម្បត្តិហើយ ឲ្យពេលវេលាកន្លងទៅពីរ-បីថ្ងៃ បង់ប្រុសគ្រប់គ្នាបានទៅកាន់ទីលំនៅរៀងៗ ខ្លួន ។ ព្រះបាទគាមណិគ្រងរាជសម្បត្តិដោយធម៌ លុះអស់ព្រះជន្មហើយ ក៏ទៅតាមយថាកម្ម ។ ចំណែកព្រះបរមពោធិសត្វ ធ្វើបុណ្យមានទានជាដើម លុះអស់ជីវិតហើយ ក៏ទៅតាមយថាកម្មដូចគ្នា ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ លុះចប់សច្ចៈហើយ ភិក្ខុអ្នកលះបង់សេចក្តីព្យាយាមតាំងនៅក្នុងអរហត្ត ។ ព្រះសាស្តា ទ្រង់ត្រាស់រឿងពីរបន្តអនុសន្ធិ ហើយទ្រង់ប្រជុំជាតកថា ព្រះបាទគាមណិក្នុងកាលនោះ បានមកជាភិក្ខុអ្នកលះបង់សេចក្តីព្យាយាម ចំណែកអាចារ្យ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា គាមណិជាតក ទី ៨ ។

# អដ្ឋកថា មឃទេវជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការយាងចេញមហាភិនិក្ខ្រមណ៍ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ឧត្តមង្គរុហា មយ្ហំ** ដូច្នេះជាដើម ។

ការចេញមហាភិនិក្ខ្រមណ៍នោះ បានពោលទុកហើយ ក្នុងនិទានកថា ខាងដើមនោះឯង ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយអង្គុយពណ៌នាអំពីការយាងចេញបព្វជ្ជារបស់ព្រះទសពល ។ លំដាប់នោះ ព្រះសាស្តាស្តេចយាងមកកាន់រោងធម្មសភា គង់លើបវរពុទ្ធាសនៈហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មិនបានអង្គុយសន្ទនាគ្នាដោយរឿងដទៃទេ ពួកខ្ញុំព្រះអង្គអង្គុយពណ៌នាអំពីការយាងចេញបព្វជ្ជារបស់ព្រះអង្គប៉ុណ្ណោះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញបួសតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ចេញបួសហើយដូចគ្នា ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះបរមសាស្តា ដើម្បីទ្រង់ត្រាស់រឿងនោះឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់បានធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងនគរមិថិលា ដែនវិទេហៈ មានព្រះរាជាព្រះនាមថា មឃទេវៈ ជាព្រះរាជាដែលគ្រប់គ្រងរាជ្យដោយធម៌ ។ ព្រះរាជាអង្គនោះ ទ្រង់នៅក្នុងវ័យលេងជាកុមារអស់ ៨៤.០០០ ឆ្នាំ តាំងនៅក្នុងភាពជាឧបរាជក៏ដូចគ្នា ។ ព្រះបាទមឃទេវៈនោះ ទ្រង់ឲ្យកាលវេលាក្នុងភាពជាព្រះរាជាកន្លងទៅអស់កាលយូរ ។ ថ្ងៃមួយ ទ្រង់ហៅជាងកោរកាត់មកត្រាស់ថា នៃជាងកោរកាត់សម្លាញ់ អ្នកឃើញសក់ស្កូវលើក្បាលខ្ញុំក្នុងកាលណា ចូរប្រាប់ខ្ញុំក្នុងកាលនោះ ។ ចំណែកជាងកោរ-កាត់នោះ ក៏បានធ្វើឲ្យកាលវេលាដ៏យូរនោះ កន្លងទៅដូចគ្នា ។ ថ្ងៃមួយឃើញព្រះកេសាស្កូវ ១ សរសៃ ក្នុងរវាងព្រះកេសាទាំងឡាយដែលមានពណ៌ខ្មៅដូចផ្កាអញ្ចាំនរបស់ព្រះរាជា ទើបក្រាបទូលថា **ទេវ ឯកំ តេ បលិតំ ទិស្សតិ** បពិត្រព្រះសម្មតិទេព កេសាស្កូវមួយសរសៃប្រាកដដល់ទ្រង់ហើយ ។

ព្រះរាជាត្រាស់ថា **តេន ហិ មេ សម្ម តំ បលិតំ ឧទ្ធរិត្វា ចាណិម្ហិ បបេហិ** អើសម្លាញ់ បើយ៉ាងនោះ ចូរអ្នកដកស្កូវរបស់យើងមកដាក់លើបាតដៃ ។ កាលព្រះរាជាត្រាស់យ៉ាងនោះ ជាងកោរកាត់ក៏យកសណ្ដាសមាសដក ហើយដាក់ព្រះកេសាស្កូវឲ្យប្រតិស្ឋានលើបាតព្រះហស្តរបស់ព្រះរាជា ។ ក្នុងកាលនោះ ព្រះរាជាមានព្រះជន្មាយុនៅសល់ ៨៤.០០០ ឆ្នាំទៀត ទើបសោយទិវង្គត កាលបើយ៉ាងនោះ កាល

ទ្រង់បានសក់ស្កូវហើយ ទ្រង់ក៏សម្គាល់ព្រះអង្គថា ហាក់ដូចជាមច្ចុរាជមកឈរក្បែរៗ ហាក់បីដូចជាខ្លួនចូលមកក្នុងបណ្ណសាលាដែលមានភ្លើងឆេះដូច្នោះ ទ្រង់ដល់នូវសេចក្ដីសង្វេគ ទើបទ្រង់ត្រិះរិះថា ម្នាលមឃទេវៈល្ងង់ខ្លៅ ឯងមិនអាចលះកិលេសនេះ ដរាបមានអាយុប្រមាណប៉ុណ្ណេះ រហូតសក់ស្កូវ កាលព្រះបាទមឃទេវៈនោះ ទ្រង់ពិចារណាដល់សក់ដែលស្កូវហើយ ការក្ដៅក្រហាយខាងក្នុងក៏កើតឡើង ព្រះសេទោក៏ហូរចេញអំពីសរីរៈ សំពត់សាដកបានដល់នូវអាការដែលត្រូវដូតយកញើសចេញ ព្រះបាទមឃទេវៈនោះ ទ្រង់ព្រះតម្រិះថា អញគួរចេញបួសក្នុងថ្ងៃនេះឯង ទើបប្រទានស្រុកសួយដែលមានតម្លៃ ៧ ពាន់ដល់ជាងកោរកាត់ ទ្រង់ត្រាស់ឲ្យហៅព្រះរាជឱរសច្បងមក ហើយត្រាស់ថា

នែបា សក់ស្កូវប្រាកដលើក្បាលរបស់ឪពុកហើយ ឪពុកចាស់ហើយ ឯកាមរបស់មនុស្ស ឪពុកក៏បានបរិភោគហើយ ឥឡូវនេះ ឪពុកនឹងស្វែងរកកាមដែលជាទិព្វ នេះជាកាលចេញបួសរបស់ឪពុក ចូរអ្នកគ្រប់គ្រងរាជសម្បត្តិនេះ ចំណែកឪពុកបួសហើយ នឹងនៅធ្វើសមណធម៌ក្នុងអម្ពវនឧទ្យានឈ្មោះមឃទេវៈ ។ អាមាត្យទាំងឡាយចូលទៅគាល់ព្រះរាជាដែលមានព្រះរាជបំណងចង់បួសយ៉ាងនោះ ហើយក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព អ្វីជាហេតុចេញបួសរបស់ព្រះអង្គ ?

ព្រះរាជា ទ្រង់កាន់យកសក់ស្កូវនោះបង្ហាញ ហើយត្រាស់ព្រះ

គាថាដល់អាមាត្យទាំងឡាយថា

**ឧត្តមង្គរុហា មយ្ហំ ឥមេ ជាតា វយោហរា**
**បាតុភូតា ទេវទូតា បព្វជ្ជាសមយោ មមាតិ ។**

សក់ទាំងឡាយនេះ នាំទៅនូវវ័យ ( ស្កូវ ) កើតដល់អញ
ហើយ ទេវទូត កើតប្រាកដហើយ ( នេះ ) ជាសម័យ
នៃផ្នួសរបស់អញ ។

បណ្តាបទទាំងនោះ បទថា **ឧត្តមង្គរុហា** បានដល់ សក់ ពិត ហើយ សក់ទាំងឡាយហៅថា **ឧត្តមង្គរុហា** ព្រោះដុះឡើងក្នុងទីខ្ពស់ នៃអវយវៈ មានដៃនិងជើងជាដើម គឺលើក្បាល ។

បទថា **ឥមេ ជាតា វយោហរា** សេចក្តីថា នៃបាទាំងឡាយ ចូរមើលសក់ស្កូវទាំងនេះកើតហើយ ឈ្មោះថា ជាហេតុនាំយកវ័យទៅ ព្រោះនាំយកវ័យទាំង ៣ ទៅ ដោយភាវៈប្រាកដជាសក់ស្កូវ ។

បទថា **បាតុភូតា** បានដល់ កើតឡើងហើយ ។

បទថា **ទេវទូតា** សេចក្តីថា មច្ចុឈ្មោះថា ទេវៈ ដែលឈ្មោះថា ទេវទូត ព្រោះជាទូតនៃទេវៈនោះ ពិតហើយ កាលសក់ស្កូវទាំងឡាយ ប្រាកដលើក្បាល បុគ្គលរមែងហាក់ដូចជាឈរក្នុងសម្នាក់របស់ស្តេច មច្ចុរាជ ព្រោះដូច្នោះ ទើបសក់ស្កូវទាំងឡាយលោកហៅថា ទូតរបស់ ទេវៈ គឺមច្ចុ ។ ដែលឈ្មោះថា ទេវទូត ព្រោះជាទូតដូចគ្នានឹងទេវៈ

ដូច្នេះក៏មាន ដូចបុគ្គលដែលទេវតាមានខ្លួនប្រដាប់តាក់តែងហើយ ឈរក្នុងអាកាសពោលថា អ្នកនឹងស្លាប់ក្នុងថ្ងៃឈ្មោះនោះ យ៉ាងណា កាលសក់ស្កូវទាំងឡាយប្រាកដហើយលើក្បាល ក៏រមែងដូចជាទេវតាព្យាករដូច្នោះ ដូចគ្នា ព្រោះហេតុនោះ ទើបសក់ស្កូវទាំងឡាយ លោកពោលថាជាទូត ដូចជាទេវៈ ។ ដែលឈ្មោះថា ទេវទូត ព្រោះជាទូតរបស់វិសុទ្ធិទេពទាំងឡាយ ដូច្នេះក៏មាន ពិតហើយ ព្រះពោធិសត្វគ្រប់អង្គទតឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងអ្នកបួសប៉ុណ្ណោះ ក៏ដល់នូវការសង្វេគហើយចេញបួស សមដូចព្រះតម្រាស់ថា

**ជិណ្ណញ្ច ទិស្វា ទុក្ខិតញ្ច [១] ព្យាធិតំ**
**មតញ្ច ទិស្វា គតមាយុសង្ខយំ**
**តតោ អហំ និក្ខមិត្វាន បព្វជឹ**
**បហាយ កាមានិ មនោរមានីតិ ។**

ខ្ញុំឃើញមនុស្សចាស់ជរា ឈឺចាប់ ប្រកបដោយទុក្ខ ទាំងឃើញមនុស្សដល់នូវការអស់ទៅនៃអាយុ ស្លាប់ហើយ ហេតុនោះ ខ្ញុំលះបង់កាមជាទីត្រេកអរនៃចិត្ត ហើយចេញបួស [២] ។

---

១-**ទុខិតញ្ច** ទើបត្រូវ បើត្រួតលើសមាត្រា ច្បាប់មហាចុឡា និងច្បាប់ឆដ្ឋសង្គាយនាក៏ **ទុខិតញ្ច** ដែរ ។ ២- បិ.៥៦ , ទំ.១៥៩ ។

ដោយបរិយាយនេះ ទើបសក់ស្កូវទាំងឡាយលោកហៅថា ទេវ-ទូត ព្រោះជាទូតនៃវិសុទ្ធិទេពទាំងឡាយ ។

ដោយបទថា **បព្វជ្ជាសមយោ មមំ** នេះ លោកសម្តែងថា នេះជាកាលនៃការកាន់យកសមណភេទ ដែលបានឈ្មោះថា បព្វជ្ជា ព្រោះអត្ថថា ចេញចាកភាពជាគ្រហស្ថរបស់យើង ។

ព្រះបាទមឃទេវៈនោះ កាលត្រាស់យ៉ាងនេះហើយ ទើបលះបង់រាជសម្បត្តិ បួសជាឥសីនៅក្នុងថ្ងៃនោះឯង គង់នៅក្នុងមឃទេវម្ពវ័ននោះ ចម្រើនព្រហ្មវិហារ ៤ ហើយ រស់នៅតទៅទៀតរហូត ៨៤.០០០ ឆ្នាំ មានឈានមិនសាបសូន្យសោយទិវង្គតហើយក៏ទៅកាន់ព្រហ្មលោក ចុតិចាកព្រហ្មលោកនោះ បានជាព្រះរាជាព្រះនាមថា នេមិ ក្នុងក្រុងមិថិលានោះឯងទៀត បន្តវង្សរបស់ព្រះអង្គមិនឲ្យសាបសូន្យ ហើយទ្រង់ក៏បួសនៅក្នុងអម្ពវ័ននោះឯង ចម្រើនព្រហ្មវិហារត្រឡប់ទៅកើតក្នុងព្រហ្មលោកដូចមុនទៀត ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតចេញអភិនិក្ខមណ៍តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏ចេញបួសហើយដូចគ្នា ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសអរិយសច្ចៈ ៤ ក្នុងកាលចប់អរិយសច្ចៈ ភិក្ខុពួក

ខ្លះបានជាព្រះសោតាបន្ន ភិក្ខុពួកខ្លះបានជាព្រះសកទាគាមី ភិក្ខុពួកខ្លះបានជាព្រះអនាគាមី ។

ព្រះសាស្តា ទ្រង់ត្រាស់រឿងទាំងពីរ បន្តអនុសន្ធិដោយប្រការដូច្នេះហើយ ទ្រង់ប្រជុំជាតកថា ជាងកោរកាត់ក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ បុត្តច្បងក្នុងកាលនោះ បានមកជារាហុលក្នុងកាលឥឡូវនេះ ចំណែកព្រះបាទមឃទេវៈគឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មឃទេវជាតក ទី ៩ ។

# អដ្ឋកថា សុខវិហារិជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់អាស្រ័យអនុបិយនគរ ប្រថាប់នៅក្នុងអនុបិយអម្ពវ័ន ទ្រង់ប្រារព្ធព្រះភទ្ទិយត្ថេរ ដែលមានប្រក្រតីនៅជាសុខ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យញ្ច អញ្ញេ ន រក្ខន្តិ** ដូច្នេះជាដើម ។

ព្រះភទ្ទិយត្ថេរ ជាអ្នកមានប្រក្រតីនៅជាសុខ មានព្រះឧបាលីជាគម្រប់ ៧ បួសក្នុងសមាគមក្សត្រ ៦ ព្រះអង្គ ។ បណ្តាព្រះថេរៈទាំងនោះ ព្រះភទ្ទិយត្ថេរ ១ ព្រះកម្ពិលត្ថេរ ១ ព្រះភគុត្ថេរ ១ ព្រះឧបាលិត្ថេរ ១ សម្រេចព្រះអរហត្ត ចំណែកព្រះអានន្ទបានជាព្រះ

សោតាបន្ន ព្រះអនុរុទ្ធត្ថេរជាអ្នកមានទិព្វចក្ខុ ឯភិក្ខុទេវទត្តបានឈាន ដែលជាលោកិយ ។ ឯរឿងរបស់ក្សត្រទាំង ៦ អង្គ នឹងមានជាក់ច្បាស់ ក្នុង **ខណ្ឌហាលជាតក** [១] ឯណោះ ។ ចំណែកព្រះភទ្ទិយត្ថេរ រក្សាគ្រប់គ្រងព្រះអង្គក្នុងកាលដែលជាព្រះរាជា ក៏ទ្រង់នៅតែមានការភិតភ័យកើតឡើង ទោះបីមានអ្នករក្សាសន្ធឹកសន្ធាប់ដូចជាទេវតាចាត់ការរក្សា ភ័យក៏នៅតែកើតដល់ព្រះអង្គ ទ្រង់បម្រះនឿលទៅមកលើមហាសយនា ក្នុងប្រាសាទខាងលើ តែឥឡូវនេះ កាលសម្រេចអរហត្តហើយ សូម្បីនៅក្នុងទីណាមួយ មានព្រៃជាដើម ក៏ពិចារណាឃើញភាពដែលព្រះអង្គប្រាសចាកភ័យ ទើបបន្លឺឧទានថា **អហោ សុខំ អហោ សុខំ** សុខហ៎ សុខហ៎ ។ ភិក្ខុទាំងឡាយបានស្តាប់ឮដូច្នោះ ក៏ក្រាបទូលព្រះមានព្រះភាគថា ព្រះភទ្ទិយត្ថេរព្យាករអរហត្តផល ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភទ្ទិយៈមានប្រក្រតីនៅជាសុខ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ជាអ្នកមានប្រក្រតីនៅជាសុខហើយដូចគ្នា ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះបរមសាស្តា ដើម្បីទ្រង់ត្រាស់សម្តែងរឿងនោះឲ្យជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់ធ្វើហេតុដែលអន្តរកពបិទបាំងទុក ឲ្យ

---

១- បិដកខ្មែរ ជាចន្ទកុមារជាតក ។

ប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វជាព្រាហ្មណមហាសាល ឃើញទោសក្នុងកាមទាំងឡាយ ឃើញអានិសង្សក្នុងការចេញបួស ក៏លះបង់កាមទាំងឡាយចូលទៅកាន់ព្រៃហិមពាន្តបួសជាឥសី ធ្វើសមាបត្តិ ៨ ឲ្យកើតឡើង សូម្បីបរិវាររបស់ព្រះពោធិសត្វក៏មានច្រើនសន្ធឹកសន្ធាប់ គឺមានតាបសរហូតដល់ ៥០០ រូប ។ ក្នុងរដូវភ្លៀង ព្រះពោធិសត្វចេញអំពីព្រៃហិមពាន្តចោមរោមដោយពួកតាបស ត្រាច់ចារិកទៅតាមគាមនិគមជាដើម លុះដល់នគរពារាណសី ក៏អាស្រ័យព្រះរាជា សម្រេចការនៅក្នុងព្រះរាជឧទ្យាន លោកនៅក្នុងព្រះរាជឧទ្យាននោះអស់កាល ៤ ខែក្នុងរដូវភ្លៀង ហើយក៏ទូលលាព្រះរាជា ។ លំដាប់នោះ ព្រះរាជាទ្រង់អង្វរព្រះពោធិ-សត្វថា បពិត្រលោកម្ចាស់ លោកម្ចាស់ចាស់ជរាហើយ ប្រយោជន៍អ្វីដោយការនៅក្នុងព្រៃហិមពាន្តនោះ សូមលោកម្ចាស់បញ្ជូនអន្តេវាសិកទាំងឡាយទៅព្រៃហិមពាន្ត ហើយលោកម្ចាស់គង់នៅក្នុងទីនេះចុះ ។ តាបសពោធិសត្វ ក៏ទុកដាក់តាបស ៥០០ រូប ជាមួយនឹងអន្តេវាសិកច្បងហើយបញ្ជូនតាបសទាំងនោះទៅដោយពាក្យថា នែលោកទាំងឡាយចូរលោកទាំងឡាយទៅកាន់ព្រៃហិមពាន្តជាមួយតាបសនេះ ចំណែកខ្ញុំនៅក្នុងទីនេះឯង ហើយខ្លួនឯងក៏សម្រេចការនៅក្នុងព្រះរាជឧទ្យាន

នោះឯង ។ ចំណែកតាបសដែលជាសិស្សច្បងរបស់ព្រះពោធិសត្វនោះ ជារាជបព្វជិត លះរាជសម្បត្តិធំ ចេញបួស ធ្វើកសិណបរិកម្មបានសមា-បត្តិ ៨ ជាប្រធានអន្តេវាសិកនោះ នៅក្នុងព្រៃហិមពាន្តជាមួយតាបសទាំងឡាយ ( ថ្ងៃមួយ ) មានបំណងនឹងឃើញអាចារ្យ ក៏ហៅតាបសទាំងនោះមកហើយពោលថា នែលោកទាំងឡាយ លោកកុំក្តៅក្រហាយឡើយ ចូរនៅក្នុងទីនេះហើយ ខ្ញុំឃើញអាចារ្យហើយ ខ្ញុំនឹងត្រឡប់មកហើយក៏ទៅកាន់សម្នាក់របស់អាចារ្យ ថ្វាយបង្គំ ធ្វើបដិសណ្ឋារៈហើយក្រាលកន្ទេលផែងមួយផ្ទាំង ដេកក្នុងសម្នាក់របស់អាចារ្យនោះឯង ។ សម័យនោះ ព្រះរាជា ទ្រង់ព្រះតម្រិះថា អញនឹងទៅសួរសុខទុក្ខតាបស ទើបស្តេចយាងទៅកាន់ព្រះរាជឧទ្យាន ថ្វាយបង្គំហើយ គង់ក្នុងចំណែកម្ខាង ។ ឯតាបសដែលជាអន្តេវាសិក សូម្បីឃើញព្រះរាជាហើយ ក៏មិនក្រោកឡើង ដេកយ៉ាងនោះឯង ហើយបន្លឺឧទានថា **អហោ សុខំ អហោ សុខំ** សុខហ្ន៎ សុខហ្ន៎ ។ ព្រះរាជា ទ្រង់តូចព្រះទ័យគិតក្នុងចិត្តថា តាបសនេះ ឃើញអញហើយមិនក្រោកឡើង ទើបត្រាស់នឹងព្រះពោធិសត្វថា បពិត្រលោកម្ចាស់ តាបសនេះ ប្រហែលជាឆ្អាន់តាមត្រូវការ ទើបសម្រេចការដេកយ៉ាងសប្បាយ បន្លឺឧទានថា សុខហ្ន៎ សុខហ្ន៎ ។

ព្រះពោធិសត្វពោលថា មហាបពិត្រ តាបសនេះ ក្នុងកាលមុនក៏

ជាព្រះរាជាធំដូចព្រះអង្គដែរ តាបសនេះគិតថា កាលមុនអាត្មាអញនៅជាគ្រហស្ថ សោយសិរីរាជសម្បត្តិ សូម្បីមានមនុស្សជាច្រើនកាន់អាវុធយាមរក្សា ក៏មិនមាននូវសេចក្ដីសុខបែបនេះ ទើបប្រារព្ធសុខក្នុងការបួស និងសុខក្នុងឈានរបស់ខ្លួនបន្លឺឧទាននេះ កាលពោលយ៉ាងនេះហើយ ដើម្បីសម្ដែងធម្មកថាដល់ព្រះរាជា ទើបពោលគាថានេះថា

**យញ្ច អញ្ញេ ន រក្ខន្តិ យោ ច អញ្ញេ ន រក្ខតិ**
**ស វេ រាជ សុខំ សេតិ កាមេសុ អនបេក្ខវាតិ ។**

ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សា
ពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្ដី
អាឡោះអាល័យក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ ។

បណ្ដាបទទាំងនោះ បទថា **យញ្ច អញ្ញេ ន រក្ខន្តិ** សេចក្ដីថា បុគ្គលពួកដទៃជាច្រើន រមែងមិនរក្សាបុគ្គលណា ។

បទថា **យោ ច អញ្ញេ ន រក្ខតិ** សេចក្ដីថា បុគ្គលណាមិនរក្សាបុគ្គលដទៃជាច្រើន ដោយគិតថា អាត្មាអញម្នាក់ឯងសោយរាជសម្បត្តិ ។

បទថា **ស វេ រាជ សុខំ សេតិ** សេចក្ដីថា មហាបពិត្រ បុគ្គលនោះ ម្នាក់ឯង មិនមានសម្ងាញ់ ជាអ្នកស្ងាត់ ជាអ្នកដល់ព្រមដោយសេចក្ដីសុខផ្លូវកាយនិងផ្លូវចិត្ត រមែងដេកជាសុខ ។ ពាក្យថា ដេកជា

*សុខនេះ គ្រាន់តែជាប្រធាននៃទេសនាប៉ុណ្ណោះ រមែងដេកជាសុខតែម្យ៉ាង ប៉ុណ្ណោះ ក៏មិនមែន ឯបុគ្គលដែលមានសភាពបែបនេះ រមែងដើរ ឈរ អង្គុយ ដេកជាសុខ គឺបានទទួលសេចក្ដីសុខគ្រប់ឥរិយាបថនោះឯង ។*

*បទថា* **កាមេសុ អនបេក្ខោ** *សេចក្ដីថា មហាបពិត្រ បុគ្គល បែបនេះ វៀរចាកការសម្លឹងក្នុងវត្ថុកាម និងកិលេសកាម គឺប្រាសចាក ឆន្ទរាគៈ មិនមានតណ្ហា រមែងនៅជាសុខគ្រប់ឥរិយាបថ ។*

*ព្រះរាជា ទ្រង់សណ្ដាប់ព្រះធម្មទេសនានេះហើយ មានព្រះទ័យ ត្រេកអរ ថ្វាយបង្គំ ( តាបសទាំងពីរ ) ហើយស្ដេចយាងទៅកាន់ព្រះរាជ និវេសន៍វិញ ។ ចំណែកអន្តេវាសិកថ្វាយបង្គំអាចារ្យហើយ ក៏ទៅកាន់ ព្រៃហិមពាន្តដូចគ្នា ។ ព្រះពោធិសត្វគង់ក្នុងទីនោះឯង មានឈានមិន សាបសូន្យ ធ្វើកាលកិរិយាហើយកើតក្នុងព្រហ្មលោក ។*

*ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែង ហើយ ទ្រង់ត្រាស់រឿងទាំងពីរ បន្តអនុសន្ធិប្រជុំជាតកថា អន្តេវាសិក ក្នុងកាលនោះ បានមកជាភទ្ទិយត្ថេរ ចំណែកគ្រូជាអាចារ្យនៃ គណៈ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សុខវិហារិជាតក ទី ១០ ។

ចប់ អបណ្ណកវគ្គ ទី ១ ។

# រួមជាតកដែលមាននៅក្នុងវគ្គនេះ គឺ

*អបណ្ណកជាតក ១ វណ្ណុបថជាតក ១ សេរិវវាណិជជាតក ១ ចុល្លកសេដ្ឋិជាតក ១ តណ្ឌុលនាឡិជាតក ១ ទេវធម្មជាតក ១ កដ្ឋហារិជាតក ១ គាមណិជាតក ១ មឃទេវជាតក ១ សុខវិហារិជាតក ១ ។*

# សីលវគ្គ ទី ២

## អដ្ឋកថា លក្ខណជាតក ទី ១

*ព្រះបរមសាស្ដា កាលទ្រង់អាស្រ័យនៅក្នុងនគររាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ហោតិ សីលវតំ អត្ថោ** *ដូច្នេះជាដើម ។*

*រឿងរបស់ទេវទត្តរហូតដល់ការប្រកបកម្ម គឺការសម្លាប់យ៉ាងធ្ងន់ នឹងជាក់ច្បាស់ក្នុង* **ខណ្ឌហាលជាតក** *រឿងនៃការលែងដំរីធនបាលនឹងជាក់ច្បាស់ក្នុង* **ចុល្លហំសជាតក** *ក្នុង (* **អសីតិនិបាត** *) និងការដែលត្រូវផែនដីស្រូបនឹងជាក់ច្បាស់ក្នុង* **សមុទ្ទវាណិជជាតក** *ក្នុង* **ទ្វាទសកនិបាត** *។*

*សម័យមួយ ភិក្ខុទេវទត្តទូលសូមវត្ថុ ៥ ប្រការ កាលមិនបានសម្រេច ទើបបំបែកសង្ឃ នាំភិក្ខុ ៥០០ រូប ទៅកាន់គយាសីសប្រទេស ក្នុងកាលនោះ ញាណរបស់ភិក្ខុទាំងនោះ ក៏ដល់នូវភាពចាស់ក្លាហើយ ព្រះទសពល ទ្រង់ជ្រាបដូច្នោះ ក៏ត្រាស់ហៅអគ្គសាវកទាំងគូមក ហើយត្រាស់ថា ម្នាលសារីបុត្តនិងមោគ្គល្លាន ភិក្ខុ ៥០០ រូបជាកូនសិស្សរបស់ពួកអ្នក គាប់ចិត្តក្នុងលទ្ធិរបស់ទេវទត្ត ទៅជាមួយទេវទត្តហើយ ឥឡូវនេះ ញាណរបស់ភិក្ខុទាំងនោះចាស់ក្លាហើយ ពួកអ្នកចូរទៅកាន់ទីនោះមួយអន្ទើដោយភិក្ខុទាំងឡាយ សម្ដែងធម៌ដល់ភិក្ខុទាំងនោះ ឲ្យភិក្ខុទាំង*

នោះ ត្រាស់ដឹងមគ្គនិងផលហើយចូរនាំមក ។ អគ្គសាវកទាំងពីរអង្គនោះក៏ទៅកាន់គយាសីសប្រទេសនោះ សម្ដែងធម៌ដល់ភិក្ខុទាំងនោះ ឲ្យត្រាស់ដឹងហើយដោយមគ្គផល ស្អែកឡើងក្នុងវេលាថ្ងៃរះ ក៏នាំភិក្ខុទាំងនោះ មកកាន់វត្តវេឡុវ័នមហាវិហារវិញ ។ ក្នុងកាលដែលព្រះសារីបុត្ត-ត្ថេរមកថ្វាយបង្គំព្រះទសពលហើយឈរ ភិក្ខុទាំងឡាយនាំគ្នាសរសើរព្រះថេរៈ ហើយក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះធម្មសេនាបតីដែលជាបងប្រុសធំរបស់ខ្ញុំព្រះអង្គទាំងឡាយ កាលភិក្ខុ ៥០០ អង្គចោមរោមមក ល្អអ្វីម៉្លេះទេ ចំណែកទេវទត្តជាអ្នកមានបរិវារវិនាសហើយ ។

ព្រះសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តដែលពួកញាតិចោមរោមមកល្អយ៉ាងនេះ តែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុងកាលមុនក៏រុងរឿងដូចគ្នា ចំណែកទេវទត្តវិនាសចាកពួកញាតិតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏វិនាសមកហើយដូចគ្នា ។ ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះមានព្រះភាគ ដើម្បីទ្រង់ត្រាស់សម្ដែងរឿងនោះឲ្យជាក់ច្បាស់ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមគធៈមួយអង្គ គ្រងរាជសម្បត្តិក្នុងនគររាជគ្រឹះ ក្នុងដែនមគធៈ ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុង

កំណើតមិគជាតិ លុះធំចម្រើនវ័យហើយ មានម្រឹគជាបរិវារ ១ ពាន់ នៅក្នុងដងព្រៃនោះ ។ ព្រះពោធិសត្វនោះ មានកូនពីរគឺ លក្ខណៈ ១ កាឡៈ ១ ។ ក្នុងវេលាដែលខ្លួនចាស់ព្រះពោធិសត្វ ( ហៅកូនមក ) ពោលថា **តាតា អហំ ឥទានិ មហល្លកោ តុម្ហេ ឥមំ គណំ បរិហរថ** នែបាទាំងពីរ ឥឡូវនេះ ឪពុកចាស់ហើយ ចូរបាទាំងពីរគ្រប់គ្រងហ្វូងម្រឹគនេះ ហើយចែកហ្វូងម្រឹគដល់កូនទាំងពីរ កូនមួយ ៥០០ ។ តាំងអំពីកាលនោះមក ម្រឹគទាំងពីរក៏គ្រប់គ្រងរក្សាហ្វូងម្រឹគទាំងនោះ ។ សម័យនោះ ក្នុងដែនមគធៈជាសម័យដែលសម្បូរដោយសន្ទូង អន្តរាយរមែងកើតដល់ម្រឹគទាំងឡាយដែលរស់នៅក្នុងព្រៃ ។ កាលពួកមនុស្សត្រូវការសម្លាប់ពួកម្រឹគដែលមកស៊ីសន្ទូង ក៏ជីករណ្ដៅបង្កប់ដាក់ចម្រូងខ្លះ ធ្វើអង្គប់ថ្មយន្តខ្លះ ដាក់អន្ទាក់ មានអន្ទាក់ធ្វើដោយដងសម្រាប់វាត់ខ្លះ ម្រឹគជាច្រើនក៏ដល់នូវសេចក្ដីវិនាស ។ ព្រះពោធិសត្វដឹងរដូវកាលដែលពេញទៅដោយសន្ទូង ទើបហៅកូនទាំងពីរមកពោលថា នែបាទាំងពីរ សម័យនេះ ជាសម័យដែលច្រើនទៅដោយសន្ទូង ម្រឹគជាច្រើនដល់នូវសេចក្ដីវិនាស ឪពុកចាស់ហើយ នឹងសម្ងំនៅក្នុងទីមួយកន្ទែង ដោយឧបាយណាមួយ ពួកអ្នកចូរនាំហ្វូងម្រឹគទៅកាន់ជើងភ្នំក្នុងព្រៃ ក្នុងវេលាដែលគេដកសន្ទូងហើយសឹមមក ។ កូនទាំងពីរនោះ ទទួលពាក្យរបស់ឪពុកថា សាធុហើយ ក៏នាំគ្នាទៅមួយអន្ទើដោយបរិវារ ។ ឯពួកមនុស្ស

ទាំងឡាយ រមែងដឹងផ្លូវដែលពួកម្រឹគទាំងនោះទៅ និងផ្លូវដែលពួកម្រឹគទាំងនោះមកថា ក្នុងពេលនេះ ពួកម្រឹគចុះអំពីលើភ្នំ ក្នុងពេលនេះ ពួកម្រឹគនាំគ្នាឡើងទៅលើភ្នំ ពួកមនុស្សទាំងនោះ ក៏នាំគ្នាអង្គុយក្នុងទីកំបាំងចាក់ម្រឹគដែលមកហើយឲ្យស្លាប់ ។ ចំណែកម្រឹគឈ្មោះកាឡៈ ព្រោះភាពដែលខ្លួនជាសត្វល្ងង់ ទើបមិនដឹងថា វេលានេះគួរទៅ ( វេលានេះគួរមក ) នាំពួកម្រឹគចូលទៅកាន់ទ្វារស្រុក ទាំងក្នុងវេលាព្រឹកនិងក្នុងវេលាល្ងាច ទាំងក្នុងវេលាព្រលប់និងក្នុងវេលាទៀបភ្លឺ ពួកមនុស្សឈរនិងអង្គុយតាមប្រក្រតីនោះឯង ក្នុងទីនោះៗ ញុំាងម្រឹគជាច្រើនឲ្យដល់នូវសេចក្ដីវិនាស ។ ម្រឹគឈ្មោះកាឡៈនោះ ធ្វើឲ្យម្រឹគជាច្រើនដល់នូវសេចក្ដីវិនាស ព្រោះភាពដែលខ្លួនជាសត្វល្ងង់ខ្លៅយ៉ាងនេះ ទើបចូលទៅកាន់ព្រៃដោយម្រឹគមានប្រមាណតិចតួចប៉ុណ្ណោះ ។ ឯម្រឹគឈ្មោះលក្ខណៈជាបណ្ឌិត ជាម្រឹគមានប្រាជ្ញា ឈ្លាសក្នុងឧបាយ ដឹងថាពេលនេះគួរទៅ ( ពេលនេះគួរមក ) កាលម្រឹគឈ្មោះលក្ខណៈនោះចូលទៅកាន់ទ្វារស្រុក មិនទៅក្នុងពេលថ្ងៃ មិនទៅក្នុងពេលព្រលប់ មិនទៅក្នុងពេលទៀបភ្លឺ នាំពួកម្រឹគទៅក្នុងវេលាកណ្ដាលអធ្រាត្រប៉ុណ្ណោះ ព្រោះដូច្នោះ លក្ខណម្រឹគនោះមិនធ្វើហ្វូងម្រឹគ សូម្បីតែមួយឲ្យវិនាស ។ ម្រឹគទាំងនោះ នៅក្នុងព្រៃអស់កាល ៤ ខែ កាលពួកមនុស្សដកសន្ទូងហើយ ទើបនាំគ្នាចុះអំពីភ្នំ កាឡម្រឹគទៅតាមក្រោយ ធ្វើម្រឹគទាំងអស់

ឲ្យដល់នូវសេចក្ដីវិនាស ដូចពោលនោះឯង មកតែម្នាក់ឯងប៉ុណ្ណោះ ។ ចំណែកម្រឹគឈ្មោះលក្ខណៈ សូម្បីតែម្រឹគមួយក៏មិនឲ្យវិនាស ម្រឹគទាំង ៥០០ ចោមរោមលក្ខណម្រឹគ ហើយមកកាន់សម្នាក់របស់មេនិងបា ។ ចំណែកព្រះពោធិសត្វឃើញកូនទាំងពីរមក កាលប្រឹក្សាជាមួយមេម្រឹគ ទើបពោលគាថានេះថា

**ហោតិ សីលវតំ អត្ថោ បដិសន្ថារវុត្តិនំ**
**លក្ខណំ បស្ស អាយន្តំ ញាតិសង្ឃបុរក្ខិតំ**
**អថ បស្សសិមំ កាឡំ សុវិហីនំវ ញាតិភីតិ ។**

សេចក្ដីចម្រើនតែងមាន ដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្ត បដិសន្ថារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ ( កំពុងដើរមក ) ឬទេ ។

បណ្ដាបទទាំងនោះ បទថា **សីលវតំ** សេចក្ដីថា ឈ្មោះថា ជាអ្នកមានសីល គឺសម្បូរដោយអាចារៈ ព្រោះមានសេចក្ដីសុខជាប្រក្រតី ។

បទថា **អត្ថោ** បានដល់ សេចក្ដីចម្រើន ។

បទថា **បដិសន្ថារវុត្តិនំ** ឈ្មោះថា ជាអ្នកមានប្រក្រតីប្រព្រឹត្ត បដិសណ្ឋារៈ ព្រោះជាអ្នកមានប្រក្រតីប្រព្រឹត្តក្នុងធម្មបដិសណ្ឋារៈ និង អាមិសបដិសណ្ឋារៈ ដល់ជនទាំងនោះ ដែលជាអ្នកមានប្រក្រតីប្រព្រឹត្ត

ក្នុងបដិសណ្ឋារៈ ។ ក្នុងទីនេះ គប្បីជ្រាបធម្មបដិសណ្ឋារៈ ដូចជាហាម ការធ្វើនូវអំពើបាប ការឲ្យដំបូន្មាន និងការបង្រៀនជាដើម គប្បីជ្រាប អាមិសបដិសណ្ឋារៈ ដូចជាការឲ្យចំណីអាហារ ទំនុកបម្រុងអ្នកជំងឺ និង ធ្វើការរក្សាប្រកបដោយធម៌ លោកពោលពាក្យអធិប្បាយទុកថា ឈ្មោះ ថា សេចក្ដីចម្រើនរមែងមានដល់ជនដែលជាបណ្ឌិត ដែលដល់ព្រម ដោយអាចារៈ ដែលតាំងនៅក្នុងបដិសណ្ឋារៈទាំងពីរនេះ ឥឡូវនេះ ព្រះ ពោធិសត្វ កាលហៅមេម្រឹគដើម្បីនឹងសម្ដែងសេចក្ដីចម្រើននោះ ទើប ពោលពាក្យថា ចូរនាងមើលម្រឹគឈ្មោះលក្ខណៈដូច្នេះជាដើម ។ ក្នុង ពាក្យដែលពោលនោះ មានសេចក្ដីសង្ខេបដូចតទៅនេះថា នាងចូរមើល កូនរបស់នាងដែលសម្បូរដោយអាចារៈនិងបដិសណ្ឋារៈ មិនធ្វើសូម្បីតែ ម្រឹគមួយឲ្យវិនាសក្នុងពពួកញាតិ ត្រូវពពួកញាតិធ្វើឲ្យនៅខាងមុខ គឺឲ្យ ដើរមុខចោមរោមមកហើយ តែនាងចូរមើលម្រឹគឈ្មោះកាឡៈនេះ ជា អ្នកមានប្រាជ្ញាថោកថយ វៀរចាកសម្បទា គឺ អាចារៈនិងបដិសណ្ឋារៈ ជាអ្នកសាបសូន្យចាកញាតិទាំងឡាយ មិនសេសសល់សូម្បីតែម្រឹគមួយ ហើយមកតែឯង ។ ព្រះពោធិសត្វសរសើរកូនរបស់ខ្លួនយ៉ាងនេះហើយ តាំងនៅដរាបដល់អស់អាយុ លុះចុតិហើយក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្តត្រូវពួក ញាតិចោមរោមហើយរុងរឿង តែក្នុងកាលឥឡូវនេះក៏មិនមែន សូម្បីក្នុង

*កាលមុនក៏រុងរឿងដូចគ្នា ឯទេវទត្តសាបសូន្យចាកពួកគណៈ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏វិនាសសាបសូន្យចាកពួកញាតិដូចគ្នា ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ត្រាស់រឿងទាំងពីរ បន្តអនុសន្ធិហើយទ្រង់ប្រជុំជាតកថា ម្រឹគឈ្មោះកាឡៈក្នុងកាលនោះ បានមកជាទេវទត្ត បរិស័ទរបស់ម្រឹគឈ្មោះកាឡៈក្នុងកាលនោះ បានមកជាបរិស័ទរបស់ទេវទត្តក្នុងកាលឥឡូវនេះ ម្រឹគឈ្មោះលក្ខណៈក្នុងកាលនោះ បានមកជាសារីបុត្ត ឯបរិស័ទរបស់ម្រឹគឈ្មោះលក្ខណៈក្នុងកាលនោះ ក៏បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះដែរ មេម្រឹគដែលជាមាតាក្នុងកាលនោះ បានមកជារាហុលមាតា ចំណែកបាម្រឹគក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា លក្ខណជាតក ទី ១ ។

# អដ្ឋកថា និគ្រោធមិគជាតក ទី ២

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីដែលជាមាតារបស់ព្រះកុមារកស្សបត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **និគ្រោធមេវ សេវេយ្យ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនីនោះ ជាធីតារបស់សេដ្ឋីដែលមានទ្រព្យច្រើននៅក្នុងនគររាជគ្រឹះ មានកុសលមូលបានធ្វើទុកហើយពេញបរិបូណ៌ មានសង្ខារញាំញីហើយ ជាបច្ឆិមភវិកសត្វ (ជាសត្វដែលមានភពចុងក្រោយ) ឧបនិស្ស័យនៃព្រះអរហត្តសន្ធោសន្ធៅក្នុងហទយៈរបស់នាង ដូចប្រទីបដែលឆេះនៅក្នុងផ្ទាំងដូច្នោះ ។ គ្រានោះ ចាប់តាំងពីនាងធំដឹងក្ដីហើយ ធីតាសេដ្ឋីនោះ មិនត្រេកអរក្នុងផ្ទះ មានបំណងនឹងបួស ទើបពោលនឹងមាតាបិតាថា បពិត្រលោកឪពុកអ្នកម្ដាយ ចិត្តរបស់ខ្ញុំមិនត្រេកអរក្នុងឃរាវាស ខ្ញុំមានបំណងនឹងបួសក្នុងព្រះពុទ្ធសាសនា ដែលជាគ្រឿងនាំចេញចាកទុក្ខ សូមលោកទាំងពីរឲ្យខ្ញុំបួសចុះ ។

មាតាពោលថា នែនាង កូននិយាយអ្វី ត្រកូលនេះមានទ្រព្យសម្បត្តិច្រើន ហើយនាងជាធីតាតែមួយរបស់យើងទាំងឡាយ នាងមិនគួរបួសឡើយ ។ សូម្បីនាងអង្វររឿយៗ ក៏មិនបានការអនុញ្ញាតឲ្យបព្វជ្ជាអំពីសម្នាក់របស់មាតាបិតា ទើបគិតថា ណ្ហើយចុះ អញទៅកាន់ត្រកូលស្វាមី ញ៉ាំងស្វាមីឲ្យសណ្ដោសប្រោសប្រណី ហើយសឹមបួស ។ លុះ

នាងចម្រើនវ័យហើយ ក៏ទៅកាន់ត្រកូលស្វាមី ជាស្ត្រីមានសីល មានកល្យាណធម៌ គ្រប់គ្រងផ្ទះ ។ លំដាប់នោះ ព្រោះអាស្រ័យការនៅរួមនាងក៏តាំងគភ៌ នាងមិនដឹងថាមានគភ៌ឡើយ ។ គ្រានោះ មហាជនឃោសនា គឺប្រកាសបុណ្យនក្ខត្តឫក្សក្នុងនគរ អ្នកនគរទាំងអស់នាំគ្នាលេងនក្ខត្តឫក្ស នគរមានការប្រដាប់តាក់តែងដូចទេវនគរ ។ កាលការលេងនក្ខត្តឫក្សដ៏ធំក្រៃលែងយ៉ាងនេះ កំពុងប្រព្រឹត្តទៅ នាងក៏មិនលាបមិនប្រោះព្រំរាងកាយរបស់ខ្លួន មិនប្រដាប់តាក់តែង ត្រាច់ទៅតាមធម្មតាប្រក្រតីនោះឯង ។ លំដាប់នោះ ស្វាមីក៏ពោលនឹងនាងថា នែនាងដ៏ចម្រើន នគរទាំងមូលអាស្រ័យនក្ខត្តឫក្ស តែនាងមិនបដិបត្តិសរីរៈ មិនធ្វើការប្រដាប់តាក់តែង ព្រោះហេតុអ្វីហ្ន៎ ?

នាងពោលថា បពិត្រអយ្យបុត្ត រាងកាយពេញដោយសាកសព ៣២ ប្រការ ប្រយោជន៍អ្វីដោយរាងកាយដែលប្រដាប់ហើយ ព្រោះកាយនេះ ទេវតា ព្រហ្ម ក៏មិនបាននិម្មិត មិនមែនសម្រេចដោយមាសដោយកែវមណី ដោយខ្លឹមចន្ទន៍ក្រហម មិនមែនកើតក្នុងផ្កាឈូកសផ្កាកុមុទ និងផ្កាឧប្បលខៀវ តែពេញទៅដោយលាមក មិនស្អាត មិនមែនពេញដោយអមតឱសថ ដោយពិត កើតក្នុងសាកសព មានមាតាបិតាជាដែនកើត មានការដុសខាត់ គក់ច្របាច់ជាប្រក្រតី មានការបែកធ្លាយនិងការខ្ចាត់ខ្ចាយរាត់រាយទៅជាធម្មតា ជាព្រៃស្មសាន ដែលតណ្ហា

ចូលទៅប្រកាន់ ជាហេតុនៃសេចក្ដីសោក ជាទីតាំងនៃការកន្ទក់កន្ទេញ ជាទីអាស្រ័យរបស់រោគទាំងពួង ជាទីទទួលគ្រឿងកម្មករណៈ មានការវាយដំជាដើម ជារបស់ស្អុយក្នុង ហូរចេញនូវវត្ថុមិនស្អាតជានិច្ច ជាលំនៅរបស់ពួកជង្គូវច្រើនត្រកូល ទីបំផុតក៏ធ្លាក់ចុះក្នុងព្រៃស្មសាន គឺមានការស្លាប់ជាទីបំផុត តែរាងកាយនេះ ជាទីត្រេកអរក្នុងគន្លងចក្ខុរបស់សត្វលោកទាំងពួងទៅវិញ ។

អដ្ឋិន្ហារុហិ សំយុត្តោ តចមំសាវលេបនោ
ឆវិយា កាយោ បដិច្ឆន្នោ យថាភូតំ ន ទិស្សតិ ។

កាយប្រកបដោយឆ្អឹងនិងសរសៃទាំងឡាយ គ្របដណ្ដប់ដោយស្បែកនិងសាច់ បិទបាំងដោយសម្បុរថ្ងៃ មិនប្រាកដតាមពិត ។

អន្តបូរោ ឧទរបូរោ យកាបេឡស្ស វត្ថិនោ
ហទយស្ស បប្ផាសស្ស វក្កស្ស បិហកស្ស ច
សិង្ឃាណិកាយ ខេលស្ស សេទស្ស ច មេទស្ស ច
លោហិតស្ស លសិកាយ បិត្តស្ស ច វសាយ ច ។

កាយពេញដោយពោះវៀនផង ពេញដោយអាហារថ្មីផង ដោយដុំថ្លើមផង ដោយក្រពះនោមផង ដោយបេះដូងផង ដោយសួតផង ដោយទាចផង ដោយក្រពះបាយផង ដោយទឹកសំបោរផង ដោយទឹកមាត់ផង ដោយញើសផង ដោយ

*ខ្ទាញ់ខាប់ផង ដោយឈាមផង ដោយទឹករំអិលផង ដោយទឹកប្រមាត់ផង ដោយខ្ទាញ់រាវផង ។*

**អថស្ស នវហិ សោតេហិ អសុចី សវតិ សព្វទា**
**អក្ខិម្ហា អក្ខិគូថកោ កណ្ណម្ហា កណ្ណគូថកោ**
**សិង្ឃាណិកា ច នាសតោ មុខេន វមតេកទា**
**បិត្តំ សេម្ហំ ច វមតិ កាយម្ហា សេទជល្លិកា ។**

*មួយទៀត វត្ថុមិនស្អាត រមែងហូរចេញតាមរន្ធទាំង ៩ របស់កាយនោះសព្វកាល គឺព្រៀកភ្នែក ហូរចេញអំពីភ្នែក មូលត្រចៀក ហូរចេញអំពីត្រចៀក ទឹកសំបោរហូរចេញអំពីច្រមុះ ជួនណាចេញតាមមាត់ ប្រមាត់និងស្លេស្ម ក៏ខ្ពុរចេញតាមមាត់ដែរ ញើសនិងក្អែល ហូរចេញអំពីកាយ ។*

**អថស្ស សុសិរំ សីសំ មត្ថលុង្គស្ស បូរិតំ**
**សុភតោ នំ មញ្ញតិ ពាលោ អវិជ្ជាយ បុរក្ខតោ ។**

*មួយទៀត កាយនោះ មានក្បាលប្រហោង ពេញដោយខួរក្បាល ជនពាលត្រូវអវិជ្ជារួបរឹតហើយ រមែងសម្គាល់កាយនោះថាល្អ[១] ។*

---

១- បិ.៥៤ , ទំ.៦៥ ។

អនន្តាទីនវោ កាយោ វិសរុក្ខសមូបមោ
អាវាសោ សព្វរោគានំ បុញ្ជោ ទុក្ខស្ស កេវលោ ។

*រាងកាយជារបស់មានទោស រកទីបំផុតគ្មាន មានឧបមាដូចដើមឈើមានពិស ជាលំនៅនៃរោគទាំងពួង ជាគំនរនៃកងទុក្ខទាំងអស់ (១) ។*

សចេ ឥមស្ស កាយស្ស អន្តោ ពាហិរតោ សិយា
ទណ្ឌំ ធុវំ គហេត្វាន កាកេ សោណេ ច វារយេ ។

*បើត្រឡប់ផ្នែកខាងក្នុងរបស់រាងកាយនេះ ឲ្យមកខាងក្រៅ នឹងត្រូវកាន់ដំបងចាំដេញក្អែកនិងឆ្កែ ដោយពិត ។*

ទុគ្គន្ធោ អសុចិ កាយោ កុណបោ ឧក្ការូបមោ
និន្ទិតោ ចក្ខុភូតេហិ កាយោ ពាលាភិនន្ទិតោ ។

*កាយមិនស្អាត មានក្លិនស្អុយ ពេញដោយសាកសព ប្រៀបដូចបង្គន់ បុគ្គលមានចក្ខុតិះដៀល តែបុគ្គលល្ងង់ខ្លៅនាំគ្នាត្រេកអរហើយ ។*

អល្លចម្មបដិច្ឆន្នោ នវទ្វារោ មហាវណោ
សមន្តតោ បគ្ឃរតិ អសុចិ បូតិគន្ធិយោ ។

---

*១- បិ. ៧៥ , ទំ. ២៩៦ ។*

*កាយនេះ ត្រូវស្បែកស្រស់បិទបាំងទុក មានទ្វារ ៩ ប្រៀបដូចជាមុខដំបៅ ជារបស់មិនស្អាត មានក្លិនស្អុយហូរចេញសព្វទិស* (១) ។

**យទា ច សោ មតោ សេតិ ឧទ្ធុមាតោ វិនីលកោ**
**អបវិទ្ធោ សុសានស្មឹ អនបេក្ខា ហោន្តិ ញាតយោ ។**
**ខាទន្តិ នំ សុវាណា ច សិង្គាលា ច វកា កិមី**
**កាកា គិជ្ឈា ច ខាទន្តិ យេ ចញ្ញេ សន្តិ បាណិនោ ។**

*កាលណាកាយនោះ ស្លាប់ទៅ ដេកនៅហើមប៉ោង មានពណ៌ខៀវ ត្រូវគេបោះចោលទៅក្នុងព្រៃស្មសានហើយ កាលណោះជនទាំងឡាយជាញាតិ ក៏លែងរមិល ស្វាន ចចក ក្អែ ដង្កូវ ជញ្ជែងស៊ីកាយស្លាប់នោះ ចំណែកពួកសត្វដទៃ មានក្អែកត្មាតជាដើម ក៏ចឹកស៊ីនូវកាយស្លាប់នោះដែរ ។*

**សុត្វាន ពុទ្ធវចនំ ភិក្ខុ បញ្ញាណវា ឥធ**
**សោ ខោ នំ បរិជានាតិ យថាភូតញ្ហិ បស្សតិ ។**

*ភិក្ខុណាក្នុងសាសនានេះ ជាអ្នកមានបញ្ញា បានស្តាប់នូវពុទ្ធវចនៈហើយ ភិក្ខុនោះ រមែងកំណត់ដឹងនូវកាយនោះ ព្រោះ*

---

*១- វិសុទ្ធិមគ្គ អសុភកម្មដ្ឋាននិទ្ទេស ។*

*ឃើញច្បាស់តាមពិត ។*

**យថា ឥទំ តថា ឯតំ យថា ឯតំ តថា ឥទំ**
**អជ្ឈត្តញ្ច ពហិទ្ធា ច កាយេ ឆន្ទំ វិរាជយេ ។**
**ឆន្ទរាគវិរត្តោ សោ ភិក្ខុ បញ្ញាណវា ឥធ**
**អជ្ឈគា អមតំ សន្តិ និព្វានបទមច្ចុតំ ។**

*សរីរៈរស់នេះយ៉ាងណា សរីរៈស្លាប់នុ៎ះក៏យ៉ាងនោះ សរីរៈស្លាប់នុ៎ះយ៉ាងណា សរីរៈរស់នេះក៏យ៉ាងនោះ ភិក្ខុគប្បីរំសាយនូវសេចក្តីប្រាថ្នាក្នុងកាយ ទាំងខាងក្នុង ទាំងខាងក្រៅក្នុងសាសនានេះ ភិក្ខុនោះ មានបញ្ញាប្រាសចាកឆន្ទរាគ ដល់នូវបទគឺព្រះនិព្វាន ជាធម្មជាតមិនស្លាប់ ចេញចាកវានៈគឺតណ្ហា ជាធម្មជាតស្ងប់ មិនច្យុត [១] ។*

*ខ្ញុំបន្ទោបង់នូវការត្រេកត្រអាលក្នុងកាយទាំងពួង ទាំងខាងក្នុងនិងខាងក្រៅហើយ បពិត្រអយ្យបុត្ត ខ្ញុំនឹងប្រដាប់រាងកាយនេះ ធ្វើអ្វី ? កាលធ្វើនូវការប្រដាប់កាយនេះ ហាក់ដូចជាធ្វើចិត្រកម្មខាងក្រៅធ្នាំងដែលពេញដោយលាមក ។ សេដ្ឋីបុត្តបានស្តាប់ពាក្យរបស់នាងដូច្នោះហើយ ក៏ពោលថា* **ភទ្ទេ តុំ ឥមស្ស សរីរស្ស ឥមេ ទោសេ**

---

*១- បិ.៥៤ , ទំ.៦៦ ។*

**បស្សមានា កស្មា ន បព្វជិស្សសិ** នែនាងដ៏ចម្រើន នាងឃើញទោសទាំងឡាយ ក្នុងពងកាយយ៉ាងនេះ ហេតុអ្វីក៏នាងមិនបួសហ: ?

នាងពោលថា **អយ្យបុត្ត អហំ បព្វជ្ជំ លភមានា អជ្ជេវ បព្វជេយ្យំ** បពិត្រអយ្យបុត្ត បើខ្ញុំបានបួស ខ្ញុំនឹងបួសក្នុងថ្ងៃនេះឯង ។

សេដ្ឋីបុត្តពោលថា សាធុ ខ្ញុំនឹងឲ្យនាងបួស ( កាលពោលយ៉ាងនេះហើយ ) បំពេញមហាទាន ធ្វើមហាសក្ការ: ហើយនាំនាងទៅកាន់សម្នាក់ភិក្ខុនីដោយបរិវារធំ កាលឲ្យនាងបួស បានឲ្យបួសក្នុងសម្នាក់ភិក្ខុនីដែលជាបក្សពួករបស់ភិក្ខុទេវទត្ត នាងបានបព្វជ្ជាហើយ តម្រិះពេញបរិបូណ៌ ត្រេកអរហើយ ។ កាលនោះ គភ៌របស់នាងចាស់ហើយ ភិក្ខុនីទាំងឡាយឃើញភាពដែលឥន្ទ្រីយ៍ទាំងឡាយប្រែប្រួលទៅ ខ្នងដៃនិងខ្នងជើងហើមឡើង និងឃើញពោះធំ ទើបសួរថា បពិត្រអ្នកនាងម្ចាស់ នាងប្រាកដហាក់ដូចជាស្ត្រីមានគភ៌ តើរឿងនេះដូចម្ដេច ?

ភិក្ខុនីនោះពោលថា បពិត្រអ្នកនាងម្ចាស់ទាំងឡាយ ខ្ញុំមិនដឹងថាហេតុឈ្មោះនេះ កើតឡើងដូចម្ដេចនោះទេ ប៉ុន្តែសីលរបស់ខ្ញុំបរិបូណ៌នោះឯង ។ លំដាប់នោះ ភិក្ខុនីទាំងនោះ ក៏នាំភិក្ខុនីនោះទៅកាន់សម្នាក់របស់ភិក្ខុទេវទត្ត ហើយសួរភិក្ខុទេវទត្តថា បពិត្រលោកម្ចាស់ កុលធីតានេះ ញ៉ាំងស្វាមីឲ្យសណ្ដោសប្រោសប្រណីបានដោយលំបាក ទើបបានបព្វជ្ជា ឥឡូវនេះគភ៌របស់នាងប្រាកដ យើងខ្ញុំទាំងឡាយមិនដឹងថា

កុលធីតានេះ តាំងតក់ក្នុងកាលនៅជាគ្រហស្ថ ឬតាំងតក់ក្នុងកាលដែលបួសហើយនោះទេ ឥឡូវនេះ យើងទាំងឡាយគួរធ្វើដូចម្តេច ? ព្រោះភាពនៃខ្លួនមិនដឹង និងព្រោះខន្តិ មេត្តា និងករុណាមិនមាន ទើបទេវទត្តគិតយ៉ាងនេះថា ការតិះដៀលនឹងកើតឡើងដល់អញថា ភិក្ខុនីនៅក្នុងសម្នាក់របស់ទេវទត្ត មានគភ៌ តែទេវទត្តបែរជាព្រងើយកន្តើយ ណ្ហើយចុះ អញនឹងឲ្យភិក្ខុនីនេះសឹកទើបគួរ ។ ភិក្ខុទេវទត្តមិនទាន់ពិចារណាក៏ស្ទុះចេញទៅដូចថ្មរមៀល ពោលថា ពួកនាង ចូរឲ្យភិក្ខុនីនេះសឹក ។ ភិក្ខុនីទាំងនោះ ស្តាប់ពាក្យរបស់ទេវទត្តហើយ ក្រោកឡើងថ្វាយបង្គំ ត្រឡប់ទៅកាន់សម្នាក់របស់ខ្លួនវិញ ។ លំដាប់នោះ ភិក្ខុនីនោះពោលនឹងភិក្ខុនីទាំងនោះថា បពិត្រអ្នកនាងម្ចាស់ទាំងឡាយ លោកម្ចាស់ទេវទត្តមិនមែនជាព្រះពុទ្ធ ការបួសរបស់ខ្ញុំក្នុងសម្នាក់របស់លោកម្ចាស់ទេវទត្តនោះ មិនមានទេ បព្វជ្ជារបស់ខ្ញុំឧទ្ទិសចំពោះព្រះសម្មាសម្ពុទ្ធ ដែលជាអគ្គបុគ្គលក្នុងលោក ម្យ៉ាងទៀត បព្វជ្ជានេះខ្ញុំបានដោយលំបាកណាស់ សូមអ្នកនាងម្ចាស់ទាំងឡាយ កុំធ្វើបព្វជ្ជារបស់ខ្ញុំឲ្យអន្តរធានឡើយ មកអ្នកនាងម្ចាស់ទាំងឡាយ ពួកយើងនឹងទៅកាន់វត្តជេតពន ដើម្បីគាល់ព្រះបរមសាស្តា ។ ភិក្ខុនីទាំងឡាយនោះក៏នាំភិក្ខុនីនោះ ចេញអំពីនគររាជគ្រឹះ អស់ចម្ងាយផ្លូវ ៤៥ យោជន៍ ទៅដល់វត្តជេតពនមហាវិហារដោយលំដាប់ ថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលរឿងនោះឲ្យ

ទ្រង់ជ្រាប ។

ព្រះមានព្រះភាគ ទ្រង់ព្រះតម្រិះថា ភិក្ខុនីនេះ មានគភ៌កាលនៅជាគ្រហស្ថដោយពិត តែទោះបីជាដូច្នោះ ពួកតិរ្ថិយក៏នឹងបានឱកាសថា ព្រះសមណគោតមនាំភិក្ខុនីដែលទេវទត្តបោះបង់ចោលហើយមក ព្រោះដូច្នោះ ដើម្បីកាត់នូវពាក្យនិន្ទានេះ គួរនឹងវិនិច្ឆ័យអធិករណ៍នេះ ក្នុងកណ្ដាលបរិស័ទ មានព្រះរាជាជាដើម ។ លុះស្អែកឡើង ទើបព្រះបរមសាស្ដា ត្រាស់ឲ្យយាងព្រះបាទកោសល អញ្ជើញអនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខាមហាឧបាសិកា និងត្រកូលធំៗ ដទៃទៀតដែលមានកេរ្តិ៍ឈ្មោះ ។ ក្នុងវេលាល្ងាច កាលដែលបរិស័ទ ៤ ប្រជុំគ្នាហើយ ទើបទ្រង់ត្រាស់ហៅព្រះឧបាលិត្ថេរមកថា អ្នកចូរជម្រះកម្មរបស់ភិក្ខុនីនេះ ក្នុងកណ្ដាលបរិស័ទ ៤ ។

ព្រះថេរៈទទួលព្រះតម្រាស់ថា សាធុ ព្រះអង្គ ហើយក៏និមន្តទៅកណ្ដាលបរិស័ទ អង្គុយលើអាសនៈដែលគេតាក់តែងទុកដើម្បីខ្លួន ហើយឲ្យហៅនាងវិសាខាឧបាសិកាមក ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះរាជា ឲ្យទទួលអធិករណ៍នេះថា នែនាងវិសាខា ចូរនាងទៅ ចូរនាងដឹងថា ភិក្ខុនីនេះ បួសក្នុងខែឈ្មោះនោះ ថ្ងៃនោះ ហើយចូរដឹងថា នាងមានគភ៌មុន ឬក៏ក្រោយបួស ។ មហាឧបាសិកាទទួលពាក្យថា សាធុ ហើយក៏ឲ្យបាំងវាំងនន ពិនិត្យមើលត្រង់ទីបំផុតនៃដៃ ជើង ផ្ចិត និងពោះរបស់ភិក្ខុនីនោះ

ខាងក្នុងរាំងនន រាប់ខែនិងថ្ងៃ ក៏ដឹងថា នាងតាំងគភ៌ក្នុងភាវៈជាគ្រហស្ថដោយពិត ទើបទៅកាន់សម្នាក់របស់ព្រះថេរៈ ហើយប្រាប់សេចក្តីនោះ ។ ព្រះឧបាលិត្ថេរបានធ្វើភិក្ខុនីនោះ ឲ្យជាបុគ្គលបរិសុទ្ធក្នុងកណ្តាលបរិស័ទ ៤ ភិក្ខុនីនោះជាអ្នកបរិសុទ្ធហើយ ថ្វាយបង្គំភិក្ខុសង្ឃ ហើយថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ ទៅកាន់សម្នាក់របស់ខ្លួនវិញ មួយអន្លើដោយភិក្ខុនីទាំងឡាយ ។ ភិក្ខុនីនោះ កាលគភ៌ចាស់ហើយ ក៏ប្រសូតបុត្តមានអានុភាពច្រើនដែលជាអ្នកតាំងសេចក្តីប្រាថ្នាទុក ទៀបបាទមូលរបស់ព្រះសម្ពុទ្ធទ្រង់ព្រះនាមថា បទុមុត្តរៈ ។

ថ្ងៃមួយ ព្រះរាជាយាងទៅជិតៗ សម្នាក់របស់ភិក្ខុនី ទ្រង់បានឮសំឡេងទារក ទើបត្រាស់សួរអាមាត្យទាំងឡាយ អាមាត្យទាំងឡាយដឹងហេតុនោះ ក៏ក្រាបទូលថា បពិត្រព្រះសម្មតិទេព ភិក្ខុនីនោះ ប្រសូតបុត្តហើយ នោះជាសំឡេងទារករបស់ភិក្ខុនីនោះឯង ។

ព្រះរាជាត្រាស់ថា នែអ្នក ឈ្មោះថាការប្រតិបត្តិទារក ជាកង្វល់របស់ភិក្ខុនីទាំងឡាយ ពួកយើងនឹងចិញ្ចឹមទារកនោះ ។ ព្រះរាជា ទ្រង់ប្រគល់ទារកនោះឲ្យដល់ស្រីរបាំទាំងឡាយ ញុាំងទារកឲ្យធំធាត់ដោយការចិញ្ចឹមបីបាច់ដូចជាបុត្តរបស់ខ្លួន ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ ក៏បានដាក់ឈ្មោះថា កស្សប ។ កាលនោះ មនុស្សទាំងឡាយស្គាល់ថា កុមារកស្សប ព្រោះធំចម្រើនដោយការចិញ្ចឹមគ្រប់យ៉ាងដូចជារាជកុមារ ។

លុះដល់បានអាយុ ៧ ឆ្នាំ កុមារកស្សបនោះ បួសក្នុងសម្នាក់របស់ព្រះបរមសាស្ដា ។ កាលមានអាយុ ២០ ឆ្នាំបរិបូណ៌ ក៏បានឧបសម្បទា ញុំាងកាលវេលាឲ្យកន្លងទៅ ជាអ្នកពោលធម៌ដ៏វិចិត្រក្នុងធម្មកថិកទាំងឡាយ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់តែងតាំងព្រះកុមារកស្សបនោះ ក្នុងតំណែងឯតទគ្គថា

**ឯតទគ្គំ ភិក្ខវេ មម សាវកានំ ភិក្ខូនំ**
**ចិត្តកថិកានំ យទិទំ កុមារកស្សបោ ។**

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកថេះសម្ដីដ៏វិចិត្រ
ដែលជាសាវករបស់តថាគត ស្រេចនឹងកុមារកស្សបៈ[១] ។

ខាងក្រោយមក ព្រះកុមារកស្សបនោះក៏បានសម្រេចអរហត្ត ក្នុងកាលដែលបានស្ដាប់វម្មិកសូត្រ ។ ចំណែកភិក្ខុនីដែលជាមាតារបស់ព្រះកុមារកស្សបៈនោះ ក្រោយមកក៏សម្រេចអរហត្តដូចគ្នា កុមារកស្សបត្ថេរនោះ ប្រាកដក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញបូណ៌មី អណ្ដែតលើអាកាសដូច្នោះ ។

ថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ត្រឡប់អំពីបិណ្ឌបាតខាងក្រោយភត្ត ទ្រង់ប្រទានឱវាទដល់ភិក្ខុទាំងឡាយហើយ ទ្រង់យាងចូលកាន់ព្រះ

---

១- បិ. ៤០ , ទំ. ៥៤ ។

គន្ធកុដិ ភិក្ខុទាំងឡាយទទួលឱវាទហើយ ឲ្យភាគនៃចំណែកថ្ងៃអស់ទៅក្នុងទីដែលជាទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃរៀងៗខ្លួន លុះដល់វេលាល្ងាច ប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយពណ៌នាគុណរបស់ព្រះសព្វញ្ញូថា នៃអាវុសោទាំងឡាយ ទេវទត្តធ្វើជនទាំងពីរគឺ កុមារកស្សប និងព្រះថេរីឲ្យវិនាស ព្រោះភាពដែលខ្លួនល្ងង់ខ្លៅ និងព្រោះភាពដែលខ្លួនមិនមានខន្តី និងមេត្តាជាដើម តែព្រះសម្មាសម្ពុទ្ធ ទ្រង់ជាបច្ច័យដល់ជនទាំងពីរ ព្រោះទ្រង់ជាធម្មរាជា និងព្រោះទ្រង់ដល់ព្រមដោយខន្តីមេត្តានិងករុណា ។ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់រោងធម្មសភាដោយពុទ្ធលីលា គង់លើបវរពុទ្ធាសនៈដែលគេក្រាលទុក ហើយមានព្រះតម្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គសន្ទនាគ្នាដោយរឿងព្រះគុណរបស់ព្រះអង្គប៉ុណ្ណោះ ហើយក្រាបទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាបច្ច័យ និងជាទីពឹងដល់ជនទាំងពីរនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន តថាគតក៏បានជាទីពឹងហើយដូចគ្នា ភិក្ខុទាំងឡាយក្រាបទូលអារាធនាព្រះសាស្តា ដើម្បីទ្រង់សម្តែងរឿងនោះឲ្យ

ជាក់ច្បាស់ ព្រះមានព្រះភាគ ទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុក ឲ្យប្រាកដដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វ ទ្រង់បដិសន្ធិក្នុងកំណើតមិគជាតិ ។ ព្រះពោធិសត្វនោះ កាលប្រសូតចាកផ្ទៃរបស់មេ ក៏មានពណ៌ដូចមាស ភ្នែកទាំងគូរបស់ព្រះពោធិសត្វប្រៀបដូចជាគ្រាប់កែវមណី ស្នែងទាំងគូមានពណ៌ដូចប្រាក់ មុខមានពណ៌ដូចគំនរសំពត់កម្ពលក្រហម ជើងទាំង ៤ ដូចគ្នានឹងធ្វើបរិកម្មដោយរសនៃទឹកល័ក្ត ( ដូចលាបដោយទឹកល័ក្ខ ) កន្ទុយដូចគ្នានឹងកន្ទុយរបស់សត្វចាមរី រាងកាយរបស់ម្រឹគនោះ មានទំហំប្រមាណប៉ុនកូនសេះ មានបរិវារ ៥០០ មានឈ្មោះថា និគ្រោធ-មិគរាជ សម្រេចការនៅក្នុងព្រៃ ។ ក្នុងទីមិនឆ្ងាយអំពីទីនោះ មានម្រឹគមួយទៀត មានបរិវារ ៥០០ ដូចគ្នា ឈ្មោះថា សាខៈ អាស្រ័យនៅ ឯម្រឹគសាខៈក៏មានពណ៌ដូចមាសដូចគ្នា ។ សម័យនោះ ព្រះបាទពារាណសីទ្រង់ខ្វល់ខ្វាយក្នុងការសម្លាប់ម្រឹគ បើថ្ងៃណាមិនបានសាច់ម្រឹគ ទ្រង់ក៏មិនសោយព្រះក្រយា ទ្រង់ធ្វើពួកមនុស្សឲ្យខានធ្វើការងារ ញុំាងអ្នកនិគមនិងអ្នកជនបទទាំងពួងឲ្យប្រជុំគ្នា ហើយទ្រង់ចេញទៅបរបាញ់ម្រឹគរាល់ថ្ងៃ ។ ពួកមនុស្សគិតគ្នាថា ព្រះរាជាអង្គនេះ ធ្វើពួកយើងឲ្យខូចខាតការងារ បើដូច្នោះ ពួកយើងដាក់ចំណីរបស់ម្រឹគទុកក្នុងព្រះរាជឧទ្យាន

រៀបចំទឹកផឹកទុក ហើយកៀងម្រឹគឲ្យចូលទៅកាន់ព្រះរាជឧទ្យាន បិទទ្វារថ្វាយព្រះរាជាចុះ ។ ពួកជនទាំងនោះ ក៏នាំគ្នាដាំបន្លែដែលជាចំណីរបស់ម្រឹគទុកក្នុងព្រះរាជឧទ្យាន រៀបចំធ្វើស្រះទឹកហើយប្រកបទ្វារ កាន់អាវុធគ្រប់ប្រភេទមានដំបងជាដើម ចូលទៅក្នុងព្រៃស្វែងរកម្រឹគ គិតថាពួកយើងនឹងចាប់ម្រឹគទាំងឡាយដែលនៅត្រង់កណ្ដាល ទើបនាំគ្នាព័ទ្ធព្រៃប្រមាណ ១ យោជន៍ ហើយក៏បង្រួមគ្នាចូលមកតាមលំដាប់ ម្រឹគឈ្មោះនិគ្រោធនិងម្រឹគឈ្មោះសាខៈ ក៏នៅត្រង់កណ្ដាលហ្វូងមនុស្សទាំងនោះ កាលឃើញពួកម្រឹគទាំងនោះហើយ ក៏យកដំបងវាយគុម្ពឈើនិងផែនដី ដេញពួកម្រឹគឲ្យចេញអំពីព្រៃស្តុក នាំគ្នាវាអាវុធទាំងឡាយមានដាវ លំពែង និងធ្នូជាដើម បន្ទឺសំឡេងខ្លាំង កៀងពួកម្រឹគទាំងនោះឲ្យចូលក្នុងព្រះរាជឧទ្យានហើយបិទទ្វារ រួចនាំគ្នាចូលទៅគាល់ព្រះរាជាហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព កាលទ្រង់យាងទៅបរបាញ់ម្រឹគជាប្រចាំ ទ្រង់ធ្វើការងាររបស់ទូលបង្គំទាំងឡាយឲ្យវិនាស ពួកទូលបង្គំកៀងម្រឹគទាំងឡាយចេញអំពីព្រៃ ដាក់ពេញក្នុងព្រះរាជឧទ្យានរបស់ព្រះអង្គ ចាប់តាំងអំពីពេលនេះទៅ សូមទ្រង់សោយសាច់ម្រឹគទាំងនោះហើយក៏ថ្វាយបង្គំលាព្រះរាជា នាំគ្នាចៀសចេញទៅ ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់ពាក្យរបស់មនុស្សទាំងនោះហើយ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យានទតឃើញម្រឹគទាំងឡាយ ទ្រង់ឃើញម្រឹគមានពណ៌ដូចមាស

ពីរ ទើបទ្រង់ព្រះរាជទានអភ័យដល់ម្រឹគទាំងពីរនោះ ។ ចាប់តាំងអំពីពេលនោះមក ជួនកាលទ្រង់យាងទៅដោយព្រះអង្គឯង សម្លាប់ម្រឹគមួយហើយនាំមក ជួនកាលទ្រង់ប្រើអ្នកពិសេស ( ចុងភៅ ) របស់ព្រះអង្គឲ្យទៅសម្លាប់ ហើយនាំយកម្រឹគទាំងឡាយមក ម្រឹគទាំងឡាយគ្រាន់តែឃើញធ្នូប៉ុណ្ណោះ ត្រូវមរណភ័យគ្របសង្កត់នាំគ្នារត់ទៅ បានទទួលការប្រហារពីរ-បីដង លំបាកខ្លះ របួសខ្លះ ដល់នូវការស្លាប់ខ្លះ ទើបពួកម្រឹគប្រាប់ហេតុការណ៍នោះដល់ព្រះពោធិសត្វ ។ ព្រះមហាសត្វឲ្យហៅម្រឹគឈ្មោះសាខៈមកហើយពោលថា នែសម្លាញ់ ម្រឹគជាច្រើនដល់នូវការវិនាស កាលម្រឹគត្រូវស្លាប់ដោយចំណែកមួយ ចាប់អំពីពេលនេះទៅ បុគ្គលកាលសម្លាប់ កុំចាំបាច់យកព្រួញបាញ់ម្រឹគ វារៈរបស់ម្រឹគទាំងឡាយ ចូរមានក្នុងទីសម្លាប់ គឺត្រង់ជ្រញ់របស់អ្នកពិសេសចុះ វារៈចូរមានដល់បរិស័ទរបស់យើងមួយថ្ងៃម្នាក់ គឺដល់បរិស័ទរបស់ខ្ញុំមួយថ្ងៃ ដល់បរិស័ទរបស់អ្នកមួយថ្ងៃ ម្រឹគណាដែលដល់វេនក៏ចូរទៅដេកដាក់ក្បាលលើជ្រញ់របស់អ្នកពិសេស កាលបើដូច្នោះ ម្រឹគទាំងឡាយ ក៏នឹងមិនលំបាក ។ ម្រឹគឈ្មោះសាខៈ ក៏ទទួលយល់ព្រមហើយ ។ ចាប់តាំងអំពីពេលនោះមក ម្រឹគណាដែលដល់វេន ក៏ត្រូវទៅដេកដាក់កលើជ្រញ់របស់អ្នកពិសេសនោះឯង អ្នកពិសេសមកសម្លាប់ម្រឹគដែលដេកក្នុងទីនោះ ហើយក៏ទៅ ។ ថ្ងៃមួយ វេនក៏ដល់មេម្រឹគដែលមានគភ៌មួយ

ជាបរិវាររបស់ម្រឹគឈ្មោះសាខៈ មេម្រឹគនោះ ចូលទៅរកសាខម្រឹគ ហើយពោលថា បពិត្រលោកម្ចាស់ ខ្ញុំមានទម្ងន់ ចាំកើតកូនហើយ យើងខ្ញុំទាំងពីរនឹងទៅតាមវារៈ សូមលោកឲ្យវារៈរបស់ខ្ញុំរំលងសិនចុះ ។

សាខម្រឹគពោលថា យើងមិនអាចធ្វើវារៈរបស់នាងឲ្យជាវារៈដល់ម្រឹគដទៃៗ ឡើយ នាងប៉ុណ្ណោះដឹងថានាងមានកូន ចូរនាងទៅចុះ ។ មេម្រឹគនោះ កាលមិនបានការអនុគ្រោះក្នុងសម្នាក់របស់សាខម្រឹគ ទើបចូលទៅរកនិគ្រោធម្រឹគប្រាប់សេចក្ដីនោះ ព្រះមហាសត្វបានស្ដាប់ពាក្យរបស់មេម្រឹគនោះហើយ គិតថា ព្រះពោធិសត្វទាំងឡាយក្នុងកាលមុនឃើញទុក្ខរបស់បុគ្គលដទៃ រមែងមិនសោកស្ដាយក្នុងជីវិត ធ្វើប្រយោជន៍ជារបស់អ្នកដទៃ ដោយប្រយោជន៍ខ្លួននោះឯង ព្រះពោធិសត្វទាំងឡាយតែងធ្ងន់ក្នុងវត្ថុទាំងនេះ ( សមដូចលោកពោលទុកថា )

ពួកបក្សី បសុសត្វ ម្រឹគក្នុងព្រៃទាំងអស់ រមែងរស់នៅដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ ជាអ្នកស្ងប់ ត្រេកអរហើយក្នុងប្រយោជន៍ដល់សត្វ រមែងញុំាងអ្នកដទៃឲ្យរស់នៅ ឯអ្នកប្រាជ្ញទាំងនោះលះបង់នូវទ្រព្យ អវយវៈ និងជីវិត ដើម្បីប្រយោជន៍ អាត្មាអញ ជាអ្នកអាចញុំាងពួកសត្វជាច្រើនព្រមទាំងទេវលោកឲ្យឆ្លងបាន ការមិនមានបុណ្យ ព្រោះកាយដែលឥតសារៈនេះ អញនឹងបានលាភរបស់បុគ្គល

ដែលជាអ្នកមិនញាប់ញ័រដោយខ្លួនឯង ដោយពិត ។

កាលគិតដូច្នេះហើយ ក៏ពោលថា ចូរនាងទៅចុះ យើងនឹងឲ្យវារៈរបស់នាងធ្វើងទៅ កាលពោលហើយ ខ្លួនឯងក៏ទៅដេកដាក់ក្បាលត្រង់ជ្រញ់សម្រាប់សម្លាប់ អ្នកពិសេសឃើញដូច្នោះ ក៏គិតថា ស្ដេចម្រឹគនេះព្រះរាជាបានឲ្យអភ័យហើយ ហេតុដូចម្ដេចហ្ន៎ ទើបមកដេកត្រង់ជ្រញ់ ក៏ប្រញាប់ទៅក្រាបទូលដល់ព្រះរាជា ។ ព្រះរាជា ទ្រង់យាងឡើងរថមករំពេចនោះឯង ទ្រង់យាងចូលទៅដោយបរិវារធំ ឃើញព្រះពោធិសត្វទើបត្រាស់ថា នែស្ដេចម្រឹគសម្លាញ់ យើងឲ្យអភ័យដល់អ្នកហើយ មិនមែនឬ ព្រោះហេតុអ្វី ទើបអ្នកមកដេកក្នុងទីនេះ ?

ស្ដេចម្រឹគពោលថា បពិត្រមហារាជ មានមេម្រឹគមួយ មានគភ៌ពោលថា សូមលោកធ្វើវារៈរបស់ខ្ញុំឲ្យដល់ម្រឹគដទៃ ទូលបង្គំមិនអាចបោះសេចក្ដីស្លាប់នេះ ទៅលើម្រឹគណាមួយបាន ព្រោះដូច្នោះ ទើបទូលបង្គំឲ្យជីវិតរបស់ខ្លួនដល់មេម្រឹគនោះ កាន់យកការស្លាប់របស់មេម្រឹគនោះជំនួស ទើបមកដេកក្នុងទីនេះ បពិត្រមហារាជ សូមទ្រង់កុំសង្ស័យក្នុងហេតុណាឡើយ ។

ព្រះរាជាត្រាស់ថា នែសុវណ្ណមិគរាជ សូម្បីក្នុងពួកមនុស្សទាំងឡាយ ខ្ញុំក៏មិនធ្លាប់ឃើញបុគ្គលដែលដល់ព្រមដោយខន្តី មេត្តា និងករុណាដូចអ្នកដែរ ដោយហេតុនេះ ទើបខ្ញុំជ្រះថ្លានឹងអ្នក សូមអ្នក

ក្រោកឡើង ខ្ញុំឲ្យអភ័យដល់អ្នកនិងមេម្រឹគនោះ ។

ស្តេចម្រឹគពោលថា បពិត្រព្រះសម្មតិទេព កាលទូលបង្គំទាំងពីរបានអភ័យហើយ ម្រឹគដ៏សេសក្រៅអំពីនោះ តើនឹងធ្វើដូចម្តេច?

ព្រះរាជាត្រាស់ថា ខ្ញុំនឹងឲ្យអភ័យដល់ម្រឹគដែលសេសសល់នោះទៀត ។

ស្តេចម្រឹគក្រាបទូលថា បពិត្រមហារាជ កាលបើយ៉ាងនោះ ម្រឹគទាំងឡាយ ក្នុងព្រះរាជឧទ្យានប៉ុណ្ណោះ បានអភ័យ ចុះម្រឹគដែលសេសសល់ គឺម្រឹគក្រៅឧទ្យាន ទ្រង់គិតដូចម្តេច ?

ព្រះរាជាត្រាស់ថា ខ្ញុំនឹងឲ្យអភ័យដល់ម្រឹគទាំងនោះ ។

ស្តេចម្រឹគក្រាបទូលថា បពិត្រមហារាជ ម្រឹគទាំងឡាយបានទទួលអភ័យ តើសត្វជើង ៤ ដែលសេសសល់ឯទៀត ទ្រង់គិតដូចម្តេច ?

ព្រះរាជាត្រាស់ថា សូម្បីសត្វជើង ៤ ដទៃទៀត ក៏ខ្ញុំឲ្យអភ័យដូចគ្នា ។

ព្រះពោធិសត្វក្រាបទូលថា បពិត្រមហារាជ សត្វជើង ៤ បានទទួលអភ័យហើយ តើពួកបក្សីទ្រង់គិតដូចម្តេច ?

ព្រះរាជាត្រាស់ថា សូម្បីពួកបក្សី ក៏ខ្ញុំឲ្យអភ័យ ។

ម្រឹគពោធិសត្វក្រាបទូលថា ពួកបក្សីទ្រង់ក៏ឲ្យអភ័យហើយ ចុះត្រីដែលនៅក្នុងទឹក ទ្រង់គិតដូចម្តេច?

*ព្រះរាជាត្រាស់ថា សូម្បីពួកត្រីទាំងនោះ ក៏ខ្ញុំឲ្យអភ័យដែរ ។*

*ព្រះមហាសត្វទូលសុំអភ័យដល់សព្វសត្វ ចំពោះព្រះរាជាយ៉ាងនេះហើយ ក្រោកឡើងឈរ ញ៉ាំងព្រះរាជាឲ្យតាំងនៅក្នុងសីល ៥ ហើយសម្ដែងធម៌ដល់ព្រះរាជាដោយពុទ្ធលីលាថា បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងព្រះជនក ព្រះជននី ក្នុងព្រះឱរស ព្រះធីតា ក្នុងព្រាហ្មណ៍គហបតី ក្នុងអ្នកនគរ និងអ្នកជនបទ កាលបើទ្រង់ប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ខាងមុខអំពីមរណៈ ព្រោះកាយបែកធ្លាយទៅ ក៏នឹងដល់សុគតិទេវលោក ដូច្នេះ ហើយសម្រាកក្នុងព្រះរាជឧទ្យានពីរ-បីថ្ងៃ ឲ្យឱវាទដល់ព្រះរាជា មានពួកបរិវារចោមរោមហើយក៏ទៅកាន់ព្រៃ ។ មេម្រឹគនោះ ក៏កើតកូនមកដូចគ្នានឹងបាច់ផ្កា ។ កូនម្រឹគនោះ កាលរត់លេងបានក៏ទៅកាន់សម្នាក់របស់សាខម្រឹគ ។ លំដាប់នោះ មេម្រឹគឃើញកូនម្រឹគនោះ កំពុងរត់ទៅកាន់សម្នាក់របស់សាខម្រឹគនោះ ទើបពោលថា នែកូន ចាប់អំពីពេលនេះទៅ អ្នកកុំទៅកាន់សម្នាក់របស់សាខម្រឹគឡើយ គប្បីចូលទៅកាន់សម្នាក់របស់និគ្រោធម្រឹគប៉ុណ្ណោះ កាលនឹងទូន្មានកូន ទើបពោលគាថានេះថា*

**និគ្រោធមេវ សេវេយ្យ ន សាខំ ឧបសំវសេ**
**និគ្រោធស្មឹ មតំ សេយ្យោ យញ្ចេ សាខស្មិ ជីវិតន្តិ ។**

*បុគ្គលគប្បីសេព នូវម្រឹគឈ្មោះនិគ្រោធៈ តែម្យ៉ាង កុំគប្បីសេព*

នូវម្រឹគឈ្មោះសាខៈឡើយ ការស្លាប់ក្នុងសម្នាក់នៃម្រឹគឈ្មោះ
និគ្រោធៈ ជាការប្រសើរ ការរស់នៅក្នុងសម្នាក់នៃម្រឹគឈ្មោះ
សាខៈ ពុំប្រសើរឡើយ ។

បណ្ដាបទទាំងនោះ បទថា **និគ្រោធមេវ សេវេយ្យ** សេចក្ដីថា នែបា អ្នកក្ដី អ្នកដទៃក្ដី កាលប្រាថ្នាចំពោះប្រយោជន៍ដល់ខ្លួន គួរសេព ឬគួរគប់រកតែស្ដេចម្រឹគឈ្មោះនិគ្រោធប៉ុណ្ណោះ ។

បទថា **ន សាខំ ឧបសំវសេ** សេចក្ដីថា តែម្រឹគឈ្មោះសាខៈ មិនគួរចូលទៅនៅរួម គឺមិនគួរចូលទៅជិតហើយនៅរួម បានដល់ មិនគួរអាស្រ័យម្រឹគឈ្មោះសាខៈ ចិញ្ចឹមជីវិត ។

បទថា **និគ្រោធស្មឹ មតំ សេយ្យោ** សេចក្ដីថា សូម្បីការស្លាប់ក្បែរបាតជើងរបស់ស្ដេចម្រឹគឈ្មោះនិគ្រោធ ប្រសើរជាង គឺឧត្ដមបំផុត ។

បទថា **យញ្ចេ សាខស្មិ ជីវិតំ** សេចក្ដីថា ឯការរស់នៅក្នុងសម្នាក់របស់ម្រឹគឈ្មោះសាខៈនោះ មិនប្រសើរ គឺមិនឧត្ដមឡើយ ។

ចាប់តាំងអំពីពេលនោះ ពួកម្រឹគដែលបានអភ័យ នាំគ្នាស៊ីសន្ទូងរបស់ពួកមនុស្ស ។ មនុស្សទាំងឡាយមិនអាចវាយ ឬដេញម្រឹគទាំងឡាយដោយគិតថា ម្រឹគទាំងនេះ ព្រះរាជាឲ្យអភ័យហើយ ទើបនាំគ្នាប្រជុំត្រង់លានព្រះរាជវាំង ក្រាបទូលសេចក្ដីនោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា យើងជ្រះថ្លាបានឲ្យពរនោះដល់ស្ដេចម្រឹគឈ្មោះនិគ្រោធ

ទោះបីយើងត្រូវលះបង់រាជសម្បត្តិ ក៏មិនអាចទម្លាយពាក្យប្តេជ្ញានោះ អ្នកទាំងឡាយចូរទៅចុះ អ្នកណាមួយក៏មិនអាចសម្លាប់ម្រឹគទាំងឡាយក្នុងដែនរបស់យើងបានឡើយ ។ ស្តេចម្រឹគនិគ្រោធបានស្តាប់ហេតុ-ការណ៍នោះហើយ ក៏ប្រជុំពួកម្រឹគ ឲ្យឱវាទដល់ម្រឹគទាំងឡាយថា ចាប់ពីពេលនេះទៅ អ្នកទាំងឡាយកុំស៊ីសន្ទូងរបស់ពួកមនុស្ស ដូច្នេះ ហើយប្រាប់ដល់មនុស្សទាំងឡាយថា ចាប់តាំងពីពេលនេះទៅ មនុស្សទាំងឡាយធ្វើស្រែចម្ការ កុំចាំបាច់ធ្វើរបងឡើយ គ្រាន់តែចងសញ្ញាដោយស្លឹកឈើក្ដួចជាកំណួចប៉ុណ្ណោះ ម្រឹគទាំងឡាយនឹងមិនបរិភោគដំណាំរបស់អ្នកទាំងឡាយឡើយ ។ បានឮថា ចាប់ពីពេលនោះមក មនុស្សទាំងឡាយ ក៏ធ្វើសញ្ញាស្លឹកឈើដើម្បីរក្សាដំណាំរបស់ខ្លួន ម្រឹគសូម្បីតែមួយដែលហ៊ានកន្លង គឺប្រព្រឹត្តល្មើសក្នុងសញ្ញាស្លឹកឈើនោះ មិនមានឡើយ បានឮថា នេះជាឱវាទដែលពួកម្រឹគទាំងនោះ បានអំពីព្រះពោធិ-សត្វ ។ ព្រះមហាសត្វទូន្មានម្រឹគយ៉ាងនេះហើយ តាំងនៅជាបដល់អស់អាយុ មួយអន្លើដោយម្រឹគទាំងឡាយ ក៏ទៅតាមយថាកម្ម ។ ឯព្រះរាជា ទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យទាំងឡាយ លុះអស់ព្រះជន្មក៏ទៅតាមយថាកម្មដូចគ្នា ។

ព្រះបរមសាស្តា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាទីពឹងអាស្រ័យរបស់មាតាកុមារកស្សបនិងកុមារកស្សប តែក្នុងកាលឥឡូវ

*នេះប៉ុណ្ណោះក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាទីពឹងអាស្រ័យហើយដូចគ្នា ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ក៏ប្រកាសសច្ចៈ ៤ ធ្វើរឿងទាំងពីរឲ្យជាប់តគ្នា ហើយទ្រង់ប្រជុំជាតកថា សាខម្រឹគក្នុងកាលនោះ បានមកជាទេវទត្ត បរិស័ទរបស់សាខម្រឹគនោះ ក៏បានមកជាបរិស័ទរបស់ទេវទត្តក្នុងកាលឥឡូវនេះ មេម្រឹគក្នុងកាលនោះ បានមកជាភិក្ខុនីមាតាកុមារកស្សប កូនម្រឹគក្នុងកាលនោះ បានមកជាកុមារកស្សប ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកស្តេចម្រឹគនិគ្រោធ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា និគ្រោធមិគជាតក ទី ២ ។

# អដ្ឋកថា កណ្ឋិនជាតក ទី ៣

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ គឺភរិយាក្នុងកាលមុន ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **ធិរត្ថុ កណ្ឋិនំ សល្លំ** ដូច្នេះជាដើម ។

ការលួងលោមនោះ នឹងជាក់ច្បាស់ក្នុង **ឥន្ទ្រិយជាតក អដ្ឋកនិបាត** ឯណោះ ។ ព្រះមានព្រះភាគ ទ្រង់បានត្រាស់ព្រះតម្រាស់នេះនឹងភិក្ខុនោះថា ម្នាលភិក្ខុ ក្នុងកាលមុនអ្នកអាស្រ័យមាតុគ្រាមនេះ ក៏ដល់នូវការអស់ជីវិត រើបម្រះលើរងើកភ្លើងដែលប្រាសចាកអណ្ដាត ។ កាលភិក្ខុទាំងឡាយក្រាបទូលអារាធនា ដើម្បីទ្រង់សម្ដែងរឿងនោះឲ្យជាក់ច្បាស់ ទើបទ្រង់ធ្វើហេតុដែលអន្តរភពបិទបាំងទុកឲ្យប្រាកដហើយខាងមុខអំពីនេះទៅ យើងនឹងមិនពោលដល់ការដែលភិក្ខុទាំងនោះក្រាបទូលអារាធនាទៀតឡើយ និងភាពដែលត្រូវអន្តរភពបិទបាំងក៏មិនពោលនឹងពោលចំពោះពាក្យមានប្រមាណប៉ុណ្ណេះថា **អតីតំ អាហរិ** ប្រែថាទ្រង់នាំអតីតនិទានមកសម្ដែងដូច្នេះប៉ុណ្ណោះ កាលពោលពាក្យមានប្រមាណប៉ុណ្ណេះ ក៏គប្បីប្រកបហេតុការណ៍ទាំងអស់នេះ គឺការក្រាបទូលអារាធនា ការប្រៀបធៀបដូចនាំព្រះចន្ទចេញចាកពពក និងភាពដែលហេតុត្រូវអន្តរភពបិទបាំងទុក ដោយន័យដូចពោលទុកខាងដើមនោះឯង ហើយគប្បីជ្រាប ។

ក្នុងអតីតកាល កាលព្រះបាទមគធៈសោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ដែនមគធៈ ។ ក្នុងកាលនោះ ជាសម័យដែលសន្ទូងរបស់អ្នកមគធៈកំពុងដុះលូតលាស់ ម្រឹគទាំងឡាយមានអន្តរាយច្រើន ម្រឹគទាំងនោះចូលទៅកាន់ជើងភ្នំ កាលនោះមានម្រឹគភ្នំមួយ អាស្រ័យនៅក្នុងព្រៃមួយកន្លែង ម្រឹគនោះ បានធ្វើសេចក្តីស្និទ្ធស្នាលជាមួយម្រឹគញីដែលជាម្រឹគស្រុកមួយក្បាល ក្នុងវេលាដែលពួកម្រឹគទាំងនោះ ចុះអំពីភ្នំត្រឡប់មកកាន់ជាយដែនវិញ ម្រឹគភ្នំនោះ ក៏បានចុះមកជាមួយម្រឹគទាំងនោះឯង ព្រោះមានចិត្តប្រតិព័ទ្ធក្នុងម្រឹគញីនោះ ។ លំដាប់នោះ ម្រឹគញីនោះក៏ពោលនឹងម្រឹគភ្នំថា **ត្វំ ខោសិ អយ្យ បព្វតេយ្យោ ពាលមិគោ គាមន្តោ ច ណាម សាសង្កោ សប្បដិភយោ មា អម្ហេហិ សទ្ធឹ ឱតរិ** នែអ្នក អ្នកជាម្រឹគភ្នំល្ងង់ខ្លៅ ធម្មតាជាយដែនជាទីដែលគួរភ័យខ្លាច ជាទីដែលគួររង្កៀស មានភ័យចំពោះមុខ អ្នកកុំចុះមកជាមួយពួកយើងឡើយ ម្រឹគភ្នំនោះមិនត្រឡប់ ព្រោះមានចិត្តប្រតិព័ទ្ធម្រឹគញីនោះបានមកជាមួយម្រឹគញីនោះឯង ។ អ្នកមគធៈដឹងថា ឥឡូវនេះ ជាពេលដែលពួកម្រឹគចុះអំពីភ្នំ ទើបឈរលាក់ខ្លួនក្បែរផ្លូវ ។ ក្នុងរវាងផ្លូវដែលម្រឹគទាំងពីរនោះដើរមក មានព្រានម្នាក់ឈរលាក់ខ្លួនក្នុងគុម្ពោតព្រៃក្បែរផ្លូវនោះ ម្រឹគញីប៉ះក្លិនមនុស្ស ក៏គិតថា ប្រហែលជាមានព្រានព្រៃឈរនៅក្នុងទីនេះ ទើបធ្វើម្រឹគភ្នំល្ងង់ខ្លៅនោះឲ្យនៅអំពីខាងមុខ ចំណែកខ្លួន

ឯងដើរតាមក្រោយ ព្រានបានធ្វើម្រឹគនោះឲ្យដួលក្នុងទីនោះឯង ដោយការបាញ់ត្រឹមតែមួយព្រួញប៉ុណ្ណោះ ម្រឹគញីដឹងថា ម្រឹគនោះ ត្រូវព្រួញហើយ ក៏លោតគេច រត់ទៅដោយកម្លាំងដ៏រហ័សដូចខ្យល់បក់ ។ នាយព្រានចេញអំពីគុម្ពោតព្រៃពន្លះសាច់ម្រឹគ បង្កាត់ភ្លើងអាំងសាច់លើរងើកភ្លើងដែលប្រាសចាកអណ្តាត បរិភោគហើយផឹកទឹក រែកសាច់ដែលសេសសល់ទៅដោយដងរែក ដោយមានឈាមម្រឹគហូរស្រក់ ទៅកាន់ផ្ទះរបស់ខ្លួនឲ្យពួកទារកត្រេកអរហើយ ។ ក្នុងកាលនោះ ព្រះពោធិសត្វកើតក្នុងកំណើតទេវតាក្នុងដងព្រៃនោះ ។ ព្រះពោធិសត្វឃើញហេតុ-ការណ៍ហើយ ទើបគិតថា ម្រឹគល្ងង់ខ្លៅនេះ ស្លាប់ព្រោះអាស្រ័យមាតាព្រោះអាស្រ័យបិតាក៏ទេ ដោយពិតស្លាប់ព្រោះអាស្រ័យកាម ពិតហើយព្រោះកាមជានិមិត្តហេតុ ទើបសត្វទាំងឡាយដល់នូវទុក្ខច្រើនប្រការមានការកាត់ដៃជាដើម ក្នុងសុគតិ និងមានការជាប់នូវចំណង ៥ ប្រការជាដើម ក្នុងទុគ្គតិ ។ ឈ្មោះថា ការធ្វើទុក្ខ គឺការស្លាប់ឲ្យកើតឡើងដល់អ្នកដទៃ ក៏ត្រូវតិះដៀលក្នុងលោកនេះ សូម្បីជនបទណា មានស្ត្រីជាអ្នកដឹកនាំចាត់ចែងគ្រប់គ្រង ក៏ត្រូវតិះដៀល ពួកសត្វណាធ្លាក់ក្នុងអំ-ណាចរបស់មាតុគ្រាម ក៏ត្រូវតិះដៀលដូចគ្នា ហើយសម្តែងរឿងសម្រាប់តិះដៀល ៣ ប្រការដោយគាថាមួយ កាលទេវតាទាំងឡាយក្នុងព្រៃឲ្យសាធុការហើយ បូជាដោយផ្កាកម្រងនិងគ្រឿងក្រអូបជាដើម កាលញ៉ាំង

ដងព្រៃនោះឲ្យខ្ទរខ្ទារដោយសំឡេងដ៏ពីរោះ ទើបសម្តែងធម៌ដោយគាថានេះថា

**ធិរត្ថុ កណ្ឌិនំ សល្លំ បុរិសំ គាឡ្ហវេធិនំ**
**ធិរត្ថុ តំ ជនបទំ យត្ថិត្ថី បរិណាយិកា**
**តេ វាបិ ធិក្កិតា សត្តា យេ ឥត្ថីនំ វសំ គតាតិ ។**

ចូរតិះដៀលនូវបុរសអ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង[១] ស្រីជាបរិណាយិកា ( អ្នកត្រួតត្រា ) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះក៏បណ្ឌិតតិះដៀលហើយ ។

បណ្ដាបទទាំងនោះ បទថា **ធិរត្ថុ** ក្នុងគាថានោះ ត្រឹមតែជានិបាតប្រើក្នុងអត្ថថា តិះដៀល ក្នុងទីនេះ សព្ទថា **ធិរត្ថុ** នោះ គប្បីឃើញថា ប្រើក្នុងការតិះដៀល ដោយអំណាចនៃការភ័យខ្លាច និងការតក់ស្លុត ពិតហើយ ព្រះពោធិសត្វជាបុគ្គលតក់ស្លុតផង ភ័យខ្លាចផង

---

១- គួរប្រែថា ចូរតិះដៀលនូវបុរសដែលមានសរ ( ជាអាវុធ ) ដែលបាញ់ទៅពេញកម្លាំង ទើបត្រូវតាមន័យរបស់អដ្ឋកថា ព្រោះព្រះពោធិសត្វតិះដៀលជន ៣ ពួក គឺ បុរសអ្នកកាន់ធ្នូ ១ ជនបទដែលមានស្រីជាអ្នកដឹកនាំ ១ និងសត្វដែលធ្លាក់ក្នុងអំណាចស្រី ១ ។

ទើបពោលយ៉ាងនោះ ។ បុគ្គលដែលឈ្មោះថា **កណ្ឋី** ព្រោះជាអ្នកមានព្រួញ ។ នូវបុគ្គលដែលមានព្រួញនោះ ។ ឯព្រួញនោះ គេហៅថា **សល្ល** ព្រោះអត្ថថា ចាក់ចូលទៅ ព្រោះដូច្នោះ ទើបក្នុងពាក្យថា **កណ្ឋិនំ សល្លំ** នេះ មានអត្ថថា បុគ្គលមានព្រួញ ម្យ៉ាងទៀត ឈ្មោះថា បុគ្គលមានព្រួញ ព្រោះមានព្រួញ ។ នូវបុគ្គលមានព្រួញនោះ ។ ឈ្មោះថា **គាឡ្ហវេធិ** ជាអ្នកបាញ់ទៅពេញកម្លាំង ព្រោះកាលឲ្យនូវការប្រហារដ៏ខ្លាំងក្លា ទើបបាញ់ពេញកម្លាំង ដោយធ្វើឲ្យមានរបួសធំ ។ បុគ្គលបាញ់ទៅយ៉ាងពេញកម្លាំងនោះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះថា យើងតិះដៀលបុគ្គលដែលប្រកបដោយអាវុធ មានប្រការផ្សេងៗ ។ ឈ្មោះ ថា **សល្ល** ព្រួញ ព្រោះបាញ់ទៅត្រង់ៗ ដោយមានសណ្ឋានដូចស្លឹកកោរមុខៈជាផល ដែលបាញ់ទៅយ៉ាងពេញកម្លាំងនោះ ។

បទថា **បរិណាយិកា** បានដល់ ជាធំ គឺជាអ្នកចាត់ចែង ។

បទថា **ធិក្កិតា** ប្រែថា តិះដៀលហើយ ។ ពាក្យដ៏សេសក្នុងគាថានេះ មានអត្ថងាយយល់ហើយ ខាងមុខអំពីនេះទៅ ខ្ញុំនឹងមិនពោលពាក្យសូម្បីមានប្រមាណប៉ុណ្ណេះ នឹងពោលពណ៌នាពាក្យដែលមានអត្ថលំបាកយល់ប៉ុណ្ណោះ ។

ព្រះបរមពោធិសត្វ កាលសម្តែងរឿងសម្រាប់តិះដៀល ៣ ប្រការ

ដោយគាថាមួយយ៉ាងនេះហើយ ធ្វើដងព្រៃឲ្យខ្ទរខ្ទារ សម្ដែងធម៌ដោយពុទ្ធលីលា ដូច្នេះ ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលអផ្សុកនោះ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្ដា ទ្រង់ត្រាស់រឿងពីរ បន្តអនុសន្ធិគ្នាហើយទ្រង់ប្រជុំជាតក ខាងមុខអំពីនេះទៅ ខ្ញុំនឹងមិនពោលពាក្យថា ត្រាស់រឿងទាំងពីរនេះ នឹងពោលចំពោះពាក្យមានប្រមាណប៉ុណ្ណេះថា ទ្រង់បន្តអនុសន្ធិដូច្នេះ ឯពាក្យនេះនឹងមិនពោលទុក ក៏គប្បីប្រកបសេចក្ដីដោយន័យដូចបានពោលហើយខាងដើមនោះឯង ។ ម្រឹគភ្នំក្នុងកាលនោះ បានមកជាភិក្ខុដែលអផ្សុកក្នុងកាលឥឡូវនេះ ម្រឹគមេក្នុងកាលនោះ បានមកជាភរិយាចាស់ក្នុងកាលឥឡូវនេះ ចំណែកទេវតាជាអ្នកសម្ដែងធម៌អំពីទោសក្នុងកាមទាំងឡាយក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កណ្ឌិនជាតក ទី ៣ ។

# អដ្ឋកថា ទាតមិគជាតក ទី ៤

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន ភិរត្តិ រសេហិ ចាបិយោ** ដូច្នេះជាដើម ។

បានឮថា កាលព្រះបរមសាស្តា ទ្រង់អាស្រ័យនៅក្នុងនគររាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័នមហាវិហារ ។ ថ្ងៃមួយ បុត្តរបស់សេដ្ឋីអ្នកមានទ្រព្យច្រើនម្នាក់ ឈ្មោះថា តិស្សកុមារ ទៅកាន់វត្តវេឡុវ័ន ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយមានបំណងនឹងបួស ទើបទូលសូមបព្វជ្ជា កាលមាតាបិតាមិនអនុញ្ញាត គឺត្រូវបដិសេធ ទើបធ្វើការអត់អាហារអស់ ៧ ថ្ងៃ ដើម្បីឲ្យមាតាបិតាអនុញ្ញាត ដូចគ្នានឹងព្រះរដ្ឋបាលត្ថេរដូច្នោះ បានបួសក្នុងសម្នាក់របស់ព្រះសាស្តាហើយ ។ ព្រះមានព្រះភាគ កាលទ្រង់ឲ្យតិស្សកុមារនោះបួសហើយ ទ្រង់គង់នៅក្នុងវិហារវេឡុវ័នប្រមាណកន្លះខែ ក៏យាងទៅកាន់វត្តជេតពន ទ្រង់គង់ក្នុងវត្តជេតពននោះ កុលបុត្តនោះ សមាទានធុតង្គ ១៣ ត្រាច់បិណ្ឌបាតតាមលំដាប់ច្រកក្នុងនគរសាវត្ថី ញុំាងកាលវេលាឲ្យកន្លងទៅ ជនទាំងឡាយតែងហៅលោកថា ព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ បានជាអ្នកប្រាកដច្បាស់ គឺគេស្គាល់ទូទៅក្នុងព្រះពុទ្ធសាសនា ដូចព្រះចន្ទពេញបូណ៌មីប្រាកដក្នុងលំហមេឃដូច្នោះ ។ ក្នុងកាលនោះ ការលេងនក្ខត្តឫក្សកំពុងប្រព្រឹត្តទៅក្នុង

នគររាជគ្រឹះ មាតាបិតារបស់ព្រះថេរៈ យកប្រអប់ប្រាក់ដែលរក្សាគ្រឿងប្រដាប់របស់ព្រះថេរៈ ក្នុងកាលនៅជាគ្រហស្ថនោះមកបើកមើល ហើយយកមកដាក់ត្រង់ទ្រូងទ្រហោយំ ពោលថា ក្នុងកាលលេងនក្ខត្តឫក្សដទៃៗ កូនរបស់ពួកយើងប្រដាប់ដោយគ្រឿងអលង្ការនេះ ហើយលេងនក្ខត្តឫក្ស ព្រះសមណគោតមនាំកូនតែមួយរបស់យើងទៅកាន់នគរសាវត្ថីហើយ ឥឡូវនេះ កូនរបស់យើងនោះអង្គុយក្នុងទីណាហ្ន៎ ឈរក្នុងទីណាហ្ន៎ ។ លំដាប់នោះ នាងវណ្ណទាសីទៅកាន់នគរនោះ ឃើញភរិយារបស់សេដ្ឋីកំពុងយំ ទើបសួរថា បពិត្រអ្នកម៉ែ អ្នកម៉ែយំព្រោះអ្វី ? ភរិយារបស់សេដ្ឋីក៏ប្រាប់សេចក្ដីនោះ នាងវណ្ណទាសីពោលថា បពិត្រអ្នកម៉ែ កូនរបស់អ្នកម៉ែស្រឡាញ់អ្វី ? ភរិយារបស់សេដ្ឋីប្រាប់ថា ស្រឡាញ់ចូលចិត្តរបស់ឈ្មោះនោះ ឈ្មោះនោះ ។ នាងវណ្ណទាសីពោលថា បើអ្នកម៉ែឲ្យភាពជាធំក្នុងផ្ទះទាំងអស់ដល់ខ្ញុំសោត ខ្ញុំនឹងនាំកូនរបស់អ្នកម៉ែមក ។ ភរិយារបស់សេដ្ឋីទទួលថា បាន ហើយឲ្យស្បៀង បញ្ជូននាងវណ្ណទាសីនោះទៅដោយបរិវារធំ រួចពោលថា ចូរនាងទៅ ហើយនាំកូនរបស់ខ្ញុំមកដោយកម្លាំងរបស់ខ្លួន ។ នាងវណ្ណទាសីនោះ អង្គុយក្នុងយានតូចដែលបិទបាំងទុកទៅកាន់នគរសាវត្ថី កាន់យកការនៅអាស្រ័យក្បែរផ្លូវមួយ ដែលព្រះថេរៈតែងត្រាច់បិណ្ឌបាត មិនឲ្យព្រះថេរៈឃើញពួកមនុស្សដែលមកអំពីត្រកូលរបស់សេដ្ឋី ចោមរោមដោយបរិវាររបស់

ខ្លួនប៉ុណ្ណោះ កាលព្រះថេរៈចូលទៅបិណ្ឌបាត បានប្រគេនយាគូមួយវែក និងភិក្ខាមានរសឆ្ងាញ់ ទាក់ព្រះថេរៈដោយចំណង់ក្នុងរសទុកតាំងអំពីខាងដើម ហើយនិមន្តឲ្យអង្គុយក្នុងផ្ទះ ប្រគេនភិក្ខាដោយលំដាប់ ដឹងថា ព្រះថេរៈធ្លាក់នៅក្នុងអំណាចរបស់ខ្លួន ទើបសម្តែងអាការជាឈឺដេកនៅខាងក្នុងបន្ទប់ ។ ព្រះថេរៈត្រាច់ទៅតាមលំដាប់ច្រកក្នុងវេលាភិក្ខាចារ បានទៅដល់ទ្វារផ្ទះនោះ ជនជាបរិវារ បានទទួលបាត្ររបស់លោកហើយនិមន្តឲ្យគង់ក្នុងផ្ទះ ។ ព្រះថេរៈគង់ហើយសួរថា **កហំ ឧបាសិកា** ឧបាសិកាទៅណា ?

ជនជាបរិវារឆ្លើយថា **គិលានា ភន្តេ តុម្ហាកំ ទស្សនំ ឥច្ឆតិ** បពិត្រលោកម្ចាស់ ឧបាសិកាមានជំងឺ ប្រាថ្នានឹងឃើញលោកម្ចាស់ ។

ព្រះថេរៈត្រូវតណ្ហាក្នុងរសរឹតរុំ ទម្លាយនូវការសមាទានរបស់ខ្លួនចូលទៅកាន់ទីដែលនាងវណ្ណទាសីនោះដេក ។ នាងវណ្ណទាសីដឹងហេតុនៃការមកដើម្បីខ្លួន ទើបចងព្រះថេរៈនោះដោយរសតណ្ហា ឲ្យសឹកហើយ ឲ្យតាំងនៅក្នុងអំណាចរបស់ខ្លួន ឲ្យអង្គុយខាងក្នុងយាន នាំទៅកាន់នគររាជគ្រឹះនោះឯង ដោយបរិវារធំ ។

ភិក្ខុទាំងឡាយអង្គុយប្រជុំក្នុងរោងធម្មសភាសន្ទនាគ្នាថា បានឮថានាងវណ្ណទាសីម្នាក់ ចងព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ដោយរសតណ្ហានាំទៅហើយ ។ ព្រះបរមសាស្តាទ្រង់យាងចូលកាន់រោងធម្មសភា គង់

លើបវរពុទ្ធាសនៈដែលគេតាក់តែងទុកហើយ ទ្រង់មានព្រះតម្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ? ភិក្ខុទាំងនោះក៏ក្រាបទូលរឿងរ៉ាវនោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះជាប់ក្នុងរសតណ្ហា ធ្លាក់នៅក្នុងអំណាចរបស់នាងវណ្ណទាសីនោះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុន ក៏ធ្លាក់ក្នុងអំណាចរបស់នាងដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងនគរពារាណសី នាយឧទ្យានបាលរបស់ព្រះបាទព្រហ្មទត្ត ឈ្មោះថា សញ្ជ័យ ។ គ្រានោះ មានម្រឹគស្មាន់[១] មួយមកកាន់ឧទ្យាននោះ ឃើញឧទ្យានបាលនោះហើយក៏គេចទៅ ចំណែកឧទ្យានបាលឈ្មោះសញ្ជ័យ មិនបានសម្គុតគំរាម ឬបង្អើលម្រឹគស្មាន់នោះឲ្យចេញទៅ ម្រឹគស្មាន់នោះ ក៏ត្រាច់មកក្នុងឧទ្យាននោះរឿយៗ ឧទ្យានបាលនោះ នាំយកផ្កានិងផ្លែឈើមានប្រការផ្សេងៗ មកពីព្រះរាជឧទ្យានអំពីព្រលឹម នាំទៅថ្វាយព្រះរាជារាល់ៗ ថ្ងៃ ។ សម័យមួយ ព្រះរាជាត្រាស់សួរឧទ្យានបាលនោះថា នែឧទ្យានបាលសម្លាញ់ អ្នកឃើញភាពអស្ចារ្យអ្វី ក្នុងឧទ្យានខ្លះដែរឬទេ ?

---

១-ម្រឹគអម្បូរឈ្លូស ប្រើស ក្តាន់ ដែលជាសត្វមានជាតិភ្ញាក់ផ្អើល ។

ឧទ្យានបាលក្រាបទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនឃើញវត្ថុដទៃ ឃើញតែម្រឹគស្មាន់មួយត្រាច់មកក្នុងព្រះរាជឧទ្យាន ទូលបង្គំបានឃើញត្រឹមតែប៉ុណ្ណោះ ។

ព្រះរាជាត្រាស់សួរថា អ្នកអាចចាប់ម្រឹគស្មាន់នោះបានដែរឬទេ ?

ឧទ្យានបាលក្រាបទូលថា បើបានទឹកឃ្មុំ ទូលបង្គំអាចនាំម្រឹគនោះឲ្យចូលមកខាងក្នុងព្រះរាជនិវេសន៍បាន ។ ព្រះរាជា ទ្រង់ឲ្យទឹកឃ្មុំដល់ឧទ្យានបាលនោះ ។ ឧទ្យានបាលនោះ ទទួលទឹកឃ្មុំហើយទៅកាន់ឧទ្យាន យកទឹកឃ្មុំប្រោះលើចុងស្មៅទាំងឡាយ ក្នុងទីដែលម្រឹគនោះត្រាច់ទៅ ។ ម្រឹគស្មាន់មកស៊ីស្មៅដែលប្រោះដោយទឹកឃ្មុំ ជាប់ចិត្តក្នុងរសតណ្ហា មិនទៅកាន់ទីដទៃ មកចំពោះតែក្នុងឧទ្យាននោះប៉ុណ្ណោះ ។ ឧទ្យានបាលដឹងថា ម្រឹគស្មាន់នោះ ជាប់ចិត្តក្នុងស្មៅដែលលាបដោយទឹកឃ្មុំ ក៏បង្ហាញខ្លួនឲ្យឃើញដោយលំដាប់ ម្រឹគស្មាន់នោះ កាលឃើញឧទ្យានបាលនោះពីរ-បី ថ្ងៃដំបូងក៏គេចទៅ ប៉ុន្តែលុះឃើញរឿយៗ ក៏ស្និទ្ធស្នាល ទោះបីស៊ីស្មៅដែលនៅក្នុងដៃរបស់ឧទ្យានបាល ក៏មិនផ្អើល ។ ឧទ្យានបាលដឹងថា ម្រឹគស្មាន់នេះស្និទ្ធស្នាលហើយ ទើបយកកន្ទេលផែងព័ទ្ធសងខាងផ្លូវ រហូតដល់ព្រះរាជនិវេសន៍ ហើយយកមែកឈើដែលបាក់ដាក់ពង្រាយក្នុងទីនោះៗ ស្ពាយឃ្លោកដែលដាក់ទឹកឃ្មុំ កាន់បាច់ស្មៅ ហើយពោយស្មៅដែលលាបដោយទឹកឃ្មុំខាងមុខម្រឹគនោះ ម្រឹគបានចូលទៅកាន់

ខាងក្នុងព្រះរាជនិវេសន៍នោះឯង ។ កាលម្រឹគចូលទៅខាងក្នុងហើយ មនុស្សទាំងឡាយក៏បិទទ្វារ ម្រឹគឃើញមនុស្សទាំងឡាយ មានខ្លួនញ័ររន្ធត់ ខ្លាចមរណភ័យ ទើបរត់ទៅរត់មកក្នុងព្រះរាជនិវេសន៍ ។ ព្រះរាជាទ្រង់យាងចុះអំពីប្រាសាទ ទតឃើញម្រឹគនោះមានខ្លួនញ័រចំប្រប់ ទើបត្រាស់ថា ធម្មតាម្រឹគរមែងមិនទៅកាន់ទីដែលមនុស្សឃើញខ្លួនអស់ ៧ ថ្ងៃ រមែងមិនទៅកាន់ទីដែលត្រូវមនុស្សសម្លុតគំរាម រហូតអស់មួយជីវិត តែក្នុងកាលឥឡូវនេះ ម្រឹគស្មាន់ដែលអាស្រ័យដងព្រៃរស់នៅបែបនេះ ត្រូវចងដោយចំណងគឺរស មកកាន់ទីមានសភាពបែបនេះ អ្នកដ៏ចម្រើនទាំងឡាយ ឈ្មោះថា វត្ថុដែលអាក្រក់ជាងចំណង់ក្នុងរស រមែងមិនមានក្នុងលោកហ្ន៎ ហើយទ្រង់ផ្តើមពោលនូវព្រះគាថានេះថា

**ន កិរត្ថិ រសេហិ បាបិយោ**
**អាវាសេហិ វា សន្ថវេហិ វា**
**វាតមិគំ គហនដិស្សិតំ**
**វសមានេសិ រសេហិ សញ្ជយោតិ ។**

(ឆន្ទរាគ) ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគដោយរសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះ សញ្ជ័យ បាននាំសត្វឈ្លូសដែលអាស្រ័យនូវព្រៃស្បាត មកកាន់អំណាច (របស់ខ្លួន) បាន

ព្រោះតែរសទាំងឡាយ ។

សព្ទថា **កិរ** ប្រែថា បានឮថា ក្នុងគាថានោះ ជានិបាតប្រើក្នុងអត្ថថា បានឮ បានស្តាប់ ។ បទថា **រសេហិ** ប្រែថា ដោយរសទាំងឡាយ សេចក្តីថា ដោយរសផ្អែមនិងរសជូរជាដើម ដែលគប្បីដឹងដោយអណ្តាត ។

បទថា **ធាបិយោ** ប្រែថា អាក្រក់ជាង ។

បទថា **អាវាសេហិ វា សន្ថវេហិ វា** សេចក្តីថា ការត្រេកត្រអាលដោយអំណាចការពេញចិត្តក្នុងទីលំនៅ គឺទីកន្លែងរស់នៅជាប្រចាំក្តី ក្នុងការស្និទ្ធស្នាលដោយអំណាចភាពជាមិត្តក្តី លាមកពិត តែរសក្នុងការបរិភោគដែលប្រព្រឹត្តទៅដោយឆន្ទរាគៈនោះឯង ជាសភាពអាក្រក់ជាងការបរិភោគដោយឆន្ទរាគៈក្នុងទីលំនៅ និងការស្និទ្ធស្នាលដោយភាពជាមិត្ត រាប់រយដង រាប់ពាន់ដង រាប់សែនដង ព្រោះអត្ថថា ត្រូវសេពចំពោះជាប្រចាំ និងព្រោះវៀរចាកអាហារហើយ ការរក្សាជីវិតិន្ទ្រិយ ក៏មិនមាន ព្រះពោធិសត្វទ្រង់ធ្វើអត្ថនេះ ឲ្យដូចជាម្រឹគដែលដើរតាមស្មៅមកដោយល្អ ទើបត្រាស់ថា ( ឆន្ទរាគ ) ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគដោយរសទាំងឡាយ មិនមានទេ ឥឡូវនេះ ព្រះបរមពោធិសត្វ កាលសម្តែងថា រសទាំងនោះជាធម្មជាតអាក្រក់ ទើបត្រាស់ពាក្យជាដើមថា **វាតមិគំ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **គហាឩនិស្សិតំ** ប្រែថា អាស្រ័យទីដែលជាដងព្រៃ លោកពោលអធិប្បាយទុកថា អ្នកទាំងឡាយ ចូរមើលភាពដែលរសទាំងឡាយ ជាសភាវៈអាក្រក់ ឧទ្យានបាលឈ្មោះសញ្ជ័យនាំម្រឹគស្មាន់នេះ ដែលអាស្រ័យនៅក្នុងដងព្រៃ គឺក្នុងព្រៃជ្រៅ មកកាន់អំណាចរបស់ខ្លួនដោយរសទឹកឃ្មុំ វត្ថុដទៃដែលអាក្រក់ជាង គឺលាមកជាង ឈ្មោះថា អាក្រក់ជាងរសទាំងឡាយ ដែលមានការបរិភោគដោយឆន្ទរាគៈ រមែងមិនមាន ដោយប្រការទាំងពួង ។

ព្រះបរមពោធិសត្វ ត្រាស់ទោសនៃតណ្ហាក្នុងរសដោយប្រការដូច្នេះ កាលត្រាស់ហើយ ទើបបញ្ជូនម្រឹគនោះទៅកាន់ព្រៃវិញ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងវណ្ណទាសីនោះចងភិក្ខុនោះ ដោយរសតណ្ហា ធ្វើទុកក្នុងអំណាចរបស់ខ្លួន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏បានធ្វើហើយដូចគ្នា ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ឧទ្យានបាលឈ្មោះសញ្ជ័យក្នុងកាលនោះ បានមកជានាងវណ្ណទាសី ក្នុងកាលឥឡូវនេះ ម្រឹគស្មាន់ក្នុងកាលនោះ បានមកជាចូឡបិណ្ឌបាតិកភិក្ខុ ចំណែកព្រះបាទពារាណសី គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា វាតមិគជាតក ទី ៤ ។

# អដ្ឋកថា ខរាទិយជាតក ទី ៥

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលប្រដៅក្រមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **អដ្ឋក្ខុរំ ខរាទិយេ** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុនោះជាអ្នកប្រដៅក្រ មិនទទួលឱវាទ លំដាប់នោះព្រះបរមសាស្តា បានត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកជាមនុស្សប្រដៅក្រ មិនទទួលឱវាទ ពិតឬ?*

*ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយ ព្រះអង្គ ។*

*ព្រះសាស្តាត្រាស់ថា សូម្បីក្នុងកាលមុនអ្នកក៏មិនទទួលឱវាទរបស់បណ្ឌិតទាំងឡាយ ព្រោះភាពជាអ្នកប្រដៅក្រ ទើបជាប់អន្ទាក់ដល់នូវការអស់ជីវិត ហើយទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វជាម្រឹគ ចោមរោមដោយម្រឹគនៅក្នុងព្រៃ ។ លំដាប់នោះ កាលម្រឹគញីដែលជាប្អូនស្រីរបស់ព្រះពោធិសត្វ បង្ហាញកូនរបស់ខ្លួន ហើយឲ្យទទួលយកដោយពាក្យថា* **ភាតិក មយំ តេ ភាគិនេយ្យោ ឯតំ មិគមាយំ ឧគ្គណ្ហាបេហិ** *បពិត្របងប្រុស នេះជាក្មួយរបស់បង សូមបងឲ្យរៀនមាយារបស់ម្រឹគណាមួយ ។ ម្រឹគ*

ពោធិសត្វពោលនឹងក្មួយនោះថា ក្នុងពេលឈ្មោះនោះ ចូរអ្នកមករៀនចុះ ។ ម្រឹគដែលជាក្មួយនោះ មិនមកតាមពេលកំណត់ ធ្វើ ៧ ថ្ងៃឲ្យកន្លងទៅដូចមួយថ្ងៃនោះឯង ។ កាលម្រឹគជាក្មួយនោះ មិនមករៀនមាយារបស់ម្រឹគហើយត្រាច់ទៅក៏ជាប់អន្ទាក់ ចំណែកមេរបស់ម្រឹគនោះចូលទៅរកម្រឹគដែលជាបងប្រុសហើយសួរថា បពិត្របង បងឲ្យក្មួយរបស់បងរៀនមាយារបស់ម្រឹគហើយឬ ?

ព្រះពោធិសត្វពោលថា នាងកុំទោមនស្សឡើយ បុត្តនោះមិនទទួលឱវាទ គឺពាក្យប្រៀនប្រដៅទេ បុត្តរបស់នាងមិនរៀនយកមាយារបស់ម្រឹគ ជាអ្នកមិនមានបំណងនឹងទទួលឱវាទឡើយ ហើយពោលគាថានេះថា

**អដ្ឋក្ខុរំ ខរាទិយេ មិគំ វង្កាតិវង្កិនំ**
**សត្តកាលេហតិក្កន្តំ ន នំ ឱវទិតុស្សហេតិ ។**

ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចគល់និងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលនៃដំបូន្មាន ៧ [១] នោះបានឡើយ ។

---

១- បទថា **សត្តកាលេហតិក្កន្តំ** គួរប្រែថា ជាសត្វកន្លងកាលនៃដំបូន្មាន ៧ ថ្ងៃ ទើបត្រូវតាមន័យអដ្ឋកថា ។

បណ្ដាបទទាំងនោះ បទថា **អដ្ឋក្ខុរំ** បានដល់ មានក្រចក ៨ ព្រោះជើងនីមួយៗ មានក្រចកពីរ ។ ព្រះពោធិសត្វហៅមេម្រឹគនោះដោយឈ្មោះថា ខរាទិយា ។

បទថា **មិគំ** ជាពាក្យរួម កាន់យកម្រឹគគ្រប់ប្រភេទ ។

បទថា **វង្កាតិវង្កិនំ** បានដល់ កោងក្រៃលែងជាងកោង គឺកោងតាំងអំពីគល់ស្នែងរហូតដល់ចុងស្នែង ឈ្មោះថា ជាអ្នកមានស្នែងកោងតាំងអំពីគល់រហូតដល់ចុង ព្រោះម្រឹគនោះមានស្នែងមានសភាពដូច្នោះ ទើបឈ្មោះថា កោងអំពីគល់រហូតដល់ចុង គឺមានស្នែងកោងតាំងអំពីគល់រហូតដល់ចុងនោះ ។

បទថា **សត្តកាលេហាតិក្កន្តំ** បានដល់ ដែលកន្លងឱវាទដោយពេលវេលាដែលឲ្យឱវាទអស់ ៧ ថ្ងៃ ។

ដោយបទថា **ន នំ ឱវទិតុស្សហេ** នេះ លោកសម្ដែងថា យើងមិនអាចឲ្យឱវាទម្រឹគដែលប្រដៅក្រនេះ សូម្បីតែការគិតដើម្បីនឹងទូន្មានម្រឹគនេះ ក៏មិនកើតឡើងដល់យើង ។

ក្នុងកាលនោះ ព្រានសម្លាប់ម្រឹគដែលប្រដៅក្រជាប់អន្ទាក់នោះកាន់យកតែសាច់ ហើយចៀសចេញទៅ ។

ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុ អ្នកជាបុគ្គលប្រដៅក្រ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនក៏ជាបុគ្គលប្រដៅ

ក្រដូចគ្នា ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែង ហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ម្រឹគដែលជាក្មួយក្នុងកាលនោះ បានមកជាភិក្ខុដែលប្រដៅក្រក្នុងកាលឥឡូវនេះ មេម្រឹគដែលជាប្អូនក្នុងកាលនោះ បានមកជាឧប្បលវណ្ណាថេរីក្នុងកាលឥឡូវនេះ ចំណែកម្រឹគដែលជាអ្នកឲ្យឱវាទក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ខរាទិយជាតក ទី ៥ ។

# អដ្ឋកថា តិបល្លត្ថមិគជាតក ទី ៦

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងពទរិការាម ក្នុងនគរកោសម្ពី ទ្រង់ប្រារព្ធព្រះរាហុលត្ថេរ ដែលប្រាថ្នាចំពោះការសិក្សា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **មិគំ តិបល្លត្ថំ** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា ក្នុងសម័យមួយ កាលព្រះបរមសាស្ដា ទ្រង់យាង ទៅកាន់ដែនអាឡវី គង់នៅក្នុងអគ្គាឡវចេតិយ ។ ក្នុងពេលថ្ងៃមានការស្ដាប់ធម៌ ឧបាសក ឧបាសិកា ភិក្ខុ និងភិក្ខុនីជាច្រើន ទៅកាន់វិហារដើម្បីស្ដាប់ធម៌ ។ កាលវេលាកន្លងទៅ ឧបាសិកា និងភិក្ខុនីទាំងឡាយមិនទៅ មានតែពួកភិក្ខុ និងពួកឧបាសកទាំងឡាយប៉ុណ្ណោះ ( ដែលទៅ )

តាំងអំពីនោះ ក៏មានការស្តាប់ធម៌ក្នុងពេលយប់ ក្នុងកាលចប់ការស្តាប់ធម៌ ភិក្ខុទាំងឡាយដែលជាព្រះថេរៈនាំគ្នាទៅកាន់លំនៅរៀងៗខ្លួន ភិក្ខុកំលោះ សាមណេរ និងពួកឧបាសកដេកត្រង់ឧបដ្ឋានសាលានោះឯង កាលពួកភិក្ខុកំលោះនិងពួកឧបាសកទាំងនោះ ចូលដល់ភាពនិទ្រា បុគ្គលខ្លះដេកស្រមុក បុគ្គលខ្លះដេកសង្កៀតធ្មេញ បុគ្គលខ្លះដេកមួយស្របក់ហើយក្រោកឡើង ពួកឧបាសកឃើញអាការប្លែកៗ របស់ភិក្ខុកំលោះ ក៏ទៅក្រាបទូលសេចក្តីនោះដល់ព្រះសម្មាសម្ពុទ្ធ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទថា **យោ បន ភិក្ខុ អនុបសម្បន្នេន សហ សេយ្យំ កប្បេយ្យ បាចិត្តិយំ** ភិក្ខុណាមួយដេកជាមួយនឹងអនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយៈ[១] ។

ព្រះបរមសាស្តា កាលទ្រង់បញ្ញត្តសិក្ខាបទដូច្នេះហើយ ទ្រង់យាងទៅកាន់នគរកោសម្ពី ។ ក្នុងការបញ្ញត្តិសិក្ខាបទនោះ ភិក្ខុទាំងឡាយក៏ពោលនឹងព្រះរាហុលថា អាវុសោរាហុល ព្រះមានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទទុកហើយ ឥឡូវនេះ ចូរលោកដឹងលំនៅរបស់ខ្លួន ។ ក្នុងកាលមុន ភិក្ខុទាំងឡាយបានធ្វើការអនុគ្រោះដល់ព្រះរាហុលនោះ នាំមកកាន់ទីលំនៅរបស់ខ្លួនហើយឲ្យព្រះរាហុលសម្រាក ព្រោះអាស្រ័យការ

---

១- បិ.៣ , ទំ. ២៩០ ។

គោរពក្នុងព្រះសាស្តា និងភាពដែលព្រះរាហុលនោះជាអ្នកស្រឡាញ់ចំពោះការសិក្សា បានរៀបចំគ្រែតូច ឲ្យចីវរដើម្បីទទួរក្បាល តែថ្ងៃនោះសូម្បីតែទីលំនៅក៏មិនបានឲ្យ ព្រោះខ្លាចចំពោះសិក្ខាបទ ។ ចំណែកព្រះរាហុលភទ្ទនោះ ក៏មិននិមន្តទៅកាន់សម្នាក់របស់ព្រះសាស្តា ដោយគិតថា ជាព្រះបិតារបស់អញ ឬនិមន្តទៅកាន់សម្នាក់ព្រះធម្មសេនាបតីដោយគិតថា ជាឧបជ្ឈាយ៍របស់អញ ឬមួយក៏និមន្តទៅកាន់សម្នាក់របស់ព្រះមហាមោគ្គល្លានដោយគិតថា ជាអាចារ្យរបស់អញ ឬក៏និមន្តទៅកាន់លំនៅរបស់ព្រះអានន្ទ ដោយគិតថា ជាលោកពូរបស់អញ បានចូលទៅកាន់វច្ចកុដិសម្រាប់បន្ទោបង់របស់ព្រះសាស្តា ដូចចូលទៅកាន់វិមានរបស់ព្រហ្ម សម្រេចការនៅហើយ ។ ឯទ្វារវច្ចកុដិសម្រាប់ប្រើប្រាស់របស់ព្រះសម្ពុទ្ធទាំងឡាយ បិតជិតស្និទ្ធល្អ ប្រស់ព្រំដោយគ្រឿងក្រអូប មានកម្រងផ្កាចងសំយុង ដុតប្រទីបមួយយប់ទល់ភ្លឺ ឯព្រះរាហុលភទ្ទអាស្រ័យសម្បត្តិរបស់វច្ចកុដិនោះ ទើបចូលទៅខាងក្នុងវច្ចកុដិនោះ ម្យ៉ាងទៀត ព្រោះភិក្ខុទាំងឡាយពោលថា ចូរលោកដឹងទីលំនៅ និងព្រោះភាពជាអ្នកស្រឡាញ់ចំពោះការសិក្សា ដោយគោរពក្នុងឱវាទ ទើបចូលទៅកាន់វច្ចកុដិនោះ ។ ឯក្នុងចន្លោះៗ ( ក្នុងកាលរៀងៗមក ) ភិក្ខុទាំងឡាយឃើញលោកមកអំពីចម្ងាយ ដើម្បីសាកល្បង ទើបធ្វើបង្គីឬអំបោសដែលសម្រាប់បោសសំរាមទុកខាងក្រៅ កាលព្រះរាហុលមានអាយុនោះមក

ដល់ក៏ពោលថា អាវុសោ អ្នកណាចោលរបស់ទាំងនេះ ។ ក្នុងការធ្វើនោះ កាលភិក្ខុខ្លះពោលថា ព្រះរាហុលមកផ្លូវនេះ តែព្រះរាហុលនោះមិនពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនដឹងរឿងនេះ ត្រឡប់ជាទុកដាក់វត្ថុនោះ ហើយសូមខមាទោសថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយអត់ទោសដល់ខ្ញុំ ហើយទើបទៅ ។ ព្រះរាហុលនោះជាអ្នកស្រឡាញ់ចំពោះការសិក្សាយ៉ាងនេះ លោកអាស្រ័យភាពជាអ្នកប្រាថ្នាចំពោះការសិក្សានោះឯង ទើបចូលទៅក្នុងវច្ចកុដិនោះ ។

កាលមុនអរុណរះ ព្រះសាស្តា ទ្រង់ប្រថាប់ឈរត្រង់ទ្វារវច្ចកុដិ ហើយទ្រង់ព្រះឧកាសិត ( គ្រហែម ) ឯព្រះរាហុលក៏គ្រហែមតប ។

ព្រះបរមសាស្តាត្រាស់សួរថា **កោ ឯសោ** នរណា ?

ព្រះរាហុលក្រាបទូលថា **អហំ រាហុលោ** បពិត្រព្រះអង្គ ខ្ញុំព្រះអង្គរាហុល ហើយចេញមកថ្វាយបង្គំ ។

ព្រះបរមសាស្តាត្រាស់សួរថា ម្នាលរាហុល ព្រោះហេតុអ្វីទើបអ្នកដេកក្នុងទីនេះ ?

ព្រះរាហុលក្រាបទូលថា បពិត្រព្រះអង្គ ព្រោះមិនមានលំនៅ ព្រោះថា ក្នុងកាលមុន ភិក្ខុទាំងឡាយតែងធ្វើនូវការអនុគ្រោះដល់ខ្ញុំព្រះអង្គ តែឥឡូវនេះមិនឲ្យទីលំនៅព្រោះខ្លាចត្រូវអាបត្តិ ខ្ញុំព្រះអង្គគិតថា ទីនេះមិនបៀតបៀនអ្នកដទៃ ដោយហេតុនេះ ទើបដេកក្នុងទីនេះ ។

លំដាប់នោះ ព្រះសាស្ដាក៏កើតធម្មសង្វេគឡើងថា ខាងដើមភិក្ខុទាំងឡាយលះបង់រាហុលយ៉ាងនេះ អំណឹះតទៅ ឲ្យទារកក្នុងត្រកូលទាំងឡាយដទៃ បួសហើយ នឹងធ្វើដូចម្ដេច ។ លំដាប់នោះ ព្រះសាស្ដាឲ្យភិក្ខុទាំងឡាយប្រជុំគ្នាអំពីព្រលឹម ហើយត្រាស់សួរព្រះធម្មសេនាបតីថា

ម្នាលសារីបុត្ត អ្នកដឹងទេថា យប់មិញរាហុលនៅក្នុងទីណា ?

ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជ្រាបទេ ។

ព្រះសាស្ដាត្រាស់ថា ម្នាលសារីបុត្ត យប់មិញរាហុលនៅក្នុងវច្ចកុដិ ម្នាលសារីបុត្ត អ្នកទាំងឡាយ កាលលះបង់រាហុលបានយ៉ាងនេះ អំណឹះតទៅ ឲ្យទារកក្នុងត្រកូលទាំងឡាយបួសហើយនឹងធ្វើដូចម្ដេច កាលបើយ៉ាងនោះ កុលបុត្តដែលបួសក្នុងសាសនានេះ នឹងជាអ្នកមិនមានទីពឹង ឥឡូវនេះ ចាប់អំពីពេលនេះទៅ **អនុជានាមិ ភិក្ខវេ អនុបសម្បន្នេន ទ្វិរត្តតិរត្តំ សហ សេយ្យំ កប្បេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យអ្នកទាំងឡាយ សម្រេចនូវទីដេកជាមួយនឹងអនុបសម្បន្ន អស់ពីរយប់ឬបីយប់បាន [១] ដូច្នេះ ។ ហើយទ្រង់បញ្ញត្តសិក្ខាបទ ទ្រង់ធ្វើឲ្យជាអនុប្បញ្ញត្តិក្នុងសេចក្ដីនេះ ។

---

១-បិ.៣ , ទំ. ២៩១ ។

សម័យនោះ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងរោងធម្មសភាហើយ ពោលគុណរបស់ព្រះរាហុលថា មើលចុះ អាវុសោទាំងឡាយ រាហុលនេះ ស្រឡាញ់ចំពោះការសិក្សាជាកំណត់ ឈ្មោះថា បុគ្គលត្រូវភិក្ខុទាំងឡាយពោលថា លោកចូរដឹងលំនៅរបស់ខ្លួន ក៏មិនឆ្លើយឆ្លងនឹងភិក្ខុមួយរូបថា ខ្ញុំជាកូនរបស់ព្រះទសពល លោកទាំងឡាយជាអ្នកណា ពួកលោកនោះឯង ចូរចៀសចេញទៅ ដូច្នេះហើយ បានសម្រេចការនៅក្នុងវច្ចកុដិ ។ កាលភិក្ខុទាំងនោះនាំគ្នាពោលយ៉ាងនេះ ព្រះបរមសាស្តាទ្រង់យាងចូលទៅកាន់រោងធម្មសភា គង់លើអាសនៈដែលគេតាក់តែងទុកហើយ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ? ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយសិក្ខាកាមកថា ( ពោលដោយភាពស្រឡាញ់ចំពោះការសិក្សា ) របស់ព្រះរាហុល មិនមែនសន្ទនាគ្នាដោយរឿងដទៃឡើយ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នកស្រឡាញ់ចំពោះការសិក្សា តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុនកើតក្នុងកំណើតសត្វតិរច្ឆាន ក៏ជាអ្នកស្រឡាញ់ចំពោះការសិក្សាដូចគ្នាហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមគធរាជមួយអង្គ គ្រងរាជសម្បត្តិក្នុងនគរ

រាជគ្រឹះ ។ ក្នុងកាលនោះ ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតម្រឹគ ដែលពួកម្រឹគចោមរោមហើយនៅក្នុងព្រៃ ។ គ្រានោះ មេម្រឹគមួយជាប្អូនរបស់ព្រះពោធិសត្វ នាំកូនតូចរបស់ខ្លួនចូលទៅរក ( ព្រះពោធិសត្វ ) ហើយពោលថា បពិត្របង សូមបងឲ្យក្មួយរបស់បងនេះ សិក្សាមាយារបស់ម្រឹគ ។ ព្រះពោធិសត្វទទួលពាក្យថា សាធុ ហើយពោលថា នែបា ចូរបាទៅសិនចុះ វេលាឈ្មោះនោះ ចូរបាមកសិក្សា ។ ក្មួយនោះមិនកន្លងពេលវេលាដែលឪពុកធំប្រាប់ ទៅរកឪពុកធំនោះ ហើយសិក្សាមាយារបស់ម្រឹគ ។ ថ្ងៃមួយ ម្រឹគនោះ ត្រាច់ទៅក្នុងព្រៃជាប់អន្ទាក់ ទើបស្រែកឲ្យម្រឹគដទៃដឹងថា ខ្ញុំជាប់អន្ទាក់ហើយ ។ ពួកម្រឹគនាំគ្នាផ្អើលរត់ទៅប្រាប់មេរបស់ម្រឹគនោះថា **បុត្តោ តេ ចាសេន ពទ្ធោ** កូនរបស់នាងជាប់អន្ទាក់ហើយ ។ មេម្រឹគនោះ ក៏ចូលទៅកាន់សម្នាក់របស់បងប្រុសសួរថា តើបងឲ្យក្មួយរបស់បងសិក្សាមាយារបស់ម្រឹគហើយឬ ?

ព្រះពោធិសត្វពោលថា នាងកុំរង្កៀសកម្មដ៏លាមកណាមួយរបស់កូននាងឡើយ យើងឲ្យកូនរបស់នាងសិក្សាមាយារបស់ម្រឹគល្អហើយ កូនរបស់នាងនឹងលះបង់អន្ទាក់នោះហើយត្រឡប់មក ទើបពោលគាថានេះថា

**មិគំ តិបល្លត្ថមនេកមាយំ**
**អដ្ឋក្ខុរំ អឌ្ឍរត្តាបចាយឹ**

**ឯកេន សោតេន ឆមាសស្សន្តោ**
**ឆហិ កលាហតិភោតិ ភាតិនេយ្យោតិ ។**

*អញបានញ៉ាំងម្រឹគ មានដំណេក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយបានដកដង្ហើមខ្ទប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត ( ព្រានព្រៃ ) ដោយកល ៦ យ៉ាង ។*

*បណ្តាបទទាំងនោះ បទថា* **មិគំ** *បានដល់ ម្រឹគដែលជាក្មួយ ។ បទថា* **តិបល្លត្ថំ** *សេចក្តីថា ការដេកហៅថា* **តិបល្លត្ថ** *ឈ្មោះថាជាអ្នកមានការដេក ៣ ឥរិយាបថ ព្រោះមានការដេកដោយអាការ ៣ យ៉ាង គឺដេកដោយចំហៀងទាំងពីរ និងដោយអាការដូចគោដេក គឺដេកដាក់ពោះទៅក្រោម ។ នូវម្រឹគដែលមានដំណេក ៣ នោះ ។ បទថា* **អនេកមាយំ** *បានដល់ មានមាយាច្រើន គឺមានកលច្រើន ។*

*បទថា* **អដ្ឋក្ខុរំ** *បានដល់ ជាអ្នកប្រកបដោយក្រចក ៨ ព្រោះជើងនីមួយៗ មានក្រចក ២ ។*

*បទថា* **អឌ្ឍរត្តាបចាយឹ** *សេចក្តីថា ម្រឹគឈ្មោះថា ផឹកទឹកក្នុងវេលាកណ្តាលយប់ ព្រោះរំលងបឋមយាមហើយ ក្នុងវេលាមជ្ឈិមយាម ទើបមកអំពីព្រៃហើយផឹកទឹក ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកផឹកទឹកក្នុងវេលាកណ្តាលយប់ ។ នូវម្រឹគនោះ ។ អធិប្បាយថា ម្រឹគ*

ដែលផឹកទឹកក្នុងវេលាកណ្ដាលយប់ យើងឲ្យម្រឹគដែលជាក្មួយរបស់យើងរៀនមាយារបស់ម្រឹគល្អហើយ ។

សួរថា ឲ្យរៀនដូចម្ដេច ?

ឆ្លើយថា នែប្អូនស្រី យើងឲ្យរៀនដោយប្រការដែលម្រឹគជាក្មួយដកដង្ហើមត្រង់ផែនដីដោយច្រមុះម្ខាង បញ្ឆោតព្រានដោយកលមាយា ៦ ប្រការ លោកពោលពាក្យអធិប្បាយនេះទុកថា យើងឲ្យកូនរបស់នាងរៀនហើយ ដោយប្រការដែលក្មួយនោះ មិនដកដង្ហើមក្នុងរន្ធច្រមុះខាងលើ ហើយដកដង្ហើមក្នុងរន្ធច្រមុះដែលនៅផ្ទប់ត្រង់ផែនដីនោះឯង គឺដោយច្រមុះម្ខាងដែលជាប់នឹងផែនដី ទើបគ្របសង្កត់ អធិប្បាយថា ទើបកន្ទងនាយព្រានដោយកលមាយា ៦ ប្រការ គឺដោយ ៦ ចំណែក ។

សួរថា កលមាយា ៦ ប្រការនោះ តើដូចម្ដេច ?

ឆ្លើយថា កលមាយា ៦ ប្រការនោះគឺ ដោយការលាតជើងទាំង ៤ ត្រង់ហើយដេកផ្អៀង ១ ដោយប្រើក្រចកទាំងឡាយកាយស្មៅនិងដីផុយៗ ១ ដោយធ្វើអណ្ដាតលៀនចេញមក ១ ដោយការធ្វើពោះឲ្យប៉ោងធំ ១ ដោយការបន្ទោបង់ឧច្ចារៈបស្សាវៈចេញមក ១ ដោយការអត់ដង្ហើម ១ ម្យ៉ាងទៀត លោកពោលថា នែប្អូនស្រី យើងឲ្យម្រឹគជាក្មួយរៀនមាយារបស់ម្រឹគ ដោយប្រការដែលគេអាចបញ្ឆោតព្រានតាមសញ្ញាថា ម្រឹគនេះស្លាប់ហើយ ដោយកលមាយាទាំង ៦ នេះ គឺដោយការកាយដី

ផុយៗ មកត្រង់ទីចំពោះមុខ ១ ដោយការបង្អោនខ្លួនទៅ ១ ដោយការត្រាប់ទៅទាំងសងខាង ១ ដោយការធ្វើពោះឲ្យប៉ោងឡើង ១ ដោយការធ្វើពោះឲ្យផត ១ និងឲ្យម្រឹគជាក្មួយនោះរៀនយកហើយ ដោយប្រការដែលម្រឹគជាក្មួយនោះ ដកដង្ហើមត្រង់ច្រមុះដែលផ្ទប់នឹងផែនដី ១ ធ្វើកលមាយា ៦ ប្រការ ដោយហេតុ ៦ ប្រការ ដែលសម្តែងទុកដោយន័យទាំងពីរ អធិប្បាយថា នឹងធ្វើល្បិច គឺបោកបញ្ឆោតនាយព្រាន ។ ព្រះពោធិសត្វហៅម្រឹគដែលជាប្អូនថា **ភោតិ** ប្រែថា នាងដ៏ចម្រើន ។

ដោយបទថា **ភាគិនេយ្យោ** នេះ ព្រះពោធិសត្វសំដៅដល់ម្រឹគដែលជាក្មួយបោកបញ្ឆោតព្រានដោយហេតុ ៦ ប្រការយ៉ាងនេះ ។

ព្រះពោធិសត្វ កាលសម្តែងភាពដែលក្មួយរៀនមាយាម្រឹគល្អហើយ ទើបលួងលោមម្រឹគញីដែលជាប្អូនឲ្យធូរស្បើយ ដោយប្រការយ៉ាងនេះ ។ កូនម្រឹគនោះ ជាប់អន្ទាក់មិនរើបម្រះឡើយ ដេកសណ្តូកជើងទាំង ៤ ទៅកាន់ទីដែលជាផាសុកត្រង់ផែនដី យកក្រចកទាំងឡាយនោះ កាយដីក្នុងទីជុំវិញ ដោយជើងទាំង ៤ ធ្វើដីនិងស្មៅឲ្យរាត់រាយ បន្ទោបង់ឧច្ចារៈបស្សាវៈចេញមក ធ្វើកឲ្យត្រង់ លៀនអណ្តាត ធ្វើសរីរៈឲ្យប្រឡាក់ដោយទឹកមាត់ ធ្វើខ្លួនឲ្យប៉ោងដោយការមិនដកដង្ហើម ធ្វើភ្នែកទាំងពីរឲ្យបញ្ឈរ ធ្វើខ្យល់ដង្ហើមក្នុងរន្ធច្រមុះខាងក្រោម មិនដកដង្ហើមក្នុងរន្ធច្រមុះខាងលើ ធ្វើសរីរៈឲ្យរឹង សម្តែងអាការរបស់ម្រឹគដែលស្លាប់

ហើយ ចំណែករុយក្បាលខៀវទាំងឡាយ ក៏មកចោមរោមម្រឹគនោះ ក្អែកទាំងឡាយ ក៏នាំគ្នាមកទំក្បែរៗនោះ ។ នាយព្រានយកដៃទះពោះ គិតថា ម្រឹគនេះ ប្រហែលជាជាប់អន្ទាក់យូរពេក ទើបហើមស្អុយយ៉ាង នេះ ព្រាននោះស្រាយខ្សែអន្ទាក់នោះចេញ ដោយគិតថា ឥឡូវនេះ អញនឹងពន្ធុះម្រឹគនេះ យកតែសាច់ទៅ ជាអ្នកមិនមានសេចក្ដីសង្ស័យ ហើយចេញទៅរកកាប់មែកឈើមកទ្រាប់ ចំណែកកូនម្រឹគក្រោកឡើង ឈរដោយជើងទាំង ៤ រលាស់កាយ សណ្ដូកកហើយ បានទៅកាន់ សម្នាក់របស់មេយ៉ាងរហ័ស ដូចពពកដែលត្រូវខ្យល់ព្យុះធំបក់ដូច្នោះ ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ រាហុលជាអ្នក ស្រឡាញ់ចំពោះការសិក្សាតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកស្រឡាញ់ចំពោះការសិក្សាដូចគ្នា ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែង ហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា កូនម្រឹគដែលជាក្មួយក្នុងកាល នោះ បានមកជារាហុលក្នុងកាលឥឡូវនេះ មេម្រឹគក្នុងកាលនោះ បាន មកជាឧប្បលវណ្ណាថេរី ក្នុងកាលឥឡូវនេះ ចំណែកម្រឹគដែលជាអ៊ំក្នុង កាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា តិបល្លត្ថមិគជាតក ទី ៦ ។

# អដ្ឋកថា មាលុតជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបព្វជិតដែលបួសឯចាស់ពីររូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **កាឡោ វា យទិ វា ជុណ្ហោ** *ដូច្នេះជាដើម ។*

*បានឮថា បព្វជិតទាំងពីររូបនោះ នៅក្នុងដងព្រៃមួយកន្លែង ក្នុងកោសលជនបទ ភិក្ខុមួយរូបឈ្មោះកាឡត្ថេរ មួយរូបទៀតឈ្មោះជុណ្ហត្ថេរ ។ ថ្ងៃមួយ ព្រះជុណ្ហត្ថេរ សួរព្រះកាឡត្ថេរថា* **ភន្តេ កាឡ សីតំ នាម កស្មឹ កាលេ ហោតិ** *បពិត្រលោកកាឡៈដ៏ចម្រើន ធម្មតារងាតែងមានក្នុងពេលណា ?*

*ព្រះកាឡត្ថេរនោះឆ្លើយថា* **កាឡេ ហោតិ** *រងាមានខាងរនោច ។*

*ថ្ងៃមួយ ព្រះកាឡត្ថេរ សួរព្រះជុណ្ហត្ថេរថា* **ភន្តេ ជុណ្ហ សីតំ នាម កស្មឹ កាលេ ហោតិ** *បពិត្រលោកជុណ្ហៈដ៏ចម្រើន ធម្មតារងា រមែងមានក្នុងពេលណា ?*

*ព្រះជុណ្ហត្ថេរនោះឆ្លើយថា* **ជុណ្ហេ ហោតិ** *រងាររមែងមានខាងខ្នើត ។ ព្រះថេរៈទាំងពីរអង្គនោះ កាលមិនអាចកាត់នូវសេចក្តីសង្ស័យរបស់ខ្លួនបាន ទើបនាំគ្នាទៅកាន់សម្នាក់របស់ព្រះបរមសាស្តា ថ្វាយបង្គំហើយក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតារងា រមែងមានក្នុងកាលណា ?*

ព្រះមានព្រះភាគ ទ្រង់ព្រះសណ្តាប់ពាក្យរបស់ភិក្ខុនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏ឆ្លើយបញ្ហានេះដល់អ្នកទាំងពីរហើយ តែអ្នកទាំងពីរកំណត់មិនបាន ព្រោះសង្ខេបនៃភព ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល នាជើងភ្នំមួយ មានសត្វពីរជាសម្លាញ់នឹងគ្នា គឺសត្វរាជសីហ៍មួយ សត្វខ្លាធំមួយ នៅក្នុងគុហាជាមួយគ្នានោះឯង ក្នុងកាលនោះ ព្រះបរមពោធិសត្វបួសជាឥសី ត្រង់ជើងភ្នំនោះដូចគ្នា ។ ថ្ងៃមួយ វិវាទក៏កើតឡើងដល់សម្លាញ់ទាំងពីរនោះ ព្រោះអាស្រ័យភាពរងា ខ្លាធំពោលថា រងាររមែងមានខាងរនោច រាជសីហ៍ពោលថា រងាររមែងមានចំពោះខាងខ្នើតប៉ុណ្ណោះ ។ សម្លាញ់ទាំងពីរនោះ មិនអាចកាត់សេចក្តីសង្ស័យនោះបាន ទើបមកសួរព្រះមហាសត្វ ។ ព្រះមហាសត្វក៏ពោលគាថានេះថា

**កាឡេ វា យទិ វា ជុណ្ហេ យទា វាយតិ មាលុតោ**
**វាតជានិ ហិ សីតានិ ឧភោត្ថមបរាជិតាតិ ។**

កាលណា ខ្យល់បក់ ទោះខាងរនោចក្តីខាងខ្នើតក្តី កាលនោះ ត្រជាក់ទាំងឡាយ ក៏កើតអំពីខ្យល់ អ្នកទាំងពីរ មិនចាលចាញ់ ក្នុងប្រស្នានេះឡើយ ។

បណ្តាបទទាំងនោះ បទថា **កាឡេ វា យទិ វា ជុណ្ហេ**

បានដល់ ក្នុងបក្ខខាងរនោចក្តី ក្នុងបក្ខខាងខ្នើតក្តី ។

បទថា **យទា វាយតិ មាលុតោ** សេចក្តីថា សម័យណា មានខ្យល់បក់មកអំពីទិសខាងកើតជាដើម សម័យនោះ រងាររមែងមាន ព្រោះហេតុអ្វី ? ព្រោះភាពរងាររមែងកើតឡើងអំពីខ្យល់ អធិប្បាយថា ព្រោះហេតុ កាលខ្យល់មាននោះឯង ទើបការរងាមាន ក្នុងសេចក្តីនេះ កាឡបក្ខក្តី សុក្កបក្ខក្តី មិនជាប្រមាណឡើយ ។

បទថា **ឧភោត្ថមបរាជិតា** សេចក្តីថា អ្នកទាំងពីរ មិនមានអ្នកណាចាញ់ មិនមានអ្នកណាឈ្នះ ក្នុងបញ្ហានេះ ។ ព្រះបរមពោធិសត្វឲ្យសម្លាញ់ទាំងពីរនោះ យល់ព្រមដោយប្រការដូច្នេះ ។

ចំណែកព្រះបរមសាស្តា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងកាលមុន តថាគតក៏បានឆ្លើយបញ្ហានេះដល់អ្នកទាំងឡាយហើយ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងកាលចប់សច្ចៈ ព្រះថេរៈទាំងពីររូបនោះ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ខ្លាធំក្នុងកាលនោះ បានមកជាកាឡភិក្ខុ រាជសីហ៍ ក្នុងកាលនោះ បានមកជាជុណ្ហភិក្ខុ ចំណែកតាបសដែលដោះស្រាយប្រស្នាក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មាលុតជាតក ទី ៧ ។

# អដ្ឋកថា មតកភត្តជាតក ទី ៨

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធមតកភត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ឯវញ្ចេ សត្តា ជានេយ្យុំ** *ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា ក្នុងកាលនោះមនុស្សទាំងឡាយសម្លាប់ពពែជាដើម ឲ្យមតកភត្ត ( ឧទ្ទិសដល់ញាតិទាំងឡាយដែលស្លាប់ទៅហើយ ) ភិក្ខុទាំងឡាយឃើញមនុស្សទាំងនោះ ធ្វើយ៉ាងនោះ ទើបក្រាបទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ មនុស្សទាំងឡាយធ្វើសត្វមានជីវិតជាច្រើនឲ្យដល់នូវការអស់ជីវិត ហើយឲ្យឈ្មោះថា មតកភត្ត សេចក្ដីចម្រើនក្នុងការឲ្យមតកភត្តនេះ មានដែរឬហ្ន៎ ព្រះអង្គ ?*

*ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាសេចក្ដីចម្រើនណាមួយ ក្នុងបាណាតិបាត ដែលជនទាំងនេះធ្វើដោយគិតថា ពួកយើងនឹងឲ្យមតកភត្តដូច្នេះ រមែងមិនមានឡើយ ក្នុងកាលមុនបណ្ឌិតទាំងឡាយអង្គុយក្នុងអាកាសសម្ដែងធម៌ ពោលទោសក្នុងការធ្វើបាណាតិបាតនេះ ឲ្យជនក្នុងជម្ពូទ្វីបទាំងមូលលះបង់នូវកម្មអាក្រក់នោះ តែឥឡូវនេះ កម្មនោះត្រឡប់កើតឡើងសាជាថ្មីទៀត ព្រោះសត្វទាំងឡាយនោះជាអ្នកនៅក្នុងសង្ខេបនៃភព ហើយទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី មានអាចារ្យទិសាបាមោក្ខដែលជាអ្នកសម្រេចត្រៃវេទម្នាក់ គិតថា នឹងធ្វើមតកភត្ត ទើបឲ្យចាប់ពពែមួយមក ពោលនឹងអន្តេវាសិកទាំងឡាយថា នែបាទាំងឡាយ ពួកបាចូរនាំពពែនេះទៅកាន់ស្ទឹង យកកម្រងផ្កាពាក់ត្រង់ក ប្រោះព្រំ ប្រដាប់តាក់តែងហើយ សឹមនាំមក ។ អន្តេវាសិកទាំងឡាយទទួលពាក្យហើយ នាំពពែនោះទៅកាន់ស្ទឹង ឲ្យងូតទឹកប្រដាប់តាក់តែងហើយ ចងទុកត្រង់ឆ្នេរស្ទឹង ។ ពពែនោះឃើញកម្មចាស់របស់ខ្លួនកើតសោមនស្សថា* **ឯវរូបា ជាម ទុក្ខា អជ្ជ មុច្ចិស្សាមិ** *អញរួចផុតចាកទុក្ខមានសភាពបែបនេះ ក្នុងថ្ងៃនេះ ហើយក៏សើចដូចគេវាយឆ្នាំងដី ហើយក៏ត្រឡប់មានស្មារតីគិតបានទៀតថា* **អយំ ព្រាហ្មណោ មំ ឃាតេត្វា មយា លទ្ធទុក្ខំ លភិស្សតិ** *ព្រាហ្មណ៍នេះ សម្លាប់អញហើយ នឹងសោយនូវទុក្ខដូចដែលអញធ្លាប់សោយហើយ កើតសេចក្តីករុណាចំពោះព្រាហ្មណ៍ ក៏យំដោយសំឡេងខ្លាំង ។ លំដាប់នោះ មាណពទាំងនោះ ក៏សួរពពែនោះថា នែពពែសម្លាញ់ ហេតុអ្វីទើបអ្នកសើចផងយំផង ដោយសំឡេងខ្លាំងដូច្នេះ តើអ្នកសើចព្រោះហេតុអ្វី តើអ្នកយំព្រោះហេតុអ្វី ?*

*ពពែឆ្លើយថា លោកទាំងឡាយគប្បីសួរហេតុនេះ ក្នុងសម្នាក់អាចារ្យរបស់លោក ។ មាណពទាំងនោះក៏នាំពពែនោះទៅ ហើយប្រាប់*

ហេតុនេះដល់អាចារ្យ អាចារ្យបានស្តាប់ពាក្យរបស់មាណពទាំងនោះ ហើយក៏សួរថា នែពពែ ព្រោះហេតុអ្វីទើបអ្នកសើច ព្រោះហេតុអ្វីទើបអ្នកយំ?

ពពែរឭកដល់កម្មដែលខ្លួនបានធ្វើ ដោយញាណជាគ្រឿងរឭកជាតិបាន ទើបឆ្លើយនឹងព្រាហ្មណ៍ថា បពិត្រព្រាហ្មណ៍ ក្នុងកាលមុន ខ្ញុំជាព្រាហ្មណ៍ស្វាធ្យាយមន្តដូចជាលោកនោះឯង គិតថា នឹងឲ្យមតកភត្ត ទើបឲ្យសម្លាប់ពពែមួយហើយឲ្យមតកភត្ត ព្រោះខ្ញុំសម្លាប់ពពែមួយ ខ្ញុំនោះ ដល់នូវការស្លាប់ គឺត្រូវគេកាត់ក្បាលក្នុង ៤៩៩ អត្តភាព នេះជាអត្តភាពទី ៥០០ របស់ខ្ញុំ គឺជាអត្តភាពក្នុងទីបំផុត ខ្ញុំកើតសោមនស្សថា ថ្ងៃនេះ អាត្មាអញនឹងរួចផុតចាកទុក្ខដែលមានសភាពបែបនេះ ដោយហេតុនេះ ទើបខ្ញុំសើច តែខ្ញុំយំព្រោះអាណិតដល់លោក ដោយគិតថា កាលពីមុនខ្ញុំសម្លាប់ពពែមួយ សោយនូវទុក្ខ គឺត្រូវគេកាត់ក្បាលអស់ ៥០០ ជាតិ ទើបផុតទុក្ខនោះ ថ្ងៃនេះ ព្រាហ្មណ៍សម្លាប់អាត្មាអញហើយ នឹងទទួលទុក្ខ គឺត្រូវគេកាត់ក្បាល ៥០០ ជាតិដូចអញដែរ ។

ព្រាហ្មណ៍ពោលថា អើពពែ អ្នកកុំខ្លាចឡើយ ខ្ញុំនឹងមិនសម្លាប់អ្នកទេ ។

ពពែពោលថា នែព្រាហ្មណ៍ លោកនិយាយអ្វី ទោះបីលោកសម្លាប់ខ្ញុំក្តី មិនសម្លាប់ក្តី ថ្ងៃនេះ ខ្ញុំមិនអាចផុតអំពីសេចក្តីស្លាប់បាន

ឡើយ ។

ព្រាហ្មណ៍ពោលថា នែពពែ អ្នកកុំខ្លាចឡើយ ខ្ញុំនឹងរក្សាអ្នក ត្រាច់ទៅជាមួយអ្នកប៉ុណ្ណោះ ។

ពពែពោលថា នែព្រាហ្មណ៍ ការរក្សារបស់លោកមានប្រមាណតិច បំណែកបាបកម្មមានកម្លាំងច្រើន ។ ព្រាហ្មណ៍ឲ្យលែងពពែនោះហើយពោលថា យើងនឹងមិនឲ្យអ្នកណាម្នាក់សម្លាប់ពពែនេះឡើយ ។ ព្រាហ្មណ៍នាំពួកអន្តេវាសិកត្រាច់ទៅជាមួយពពែនោះឯង ។ ពពែគ្រាន់តែគេលែងទៅប៉ុណ្ណោះ ក៏ងើយកឡើង គិតនឹងបរិភោគស្លឹកឈើដែលដុះនៅក្បែរផ្ទាំងថ្មមួយផ្ទាំង រំពេចនោះឯង រន្ទះក៏ធ្លាក់ចុះលើផ្ទាំងថ្មនោះ បំណែកថ្មមួយ ក៏ហោះមកកាត់កពពែដែលកំពុងងើយនោះ ក្បាលក៏ដាច់ទៅ មហាជនទាំងឡាយប្រជុំគ្នាហើយ ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វកើតជារុក្ខទេវតាក្នុងទីនោះ ។ ព្រះមហាសត្វ កាលមហាជនកំពុងឃើញនោះឯង អង្គុយពត់ភ្នែនក្នុងអាកាសដោយទេវានុភាព ពោលថា សត្វដឹងនូវផលរបស់បាបយ៉ាងនេះ មិនគួរធ្វើនូវបាបឡើយ កាលនឹងសម្ដែងធម៌ដោយសំឡេងដ៏ពីរោះ ទើបពោលគាថានេះថា

ឯវញ្ចេ សត្តា ជានេយ្យុំ ទុក្ខាយំ ជាតិសម្ភវោ
ន បាណោ បាណិនំ ហញ្ញេ បាណឃាតី ហិ សោចតីតិ ។

បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំ

មកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក ។

បណ្ដាបទទាំងនោះ បទថា **ឯវញ្ចេ សត្តា ជានេយ្យុំ** សេចក្ដីថា សត្វទាំងនេះ គប្បីដឹងយ៉ាងនេះ ។

សួរថា គប្បីដឹងដូចម្ដេច ?

ឆ្លើយថា គប្បីដឹងថា ជាតិសម្ភពនេះជាទុក្ខ អធិប្បាយថា បើគប្បីដឹងថា ការកើតក្នុងភពនោះៗ និងការសម្ភព ពោលគឺការចម្រើនរបស់បុគ្គលដែលកើតដោយលំដាប់នេះ ឈ្មោះថាជាទុក្ខ ព្រោះជាវត្ថុ គឺជាទីតាំងនៃទុក្ខទាំងឡាយ មានជរា ព្យាធិ មរណៈ កាលជួបនឹងវត្ថុដែលមិនជាទីប្រាថ្នា ការព្រាត់ប្រាសចាកវត្ថុដែលជាទីស្រឡាញ់ និងការត្រូវកាត់ដៃ កាត់ជើងជាដើម ។

បទថា **ន ចាណោ ចាណិនំ ហញ្ញេ** សេចក្ដីថា សត្វណាមួយដឹងថា ជាតិសម្ភព ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខថា បុគ្គលធ្វើសត្វដទៃឲ្យចម្រើន រមែងបាននូវសេចក្ដីចម្រើនក្នុងជាតិសម្ភព កាលបៀត-បៀនសត្វដទៃ រមែងបានទទួលការបៀតបៀនដូច្នេះ ទើបមិនគួរសម្លាប់សត្វដទៃ អធិប្បាយថា សត្វមិនគួរសម្លាប់សត្វ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះបុគ្គលដែលមានប្រក្រតីសម្លាប់សត្វ រមែងសោយ

សោក អធិប្បាយថា ព្រោះបុគ្គលដែលមានប្រក្រតីសម្លាប់សត្វ ដោយការចូលទៅកាត់ផ្តាច់ជីវិតិន្ទ្រិយរបស់សត្វដទៃ ដោយប្រយោគឯណានីមួយ ក្នុងបណ្តាប្រយោគ ៦ មានសាហត្ថិកប្បយោគជាដើម នឹងសោយទុក្ខដ៏មហន្តក្នុងអបាយទាំង ៤ នេះ គឺក្នុងមហានរក ៨ រណ្តៅ ក្នុងឧស្សទនរក ១៦ រណ្តៅ ក្នុងកំណើតសត្វតិរច្ឆានមានប្រការផ្សេងៗ ក្នុងកំណើតបេត្តិវិស័យ និងក្នុងកំណើតអសុរកាយ ឈ្មោះថា រមែងសោយសោកដោយការសោយសោកដែលមានការដុតចម្អិន គឺឆេះខាងក្នុងជាលក្ខណៈអស់កាលយូរ ម្យ៉ាងទៀត សត្វដឹងថា ពពែនេះសោយសោកហើយ ព្រោះមរណភ័យយ៉ាងណា បុគ្គលមានប្រក្រតីសម្លាប់សត្វ រមែងសោយសោកអស់កាលយូរដូច្នោះ យ៉ាងនេះហើយ មិនគួរសម្លាប់សត្វ អធិប្បាយថា បុគ្គលមិនគួរធ្វើនូវកម្មគឺបាណាតិបាត ឯបុគ្គលដែលវង្វេងព្រោះមោហៈ កាលអវិជ្ជាធ្វើឲ្យជាបុគ្គលខ្វាក់ហើយ មិនឃើញទោសនេះ រមែងធ្វើនូវបាណាតិបាត ។

ព្រះបរមពោធិសត្វ សម្តែងធម៌ដោយលើកភ័យក្នុងនរកមកគំរាមដោយប្រការដូច្នេះ មនុស្សទាំងឡាយស្តាប់ព្រះធម្មទេសនានោះហើយ ខ្លាចភ័យក្នុងនរក នាំគ្នាវៀរចាកបាណាតិបាត ។ ចំណែកព្រះពោធិសត្វ កាលសម្តែងធម៌ហើយ ញុំាងមហាជនឲ្យតាំងនៅក្នុងសីល ៥ លុះអស់ជីវិតក៏បានទៅតាមយថាកម្ម ។

ចំណែកមហាជនតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើម ញុំាំងទេវនគរឲ្យពេញហើយ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ម្នាលភិក្ខុទាំងឡាយ សម័យនោះរុក្ខទេវតា គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មតកភត្តជាតក ទី ៨ ។

# អដ្ឋកថា អាយាចិតភត្តជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពលិកម្ម គឺការបួងសួងដល់ទេវតាទាំងឡាយ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **សចេ មុញ្ចេ បេច្ច មុញ្ចេ** ដូច្នេះជាដើម។

បានឮថា ក្នុងកាលនោះ មនុស្សទាំងឡាយ កាលទៅជួញដូរបាននាំគ្នាសម្លាប់សត្វ ធ្វើពលិកម្មដល់ទេវតាទាំងឡាយ បួងសួងបន់ស្រន់ថា **មយំ អនន្តរាយេន អត្ថសិទ្ធឹ បត្វា អាគន្ត្វា បុន តុម្ហាកំ ពលិកម្មំ ករិស្សាម** បើយើងខ្ញុំទាំងឡាយ ដល់នូវការសម្រេចប្រយោជន៍ដោយមិនមានអ្វីរារាំង ហើយត្រឡប់មក នឹងធ្វើពលិកម្មដល់លោកទាំងឡាយ ដូច្នេះហើយ ទើបនាំគ្នាទៅ ។ ក្នុងកាលនោះ ពួកជនទាំងនោះ

ក៏ដល់នូវការសម្រេចប្រយោជន៍ ដោយមិនមានអន្តរាយណាមួយ ពួកជនទាំងនោះសម្គាល់ថា ផលនេះកើតដោយអានុភាពរបស់ទេវតា ទើបនាំគ្នាសម្លាប់សត្វជាច្រើនធ្វើពលិកម្ម ដើម្បីលាបំណន់ ។

ភិក្ខុទាំងឡាយឃើញដូច្នោះហើយ ទើបទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ប្រយោជន៍ក្នុងការបន់ស្រន់បួងសួងនេះ មានដែរឬទេ ? ព្រះបរមសាស្តា ទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល មានកុដុម្ពិកៈម្នាក់នៅក្នុងស្រុកមួយ នាដែនកាសី បេ្តជ្ញាពលិកម្មដល់ទេវតាដែលអាស្រ័យត្រង់ដើមជ្រៃមួយដើម ក្បែរទ្វារស្រុក ហើយត្រឡប់មកដោយមិនមានអន្តរាយ ទើបសម្លាប់សត្វជាច្រើន ហើយនាំទៅកាន់គល់ជ្រៃដោយតាំងចិត្តថា នឹងលាបំណន់ ។ ខណៈនោះ រុក្ខទេវតាឈរត្រង់ប្រគាបឈើបានពោលគាថានេះថា

**សចេ មុញ្ចេ បេច្ច មុញ្ចេ មុច្ចមានោ ហិ ពជ្ឈសិ**
**ន ហេវំ ធីរា មុច្ចន្តិ មុត្តិ ពាលស្ស ពន្ធនន្តិ ។**

បើអ្នកចង់រួច ត្រូវរួចក្នុងលោកខាងនាយ ព្រោះថា អ្នករួចឥឡូវនេះ គង់ជាប់ ( ដោយបាបកម្ម ) អ្នកប្រាជ្ញទាំងឡាយមិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថាចំណងវិញទេ ។

*បណ្ដាបទទាំងនោះ បទថា* **សចេ មុញ្ចេ បេច្ច មុញ្ចេ** *សេចក្ដីថា នៃបុរសដ៏ចម្រើន បើអ្នកចង់ដោះខ្លួន គឺអ្នកប្រាថ្នានឹងដោះខ្លួន អ្នកលះលោកនេះទៅហើយ ក៏នឹងផុតបាន គឺចូរផុតដោយប្រការដែលមិនជាប់ជំពាក់ក្នុងលោកខាងមុខ ។*

*បទថា* **មុច្ចមានោ ហិ ពជ្ឈសិ** *សេចក្ដីថា ឯអ្នកកាលនឹងដោះដោយប្រការដែលប្រាថ្នាដើម្បីសម្លាប់សត្វ ឈ្មោះថា គង់ជាប់ដោយកម្មដ៏លាមក ។*

*សួរថា ព្រោះហេតុអ្វី ?*

*ឆ្លើយថា ព្រោះអ្នកប្រាជ្ញទាំងឡាយ មិនដោះខ្លួនដោយអាការយ៉ាងនេះឡើយ អធិប្បាយថា បុរសដែលជាបណ្ឌិតទាំងនោះ រមែងមិនដោះខ្លួនដោយពាក្យសន្យាយ៉ាងនេះ ។*

*សួរថា ព្រោះហេតុអ្វី?*

*ឆ្លើយថា ព្រោះការដោះខ្លួនបែបនេះ ជាហេតុជាប់ជំពាក់របស់បុគ្គលពាល គឺជម្មតាការដោះខ្លួនព្រោះធ្វើបាណាតិបាតនេះ រមែងជាហេតុជាប់ជំពាក់របស់បុគ្គលពាល ។ រុក្ខទេវតាសម្ដែងធម៌ដោយប្រការដូច្នេះ តាំងអំពីពេលនោះមក មនុស្សទាំងឡាយវៀរចាកកម្ម គឺបាណាតិបាតដែលមានសភាពបែបនេះ នាំគ្នាប្រព្រឹត្តធម៌ញុំាងទេវនគរឲ្យពេញហើយ ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង ហើយ ទ្រង់បន្តអនុសន្ធិហើយប្រជុំជាតកថា សម័យនោះ រុក្ខទេវតា គឺ* **តថាគត** *នេះឯង ។*

ចប់ អដ្ឋកថា អាយាចិតភត្តជាតក ទី ៩ ។

# អដ្ឋកថា នឡបានជាតក ទី ១០

*ព្រះបរមសាស្តា កាលទ្រង់ចារិកទៅក្នុងកោសលជនបទ ដល់ស្រុកមួយឈ្មោះ នឡកបានគាម ទ្រង់គង់នៅក្នុងកេតកវ័ន ជិតនឡកបានបោក្ខរណី ទ្រង់ប្រារព្ធដើមបបុសទាំងឡាយ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **ទិស្វា បទមនុត្តិណ្ណំ** *ដូច្នេះជាដើម ។*

*បានឮថា ក្នុងកាលនោះ ភិក្ខុទាំងឡាយងូតទឹកក្នុងស្រះបោក្ខរណីឈ្មោះនឡកបាន ហើយឲ្យពួកសាមណេរដកដើមបបុសមក ដើម្បីធ្វើបំពង់ម្ជុល ឃើញដើមបបុសនោះជាបំពង់រហូត ( មិនមានថ្នាំងតាំងអំពីចុងដល់គល់ ) ទើបចូលទៅគាល់ព្រះមានព្រះភាគហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គឲ្យសាមណេរកាន់យកដើមបបុសទាំងឡាយមក ដើម្បីធ្វើបំពង់ម្ជុល ដើមបបុសទាំងនេះជាបំពង់មិនមានថ្នាំងតាំងអំពីគល់រហូតដល់ចុង តើព្រោះហេតុអ្វីហ្ន៎ ?*

*ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នេះជាការអធិដ្ឋានក្នុងអតីតរបស់តថាគត ហើយទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា*

*បានឮថា ក្នុងអតីតកាល ត្រង់ទីនោះជាព្រៃ មានអារក្សទឹកមួយតែងទំពាស៊ីមនុស្ស សត្វ ដែលចុះទៅក្នុងស្រះបោក្ខរណី ( ក្នុងព្រៃ ) នោះ ។ ក្នុងកាលនោះ ព្រះពោធិសត្វជាស្ដេចស្វា មានទំហំប៉ុនសត្វរមាំង ចោមរោមដោយពួកពានរ ៨ ម៉ឺនជាបរិវារ អាស្រ័យនៅក្នុងព្រៃនោះ ។ ស្ដេចស្វានោះ កាលទូន្មាន ក៏ទូន្មានដល់ពួកពានរទាំងឡាយថា នែបាទាំងឡាយ ក្នុងព្រៃនេះ មានដើមឈើពុលខ្លះ មានស្រះបោក្ខរណីដែលកើតឯងមានអមនុស្សហួងហែងរក្សាខ្លះ អ្នកទាំងឡាយ កាលទំពាស៊ីផ្លែឈើតូចធំដែលមិនធ្លាប់ស៊ី ឬកាលបើផឹកទឹកដែលមិនធ្លាប់ផឹក ត្រូវសួរខ្ញុំជាមុន ។ ពួកពានរទាំងនោះទទួលពាក្យថា សាធុហើយ ថ្ងៃមួយក៏ទៅដល់ទីដែលមិនធ្លាប់ទៅ ត្រាច់ទៅក្នុងទីនោះច្រើនថ្ងៃ កាលស្វែងរកទឹកផឹក ក៏ឃើញស្រះបោក្ខរណីមួយ មិនហ៊ានផឹកទឹក អង្គុយចាំការមករបស់ព្រះពោធិសត្វ ។ ព្រះមហាបុរស កាលមកដល់ហើយសួរថា* **កឹ តាតា បានីយំ ន បិវថ** *នែបាទាំងឡាយ ហេតុអ្វីទើបអ្នកទាំងឡាយមិនផឹកទឹក ?*

*ពួកពានរឆ្លើយថា* **តុម្ហាកំ អាគមនំ ឱលោកេម** *ពួកខ្ញុំ*

រង់ចាំការមករបស់លោក ។

ស្តេចស្វាពោលថា **សុដ្ឋុ តាត** នែបាទាំងឡាយ ពួកអ្នកធ្វើនេះល្អហើយ ទើបដើរផ្ទៃលស្រះបោក្ខរណីនោះ កំណត់ស្នាមជើង ឃើញតែស្នាមជើងដែលចុះទៅ មិនឃើញស្នាមជើងឡើងមក ព្រះពោធិសត្វដឹងថា ស្រះបោក្ខរណីនេះអមនុស្សហួងហែងដោយឥតសង្ស័យ ទើបពោលថា នែបាទាំងឡាយ អ្នកទាំងឡាយមិនផឹកទឹក ឈ្មោះថា ប្រពៃហើយ ដ្បិតស្រះបោក្ខរណីនេះអមនុស្សហួងហែងហើយ ។ ចំណែកអារក្សទឹកដឹងថាពានរទាំងនោះមិនចុះ ក៏ដំណែងខ្លួនជាបុគ្គលមានពោះពណ៌ខៀវ មានមុខពណ៌លឿង ដៃជើងពណ៌ក្រហម មានរូបរាងគួរខ្លាចគួរខ្ពើម ជ្រែកផ្ទៃទឹកឡើងមកពោលថា ព្រោះហេតុអ្វីទើបពួកអ្នកអង្គុយសូមចុះក្នុងស្រះបោក្ខរណីនេះផឹកទឹកចុះ ។ លំដាប់នោះ ព្រះពោធិសត្វសួរអារក្សទឹកនោះថា អ្នកជាអារក្សទឹកកើតនៅក្នុងស្រះនេះឬ ?

អារក្សទឹកឆ្លើយថា អើយើងកើតក្នុងស្រះនេះ ។

ព្រះពោធិសត្វសួរថា អ្នករមែងបានបុគ្គលដែលចុះទៅក្នុងស្រះបោក្ខរណីនេះឬ ?

អារក្សទឹកឆ្លើយថា អើយើងបាន យើងមិនដោះលែងអ្នកណាមួយឡើយ ដោយហោច សូម្បីតែបក្សីដែលចុះក្នុងស្រះបោក្ខរណីនេះ ឯអ្នកទាំងអស់សោត យើងក៏នឹងទំពាស៊ី ។

ព្រះពោធិសត្វពោលថា ពួកយើងមិនឲ្យអ្នកស៊ីពួកយើងឡើយ ។

អារក្សទឹកសួរថា អ្នកទាំងឡាយមិនផឹកទឹកនេះ មិនមែនឬ?

ព្រះមហាសត្វឆ្លើយថា អើ ពួកយើងនឹងផឹក តែផឹកដោយមិនធ្លាក់ក្នុងអំណាចរបស់អ្នក ។

អារក្សទឹកសួរថា បើដូច្នោះ ពួកអ្នកនឹងផឹកដូចម្ដេច ?

ស្ដេចពានរឆ្លើយថា អ្នកសម្គាល់ថាយើងនឹងចុះផឹកទឹកឬ ដ្បិតថាពួកយើងនឹងមិនចុះទៅទេ យើងនឹងឲ្យពានរទាំង ៨ ម៉ឺន កាន់កំណាត់ដើមបបុសមួយម្នាក់ ផឹកទឹកក្នុងស្រះបោក្ខរណីរបស់អ្នកដូចផឹកទឹកដោយដើមឈូកដូច្នោះ កាលបើយ៉ាងនេះ អ្នកមិនអាចស៊ីពួកយើងបានឡើយ ។ ព្រះសាស្ដា កាលទ្រង់ដឹងច្បាស់សេចក្ដីនេះ គឺទ្រង់ត្រាស់ជាព្រះសព្វញ្ញុពុទ្ធហើយ ទើបត្រាស់គាថាពីរបទដំបូងនៃគាថានេះថា [១]

**ទិស្វា បទមនុត្តិណ្ណំ ទិស្វានោតរិតំ បទំ**

**នឡេន វារី បិវិស្សាម នេវ មំ ត្វំ វធិស្សសីតិ ។**

យើងឃើញស្នាមជើងដែលមិនឡើង ឃើញតែស្នាមជើង

ដែលចុះ យើងផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់

១- ក្នុងអដ្ឋកថា លោកលើកតែគាថា ២ បាទដំបូងប៉ុណ្ណោះ តែក្នុងទីនេះ យើងលើកយកមួយគាថា ( ៤ បាទ ) ដើម្បីងាយយល់ ងាយស្ដាប់ ។

យើងមិនបានឡើយ ។

អត្ថនៃពាក្យដែលជាគាថានោះ មានដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ស្តេចស្វានោះជាមហាបុរស មិនបានឃើញស្នាមជើងឡើងមក សូម្បីតែមួយក្នុងស្រះបោក្ខរណីនោះ បានឃើញតែស្នាមជើងចុះទៅប៉ុណ្ណោះ កាលឃើញយ៉ាងនោះ គឺមិនឃើញស្នាមជើងឡើង ឃើញតែស្នាមជើងចុះ ទើបដឹងថា ស្រះបោក្ខរណីនេះ អមនុស្សហួងហែងពិត កាលចរចាជាមួយអារក្សទឹកនោះ ទើបពោលថា ពួកយើងនឹងផឹកទឹកដោយដើមបបុស អធិប្បាយថា ពួកយើងនឹងផឹកទឹកក្នុងស្រះបោក្ខរណីរបស់អ្នកដោយដើមបបុស ព្រះមហាសត្វពោលបន្តថា អ្នកនឹងសម្លាប់យើងមិនបាន អធិប្បាយថា យើងមួយអន្លើដោយបរិស័ទផឹកទឹកដោយដើមបបុសយ៉ាងនេះ សូម្បីអ្នកក៏សម្លាប់យើងមិនបាន ។

ព្រះពោធិសត្វ កាលពោលយ៉ាងនេះហើយ ទើបឲ្យនាំដើមបបុសមួយដើមមក ពិចារណាដល់បារមីទាំងឡាយ ហើយធ្វើសច្ចកិរិយាយកមាត់ផ្លុំ ដើមបបុសក៏ក្លាយទៅជាបំពង់តាំងអំពីគល់រហូតដល់ចុង មិនមានថ្នាំងក្នុងទីណាមួយឡើយ ។ ព្រះពោធិសត្វឲ្យនាំដើមបបុសដទៃៗមក ហើយផ្លុំចែកហ្វូងស្វាទាំងឡាយដោយទំនងនេះ កាលបើធ្វើដូចពោលមកនេះមិនអាចឲ្យសម្រេចបាន ព្រោះដូច្នោះ មិនគួរកាន់យកយ៉ាងនោះ ។ ឯព្រះពោធិសត្វអធិដ្ឋានថា ដើមបបុសទាំងអស់ដែល

កើតជុំវិញស្រះបោក្ខរណីនេះ ចូរជាបំពង់ទាំងអស់ចុះ ព្រោះឧបចារៈនៃប្រយោជន៍របស់ព្រះពោធិសត្វទាំងឡាយជាសភាពក្រៃលែង ការអធិដ្ឋានរមែងសម្រេច តាំងអំពីនោះមក ដើមបបុសដែលកើតជុំវិញស្រះបោក្ខរណីនោះគ្រប់ដើម ក៏ពុំមានថ្នាំង ជាបំពង់រហូតមក ។

ពិតហើយ ក្នុងកប្បនេះ ឈ្មោះថាបាដិហារិយ៍ដែលតាំងនៅអស់កប្ប មាន ៤ ប្រការ ។

សួរថា តើបាដិហារិយ៍ ៤ ប្រការនោះ ដូចម្តេច ?

ឆ្លើយថា គឺគ្រឿងសម្គាល់រូបទន្សាយក្នុងវង្វង់ព្រះចន្ទ នឹងតាំងនៅអស់មួយកប្ប នេះជាបាដិហារិយ៍ ១ ទីដែលភ្លើងរលត់ក្នុង **វដ្ដកជាតក** ភ្លើងមិនឆេះក្នុងទីនោះអស់មួយកប្ប នេះជាបាដិហារិយ៍ ១ ស្ថានទីដែលជាលំនៅរបស់ឃដិការនាយស្មូនឆ្នាំង ភ្លៀងក៏មិនស្រក់ចំត្រង់បាតផ្ទះនោះអស់មួយកប្ប នេះជាបាដិហារិយ៍ ១ ដើមបបុសដែលតាំងនៅជុំវិញស្រះបោក្ខរណីនោះ ជាបំពង់តែមួយអស់មួយកប្ប នេះជាបាដិហារិយ៍ ១ ឈ្មោះថា បាដិហារិយ៍ដែលតាំងនៅអស់មួយកប្ប គឺមួយអាយុផែនដីមានប្រការដូចពោលមកដូច្នេះ ។

ព្រះពោធិសត្វ កាលអធិដ្ឋានយ៉ាងនេះហើយ ទើបអង្គុយកាន់ដើមបបុសមួយ ចំណែកពួកពានរទាំង ៨ ម៉ឺន ក៏កាន់យកដើមបបុសមួយម្នាក់ៗ អង្គុយជុំវិញស្រះបោក្ខរណី ។ ក្នុងវេលាដែលព្រះពោធិសត្វយក

*ដើមបបុសបឺតទឹក ពានរទាំងនោះ ក៏អង្គុយត្រង់មាត់ច្រាំងនៃស្រះនោះផឹកទឹកហើយ កាលពានរទាំងនោះផឹកទឹកយ៉ាងនេះ អារក្សទឹកមិនអាចបានពានរសូម្បីតែមួយ ក៏ទោមនស្ស ទើបទៅកាន់និវេសន៍របស់ខ្លួនវិញ ចំណែកព្រះពោធិសត្វព្រមទាំងបរិវារ ក៏ចូលទៅកាន់ព្រៃដូចគ្នា ។*

*ព្រះបរមសាស្ដាទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាដើមបបុសទាំងឡាយនេះ ជាបំពង់តែមួយ ជាការអធិដ្ឋានក្នុងកាលមុនរបស់តថាគតនោះឯង ។*

*ព្រះបរមសាស្ដា កាលទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា អារក្សទឹកក្នុងកាលនោះ បានមកជាទេវទត្តក្នុងកាលឥឡូវនេះ ពានរ ៨ ម៉ឺនក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកស្ដេចពានរដែលឈ្លាសក្នុងឧបាយក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា នឡបានជាតក ទី ១០ ។

ចប់ សីលវគ្គ ទី ២ ។

# រួមជាតកដែលមាននៅក្នុងវគ្គនេះ គឺ

*លក្ខណជាតក ១ និគ្រោធមិគជាតក ១ កណ្ឌិនជាតក ១ វាតមិគជាតក ១ ខរាទិយជាតក ១ តិបល្លត្ថមិគជាតក ១ មាលុតជាតក ១ មតកភត្តជាតក ១ អាយាចិតភត្តជាតក ១ នឡបានជាតក ១ ។*

# កុរុង្គវគ្គ ទី ៣
# អដ្ឋកថា កុរុង្គមិគជាតក ទី ១

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ញាតមេតំ កុរុង្គស្ស** *ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា សម័យមួយ ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងធម្មសភា ពោលទោសរបស់ទេវទត្តថា នៃអាវុសោទាំងឡាយ ទេវទត្តប្រកបនាយខ្មាន់ធ្នូដើម្បីផ្ដាច់ព្រះជន្មព្រះតថាគត ប្រមៀលថ្ម លែងដំរីធនបាលកៈ ព្យាយាមដើម្បីផ្ដាច់ព្រះជន្មរបស់ព្រះទសពល ក្នុងកាលទាំងពួង ។ លំដាប់នោះ ព្រះសាស្ដា ទ្រង់យាងមកកាន់រោងធម្មសភា ប្រថាប់គង់លើបវរពុទ្ធាសនៈដែលគេតាក់តែងទុក ហើយទ្រង់មានព្រះតម្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?*

*ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយអង្គុយសន្ទនាគ្នា ដោយពោលទោសរបស់ភិក្ខុទេវទត្តថា ភិក្ខុទេវទត្តព្យាយាមដើម្បីផ្ដាច់ព្រះជន្មរបស់ព្រះអង្គ ។*

*ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមផ្ដាច់ព្រះជន្មរបស់តថាគតតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បី*

ក្នុងកាលមុនក៏ធ្លាប់ព្យាយាមដូចគ្នា តែមិនអាចសម្លាប់តថាគតបាន ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ក្នុងកាលនោះ ព្រះពោធិសត្វយោនយកកំណើតជាប្រើសទំពាស៊ីផ្លែឈើទាំងឡាយក្នុងដងព្រៃមួយ ។ សម័យមួយ ប្រើសនោះស៊ីផ្លែចំបក់មួយដើមដែលមានផ្លែស្អេកស្កះ សម័យនោះ មានព្រានផ្ទះម្នាក់ពិចារណាស្នាមជើងនៃម្រឹគទាំងឡាយ ហើយទើបចងផ្ទះលើដើមឈើអង្គុយលើផ្ទះនោះ យកលំពែងចាំចាក់ម្រឹគដែលមកស៊ីផ្លែឈើ ហើយលក់សាច់របស់ម្រឹគទាំងនោះចិញ្ចឹមជីវិត ។ ថ្ងៃមួយ ព្រានឃើញស្នាមជើងរបស់ព្រះពោធិសត្វត្រង់គល់ឈើនោះ ទើបចងផ្ទះខាងលើដើមចំបក់នោះ ហើយបរិភោគអាហារអំពីព្រលឹម កាន់លំពែងចូលទៅក្នុងព្រៃឡើងទៅអង្គុយលើផ្ទះនោះ ។ ចំណែកព្រះពោធិសត្វក៏ចេញពីលំនៅអំពីព្រលឹមដោយបំណងថា អញនឹងស៊ីផ្លែចំបក់ តែមិនបានចូលទៅដោយរួសរាន់ត្រង់គល់ចំបក់នោះឡើយ គិតថា ជួនកាល ពួកព្រានកាច់ផ្ទះលើដើមឈើ អន្តរាយបែបនេះមានដែរឬទេហ្ន៎ ? ទើបឈរពិចារណាមើលអំពីខាងក្រៅ ។ ចំណែកព្រានដឹងថា ព្រះពោធិសត្វមិនចូលមកអង្គុយលើផ្ទះនោះបោះផ្លែចំបក់ឲ្យធ្លាក់ទៅខាងមុខព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា ផ្លែឈើទាំងនេះ ( ធ្លាក់មិនត្រង់ ) មកធ្លាក់អំពីខាងមុខ

អញ ខាងលើដើមឈើនេះ មានព្រានដែរឬហ្ន៎ កាលសម្លឹងមើលរឿយៗ ក៏ឃើញព្រានព្រៃ តែធ្វើជាមិនឃើញ ពោលថា នែដើមឈើដ៏ចម្រើន ក្នុងកាលមុនផ្លែរបស់អ្នកធ្លាក់ចុះមកត្រង់ៗ តែថ្ងៃនេះ អ្នកលះបង់រុក្ខធម៌ហើយ កាលអ្នកលះបង់រុក្ខធម៌យ៉ាងនេះ ខ្ញុំនឹងចូលទៅរកគល់ឈើដទៃ ដើម្បីស្វែងរកអាហាររបស់ខ្ញុំ ហើយពោលគាថានេះថា

**ញាតមេតំ កុរុង្គស្ស យំ ត្វំ សេបណ្ណិ សេយ្យសិ**
**អញ្ញំ សេបណ្ណិំ គច្ឆាមិ ន មេ តេ រុច្ចតេ ផលន្តិ ។**

ម្នាលដើមចំបក់ អ្នកជម្រុះផ្លែមកដោយហេតុណា ហេតុនុ៎ះ អញជាប្រើសបានដឹងហើយ អញនឹងទៅកាន់ដើមចំបក់ឯទៀត ផ្លែរបស់អ្នកអញមិនពេញចិត្តទេ ។

បណ្ដាបទទាំងនោះ បទថា **ញាតំ** បានដល់ ប្រាកដ គឺកើតហើយ ។ បទថា **ឯតំ** យោគជា **ឥទំ** ។ បទថា **កុរុង្គស្ស** ប្រែថា ម្រឹគប្រភេទប្រើស ។

បទថា **យំ ត្វំ សេបណ្ណិ សេយ្យសិ** សេចក្ដីថា នែដើមចំបក់ដ៏ចម្រើន កាលដែលអ្នកធ្លាក់ផ្លែមកខាងមុខខ្ញុំ គឺបានជាអ្នកមានផ្លែធ្លាក់ខ្ចាយ ( រៀច ) មក ទាំងអស់នោះ កើតជាវត្ថុលាមកសម្រាប់ប្រើស ។

ដោយបទថា **ន មេ តេ រុច្ចតេ ផលំ** នេះ ប្រើសពោលថា ខ្ញុំមិនគាប់ចិត្តក្នុងផ្លែរបស់អ្នក ដែលធ្លាក់ចុះមករៀចយ៉ាងនេះ សូមអ្នក

*ឈប់ចុះ ខ្ញុំនឹងទៅកាន់ទីដទៃ ដូច្នេះ ហើយក៏ទៅ ។*

*លំដាប់នោះ ព្រាននោះ អង្គុយនៅលើផ្ទះនោះឯង ពួយលំពែងទៅដើម្បីឲ្យត្រូវព្រះពោធិសត្វ ហើយពោលថា* **គច្ឆ វិរទ្ធោជានិម្ហិ តំ** *អាទៅចុះ ឥឡូវនេះ អញខុសបំណងហើយ ។ ព្រះមហាសត្វបែរមកហើយពោលថា* **អម្ភោ បុរិស ឥជានីសិ កិញ្ចាបិ មំ វិរទ្ធោ អដ្ឋ បនមហានិរយេ សោឡស ឧស្សទនិរយេ បញ្ចវិធពន្ធនានីនិ ចកម្មការណានិ អវិរទ្ធោយេវាសិ** *រឺយបុរសដ៏ចម្រើន ឥឡូវនេះ អ្នកខុសបំណងនឹងខ្ញុំក៏ពិត តែទោះជាយ៉ាងនោះ អ្នកមិនខុសបំណងក្នុងមហានរក ៨ រណ្ដៅ ឧស្សទនរក ១៦ រណ្ដៅ និងកម្មករណៈទាំងឡាយមានចំណង ៥ ប្រការជាដើម កាលពោលយ៉ាងនេះហើយក៏ទៅតាមគាប់ចិត្ត នាយព្រានចុះមកហើយ ក៏ទៅតាមការគាប់ចិត្តដូចគ្នា ។*

*ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទេវទត្តព្យាយាមដើម្បីសម្លាប់តថាគត តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនទេ សូម្បីក្នុងកាលមុនក៏ព្យាយាមហើយដូចគ្នា ។*

*ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា នាយព្រានកាច់ផ្ទះក្នុងកាលនោះបានមកជាទេវទត្ត ចំណែកប្រើសក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៗ*

ចប់ អដ្ឋកថា កុរុង្គមិគជាតក ទី ១ ។

# អដ្ឋកថា កុក្កុរជាតក ទី ២

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការប្រព្រឹត្តជាប្រយោជន៍ដល់ញាតិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **យេ កុក្កុរា** *ដូច្នេះជាដើម ។*

*ការប្រព្រឹត្តជាប្រយោជន៍ដល់ញាតិនោះ នឹងមានជាក់ច្បាស់ក្នុង* **ភទ្ទសាលជាតក ទ្វាទសកនិបាត** *ឯណោះ ។*

*ព្រះបរមសាស្ដា ទ្រង់តាំងរឿងនេះហើយ ទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះពោធិសត្វ ទ្រង់អាស្រ័យកម្មបែបនោះកើតក្នុងកំណើតសុនខ ចោមរោមដោយសុនខច្រើនរយនៅក្នុងព្រៃស្មសានធំ ។*

*ថ្ងៃមួយ ព្រះរាជា ទ្រង់ឡើងរថទឹមដោយសេះសិន្ធពពណ៌ស ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង យាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ក្រសាលក្នុងឧទ្យាននោះរហូតដល់ថ្ងៃលិច កាលព្រះអាទិត្យអស្ដង្គតហើយ ទើបទ្រង់ចូលនគរ ។ រាជបុរសទាំងឡាយដាក់ស្បែកនិងកូនកំព្រាតាមដែលចងទុកនោះឯងត្រង់លានព្រះរាជវាំង កាលភ្លៀងធ្លាក់កណ្ដាលរាត្រី រថនោះក៏សើមដោយភ្លៀង ឆ្កែដែលចិញ្ចឹមទុកក្នុងរាជត្រកូលចុះអំពីប្រាសាទជាន់លើ ទំពាស៊ីស្បែកនិងកូនកំព្រារបស់រថទាំងនោះ ។*

ស្អែកឡើង ពួករាជបុរសក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ឆ្កែទាំងឡាយមកតាមលូបង្ហូរទឹក ទំពាស៊ីស្បែកនិងកូនកំព្រារបស់រថនោះ ។ ព្រះរាជា ទ្រង់ព្រះពិរោធនឹងពួកសុនខ ទើបត្រាស់ថា ពួកអ្នកចូរសម្លាប់ឆ្កែក្នុងទីដែលបានឃើញហើយ ។ តាំងអំពីកាលនោះមក មហាវិនាសក៏កើតឡើងដល់ពួកឆ្កែទាំងឡាយ ពួកឆ្កែទាំងនោះ កាលត្រូវសម្លាប់ក្នុងទីដែលមនុស្សទាំងឡាយឃើញ ទើបរត់គេចទៅកាន់ព្រៃខ្មោចហើយនាំគ្នាទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វសួរថា អ្នកទាំងឡាយនាំគ្នាមកប្រជុំច្រើនម្ល៉េះ តើព្រោះហេតុអ្វីហ្ន៎ ?

ឆ្កែទាំងនោះពោលថា ព្រះរាជាទ្រង់ព្រះពិរោធ បានឮថា ឆ្កែស៊ីស្បែកនិងកូនកំព្រារបស់រថក្នុងព្រះរាជវាំង ទើបទ្រង់បញ្ជាឲ្យសម្លាប់ ឆ្កែទាំងឡាយជាច្រើនដល់នូវសេចក្ដីវិនាស មហាភ័យកើតឡើងហើយ ។ ព្រះពោធិសត្វគិតថា ក្នុងទីដែលមានការរក្សាតឹងរ៉ឹងយ៉ាងនេះ ឆ្កែទាំងឡាយខាងក្រៅមិនអាចមានឱកាស កម្មនេះ ជាកម្មរបស់ឆ្កែដែលចិញ្ចឹមក្នុងព្រះរាជនិវេសន៍ជាប្រាកដ ភ័យណាមួយមិនមានដល់ពួកចោរ ឯពួកដែលមិនមែនជាចោរ ត្រឡប់ជាបានទទួលនូវសេចក្ដីស្លាប់ បើដូច្នោះអញនឹងបង្ហាញពួកចោរដល់ព្រះរាជា ហើយឲ្យជីវិតដល់ពួកញាតិ ។ ព្រះពោធិសត្វលួងលោមពួកញាតិទាំងឡាយឲ្យធូរស្បើយក្នុងចិត្តថា អ្នកទាំងឡាយកុំភ័យខ្លាចឡើយ ខ្ញុំនឹងនាំសួស្ដីមកឲ្យដល់អ្នកទាំងឡាយ ពួក

អ្នកចូរនៅក្នុងទីនេះ ទម្រាំខ្ញុំត្រឡប់មកវិញ ហើយពិចារណាដល់បារមី ធ្វើមេត្តាភាវនាឲ្យជាបុរេចារិក ហើយអធិដ្ឋានថា បុគ្គលណាមួយ កុំបីគ្រវែងអាត្មាអញដោយដុំថ្ម ដុំដី ឬដោយដំបងឡើយ ។ ព្រះពោធិសត្វតែម្នាក់ឯងប៉ុណ្ណោះចូលទៅកាន់នគរ គ្រានោះ សត្វសូម្បីតែម្នាក់ ឃើញព្រះពោធិសត្វហើយឈ្មោះថា ក្រោធសម្លឹងមើល មិនមានឡើយ ។

ចំណែកព្រះរាជា ទ្រង់បញ្ជាឲ្យសម្លាប់សុនខហើយ ប្រថាប់គង់ក្នុងទីវិនិច្ឆ័យដោយព្រះអង្គឯង ។ ព្រះពោធិសត្វចូលទៅកាន់ទីវិនិច្ឆ័យនោះ ហើយរត់ចូលទៅខាងក្រោមអាសនៈរបស់ព្រះរាជា ។ លំដាប់នោះ ពួករាជបុរសក៏ផ្តើមនាំព្រះពោធិសត្វចេញមក តែព្រះរាជាទ្រង់ហាម ។ ព្រះពោធិសត្វសម្រាកបន្តិចហើយ ចេញមកអំពីក្រោមអាសនៈ ថ្វាយបង្គំព្រះរាជាហើយទូលសួរថា **ទេវ តុម្ហេ កុក្កុរេ មារាបេថ** បានឮថា ព្រះអង្គទ្រង់ឲ្យសម្លាប់ឆ្កែ ពិតឬ?

ព្រះរាជាត្រាស់ថា **អាម មារាបេមហំ** អើ យើងឲ្យសម្លាប់ ។

ព្រះពោធិសត្វទូលសួរថា បពិត្រព្រះចមនរៈ ឆ្កែទាំងនោះ មានកំហុសអ្វី ?

ព្រះរាជាត្រាស់ថា ឆ្កែទាំងឡាយវាទំពាស៊ីស្បែក និងកូនកំព្រានៃរថរបស់យើង ។

ព្រះមហាសត្វទូលសួរថា ព្រះអង្គទ្រង់ស្គាល់ឆ្កែដែលទំពាស៊ីស្បែក

និងកូនកំព្រានោះហើយឬ?

ព្រះរាជាត្រាស់ថា យើងមិនដឹង ។

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់មិនជ្រាបចោរដែលទំពាស៊ីស្បែកនិងកូនកំព្រានេះ ហើយទ្រង់បែរជាឲ្យសម្លាប់ឆ្កែដែលមិនបានស៊ីក្នុងទីដែលឃើញ មិនសមគួរឡើយ ។

ព្រះរាជាត្រាស់ថា ព្រោះពួកឆ្កែទាំងនោះ ស៊ីនូវស្បែកនិងកូនកំ-ព្រា ទើបយើងបញ្ជាឲ្យសម្លាប់សុនខថា ពួកអ្នកចូរសម្លាប់សុនខដែលអ្នកទាំងឡាយបានឃើញហើយ ។

ព្រះពោធិសត្វទូលសួរថា មនុស្សទាំងឡាយនោះ សម្លាប់សុនខទាំងឡាយទាំងអស់ឬ ឬថាសុនខដែលមិនសម្លាប់ក៏មាន?

ព្រះរាជាត្រាស់ថា មាន សុនខដែលចិញ្ចឹមក្នុងរាជដំណាក់របស់យើង មិនបានឲ្យសម្លាប់ឡើយ ។

ព្រះមហាសត្វទូលថា បពិត្រមហារាជ ទ្រង់បានត្រាស់អម្បាញ់-មិញហើយថា ព្រោះពួកសុនខទំពាស៊ីស្បែកនិងកូនកំព្រារបស់រថ ទើបយើងបញ្ជាឲ្យសម្លាប់សុនខថា ពួកអ្នកទាំងឡាយ ចូរសម្លាប់សុនខក្នុងទីដែលឃើញហើយ តែឥឡូវនេះ ទ្រង់ត្រាស់ថា សុនខដែលចិញ្ចឹមក្នុងព្រះរាជដំណាក់របស់យើងមិនត្រូវសម្លាប់ឡើយ កាលបើយ៉ាងនេះ ទ្រង់ពិតជាលុះក្នុងអគតិមានឆន្ទាគតិជាដើម ឈ្មោះថា ការលុះក្នុងអគតិមិន

សមគួរឡើយ មិនជាទសពិធរាជធម៌ ធម្មតាព្រះរាជាអ្នកស្វែងរកហេតុនិងមិនមែនហេតុដូចជាជញ្ជីងទើបសមគួរ ឥឡូវនេះ ឆ្កែដែលចិញ្ចឹមក្នុងរាជត្រកូលមិនបាននូវការស្លាប់ ឯឆ្កែដែលទុព្វលប៉ុណ្ណោះទើបបាន កាលបើដូច្នេះ នេះមិនមែនជាការសម្លាប់ឆ្កែទូទៅ តែនេះឈ្មោះថាជាការសម្លាប់ឆ្កែដែលទុព្វល ។ កាលទូលយ៉ាងនេះហើយ ទើបបន្លឺសូរសៀងដ៏ពីរោះក្រាបទូលថា បពិត្រមហារាជ វត្ថុដែលព្រះអង្គទ្រង់ធ្វើនោះមិនជាធម៌ កាលសម្ដែងធម៌ដល់ព្រះរាជា ទើបពោលគាថានេះថា

**យេ កុក្កុរា រាជកុលម្ហិ វឌ្ឍា**
**កោលេយ្យកា វណ្ណពលូបបន្នា**
**តេមេ ន វជ្ឈា មយមស្ម វជ្ឈា**
**នាយំ សឃច្ចា ទុព្វលឃាតិកាយំ ។**

ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរនិងកម្លាំង ចម្រើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថាសម្លាប់ដោយត្រឹមត្រូវឡើយ នេះឈ្មោះថាសម្លាប់តែឆ្កែដែលមានកម្លាំងខ្សោយ ។

បណ្ដាបទទាំងនោះ បទថា **យេ កុក្កុរា** បានដល់ សុនខពួកណា ធម្មតាបសុរាវៈ ទោះបីមានកម្ដៅក្ដៅក៏គង់ហៅថា ទឹកនោមស្អុយ

ឆ្កែចចក សូម្បីកើតក្នុងថ្ងៃនោះ ក៏ហៅថា ចចកចាស់ វល្លិ៍ផោម សូម្បីទើបតែដុះ ក៏ហៅថា វល្លិ៍ផោម កាយសូម្បីមានពណ៌ដូចមាស ក៏ហៅថា កាយស្អុយ យ៉ាងណា ឆ្កែទាំងឡាយ សូម្បីមានអាយុ ១០០ ឆ្នាំ ក៏ហៅថា កុក្កុរៈ គឺកូនឆ្កែដូច្នោះ ដូចគ្នា ព្រោះហេតុនោះ សុនខទាំងនោះ សូម្បីចាស់សម្បូណ៌ដោយកម្លាំងកាយ ក៏ហៅថា កុក្កុរៈ ដូចគ្នា ។

បទថា **វឌ្ឍា** ប្រែថា ចម្រើនធំធាត់ ។

បទថា **កោលេយ្យកា** បានដល់ កើតហើយ មានហើយ ចម្រើនហើយក្នុងរាជត្រកូល ។

បទថា **វណ្ណពលូបបន្នា** បានដល់ សម្បូណ៌ដោយពណ៌នៃរាងកាយ និងកម្លាំងកាយ ។

បទថា **តេមេ ន វជ្ឈា** ប្រែថា សុនខទាំងនេះ មានម្ចាស់ មានការរក្សា ទើបមិនត្រូវសម្លាប់ ។

បទថា **មយមស្ម វជ្ឈា** សេចក្តីថា យើងទាំងឡាយមិនមានម្ចាស់ មិនមានការរក្សា ជាសុនខដែលត្រូវសម្លាប់ ។

បទថា **នាយំ សឃច្ចា** សេចក្តីថា កាលបើដូច្នោះ នេះរមែងមានឈ្មោះថា ជាការសម្លាប់ដោយប្លែកគ្នា ។

បទថា **ទុព្វលឃាតិកាយំ** សេចក្តីថា នេះរមែងមានឈ្មោះថា ជាការសម្លាប់ដ៏ទុព្វល ព្រោះសម្លាប់ចំពោះឆ្កែដែលទុព្វលទាំងឡាយ

អធិប្បាយថា ធម្មតាព្រះរាជាទាំងឡាយ គួរសង្កត់សង្កិនពួកចោរ ពួកដែលមិនមែនជាចោរ មិនគួរសង្កត់សង្កិន តែក្នុងហេតុការណ៍នេះ ទោសណាមួយមិនមានដល់ពួកចោរ ពួកដែលមិនមែនជាចោរត្រូវឡប់បាននូវការស្លាប់ ឱ ក្នុងលោកនេះ វត្ថុដែលមិនគួររមែងប្រព្រឹត្តទៅ ឱ អធម៌រមែងប្រព្រឹត្តទៅហើយ ។

ព្រះរាជាបានស្ដាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទើបត្រាស់សួរថា នែបណ្ឌិត អ្នកដឹងឬថាឆ្កែឈ្មោះនោះ ជាអ្នកស៊ីស្បែកនិងកូនកំព្រារបស់រថ ?

ព្រះពោធិសត្វក្រាបទូលថា ទូលបង្គំដឹង ។

ព្រះរាជាត្រាស់សួរថា ឆ្កែពួកណាជាអ្នកស៊ី ?

ព្រះពោធិសត្វក្រាបទូលថា ពួកឆ្កែដែលចិញ្ចឹមនៅក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ជាអ្នកស៊ី ។

ព្រះរាជាត្រាស់សួរថា អ្នកត្រូវពិសោធដូចម្ដេច ទើបដឹងថាឆ្កែពួកនោះ ជាអ្នកស៊ី ?

ព្រះមហាសត្វក្រាបទូលថា ទូលបង្គំនឹងបង្ហាញនូវភាពដែលឆ្កែទាំងនោះស៊ី ។

ព្រះរាជាត្រាស់ថា ចូរបង្ហាញមកចុះបណ្ឌិត ។

ព្រះមហាសត្វក្រាបទូលថា សូមទ្រង់នាំយកពួកឆ្កែដែលចិញ្ចឹម

ក្នុងព្រះរាជដំណាក់របស់ព្រះអង្គមក ហើយឲ្យនាំយកតក្ក ( ទឹកដោះដែលគេចម្អិនមួយអំពុះ ) និងឫសស្បូវភ្លាំងបន្តិចមក ។ ព្រះរាជាទ្រង់ធ្វើយ៉ាងនោះ ។ លំដាប់នោះ ព្រះពោធិសត្វឲ្យបុកឫសស្បូវភ្លាំងដាក់ជាមួយតក្កហើយទូលព្រះរាជាថា សូមទ្រង់ឲ្យឆ្កែទាំងនេះផឹក ។ ព្រះរាជា ទ្រង់ធ្វើយ៉ាងនោះ ឆ្កែទាំងឡាយដែលផឹកហើយ ក៏បន្ទោបង់ចេញមកមួយអន្ទើដោយស្បែកទាំងឡាយ ព្រះរាជា ទ្រង់ត្រេកអរថា សុនខនេះ ព្យាករដូចព្រះសព្វញ្ញុពុទ្ធ ទើបទ្រង់ធ្វើការបូជាព្រះពោធិសត្វដោយស្វេតច្ឆត្រ ។

ព្រះពោធិសត្វសម្តែងធម៌ថ្វាយព្រះរាជា ដោយគាថាពោលអំពីការប្រព្រឹត្តធម៌ ១០ ប្រការដែលមកក្នុង **តេសកុណជាតក** ដែលមានសេចក្តីថា

**ធម្មំ ចរ មហារាជ មាតាបិតូសុ ខត្តិយ**
**ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ ។**

បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបម្រើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌[១] ដូច្នេះជាដើម ។

---

១-បិ.៦០ , ទំ.២៣០ ។

*ហើយក្រាបទូលថា បពិត្រមហារាជ ចាប់តាំងអំពីពេលនេះទៅ សូមទ្រង់កុំប្រមាទ ឲ្យព្រះរាជាតាំងនៅក្នុងសីល ៥ ហើយ ទើបថ្វាយស្វេតច្ឆត្រដល់ព្រះរាជាវិញ ។ ព្រះរាជា ទ្រង់បានស្ដាប់ធម្មកថារបស់ព្រះពោធិសត្វហើយ ទ្រង់ឲ្យអភ័យដល់សត្វទាំងពួង ផ្ដើមតាំងនិច្ចភត្តនិងភោជនរបស់ព្រះអង្គដល់សុនខទាំងពួង មានព្រះពោធិសត្វជាដើម ទ្រង់តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ទ្រង់ធ្វើបុណ្យមានទានជាដើម កាលអស់ព្រះជន្មាយុសោយទិវង្គតហើយ ក៏បានកើតក្នុងទេវលោក* **កុក្កុរោវាទ** *បានប្រព្រឹត្តទៅអស់ ១ ម៉ឺនឆ្នាំ ចំណែកព្រះពោធិសត្វតាំងនៅរហូតដល់អស់អាយុហើយ ក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រព្រឹត្តប្រយោជន៍ឲ្យដល់ញាតិទាំងឡាយ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុនក៏បានប្រព្រឹត្តហើយដូចគ្នា ។*

*ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ បរិស័ទដ៏សេសក្រៅអំពីនេះ បានមកជាពុទ្ធបរិស័ទ ចំណែកកុក្កុរបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កុក្កុរជាតក ទី ២ ។

# អដ្ឋកថា ភោជាជានីយជាតក ទី ៣

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុលះបង់សេចក្តីព្យាយាមមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **អបិ បស្សេន សេមានោ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា សម័យនោះ ព្រះបរមសាស្តាហៅភិក្ខុនោះមកហើយត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុន បានធ្វើសេចក្តីព្យាយាមក្នុងទីដែលមិនមែនជាលំនៅ ( លានចម្បាំង ) សូម្បីបានទទួលរបួសក៏មិនលះបង់នូវសេចក្តីព្យាយាម ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលសេះសិន្ធព ឈ្មោះភោជាជានីយៈ សម្បូណ៌ទៅដោយអាការទាំងពួង បានជាសេះមង្គលរបស់ព្រះបាទពារាណសី ។ ព្រះពោធិសត្វនោះ បរិភោគភោជនស្រូវសាលីដែលមានក្លិនក្រអូប ដែលគេរក្សាទុកអស់ ៣ ឆ្នាំ ដល់ព្រមដោយរសដ៏ប្រសើរផ្សេងៗ ក្នុងថាសមាសដែលមានតម្លៃ ១ សែន ឈរលើផែនដីដែលបូកលាបដោយគ្រឿងក្រអូបមានកំណើត ៤ ( គន្ធជាតិ ៤ ប្រការ ) ទីកន្លែងដែលឈរនោះ ព័ទ្ធដោយវាំងននកម្ពលពណ៌ក្រហម ខាងលើបាំងពិដានសំពត់ដែលវិចិត្រដោយផ្កាយមាស សំយុងកម្រងផ្កា និងកម្រងគ្រឿង*

ក្រអូប អុជប្រទីបដែលធ្វើអំពីគ្រឿងក្រអូប ។ ឈ្មោះថា ព្រះរាជាទាំងឡាយដែលមិនប្រាថ្នារាជសម្បត្តិក្នុងនគរពារាណសី រមែងមិនមាន ។ សម័យមួយ ព្រះរាជា ៧ អង្គនាំគ្នាព័ទ្ធនគរពារាណសី ហើយបញ្ជូនរាជសារមកព្រះបាទពារាណសីថា តើឲ្យរាជសម្បត្តិដល់ពួកយើងទាំងឡាយ ឬក៏ច្បាំង ? ព្រះបាទពារាណសីឲ្យប្រជុំអាមាត្យទាំងឡាយហើយ ប្រាប់ដំណឹងនោះ ហើយត្រាស់សួរថា នែបាទាំងឡាយ ឥឡូវនេះ ពួកយើងនឹងធ្វើដូចម្តេច ?

អាមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ជាដំបូងទ្រង់មិនចាំបាច់ច្បាំងឡើយ សូមទ្រង់បញ្ជូនទាហានសេះឈ្មោះនោះ ឲ្យធ្វើការច្បាំង កាលទាហានសេះនោះមិនអាច ទូលបង្គំទាំងឡាយនឹងដឹងក្នុងកាលជាខាងក្រោយ ។ ព្រះរាជាត្រាស់ឲ្យហៅទាហានសេះនោះមក ហើយត្រាស់ថា **សក្ខិស្សសិ តាត សត្តហិ រាជូហិ សទ្ធឹ យុទ្ធំ កាតុំ** នែបា អ្នកអាចធ្វើចម្បាំងជាមួយព្រះរាជា ៧ អង្គបានដែរឬទេ ?

ទាហានសេះក្រាបទូលថា **ទេវ សចេ ភោជាជានីយសិន្ធវំ លភាមិ តិដ្ឋន្តុ សត្ត រាជានោ សកលជម្ពុទីបេ រាជូហិបិ សទ្ធឹ យុជ្ឈិតុំ សក្ខិស្សាមិ** បពិត្រព្រះសម្មតិទេព បើទូលបង្គំបានសេះសិន្ធព ឈ្មោះភោជាជានីយៈសោត ព្រះរាជា ៧ អង្គ ចូរលើកទុកចុះ ទូលបង្គំអាចច្បាំងជាមួយព្រះរាជាទូទាំងជម្ពូទ្វីប ។

ព្រះរាជាត្រាស់ថា នែបា សេះសិន្ធពកោជាជានីយៈក្តី សេះដទៃៗក្តី ឲ្យតែអ្នកត្រូវការក៏ចូរយកទៅចុះ ។ ទាហានសេះនោះទទួលព្រះរាជតម្រាស់ថា សាធុ ហើយថ្វាយបង្គំព្រះរាជា ចុះអំពីប្រាសាទ ឲ្យនាំសេះសិន្ធពកោជាជានីយៈមក ខ្លួនឯងក៏ចងគ្រឿងក្រោះគ្រប់ប្រការ សៀតព្រះខ័នឡើងផែលលើសេះសិន្ធពដ៏ប្រសើរ ចេញអំពីនគរទៅដូចផ្លេកបន្ទោរ ទម្លាយកងពលទី ១ ចាប់ព្រះរាជាបាន ១ អង្គ យកមកប្រគល់ឲ្យពលទាហានក្នុងនគរហើយត្រឡប់ទៅទៀត ទម្លាយកងពលទី ២ កងពលទី ៣ ក៏ដូចគ្នា ចាប់ព្រះរាជាបាន ៥ អង្គដោយទំនងនេះ ហើយទម្លាយកងពលទី ៦ ក្នុងគ្រាចាប់ព្រះរាជាអង្គទី ៦ សេះសិន្ធពកោជាជានីយៈបានត្រូវរបួសឈាមហូរពេញខ្លួន វេទនាដ៏ខ្លាំងក្លាក៏ប្រព្រឹត្តទៅ ទាហានសេះនោះដឹងថា សេះសិន្ធពនោះត្រូវរបួសហើយ ទើបឲ្យសេះសិន្ធពកោជាជានីយៈដេកត្រង់ទ្វារព្រះរាជវាំង ហើយបន្ធូរក្រោះ ដើម្បីចងឲ្យសេះដទៃ ។ ព្រះមហាសត្វទាំងដែលកំពុងដេកផ្អៀង បើកភ្នែកឡើងឃើញទាហានសេះធ្វើយ៉ាងនោះ ក៏គិតថា ទាហានសេះនេះចងក្រោះសេះដទៃ សេះនេះមិនអាចទម្លាយកងពលទី ៧ ហើយចាប់ស្តេចអង្គទី ៧ បាន កម្មដែលអញធ្វើទុកហើយនឹងវិនាសអស់ សូម្បីនាយទាហានសេះដែលមិនមានបុគ្គលប្រៀបក៏នឹងវិនាស ព្រះរាជាក៏នឹងធ្លាក់ក្នុងកណ្តាប់ដៃរបស់ព្រះរាជាដទៃ វៀរអាត្មាអញចេញហើយ អ្នកដទៃ

ឈ្មោះថាអាចទម្លាយកងពលទី ៧ ហើយចាប់ព្រះរាជាអង្គទី ៧ បាន រមែងមិនមានឡើយ ទាំងដែលខ្លួនដេកផ្អៀងនោះឯង បានឲ្យហៅនាយទាហានសេះមកហើយពោលថា នៃនាយទាហានសេះសម្លាញ់ រៀរខ្ញុំចេញហើយ ឈ្មោះថាសេះដទៃ ដែលជាអ្នកអាចទម្លាយកងពលទី ៧ ហើយចាប់ព្រះរាជាអង្គទី ៧ បាន មិនមានឡើយ ។ ខ្ញុំនឹងមិនធ្វើកម្មដែលខ្ញុំធ្វើហើយឲ្យវិនាសឡើយ ចូរអ្នកឲ្យខ្ញុំក្រោកឡើងហើយចងក្រោះចុះ កាលពោលដូច្នេះហើយ ទើបពោលគាថានេះថា

**អបិ បស្សេន សេមានោ សល្លេភិ សល្លលីកតោ**
**សេយ្យោវ វឡវា ភោជ្ជោ យុញ្ជ មញ្ញេវ សារថីតិ ។**

សេះភោជាជានីយ សូម្បីត្រូវសរទាំងឡាយមុតហើយ ដេកផ្អៀង គង់ប្រសើរជាងសេះសាមញ្ញ នៃសារថី អ្នកចូរទឹមខ្ញុំដោយគ្រឿងក្រឹសទាំងឡាយចុះ ។

បណ្តាបទទាំងនោះ បទថា **អបិ បស្សេន សេមានោ** បានដល់ សូម្បីដេកមួយចំហៀងនោះឯង ។

បទថា **សល្លេភិ សល្លលីកតោ** សេចក្តីថា ជាអ្នកត្រូវព្រួញទាំងឡាយហើយ ។

បទថា **សេយ្យោវ វឡវា ភោជ្ជោ** សេចក្តីថា សេះខ្ចកដែលមិនបានកើតក្នុងត្រកូលសេះសិន្ធពឈ្មោះថា វឡវ សេះភោជាជានីយ

សិន្ធពឈ្មោះថា គោជ្ញៈ ដូច្នោះសេះគោជាជានីយសិន្ធពនោះឯង សូម្បីត្រូវព្រួញមុតហើយ ក៏គង់ប្រសើរឧត្តមជាងសេះខ្ចកនោះ ។

ដោយបទថា **យុញ្ជ មញ្ញេវ សារថី** នេះ ព្រះពោធិសត្វពោលថា ព្រោះហេតុដែលខ្ញុំទៅដោយអាការយ៉ាងនេះ ក៏គង់ប្រសើរជាងដូច្នេះ ចូរអ្នកប្រកបខ្ញុំចុះ កុំប្រកបសេះដទៃឡើយ ។

នាយទាហានសេះនោះ គ្រាហ៍ព្រះមហាសត្វឲ្យក្រោកឡើង រុំរបួសហើយចងក្រោះសាជាថ្មី រៀបរយហើយ ឡើងអង្គុយលើខ្នងព្រះពោធិសត្វនោះ ទម្លាយកងពលទី ៧ ចាប់ព្រះរាជាអង្គទី ៧ ហើយប្រគល់ឲ្យពលរបស់ព្រះរាជា ។ មនុស្សទាំងឡាយនាំព្រះពោធិសត្វមកកាន់ទ្វារព្រះរាជវាំង ព្រះរាជាយាងចេញមកដើម្បីទតព្រះពោធិសត្វនោះ ។

ព្រះមហាសត្វក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ទ្រង់កុំសម្លាប់ព្រះរាជាទាំង ៧ អង្គឡើយ សូមទ្រង់ឲ្យព្រះរាជាទាំងនោះ ធ្វើនូវសម្បថហើយដោះលែងទៅ សូមទ្រង់ប្រទានយសដែលគប្បីប្រទានដល់ទូលបង្គំនិងនាយទាហានសេះ ឲ្យចំពោះដល់នាយទាហានសេះតែម្នាក់ប៉ុណ្ណោះ កាលចាប់ព្រះរាជា ៧ អង្គបានហើយ ធ្វើទាហានដែលធ្វើនូវការច្បាំងឲ្យវិនាស ( មិនបូជា ) រមែងមិនគួរ សូមទ្រង់បំពេញទានរក្សាសីល គ្រងរាជសម្បត្តិដោយធម៌ ។ កាលព្រះពោធិសត្វឲ្យឱវាទដល់ព្រះរាជាយ៉ាងនេះហើយ មនុស្សទាំងឡាយក៏ដោះក្រោះចេញអំពី

ព្រះពោធិសត្វ គ្រាន់តែដោះគ្រោះចេញប៉ុណ្ណោះ ព្រះពោធិសត្វក៏ស្លាប់ទៅ ។ ព្រះរាជា ទ្រង់ឲ្យធ្វើឈាបនកិច្ចសរីរៈរបស់ព្រះពោធិសត្វនោះ បានប្រទានយសធំដល់នាយទាហានសេះ ទ្រង់ឲ្យព្រះរាជា ៧ អង្គនោះធ្វើនូវសម្បថ មិនប្រទូសរ៉ាយដល់ព្រះអង្គទៀត ហើយទ្រង់ដោះលែងទៅ ទ្រង់គ្រប់គ្រងរាជសម្បត្តិដោយធម៌ស្មើ ក្នុងវេលាអស់ព្រះជន្មាយុក៏ទៅតាមយថាកម្ម ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុនបានធ្វើនូវសេចក្តីព្យាយាម ក្នុងទីដែលមិនមែនជាប្រភពកើត ( លំនៅ ) យ៉ាងនេះ សូម្បីបានទទួលនូវរបួសមានសភាពបែបនេះ ក៏មិនលះបង់នូវសេចក្តីព្យាយាម ចំណែកអ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំសត្វចេញចាកទុក្ខមានសភាពបែបនេះ ព្រោះហេតុអ្វីទើបលះបង់នូវសេចក្តីព្យាយាម ? ហើយទ្រង់ប្រកាសសច្ចៈ ៤ ក្នុងវេលាចប់សច្ចៈ ភិក្ខុដែលលះបង់សេចក្តីព្យាយាម តាំងនៅក្នុងអរហត្តផល ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ទាហានសេះក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកភោជាជានីយសិន្ធពក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ភោជាជានីយជាតក ទី ៣ ។

# អដ្ឋកថា អាជញ្ញជាតក ទី ៤

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកលះបង់សេចក្តីព្យាយាមដូចគ្នា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យទា យទា** *ដូច្នេះជាដើម ។*

*ព្រះមានព្រះភាគ ទ្រង់ហៅភិក្ខុនោះមកហើយត្រាស់ថា ម្នាលភិក្ខុបណ្ឌិតទាំងឡាយក្នុងកាលមុន សូម្បីជាអ្នកត្រូវប្រហារ ទាំងក្នុងទីដែលមិនមែនជាប្រភពកើត (លំនៅ) ក៏បានធ្វើនូវសេចក្តីព្យាយាមហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះរាជា ៧ អង្គ នាំគ្នាព័ទ្ធនគរពារាណសីទុកដោយន័យដែលមានក្នុងរឿងមុននោះឯង ។ លំដាប់នោះ អ្នកចម្បាំងប្រចាំរថម្នាក់ទឹមសេះសិន្ធព ២ ដែលជាសេះបងនិងសេះប្អូនចេញអំពីនគរ ទម្លាយកងពលទី ៦ ចាប់បានព្រះរាជា ៦ អង្គ ខណៈនោះ សេះជាបងក៏ត្រូវរបួស ទើបនាយសារថីបញ្ជូនមកកាន់ទ្វារព្រះរាជវាំង ដកសេះដែលជាបងចេញអំពីរថ ធ្វើគ្រោះឲ្យធូរហើយឲ្យដេកផ្អៀងក្នុងចំណែកម្ខាង ផ្តើមពាក់គ្រោះឲ្យសេះដទៃ ព្រះពោធិសត្វឃើញដូច្នោះក៏គិតដោយន័យដូចរឿងមុននោះឯង ហើយឲ្យហៅសារថីមក ទាំងដែលខ្លួនកំពុងដេកនោះឯងបានពោលគាថានេះថា*

**យទា យទា យត្ថ យទា　　យត្ថ យត្ថ យទា យទា**
**អាជញ្ញោ ករុតេ វេគំ　　　ហាយន្តិ តត្ថ វាឡវាតិ ។**

*សេះអាជានេយ្យ ធ្វើនូវសន្ទុះក្នុងទីណា ក្នុងកាលណាម្ដងៗ ឬក្នុងខណៈណា ក្នុងមណ្ឌលចម្បាំងណា ក្នុងកាលណាម្ដងៗ សេះសាមញ្ញទាំងឡាយ តែងសាបសូន្យ ក្នុងកាលនោះ ក្នុងទីនោះ ។*

*បណ្ដាបទទាំងនោះ បទថា* **យទា យទា** *បានដល់ ក្នុងកាលណាៗ ក្នុងបណ្ដាកាល មានពេលព្រឹកជាដើម ។ បទថា* **យត្ថ** *បានដល់ ក្នុងទីណា គឺក្នុងផ្លូវ ឬក្នុងលានចម្បាំង ។ បទថា* **យទា** *គឺក្នុងខណៈណា ។*

*បទថា* **យត្ថ យត្ថ** *បានដល់ ក្នុងលានចម្បាំងដ៏ច្រើន ដូចជាកងពល ៧ កងជាដើម ។ បទថា* **យទា យទា** *បានដល់ ក្នុងកាលណាៗ គឺក្នុងកាលដែលបានទទួលរបួសក្ដី មិនបានទទួលរបួសក្ដី ។*

*បទថា* **អាជញ្ញោ ករុតេ វេគំ** *សេចក្ដីថា សេះអាជានេយ្យ គឺសេះសិន្ធពដ៏ប្រសើរ ជាអ្នកមានសភាពដឹងទូទៅដល់ហេតុដែលចិត្តរបស់សារថីគិត ប្រើកម្លាំងដ៏រហ័ស គឺព្យាយាម ប្រារព្ធសេចក្ដីព្យាយាម ។*

*បទថា* **ហាយន្តិ តត្ថ វាឡវា** *សេចក្ដីថា កាលសេះអាជានេយ្យនោះប្រើកម្លាំងដ៏រហ័ស សេះខ្ចក ពោលគឺសេះធម្មតាក្រៅអំពីនេះ រមែង*

*ថមថយ គឺវមែងអាប់ឱន ព្រោះដូច្នោះ ( ទើបព្រះពោធិសត្វពោលថា ) ចូរអ្នកទឹមចំពោះខ្ញុំប៉ុណ្ណោះ ក្នុងរថមួយនេះ ។*

*សារថីគ្រាហ៍ព្រះពោធិសត្វឲ្យក្រោកឡើង ទឹមហើយទម្លាយកងពលទី ៧ នាំយកព្រះរាជាទី ៧ មក បររថមកកាន់ទ្វារព្រះរាជវាំងហើយដោះសេះសិន្ធព ព្រះពោធិសត្វដេកផ្អៀងក្នុងចំណែកម្ខាង ថ្វាយឱវាទដល់ព្រះរាជាដោយន័យដូចរឿងមុននោះឯង ហើយក៏ស្លាប់ទៅ ។ ព្រះរាជា ទ្រង់បញ្ជាឲ្យធ្វើឈាបនកិច្ចសរីរៈរបស់ព្រះពោធិសត្វនោះ ហើយធ្វើសមាន ( ការរាប់អាន ) ដល់សារថីប្រចាំរថ ទ្រង់គ្រងរាជសម្បត្តិប្រ-កបដោយធម៌ស្មើ លុះអស់ព្រះជន្មហើយក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈ ក្នុងវេលាចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងអរហត្តផល ។ ព្រះបរមសាស្តា ទ្រង់ប្រជុំជាតកថា ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទត្ថេរ សារថីបានមកជាសារីបុត្ត ចំណែកសេះសិន្ធពគឺ* **តថាគតអរហន្តសម្មាសម្ពុទ្ធ** *នេះឯង ៕*

ចប់ អដ្ឋកថា អាជញ្ញជាតក ទី ៤ ។

# អដ្ឋកថា តិត្ថជាតក ទី ៥

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលធ្លាប់ជាជាងមាសមួយរូប ជាសទ្ធិវិហារិករបស់ព្រះធម្មសេនាបតី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អញ្ញមញ្ញេហិ តិត្ថេហិ** ដូច្នេះជាដើម ។

ឯអាសយានុសយញ្ញាណ រមែងមានដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះ មិនមានដល់បុគ្គលដទៃ ព្រោះដូច្នោះ ទើបព្រះធម្មសេនាបតីមិនដឹងអាសយៈ គឺអធ្យាស្រ័យ និងអនុសយៈ គឺកិលេសដែលនៅក្នុងខន្ធសន្តានរបស់សទ្ធិវិហារិក ព្រោះភាពដែលខ្លួនមិនមានអាសយានុសយញ្ញាណ ទើបប្រាប់ចំពោះអសុភកម្មដ្ឋានប៉ុណ្ណោះ អសុភកម្មដ្ឋាននោះមិនជាទីសប្បាយដល់សទ្ធិវិហារិកនោះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះបានឮថា សទ្ធិវិហារិករបស់ព្រះធម្មសេនាបតីនោះបដិសន្ធិក្នុងត្រកូលជាងមាសប៉ុណ្ណោះអស់ ៥០០ ជាតិ កាលបើដូច្នោះ ទើបអសុភកម្មដ្ឋានមិនជាទីសប្បាយដល់សទ្ធិវិហារិកនោះ ព្រោះជាអ្នកថ្មីកក្នុងការឃើញមាសដែលបរិសុទ្ធប៉ុណ្ណោះ អស់កាលយូរ សទ្ធិវិហារិកនោះ មិនអាចធ្វើត្រឹមតែនិមិត្តឲ្យកើតឡើងក្នុងកម្មដ្ឋាននោះ រហូតអស់កាល ៤ ខែ ព្រះធម្មសេនាបតី មិនអាចឲ្យអរហត្តដល់សទ្ធិវិហារិករបស់

ខ្លួន ទើបគិតថា ភិក្ខុនេះប្រហែលជាពុទ្ធវេនេយ្យពិតប្រាកដ អញនឹងនាំទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ទើបនាំសទ្ធិវិហារិកនោះទៅកាន់សម្នាក់របស់ព្រះទសពលដោយខ្លួនឯងអំពីព្រលឹម ។ ព្រះបរមសាស្តាត្រាស់សួរថា ម្នាលសារីបុត្ត អ្នកនាំភិក្ខុមួយរូបមកឬ?

ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឲ្យកម្មដ្ឋានដល់ភិក្ខុនេះ តែភិក្ខុនេះមិនអាចធ្វើ សូម្បីត្រឹមតែនិមិត្តឲ្យកើតឡើងអស់កាល ៤ ខែ ខ្ញុំព្រះអង្គគិតថា ភិក្ខុនេះ ប្រហែលជាពុទ្ធវេនេយ្យ ទើបនាំលោកមកកាន់សម្នាក់របស់ព្រះអង្គ ។

ព្រះបរមសាស្តាត្រាស់សួរថា ម្នាលសារីបុត្ត អ្នកឲ្យកម្មដ្ឋានអ្វីដល់សទ្ធិវិហារិករបស់អ្នក?

ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឲ្យអសុភកម្មដ្ឋាន ។

ព្រះសាស្តាត្រាស់ថា ម្នាលសារីបុត្ត អ្នកមិនមានញាណជាគ្រឿងដឹងអធ្យាស្រ័យនិងអនុស័យរបស់សត្វទាំងឡាយ អ្នកទៅចុះ ក្នុងពេលល្ងាច សឹមមកនាំសទ្ធិវិហារិករបស់អ្នកទៅវិញ ។ ព្រះសាស្តាទ្រង់បញ្ជូនព្រះថេរៈទៅយ៉ាងនេះហើយ បានឲ្យសំពត់ស្លៀកនិងចីវរដែលជាទីពេញចិត្តដល់ភិក្ខុនោះ ហើយទ្រង់នាំភិក្ខុនោះចូលទៅបិណ្ឌបាតក្នុងស្រុក ទ្រង់ប្រទានរបស់ទំពានិងរបស់ឆាន់ប្រណីតៗ ចោមរោមដោយមហាភិក្ខុសង្ឃ

ត្រឡប់មកកាន់វិហារវិញ ។ ព្រះសាស្តា ទ្រង់ញុំាងកាលវេលាកន្លះថ្ងៃឲ្យអស់ទៅក្នុងព្រះគន្ធកុដិ លុះវេលាល្ងាច ទ្រង់នាំភិក្ខុនោះត្រាច់ចារិកទៅក្នុងវិហារ ទ្រង់និម្មិតស្រះបោក្ខរណីមួយក្នុងអម្ពវ័ន ហើយទ្រង់និម្មិតគុម្ពឈូកធំក្នុងស្រះបោក្ខរណីនោះ និងទ្រង់និម្មិតផ្កាឈូកក្រហម ១ ក្នុងគុម្ពឈូកនោះ ហើយត្រាស់ឲ្យភិក្ខុនោះអង្គុយដោយព្រះតម្រាស់ថា នែភិក្ខុអ្នកចូលអង្គុយមើលផ្កាឈូកនេះ ហើយទ្រង់ចូលកាន់ព្រះគន្ធកុដិ ។ ភិក្ខុនោះ សម្លឹងមើលផ្កាឈូកនោះរឿយៗ ព្រះសាស្តា ទ្រង់ធ្វើឲ្យផ្កាឈូកនោះស្វិតស្រពោន ផ្កាឈូកនោះ កាលភិក្ខុនោះកំពុងសម្លឹងមើលក៏ស្វិតស្រ-ពោនថមថយពណ៌ទៅ កាលបើដូច្នោះ ត្របកផ្កាឈូកនោះក៏ជ្រុះទៅដោយជុំវិញ កាលជ្រុះអស់ហើយដោយជុំវិញ បានជ្រុះហើយក្នុងមួយសន្ទុះប៉ុណ្ណោះ បន្ទាប់អំពីនោះ កេសរក៏ជ្រុះទៅ សល់នៅតែផ្ទៃឈូកខ្ចីខាងក្នុង ភិក្ខុនោះឃើញដូច្នោះ ទើបគិតថា ផ្កាឈូកនេះស្រស់ល្អ គួររមិលមើលដ៏ម៉្លេះ កាលបើដូច្នោះ ពណ៌របស់ផ្កាឈូកក៏គង់ប្រែប្រួលទៅត្របកនិងកេសរក៏រុះរោយទៅ សល់នៅត្រឹមតែផ្ទៃខ្ចីខាងក្នុងប៉ុណ្ណោះ ការចាស់ជរារបស់ផ្កាឈូកដែលមានសភាពបែបនេះ គង់ប្រាកដ ចំណង់បើរាងកាយរបស់អាត្មាអញ តើនឹងតាំងនៅឯណាបាន សង្ខារទាំងឡាយមិនទៀងហ្ន៎ ទើបផ្តើមចម្រើនវិបស្សនា ។ ព្រះទសពលទ្រង់ជ្រាបថា ចិត្តរបស់ភិក្ខុនោះ ឡើងកាន់វិបស្សនាហើយ ទ្រង់គង់នៅក្នុងព្រះគន្ធកុដិនោះ

ឯង ទ្រង់បញ្ចេញឱភាសឲ្យភិក្ខុនោះឃើញ ហើយត្រាស់ព្រះគាថានេះថា

**ឧច្ឆិន្ទ សិនេហមត្តនោ**

**កុមុទំ សារទិកំវ បាណិនា**

**សន្តិមគ្គមេវ ព្រូហយ**

**និព្វានំ សុគតេន ទេសិតំ ។**

*អ្នកចូរដកសេចក្ដីស្រឡាញ់របស់ខ្លួនចេញ ដូចបុគ្គល ដកផ្កា កុមុទ ដែលកើតក្នុងសរទកាលដោយដៃ អ្នកចូរបណ្ដុះនូវផ្លូវ សន្តិភាពតែម្យ៉ាង ព្រះនិព្វាន ព្រះសុគតសម្ដែងទុកហើយ[១] ។*

*ក្នុងវេលាចប់គាថា ភិក្ខុនោះក៏សម្រេចអរហត្ត ទើបគិតថា អាត្មាអញជាបុគ្គលរួចផុតហើយអំពីភពទាំងពួង ហើយបន្លឺឧទានដោយគាថាទាំងឡាយថា*

**សោ វុត្ថវាសោ បរិបុណ្ណមានសោ**

**ខីណាសវោ អន្តិមទេហធារី**

**វិសុទ្ធសីលោ សុសមាហិតិន្ទ្រិយោ**

**ចន្ទោ យថា រាហុមុខា បមុត្តោ ។**

**តមោកតំ មោហមហន្ធការំ**

---

*១-បិ. ៥២ , ទំ. ៨០ ។*

វិធោចយិ សព្វមលំ អសេសំ
អាលោកបជ្ជោតកោ បភង្ករោ
សហស្សរំសី វិយ ភាណុមា ឯភេតិ ។

អាត្មាអញនោះ មានធម៌ជាគ្រឿងនៅចប់ហើយ មានឆន្ទៈក្នុងចិត្តបរិបូណ៌ហើយ មានអាសវៈអស់ហើយ ទ្រទ្រង់ទុកនូវរាងកាយជាចុងក្រោយ មានសីលបរិសុទ្ធ មានឥន្ទ្រិយតាំងមាំដោយល្អ រួចផុតហើយ ដូចព្រះចន្ទផុតអំពីមាត់រាហុ ដូច្នោះ អាត្មាអញបន្ទោបង់នូវមន្ទិលទាំងពួង ដែលធ្វើងងឹត គឺមោហៈឲ្យដាច់ទៅ ដូចព្រះអាទិត្យមានរស្មីរាប់ពាន់បញ្ចេញពន្លឺ ធ្វើនូវពន្លឺដ៏រុងរឿង ក្នុងលំហមេឃដូច្នោះ ។

កាលបន្លឺឧទានហើយ ទើបមកថ្វាយបង្គំព្រះបរមសាស្តា ចំណែកព្រះថេរៈក៏មកថ្វាយបង្គំព្រះមានព្រះភាគ ហើយនាំសទ្ធិវិហារិករបស់ខ្លួនទៅ ។ ដំណឹងនេះកើតប្រាកដក្នុងរវាងភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយអង្គុយពណ៌នាព្រះគុណរបស់ព្រះទសពលក្នុងរោងធម្មសភាថា អាវុសោទាំងឡាយ ព្រះសារីបុត្តត្ថេរមិនដឹងអធ្យាស្រ័យរបស់សទ្ធិវិហារិករបស់ខ្លួន ព្រោះមិនមានអាសយានុសយញ្ញាណ តែព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់បានប្រទានអរហត្ត មួយអន្លើដោយបដិសម្ភិទាដល់ភិក្ខុនោះ ក្នុងថ្ងៃ ១ ប៉ុណ្ណោះ ឱ ឈ្មោះថាព្រះពុទ្ធទាំងឡាយ ទ្រង់មានអានុភាពច្រើន ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងមកកាន់រោងធម្មសភា គង់លើអាសនៈដែលគេក្រាលទុកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយរឿងដទៃក៏មិនមែន តែអង្គុយសន្ទនាគ្នាដោយរឿងព្រះញាណរបស់ព្រះអង្គ ដែលជាគ្រឿងដឹងអធ្យាស្រ័យនិងអនុស័យនៃសទ្ធិវិហារិករបស់ព្រះធម្មសេនាបតីប៉ុណ្ណោះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនជាអស្ចារ្យទេ ដ្បិតឥឡូវនេះ តថាគតជាព្រះសម្មាសម្ពុទ្ធហើយ ដឹងអធ្យា-ស្រ័យរបស់បុគ្គលនោះ សូម្បីក្នុងកាលមុនតថាគតក៏ដឹងអធ្យាស្រ័យរបស់ភិក្ខុនោះដូចគ្នា ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វជាអ្នកបង្រៀនអត្ថ និងបង្រៀនធម៌ដល់ព្រះរាជាអង្គនោះ ។ ក្នុងកាលនោះ ពួកអ្នកចិញ្ចឹមសេះឲ្យសេះខ្វកផឹកនិងងូតទឹកមុនសេះដទៃ ក្នុងកំពង់សេះមង្គលរបស់ព្រះរាជា សេះមង្គលនោះ ត្រូវឲ្យចុះក្នុងកំពង់ដែលសេះខ្វកងូតហើយ ក៏ខ្ពើមរអើម មិនប្រាថ្នានឹងចុះ ។ អ្នកចិញ្ចឹមសេះមកក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព សេះមង្គលមិនប្រាថ្នានឹងចុះក្នុងកំពង់ទឹក ។

ព្រះរាជា ទ្រង់បញ្ជូនព្រះមហាសត្វទៅដោយព្រះតម្រាស់ថា នៃបណ្ឌិត ចូរអ្នកទៅ ចូរដឹងថា ព្រោះហេតុអ្វីទើបសេះមិនចុះក្នុងកំពង់ទឹក?

ព្រះពោធិសត្វទទួលព្រះរាជបញ្ជាថា សាធុ ហើយក៏ទៅកាន់ឆ្នេរស្ទឹង ពិនិត្យមើលក៏ដឹងថាសេះមិនមានរោគ ទើបពិចារណាថា ព្រោះហេតុអ្វីហ្ន៎ ទើបសេះនេះមិនចុះក្នុងកំពង់នេះ ក៏គិតឃើញថា សេះដទៃបានចុះក្នុងកំពង់នេះមុន ដោយហេតុនោះ សេះនេះរង្កៀសទើបមិនចុះ ហើយសួរអ្នកចិញ្ចឹមសេះថា នៃអ្នកដ៏ចម្រើន ត្រង់កំពង់នេះអ្នកទាំងឡាយឲ្យសេះណាផ្ងូតមុន?

ពួកគង្វាលសេះពោលថា បពិត្រលោកម្ចាស់ ខ្ញុំឲ្យសេះខ្នកង្ងូតមុនសេះដទៃ ។ ព្រះពោធិសត្វដឹងអធ្យាស្រ័យរបស់សេះនោះថា សេះនេះរង្កៀសទើបមិនប្រាថ្នានឹងង្ងូតក្នុងកំពង់នេះ ព្រោះខ្លួនជាសត្វមានគុណសម្បត្តិ កាលឲ្យសេះនេះង្ងូតក្នុងកំពង់នេះមុនទើបគួរ ក៏ពោលថា នៃអ្នកដ៏ចម្រើន មធុបាយាសដែលចម្អិនដោយសប្បិ (ទឹកដោះថ្លា) ដោយទឹកឃ្មុំនិងទឹកអំពៅ កាលបុគ្គលបរិភោគរឿយៗមុន រមែងមានការធុញទ្រាន់ សេះនេះង្ងូតត្រង់កំពង់នេះច្រើនដង សូមពួកអ្នកឲ្យសេះនេះចុះក្នុងកំពង់ដទៃ ហើយឲ្យង្ងូតនិងផឹកចុះ ទើបពោលគាថានេះថា

អញ្ញមញ្ញេហិ តិត្ថេហិ អស្សំ បាយេហិ សារថិ
អច្ចាសនស្ស បុរិសោ បាយាសស្សបិ តប្បតីតិ។

ម្នាលសារថី អ្នកចូរញ៉ាំងសេះឲ្យផឹក ( ទឹក ) តាមកំពង់ទឹក
ទាំងឡាយដទៃៗ ចុះ ឯសេះឆ្អែតដោយបាយាស ដោយ
ការស៊ីជ្រុលហើយ ( រមែងមិនត្រូវការបរិភោគទៀតទេ ) ។

បណ្ដាបទទាំងនោះ បទថា **អញ្ញមញ្ញេហិ** ញែកសព្ទចេញជា **អញ្ញេហិ អញ្ញេហិ** ប្រែថា ដទៃៗ ។

បទថា **ចាយេហិ** ប្រែថា ចូរឲ្យផឹក នេះជាប្រធាននៃទេសនា អធិប្បាយថា ចូរឲ្យផ្ញួតនិងឲ្យផឹក ។

បទថា **អច្ចាសនស្ស** នេះជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថនៃតតិយាវិភត្តិ អធិប្បាយថា ស៊ីក្រៃលែង គឺបរិភោគក្រៃលែង ។

បទថា **ចាយាសស្សបិ តប្បតិ** សេចក្ដីថា រមែងឆ្អែត គឺជាអ្នកឆ្អែត ជាអ្នកដែលគេចិញ្ចឹមឲ្យឆ្អែតហើយដោយបាយាសដែលចម្អិនដោយសប្បិជាដើម រមែងមិនដល់នូវសេចក្ដីត្រូវការនឹងបរិភោគទៀត ព្រោះដូច្នោះ ទើបសេះនេះដល់នូវការធុញទ្រាន់ ព្រោះការផ្ញួតជាប្រចាំក្នុងកំពង់នេះ ចូរអ្នកទាំងឡាយឲ្យផ្ញួតក្នុងកំពង់ដទៃចុះ ។

អ្នកចិញ្ចឹមសេះទាំងនោះ បានស្ដាប់ពាក្យរបស់ព្រះបរមពោធិសត្វហើយ ទើបឲ្យសេះចុះក្នុងកំពង់ដទៃ ឲ្យផឹកនិងឲ្យផ្ញួត ។ ក្នុងវេលាដែលសេះផឹកនិងផ្ញួតហើយ ព្រះមហាសត្វបានមកកាន់សម្នាក់របស់ព្រះរាជាវិញ ។ ព្រះរាជាត្រាស់សួរថា **កឹ តាត អស្សោ ផ្ហាតោ ច បីតោ**

ច នៃបា សេះផ្ងូតនិងផឹកហើយឬ ?

ព្រះពោធិសត្វក្រាបទូលថា **អាម ទេវ** ករុណាថ្ងៃវិសេស ។

ព្រះរាជាត្រាស់សួរថា តើព្រោះហេតុអ្វី ទើបសេះមិនប្រាថ្នានឹងផឹក មិនប្រាថ្នានឹងផ្ងូត ?

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រោះហេតុឈ្មោះនេះ ព្រោះហេតុឈ្មោះនេះ ហើយក្រាបទូលហេតុទាំងពួង ។

ព្រះរាជាត្រាស់ថា ឱ បណ្ឌិត អ្នករមែងដឹងអធ្យាស្រ័យ សូម្បីតែសត្វតិរច្ឆានបែបនេះ ហើយប្រទានយសធំដល់ព្រះពោធិសត្វ ។ ក្នុងវេលាអស់ព្រះជន្ម ព្រះរាជាក៏ទៅតាមយថាកម្ម ចំណែកព្រះពោធិសត្វក៏បានទៅតាមយថាកម្មដូចគ្នា ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតដឹងអធ្យាស្រ័យរបស់ភិក្ខុនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ដឹងហើយដូចគ្នា ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា សេះមង្គលក្នុងកាលនោះ បានមកជាភិក្ខុរូបនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ ចំណែកអាមាត្យដែលជាបណ្ឌិតក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា តិត្ថជាតក ទី ៥ ។

# អដ្ឋកថា មហិឡាមុខជាតក ទី ៦

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **បុរាណចោរាន វចោ និសម្ម** *ដូច្នេះជាដើម ។*

*សេចក្ដីពិស្ដារថា ភិក្ខុទេវទត្តបានធ្វើឲ្យព្រះបាទអជាតសត្តុកុមារជ្រះថ្លាហើយញ៉ាំងលាភសក្ការៈឲ្យកើតឡើង អជាតសត្តុកុមារបានឲ្យគេសង់វិហារត្រង់គយាសីសប្រទេសដើម្បីភិក្ខុទេវទត្ត ហើយនាំទៅចំពោះនូវភោជនដែលចម្អិនដោយអង្ករស្រូវសាលីមានក្លិនក្រអូប ដែលគេរក្សាទុកអស់ ៣ ឆ្នាំ មានឱជារសដ៏ប្រសើរ មួយថ្ងៃ ៥០០ សម្រាប់ ព្រោះអាស្រ័យលាភសក្ការៈបរិវាររបស់ទេវទត្តក៏រីកចម្រើនឡើង ភិក្ខុទេវទត្តព្រមទាំងបរិវារនៅក្នុងវិហារនោះឯង ។ សម័យនោះ មានសម្លាញ់ពីរនាក់ជាអ្នកនគររាជគ្រឹះ ក្នុងសម្លាញ់ទាំងពីរនាក់នោះ សម្លាញ់ម្នាក់បួសក្នុងសម្នាក់របស់ព្រះសាស្តា ម្នាក់ទៀតបួសក្នុងសម្នាក់របស់ភិក្ខុទេវទត្ត ។ សម្លាញ់ទាំងពីរនាក់នោះ រមែងឃើញគ្នានឹងគ្នាក្នុងទីនោះៗ សូម្បីទៅវិហារក៏ឃើញគ្នា ។ ថ្ងៃមួយ ភិក្ខុជា ( សម្លាញ់ ) ដែលជាកូនសិស្សរបស់ទេវទត្តពោលនឹងសម្លាញ់នោះថា អាវុសោ លោកត្រាច់បិណ្ឌបាតមានញើសហូរពល់ៗ ថ្ងៃធ្វើអ្វី លោកអង្គុយក្នុងវិហារ ត្រង់គយាសីសប្រទេសប៉ុណ្ណោះ នឹងបានបរិភោគភោជនដែលល្អ មានរសប្រសើរផ្សេងៗ*

បាយាសដែលមានសភាពបែបនោះមិនមានក្នុងវិហារនេះ លោកសោយទុក្ខធ្វើអ្វី ប្រយោជន៍អ្វីដល់លោក ការមកកាន់គយាសីសប្រទេសអំពីព្រលឹម ឆាន់បបរព្រមទាំងសម្ទុឧត្តរិភង្គ ទំពារបស់គួរទំពា ១៨ ប្រភេទ ហើយបរិភោគភោជនល្អៗ ប្រកបដោយរសដ៏ប្រសើរ តើមិនគួរទេឬ ? ភិក្ខុនោះ ត្រូវភិក្ខុជាសម្លាញ់បបួលរឿយៗ ជាអ្នកមានបំណងនឹងទៅ ចាប់តាំងអំពីពេលនោះ ក៏ទៅកាន់គយាសីសប្រទេស បរិភោគហើយមកកាន់វត្តវេឡុវ័នក្នុងវេលាល្ងាច ភិក្ខុនោះ មិនអាចបិទបាំងនូវកម្មនោះបាន មិនយូរប៉ុន្មានដំណឹងក៏ប្រាកដថា ភិក្ខុនោះ ទៅកាន់គយាសីសប្រទេសបរិភោគភត្តដែលគេឧបដ្ឋាកចំពោះទេវទត្ត ។ លំដាប់នោះ សម្លាញ់ទាំងឡាយនាំគ្នាមកសួរភិក្ខុនោះថា នែអាវុសោ បានឮថា លោកបរិភោគភត្តដែលគេឧបដ្ឋាកដល់ភិក្ខុទេវទត្ត ពិតឬ ?

ភិក្ខុនោះសួរថា អ្នកណាពោលយ៉ាងនេះ ?

សម្លាញ់ទាំងនោះឆ្លើយថា បុគ្គលនោះ និងបុគ្គលនោះពោល ។

ភិក្ខុនោះក៏ពោលថា អាវុសោទាំងឡាយ ខ្ញុំទៅកាន់គយាសីសប្រទេសបរិភោគ ពិតមែនហើយ តែទេវទត្តមិនបានឲ្យភត្តដល់ខ្ញុំទេ អ្នកដទៃជាអ្នកឲ្យ ។

ភិក្ខុជាសម្លាញ់ទាំងនោះពោលថា អាវុសោ ភិក្ខុទេវទត្តជាចម្រូងជាបន្ទាចំពោះព្រះពុទ្ធ ជាអ្នកទ្រុស្តសីល ញុំាងព្រះបាទអជាតសត្តុឲ្យ

ជ្រះថ្លា ហើយញុំាងលាភសក្ការៈឲ្យកើតឡើងដល់ខ្លួន មិនប្រកបដោយធម៌ លោកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខ មានសភាពបែបនេះ បែរជាទៅបរិភោគភោជនដែលកើតឡើងដល់ទេវទត្ត ដែលមិនប្រកបដោយធម៌ ណ្ហើយចុះ មកយើងទាំងឡាយនឹងនាំលោកទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយនាំភិក្ខុនោះទៅកាន់រោងធម្មសភា ។ ព្រះមានព្រះភាគ ទ្រង់ឃើញភិក្ខុនោះប៉ុណ្ណោះ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនាំភិក្ខុអ្នកមិនប្រាថ្នាមកហើយឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា ករុណាព្រះអង្គ ភិក្ខុនេះបួសក្នុងសម្នាក់ព្រះអង្គ ហើយបរិភោគភោជនដែលកើតឡើងក្នុងសម្នាក់ទេវទត្តដែលបានមកមិនប្រកបដោយធម៌ ។

ព្រះសាស្តាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកបរិភោគភោជនដែលកើតដល់ទេវទត្ត ដែលមិនប្រកបដោយធម៌ ពិតឬ ?

ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ទេវទត្តមិនបានឲ្យភត្តដល់ខ្ញុំព្រះអង្គទេ តែភិក្ខុដទៃៗជាអ្នកឲ្យ ទើបខ្ញុំព្រះអង្គបរិភោគភត្តនោះ ។

ព្រះមានព្រះភាគត្រាស់ថា នៃភិក្ខុ អ្នកកុំបណ្តោះបណ្តោក្នុងរឿងនេះឡើយ ទេវទត្តជាបុគ្គលមិនមានអាចារៈ ជាអ្នកទ្រុស្តសីល អ្នកបួសក្នុងសាសនានេះហើយ គប់រកសាសនានេះហើយ តើបរិភោគភត្តរបស់ទេវទត្តបានដូចម្តេច ជានិច្ចកាលអ្នកមានប្រក្រតីគប់រកពួកបុគ្គលដោយ

គ្រាន់តែឃើញ កាលត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វបានជាអាមាត្យរបស់ព្រះបាទព្រហ្មទត្តនោះ ។ ក្នុងកាលនោះ ដំរីមង្គលរបស់ព្រះបាទព្រហ្មទត្ត ឈ្មោះថា មហិឡាមុខជាដំរីមានសីល សម្បូណ៌ដោយអាចារៈនិងមារយាទ មិនបៀតបៀនដល់បុគ្គលណាមួយឡើយ ។ ថ្ងៃមួយ ចោរទាំងឡាយមកក្នុងទីជិតរោងដំរីនោះ ក្នុងលំដាប់កាលដែលជាចំណែកនៃរាត្រី អង្គុយពិភាក្សាគ្នាអំពីការលួចក្នុងទីមិនឆ្ងាយអំពីដំរីនោះ ដោយពាក្យថា យើងត្រូវជីករូងក្នុងដីយ៉ាងនេះ យើងត្រូវកាត់ជញ្ជាំងយ៉ាងនេះ យើងត្រូវធ្វើរូងក្នុងដីដោយការកាប់ឆ្ការឲ្យស្រឡះ ឲ្យប្រាសចាកគុម្ពឈើ ដូចគ្នានឹងផ្លូវ ដូចគ្នានឹងកំពង់ទឹក ហើយលួចយករបស់ទៅទើបគួរ បុគ្គលកាលនឹងលួច ត្រូវប្រហារនិងត្រូវសម្លាប់ហើយសឹមលួច កាលបើយ៉ាងនេះ ឈ្មោះថា បុគ្គលជាអ្នកអាចក្រោកឡើងប្រឆាំងជាមួយនឹងយើងមិនមាន ធម្មតាចោរ ត្រូវតែជាបុគ្គលមិនប្រកបដោយសីលនិងអាចារៈ ត្រូវតែជាមនុស្សរឹងត្អឹងគ្រោតគ្រាត ចចេសរឹងរូស កាលប្រឹក្សាគ្នាយ៉ាងនេះហើយ ទើបឲ្យគ្នារៀនយកទៅវិញទៅមក ហើយនាំគ្នាទៅ ពួកចោរនាំគ្នាមកប្រឹក្សាក្នុងទីនោះ ដោយន័យនោះឯងច្រើនថ្ងៃ គឺមួយថ្ងៃហើយមួយថ្ងៃទៀត ។

ដំរីបានស្តាប់ពាក្យរបស់ចោរទាំងនោះ សម្គាល់ថា ចោរទាំងនេះឲ្យអញសិក្សា ទើបគិតថា ចាប់តាំងអំពីពេលនេះទៅ អញត្រូវតែជាសត្វរឹងត្អឹងគ្រោតគ្រាត ចចេស ទើបក្លាយទៅជាសត្វមានសភាពបែបនោះ ព្រឹកឡើង យកប្រមោយចាប់ហ្មដំរីដែលមកអំពីព្រលឹម បោកផ្ទប់នឹងផែនដីឲ្យស្លាប់ សម្លាប់មនុស្សដែលមកហើយ ម្តងមួយៗ ។ ពួករាជបុរសក៏ក្រាបទូលដល់ព្រះរាជាថា **មហិឡាមុខោ ឧម្មត្តកោ ជាតោ ទិដ្ឋទិដ្ឋេ មារេតិ** ដំរីមហិឡាមុខៈឆ្កួតហើយ សម្លាប់មនុស្សដែលខ្លួនបានឃើញហើយ ។ ព្រះរាជា ទ្រង់បញ្ជូនព្រះបរមពោធិសត្វទៅដោយព្រះតម្រាស់ថា **គច្ឆ បណ្ឌិត ជានាហិ កេន ការណេន សោ ទុដ្ឋោ ជាតោ** នែបណ្ឌិត អ្នកចូរទៅ ចូរដឹងថា ដំរីនោះកាចព្រោះហេតុអ្វី ?

ព្រះពោធិសត្វទៅហើយដឹងថា ដំរីនោះមិនមានរោគ ក៏គិតថាព្រោះហេតុអ្វីហ្ន៎ ទើបដំរីនេះ ក្លាយជាដំរីកាច ? កាលពិចារណាទៅក៏សន្និដ្ឋានថា ដំរីនេះ បានស្តាប់ពាក្យរបស់បុគ្គលណាមួយក្នុងមិនឆ្ងាយហើយសម្គាល់ថា មនុស្សទាំងនេះឲ្យអាត្មាអញសិក្សា ទើបក្លាយជាដំរីកាចបែបនេះ ។ ព្រះពោធិសត្វសួរពួកអ្នកចិញ្ចឹមដំរីថា មានបុគ្គលណាមួយ ពោលពាក្យណាមួយក្នុងពេលរាត្រី ក្នុងទីជិតដំរីដែរឬទេ ?

ពួកអ្នកចិញ្ចឹមដំរីពោលថា បពិត្រលោកម្ចាស់ ពួកចោរនាំគ្នាមក

ពោល ។ ព្រះបរមពោធិសត្វក៏ក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ការពិការមិនមានក្នុងរាងកាយនៃដំរីរបស់ព្រះអង្គទេ ដំរីនោះកាច ព្រោះបានស្តាប់ពាក្យរបស់ពួកចោរទេតើ ។

ព្រះរាជាត្រាស់សួរថា ឥឡូវនេះ តើយើងគួរធ្វើដូចម្តេច?

ព្រះពោធិសត្វក្រាបទូលថា មានតែនិមន្តសមណព្រាហ្មណ៍ដែលជាអ្នកមានសីលឲ្យអង្គុយក្បែររោងដំរី ហើយពោលដល់សីលនិងអាចារៈទើបគួរ ។

ព្រះរាជាត្រាស់ថា ចូរធ្វើយ៉ាងនោះចុះ ។

ព្រះបរមពោធិសត្វក៏និមន្តសមណព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកមានសីល ឲ្យអង្គុយក្បែររោងដំរី ហើយពោលថា **សីលកថំ កថេថ ភន្តេ** បពិត្រលោកដ៏ចម្រើន សូមលោកទាំងឡាយ ពោលអំពីសីលកថា ។ សមណព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីមិនឆ្ងាយអំពីដំរី នាំគ្នាពោលអំពីសីលកថាថា មិនគប្បីបោសអង្អែល ( ដោយទិដ្ឋិ ) មិនគប្បីសម្លាប់នូវបុគ្គលណាមួយ គួរជាអ្នកដល់ព្រមដោយសីលនិងអាចារៈ គួរជាអ្នកប្រកបដោយខន្តី មេត្តា និងករុណា ។ ដំរីនោះ បានស្តាប់ដូច្នោះហើយ គិតថា សមណព្រាហ្មណ៍ទាំងនេះឲ្យអញសិក្សា ចាប់តាំងអំពីពេលនេះទៅ អាត្មាអញគួរជាអ្នកមានសីល ហើយតាំងនៅក្នុងសីលដូចមុនវិញ ។

ព្រះរាជាត្រាស់សួរព្រះបរមពោធិសត្វថា តើដំរីនោះ មានសីលហើយឬ ?

ព្រះមហាបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព ដំរីនោះ មានសីលហើយ ។

ព្រះរាជាត្រាស់ថា ដំរីកាចមានសភាពបែបនេះ ព្រោះអាស្រ័យបណ្ឌិតទាំងឡាយ ទើបតាំងនៅក្នុងធម៌ដែលជារបស់បុរាណ ហើយបានពោលគាថានេះថា

**បុរាណចោរាន វចោ និសម្ម**
**មហិឡាមុខោ ចោថយមានុចារិ**
**សុសញ្ញតានំ ហិ វចោ និសម្ម**
**គជុត្តមោ សព្វគុណេសុ អដ្ឋាតិ ។**

ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ ( ហ្មដំរី)
លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ
ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។

បណ្តាបទទាំងនោះ បទថា **បុរាណចោរាន** បានដល់ ពួកចោរសម័យបុរាណ ។

បទថា **និសម្ម** បានដល់ ព្រោះស្តាប់ អធិប្បាយថា ព្រោះបាន

ស្តាប់ពាក្យរបស់ពួកចោរមុន ។

បទថា **មហិឡាមុខោ** ប្រែថា មានមុខដូចគ្នានឹងដំរីញី ម្យ៉ាងទៀត ដំរីញី កាលសម្លឹងមើលចំពីមុខទើបស្អាត មើលអំពីក្រោយមិនស្អាតយ៉ាងណា ដំរីនោះក៏ដូច្នោះ កាលសម្លឹងមើលខាងមុខ ទើបស្អាត ព្រោះដូច្នោះ ទើបជនទាំងឡាយដាក់ឈ្មោះដំរីនោះថា មហិឡាមុខៈ ។

បទថា **ចោជយមានុចារិ** សេចក្តីថា ដេញតាមបោក គឺសម្លាប់ ម្យ៉ាងទៀត ព្រះបាលីក៏យ៉ាងនេះឯង ។

បទថា **សុសញ្ញតានំ** បានដល់ ជាអ្នកសង្រួមដោយល្អ គឺមានសីល ។

បទថា **គជុត្តមោ** បានដល់ ដំរីដ៏ឧត្តម គឺដំរីមង្គល ។

បទថា **សព្វគុណេសុ អដ្ឋ** បានដល់ តាំងនៅចំពោះក្នុងគុណធម៌អំពីបុរាណទាំងពួង ។

ព្រះរាជា ទ្រង់ព្រះតម្រិះថា អាមាត្យនេះដឹងអធ្យាស្រ័យ សូម្បីសត្វតិរច្ឆានទាំងឡាយ ទើបទ្រង់ព្រះរាជទានយសធំដល់ព្រះពោធិសត្វ ។

ព្រះរាជានោះ ទ្រង់គង់នៅដរាបដល់អស់ព្រះជន្ម លុះអស់ព្រះជន្មាយុហើយក៏ទៅតាមយថាកម្ម ឯព្រះពោធិសត្វក៏ដូចគ្នា ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុ សូម្បីក្នុងកាលមុនអ្នកក៏គប់រកបុគ្គលដែលគ្រាន់តែឃើញហើយដូចគ្នា ព្រោះបានស្តាប់ពាក្យរបស់

ចោរ ក៏មានចិត្តដូចចោរ លុះបានស្តាប់ពាក្យរបស់សមណព្រាហ្មណ៍ ដែលជាអ្នកតាំងនៅក្នុងធម៌ ទើបគប់រកបុគ្គលដែលតាំងនៅក្នុងធម៌ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង ហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ដំរីមហិឡាមុខៈ ក្នុងកាលនោះ បានមកជាភិក្ខុដែលសេពគប់ខុសក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាល នោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកអាមាត្យដែលជា បណ្ឌិតក្នុងកាលនោះ គឺ **តថាគតអរហន្តសម្មាសម្ពុទ្ធ** នេះឯង ៕

ចប់ អដ្ឋកថា មហិឡាមុខជាតក ទី ៦ ។

# អដ្ឋកថា អភិណ្ហជាតក ទី ៧

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ឧបាសកម្នាក់និងព្រះថេរៈចាស់មួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **នាលំ កពលំ បទាតវេ** ដូច្នេះជាដើម ។

បានឮថា ក្នុងនគរសាវត្ថីមានសម្លាញ់ពីរនាក់ បណ្តាសម្លាញ់ ទាំងពីរនោះ ម្នាក់បួសហើយបានទៅកាន់ផ្ទះរបស់សម្លាញ់ដែលជាគ្រ-ហស្ថរាល់ថ្ងៃ សម្លាញ់ម្នាក់នោះ ក៏ប្រគេនភិក្ខាដល់ភិក្ខុដែលជាសម្លាញ់ នោះ ខ្លួនឯងបរិភោគជាក្រោយ ហើយទៅកាន់វិហារជាមួយភិក្ខុដែលជា

សម្លាញ់នោះឯង សន្ទនាប្រាស្រ័យគ្នាដរាបដល់ព្រះអាទិត្យអស្តង្គត ទើបត្រឡប់មកចូលនគរវិញ ។ ចំណែកសម្លាញ់ដែលជាភិក្ខុ ជូនសម្លាញ់នោះទៅដល់ទ្វារនគរហើយ ក៏ត្រឡប់ ការស្និទ្ធស្នាលគ្នារបស់សម្លាញ់ទាំងពីរនោះ ក៏កើតប្រាកដក្នុងរវាងភិក្ខុទាំងឡាយ ។

ថ្ងៃមួយ ភិក្ខុទាំងឡាយអង្គុយពោលដល់ការស្និទ្ធស្នាលរបស់សម្លាញ់ទាំងពីរនោះ ក្នុងរោងធម្មសភា ។ ព្រះបរមសាស្តា ទ្រង់យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយសន្ទនាគ្នា ដោយកថាឈ្មោះនេះ ដោយកថាឈ្មោះនេះ ។

ព្រះបរមសាស្តា ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ទាំងពីរនេះ ជាអ្នកស្និទ្ធស្នាលនឹងគ្នាតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកស្និទ្ធស្នាលនឹងគ្នាដូចគ្នា ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វបានជាអាមាត្យរបស់ព្រះបាទព្រហ្មទត្តអង្គនោះ ។ ក្នុងកាលនោះ សុនខមួយបានទៅកាន់រោងដំរីមង្គល ស៊ីគ្រាប់បាយដែលជាកត្ត ដែលដំរីមង្គលបរិភោគហើយ

*សុនខនោះធំធាត់ដោយភោជននោះឯង ទើបកើតនូវការស្និទ្ធស្នាលជាមួយដំរីមង្គល បរិភោគនៅក្នុងសម្នាក់របស់ដំរីមង្គលនោះឯង សត្វទាំងពីរមិនអាចប្រាសចាកគ្នានឹងគ្នាបាន ដំរីយកប្រមោយចាប់សុនខនោះប្រមៀលទៅមក ហើយលើកឡើងដាក់លើក្បាល ។ ថ្ងៃមួយ មនុស្សអ្នកជនបទម្នាក់ឲ្យតម្លៃដល់អ្នកចិញ្ចឹមដំរី ហើយចាប់យកកូនឆ្កែនោះទៅផ្ទះរបស់ខ្លួន តាំងអំពីពេលនោះមក ដំរីកាលមិនឃើញកូនឆ្កែក៏មិនបរិភោគ មិនផឹក មិនងូត ពួកអ្នកចិញ្ចឹមដំរីក៏ក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជា ទ្រង់បញ្ជូនព្រះបរមពោធិសត្វទៅដោយព្រះតម្រាស់ថា នែបណ្ឌិត ចូរអ្នកទៅ ចូរដឹងថា ព្រោះហេតុអ្វីទើបដំរីធ្វើយ៉ាងនោះ ? ព្រះពោធិសត្វទៅកាន់រោងដំរីដឹងថា ដំរីទោមនស្ស ខូចចិត្ត ទើបគិតថា រោគមិនប្រាកដក្នុងរាងកាយរបស់ដំរីនេះ ការស្និទ្ធស្នាលក្នុងឋានៈជាមិត្តជាមួយបុគ្គលណាមួយគប្បីមានដល់ដំរីនេះ ដំរីនេះ ប្រហែលជាមិនឃើញមិត្តនោះ ទើបត្រូវសេចក្តីសោកគ្របសង្កត់ កាលគិតហើយក៏សួរជនអ្នកចិញ្ចឹមដំរីថា* **អត្ថិ នុ ខោ ឥមស្ស កេនចិ សទ្ធឹ វិស្សាសោ** *នៃអ្នកទាំងឡាយ ការស្និទ្ធស្នាលនឹងបុគ្គលណាមួយរបស់ដំរីនេះ មានដែរឬទេ ?*

*ពួកអ្នកចិញ្ចឹមដំរីពោលថា* **អាម អត្ថិ សាមិ ឯកេន សុនខេន សទ្ធឹ ពលវា មេត្តិ** *បពិត្រលោកម្ចាស់ ដំរីនេះស្និទ្ធស្នាលដ៏ក្រៃលែងជា*

មួយសុនខមួយ ។

ព្រះពោធិសត្វសួរថា **កហំ សោ ឯតរហិ** ឥឡូវនេះ សុនខនោះ នៅឯណា ?

ពួកអ្នកចិញ្ចឹមដំរីឆ្លើយថា **ឯកេន មនុស្សេន នីតោ** ត្រូវមនុស្សម្នាក់នាំយកទៅហើយ ។

ព្រះពោធិសត្វសួរថា ចុះទីលំនៅរបស់មនុស្សនោះ ពួកអ្នកស្គាល់ដែរឬទេ ?

ពួកអ្នកចិញ្ចឹមដំរីពោលថា ខ្ញុំមិនស្គាល់ទេ ។ ព្រះមហាសត្វបានទៅកាន់សម្នាក់របស់ព្រះរាជាហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព អាពាធ ឬជំងឺដម្កាត់ណាមួយ មិនមានដល់ដំរីនេះទេ តែដំរីនេះមានសេចក្ដីស្និទ្ធស្នាលជាមួយសុនខមួយក្បាល ដំរីនេះប្រហែលជាមិនឃើញសុនខនោះ ទើបមិនបរិភោគ ហើយពោលគាថានេះថា

**នាលំ កពលំ បទាតវេ**

**ន បិណ្ឌំ ន កុសេ ន ឃំសិតុំ**

**មញ្ញាមិ អភិណ្ហទស្សនា**

**នាគោ សិនេហមកាសិ កុក្កុរេតិ ។**

(ដំរី) មិនអាចកាន់យកនូវពំនូតបាយ មិនអាចកាន់យកនូវដុំបាយ មិនអាចកាន់យកនូវស្មៅទាំងឡាយ មិនអាច

ត្រដុស (សរីរៈ) ទេ ខ្ញុំសម្គាល់ថាដំរីបានធ្វើសេចក្ដីស្រឡាញ់ស្មោះចំពោះឆ្កែ ព្រោះការឃើញរឿយៗ ។

បណ្ដាបទទាំងនោះ បទថា **ជាលំ** ប្រែថា មិនអាច ។

បទថា **កពលំ** បានដល់ ដុំបាយដែលឲ្យចំពោះដំបូងក្នុងវេលាបរិភោគ ។

បទថា **បជាតវេ** ប្រែថា ដើម្បីទទួលយក គប្បីជ្រាបការលុប **អា** អក្ខរៈទាក់ទងដោយវិធីសន្ធិ គឺការភ្ជាប់សព្ទ អធិប្បាយថា ដើម្បីកាន់យក ។

បទថា **ន បិណ្ឌំ** បានដល់ មិនអាចដើម្បីទទួលយកដុំភត្តដែលគេពូតឲ្យ ។

បទថា **ន កុសេ** បានដល់ មិនអាចទទួលយកសូម្បីត្រឹមតែស្មៅទាំងឡាយដែលគេឲ្យបរិភោគ ។

បទថា **ន ឃំសិតុំ** សេចក្ដីថា ឲ្យងូតក៏មិនអាចនឹងដុសសម្អាតរាងកាយ ។

ព្រះបរមពោធិសត្វក្រាបទូលដល់ព្រះរាជា ដល់ហេតុទាំងពួងថា ដំរីនោះមិនអាចធ្វើ ដោយហេតុយ៉ាងនេះហើយ ទើបក្រាបទូលដល់ហេតុដែលខ្លួនកំណត់ ហើយក្រាបទូលពាក្យជាដើមថា **មញ្ញាមិ** ប្រែថា ទូលបង្គំសម្គាល់ថា ដូច្នេះ ។

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ទើបត្រាស់សួរថា នែបណ្ឌិត ឥឡូវនេះ យើងគួរធ្វើដូចម្តេច ?

ព្រះបរមពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព បានឮថា មនុស្សម្នាក់នាំយកសុនខ ដែលជាសម្លាញ់របស់ដំរីមង្គលនោះទៅហើយ សូមទ្រង់ឲ្យមនុស្សត្រាច់វាយស្គរប្រកាសថា ជនទាំងឡាយឃើញឆ្កែនោះក្នុងផ្ទះរបស់អ្នកណា អ្នកនោះនឹងត្រូវពិន័យទ្រព្យឈ្មោះនេះ ដូច្នេះ ។ ព្រះរាជាទ្រង់ឲ្យធ្វើយ៉ាងនោះ បុរសនោះ បានស្តាប់សេចក្តីប្រកាសនោះហើយមានការភ័យខ្លាច ក៏លែងសុនខនោះ សុនខកាលរួចខ្លួនហើយ ក៏ប្រញាប់ប្រញាល់រត់ទៅកាន់សម្នាក់ដំរីនោះ ។ ដំរីយកប្រមោយចាប់សុនខនោះដាក់លើក្បាល កន្ទក់កន្ទេញហើយទើបដាក់ចុះអំពីក្បាលមកវិញ កាលសុនខនោះបរិភោគហើយ ទើបខ្លួនបរិភោគជាក្រោយ ។ ព្រះរាជា ទ្រង់ព្រះតម្រិះថា អាមាត្យនេះ ដឹងអធ្យាស្រ័យរបស់សត្វតិរច្ឆាន ទើបប្រទានយសធំដល់ព្រះពោធិសត្វ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជនទាំងពីររូបនេះ ជាអ្នកស្និទ្ធស្នាលនឹងគ្នាតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកស្និទ្ធស្នាលហើយដូចគ្នាដែរ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្តូរធម្មកថាមកប្រកាសអរិយសច្ច:៤ ទ្រង់បន្តអនុសន្ធិហើយ

ប្រជុំជាតក ឈ្មោះថា ការប្តូរមកសម្តែងដោយសច្ចៈ ៤ នេះ រមែងមាន គ្រប់ជាតកនោះឯង តែយើងនឹងសម្តែងការប្តូរមកសម្តែងកថាដោយ អរិយសច្ចៈ ៤ ចំពោះក្នុងជាតកណា ដែលប្រាកដអានិសង្សដល់បុគ្គល នោះៗ ប៉ុណ្ណោះ ។ សុនខក្នុងកាលនោះ បានមកជាឧបាសកក្នុងកាល ឥឡូវនេះ ដំរីក្នុងកាលនោះ បានមកជាព្រះថេរៈចាស់ក្នុងកាលឥឡូវនេះ ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែក អាមាត្យដែលជាបណ្ឌិត គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា អភិណ្ហជាតក ទី ៧ ។

# អដ្ឋកថា នន្ទិវិសាលជាតក ទី ៨

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធ ពាក្យពោលគ្រោតគ្រាត ពាក្យពោលបញ្ឈឺចិត្តរបស់ពួកឆព្វគ្គិយភិក្ខុ ទើប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មនុញ្ញមេវ ភាសេយ្យ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា សម័យនោះ ពួកឆព្វគ្គិយភិក្ខុបង្កនូវជម្លោះ គំ-រាមកំហែង ចាក់ដោត ជេរប្រទេចភិក្ខុទាំងឡាយ ដោយពាក្យសម្រាប់ ជេរ ១០ ប្រការ ភិក្ខុទាំងឡាយក៏ក្រាបទូលព្រះមានព្រះភាគ ទើបព្រះ

សាស្តា ទ្រង់ឲ្យហៅឆព្វគ្គិយភិក្ខុនោះមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ពួកអ្នកបង្កនូវជម្លោះ ពិតឬ ? កាលពួកឆព្វគ្គិយ-ភិក្ខុក្រាបទូលថា ករុណាព្រះអង្គ ទើបទ្រង់តិះដៀលហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា វាចាគ្រោតគ្រាត នាំមកនូវសេចក្តីវិនាស មិនជាទីស្រឡាញ់ សូម្បីតែសត្វតិរច្ឆាន ក្នុងកាលមុនសត្វតិរច្ឆានមួយរមែងញុំាងបុគ្គលដែលហៅខ្លួនដោយពាក្យគ្រោតគ្រាត ឲ្យចាញ់ភ្នាល់អស់ ១ ពាន់ ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល មានព្រះរាជាមួយព្រះអង្គព្រះនាមថា គន្ធារៈ គ្រងរាជសម្បត្តិក្នុងតក្កសិលានគរ ដែនគន្ធារៈ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងកំណើតគោ ។ ក្នុងកាលដែលព្រះពោធិសត្វនៅជាកូនគោនោះ ព្រាហ្មណ៍ម្នាក់ បានព្រះពោធិសត្វអំពីសម្នាក់របស់ទាយកអ្នកឲ្យទក្ខិណា ទើបដាក់ឈ្មោះគោនោះថា នន្ទិវិសាល ហើយតាំងទុកក្នុងឋានៈជាកូនដោយសេចក្តីស្រឡាញ់ច្រើន ឲ្យបបរនិងភត្តជាដើម ចិញ្ចឹមរក្សាហើយ ។ ព្រះពោធិសត្វចម្រើនវ័យហើយ គិតថា ព្រាហ្មណ៍នេះ ប្រតិបត្តិអញដោយលំបាក ឈ្មោះថា គោដទៃដែលមានធុរៈស្មើដូចអាត្មាអញ រមែងមិនមានក្នុងជម្ពូទ្វីបទាំងមូល បើដូច្នោះ អញគប្បីបង្ហាញកម្លាំងរបស់ខ្លួនហើយឲ្យថ្លៃចិញ្ចឹមដល់ព្រាហ្មណ៍ ។ ថ្ងៃមួយ ព្រះពោធិសត្វពោលនឹងព្រាហ្មណ៍នោះថា បពិត្រព្រាហ្មណ៍ សូមលោកទៅរកគោវិន្ទកសេដ្ឋីនោះ

ហើយពោលថា គោរបស់ខ្ញុំអាចញ៉ាំងរទេះ ១០០ ដែលចងជាប់គ្នាឲ្យទៅមុខបាន ហើយចូរដាក់ប្រាក់ ១ ពាន់កហាបណៈភ្នាល់ជាមួយសេដ្ឋីនោះចុះ ។ ព្រាហ្មណ៍នោះក៏ទៅកាន់សម្នាក់របស់សេដ្ឋីសន្ធនាថា ក្នុងនគរនេះ តើគោអ្នកណាជល់ព្រមដោយកម្លាំង ?

លំដាប់នោះ សេដ្ឋីក៏ពោលនឹងព្រាហ្មណ៍នោះថា គោឈ្មោះនោះនិងគោឈ្មោះនោះ ហើយពោលបន្តថា ទូទាំងនគរ ឈ្មោះថាគោទាំងឡាយដែលស្មើនឹងគោរបស់ខ្ញុំមិនមានទេ ។

ព្រាហ្មណ៍ពោលថា ឯគោរបស់ខ្ញុំទើបជាគោខ្លាំង អាចអូសរទេះ ១០០ ដែលចងជាប់គ្នាឲ្យកម្រើកបាន ។

សេដ្ឋីពោលថា នែគហបតី គោបែបនេះនឹងមានមកអំពីណា ?

ព្រាហ្មណ៍ពោលថា មាន ក្នុងផ្ទះរបស់ខ្ញុំ ។

សេដ្ឋីពោលថា បើយ៉ាងនោះ អ្នកហ៊ានភ្នាល់នឹងខ្ញុំដែរឬទេ ?

ព្រាហ្មណ៍ពោលថា ខ្ញុំភ្នាល់ ហើយបានដាក់ប្រាក់ ១ ពាន់កហាបណៈ ។ ព្រាហ្មណ៍នោះ ក៏ញ៉ាំងរទេះ ១០០ ឲ្យពេញដោយខ្សាច់ ក្រួសនិងថ្មជាដើម តម្រៀបគ្នាតាមលំដាប់ ហើយចងដោយខ្សែសម្រាប់ចងហើយឲ្យគោនន្ទិវិសាលនោះផ្ទួតទឹក ប្រោះដោយគ្រឿងក្រអូប ប្រដាប់នូវកម្រងផ្កាត្រង់ក ហើយទឹមគោតែមួយប៉ុណ្ណោះ ត្រង់នឹមម្ខាងទៀត ខ្លួនឯងអង្គុយលើទូករទេះ ងាជន្លួញឡើងពោលថា នែអាគោកោង នែអា

គោកៀច ចូរអូសទៅ ចូរនាំទៅ ។ ព្រះពោធិសត្វគិតថា ព្រាហ្មណ៍នេះហៅអញដែលជាបុគ្គលមិនកៀចថា គោកៀច ទើបឈរជើងទាំង ៤ នៅស្ងៀមដូចសសរ ។ ខណៈនោះឯង គោវិន្ទកសេដ្ឋីក៏ឲ្យព្រាហ្មណ៍នោះនាំទ្រព្យ ១ ពាន់កហាបណៈមក ។ ព្រាហ្មណ៍ចាញ់ភ្នាល់ដោយទ្រព្យ ១ ពាន់កហាបណៈ ទើបដោះគោហើយទៅផ្ទះរបស់ខ្លួន ត្រូវសេចក្ដីសោកគ្របសង្កត់ក៏ដេកមួយកន្លែង គោនន្ទិវិសាលត្រាច់ទៅហើយត្រឡប់មកឃើញព្រាហ្មណ៍ត្រូវសេចក្ដីសោកគ្របសង្កត់ ក៏ចូលទៅរកហើយពោលថា **កឹ ព្រាហ្មណ និទ្ទាយសិ** បពិត្រព្រាហ្មណ៍ លោកដេកលក់ហើយឬ ?

ព្រាហ្មណ៍ពោលថា **កុតោ មេ និទ្ទា សហស្សបរាជិតស្ស** ខ្ញុំចាញ់ភ្នាល់អស់ប្រាក់ ១ ពាន់កហាបណៈ តើនឹងដេកលក់មកអំពីណា ?

ព្រះពោធិសត្វពោលថា បពិត្រព្រាហ្មណ៍ ខ្ញុំនៅក្នុងផ្ទះរបស់លោកអស់កាលមានប្រមាណប៉ុណ្ណេះ ធ្លាប់ធ្វើភាជនៈណាមួយឲ្យបែកធ្លាប់ជាន់អ្នកណាៗ ឬធ្លាប់បន្ទោបង់ឧច្ចារៈបស្សាវៈ ក្នុងទីដែលមិនសមគួរដែរឬ ?

ព្រាហ្មណ៍ពោលថា មិនមានទេ ។ លំដាប់នោះ គោនន្ទិវិសាលក៏ពោលថា បើដូច្នោះ ព្រោះហេតុអ្វីទើបលោកហៅខ្ញុំដោយពាក្យថាអាគោកៀច នុ៎ះជាទោសរបស់លោកប៉ុណ្ណោះ មិនមែនជាទោសរបស់ខ្ញុំ

ទ្បើយ សូមលោកទៅកាន់សម្នាក់របស់សេដ្ឋី ហើយភ្នាល់ដោយទ្រព្យ ២ ពាន់កហាបណៈ ហើយសូមលោកកុំហៅខ្ញុំដែលជាគោមិនកៀច ដោយពាក្យថា អាគោកៀចឡើយ ។ ព្រាហ្មណ៍បានស្តាប់ពាក្យរបស់គោនន្ទិវិសាលហើយ ក៏ទៅកាន់សម្នាក់របស់សេដ្ឋី ហើយភ្នាល់ដោយទ្រព្យ ២ ពាន់កហាបណៈ ចងរទេះ ១០០ ជាប់តគ្នា ដោយន័យមុននោះឯង ប្រដាប់គោនន្ទិវិសាលហើយទឹមក្នុងរទេះទី ១ ។

សួរថា តើទឹមដូចម្តេច ?

ឆ្លើយថា ព្រាហ្មណ៍ទឹមគោនន្ទិវិសាលត្រង់នឹមម្ខាង ហើយចងនឹមម្ខាងទៀតដោយខ្សែជាប់នឹងទូក កាលបើចងខ្សែជាប់នឹងទូក នឹមក៏មិនកម្រើក កាលបើចងយ៉ាងនេះ នឹមមិនអាចកម្រើកទៅខាងនេះនិងខាងនោះ គោតែមួយប៉ុណ្ណោះក៏អាចអូសបាន ។ លំដាប់នោះ ព្រាហ្មណ៍អង្គុយលើទូករទេះ ស្ទាបខ្នងគោនន្ទិវិសាលថ្នមៗ ហើយពោលថា គោដ៏ចម្រើន ចូរបាអូសទៅ គោដ៏ចម្រើន ចូរបាទាញទៅ ។ ព្រះមហាសត្វអូសរទេះ ១០០ ដែលចងជាប់តគ្នា ដោយកម្លាំងតែម្តងប៉ុណ្ណោះ ធ្វើឲ្យរទេះដែលនៅក្រោយគេមកនៅត្រង់ទីដែលរទេះខាងមុខចត ។ គោវិន្ទកសេដ្ឋីចាញ់ហើយដោយទ្រព្យ ២ ពាន់កហាបណៈ ក៏បានឲ្យប្រាក់ ២ ពាន់កហាបណៈដល់ព្រាហ្មណ៍ មនុស្សដទៃក៏បានឲ្យទ្រព្យជាច្រើនដល់ព្រះពោធិសត្វ ទ្រព្យទាំងអស់នោះបានជារបស់ព្រាហ្មណ៍នោះឯង ព្រាហ្មណ៍

អាស្រ័យព្រះពោធិសត្វ ទើបបានទ្រព្យជាច្រើនដោយប្រការដូច្នេះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា ពាក្យគ្រោតគ្រាត មិនជាទីពេញចិត្តរបស់បុគ្គលណាឡើយ ហើយទ្រង់តិះដៀលឆព្វគ្គិយភិក្ខុ ហើយទ្រង់បញ្ញត្តសិក្ខាបទ កាលទ្រង់ត្រាស់ដឹងហើយ ទើបត្រាស់ព្រះគាថានេះថា

**មនុញ្ញមេវ ភាសេយ្យ  នាមនុញ្ញំ កុទាចនំ**
**មនុញ្ញំ ភាសមានស្ស  គរុភារំ ឧទទ្ធរិ**
**ធនញ្ច នំ អលាភេសិ  តេន ចត្តមនោ អហូតិ ។**

បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយពាក្យជាទីគាប់ចិត្ត (គោនន្ទិវិសាល) បានទាញភារៈដ៏ធ្ងន់រួច ញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយដោយការញុំាងព្រាហ្មណ៍នោះ ឲ្យបានទ្រព្យនោះផង ។

បណ្តាបទទាំងនោះ បទថា **មនុញ្ញមេវ ភាសេយ្យ** សេចក្តីថា បុគ្គល កាលពោលជាមួយអ្នកដទៃ គប្បីពោលចំពោះបិយវាចា គឺវាចាផ្អែមល្ហែមជាទីពេញចិត្ត វៀរចាកទោស ៤ ប្រការ ។

បទថា **គរុភារំ ឧទទ្ធរិ** សេចក្តីថា គោនន្ទិវិសាល កាលព្រាហ្មណ៍ពោលពាក្យមិនជាទីគាប់ចិត្ត ក៏មិនអូសភារៈ កាលព្រាហ្មណ៍ពោលពាក្យ

ជាទីស្រឡាញ់ ជាទីពេញចិត្តក្នុងពេលខាងក្រោយ ក៏អួសការៈជូនឲ្យដល់ទីបំផុត ឯ ឩ អក្ខរៈក្នុងបទថា **ឧឩទ្ធរិ** នោះ ក្នុងគាថានេះ ជាអក្ខរៈធ្វើនូវការភ្ជាប់បទ ដោយការភ្ជាប់នូវព្យញ្ជនៈនោះឯង ។

ព្រះបរមសាស្តា កាលទ្រង់នាំព្រះធម្មទេសនានេះមកថា **មនុញ្ញមេវ ភាសេយ្យ** ដោយប្រការដូច្នេះហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ព្រាហ្មណ៍ក្នុងកាលនោះ បានមកជាអានន្ទ ចំណែកគោនន្ទិវិសាល គឺ **តថាគតអរហន្តសម្មាសម្ពុទ្ធ** នេះឯង ៕

ចប់ អដ្ឋកថា នន្ទិវិសាលជាតក ទី ៨ ។

# អដ្ឋកថា កណ្ហជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធយមកប្បាដិហារិយ៍ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យតោ យតោ គរុ ធុរំ** ដូច្នេះជាដើម ។

យមកប្បាដិហារិយ៍នោះ មួយអន្លើដោយការយាងចុះអំពីទេវលោក នឹងជាក់ច្បាស់ក្នុង **សរភមិគជាតក** [១] **តេរសកនិបាត** ឯណោះ ។

---

១- បិដកខ្មែរជា សរភជាតក ។

កាលព្រះសម្មាសម្ពុទ្ធទ្រង់ធ្វើយមកប្បាដិហារិយ៍ហើយ ទ្រង់ក៏យាងទៅកាន់ទេវលោក ក្នុងថ្ងៃមហាបវារណា ទ្រង់ក៏យាងចុះមកត្រង់ទ្វារនគរសង្កស្ស ហើយទ្រង់ចូលទៅកាន់វត្តជេតពនមហាវិហារ មួយអន្លើដោយបរិវារធំ ។ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងធម្មសភា អង្គុយពោលដល់គុណរបស់ព្រះសាស្តាថា អាវុសោទាំងឡាយ ឈ្មោះថា ព្រះតថាគតមានធុរៈមិនមានបុគ្គលស្មើ បុគ្គលដទៃ ឈ្មោះថាអាចដើម្បីនាំធុរៈដែលព្រះតថាគតនាំទៅហើយ រមែងមិនមាន គ្រូទាំង ៦ ពោលថា ពួកយើងប៉ុណ្ណោះនឹងធ្វើបាដិហារិយ៍ ពួកយើងប៉ុណ្ណោះនឹងធ្វើបាដិហារិយ៍ សូម្បីបាដិហារិយ៍តែមួយក៏ធ្វើមិនបាន គួរអស្ចារ្យព្រះទសពល ទ្រង់មានធុរៈមិនមានបុគ្គលស្មើ ។ ព្រះបរមសាស្តា ទ្រង់យាងមកកាន់រោងធម្មសភា ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាគ្នាដោយរឿងដទៃ ក៏មិនមែន ពួកខ្ញុំព្រះអង្គអង្គុយសន្ទនាដោយរឿងព្រះគុណរបស់ព្រះអង្គ ដែលមានសភាពបែបនេះ បែបនេះ ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយនឹងនាំទៅនូវធុរៈដែលតថាគតនាំទៅហើយមិនបាន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន កាលតថាគតកើតក្នុងកំណើត

សត្វតិរច្ឆាន ក៏មិនមានបុគ្គលណាដែលអាចនាំធុរៈស្មើនឹងតថាគតដែរ ហើយទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វបដិសន្ធិក្នុងកំណើតគោ ។ គ្រានោះ កាលព្រះមហាសត្វនៅតូចនោះឯង ម្ចាស់គោទាំងឡាយស្នាក់នៅក្នុងផ្ទះរបស់ស្រីជរាម្នាក់ កំណត់តម្លៃជួលទីលំនៅស្នាក់អាស្រ័យ ទើបបានឲ្យកូនគោនោះ ( ទៅស្រីចាស់នោះ ជាតម្លៃជួលផ្ទះ ) ស្រីចាស់នោះ បដិបត្តិកូនគោនោះដោយបបរនិងកត្តជាដើម តាំងទុកក្នុងឋានៈជាបុត្ត ឲ្យកូនគោនោះធំចម្រើនហើយ កូនគោនោះប្រាកដឈ្មោះថា អយ្យិកាកាឡកៈ ។ គោនោះចម្រើនវ័យហើយ ជាអ្នកមានពណ៌ដូចផ្កាអញ្ចន់ ត្រាច់ទៅជាមួយគោស្រុក បានជាអ្នកដល់ព្រមដោយសីលនិងអាចារៈ ពួកក្មេងអ្នកស្រុកចាប់ត្រង់ស្នែងខ្លះ ចាប់ត្រង់ត្រចៀកខ្លះ ចាប់ត្រង់កខ្លះ ចាប់ត្រង់បូកខ្លះ ចាប់ត្រង់កន្ទុយខ្លះ ទាញមកខ្លះ អង្គុយលើខ្នងខ្លះ ។ ថ្ងៃមួយ គោនោះគិតថា **មយ្ហំ មាតា ទុគ្គតា មំ បុត្តដ្ឋានេ ឋបេត្វា ទុក្ខេន បោសេសិ យន្នូនាហំ ភតឹ កត្វា ឥមំ ទុគ្គតភាវតោ មោចេយ្យំ** ម្ដាយរបស់អញជាអ្នកក្រីក្រ តាំងអញទុកក្នុងឋានៈជាកូន ចិញ្ចឹមអាត្មាអញមកដោយសេចក្ដីលំបាក បើដូច្នោះ អញនឹងធ្វើការស៊ីឈ្នួលដើម្បីដោះនូវសេចក្ដីទុក្ខរបស់គាត់ ឲ្យផុតចាកអំពីភាពក្រីក្រ ។ ចាប់តាំងអំពី

ពេលនោះមក ព្រះមហាសត្វក៏ត្រាច់ដើម្បីរកស៊ីឈ្នួលអ្នកដទៃ ។

ថ្ងៃមួយ ឈ្មួញរទេះម្នាក់ មានរទេះ ៥០០ បរមកដល់កំពង់មួយ ដែលមិនរាបស្មើ គោទាំងឡាយរបស់ឈ្មួញរទេះនោះ មិនអាចអូសរទេះទាំងឡាយឡើងមកលើគោកបាន គោទាំង ៥០០ ដែលម្ចាស់យកនឹមមកទឹមតៗ គ្នា ក៏មិនអាចអូសរទេះសូម្បីតែមួយឲ្យឡើងមកបាន ។ ចំណែកព្រះពោធិសត្វនិងពួកគោស្រុក ត្រាច់ទៅក្នុងទីមិនឆ្ងាយអំពីកំពង់នោះ ។ ចំណែកកូនឈ្មួញរទេះក៏ជាអ្នកស្គាល់លក្ខណៈនៃគោ ខណៈនោះ ពិចារណាមើលថា ក្នុងរវាងគោទាំងនេះ គោឧសភជាអាជានេយ្យដែលអាចញុំាងរទេះទាំងនេះឲ្យឆ្លងផុត មានដែរឬហ្ន៎ បានឃើញព្រះពោធិសត្វ ក៏គិតថា នេះជាគោអាជានេយ្យ នឹងអាចអូសរទេះទាំងឡាយរបស់អញឲ្យឆ្លងភក់នេះបាន នរណាហ្ន៎ជាម្ចាស់របស់គោនេះ ទើបសួរពួកក្មេងចិញ្ចឹមគោថា នែអ្នកទាំងឡាយ អ្នកណាជាម្ចាស់គោនេះ ? ខ្ញុំនឹងទឹមគោនេះឲ្យអូសរទេះទាំងឡាយ កាលរទេះទាំងឡាយឆ្លងដល់លើគោកហើយ ខ្ញុំនឹងឲ្យថ្ងៃឈ្នួល ។

ពួកអ្នកចិញ្ចឹមគោទាំងនោះពោលថា លោកទាំងឡាយ ចូរចាប់គោនេះទឹមចុះ ដ្បិតម្ចាស់គោនេះ ក្នុងទីនេះមិនមាន ។ កូនរបស់ឈ្មួញរទេះនោះ ក៏យកខ្សែចងព្រះពោធិសត្វត្រង់ច្រមុះហើយទាញទៅ ប៉ុន្តែមិនអាចទាញឲ្យកម្រើកបាន ។ បានឮថា ព្រះពោធិសត្វមិនទៅដោយ

គិតថា បើប្រាប់តម្លៃអាត្មាអញ អញនឹងទៅ ។ កូនឈ្មួញរទេះនោះដឹងបំណងរបស់ព្រះពោធិសត្វ ទើបពោលថា នែអ្នក បើអ្នកអូសរទេះ ៥០០ របស់ខ្ញុំឡើងមកបាន ខ្ញុំនឹងឲ្យទ្រព្យក្នុងរទេះមួយ ២ កហាបណៈ ហើយនឹងឲ្យ ១ ពាន់កហាបណៈ ។ ក្នុងកាលនោះ ព្រះពោធិសត្វក៏ដើរទៅដោយខ្លួនឯង មនុស្សទាំងនោះ ក៏ទឹមព្រះពោធិសត្វត្រង់រទេះទាំងឡាយ ។ លំដាប់នោះ ព្រះពោធិសត្វអូសរទេះទាំងឡាយនោះឡើងដោយកម្លាំងរបស់ខ្លួនតែម្តងប៉ុណ្ណោះឲ្យតាំងនៅលើគោក ញុំាងរទេះទាំង ៥០០ ឲ្យផុតអំពីភក់ដោយឧបាយនេះ ។ ឈ្មួញរទេះគិតកហាបណៈ ១ ក្នុងរទេះមួយៗ បានធ្វើទ្រព្យ ៥០០ កហាបណៈឲ្យជាកញ្ចប់ ហើយចងទុកត្រង់ករបស់ព្រះពោធិសត្វ ។ ព្រះពោធិសត្វគិតថា ឈ្មួញរទេះនេះមិនឲ្យថ្លៃឈ្នួលតាមដែលកំណត់ទុក ឥឡូវនេះ អញនឹងមិនឲ្យឈ្មួញរទេះនេះទៅ ទើបឈរខាងមុខរទេះដែលនៅមុខគេនោះឯង មនុស្សទាំងឡាយព្យាយាមដើម្បីឲ្យព្រះមហាសត្វចៀសទៅ មិនអាចធ្វើឲ្យព្រះមហាសត្វចៀសចេញទៅបាន ។ បុត្តឈ្មួញរទេះគិតថា គោនេះប្រ-ហែលជាដឹងថាតម្លៃរបស់ខ្លួនមិនទាន់គ្រប់ ដ្បិតអញសន្យាថានឹងឲ្យ ២ កហាបណៈក្នុងរទេះមួយ ដូច្នេះហើយ ក៏ចងកហាបណៈ ១ ពាន់ត្រង់ក ដោយពោលថា នេះជាថ្លៃឈ្នួលដែលអ្នកអូសរទេះខ្ញុំឡើង ។ ព្រះពោធិសត្វក៏នាំយកកញ្ចប់ទ្រព្យ ១ ពាន់ទៅកាន់សម្នាក់ម្តាយ ។ ពួក

ក្មេងអ្នកស្រុកបានទៅកាន់សម្នាក់របស់ព្រះពោធិសត្វដោយគិតថា នេះជាអ្វីត្រង់កគោឈ្មោះអយ្យិកាកាឡកៈ ។ ព្រះពោធិសត្វនោះ ត្រូវក្មេងអ្នកស្រុកដើរតាម ទើបរត់ទៅកាន់សម្នាក់របស់ម្ដាយ ។ ក៏ព្រោះឲ្យរទេះ ៥០០ ឡើងមកលើគោក ទើបប្រាកដដូចជាហត់នឿយ មានភ្នែកទាំងពីរក្រហម ។ ដូនចាស់ឃើញថង់ទ្រព្យ ១ ពាន់ ត្រង់ករបស់ព្រះពោធិសត្វនោះហើយពោលថា នែបា អ្នកបានអ្វីមកអំពីណា ? ហើយសួរពួកក្មេងអ្នកស្រុក បានស្ដាប់សេចក្ដីនោះហើយ ទើបពោលថា **តាត កឹំ អហំ តយា លទ្ធភតិយា ជីវិតុកាមា កឹការណា ឯវរូបំ ទុក្ខំ អនុភោសិ** នែកូន យើងត្រូវការចិញ្ចឹមជីវិតដោយថ្លៃឈ្នួលដែលកូនបានមកឬ ព្រោះហេតុអ្វីទើបកូនសោយទុក្ខមានសភាពបែបនេះ ? ហើយក៏ឲ្យព្រះពោធិសត្វងូតទឹកក្ដៅ យកប្រេងមកលាបពេញរាងកាយ ឲ្យផឹកទឹក ឲ្យបរិភោគភោជនដែលជាទីសប្បាយ ។ ក្នុងវេលាអស់ជីវិតដូនចាស់ក៏ទៅតាមយថាកម្ម ចំណែកព្រះពោធិសត្វក៏ដូចគ្នា ។

ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកមានធុរៈមិនមានបុគ្គលស្មើតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកមានធុរៈមិនមានបុគ្គលដទៃស្មើដូចគ្នា ។ កាលទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បន្តអនុសន្ធិ កាលទ្រង់ត្រាស់ដឹងព្រមហើយ ទើបត្រាស់ព្រះគាថានេះថា

**យតោ យតោ គរុ ធុរំ យតោ គម្ភីរវត្តនិ**
**តទាស្សុ កណ្ហំ យុញ្ជន្តិ ស្វាស្សុ តំ វហតេ ធុរន្តិ ។**

*ធុរៈធ្ងន់ ក្នុងទីណាៗ ផ្លូវដ៏ជ្រៅក្នុងទីណា កាលនោះឯង ពួក ជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូស នូវធុរៈដ៏ធ្ងន់នោះទៅបាន ។*

*បណ្ដាបទទាំងនោះ បទថា* **យតោ យតោ គរុ ធុរំ** *សេចក្ដីថា ក្នុងទីណាមានធុរៈធ្ងន់ គឺក្នុងទីគ្រោតគ្រាត គោដទៃៗ មិនអាចអូសឡើង បាន ។*

*បទថា* **យតោ គម្ភីរវត្តនិ** *សេចក្ដីថា ឈ្មោះថា* **វត្តនិ** *ប្រែថា ផ្លូវ ព្រោះជាទីទៅរបស់មនុស្សទាំងឡាយ ពាក្យថា* **វត្តនិ** *នេះ ជាឈ្មោះ របស់ផ្លូវ អធិប្បាយថា ក្នុងទីណាមានផ្លូវឈ្មោះថាជ្រៅ ព្រោះមានទឹក និងភក់ច្រើន និងព្រោះភាពជាផ្លូវពុំរាបស្មើ ។*

*សព្ទថា* **អស្សុ** *ក្នុងបទថា* **តទាស្សុ កណ្ហំ យុញ្ជន្តិ** *នេះ ត្រឹមតែជានិបាត អធិប្បាយថា ក្នុងកាលនោះ ពួកជនរមែងទឹមគោខ្មៅ លោកពោលពាក្យអធិប្បាយទុកថា ក្នុងកាលណាមានធុរៈធ្ងន់ និងមាន ជង្ហុកជ្រៅ ក្នុងកាលនោះ ទើបពួកជនយកគោដទៃចេញទៅ ហើយទឹម គោខ្មៅប៉ុណ្ណោះ ។*

*សព្ទថា* **អស្សុ** *ក្នុងបទថា* **ស្វាស្សុ តំ វហតេ ធុរំ** *នេះ ក៏ត្រឹម*

*តែជានិបាតដូចគ្នា អធិប្បាយថា គោខ្មៅនោះ រមែងនាំធុរៈនោះទៅ ។*

*ព្រះមានព្រះភាគ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ គោខ្មៅប៉ុណ្ណោះ ( អាច ) នាំធុរៈទៅដូច្នេះ ដោយប្រការយ៉ាងនេះ ហើយទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ស្ត្រីចាស់ក្នុងកាលនោះ បានមកជាឧប្បលវណ្ណា ចំណែកគោអយ្យិកាកាឡកៈ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា កណ្ហជាតក ទី ៩ ។

# អដ្ឋកថា មុណិកជាតក ទី ១០

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ថុល្លកុមារី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **មា មុណិកស្ស** *ដូច្នេះជាដើម ។*

*រឿងការលួងលោមនោះ នឹងមានជាក់ច្បាស់ នៅក្នុង* **ចុល្លនារទ-កស្សបជាតក តេរសកនិបាត** *ឯណោះ ។*

*ព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកជាបុគ្គលអផ្សុក ពិតឬ ?*

*ភិក្ខុនោះក្រាបទូលថា ករុណា ព្រះអង្គ ។*

*ព្រះសាស្តាត្រាស់សួរថា ព្រោះអាស្រ័យអ្វី ?*

*ភិក្ខុនោះក្រាបទូលថា ព្រោះអាស្រ័យការលួងលោមរបស់ថុល្លកុមារី ព្រះអង្គ ។*

*ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុ ទារិកានោះ បានធ្វើសេចក្តីវិនាសដល់អ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ក្នុងថ្ងៃអាពាហ៍ពិពាហ៍របស់ទារិកានោះ អ្នកក៏ដល់នូវការអស់ជីវិតដល់នូវភាពជាសម្ងួឧត្តរិកង្គរបស់មហាជន ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វកើតក្នុងកំណើតគោ ក្នុងផ្ទះរបស់កុដុម្ពិកៈម្នាក់ក្នុងស្រុកមួយ មានឈ្មោះថា មហាលោហិត ចំណែកប្អូនប្រុសរបស់ព្រះពោធិសត្វមានឈ្មោះថា ចូឡលោហិត ធុរៈការងារក្នុងត្រកូលនោះ រមែងប្រព្រឹត្តទៅបានព្រោះអាស្រ័យគោទាំងពីរបងប្អូននោះឯង ។ ក្នុងត្រកូលនោះ មានទារិកាម្នាក់ បុរសអ្នកក្រុងម្នាក់បានសូម ( ស្តីដណ្តឹង ) ទារិកានោះដើម្បីកូនប្រុសរបស់ខ្លួន ។ មាតាបិតារបស់ទារិកានោះ បានឲ្យបបរនិងភត្ត ចិញ្ចឹមជ្រូកឈ្មោះមុណិកៈដោយបំណងថា នឹងធ្វើជាសម្ងួឧត្តរិកង្គដើម្បីភ្ញៀវទាំងឡាយ ក្នុងថ្ងៃអាពាហ៍ពិពាហ៍របស់ទារិកានោះ ។ គោឈ្មោះចូឡលោហិតឃើញដូច្នោះ ក៏សួរបងប្រុសថា ធុរៈការងារក្នុងត្រកូលនេះ កាលប្រព្រឹត្តទៅក៏ព្រោះអាស្រ័យយើងពីរនាក់បងប្អូន ទើប*

ប្រព្រឹត្តទៅបាន តែម្ចាស់របស់យើងឲ្យចំពោះតែស្មៅ និងស្មឹកឈើដល់ពួកយើង បែរជាប្រណិប័តន៍ជ្រូកដោយបបរនិងភត្ត ព្រោះហេតុអ្វីហ្ន៎ ទើបជ្រូកនោះ បានបបរនិងភត្តនោះ ? ខណៈនោះ គោដែលជាបងពោលចំពោះគោចូឡលោហិតជាប្អូនថា នែប្អូនចូឡលោហិត អ្នកកុំប្រ-ណែនភោជនរបស់ជ្រូកនោះឡើយ ជ្រូកនេះកំពុងបរិភោគភត្តដែលជាហេតុនៃសេចក្ដីស្លាប់ ក្នុងថ្ងៃអាពាហ៍ពិពាហ៍របស់កុមារិកា ជ្រូកនេះនឹងក្លាយជាសម្ភឧត្តរិកង្គសម្រាប់ភ្ញៀវដែលមក ព្រោះហេតុនោះ ទើបជនទាំងនេះបំប៉នជ្រូកនេះ ដោយកន្លងទៅពីរ-បីថ្ងៃបន្ទាប់អំពីនេះ ជនទាំងឡាយនឹងនាំគ្នាមក កាលបើយ៉ាងនោះ អ្នកនឹងបានឃើញជ្រូកនោះត្រូវចាប់ត្រង់ជើងទាំងឡាយ ទាញចេញមកអំពីក្រោមគ្រែ ត្រូវគេសម្លាប់ធ្វើជាសម្ភឧត្តរិកង្គដើម្បីភ្ញៀវទាំងឡាយ ហើយពោលគាថានេះថា

**មា មុណិកស្ស បិហយិ អាតុរន្នានិ ភុញ្ជតិ**
**អប្បោស្សុក្កោ[១] ភុសង្ខាទ ឯតំ ទីឃាយុលក្ខណន្តិ ។**

អ្នកកុំចូលចិត្ត ( ភោជន ) របស់ជ្រូកឈ្មោះមុណិកៈ ( ព្រោះ ) ជ្រូកមុណិកៈ ស៊ីភោជនក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់-ខ្វាយតិច ហើយស៊ីតែចំបើងចុះ នេះជាលក្ខណៈនៃអាយុវែង ។

---

១- ច្បាប់មហាចុឡាជា អប្បោស្សុក្កោ ។

*បណ្ដាបទទាំងនោះ បទថា* **មា មុណិកស្ស បិហយិ** *សេចក្ដីថា អ្នកកុំញុំាងសេចក្ដីប្រណៃនឲ្យកើតឡើងក្នុងភោជនរបស់ជ្រូកឈ្មោះមុណិកៈ គឺកុំប្រណៃនចំពោះជ្រូកមុណិកៈថា ជ្រូកនេះបរិភោគភោជនល្អ បានដល់ កុំប្រាថ្នាដូចជ្រូកមុណិកៈថា កាលណាហ្ន៎ អញនឹងមានសេចក្ដីសុខយ៉ាងនេះ ព្រោះជ្រូកមុណិកៈនេះ បរិភោគអាហារដែលជាហេតុក្ដៅក្រហាយ ។*

*បទថា* **អាតុរន្នានិ** *បានដល់ ភោជនជាហេតុឲ្យស្លាប់ ។*

*បទថា* **អប្បោស្សុក្កោ ភុសង្ខាទ** *សេចក្ដីថា អ្នកចូរជាបុគ្គលមានសេចក្ដីខ្វល់ខ្វាយតិចក្នុងភោជនរបស់ជ្រូកមុណិកៈនោះ ចូរបរិភោគចំបើងដែលខ្លួនបានចុះ ។*

*បទថា* **ឯតំ ទីឃាយុលក្ខណំ** *សេចក្ដីថា នេះជាហេតុនៃភាពជាអ្នកមានអាយុវែង ។*

*បន្ទាប់អំពីនោះ មិនយូរប៉ុន្មាន មនុស្សទាំងនោះក៏នាំគ្នាមកសម្លាប់ជ្រូកមុណិកៈ ហើយចាក់ដោយប្រការផ្សេងៗ ។ ព្រះពោធិសត្វពោលនឹងគោចូឡលោហិតថា* **ទិដ្ឋា តេ តាត មុណិកោ** *នៃបា ឯងឃើញជ្រូកឈ្មោះមុណិកៈ ហើយឬ ។*

*គោចូឡលោហិតពោលថា បពិត្របង ផលនៃការបរិភោគរបស់ជ្រូកមុណិកៈនោះ ខ្ញុំឃើញហើយ របស់ត្រឹមតែស្មៅ ស្លឹកឈើ និងចំបើង*

*ប៉ុណ្ណោះ របស់ពួកយើងឧត្តម មិនមានទោស និងជាលក្ខណៈនៃភាពជាអ្នកមានអាយុវែងជាងភត្តរបស់ជ្រូកមុណិកៈ ដោយរយដងពាន់ដង ។*

*ព្រះបរមសាស្តា ត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុនអ្នកអាស្រ័យកុមារិកានេះដល់នូវការអស់ជីវិត ហើយដល់នូវភាពជាសម្ភឧត្តរិភង្គរបស់មហាជនដោយប្រការយ៉ាងនេះ ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈហើយ ភិក្ខុដែលអផ្សុកចង់សឹកនោះ តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាទ្រង់បន្តអនុសន្ធិហើយប្រជុំជាតកថា មុណិកសូករៈក្នុងកាលនោះ បានមកជាភិក្ខុដែលអផ្សុកចង់សឹក កុមារិកាក្នុងកាលនោះ បានមកជាថុល្ល-កុមារិកាក្នុងកាលឥឡូវនេះ គោឈ្មោះចូឡលោហិត បានមកជាអានន្ទ ចំណែកគោឈ្មោះមហាលោហិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា មុណិកជាតក ទី ១០ ។

ចប់ កុរុង្គវគ្គ ទី ៣ ។

# រួមជាតកដែលមាននៅក្នុងវគ្គនេះ គឺ

*កុរុង្គមិគជាតក ១ កុក្កុរជាតក ១ ភោជាជានីយជាតក ១ អាជញ្ញជាតក ១ តិត្ថជាតក ១ មហិឡាមុខជាតក ១ អភិណ្ហជាតក ១ នន្ទិវិសាលជាតក ១ កណ្ហជាតក ១ មុណិកជាតក ១ ។*

# កុលាវកវគ្គ ទី ៤

# អដ្ឋកថា កុលាវកជាតក ទី ១

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលផឹកទឹកមិនត្រង ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **កុលាវកា** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុកំលោះជាសម្លាញ់នឹងគ្នាពីររូប ចេញពីនគរសាវត្ថីទៅកាន់ជនបទ នៅក្នុងទីផាសុកមួយកន្លែងតាមអធ្យាស្រ័យ ហើយគិតថានឹងគាល់ព្រះសម្មាសម្ពុទ្ធ ទើបចេញអំពីជនបទនោះ មានមុខឆ្ពោះមកកាន់វត្តជេតពន ។ ឯភិក្ខុពីររូបនោះ ភិក្ខុមួយរូបមានធម្មក្រក ចំណែកភិក្ខុមួយរូបទៀតមិនមាន ភិក្ខុទាំងពីររូបនោះ ក៏រួមគ្នាត្រងទឹក ហើយទើបផឹក ។ ថ្ងៃមួយ ភិក្ខុទាំងពីររូបនោះក៏មានជម្លោះទាស់ទែងគ្នា ភិក្ខុដែលជាម្ចាស់តម្រងទឹក មិនឲ្យតម្រងទឹកដល់ភិក្ខុក្រៅអំពីនេះប្រើប្រាស់ ត្រងទឹកផឹកចំពោះតែខ្លួនឯងប៉ុណ្ណោះ ចំណែកភិក្ខុក្រៅអំពីនេះ មិនបានតម្រងទឹក កាលមិនអាចអត់ទ្រាំនឹងសេចក្ដីស្រេកឃ្លានបាន ទើបផឹកទឹកដែលមិនបានត្រង ។ ភិក្ខុទាំងពីររូបនោះ មកដល់វត្តជេតពនដោយលំដាប់ ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។*

*ព្រះមានព្រះភាគ ទ្រង់ត្រាស់សមោទនីយកថា ហើយត្រាស់សួរថា តើពួកអ្នកមកអំពីទីណា ?*

ភិក្ខុទាំងពីររូបនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គមកអំពីស្រុកមួយ ក្នុងកោសលជនបទ ចេញអំពីស្រុកនោះមកដើម្បីគាល់ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់សួរថា ពួកអ្នកសាមគ្គីស្មោះស្ម័គ្រនឹងគ្នាហើយឬ ?

ភិក្ខុដែលមិនមានតម្រងទឹកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះ ធ្វើនូវជម្លោះទាស់ទែងជាមួយខ្ញុំព្រះអង្គក្នុងកណ្ដាលផ្លូវ ហើយមិនឲ្យតម្រងទឹកដល់ខ្ញុំព្រះអង្គ ។

ភិក្ខុក្រៅអំពីនោះក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះមិនត្រងទឹក ដឹងថាទឹកមានសត្វ នៅតែផឹក ។

ព្រះសាស្ដាត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកដឹងហើយផឹកទឹកទាំងមានសត្វឬ ?

ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ខ្ញុំព្រះអង្គមិនបានត្រងហើយផឹកមែន ។

ព្រះទសពលត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតទាំងឡាយក្នុងកាលមុនគ្រងរាជសម្បត្តិក្នុងទេវនគរ ចាញ់សង្គ្រាមរត់ទៅលើផ្ទៃសមុទ្រ គិតថាអញនឹងមិនធ្វើការសម្លាប់សត្វ ព្រោះអាស្រ័យភាពជាធំ បានលះយសធំឲ្យជីវិតដល់បក្សីគ្រុឌ ហើយទើបត្រឡប់រថ កាលទ្រង់ត្រាស់យ៉ាងនេះ

ហើយ ទើបទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបាទមគធរាជមួយអង្គ គ្រងរាជសម្បត្តិនៅក្នុងនគររាជគ្រឹះ ដែនមគធៈ ។ ក្នុងកាលនោះ ព្រះបរមពោធិសត្វកើតជាបុត្តរបស់ត្រកូលធំក្នុងស្រុកនចលគាមនោះឯង ដូចក្នុងកាលឥឡូវនេះ សក្កទេវរាជកើតក្នុងស្រុកនចលគាម ដែនមគធៈ ក្នុងអត្តភាពមុនដូច្នោះ ។ ក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយបានដាក់ឈ្មោះព្រះបរមពោធិសត្វថា មឃកុមារ ។ ព្រះមហាសត្វចម្រើនវ័យហើយ ប្រាកដឈ្មោះថា មឃមាណព ។ សម័យនោះ មាតាបិតារបស់ព្រះពោធិសត្វ ក៏បាននាំទារិកាមកអំពីត្រកូលដែលមានជាតិស្មើគ្នា ដើម្បីជាភរិយារបស់ព្រះមហាសត្វ ។ ព្រះមហាសត្វចម្រើនដោយបុត្តនិងធីតាទាំងឡាយ បានជាទានបតី រក្សាសីល ៥ ។ ក្នុងស្រុកនោះមានមនុស្ស ៣៣ ត្រកូលប៉ុណ្ណោះ ថ្ងៃមួយមនុស្សក្នុងត្រកូលទាំង ៣៣ ត្រកូលនោះ ឈរត្រង់កណ្ដាលស្រុក ធ្វើការងារក្នុងស្រុក ព្រះពោធិសត្វយកជើងទាំងពីរវែកធូលីហើយឈរ ធ្វើប្រទេសនោះឲ្យគួរជាទីត្រេកអរ ឈរហើយ ។ គ្រានោះ បុរសម្នាក់មកឈរក្នុងទីនោះ ទើបព្រះបរមពោធិសត្វធ្វើទីដទៃទៀតឲ្យគួរជាទីត្រេកអរហើយឈរ សូម្បីក្នុងទីនោះ មនុស្សដទៃក៏មកឈរទៀត ព្រះពោធិសត្វបានធ្វើទីដទៃៗ ឲ្យគួរជាទីត្រេកអរ រួមសេចក្ដីថា បានធ្វើទីឈរគួរជាទីត្រេកអរដល់មនុស្សទាំងឡាយ ។ សម័យក្រោយមក បានសាងបារាំ

ក្នុងទីនោះ សូម្បីបារាំក៏ឲ្យរើចេញ ហើយឲ្យសាងសាលា ក្រាលអាសនៈ គឺក្រាលបន្ទះក្ដារក្នុងសាលានោះ ហើយតម្កល់ពាងទឹកទុក ។ សម័យក្រោយមក ជន ៣២ នាក់នោះ ក៏មានឆន្ទៈស្មើគ្នាជាមួយនឹងព្រះមហាសត្វ ។ ព្រះពោធិសត្វឲ្យជនទាំង ៣២ នាក់នោះ តាំងនៅក្នុងសីល ៥ ។ ចាប់តាំងអំពីពេលនោះមក ក៏ត្រាច់ធ្វើបុណ្យទាំងឡាយជាមួយជនទាំងនោះ ជនទាំងនោះ កាលធ្វើបុណ្យជាមួយព្រះមហាសត្វ ក៏ក្រោកឡើងអំពីព្រលឹម កាន់កាំបិត ប៉ូវថៅ និងអង្រែ យកអង្រែវាយថ្មឲ្យបែក ធ្វើផ្លូវធំដែលមានមុម ៤ ជាដើម ហើយពង្រាបឲ្យស្មើ នាំយកដើមឈើដែលអាចប៉ះភ្លៅរថទាំងឡាយចេញ ធ្វើទីពុំរាបស្មើឲ្យរាបស្មើ ចងស្ពាន ជីកស្រះបោក្ខរណី សាងសាលា ឲ្យទាន រក្សាសីល ដោយច្រើនអ្នកស្រុកទាំងអស់ តាំងនៅក្នុងឱវាទរបស់ព្រះមហាសត្វហើយរក្សាសីល ដោយប្រការយ៉ាងនេះ ។ លំដាប់នោះ មេស្រុករបស់ជនទាំងនោះគិតថា ក្នុងកាលមុន កាលមនុស្សទាំងនេះផឹកស្រា ធ្វើបាណាតិបាត អញគង់បានទ្រព្យដោយអំណាចកហាបណៈ ថ្លៃឌីទឹនស្រាជាដើម និងដោយអំណាចពលី តែឥឡូវនេះ មឃមាណពឲ្យរក្សាសីល មិនឲ្យជនទាំងនោះធ្វើបាណាតិបាតជាដើម ម្យ៉ាងទៀត ឥឡូវនេះ នឹងឲ្យយើងទាំងឡាយរក្សាសីល ៥ ទើបខឹងក្រោធ ចូលទៅគាល់ព្រះរាជាហើយក្រាបទូលថា

**ទេវ ពហូ ចោរា គាមឃាតាទីនិ ករោន្តា វិចរន្តិ** បពិត្រ

ព្រះសម្មតិទេព ពួកចោរជាច្រើន ត្រាច់ធ្វើការសម្លាប់អ្នកស្រុកជាដើម ។

ព្រះរាជា ទ្រង់ស្តាប់ពាក្យរបស់មេស្រុកនោះហើយ ទើបត្រាស់បញ្ជាថា **តេ្ឋ តេ អានេហិ** ពួកអ្នក ចូរទៅនាំមនុស្សទាំងនោះមក ។ មេស្រុកនោះ ក៏ទៅចងមនុស្សទាំងនោះនាំមក ហើយក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ពួកមនុស្សដែលទូលបង្គំនាំមកនេះ ជាចោរ ។

លំដាប់នោះ ព្រះរាជា ទ្រង់មិនជម្រះកម្មរបស់ជនទាំងនោះឡើយ ត្រាស់បញ្ជាថា អ្នកទាំងឡាយ ចូរឲ្យដំរីជាន់ជនទាំងនេះ ។ បន្ទាប់អំពីនោះ រាជបុរសក៏ឲ្យជនទាំងនោះដេកត្រង់លានព្រះរាជវាំង ហើយនាំដំរីមក ។ ព្រះពោធិសត្វទូន្មានដល់ជនទាំងនោះថា នែអ្នកទាំងឡាយ ចូរអ្នកពិចារណាដល់សីល ចូរចម្រើនមេត្តាក្នុងមនុស្សដែលធ្វើការញុះញង់ក្នុងព្រះរាជា ក្នុងដំរី និងក្នុងរាងកាយរបស់ខ្លួនឲ្យដូចគ្នា ជនទាំងនោះបានធ្វើយ៉ាងនោះ ។ លំដាប់នោះ រាជបុរសទាំងឡាយក៏នាំដំរីចូលទៅដើម្បីឲ្យព្រួចជនទាំងនោះ ដំរីនោះ សូម្បីត្រូវមនុស្សនាំចូលទៅ ក៏មិនចូលទៅ បន្លឺសំឡេងខ្លាំងហើយរត់ទៅ ។ លំដាប់នោះ ទើបនាំដំរីដទៃៗមក ដំរីទាំងនោះក៏គេចទៅយ៉ាងនោះដូចគ្នា ។

ព្រះរាជាត្រាស់ថា ប្រហែលមានឱសថណាមួយនៅក្នុងដៃរបស់ជនទាំងនេះ ពួកអ្នកចូរពិនិត្យមើល ។ ពួករាជបុរសពិនិត្យមើលហើយ

មិនឃើញមានអ្វី ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព មិនមានអ្វីទេព្រះអង្គ ។

ព្រះរាជាត្រាស់ថា បើយ៉ាងនោះ ប្រហែលជាជនទាំងនេះ រាយមន្តណាមួយ ពួកអ្នកចូរសាកសួរគេមើល មន្តសម្រាប់រាយរបស់ជនទាំងឡាយមានឬ?

រាជបុរសទាំងឡាយក៏សាកសួរ ព្រះពោធិសត្វឆ្លើយថា មាន ។

រាជបុរសទាំងឡាយក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព បានឮថា មន្តសម្រាប់រាយ មានព្រះអង្គ ។ ព្រះរាជាត្រាស់ឲ្យហៅជនទាំងនោះមកហើយត្រាស់ថា អ្នកទាំងឡាយ ចូរប្រាប់មន្តទាំងឡាយដែលអ្នកចេះ ។

ព្រះពោធិសត្វក្រាបទូលថា បពិត្រព្រះសម្មតិទេព ឈ្មោះថា មន្តរបស់ទូលបង្គំទាំងឡាយដទៃមិនមានទេ តែទូលបង្គំទាំងឡាយប្រមាណ ៣៣ នាក់ មិនសម្លាប់សត្វ មិនលួចទ្រព្យគេ មិនប្រព្រឹត្តខុសក្នុងកាម មិនពោលពាក្យកុហក មិនផឹកទឹកស្រវឹង ចម្រើនមេត្តា ឲ្យទាន ធ្វើផ្លូវឲ្យស្មើ ជីកស្រះបោក្ខរណី សាងសាលា នេះជាមន្ត ជាគ្រឿងការពារ ជាសេចក្តីចម្រើនរបស់ទូលបង្គំទាំងឡាយ ។ ព្រះរាជា ទ្រង់ជ្រះថ្លាចំពោះជនទាំងនោះ ទ្រង់បានឲ្យសម្បត្តិក្នុងផ្ទះរបស់មេស្រុកដែលធ្វើការញុះញង់ទាំងអស់ និងទ្រង់បានឲ្យមេស្រុកនោះ ជាទាសៈរបស់ជនទាំងនោះ

ហើយទ្រង់បានឲ្យដំរីនិងស្រុកដល់ជនទាំងនោះដូចគ្នា ។ ចាប់តាំងអំពីពេលនោះមក ជនទាំងនោះធ្វើបុណ្យទាំងឡាយតាមគាប់ចិត្ត គិតថានឹងសាងសាលាធំក្នុងផ្លូវដែលមានមុខ ៤ ទើបហៅជាងឈើមក ហើយផ្ដើមសាងសាលា តែមិនបានឲ្យមាតុគ្រាមទាំងឡាយមានចំណែកបុណ្យក្នុងសាលានោះ ព្រោះមិនមានការពេញចិត្តក្នុងមាតុគ្រាមទាំងឡាយ ។

សម័យនោះ ក្នុងផ្ទះរបស់ព្រះពោធិសត្វមានស្ត្រី ៤ នាក់ គឺនាងសុធម្មា នាងសុចិត្រា នាងសុនន្ទា នាងសុជាតា ។ បណ្ដាស្ត្រីទាំងនោះ នាងសុធម្មាត្រូវរ៉ូវជាមួយជាងឈើ ពោលថា នែបងប្រុស សូមបងធ្វើខ្ញុំឲ្យជាធំក្នុងសាលានេះ ដូច្នេះ ហើយបានឲ្យសំណូក ។ ជាងឈើនោះទទួលពាក្យថា សាធុហើយក្លែងជាក្មេចមិនទាន់ធ្វើហោជាង ប៉ុន្តែលួចចាំងចោះធ្វើហោជាងឲ្យសម្រេចហើយ កាលនឹងលើកហោជាង ទើបពោលថា ស្លាប់ហើយអ្នកទាំងឡាយ ខ្ញុំមិនបានរឭកដល់វត្ថុម្យ៉ាង ។

ជនទាំងឡាយសួរថា លោកដ៏ចម្រើន តើរបស់នោះឈ្មោះអ្វី ?

ជាងឈើពោលថា ការបានហោជាងទើបគួរ ។

ជនទាំងនោះពោលថា ណ្ហើយចុះ យើងនឹងនាំមកឲ្យ ។

ជាងឈើពោលថា ពួកយើងមិនអាចធ្វើដោយឈើដែលកាប់ភ្លាមៗ បើបានហោជាងដែលគេកាត់ទុកមុនហើយ ចាំងចោះធ្វើសម្រេចហើយ ទើបគួរ ។

ជនទាំងនោះពោលថា ឥឡូវនេះ តើយើងគិតធ្វើដូចម្តេច?

ជាងឈើពោលថា បើហោជាងសម្រាប់លក់ដែលគេធ្វើទុកស្រេចហើយ ក្នុងផ្ទះរបស់អ្នកណាមាន ចូរអ្នករកហោជាងនោះ ។ ជនទាំងនោះ កាលស្វែងរកក៏បានជួបក្នុងផ្ទះរបស់នាងសុធម្មា មិនបានដោយមូលតម្លៃ តែកាលនាងសុធម្មាពោលថា បើអ្នកទាំងឡាយធ្វើខ្ញុំឲ្យមានចំណែកបុណ្យផង ខ្ញុំនឹងឲ្យ ទើបនាំគ្នាពោលថា ពួកយើងមិនឲ្យចំណែកបុណ្យដល់មាតុគ្រាមទាំងឡាយទេ ។ លំដាប់នោះ ជាងឈើក៏ពោលនឹងជនទាំងនោះថា នែអ្នកទាំងឡាយ អ្នកទាំងឡាយនិយាយអ្វី ឈ្មោះថាទីដែលមិនមានមាតុគ្រាមមិនមានទេ វៀរតែព្រហ្មលោក អ្នកទាំងឡាយចូរកាន់យកហោជាងនេះចុះ កាលបើដូច្នោះ ការងារទាំងឡាយរបស់ពួកយើងនឹងដល់នូវការសម្រេច ។ ជនទាំងនោះក៏ពោលថា សាធុ ហើយកាន់យកហោជាងទៅកាន់សាលាឲ្យសម្រេច ហើយក្រាលបន្ទះក្តារសម្រាប់អង្គុយ តម្កល់ពាងទឹក ផ្តើមតាំងយាគូនិងកត្តជាដើមជាប្រចាំ ព័ទ្ធសាលាដោយកំពែង ប្រកបទ្វារ ពោយខ្សាច់ក្នុងកំពែង ដាំជួរនៃដើមត្នោតខាងក្រៅកំពែង ។ ចំណែកនាងសុចិត្រា ឲ្យធ្វើឧទ្យានក្នុងទីនោះ មិនមានពាក្យដែលនឹងពោលថា ដើមឈើមានផ្កានិងឈើមានផ្លែឈ្មោះនោះ មិនមានក្នុងឧទ្យាននោះ ។ ចំណែកនាងសុនន្ទាឲ្យជីកស្រះបោក្ខរណីក្នុងទីនោះដូចគ្នា ឲ្យដេរដាសដោយឈូកដែលមានពណ៌

៥ ដែលគួរជាទីត្រេកអរ ។ នាងសុជាតាមិនបានធ្វើអ្វីនឹងគេ ។ ព្រះពោធិសត្វបំពេញវត្តបទទាំង ៧ គឺ ការបម្រើមាតា ១ ការបម្រើបិតា ១ ការធ្វើនូវការឱនលំទោនចំពោះត្រកូលរៀមច្បង ១ ការពោលវាចាសច្ចៈ ១ វាចាមិនគ្រោតគ្រាត ១ វាចាមិនញុះញង់ ១ និងធ្វើឲ្យវិនាសនូវសេចក្តីកំណាញ់ ១ ដល់នូវភាពជាបុគ្គលគួរសរសើរយ៉ាងនេះថា

**មាតាបេតិភរំ ជន្តុំ កុលេ ជេដ្ឋាបចាយិនំ**
**សណ្ហំ សខិលសម្ភាសំ បេសុណេយ្យប្បហាយិនំ**
**មច្ឆេរវិនយេ យុត្តំ សច្ចំ កោធាភិភុំ នរំ**
**តំ វេ ទេវា តាវតឹសា អាហុ សប្បុរិសោ ឥតីតិ ។**

ពួកទេវតានៅឋានតាវត្តិង្ស បានហៅជនអ្នកចិញ្ចឹមមាតាបិតា អ្នកកោតក្រែងបុគ្គលជាច្បង ក្នុងត្រកូល មានវាចាល្អិតទន់ និយាយតែពាក្យផ្អែមល្ហែម លះបង់ពាក្យញុះញង់ ប្រកបក្នុងការលះបង់សេចក្តីកំណាញ់ មានសម្តីទៀងទាត់ ជាជនគ្របសង្កត់សេចក្តីក្រោធនោះឯង ថាជាសប្បុរស [១] ។

ព្រះបរមពោធិសត្វក្នុងវេលាអស់ជីវិត ក៏កើតជាសក្កទេវរាជក្នុងឋានតាវត្តិង្ស សម្លាញ់របស់ព្រះបរមពោធិសត្វទាំងអស់ ក៏កើតក្នុងឋាន

---

១-បិ.៣០ , ទំ. ២៧៣ ។

តាវត្តិង្សនោះឯង ដូចគ្នា ។

ក្នុងកាលនោះ ពួកអសុរទាំងឡាយជាអ្នកអាស្រ័យក្នុងឋានតាវត្តិង្ស ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា យើងទាំងឡាយប្រយោជន៍អ្វីដោយរាជសម្បត្តិដែលជាសាធារណៈទូទៅដល់ជនដទៃ ទើបឲ្យពួកអសុរផឹកគ្រឿងស្រវឹងដែលជាទឹក ហើយឲ្យចាប់ពួកអសុរដែលស្រវឹងត្រង់ជើង បោះចុះទៅកាន់ត្រង់ជើងភ្នំសិនេរុ ពួកអសុរទាំងនោះ រមែងដល់ភពអសុរនោះឯង ។

ឈ្មោះថា ភពអសុរមានទំហំប៉ុនឋានតាវត្តិង្សទេវលោក ក្នុងភាគខាងក្រោម គឺជើងភ្នំសិនេរុ ។ ក្នុងភពអសុរនោះ មានដើមឈើតាំងនៅមួយជួរកប្ប ឈ្មោះថា ដើមចិត្តបាដលិ ( ដើមច្រនៀង ) ដូចគ្នានឹងដើមបារិច្ឆត្តកៈរបស់ទេវតាដូច្នោះ កាលដើមចិត្តបាដលិមានផ្ការីក ពួកអសុរទាំងនោះក៏ដឹងថា នេះមិនមែនជាទេវលោករបស់ពួកយើង ព្រោះថាក្នុងទេវលោកដើមបារិច្ឆត្តកៈរមែងរីក ដូច្នេះ ។ លំដាប់នោះ ពួកអសុរទាំងនោះ ក៏ពោលថា សក្កចាស់ធ្វើពួកយើងឲ្យស្រវឹង ហើយបោះពួកយើងមកក្នុងសមុទ្ទ ដណ្ដើមយកទេវនគររបស់ពួកយើង ពួកយើងទាំងឡាយនឹងធ្វើចម្បាំងជាមួយសក្កចាស់នោះ ហើយដណ្ដើមយកទេវនគររបស់ពួកយើងមកវិញ ទើបក្រោកឡើងត្រាច់សញ្ចរទៅតាមភ្នំសិនេរុដូចស្រមោចក្រហមឡើងសសរដូច្នោះ ។ សក្កទេវរាជ ទ្រង់បានដំណឹងថា

ពួកអសុរឡើងមក ទើបហោះឡើងចំពោះទៅលើមហាសមុទ្ទ ត្រូវពួកអសុរទាំងនោះឲ្យចាញ់ហើយ ទើបគេចទៅខាងចុងមហាសមុទ្ទទិសខាងជើងដោយវេជ្ជយន្តរថ មានបណ្តោយប្រមាណ ១៥០ យោជន៍ ។ លំដាប់នោះ រថរបស់សក្កទេវរាជនោះក៏ស្ទុះទៅដោយរហ័ស ទើបជ្រុលចូលទៅកាន់ព្រៃរកា ទម្លាយព្រៃរកាក្នុងផ្លូវដែលទៅនោះឯង ដូចទម្លាយព្រៃបបុសដូច្នោះ ។ ពួកកូនគ្រុឌធ្លាក់ចូលទៅក្នុងមហាសមុទ្ទស្រែកដោយសំឡេងកងរំពង ។ សក្កទេវរាជត្រាស់សួរមាតលិសារថីថា នៃមាតលិសម្លាញ់ នុ៎ះជាសំឡេងអ្វី សំឡេងនេះ គួរករុណាពន់ពេក ។

មាតលិក្រាបទូលថា បពិត្រទេវៈ ព្រៃរកាទាំងនេះ បានដាច់ដោយកម្លាំងរថរបស់យើងហើយធ្លាក់ទៅ ពួកកូនគ្រុឌទាំងឡាយ ត្រូវមរណភ័យគំរាម ទើបនាំគ្នាស្រែកដោយសំឡេងខ្លាំង ។

ព្រះមហាសត្វត្រាស់ថា នៃមាតលិសម្លាញ់ កូនគ្រុឌទាំងនេះ កុំលំបាកព្រោះអាស្រ័យយើងឡើយ យើងមិនអាស្រ័យភាពជាធំ ធ្វើកម្មគឺសម្លាប់សត្វ ដើម្បីប្រយោជន៍ដល់កូនគ្រុឌទាំងនោះ យើងនឹងលះបង់ជីវិតឲ្យដល់ពួកអសុរ ហើយទ្រង់ឲ្យរថត្រឡប់ ត្រាស់គាថានេះថា

**កុលាវកា មាតលិ សិម្ពលិស្មឹ**
**ឦសាមុខេន បរិវជ្ជយស្សុ**
**កាមំ ចជាម អសុរេសុ បាណំ**

**មាយិមេ ទិជា វិកុលាវា អហេសុន្តិ ។**

*ម្នាលមាតលិ ពួកកូនគ្រុឌ (ទំ) នៅដើមរកា អ្នកចូរចៀសវាង ( កុំឲ្យពួកវាលំបាក ) ដោយមុខចន្ទោលរថឡើយ តាមពិត យើងស៊ូលះជីវិត ចំពោះពួកអសុរវិញ កុំឲ្យតែកូនគ្រុឌ ទាំងនេះ មានសម្បុកខ្ទាត់ខ្ទាយ ។*

*បណ្ដាបទទាំងនោះ បទថា* **កុលាវកា** *បានដល់ ពួកកូនគ្រុឌ នោះឯង សក្កទេវរាជត្រាស់ហៅនាយសារថីថា* **មាតលិ** *។ ដោយបទ ថា* **សិម្ពលិស្មឹ** *នេះ លោកសម្ដែងថា អ្នកចូរមើលកូនគ្រុឌទាំងនោះ ដែលកំពុងទំត្រង់ដើមរកា ។*

*បទថា* **ឦសាមុខេន បរិវជ្ជយស្សុ** *សេចក្ដីថា អ្នកចូរវៀរកូន គ្រុឌទាំងនោះ ដោយប្រការដែលពួកគ្រុឌមិនក្ដៅក្រហាយដោយចន្ទោល របស់រថ ។*

*បទថា* **កាមំ ចជាម អសុរេសុ បាណំ** *សេចក្ដីថា កាល យើងលះបង់ជីវិតឲ្យដល់ពួកអសុរ សួស្ដីក៏នឹងមានដល់កូនគ្រុឌទាំងនោះ យើងនឹងលះដោយពិត គឺលះបង់ជីវិតខ្លួនឯងឲ្យដល់ពួកអសុរដោយពិត នោះឯង ។*

*បទថា* **មាយិមេ ទិជា វិកុលាវា អហេសុំ** *សេចក្ដីថា បក្សីទាំងនេះ ឈ្មោះថា កុំបីព្រាត់ប្រាសចាកសម្បុក ព្រោះសម្បុកត្រូវ*

*ខ្វាត់ខ្វាយ គឺកុំបោះទុក្ខឲ្យដល់កូនគ្រុឌទាំងនេះ ចូរឲ្យរថត្រឡប់ចុះ ។*

*មាតលិសារថីបានស្តាប់ពាក្យរបស់សក្កទេវរាជហើយ ទើបបានឲ្យរថត្រឡប់បែរមុខទៅកាន់ទេវលោកដោយផ្លូវដទៃ ។ ចំណែកពួកអសុរឃើញសក្កទេវរាជបែររថត្រឡប់ ទើបគិតថា នេះជាសក្កទេវរាជមកអំពីចក្រវាលដទៃមកជួយពិត រថនឹងត្រឡប់ព្រោះបានកម្លាំងពល ជាអ្នកខ្លាចចំពោះមរណភ័យ ទើបនាំគ្នាគេចទៅកាន់ភពអសុរវិញ ។ ចំណែកសក្កទេវរាជទ្រង់ចូលកាន់ទេវនគរហើយ ចោមរោមដោយពួកទេវតាក្នុងទេវលោកទាំងពីរ [១] បានប្រថាប់ឈរក្នុងកណ្តាលទេវនគរ ។ ខណៈនោះ វេជយន្តប្រាសាទកម្ពស់ ១ ពាន់យោជន៍ ជ្រែកផែនប្រឹថពីផុសឡើងព្រោះប្រាសាទផុសឡើងក្នុងទីបំផុតនៃជ័យជម្នះ ទើបទេវតាទាំងឡាយដាក់ឈ្មោះប្រាសាទនោះថា វេជយន្ត ។ លំដាប់នោះ សក្កទេវរាជទ្រង់តាំងការរក្សាក្នុងទី ៥ អន្លើ ដើម្បីកុំឲ្យពួកអសុរត្រឡប់មកទៀត សមដូចលោកពោលទុកថា*

**អន្តរា ទ្វិន្នំ អាយុជ្ឈបុរានំ បញ្ចវិធា បឋិតា អភិរក្ខា**
**ឧរគករោដិ បយស្ស ច ហារី មទនយុតា ចតុរោ ច មហន្តា ។**

*ក្នុងរវាងអាយុជ្ឈបុរីទាំងពីរ សក្កទេវរាជតាំងការរក្សាយ៉ាងរឹងមាំ*

---

*១- ទេវលោកទាំងពីរ គឺ ចាតុម្មហារាជិកា និងតាវត្តិង្ស ។*

ទុកក្នុងទី ៥ អន្ទើ គឺ នាគ ១ គ្រុឌ ១ កុម្ភណ្ឌ ១ យក្ស ១ ស្តេចមហារាជទាំងបួន ១ ។

សូម្បីនគរទាំងពីរគឺ ទេវនគរនិងអសុរនគរក៏ឈ្មោះថា អយុទ្ធបុរៈ ព្រោះបុគ្គលណាមួយ ក៏មិនអាចកាន់យកដោយការច្បាំង ព្រោះថា ក្នុងកាលណា ពួកអសុរមានកម្លាំង ក្នុងកាលនោះ ពួកទេវតារត់ចូលទេវនគរហើយបិទទ្វារ សូម្បីពួកអសុររាប់សែនក៏មិនអាចធ្វើអ្វីបាន ។ ក្នុងកាលណា ពួកទេវតាមានកម្លាំង ក្នុងកាលនោះ ពួកអសុរគេចទៅកាន់ភពអសុរហើយបិទទ្វារនគរ ពួកទេវតាសូម្បីរាប់សែនក៏មិនអាចធ្វើអ្វីបាន ដូច្នោះ នគរទាំងពីរនេះ ទើបឈ្មោះថា អយុទ្ធបុរៈ ប្រែថា នគរដែលបុគ្គលណាមួយច្បាំងមិនបាន ។ រវាងនគរទាំងពីរនោះ សក្កទេវរាជទ្រង់ធ្វើការរក្សាទុកក្នុងឋានៈ ៥ ប្រការ មាននាគជាដើមនេះ ។ បណ្តាឋានៈ ៥ ប្រការនោះ លោកកាន់យកនាគដោយសព្ទថា **ឧរគ** នាគទាំងនោះមានកម្លាំងក្នុងទឹក ព្រោះដូច្នោះ ទើបនាគទាំងនោះ មានការរក្សាក្នុងលំដាប់ជាន់ទី ១ នៃនគរទាំងពីរ ។ លោកកាន់យកគ្រុឌដោយសព្ទថា **ករោដិ** បានឮថា គ្រុឌទាំងនោះ មានបានៈនិងភោជនឈ្មោះថា **ករោដិ** គ្រុឌទាំងនោះ ទើបបានឈ្មោះតាមបានៈ គឺទឹកនិងភោជននោះ គ្រុឌទាំងនោះមានការរក្សាក្នុងជាន់ទី ២ នៃនគរទាំងពីរ ។ លោកកាន់យកកុម្ភណ្ឌដោយសព្ទថា **ហារិ** បានឮថា កុម្ភណ្ឌទាំងនោះ គឺទានវៈ

( អសុរសាមញ្ញនិងអារក្សទឹក ) ពួកកុម្ភណ្ឌទាំងនោះ មានការរក្សាក្នុងជាន់ទី ៣ នៃនគរទាំងពីរ ។ លោកកាន់យកពួកយក្សដោយសព្ទថា **មទនយុត** បានព្ទថា យក្សទាំងនោះ មានប្រក្រតីត្រាច់ទៅមិនស្មើ ជាអ្នកចម្បាំង យក្សទាំងនោះមានការក្សាក្នុងលំដាប់ទី ៤ នៃនគរទាំងពីរ ។ លោកពោលដល់មហារាជទាំង ៤ ដោយបទថា **ចតុរោ ច មហាគ្គា** ដូច្នេះ មហារាជទាំង ៤ នោះ មានការរក្សាក្នុងលំដាប់ទី ៥ នៃនគរទាំងពីរនោះ ព្រោះដូច្នោះ បើពួកអសុរក្រោធមានចិត្តអាក់អន់ចូលទៅកាន់ទេវបុរី ក៏ត្រូវឆ្លងកាត់បណ្តាអ្នកចម្បាំង ៥ ពួក មានពួកនាគដែលការពារក្នុងជាន់ដំបូងនៃភ្នំសត្តបរិភណ្ឌនោះ ការរក្សាដ៏សេស ក្នុងឋានៈដ៏សេសក៏យ៉ាងនោះ ។

កាលសក្កទេវរាជ ស្តេចទេវតាធ្វើនូវការរក្សាក្នុងទី ៥ អន្លើយ៉ាងនេះហើយក៏សោយទិព្វសម្បត្តិ ។ ឯនាងសុធម្មា ចុតិមកកើតជាបាទបរិចារិការបស់សក្កទេវរាជនោះឯង ឯទេវសភាឈ្មោះសុធម្មាមានប្រមាណ ៥០០ យោជន៍ ជាទីដែលសក្កទេវរាជគង់លើបល្ល័ង្កមាសទំហំ ១ យោជន៍ ខាងក្រោមស្វេតច្ឆត្រទិព្វ ទ្រង់ធ្វើកិច្ចដែលគប្បីធ្វើដល់ទេវតានិងមនុស្ស បានកើតឡើងដល់នាងសុធម្មា ព្រោះផលវិបាកដែលឲ្យហោជាង ។ ចំណែកនាងសុចិត្រា ក៏ចុតិមកកើតជាបាទបរិចារិការបស់សក្កទេវរាជដូចគ្នា ឯឧទ្យានឈ្មោះចិត្តលតាវ័ន ក៏កើតឡើងដល់នាងសុចិត្រានោះ

ព្រោះផលវិបាកនៃការធ្វើឧទ្យាន ។ ចំណែកនាងសុនន្ទា ចុតិមកកើតជាបាទបរិចារិការបស់សក្កទេវរាជដូចគ្នា ឯស្រះបោក្ខរណីឈ្មោះនន្ទា ក៏កើតឡើងដល់នាងសុនន្ទានោះ ព្រោះវិបាកនៃការជីកស្រះបោក្ខរណី ។

ចំណែកនាងសុជាតា កើតជាកុកញីនៅត្រង់ញកភ្នំមួយកន្លែង ព្រោះមិនបានធ្វើកុសលកម្មណាមួយទុក សក្កទេវរាជទ្រង់ពិចារណាថា នាងសុជាតាមិនប្រាកដ នាងកើតក្នុងទីណាហ្ន៎ កាលទ្រង់ឃើញនាងសុជាតានោះ ទើបទ្រង់យាងទៅកាន់ញកភ្នំនោះ នាំនាងមកកាន់ទេវលោក បង្ហាញទេវនគរគួរជាទីរីករាយ មានទេវសភាឈ្មោះ សុធម្មា ឧទ្យានចិត្តលតាវ័ន និងនន្ទបោក្ខរណីដល់កុកហើយទ្រង់ទូន្មានថា ស្រីទាំងនេះបានធ្វើកុសលទុក ទើបមកកើតជាបាទបរិចារិការបស់យើង ចំណែកនាងមិនបានធ្វើបុណ្យអ្វីទុកសោះ ទើបកើតក្នុងកំណើតសត្វតិរច្ឆាន ចាប់ពីពេលនេះទៅ ចូរនាងរក្សាសីល ឲ្យកុកនោះតាំងនៅក្នុងសីល ៥ ហើយនាំទៅលែងត្រង់ញកភ្នំនោះវិញ ។ ចំណែកកុកញីនោះក៏រក្សាសីលតាំងពីកាលនោះមក ។ លុះកន្លងទៅពីរ-បីថ្ងៃ សក្កទេវរាជទ្រង់ព្រះតម្រិះថា កុកញីរក្សាសីលបានឬហ្ន៎ ទើបទ្រង់យាងទៅ កាឡាខ្លួនជាត្រីដេកផ្ងារនៅអំពីខាងមុខ កុកញីនោះសម្គាល់ថា ត្រីងាប់ ទើបចឹកត្រង់ក្បាល ត្រីក៏កម្រើកកន្ទុយ លំដាប់នោះ កុកញីក៏លែងត្រីនោះ ដោយសម្គាល់ថាប្រហែលនៅមានជីវិត សក្កទេវរាជត្រាស់ថា សាធុ

សាធុ នាងអាចរក្សាសីលបាន ហើយទ្រង់ក៏យាងទៅកាន់ទេវលោក ។ កុកញីនោះ ចុតិអំពីអត្តភាពនោះហើយ មកកើតក្នុងផ្ទះរបស់នាយស្មូនឆ្នាំង ក្នុងនគរពារាណសី ។

សក្កទេវរាជទ្រង់ព្រះតម្រិះថា កុកញីនោះ កើតក្នុងទីណាហ្ន៎ ទ្រង់ជ្រាបថា កើតក្នុងត្រកូលស្មូនឆ្នាំង ទើបទ្រង់យកល្ពៅមាសដាក់ពេញយានតូច ហើយកាឡាខ្លួនជាមនុស្សចាស់អង្គុយត្រង់កណ្ដាលស្រុកស្រែកប្រកាសថា អ្នកទាំងឡាយ ចូរមកទទួលយកល្ពៅ ។

មនុស្សទាំងឡាយពោលថា បពិត្រលោកឪពុក សូមឲ្យដល់ខ្ញុំ ។

សក្កទេវរាជត្រាស់ថា យើងឲ្យដល់មនុស្សទាំងឡាយដែលជាអ្នករក្សាសីល តើអ្នកទាំងឡាយរក្សាសីលហើយឬ ?

មនុស្សទាំងឡាយពោលថា សីលពួកយើងមិនស្គាល់ ពួកយើងនឹងឲ្យតម្លៃ ។

សក្កទេវរាជត្រាស់ថា យើងមិនត្រូវការតម្លៃទេ យើងនឹងឲ្យចំពោះដល់អ្នករក្សាសីលប៉ុណ្ណោះ ។

មនុស្សទាំងឡាយពោលថា ល្ពៅអ្វីហ្ន៎ ហើយក៏ចៀសចេញទៅ ។ នាងសុជាតាស្ដាប់ដំណឹងនោះហើយ គិតថា បុរសនេះ នាំមកដើម្បីអញប៉ុណ្ណោះ ទើបនិយាយថា បពិត្រលោកឪពុក សូមលោកឲ្យខ្ញុំចុះ ។

សក្កទេវរាជត្រាស់សួរថា **សីលំ រក្ខតិ អម្ម** នៃនាង នាងរក្សា

សីលហើយឬ ?

នាងសុជាតាឆ្លើយថា **អាម សីលំ រក្ខាមិ** ខ្ញុំរក្សាសីលហើយ ។

សក្កទេវរាជត្រាស់ថា វត្ថុនេះ ខ្ញុំនាំមកដើម្បីប្រយោជន៍ដល់នាងប៉ុណ្ណោះ ហើយដាក់ត្រង់ទ្វារផ្ទះមួយអន្ទើដោយយានទោះឯង ហើយក៏ចៀសចេញទៅ ។

ចំណែកនាងសុជាតានោះ រក្សាសីលដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយក៏ទៅកើតជាធីតារបស់ស្តេចអសុរ គឺព្រះបាទវេបចិត្តិ បានជាអ្នកមានរូបស្អាតដោយអានិសង្សនៃសីល ។ ក្នុងវេលាធីតានោះចម្រើនវ័យហើយ ព្រះបាទវេបចិត្តិនោះត្រិះរិះថា កូនស្រីរបស់អញ ចូរជ្រើសរើសប្តីតាមគាប់ចិត្តរបស់ខ្លួន ទើបឲ្យពួកអសុរប្រជុំគ្នា ។

សក្កទេវរាជ ទ្រង់ប្រមើលមើលថា នាងសុជាតានោះ កើតក្នុងទីណាហ្ន៎ កាលទ្រង់ជ្រាបថា នាងកើតក្នុងភពអសុរ ទើបទ្រង់ព្រះតម្រិះថា នាងសុជាតានោះ កាលនឹងជ្រើសរើសយកប្តីតាមគាប់ចិត្ត នឹងជ្រើស-រើសយកអញ ទើបទ្រង់និម្មិតភេទជាអសុរហើយទៅក្នុងទីប្រជុំនោះ ។ ញាតិទាំងឡាយប្រដាប់នាងសុជាតាហើយ នាំមកកាន់ទីប្រជុំពោលថា ចូរនាងជ្រើសរើសស្វាមីតាមគាប់ចិត្ត ។ នាងសុជាតានោះ ក៏សម្លឹងមើលឃើញសក្កទេវរាជ ដោយអំណាចសេចក្តីស្រឡាញ់ដែលមានក្នុងកាលមុន ទើបជ្រើសរើសថា បុរសនេះជាស្វាមីរបស់ខ្ញុំ ។

សក្កទេវរាជ ក៏ទ្រង់នាំនាងមកកាន់ទេវនគរ ទ្រង់ធ្វើឲ្យជាធំជាង ស្រីទេពអប្សរប្រមាណ ២ កោដិកន្ទះ[១] ទ្រង់តាំងនៅដរាបដល់អស់ព្រះជន្មាយុ ហើយក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបត្រាស់ថា ម្នាលភិក្ខុ បណ្ឌិតក្នុងកាលមុនគ្រងរាជសម្បត្តិក្នុងទេវលោកសុខចិត្តលះបង់ជីវិតរបស់ខ្លួន មិនធ្វើបាណាតិបាតដោយប្រការយ៉ាងនេះ ឯអ្នកបួសក្នុងសាសនាដែលជាគ្រឿងនាំចេញចាកទុក្ខមានសភាពបែបនេះ ហេតុអ្វីផឹកទឹកដែលមានសត្វមិនបានត្រង ទើបទ្រង់តិះដៀលភិក្ខុនោះ ហើយទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មាតលិសារថីក្នុងកាលនោះ បានមកជាអានន្ទក្នុងកាលឥឡូវនេះ ចំណែកសក្កទេវរាជក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា កុលាវកជាតក ទី ១ ។

---

១-បាឋៈជា **អឌ្ឍតេយ្យានំ នាដិកាកោដីនំ** ក្នុងទីខ្លះប្រែថា ស្រីទេពអប្សរ ២.៥០០ កោដិ ក៏មាន ។

# អដ្ឋកថា នច្ចជាតក ទី ២

ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុអ្នកមានភណ្ឌៈច្រើនមួយរូប ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **រុទំ មនុញ្ញំ** ដូច្នេះជាដើម ។

រឿងដូចគ្នានឹងរឿងដែលពោលទុកក្នុង **ទេវធម្មជាតក** ខាងដើមនោះឯង ។

ព្រះបរមសាស្ដា ត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកជាបុគ្គលមានភណ្ឌៈច្រើន ពិតឬ?

ភិក្ខុនោះក្រាបទូលថា ករុណាព្រះអង្គ ។

ព្រះបរមសាស្ដាត្រាស់សួរថា ព្រោះហេតុអ្វីទើបអ្នកជាបុគ្គលមានភណ្ឌៈច្រើន ? ភិក្ខុនោះ គ្រាន់តែបានស្ដាប់ព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ក៏ខឹងក្រោធលះបង់សំពត់ស្បៀកសំពត់ដណ្ដប់ គិតថា ឥឡូវនេះអញនឹងត្រាច់ទៅដោយទំនងនេះឯង ហើយបានឈរជាបុគ្គលអាក្រាតក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្ដា មនុស្សទាំងឡាយនាំគ្នាពោលថា គួរតិះដៀលហ្ន៎ គួរតិះដៀលហ្ន៎ ។ ភិក្ខុនោះ ក៏ចៀសចេញទៅអំពីទីនោះវិលមកដើម្បីភាពជាហីនភេទ ។

ភិក្ខុទាំងឡាយអង្គុយប្រជុំគ្នាក្នុងរោងធម្មសភា នាំគ្នាពោលទោសភិក្ខុនោះថា ភិក្ខុនេះ ធ្វើកម្មមានសភាពបែបនេះ ក្នុងទីចំពោះព្រះភក្ត្រ

របស់ព្រះបរមសាស្តា ។ ព្រះមានព្រះភាគ ទ្រង់យាងមកហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុឈ្មោះនោះ លះបង់ហិរិនិងឱត្តប្បៈ ជាបុគ្គលអាក្រាតដូចក្មេងអ្នកស្រុក ក្នុងកណ្តាលបរិស័ទ ៤ ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះអង្គ ( ក្លាយជាបុគ្គល ) ដែលមនុស្សទាំងឡាយរង្កៀស វិលមកដើម្បីភាពជាបុគ្គលថោកទាបសាបសូន្យចាកសាសនាដូច្នោះ ទើបពួកខ្ញុំព្រះអង្គអង្គុយប្រជុំគ្នាដោយការពោលទោស មិនមែនគុណរបស់ភិក្ខុនោះ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះសាបសូន្យចាកសាសនាគឺរតនៈ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកសាបសូន្យចាកឥត្ថីរតនៈដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងគ្រាបឋមកប្ប សត្វជើង ៤ ទាំងឡាយបានតាំងរាជសីហ៍ឲ្យធ្វើជាស្តេច ពួកត្រីទាំងឡាយក៏តាំងត្រីឈ្មោះអានន្ទឲ្យធ្វើជាស្តេច ពួកបក្សីក៏តាំងសុវណ្ណហង្សឲ្យធ្វើជាស្តេច ។ ឯធីតារបស់ស្តេចសុវណ្ណហង្សនោះឯង ជាកូនហង្សមានរូបស្អាត ស្តេចសុវណ្ណហង្សនោះបានឲ្យពរដល់ធីតានោះ ធីតានោះសូមពរ គឺសូមជ្រើសរើសស្វាមីតាម

គាប់ចិត្តរបស់ខ្លួន ស្តេចហង្សឲ្យពរដល់ធីតានោះហើយ ឲ្យបក្សីទាំងពួង ក្នុងព្រៃហិមពាន្តប្រជុំគ្នា ពួកបក្សីច្រើនប្រភេទ មានហង្ស ក្ងោកជាដើម មកព្រមគ្នាហើយប្រជុំគ្នាលើផ្ទាំងថ្មធំមួយកន្លែង ។ ស្តេចហង្សហៅធីតា មកថា ចូរមកជ្រើសរើសស្វាមីតាមគាប់ចិត្តរបស់នាងចុះ ។ ធីតាហង្ស នោះពិនិត្យមើលហ្វូងបក្សី បានឃើញក្ងោកមានផ្នួតកដូចពណ៌កែវមណី មានរោមកន្ទុយវិចិត្រ ទើបប្រាប់ថា **អយំ មេ សាមិកោ ហោតុ** បក្សី នេះ ចូរជាស្វាមីរបស់ខ្ញុំ ។

ហ្វូងបក្សីទាំងឡាយក៏ចូលទៅរកក្ងោកនោះហើយពោលថា នែ សម្លាញ់ក្ងោក រាជធីតានេះ ជ្រើសរើសស្វាមីក្នុងកណ្តាលពួកបក្សីមាន ប្រមាណប៉ុណ្ណេះ បានញុំាងការពេញចិត្តឲ្យកើតឡើងក្នុងអ្នក ។ ក្ងោក គិតថា ថ្ងៃនេះ ពួកបក្សីគង់មិនទាន់ឃើញកម្លាំងរបស់អញ ទើបទម្លាយ ហិរិឱត្តប្បៈ ព្រោះមានចិត្តត្រេកអរខ្លាំងពេក ហើយក៏ចាប់ផ្តើមបើកស្លាប ពេនពង់ក្នុងកណ្តាលទីប្រជុំធំ បានជាអ្នករាំពត់ពេនពេញកម្លាំង មិន មានបិទបាំងកេរ្តិ៍ខ្មាសឡើយ ។

ស្តេចសុវណ្ណហង្សខ្មាសហើយពោលថា ក្ងោកនេះ មិនមានហិរិ ដែលមានសមុដ្ឋានតាំងឡើងខាងក្នុងឡើយ ឱត្តប្បៈដែលមានសមុដ្ឋាន តាំងឡើងខាងក្រៅ តើនឹងមានដូចម្តេច ? អញនឹងមិនឲ្យធីតារបស់អញ ដល់ក្ងោកដែលទម្លាយហិរិឱត្តប្បៈ ( នេះឡើយ ) ហើយពោលគាថាក្នុង

កណ្ដាលហ្វូងបក្សីថា

**រុទំ មនុញ្ញំ រុចិរា ច បិដ្ឋិ**
**វេឡុរិយវណ្ណូបនិភា ច គីវា**
**ព្យាមមត្តានិ ច បេក្ខុណានិ**
**នច្ចេន តេ ធីតរំ នោ ទទាមីតិ ។**

សំឡេងយំ ( របស់អ្នក ) ក៏ពីរោះ ខ្នងក៏រុងរឿង កមានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពិទូរ្យ ស្លាបទាំងឡាយ ប្រមាណមួយព្យាម អញមិនឲ្យកូនស្រីដល់អ្នក ព្រោះតែការរាំឡើយ ។

បទថា **រុទំ មនុញ្ញំ** ក្នុងគាថានោះ លោកផ្លាស់ ត អក្ខរៈជា ទ អក្ខរៈ អធិប្បាយថា សំឡេងដែលគួរពេញចិត្ត គឺសំឡេងស្រែកដ៏ពីរោះ ។

បទថា **រុចិរា ច បិដ្ឋិ** សេចក្ដីថា ខ្នងរបស់អ្នកក៏វិចិត្រស្រស់ល្អ ។

បទថា **វេឡុរិយវណ្ណូបនិភា** ប្រែថា ដូចគ្នានឹងពណ៌នៃកែវពិទូរ្យ ។

បទថា **ព្យាមមត្តានិ** ប្រែថា មានប្រមាណមួយព្យាម ។

បទថា **បេក្ខុណានិ** បានដល់ សំណុំកន្ទុយ ។

បទថា **នច្ចេន តេ ធីតរំ នោ ទទាមិ** សេចក្ដីថា ស្ដេចហង្សពោលថា យើងមិនឲ្យធីតារបស់យើងដល់អ្នក ដែលមិនមានហិរិឱត្តប្បៈបែបនេះ ព្រោះអ្នកទម្លាយហិរិឱត្តប្បៈ ហើយរាំពត់ពេននោះឯង ។

ពោលហើយ ស្ដេចហង្សនោះបានឲ្យធីតាដល់កូនហង្សដែលជាក្មួយរបស់ខ្លួនក្នុងកណ្ដាលបរិស័ទនោះឯង ។

ក្ងោកមិនបានធីតាហង្សក៏ខ្មាស ទើបហើរគេចទៅ ។ ចំណែកស្ដេចហង្សក៏ទៅកាន់លំនៅរបស់ខ្លួនវិញ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះទម្លាយហិរិឱត្តប្បៈ ហើយវិនាសចាកសាសនាគឺរតនៈ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែនទេ សូម្បីក្នុងកាលមុន ក៏ជាអ្នកវិនាសហើយចាករតនៈគឺស្រីកែវដូចគ្នា ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ក្ងោកក្នុងកាលនោះ បានមកជាភិក្ខុអ្នកមានភណ្ឌៈច្រើន ចំណែកស្ដេចហង្សក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា នច្ចជាតក ទី ២ ។

# អដ្ឋកថា សម្មោទមានជាតក ទី ៣

*ព្រះបរមសាស្តា កាលទ្រង់ចូលទៅអាស្រ័យនគរកបិលពស្តុ គង់នៅក្នុងនិគ្រោធារាម ទ្រង់ប្រារព្ធការឈ្លោះទាស់ទែងគ្នានៃព្រះញាតិ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **សម្មោទមានា** *ដូច្នេះជាដើម ។*

*ការឈ្លោះទាស់ទែងគ្នានៃព្រះញាតិនោះ នឹងមានជាក់ច្បាស់ក្នុង* **កុណាលជាតក** ( **អសីតិនិបាត** ) *ឯណោះ ។*

*ក្នុងកាលនោះ ព្រះបរមសាស្តា ទ្រង់ត្រាស់ហៅព្រះញាតិទាំងឡាយមក ហើយត្រាស់ថា មហាបពិត្រទាំងឡាយ ឈ្មោះថា ការឈ្លោះទាស់ទែងគ្នានៃព្រះញាតិទាំងឡាយ មិនសមគួរឡើយ ពិតហើយ ក្នុងកាលមុន ក្នុងវេលាសាមគ្គីគ្នា សូម្បីសត្វតិរច្ឆានទាំងឡាយក៏គ្របសង្កត់បច្ចាមិត្តដល់នូវសួស្តី ក្នុងកាលណាទាស់ទែងគ្នា ក្នុងកាលនោះ ក៏ដល់នូវសេចក្តីវិនាសធំ កាលត្រូវរាជត្រកូលទាំងឡាយក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតសត្វចាប មានចាបច្រើនពាន់ជាបរិវារនៅក្នុងដងព្រៃ ។ កាលនោះ មានព្រានចាបម្នាក់ទៅកាន់លំនៅរបស់ចាបទាំងនោះ ធ្វើសំឡេងដូចជាសត្វចាប ដឹងថាចាបទាំងនោះប្រជុំ*

គ្នាហើយ ទើបបង់សំណាញ់អំពីខាងលើចាបទាំងនោះ ហើយក្រសោបដាយដោយជុំវិញ ធ្វើឲ្យចាបទាំងអស់មករួមគ្នាហើយដាក់ពេញកំប្រោងយកទៅផ្ទះ លក់ចាបទាំងនោះចិញ្ចឹមជីវិតដោយតម្លៃនោះ ។ ថ្ងៃមួយចាបពោធិសត្វពោលនឹងចាបទាំងនោះថា នាយព្រាននេះ ធ្វើឲ្យញាតិរបស់យើងទាំងឡាយដល់នូវសេចក្ដីវិនាស ខ្ញុំដឹងឧបាយមួយដែលជាហេតុឲ្យព្រាននោះមិនអាចចាប់ពួកយើង ចាប់តាំងអំពីថ្ងៃនេះទៅ កាលព្រាននោះបង់សំណាញ់លើពួកយើង អ្នកទាំងឡាយ ចូរស៊ កក្បាលចូលទៅក្នុងក្រឡាសំណាញ់នីមួយៗ ហើយនាំគ្នាលើកសំណាញ់ឡើង ហើរទៅកាន់ទីដែលខ្លួនត្រូវការ ហើយចុះត្រង់គុម្ពឈើដែលមានបន្លា កាលបើធ្វើយ៉ាងនោះ ពួកយើងនឹងគេចផុតទៅក្នុងចំណែកខាងក្រោមត្រង់គល់នៃឈើនោះ ចាបទាំងនោះនាំគ្នាទទួលពាក្យថា សាធុ ។ ក្នុងថ្ងៃទី ២ កាលព្រានបក្សីបង់សំណាញ់អំពីខាងលើ ក៏នាំគ្នាលើកសំណាញ់ឡើង ដោយន័យដែលព្រះពោធិសត្វពោលហើយនោះឯង ហើយនាំគ្នាចុះត្រង់គល់ឈើដែលមានបន្លាមួយកន្លែង ហើយសត្វចាបទាំងនោះ ក៏គេចទៅក្នុងចន្លោះនោះៗ គឺគេចទៅក្នុងចំណែកខាងក្រោម កាលព្រានរវល់តែដោះសំណាញ់អំពីគុម្ពបន្លានោះ ពេលវេលាក៏យប់ព្រលប់ ព្រាននោះជាអ្នកមានដៃទទេត្រឡប់ទៅវិញ ។ ចាប់តាំងអំពីថ្ងៃរះឡើង ចាបទាំងនោះក៏ធ្វើយ៉ាងនោះឯង ចំណែកព្រានព្រៃ កាលដោះសំណាញ់

រហូតដល់ថ្ងៃលិច មិនបានរបស់ណាមួយ ជាអ្នកមានដៃទទេត្រឡប់ទៅផ្ទះវិញ ។ លំដាប់នោះ ភរិយារបស់គាត់ក្រោធហើយពោលថា អ្នកត្រឡប់មកដៃទទេរាល់ៗថ្ងៃ ប្រហែលជាចិញ្ចឹមស្រីដទៃខាងក្រៅទេដឹង ?

ព្រានបក្សីពោលថា នៃនាង អញមិនមានចិញ្ចឹមអ្នកដទៃឯណាឡើយ តែចាបទាំងនោះព្រមព្រៀងគ្នា ត្រាប់ទៅ វានាំយកសំណាញ់គ្រាន់តែអញបង់ទៅប៉ុណ្ណោះ ហើយចុះត្រង់គុម្ពឈើដែលមានបន្លា តែពួកវាមិនខ្វាំងក្វាវហូតនោះទេ នាងកុំទោមនស្សឡើយ កាលណាពួកវាដល់នូវការវិវាទគ្នា កាលនោះ អញនឹងនាំយកពួកវាទាំងអស់មក ធ្វើមុខរបស់នាងឲ្យស្រស់ស្រាយ ហើយពោលគាថានេះនឹងភរិយាថា

**សម្មោទមានា គច្ឆន្តិ ជាលមាទាយ បក្ខិនោ**
**យទា តេ វិវទិស្សន្តិ តទា ឯហិន្តិ មេ វសន្តិ ។**

ពួកបក្សីស្រុះស្រួលគ្នានាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនោះនឹងលុះអំណាចអញ ក្នុងកាលនោះមិនខានឡើយ ។

បណ្ដាបទទាំងនោះ បទថា **យទា តេ វិវទិស្សន្តិ** សេចក្ដីថា ក្នុងកាលណាចាបទាំងនោះ មានលទ្ធិផ្សេងៗ គ្នា មានការប្រកាន់ផ្សេងៗ គ្នា នឹងឈ្លោះទាស់ទែងគ្នា គឺនឹងធ្វើនូវជម្លោះ ។

បទថា **តទា ឯហិន្តិ មេ វសំ** សេចក្ដីថា ក្នុងកាលនោះ ចាប

ទាំងនោះនឹងមកក្នុងអំណាចរបស់អញ កាលបើដូច្នោះ អញនឹងចាប់ចាបទាំងនោះមក ធ្វើមុខរបស់នាងឲ្យស្រស់ស្រាយ ។ ព្រានលួងលោមភរិយាដោយប្រការដូចពោលមកនេះ ។

លុះកន្លងទៅពីរ-បីថ្ងៃ ចាបមួយ កាលនឹងចុះកាន់ផែនដីត្រង់ទីដែលរកស៊ី មិនបានកំណត់ ទើបជាន់ក្បាលចាបមួយទៀត ចាបដែលត្រូវគេជាន់ក្បាល ខឹងក្រោធហើយពោលថា **កោ មំ សីសេ អក្កមិ** អ្នកណាជាន់ក្បាលអញ ?

ចាបនោះក៏ពោលថា **អហំ អសល្លក្ខេត្វា អក្កមឹ មា កុជ្ឈិ** ខ្ញុំមិនបានកំណត់ទើបជាន់ សូមអ្នកកុំក្រោធឡើយ ។ ចាបនោះក៏នៅតែក្រោធ ចាបទាំងនោះ កាលនាំគ្នាពោលដដែលៗ ទើបធ្វើនូវជម្លោះថាប្រហែលជាឯងប៉ុណ្ណោះទេឬ ដែលលើកសំណាញ់ឡើងបាន ? កាលចាបទាំងនោះឈ្លោះគ្នា ព្រះពោធិសត្វគិតថា ឈ្មោះថាជម្លោះ រមែងមិនមាននូវសួស្តី ឥឡូវនេះ ចាបទាំងនេះនឹងមិនលើកសំណាញ់ បន្ទាប់អំពីនោះ នឹងនាំគ្នាដល់នូវសេចក្តីវិនាសធំ ព្រាននឹងបានឱកាស អញមិនអាចនៅក្នុងទីនេះបានទេ ។ ព្រះពោធិសត្វក៏នាំបរិស័ទរបស់ខ្លួនទៅកាន់ទីដទៃ ។ ចំណែកព្រានបក្សី លុះកន្លងទៅពីរ-បីថ្ងៃ ក៏មក ហើយធ្វើសំឡេងដូចសត្វចាប បង់សំណាញ់អំពីខាងលើចាបទាំងនោះដែលកំពុងប្រជុំគ្នា ។ លំដាប់នោះ ចាបមួយនិយាយឡើងថា បានឮថា កាលឯង

*លើកសំណាញ់ឡើងប៉ុណ្ណោះ រោមក្បាលក៏ជ្រុះ ឥឡូវនេះ ចូរឯងលើកទៅ ។*

*ចាបមួយទៀតនិយាយថា បានឮថា កាលឯងរវល់តែលើកសំណាញ់ឡើង ស្លាបទាំងពីររបស់ឯងក៏របេទៅ ឥឡូវនេះ ចូរឯងលើកសំណាញ់ចុះ ដូច្នេះ ។ កាលចាបទាំងនោះរវល់តែពោលថា ឯងចូរលើក ឯងចូរលើក ព្រានព្រៃក៏គ្របសំណាញ់ ឲ្យចាបទាំងនោះនៅរួមគ្នាខាងក្នុងហើយដាក់ពេញកំប្រោងទៅកាន់ផ្ទះ ធ្វើឲ្យភរិយាសប្បាយចិត្ត ។*

*ព្រះបរមសាស្តា ទ្រង់ត្រាស់ថា មហាបពិត្រទាំងឡាយ ឈ្មោះថាជម្លោះនៃព្រះញាតិទាំងឡាយមិនគួរយ៉ាងនេះ ព្រោះជម្លោះជាមូលហេតុនៃសេចក្តីវិនាសដោយចំណែកមួយ ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ចាបដែលមិនមែនជាបណ្ឌិតក្នុងកាលនោះ បានមកជាទេវទត្ត ចំណែកចាបដែលជាបណ្ឌិតក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សម្មោទមានជាតក ទី ៣ ។

# អដ្ឋកថា មច្ឆជាតក ទី ៤

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការលួងលោមរបស់ភរិយាចាស់ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ន មំ សីតំ ន មំ ឧណ្ហំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា ក្នុងកាលនោះ ព្រះបរមសាស្តាត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកចង់សឹក ពិតឬ?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយព្រះអង្គ ។

ព្រះសាស្តាត្រាស់សួរថា ព្រោះហេតុអ្វីទើបអ្នកអផ្សុក?

ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភរិយាកាលអំពីដើមរបស់ខ្ញុំព្រះអង្គ ជាអ្នកមានប្ញីដៃធ្វើម្ហូបឆ្ងាញ់ ខ្ញុំព្រះអង្គមិនអាចលះបង់នាងបានឡើយ ។

លំដាប់នោះ ព្រះសាស្តាបានត្រាស់នឹងភិក្ខុនោះថា ម្នាលភិក្ខុ ស្រីនោះ ជាអ្នកធ្វើសេចក្តីវិនាសដល់អ្នក តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន អ្នកក៏ដល់នូវសេចក្តីស្លាប់ព្រោះអាស្រ័យស្រីនោះដែរ តែផុតអំពីសេចក្តីស្លាប់ព្រោះអាស្រ័យតថាគត ហើយទ្រង់នាំយករឿងក្នុងអតីតមកសាធកដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វបានជាបុរោហិតរបស់ព្រះបាទព្រហ្មទត្ត

អង្គនោះ ។ ក្នុងកាលនោះ ពួកអ្នកប្រមង់បានបង់សំណាញ់នៅក្នុងស្ទឹងគ្រានោះ មានត្រីធំមួយ កំពុងតែហែលលេងជាមួយនឹងត្រីញីរបស់ខ្លួនដោយសេចក្តីត្រេកអរ ត្រីញីនោះ ហែលទៅអំពីខាងមុខត្រីធំនោះ ប៉ះនូវក្លិនសំណាញ់ក៏គេចអំពីសំណាញ់នោះទៅ ចំណែកត្រីធំនោះ ជាប់ក្នុងកាម ជាត្រីល្ងង់ខ្លៅ បានចូលទៅកាន់សំណាញ់នោះឯង ។ ពួកអ្នកប្រមង់ដឹងថាត្រីធំនោះចូលក្នុងសំណាញ់ហើយ ទើបលើកសំណាញ់ឡើងចាប់យកត្រីនោះ មិនទាន់សម្លាប់បោះទៅលើផ្នូកខ្សាច់ គិតថា នឹងអាំងត្រីនោះបរិភោគ ទើបបង្កាត់ភ្លើងហើយរកឈើអណ្តោត ។ ត្រីនោះខ្សឹកខ្សួលកន្ទក់កន្ទេញថា ការអាំងលើរងើកភ្លើង ឬការដោតដោយឈើអណ្តោតស្រួចនេះ ឬសេចក្តីទុក្ខណាមួយដទៃ មិនធ្វើឲ្យអញលំបាកឡើយ តែការដែលត្រីញីនោះដល់នូវទោមនស្សក្នុងអញថា ត្រីធំនោះបានទៅរកត្រីដទៃដោយសេចក្តីត្រេកអរ នេះប៉ុណ្ណោះទើបជាការបៀតបៀនអាត្មាអញ ហើយពោលគាថានេះថា

**ន មំ សីតំ ន មំ ឧណ្ហំ ន មំ ជាលស្មិ ពាធនំ**
**យញ្ច មំ មញ្ញតេ មច្ឆី អញ្ញំ សោ រតិយា គតោតិ ។**

ត្រជាក់មិន (បៀតបៀន) អញទេ ក្តៅក៏មិន (បៀតបៀន) អញដែរ ការបៀតបៀនអញព្រោះលប [១] មិនមានឡើយ

១- បទថា **ជាលស្មិ** គួរប្រែថា សំណាញ់ ទើបត្រូវតាមន័យក្នុងអដ្ឋកថា ។

(អញ) ព្រួយតែត្រង់ត្រីញីសម្គាល់អញថា ត្រីឈ្មោលនោះ
ទៅរកត្រីញីដទៃ ដោយតម្រេក ។

បណ្ដាបទទាំងនោះ បទថា **ន មំ សីតំ ន មំ ឧណ្ហំ** សេចក្ដីថា ត្រីទាំងឡាយរមែងមានការរងា ក្នុងកាលដែលគេលើកឡើងអំពីទឹក កាលការរងានោះប្រាសទៅ ការក្ដៅក៏រមែងមានក្នុងកាលឯក្រោយ ត្រីសំដៅយកការរងានិងការក្ដៅទាំងពីរនោះ ទើបកន្ទក់កន្ទេញថា ការរងា ការក្ដៅ រមែងមិនបៀតបៀនអាត្មាអញឡើយ មួយវិញទៀត ត្រី (នោះ) សំដៅយកសេចក្ដីទុក្ខដែលមានការអាំងលើរងើកភ្លើង ដែលនឹងមាននោះ ទើបកន្ទក់កន្ទេញថា ការក្ដៅក៏មិនបៀតបៀនអាត្មាអញ ។

ដោយបទថា **ន មំ ជាលស្មិ ពាធនំ** នេះ ត្រីកន្ទក់កន្ទេញថា ការដែលជាប់នៅក្នុងសំណាញ់នោះ ក៏មិនបៀតបៀនអាត្មាអញ ។

ក្នុងបទថា **យញ្ច មំ** ដូច្នេះជាដើម ប្រមូលសេចក្ដីដូចតទៅនេះថា ត្រីញីនោះ មិនដឹងថាអញជាប់ក្នុងសំណាញ់របស់អ្នកប្រមង់ ត្រូវគេចាប់យកទៅ កាលមិនឃើញអាត្មាអញមុខជាគិតថា ឥឡូវនេះ ត្រីធំនោះទៅស្រឡាញ់ត្រីញីដទៃដោយសេចក្ដីត្រេកអរក្នុងកាម ការដែលត្រីញីនោះ ដល់នូវទោមនស្សគិតដូច្នេះ រមែងបៀតបៀនអញ ព្រោះហេតុនោះទើបត្រីធំនោះ ដេកខ្សឹកខ្សួលលើផ្នួកខ្សាច់នោះឯង ។

សម័យនោះ បុរោហិតពោធិសត្វដែលមានបរិវារចោមរោម ក៏មក

*កាន់ឆ្នេរស្ទឹងដើម្បីផ្ទួតទឹក ឯបុរោហិតនោះ ជាអ្នកដឹងសំឡេងរបស់សត្វគ្រប់ប្រភេទ ដោយហេតុនោះ បុរោហិតនោះបានស្តាប់ត្រីកន្ទក់កន្ទេញ ទើបគិតថា ត្រីនេះ ខ្សឹកខ្សួលព្រោះកិលេស ឯត្រីដែលមានចិត្តរសាប់រសល់យ៉ាងនេះ ស្លាប់ទៅនឹងកើតក្នុងនរកប៉ុណ្ណោះ អាត្មាអញគប្បីជាទីពឹងរបស់ត្រីនេះ ។ បុរោហិតនោះ ក៏ទៅរកពួកអ្នកប្រមង់ហើយពោលថា* **អម្ភោ តុម្ហេ អម្ហាកំ ឯកទិវសម្បិ ព្យញ្ជនត្ថាយ មច្ឆំ ន ទេថ** *នែអ្នកដ៏ចម្រើន ពួកអ្នកមិនឲ្យត្រីខ្ញុំធ្វើម្ហូប ត្រឹមតែមួយថ្ងៃទេឬ ?*

*អ្នកប្រមង់ទាំងឡាយពោលថា* **កឹ វទេថ សាមិ តុម្ហាកំ រុច្ចនកមច្ឆំ គណ្ហិត្វា គច្ឆថ** *បពិត្រលោកម្ចាស់ លោកនិយាយអ្វី ចូរលោកយកត្រីតាមដែលលោកពេញចិត្តចុះ ។*

*បុរោហិតពោធិសត្វពោលថា ខ្ញុំមានការងារជាមួយអ្នកដទៃ ពួកអ្នកចូរឲ្យបំពោះតែត្រីមួយនេះប៉ុណ្ណោះ ។*

*អ្នកប្រមង់ពោលថា សូមលោកយកចុះ ។*

*ព្រះមហាសត្វយកដៃទាំងពីរចាប់ត្រីនោះ ទៅអង្គុយត្រង់ឆ្នេរស្ទឹង ហើយទូន្មានថា នែត្រីដ៏ចម្រើន ថ្ងៃនេះ បើខ្ញុំមិនបានឃើញអ្នក អ្នកនឹងដល់នូវសេចក្តីស្លាប់ ចាប់តាំងអំពីពេលនេះទៅ អ្នកកុំធ្លាក់ក្នុងអំណាចកិលេសឡើយ ហើយលែងត្រីនោះក្នុងទឹក ខ្លួនឯងក៏ទៅកាន់នគរ ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែង*

ហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុអ្នកអផ្សុកចង់សឹក ក៏តាំងនៅក្នុងសោតាបត្តិផល ។ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ត្រីញីក្នុងកាលនោះ បានមកជាបុរាណទុតិយិកា ( ប្រពន្ធក្នុងកាលមុនបួស ) ក្នុងកាលឥឡូវនេះ ត្រីធំក្នុងកាលនោះ បានមកជាភិក្ខុដែលអផ្សុកចង់សឹកក្នុងកាលឥឡូវនេះ បំណែកបុរោហិតក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា មច្ឆជាតក ទី ៤ ។

# អដ្ឋកថា វដ្ដកជាតក ទី ៥

ព្រះបរមសាស្ដា កាលទ្រង់ត្រាច់ចារិកទៅក្នុងមគធជនបទ ទ្រង់ប្រារព្ធការរលត់ទៅនៃភ្លើងព្រៃ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **សន្តិ បក្ខា អបតនា** ដូច្នេះជាដើម ។

សេចក្ដីពិស្ដារថា សម័យមួយ ព្រះបរមសាស្ដា កាលទ្រង់ត្រាច់ចារិកទៅក្នុងមគធជនបទទាំងឡាយ ទ្រង់បានត្រាច់បិណ្ឌបាតក្នុងស្រុកមគធៈមួយកន្លែង ទ្រង់ត្រឡប់អំពីបិណ្ឌបាតខាងក្រោយភត្ត កាលពួកភិក្ខុចោមរោមហើយ ទ្រង់ព្រះដំណើរចុះអំពីផ្លូវ ។ សម័យនោះ ភ្លើងព្រៃដ៏ធំក៏តាំងឡើង ភិក្ខុជាច្រើនឃើញទាំងខាងមុខនិងខាងក្រោយ ភ្លើង

នោះ មានផ្សែងសន្ធោសន្ធៅ មានអណ្តាតភ្លើងដ៏ក្រាស់កំពុងឆេះរាល មក ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុបុថុជ្ជនពួកមួយ ខ្លាចចំពោះមរណភ័យ ពោលថា ពួកយើងនឹងដុតភ្លើងកាត់ ភ្លើងដែលឆេះមកនឹងមិនឆេះពួក យើងឡើយ ទើបនាំថ្មនិងដែកមកបង្កាត់ភ្លើង ។ ចំណែកភិក្ខុខ្លះទៀត ពោលថា នែអាវុសោ ពួកអ្នកធ្វើកម្មឈ្មោះអ្វី ពួកអ្នកមិនឃើញព្រះ សម្មាសម្ពុទ្ធដែលជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ទ្រង់យាង មកជាមួយពួកយើងទេឬ ? ពួកអ្នកដូចបុគ្គលមិនឃើញព្រះចន្ទដែល អណ្តែតនៅលើមេឃ មិនឃើញព្រះអាទិត្យដែលកំពុងបញ្ចេញរស្មីរាប់ ពាន់អំពីលោកធាតុទិសខាងកើត ដូចបុគ្គលឈរត្រង់មាត់សមុទ្រ មិន ឃើញសមុទ្រ និងដូចបុគ្គលឈរផ្អែកភ្នំព្រះសិនេរុ មិនឃើញភ្នំព្រះសិនេរុ ដូច្នោះ នាំគ្នាពោលថា ដុតភ្លើងដើម្បីកាត់មុខភ្លើង ឈ្មោះថា កម្លាំង របស់ព្រះសម្ពុទ្ធ ពួកអ្នកមិនដឹងទេឬ ? មកពួកយើងនឹងទៅកាន់សម្នាក់ របស់ព្រះសាស្តា ។ ភិក្ខុទាំងនោះ កាលទៅខាងមុខនិងខាងក្រោយជុំ វិញ បានរួមគ្នាក្នុងសម្នាក់របស់ព្រះមានព្រះភាគ ។ ព្រះសម្មាសម្ពុទ្ធ មានភិក្ខុជាច្រើនជាបរិវារ ទ្រង់បានប្រថាប់ឈរក្នុងប្រទេសមួយកន្លែង ភ្លើងព្រៃដែលមានសំឡេងខ្លាំងហាក់ដូចជានឹងជន់លិចលង់ កាលមក ដល់ទីដែលព្រះសាស្តាប្រថាប់ឈរ ប្រមាណ ១៦ ករីសជុំវិញប្រទេស នោះ ក៏រលត់ទៅដូចគប់ភ្លើងដែលលិចចុះទៅក្នុងទឹកដូច្នោះ មិនអាច

គ្របសង្កត់ក្នុងទីប្រមាណ ៣២ ករីស[១] ដោយការរាលចូលមកដូច្នេះ ។ ភិក្ខុទាំងឡាយនាំគ្នាពោលគុណរបស់ព្រះបរមសាស្ដាថា គួរអស្ចារ្យហ្ន៎ ឈ្មោះថា គុណរបស់ព្រះពុទ្ធទាំងឡាយ ភ្លើងសូម្បីមិនមានចិត្តវិញ្ញាណ ក៏មិនអាចគ្របសង្កត់ទីដែលព្រះមានព្រះភាគ ទ្រង់ប្រថាប់ឈរ រមែងរលត់ទៅ ដូចគប់ភ្លើងស្មៅធ្លាក់ចុះដល់ទឹករលត់ទៅដូច្នោះ គួរអស្ចារ្យណាស់ ឈ្មោះថា អានុភាពរបស់ព្រះពុទ្ធទាំងឡាយ ។

ព្រះមានព្រះភាគ ទ្រង់បានស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលដែលភ្លើង ( ឆេះមក ) ដល់ប្រទេសនេះហើយរលត់ទៅ ជាកម្លាំងរបស់តថាគតក្នុងកាលឥឡូវនេះ ក៏មិនមែន សេចក្ដីនេះ ជាកម្លាំងនៃសច្ចៈដែលមានក្នុងកាលមុនរបស់តថាគត ដ្បិតថា ក្នុងប្រទេសនេះ ភ្លើងមិនឆេះអស់មួយកប្ប នេះឈ្មោះថា ជាបាដិហារិយ៍ដែលតាំងនៅអស់កប្ប ។ លំដាប់នោះ ព្រះអានន្ទក្រាលសង្ឃាដីបួនជាន់ ដើម្បីជាទីគង់ប្រថាប់របស់ព្រះមានព្រះភាគ ។ ព្រះបរមសាស្ដា ទ្រង់គង់ពត់ព្រះភ្នែន ចំណែកភិក្ខុសង្ឃក៏ថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយអង្គុយចោមរោម ។ លំដាប់នោះ ព្រះមានព្រះភាគ

---

១-ទីដែលទ្រង់ប្រថាប់ឈរ ១៦ ករីស ទីជុំវិញដែលភ្លើងមិនរាលមកនោះ ១៦ ករីស ទៀត ជា ៣២ ករីស ។

កាលភិក្ខុទាំងឡាយក្រាបទូលអារាធនាថា បពិត្រព្រះអង្គដ៏ចម្រើន រឿងនេះ ប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយហើយ ចំណែករឿងក្នុងអតីតជាអាថ៌កំបាំងនៅឡើយ សូមទ្រង់ត្រាស់សម្តែងរឿងក្នុងអតីតនោះឲ្យប្រាកដដល់ខ្ញុំព្រះអង្គទាំងឡាយផងចុះ ទើបព្រះបរមសាស្តាទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងដែនមគធៈ ត្រង់ប្រទេសនេះឯង ព្រះពោធិសត្វ បដិសន្ធិក្នុងកំណើតសត្វក្រួច កើតអំពីឧទរមាតា ក្នុងវេលាទម្លាយសម្បកស៊ុតចេញមក បានជាកូនក្រួច មានខ្លួនប្រមាណប៉ុនដុំរទេះដឹកទំនិញ ។ លំដាប់នោះ មេបាឲ្យព្រះពោធិសត្វដេកក្នុងសម្បុកហើយនាំអាហារមកចិញ្ចឹមដោយចំពុះ ព្រះមហាសត្វនោះ មិនមានកម្លាំងដែលអាចបើកស្លាបហើរទៅក្នុងអាកាសបាន មិនមានកម្លាំងអាចលើកជើងដើរទៅកាន់ទីទួលបាន ឯភ្លើងព្រៃតែងតែឆេះមកក្នុងទីនោះរាល់ៗ ឆ្នាំ ។ សម័យនោះ ភ្លើងព្រៃក៏ឆេះប្រទេសនោះ មានសំឡេងលាន់កងរំពង ពួកបក្សីទាំងឡាយនាំគ្នាចាកចោលសម្បុករៀងៗខ្លួន ខ្លាចចំពោះមរណភ័យស្រែកខ្សៀវខ្សារ ហើរគេចទៅ មេបារបស់ព្រះពោធិសត្វក៏ខ្លាចចំពោះមរណភ័យ បោះបង់ព្រះពោធិសត្វហើយគេចទៅ ។ ព្រះពោធិសត្វដេកក្នុងសម្បុកនោះ អើតកឡើងឃើញភ្លើងព្រៃកំពុងឆេះរាលមក ទើបគិតថា បើអញមានកម្លាំងអាចលើកស្លាបហើរទៅក្នុងអាកាសបានសោត

អញគប្បីហើរទៅកាន់ទីដទៃ បើអញមានកម្លាំងអាចលើកជើងដើរទៅបានសោត អញនឹងលើកជើងដើរទៅកាន់ទីដទៃ ចំណែកមេបារបស់អញក៏ខ្លាចចំពោះសេចក្តីស្លាប់ បោះបង់អាត្មាអញចោលតែម្នាក់ឯងកាលនឹងការពារខ្លួន ទើបគេចទៅ ឥឡូវនេះ ទីពឹងដទៃរបស់អាត្មាអញមិនមានឡើយ អញមិនមានទីពឹង ថ្ងៃនេះ អញនឹងធ្វើដូចម្តេចហ្ន៎ ទើបគួរ លំដាប់នោះ ព្រះពោធិសត្វមានគំនិតយ៉ាងនេះថា ឈ្មោះថាគុណនៃសីលរមែងមានក្នុងលោក ឈ្មោះថាគុណនៃសច្ចៈក៏រមែងមាន ក្នុងអតីតកាល ឈ្មោះថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយដែលជាអ្នកបំពេញនូវបារមីទាំងឡាយ គង់ត្រង់មណ្ឌលពោធិព្រឹក្សបានត្រាស់ដឹងព្រមក្រៃលែងហើយ ទ្រង់ដល់ព្រមដោយសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញ្ញាណ-ទស្សនៈ ទ្រង់ប្រកបដោយសច្ចៈ មេត្តា ករុណា ខន្តី រមែងមាន ឯគុណរបស់ព្រះធម៌ទាំងឡាយ ដែលព្រះសព្វញ្ញុពុទ្ធទាំងឡាយនោះ ទ្រង់ដឹងច្បាស់ហើយក៏រមែងមាន អើសច្ចៈឯណានីមួយ ក៏រមែងមាននៅក្នុងអញពិត សភាវធម៌ឯណានីមួយរមែងមានប្រាកដ ព្រោះដូច្នោះ អញរំពឹងដល់អតីតពុទ្ធទាំងឡាយ និងគុណទាំងឡាយដែលព្រះពុទ្ធក្នុងអតីតទាំងនោះដឹងច្បាស់ហើយ កាន់យកសភាវធម៌គឺសច្ចៈ ដែលមាននៅក្នុងខ្លួនអាត្មាអញ ធ្វើនូវសច្ចកិរិយាឲ្យភ្លើងថយត្រឡប់ទៅ ធ្វើសួស្តីដល់ខ្លួននិងពួកបក្សីដ៏សេសក្នុងថ្ងៃនេះ រមែងគួរ ដោយហេតុនោះ ទើបលោក

*ពោលថា*

**អត្ថិ លោកេ សីលគុណោ សច្ចំ សោចេយ្យនុទ្ទយា**
**តេន សច្ចេន កាហាមិ សច្ចកិរិយមុត្តមំ ។**

*ព្រះសព្វញ្ញុពុទ្ធ ប្រកបដោយសីលគុណ សច្ចៈ សោចេយ្យៈ (សេចក្តីស្អាត) និងសេចក្តីអាណិត សឹងមានក្នុងលោក (បើដូច្នោះ) អញនឹងធ្វើនូវសច្ចកិរិយា ដ៏ឧត្តម ដោយសច្ចៈនោះ ។*

**អាវជ្ជិត្វា ធម្មពលំ សរិត្វា បុព្វកេ ជិនេ**
**សច្ចពលមវស្សាយ សច្ចកិរិយមកាសហំ ។**

*តថាគតពិចារណាកម្លាំងធម៌ ហើយរឭកព្រះជិនស្រីក្នុងកាលមុន ធ្វើសច្ចកិរិយា ព្រោះអាស្រ័យកម្លាំងសច្ចធម៌ (នោះ) [១] ។*

*លំដាប់នោះ ព្រះពោធិសត្វរឭកដល់ព្រះគុណទាំងឡាយ របស់ព្រះពុទ្ធទាំងឡាយ ដែលបរិនិព្វានទៅហើយក្នុងអតីត ហើយប្រារព្ធដល់ភាវៈគឺសច្ចៈដែលមាននៅក្នុងខ្លួន កាលធ្វើសច្ចកិរិយា ទើបពោលគាថានេះថា*

**សន្តិ បក្ខា អបតនា សន្តិ បាទា អវញ្ចនា**
**មាតា បិតា ច និក្ខន្តា ជាតវេទ បដិក្កមាតិ ។**

---

*១- បិ. ៧៧ , ទំ.២៩៨ ។*

*ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេនិងបា (របស់យើង) ចេញបាត់ទៅហើយ នៃភ្លើងព្រៃ អ្នកចូរថយទៅចុះ ។*

*បណ្តាបទទាំងនោះ បទថា* **សន្តិ បក្ខា អបតនា** *សេចក្តីថា ឈ្មោះថា ស្លាបទាំងពីររបស់ខ្ញុំមាន គឺកើតមាន តែមិនអាចហើរ គឺមិនអាចទៅតាមអាកាសដោយស្លាបនោះបាន ព្រោះហេតុនោះ ទើបឈ្មោះថា ហើរមិនបាន ។*

*បទថា* **សន្តិ បាទា អវញ្ចនា** *សេចក្តីថា សូម្បីជើងទាំងពីររបស់ខ្ញុំក៏មាន តែមិនអាចដើរបាន គឺទៅដោយអាការដែលឈានទៅដោយជើងទាំងពីរនោះមិនបាន ព្រោះហេតុនោះ ទើបឈ្មោះថា ដើរមិនបាន ។*

*បទថា* **មាតា បិតា ច និក្ខន្តា** *សេចក្តីថា ម្យ៉ាងទៀត សូម្បីមាតាបិតាដែលនឹងនាំខ្ញុំទៅកាន់ទីដទៃនោះ ក៏ហើរទៅហើយ ព្រោះខ្លាចសេចក្តីស្លាប់ ។*

*ព្រះពោធិសត្វហៅភ្លើងថា* **ជាតវេទ** *ពិតហើយ ភ្លើងនោះ កាលកើតក៏ដឹង គឺប្រាកដ ព្រោះដូច្នោះ ទើបហៅថា* **ជាតវេទ** *ប្រែថា កើតក៏ដឹង ។*

*ដោយបទថា* **បដិក្កម** *នេះ ព្រះពោធិសត្វបញ្ជាភ្លើងថា ចូរថយ*

ទៅ គឺចូរត្រឡប់ទៅ ដូច្នេះ ។

ព្រះមហាសត្វដេកក្នុងសម្បុកនោះឯង បានធ្វើសច្ចកិរិយាថា បើស្លាបទាំងពីររបស់ខ្ញុំមាន ១ ភាវៈ គឺការបើកស្លាបទាំងពីរហើរទៅក្នុងអាកាសមិនបាន ១ ភាពដែលជើងទាំងពីរមាន ១ ភាវៈគឺការលើកជើងទាំងពីរនោះដើរទៅមិនបាន ១ ភាពដែលមាតាបិតាបោះបង់ខ្ញុំទុកក្នុងសម្បុកនោះហើយហើរទៅ ១ ទាំងអស់ជាតួសភាវៈ ម្នាលភ្លើងព្រៃ ដោយពាក្យសច្ចៈនេះ ចូរអ្នកត្រឡប់អំពីទីនេះ ។

ដំណាលគ្នានឹងសច្ចកិរិយារបស់ព្រះពោធិសត្វ ភ្លើងបានថយត្រឡប់ទៅក្នុងទីប្រមាណ ១៦ ករីស ឯការថយត្រឡប់ទៅ ក៏ឆេះក្នុងទីដទៃក្នុងព្រៃ ទាំងរលត់ហើយក្នុងទីនោះឯង ដូចគប់ភ្លើងដែលបុគ្គលជ្រលក់ក្នុងទឹកដូច្នោះ ដោយហេតុនោះ ទើបលោកពោលថា

**សហ សច្ចេ កតេ មយ្ហំ មហាបជ្ជលិតោ សិខី**
**វជ្ជេសិ សោឡស ករីសានិ ឧទកំ បត្វា យថា សិខី**
**សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ ។**

ព្រោះសច្ចកិរិយា ដែលតថាគតបានធ្វើហើយ ភ្លើងដែលឆេះសន្ធោសន្ធៅ ក៏ចៀសចម្ងាយ ១៦ ករីសៈ ( ហើយរលត់ក្នុងទីនោះ) ដូចជាគប់ភ្លើងដែលបុគ្គល ជ្រលក់ទៅក្នុងទឹក កុសលធម៌ដទៃ ស្មើនឹងសច្ចៈ នៃតថាគត ពុំមានឡើយ នេះជា

សច្ចបារមី របស់តថាគត[១] ។

ឯស្ថានទីនេះ កើតប្រាកដជាបាដិហារិយ៍ ឈ្មោះថាតាំងនៅអស់មួយកប្ប ព្រោះភ្លើងមិនឆេះក្នុងកប្បនេះទាំងមូល ។ ព្រះពោធិសត្វ កាលធ្វើសច្ចកិរិយាយ៉ាងនេះហើយ ក្នុងវេលាអស់ជីវិតក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការដែលភ្លើងមិនឆេះក្នុងទីនេះ ជាកម្លាំងរបស់តថាគត ក្នុងកាលឥឡូវនេះ ក៏មិនមែនតែជាកម្លាំងចាស់របស់តថាគត កាលតថាគតនេះឯងកើតជាសត្វក្រួចក្នុងទីនេះ ដូច្នេះ ។

ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុពួកខ្លះបានជាព្រះសោតាបន្ន ភិក្ខុពួកខ្លះបានជាព្រះសកទាគាមី ភិក្ខុពួកខ្លះក៏បានជាព្រះអនាគាមី ភិក្ខុពួកខ្លះក៏សម្រេចអរហត្ត ។ ព្រះបរមសាស្ដា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មេបាក្នុងកាលនោះ បានមកជាមាតាបិតារបស់តថាគតក្នុងកាលឥឡូវនេះ ចំណែកស្ដេចក្រួច គឺ **តថាគត** នេះឯង ។

ចប់ អដ្ឋកថា វដ្ដកជាតក ទី ៥ ។

---

១- បិ.៧៧ , ទំ.២៩៩ ។

# អដ្ឋកថា សកុណជាតក ទី ៦

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលត្រូវភ្លើងឆេះបណ្ណសាលា ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **យស្មិំ សិតា** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះ រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះបរមសាស្តា ហើយចេញអំពីវត្តជេតពន ទៅអាស្រ័យក្នុងបច្ចន្តគ្រាមមួយកន្លែង ក្នុងកោសលជនបទ ត្រង់សេនាសនៈព្រៃមួយកន្លែង ។ លំដាប់នោះ បណ្ណ-សាលារបស់ភិក្ខុនោះ ត្រូវភ្លើងឆេះក្នុងខែដំបូងនោះឯង ភិក្ខុនោះគិតថា បណ្ណសាលារបស់អញត្រូវភ្លើងឆេះហើយ អញនឹងនៅដោយលំបាក ទើបប្រាប់ដល់មនុស្សទាំងឡាយ មនុស្សទាំងនោះក៏អាងដល់ការងារនោះៗ យ៉ាងនេះថា ឥឡូវនេះ ស្រែរបស់ពួកខ្ញុំមិនមានទឹក ពួកខ្ញុំបាចទឹកបញ្ចូលស្រែហើយនឹងធ្វើប្រគេនលោកម្ចាស់ កាលបាចទឹកហើយក៏ពោលថា ចាំសាបព្រោះហើយ កាលសាបព្រោះហើយក៏ធ្វើរបង កាលធ្វើរបងហើយក៏ដកស្មៅ ច្រូតកាត់បោកបែនដូច្នេះ ឲ្យកាលវេលាកន្លងទៅអស់ ៣ ខែ ភិក្ខុនោះនៅដោយលំបាកក្នុងទីវាលអស់ ៣ ខែ ទើបមិនអាចចម្រើនកម្មដ្ឋានញុំាងគុណវិសេសឲ្យកើតឡើងបាន កាលបវារ-ណាហើយក៏ទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងចំណែកម្ខាង ។

ព្រះមានព្រះភាគ ទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុនោះ ហើយត្រាស់សួរថា ម្នាលភិក្ខុ អ្នកនៅចាំវស្សាដោយងាយឬ ? កម្មដ្ឋានរបស់អ្នកដល់ទីបំផុតហើយឬ ?

ភិក្ខុនោះ កាលក្រាបទូលរឿងនោះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កម្មដ្ឋានរបស់ខ្ញុំព្រះអង្គមិនដល់ទីបំផុតទេ ព្រោះមិនមានសេនាសនៈដែលជាសប្បាយ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន សូម្បីតែសត្វតិរច្ឆានទាំងឡាយ ក៏គង់ដឹងទីដែលជាទីសប្បាយ និងមិនជាទីសប្បាយរបស់ខ្លួន ព្រោះហេតុអ្វីទើបអ្នកមិនដឹង ? ដូច្នេះហើយ ទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វកើតក្នុងកំណើតបក្សី មានពួកបក្សីចោមរោមអាស្រ័យត្រង់ដើមឈើធំ ដែលសម្បូណ៌ដោយមែកនិងប្រគាប ក្នុងដងព្រៃមួយ ។ សម័យថ្ងៃមួយ លម្អិតក៏ធ្លាក់ទៅត្រង់មែកទាំងឡាយរបស់ដើមឈើនោះដែលសង្កៀតគ្នាទៅមក ផ្សែងក៏កើតឡើង ព្រះពោធិសត្វឃើញដូច្នោះ ទើបគិតថា មែកទាំងពីរនេះ កាលសង្កៀតគ្នារឿយៗ មុខតែក្លាយទៅជាភ្លើង ភ្លើងនោះធ្លាក់ចុះទៅជាប់ត្រង់ស្លឹកឈើចាស់ៗ ចាប់តាំងអំពីនោះ ភ្លើងនឹងដុតដើមឈើនេះ ពួកយើងមិនអាចនៅក្នុងទីនេះ

បានទេ ពួកយើងចូរគេចចេញអំពីទីនេះ ទៅកាន់ទីដទៃ ទើបគួរ ។ ព្រះពោធិសត្វក៏ពោលគាថានេះ ដល់ពួកបក្សីទាំងឡាយថា

**យន្និស្សិតា ជគតិរុហំ (វិហង្គមា) ស្វាយំ អគ្គឹ បមុញ្ចតិ**
**ទិសា ភជថ វក្កង្គា ជាតំ សរណតោ ភយន្តិ ។**

( ពួកសត្វស្លាប ) អាស្រ័យនឹងដើមឈើណា ដែលដុះលើ
ផែនដី ដើមឈើនោះ ក៏បញ្ចេញភ្លើង ម្នាលអ្នកមានអវយវៈ
( ក្បាលនិងក ) វៀចទាំងឡាយ អ្នកទាំងឡាយ ចូរគប់ទិស
(ទាំង ៤ ) ចុះ ភ័យកើតអំពីដើមឈើជាទីពឹងហើយ ។

បណ្ដាបទទាំងនោះ បទថា **ជគតិរុហំ** សេចក្ដីថា ដី លោកហៅថា **ជគតិ** ដើមឈើលោកហៅថា **ជគតិរុហ** ព្រោះដើមឈើកើតត្រង់ផែនដីនោះ ។

បទថា **វិហង្គមា** សេចក្ដីថា អាកាសលោកហៅថា **វិហ** បក្សីទាំងឡាយហៅថា **វិហង្គម** ព្រោះទៅក្នុងអាកាសនោះ ។

បទថា **ទិសា ភជថ** សេចក្ដីថា អ្នកទាំងឡាយ កាលនឹងលះដើមឈើនេះ គេចទៅអំពីទីនេះ ចូរទៅកាន់ទិសទាំង ៤ ។ ព្រះពោធិសត្វហៅបក្សីថា **វក្កង្គា** ព្រោះថា បក្សីទាំងនោះ ជួនកាលធ្វើកឲ្យត្រង់ ជួនកាលធ្វើកឲ្យវៀច ព្រោះដូច្នោះ ទើបហៅថា **វក្កង្គា** ម្យ៉ាងទៀត ឈ្មោះថា **វក្កង្គា** ព្រោះ **វក្ក** គឺស្លាបទាំងឡាយកើតក្នុងចំហៀងទាំងពីរនៃបក្សី

*ទាំងនោះដូច្នេះ ក៏មាន ។*

*បទថា* **ជាតំ សរណតោ ភយំ** *សេចក្ដីថា ភ័យកើតអំពីដើមឈើដែលជាទីពឹងអាស្រ័យរបស់ពួកយើង មកពួកយើងនាំគ្នាទៅកាន់ទីដទៃចុះ ។*

*បក្សីទាំងឡាយដែលជាបណ្ឌិត ធ្វើតាមពាក្យរបស់ព្រះពោធិសត្វ នាំគ្នាហើរទៅព្រមគ្នាជាមួយព្រះពោធិសត្វនោះ ទៅកាន់ទីដទៃ ចំណែកបក្សីទាំងឡាយដែលមិនមែនជាបណ្ឌិត នាំគ្នាពោលយ៉ាងនេះថា* **ឯវមេវ ឯស ពិន្ទុមត្តេ ឧទកេ កុម្ភីលេ បស្សតិ** *បក្សីនេះឃើញថា មានក្រពើនៅក្នុងទឹកត្រឹមតែមួយដំណក់ ហើយមិនជឿពាក្យរបស់ព្រះពោធិសត្វក៏នៅក្នុងទីនោះ ។ បន្ទាប់អំពីនោះ មិនយូរប៉ុន្មាន ភ្លើងក៏កើតឡើងឆេះដើមឈើនោះ តាមអាការដែលព្រះពោធិសត្វគិតហើយនោះឯង កាលផ្សែងនិងអណ្ដាតតាំងឡើង បក្សីទាំងឡាយមានភ្នែកងងឹតព្រោះផ្សែង មិនអាចទៅកាន់ទីដទៃបានក៏ធ្លាក់ជាចំណីភ្លើង ដល់នូវសេចក្ដីវិនាស ។*

*ព្រះបរមសាស្ដា ទ្រង់ត្រាស់ថា ម្នាលភិក្ខុ ក្នុងកាលមុន សូម្បីតែសត្វតិរច្ឆានទាំងឡាយដែលនៅលើចុងឈើ ក៏គង់ដឹងភាពសប្បាយ និងមិនសប្បាយរបស់ខ្លួនយ៉ាងនេះ ចុះហេតុដូចម្ដេច អ្នកក៏មិនដឹង ?*

*ព្រះបរមសាស្ដា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្ដែង*

*ហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ក្នុងវេលាចប់សច្ចៈ ភិក្ខុនោះតាំងនៅក្នុងសោតាបត្តិផល ។ ព្រះបរមសាស្តា ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា បក្សីទាំងឡាយដែលធ្វើតាមពាក្យរបស់ព្រះពោធិសត្វ ក្នុងកាលនោះ បានមកជាពុទ្ធបរិស័ទក្នុងកាលឥឡូវនេះ ចំណែកបក្សីដែលជាបណ្ឌិត គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា សកុណជាតក ទី ៦ ។

# អដ្ឋកថា តិត្តិរជាតក ទី ៧

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងនគរសាវត្ថី ទ្រង់ប្រារព្ធការហាមសេនាសនៈរបស់ព្រះសារីបុត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* **យេ វុឌ្ឍមបចាយន្តិ** *ដូច្នេះជាដើម ។*

*សេចក្តីពិស្តារថា កាលអនាថបិណ្ឌិកសេដ្ឋីសាងវិហារស្រេចហើយ បញ្ជូនទូតទៅយាងព្រះបរមសាស្តា ។ ព្រះតថាគត ទ្រង់យាងចេញអំពីនគររាជគ្រឹះដល់នគរវេសាលី ទ្រង់គង់នៅក្នុងនគរវេសាលីនោះ តាមគាប់ព្រះហឫទ័យ ហើយទ្រង់ព្រះតម្រិះថា នឹងទៅកាន់នគរសាវត្ថី ទើបទ្រង់ពុទ្ធដំណើរទៅ ។ សម័យនោះ អន្តេវាសិកទាំងឡាយរបស់ឆព្វគ្គិយ-ភិក្ខុនាំគ្នាធ្វើដំណើរទៅមុន កាលព្រះថេរៈទាំងឡាយមិនទាន់ចាប់សេនា-សនៈ ក៏នាំគ្នាហួងហែងសេនាសនៈ ដោយពោលថា សេនាសនៈនេះ*

សម្រាប់ឧបជ្ឈាយ៍របស់ពួកយើង សេនាសនៈនេះសម្រាប់អាចារ្យរបស់ពួកយើង សេនាសនៈនេះជារបស់ពួកយើងប៉ុណ្ណោះ ព្រះថេរៈទាំងឡាយដែលមកតាមក្រោយក៏មិនបានសេនាសនៈ អន្តេវាសិកទាំងឡាយរបស់ព្រះសារីបុត្តត្រូវនាំគ្នាស្វែងរកសេនាសនៈដើម្បីព្រះថេរៈ ក៏មិនបាន កាលព្រះថេរៈមិនបានសេនាសនៈ ក៏សម្ងំនៅដោយការអង្គុយ និងការដើរចង្ក្រមត្រង់គល់ឈើមួយកន្លែង ក្នុងទីមិនឆ្ងាយអំពីសេនាសនៈរបស់ព្រះសាស្ដា ។ ក្នុងវេលាទៀបភ្លឺ ព្រះមានព្រះភាគ ទ្រង់យាងចេញមក ទ្រង់ព្រះឧកាសិត ព្រះថេរៈក៏គ្រហែមតប ។

ព្រះសាស្ដាត្រាស់សួរថា នរណា?

ព្រះសារីបុត្តក្រាបទូលថា ខ្ញុំព្រះអង្គសារីបុត្ត ។

ព្រះសាស្ដាត្រាស់សួរថា ម្នាលសារីបុត្ត អ្នកធ្វើអ្វីនៅក្នុងទីនេះ ក្នុងពេលនេះ?

ព្រះសារីបុត្តក៏ក្រាបទូលរឿងរ៉ាវនោះ ។ កាលព្រះមានព្រះភាគទ្រង់បានស្ដាប់ពាក្យរបស់ព្រះសារីបុត្តហើយ ទ្រង់ពិចារណាថា កាលតថាគតនៅមានជីវិត ក្នុងកាលឥឡូវនេះ ភិក្ខុទាំងឡាយមិនគោរព មិនកោតក្រែងដល់គ្នានឹងគ្នា កាលតថាគតបរិនិព្វានហើយ ភិក្ខុទាំងឡាយនឹងធ្វើម្ដេចទៅហ្ន៎ ធម្មសង្វេគក៏កើតឡើង ។ កាលរាត្រីអស់ហើយ ទើបព្រះមានព្រះភាគ ទ្រង់ឲ្យហៅភិក្ខុសង្ឃប្រជុំគ្នា ហើយទ្រង់ត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ បានឮថា អន្តេវាសិករបស់ឆព្វគ្គិយភិក្ខុនាំគ្នាទៅមុន ហួងហែងសេនាសនៈរបស់ភិក្ខុទាំងឡាយដែលជាថេរៈ ពិតឬ ?

ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយព្រះអង្គ ។ បន្ទាប់អំពីនោះ ព្រះសាស្តា ទ្រង់តិះដៀលភិក្ខុទាំងនោះហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកណាហ្ន៎ រមែងគួរដល់អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ?

ភិក្ខុពួកខ្លះក្រាបទូលថា អ្នកដែលចេញបួសអំពីខត្តិយត្រកូលព្រះអង្គ ភិក្ខុពួកខ្លះក្រាបទូលថា គឺអ្នកដែលចេញបួសអំពីត្រកូលព្រាហ្មណ៍ ភិក្ខុពួកខ្លះក្រាបទូលថា អ្នកដែលចេញបួសអំពីត្រកូលគហបតី ភិក្ខុមួយពួកទៀតក្រាបទូលថា ព្រះវិន័យធរ ព្រះធម្មកថិក អ្នកបានបឋមជ្ឈានអ្នកបានទុតិយជ្ឈាន អ្នកបានតតិយជ្ឈាន អ្នកបានចតុត្ថជ្ឈាន ព្រះអង្គ ភិក្ខុពួកខ្លះទៀតក្រាបទូលថា ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះអរហន្ត អ្នកបានវិជ្ជា ៣ អ្នកបានអភិញ្ញា ៦ រមែងគួរដល់អាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ ។ ក្នុងវេលាដែលភិក្ខុទាំងឡាយពោលដល់បុគ្គលដែលគួរដល់អាសនៈដ៏ប្រសើរជាដើម តាមការគាប់ចិត្តរៀងៗខ្លួនយ៉ាងនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគួរបានអាសនៈដ៏ប្រសើរ ក្នុងសាសនារបស់តថាគត ជាអ្នកចេញបួសអំពីត្រកូលក្សត្រក៏មិនជាប្រមាណ ជាអ្នក

ចេញបួសអំពីត្រកូលព្រាហ្មណ៍ ត្រកូលគហបតី ព្រះវិន័យធរ អ្នកចេះព្រះសូត្រ អ្នកចេះអភិធម្ម អ្នកបានបឋមជ្ឈានជាដើម ព្រះសោតាបន្នជាដើម ក៏មិនជាប្រមាណឡើយ ម្នាលភិក្ខុទាំងឡាយ ដោយពិតនោះ ក្នុងសាសនានេះ គួរធ្វើការអភិវាទ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម តាមបុគ្គលដែលចាស់ជាង និងគួរបានអាសនៈដ៏ប្រសើរ ទឹកដ៏ប្រសើរ ដុំបាយដ៏ប្រសើរ តាមដែលចាស់ជាងនេះ ជាប្រមាណក្នុងសាសនានេះ ព្រោះដូច្នោះ ភិក្ខុដែលចាស់ជាង ជាអ្នកសមគួរដល់អាសនៈដ៏ប្រសើរជាដើមនេះ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ សារីបុត្ត អគ្គសាវករបស់តថាគត ជាអ្នកប្រកាសធម្មចក្កតាមតថាគតបាន សារីបុត្តគួរបានសេនាសនៈដែលជាប់នឹងតថាគត សារីបុត្តនោះ កាលមិនបានសេនាសនៈ ក៏សម្ងំត្រង់គល់ឈើអស់រាត្រីនេះ ឥឡូវនេះ អ្នកទាំងឡាយមិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគគ្នាយ៉ាងនេះ អំណឹះឥតអំពីតថាគតទៅនឹងធ្វើដូចម្តេច ។ លំដាប់នោះ ដើម្បីប្រទានឱវាទដល់ភិក្ខុទាំងនោះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងកាលមុន សូម្បីសត្វតិរច្ឆានទាំងឡាយក៏នាំគ្នាគិតថា ការដែលពួកយើងមិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគដល់គ្នានឹងគ្នា មិនសមគួរដល់ពួកយើង បណ្តាយើងទាំងឡាយ ពួកយើងនឹងដឹងបុគ្គលដែលចាស់ជាង ហើយធ្វើការអភិវាទជាដើម ដល់បុគ្គលចាស់នោះ ទើបពិចារណា

រកហេតុផលដឹងថា បណ្តាយើងទាំងឡាយ បុគ្គលនេះ ជាអ្នកចាស់ជាង ហើយធ្វើការអភិវាទដល់បុគ្គលដែលចាស់ជាងនោះ ញុំាងផ្លូវទៅកាន់ទេវលោកឲ្យពេញ ហើយទ្រង់នាំអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល មានសត្វ ៣ ជាសម្លាញ់នឹងគ្នា គឺសត្វទទា ស្វា ដំរី អាស្រ័យដើមជ្រៃធំមួយដើម នៅក្នុងហិមវន្តប្បទេស សម្លាញ់ទាំង ៣ នោះ បានជាអ្នកមិនគោរព មិនកោតក្រែង មានការប្រព្រឹត្តមិនជាសភាគដល់គ្នានឹងគ្នា ។ លំដាប់នោះ សម្លាញ់ទាំងបីនោះ មានការគិតដូច្នេះថា កាលដែលយើងទាំងឡាយនៅជាមួយគ្នាយ៉ាងនេះ មិនសមគួរឡើយ បើដូច្នោះ ពួកយើងគប្បីធ្វើអភិវាទជាដើម ដល់បណ្តាពួកយើងដែលជាអ្នកចាស់ជាង សម្លាញ់ទាំងឡាយគិតគ្នាថា **កោ បន នោ មហល្ល-កតរោ** បណ្តាពួកយើងអ្នកណាហ្ន៎ដែលចាស់ជាងគេ ។ ថ្ងៃមួយគិតគ្នាថា ឧបាយមាន ទើបសត្វទាំងបីអង្គុយត្រង់គល់ជ្រៃ សត្វទទា ស្វាក៏សួរដំរីថា នែដំរីសម្លាញ់ អ្នកស្គាល់ដើមជ្រៃនេះ តាំងពីកាលប្រមាណត្រឹមណា ?

ដំរីនោះឆ្លើយថា នែសម្លាញ់ទាំងឡាយ ក្នុងកាលដែលខ្ញុំជាកូនដំរី ខ្ញុំដើរធ្វើដើមជ្រៃនេះទុកក្នុងរវាងភ្លៅ ក្នុងវេលាដែលខ្ញុំឈរ ត្រួយរបស់វានិងពោះរបស់ខ្ញុំស្មើគ្នា ទើបខ្ញុំស្គាល់ដើមជ្រៃនេះ តាំងអំពីកាលដើមជ្រៃនេះនៅជាគុម្ព ។ សម្លាញ់ទាំងពីរក៏សួរស្វាដោយន័យមុននោះ

ស្វាពោលថា នែសម្លាញ់ទាំងឡាយ ខ្ញុំជាកូនស្វាអង្គុយលើផែនដី មិនចាំបាច់ងើយកទំពាស៊ីត្រួយជ្រៃនេះ កាលបើយ៉ាងនេះ ទើបខ្ញុំស្គាល់ដើមជ្រៃនេះ តាំងអំពីសម័យដែលជ្រៃនេះនៅតូច ។ លំដាប់នោះ ស្វានិងដំរីក៏សួរទទាដោយន័យមុននោះឯង ។ ខណៈនោះ ទទាក៏ពោលថា

នែសម្លាញ់ទាំងឡាយ កាលមុនមានដើមជ្រៃធំក្នុងទីឯណោះ ខ្ញុំស៊ីផ្លែរបស់ជ្រៃនោះហើយ មកបន្ទោបង់ដាក់ក្នុងទីនេះ បន្ទាប់អំពីនោះ ដើមជ្រៃនេះក៏ដុះ ទើបខ្ញុំស្គាល់ដើមជ្រៃនេះតាំងពីវាមិនទាន់កើត ព្រោះដូច្នោះ ទើបខ្ញុំនេះឯងចាស់ជាងអ្នកទាំងឡាយដោយកំណើត ។ កាលសត្វទទាពោលយ៉ាងនេះ ស្វានិងដំរីក៏ពោលនឹងទទាដែលជាបណ្ឌិតថា នែសម្លាញ់ លោកជាបុគ្គលចាស់ជាងយើងទាំងឡាយ ចាប់តាំងពីពេលនេះទៅ ពួកយើងនឹងធ្វើសក្ការៈ គោរពរាប់អាន ថ្វាយបង្គំ បូជា និងអភិវាទ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្មដល់លោក ហើយតាំងនៅក្នុងឱវាទរបស់លោក ម្យ៉ាងទៀត តាំងអំពីពេលនេះទៅ លោកគប្បីឲ្យឱវាទនិងអនុសាសនីដល់ពួកយើងទាំងឡាយ ។ ចាប់តាំងអំពីពេលនោះមក ទទាបានឲ្យឱវាទដល់ស្វានិងដំរីនោះ ឲ្យតាំងនៅក្នុងសីល ឯខ្លួនឯងក៏សមាទានសីល ។ សម្លាញ់ទាំង ៣ នោះ តាំងនៅក្នុងសីល ៥ មានការគោរពកោតក្រែងដល់គ្នានឹងគ្នា មានការប្រព្រឹត្តជាសភាគគ្នាក្នុងវេលាអស់ជីវិត មានទេវលោកជាទីទៅខាងមុខហើយ ការសមាទាន

របស់សម្លាញ់ទាំង ៣ នោះ មានឈ្មោះថា តិត្តិរព្រហ្មចរិយៈ ។

ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា សត្វតិរច្ឆាន នោះ គង់មានការគោរពមានការកោតក្រែងដល់គ្នានឹងគ្នា ចំណែកអ្នក ទាំងឡាយ បួសក្នុងធម្មវិន័យដែលតថាគតពោលល្អហើយយ៉ាងនេះ ព្រោះហេតុអ្វីទើបមិនគោរពកោតក្រែងដល់គ្នានឹងគ្នា ។

ព្រះសាស្តា លុះទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅ ភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម អាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរ ( ដល់ភិក្ខុ ) តាមលំដាប់ចាស់ខ្ចី ម្នាលភិក្ខុទាំងឡាយ តែថាវត្ថុជារបស់សង្ឃ ភិក្ខុមិនត្រូវឃាត់ខាំងតាមលំដាប់ចាស់ខ្ចីទេ ភិក្ខុ ណាឃាត់ខាំងត្រូវអាបត្តិទុក្កដ [១] ។

កាលទ្រង់នាំព្រះធម្មទេសនាមកយ៉ាងនេះហើយ ទ្រង់ត្រាស់ដឹង ព្រមចំពោះហើយ ទើបត្រាស់ព្រះគាថានេះថា

**យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា**
**ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយោ ច សុគ្គតីតិ ។**

ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះ

១- បិ. ១០ , ទំ. ៣១៤ ។

*បុគ្គលដែលចម្រើនហើយ ពួកជននោះ អ្នកផងគប្បីសរសើរ ក្នុងបច្ចុប្បន្នផង សម្បរាលោក គឺសុគតិ ក៏កើត ( ដល់ពួកជននោះ ) ផង ។*

*បណ្ដាបទទាំងនោះ បទថា* **យេ វុឌ្ឍមបចាយន្តិ** *សេចក្ដីថា បុគ្គលដែលជាធំ ៣ ពួក គឺធំដោយជាតិ ១ ធំដោយវ័យ ១ ធំដោយគុណ ១ បណ្ដាបុគ្គលដែលជាធំ ៣ ពួកនោះ បុគ្គលដែលសម្បូណ៌ដោយជាតិ ឈ្មោះថា ធំដោយជាតិ បុគ្គលដែលតាំងនៅក្នុងវ័យ ឈ្មោះថា ធំដោយវ័យ បុគ្គលដែលសម្បូណ៌ដោយគុណ ឈ្មោះថា ធំដោយគុណ ។ បណ្ដាអ្នកធំ ៣ ពួកនោះ បុគ្គលដែលចម្រើនដោយវ័យសម្បូរដោយគុណ លោកបំណងយកថាជាអ្នកធំក្នុងទីនេះ ។ បទថា* **អបចាយន្តិ** *សេចក្ដីថា បូជាដោយកម្ម គឺការឱនលំទោនចំពោះបុគ្គលដែលជាអ្នកមានសេចក្ដីចម្រើននោះ ។*

*បទថា* **ធម្មស្ស កោវិទា** *បានដល់ បុគ្គលដែលឈ្លាសក្នុងធម៌ គឺការប្រព្រឹត្តឱនលំទោន ចំពោះបុគ្គលដែលចម្រើន ។*

*បទថា* **ទិដ្ឋេ ធម្មេ** *បានដល់ ក្នុងអត្តភាពនេះឯង ។*

*បទថា* **បាសំសា** *ប្រែថា គួរដល់ការសរសើរ ។*

*បទថា* **សម្បរាយោ ច សុគ្គតិ** *សេចក្ដីថា ឈ្មោះថា ជាអ្នកទៅក្នុងខាងមុខ ព្រោះត្រូវទៅខាងមុខ គឺគប្បីលះលោកនេះទៅកាន់*

លោកខាងមុខ រមែងជាសុគតិដល់នរជននោះឯង ក្នុងទីនេះ មានការប្រមូលសេចក្តីមកដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ក្សត្រក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សូទ្រក្តី គ្រហស្ថក្តី បព្វជិតក្តី សត្វតិរច្ឆានក្តី សត្វទាំងនោះណាមួយជាអ្នកឈ្លាសក្នុងធម៌ គឺការឱនលំទោនចំពោះបុគ្គលដែលជាធំ ធ្វើការឱនលំទោនចំពោះបុគ្គលដែលជាធំដោយវ័យទាំងឡាយ ជាអ្នកសម្បូរដោយគុណ សត្វទាំងនោះរមែងបាននូវការសរសើរ គឺពណ៌នាសរសើរក្នុងអត្តភាពនេះឯងថា ជាអ្នកឱនលំទោនចំពោះបុគ្គលដែលចម្រើន កាលកាយបែកហើយ រមែងទៅកើតក្នុងឋានសួគ៌ ។

ព្រះបរមសាស្តា កាលទ្រង់ត្រាស់គុណរបស់ធម៌ គឺការឱនលំទោនចំពោះបុគ្គលដែលមានសេចក្តីចម្រើនយ៉ាងនេះហើយ ទើបទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ដំរីដ៏ប្រសើរក្នុងកាលនោះ បានមកជាមោគ្គល្លានស្វាក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកសត្វទទាដែលជាបណ្ឌិតក្នុងកាលនោះ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា តិត្តិរជាតក ទី ៧ ។

# អដ្ឋកថា ពកជាតក ទី ៨

*ព្រះបរមសាស្ដា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលចម្រើនដោយចីវរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* **ជាច្ចន្តំ និកាតិប្បញ្ញោ** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុដែលនៅក្នុងវត្តជេតពនមហាវិហារមួយរូប ជាអ្នកឈ្លាសក្នុងកម្មឯណានីមួយ មានការកាត់ ការខាត់ ការសម្អាត ការដេរសំពត់ដែលគប្បីធ្វើចីវរ ភិក្ខុនោះ រមែងមានចីវរច្រើនឡើងដោយភាពជាអ្នកឈ្លាសនោះ ព្រោះដូច្នោះ ទើបប្រាកដឈ្មោះថា ចីវរវឌ្ឍក: គឺជាអ្នកចម្រើនដោយចីវរ ។*

*សួរថា ភិក្ខុនេះ ធ្វើដូចម្ដេច ?*

*ឆ្លើយថា ភិក្ខុនេះយកសំពត់ចាស់ជាំគ្រាំគ្រា មកសម្ដែងហត្ថកម្មធ្វើឲ្យជាចីវរដែលមានសម្ផស្សល្អគួរជាទីពេញចិត្ត ក្នុងវេលាសម្រេចការជ្រលក់ បានជ្រលក់ដោយបាយម៉ាន ជុសខាត់ដោយសម្បកស័ង្ខ ធ្វើឲ្យមានស្រមោលភ្លឺរលោងគួរជាទីគាប់ចិត្តហើយរក្សាទុក ភិក្ខុទាំងឡាយដែលមិនចេះធ្វើចីវរ ក៏កាន់យកសំពត់សាដកថ្មីៗ ទៅកាន់សម្នាក់របស់ភិក្ខុនោះ ហើយពោលថា ពួកខ្ញុំមិនចេះធ្វើចីវរ សូមលោកធ្វើចីវរឲ្យដល់ពួកខ្ញុំផង ។*

*ភិក្ខុនោះពោលថា នៃអាវុសោទាំងឡាយ ចីវរកាលធ្វើ រមែង*

សម្រេចយឺតយូរ ចីវរដែលធ្វើទុកហើយមាន លោកទាំងឡាយចូរកាន់យកសំពត់សាដកនេះទៅ ហើយចូរឲ្យចីវរដែលមិនទាន់ធ្វើនោះមកដល់ខ្ញុំចុះ ហើយទើបនាំចីវរដែលធ្វើសម្រេចហើយមកឲ្យមើល ភិក្ខុទាំងនោះឃើញវណ្ណសម្បត្តិរបស់ចីវរនោះប៉ុណ្ណោះ មិនដឹងសាច់ខាងក្នុង សម្គាល់ថាជាចីវរថ្មី ជាចីវរដែលមានសាច់ជាប់ល្អ ទើបឲ្យសំពត់សាដកថ្មីទាំងឡាយដល់ចីវរវឌ្ឍកភិក្ខុ ហើយកាន់យកចីវរដែលធ្វើសម្រេចនោះទៅ ។ ចីវរនោះ កាលភិក្ខុទាំងនោះ បោកដោយទឹកក្តៅក្នុងវេលាតែបន្តិចបន្តួចក៏សម្តែងប្រក្រតីភាពរបស់ខ្លួន ចីវរដែលគ្រាំគ្រាក៏ប្រាកដក្នុងទីនោះ ភិក្ខុទាំងនោះក៏មានវិប្បដិសារីក្តៅក្រហាយចិត្ត ។ ភិក្ខុនោះយកសំពត់ចាស់បោកបញ្ឆោតភិក្ខុទាំងឡាយដែលមកហើយ ដោយអាការយ៉ាងនេះ រហូតប្រាកដកេរ្តិ៍ឈ្មោះទៅក្នុងទីទាំងពួង ។

ក្នុងស្រុកមួយទៀត មានចីវរវឌ្ឍកៈមួយរូបទៀត ជាអ្នកបោកបញ្ឆោតសត្វលោក ដូចចីវរវឌ្ឍកភិក្ខុដែលនៅក្នុងវត្តជេតពននោះដែរ ភិក្ខុទាំងឡាយដែលជាសម្លាញ់របស់ភិក្ខុនោះ ក៏ប្រាប់ភិក្ខុនោះថា នែអាវុសោ បានឮថា ចីវរវឌ្ឍកៈមួយរូបក្នុងវត្តជេតពនបោកបញ្ឆោតសត្វលោកយ៉ាងនេះ ។ លំដាប់នោះ ចីវរវឌ្ឍកៈនៅស្រុកក្រៅ ក៏មានគំនិតដូច្នេះថា ណ្ហើយចុះ អញនឹងបោកបញ្ឆោតចីវរវឌ្ឍកៈអ្នកក្រុងរូបនេះ ហើយទើបធ្វើចីវរចាស់ឲ្យជាទីពេញចិត្តក្រៃលែង ជ្រលក់យ៉ាងល្អ ដណ្តប់

ចីវរនោះទៅកាន់វត្តជេតពនមហាវិហារ ។

ចំណែកចីវរវឌ្ឍកៈអ្នកក្រុង គ្រាន់តែឃើញចីវរនោះប៉ុណ្ណោះ ក៏កើតសេចក្តីលោភចង់បាន ទើបសួរថា លោកដ៏ចម្រើន ចីវរនេះលោកធ្វើដោយខ្លួនឯងឬ?

ចីវរវឌ្ឍកៈស្រុកក្រៅពោលថា អើអាវុសោ ខ្ញុំធ្វើដោយខ្លួនឯង ។

ចីវរវឌ្ឍកៈអ្នកក្រុងពោលថា លោកដ៏ចម្រើន ចូរលោកឲ្យចីវរនេះដល់ខ្ញុំចុះ លោកនឹងបានចីវរដទៃ ។

ចីវរវឌ្ឍកៈស្រុកក្រៅពោលថា អាវុសោ ពួកខ្ញុំជាអ្នកស្រុកក្រៅរកបច្ច័យបានដោយលំបាក ខ្ញុំឲ្យចីវរនេះដល់លោកហើយ ខ្លួនឯងនឹងដណ្តប់អ្វី ?

ចីវរវឌ្ឍកៈអ្នកក្រុងពោលថា លោកដ៏ចម្រើន សំពត់សាដកថ្មីៗក្នុងសម្នាក់របស់ខ្ញុំមាន ចូរលោកកាន់យកសំពត់សាដកទាំងនោះ ធ្វើចីវររបស់លោកចុះ ។

ចីវរវឌ្ឍកៈស្រុកក្រៅពោលថា អើអាវុសោ ខ្ញុំនឹងសម្តែងហត្ថកម្មក្នុងចីវរនេះ កាលលោកពោលយ៉ាងនេះ ខ្ញុំនឹងធ្វើអ្វីបាន ចូរលោកកាន់យកចីវរនេះចុះ ហើយឲ្យចីវរដែលធ្វើដោយសំពត់ចាស់ដល់ចីវរវឌ្ឍកៈអ្នកក្រុង ខ្លួនឯងកាន់យកសំពត់សាដកថ្មីៗ បោកបញ្ឆោតចីវរវឌ្ឍកៈអ្នកក្រុងនោះហើយ ក៏ចៀសចេញទៅ ។ ចំណែកចីវរវឌ្ឍកៈដែលនៅក្នុង

វត្តជេតពនក៏ដណ្តប់ចីវរនោះ កន្លងទៅបានពីរ-បីថ្ងៃ ទើបបោកដោយទឹកក្តៅក៏ឃើញសភាពដើម គឺភាពជាចីវរចាស់គ្រាំគ្រា ក៏មានការខ្មាសអៀន ។ ភាពដែលចីវរវឌ្ឍកៈអ្នកក្រុងនោះ ត្រូវភិក្ខុស្រុកក្រៅបោកបញ្ឆោត ក៏កើតប្រាកដទូទៅក្នុងកណ្តាលភិក្ខុសង្ឃថា បានឮថា ចីវរ-វឌ្ឍកៈក្នុងវត្តជេតពន ត្រូវចីវរវឌ្ឍកៈស្រុកក្រៅបោកបញ្ឆោតហើយ ។ ថ្ងៃមួយ ភិក្ខុទាំងឡាយនាំគ្នាអង្គុយសន្ទនារឿងនោះ ក្នុងរោងធម្មសភា ព្រះមានព្រះភាគ ទ្រង់យាងមកកាន់ធម្មសភា ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកទាំងឡាយអង្គុយសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ? កាលភិក្ខុទាំងនោះ នាំគ្នាក្រាបទូលរឿងនោះឲ្យទ្រង់ជ្រាបហើយ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចីវរវឌ្ឍកៈដែលនៅក្នុងវត្តជេតពន ជាអ្នកបោកបញ្ឆោតភិក្ខុដទៃតែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងកាលមុនក៏ជាអ្នកបោកបញ្ឆោតហើយដូចគ្នា ឯចីវរវឌ្ឍកៈអ្នកស្រុកក្រៅមិនមែនបោកបញ្ឆោតចីវរវឌ្ឍកៈដែលនៅក្នុងវត្តជេតពន តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់បោកហើយដូចគ្នា ហើយទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល ព្រះបរមពោធិសត្វកើតជារុក្ខទេវតាត្រង់ដើមឈើដែលអាស្រ័យនៅត្រង់មាត់ស្រះឈូកមួយកន្លែង ក្នុងដងព្រៃមួយ ។

សម័យមួយ ជារដូវប្រាំង ទឹកក្នុងស្រះមួយកន្លែងដែលមិនធំពេក ក៏រីង ស្ងួត តែក្នុងស្រះនោះមានត្រីជាច្រើន ។ គ្រានោះ កុកមួយឃើញត្រី ទាំងឡាយហើយគិតថា អញនឹងបោកបញ្ឆោតត្រីទាំងនេះ ហើយស៊ី ដោយឧបាយឯណានីមួយ ទើបសំកុកត្រង់មាត់ទឹក ។ លំដាប់នោះ ត្រី ទាំងឡាយឃើញកុកហើយ ក៏សួរថា **កឹ អយ្យ ចិន្តេន្តោ និសិន្នោសិ** នៃលោក លោកអង្គុយគិតអ្វី ?

កុកឆ្លើយថា **តុម្ហាកំ ចិន្តេន្តោ និសិន្នោម្ហិ** អើ អញអង្គុយ គិតអំពីពួកអ្នក ហ្នឹងឯង ។

ត្រីទាំងឡាយសួរថា បពិត្រលោក លោកគិតដល់យើងដូចម្ដេច ?

កុកក៏ឆ្លើយថា អញគិតដល់ពួកអ្នកថា ទឹកក្នុងស្រះនេះមានតិច នឹងហួតហែងទៅ ឯការក្ដៅក៏មានច្រើន ឥឡូវត្រីទាំងនេះនឹងធ្វើដូចម្ដេច ?

លំដាប់នោះ ពួកត្រីក៏សួរទៀតថា បពិត្រលោក ពួកយើងនឹងធ្វើ ដូចម្ដេច ?

កុកពោលថា បើអ្នកទាំងឡាយធ្វើតាមពាក្យរបស់អញ អញនឹង យកចំពុះពាំបណ្ដាពួកអ្នក ម្ដងមួយៗ នាំទៅកាន់ទីសួស្ដី គឺក្នុងស្រះធំ មួយកន្លែងដែលដេរដាសដោយផ្កាឈូកមានពណ៌ ៥ ។

ត្រីទាំងឡាយពោលថា បពិត្រលោក តាំងតែអំពីបឋមកប្បមក ឈ្មោះថា កុកជាអ្នកឈឺឆ្អាលចំពោះត្រីទាំងឡាយមិនមានទេ លោក

បំណងនឹងស៊ីបណ្ដាពួកយើង ម្ដងមួយៗ ពួកយើងមិនជឿលោកទេ ។

កុកពោលថា អញមិនស៊ី បើពួកអ្នកមិនជឿអញថាមានស្រះទឹក ពួកអ្នកចូរឲ្យត្រីមួយទៅមើលស្រះនោះជាមួយនឹងអញចុះ ។

ត្រីទាំងឡាយក៏ជឿពាក្យរបស់កុកនោះ គិតថា ត្រីនេះ ជាអ្នកអាចទាំងផ្លូវទឹកនិងផ្លូវគោក ទើបឲ្យត្រីធំសម្បុរខ្មៅមួយទៅដោយពាក្យថា ចូរលោកពាំយកត្រីនេះទៅ ។ កុកនោះ ក៏ពាំត្រីនោះទៅលែងក្នុងស្រះ បង្ហាញស្រះនោះ ហើយនាំត្រឡប់មកកាន់សម្នាក់របស់ត្រីទាំងឡាយវិញ ត្រីនោះពណ៌នាសម្បត្តិរបស់ស្រះដល់ត្រីទាំងឡាយ ត្រីទាំងនោះបានស្ដាប់ពាក្យរបស់ត្រីមួយនោះហើយ ក៏មានប្រាថ្នានឹងទៅ ទើបនាំគ្នាពោលថា សាធុលោកម្ចាស់ លោកចូរពាំពួកយើងទៅ ។

កុកពាំត្រីដែលមានខ្លួនខ្មៅផង ធំផង ដំបូងនោះ ហើយនាំទៅកាន់ច្រាំងស្រះ បង្ហាញស្រះឲ្យឃើញហើយ ក៏ហើរទៅទំត្រង់ដើមថ្ងាន់ក្បែរមាត់ស្រះ ចឹកត្រីនោះ ក្នុងរវាងប្រគាបឈើដោយចំពុះឲ្យស្លាប់ ហើយស៊ីសាច់ចោលឆ្អឹងឲ្យធ្លាក់ត្រង់គល់ឈើ ហើយត្រឡប់ទៅវិញ ពោលថា ត្រីនោះ អញលែងទៅហើយ ត្រីដទៃចូរមក ហើយពាំយកម្ដងមួយៗ ដោយឧបាយនោះស៊ីត្រីអស់ត្រឡប់មកទៀត សូម្បីតែត្រីមួយក៏មិនមានសេសសល់ ។ ក្នុងស្រះនោះ មានក្ដាមមួយ កុកជាអ្នកចង់បរិភោគក្ដាមនោះ ទើបពោលថា នៃក្ដាមដ៏ចម្រើន អញនាំត្រីទាំងអស់

ទៅលែងក្នុងស្រះធំដែលដេរដាសដោយផ្កាឈូក មកអញនឹងនាំអ្នកទៅកាន់ទីនោះ ។

ក្ដាមសួរថា លោកកាលនាំខ្ញុំទៅ នឹងនាំទៅបានដូចម្ដេច ?

កុកពោលថា អញនឹងពាំយកទៅ ។

ក្ដាមពោលថា លោកកាលនាំទៅយ៉ាងនេះ នឹងធ្វើខ្ញុំឲ្យធ្លាក់ ខ្ញុំនឹងមិនទៅជាមួយលោកទេ ។

កុកពោលថា កុំខ្លាចឡើយ អញពាំអ្នកឲ្យល្អហើយទៅ ។ ក្ដាមគិតថា ឈ្មោះថា ការពាំយកត្រីទៅលែងក្នុងស្រះ រមែងមិនមានដល់កុកនេះ បើកុកលែងអញក្នុងស្រះ នេះជាការល្អ ប្រសិនបើមិនលែង អញនឹងកាត់កកុកនេះឲ្យអស់ជីវិត ។ លំដាប់នោះ ទើបក្ដាមពោលនឹងកុកនោះថា នែកុកសម្លាញ់ លោកមិនអាចពាំខ្ញុំទៅដោយល្អបានទេ ឯខ្ញុំនឹងក្ៀបលោក ទើបជាការល្អ បើខ្ញុំយកតង្កៀបរបស់ខ្ញុំក្ៀបករបស់លោកសោត ខ្ញុំនឹងធ្វើករបស់លោកឲ្យជារបស់ដែលខ្ញុំក្ៀបល្អហើយ ទើបខ្ញុំទៅជាមួយលោក ។ កុកគិតតែពីរឿងបោកក្ដាមនោះ មិនដឹងថាក្ដាមនេះបោកខ្លួន ទើបទទួលពាក្យហើយ ក្ដាមក៏យកតង្កៀបទាំងពីរក្ៀបកកុកនោះយ៉ាងខ្ជាប់ខ្ជួន ដូចជាដង្កាប់របស់ជាងមាស ហើយពោលថា ចូរលោកនាំខ្ញុំទៅក្នុងកាលឥឡូវនេះចុះ ។ កុកនោះ នាំក្ដាមទៅឲ្យឃើញស្រះហើយបែរមុខទៅរកដើមថ្ងាន់ ក្ដាមពោលថា **មាតុល អយំ**

**សហេ ឯត្តោ ត្វំ បង ឥតោ ក៏ នេសិ** នៃលោកអ៊ំ ស្រះនៅខាងនោះ តែលោកនាំខ្ញុំមកខាងនេះ ។

កុកពោលថា **ន តេ មាតុលោ អហំ ន ភគនិបុត្តោសិ វត មេ ត្វំ** អញជាអ៊ំ ជាទីស្រឡាញ់របស់អា តើអាជាក្មួយរបស់អញអំពីកាលណាហ្ន៎ ហើយពោលទៀតថា ឯងធ្វើសេចក្ដីសម្គាល់ថា អញនេះ ជាទាសៈរបស់ឯងឬ នាំឯងត្រាច់ទៅ ឯងចូរមើលឆ្អឹងត្រីក្រោមដើមថ្វាន់នោះ អញនឹងស៊ីឯងដូចត្រីដែលអញស៊ីហើយ ។

ក្ដាមពោលថា ត្រីទាំងនោះលោកអាចស៊ីបាន ព្រោះភាពដែលខ្លួនជាត្រីល្ងង់ តែខ្ញុំ លោកមិនអាចស៊ីបានទេ លោកនោះឯងនឹងដល់នូវសេចក្ដីវិនាស ដ្បិតថា លោកមិនដឹងថាខ្ញុំបោកបញ្ឆោតទេ ព្រោះខ្លួនជាសត្វល្ងង់ យើងទាំងពីរ កាលស្លាប់ក៏នឹងស្លាប់ជាមួយគ្នា យើងនឹងកាត់ក្បាលរបស់លោកឲ្យដាច់ធ្លាក់លើផែនដី ហើយក៏យកតង្កៀបមួយកៀបកកុកនោះ កុកហាមាត់មានទឹកភ្នែកហូរទាំងសងខាង ត្រូវមរណភ័យគំរាម ទើបពោលថា បពិត្រក្ដាម ខ្ញុំមិនស៊ីអ្នកទេ ចូរអ្នកឲ្យជីវិតដល់ខ្ញុំចុះ ។

ក្ដាមពោលថា បើយ៉ាងនោះ ចូរអ្នកបន្ទាបខ្លួនចុះក្នុងស្រះនេះ ។ កុកនោះក៏វិលត្រឡប់មកកាន់ស្រះនោះវិញ ហើយដាក់ក្ដាមលើភក់ត្រង់មាត់ស្រះ ក្ដាមកៀបកកុកនោះដាច់ក្នុងទីនោះ ដូចកាត់ទងឈូកដោយ

កន្ត្រែដូច្នោះ ទេវតាដែលអាស្រ័យនៅត្រង់ដើមថ្វាន់ ឃើញហេតុអស្ចារ្យនោះ កាលនឹងឲ្យសាធុការ ធ្វើព្រៃទាំងឡាយឲ្យខ្ទរខ្ទារ ទើបពោលគាថានេះ ដោយសំឡេងដ៏ពីរោះថា

**នាច្ចន្តំ និកតិប្បញ្ញោ និកត្យា សុខមេធតិ**
**អារាធេតិ និកតិប្បញ្ញោ ពកោ កក្កដកាមិវាតិ ។**

បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត រមែងមិនដល់សេចក្ដីសុខ
អស់កាលជានិច្ច ព្រោះបញ្ញាជាគ្រឿងបញ្ឆោតឡើយ បុគ្គល
មានប្រាជ្ញាជាគ្រឿងបញ្ឆោត ( នោះ ) រមែងបាន ( នូវលទ្ធ-
ផលអាក្រក់ ) ដូចសត្វកុក ( បាននូវការដាច់ក ) អំពីក្ដាម ។

បណ្ដាបទទាំងនោះ បទថា **នាច្ចន្តំ និកតិប្បញ្ញោ និកត្យា សុខមេធតិ** សេចក្ដីថា ការបោកបញ្ឆោតហៅថា **និកតិ** បុគ្គលដែលមានបញ្ញាឈ្មោះថា **និកតិ** គឺបុគ្គលដែលមានបញ្ញាបោកបញ្ឆោត រមែងមិនដល់នូវសេចក្ដីសុខដោយចំណែកមួយ គឺមិនអាចតាំងនៅក្នុងសេចក្ដីសុខនោះឯងអស់កាលជានិច្ច ព្រោះការបោកបញ្ឆោត គឺការកុហកនោះ រមែងដល់នូវសេចក្ដីវិនាសដោយចំណែកមួយប៉ុណ្ណោះ ។

បទថា **អារាធេតិ** ប្រែថា រមែងបានចំពោះ អធិប្បាយថា បុគ្គលលាមក មានបញ្ញាបោកបញ្ឆោត គឺបញ្ញាដែលសិក្សានូវផ្លូវវៀចផ្លូវកោងរមែងបានចំពោះ គឺរមែងជួបនូវផលបាបដែលខ្លួនបានធ្វើទុក ។

*សួរថា រមែងជួបនូវផលបាបដូចម្តេច ?*

*ឆ្លើយថា រមែងជួបនូវផលបាបដូចកុក ដែលដាច់កព្រោះក្តាមដូច្នោះ អធិប្បាយថា បាបបុគ្គលរមែងជួប គឺរមែងបានចំពោះនូវភ័យក្នុងបច្ចុប្បន្ន ឬក្នុងបរលោក ព្រោះបាបដែលខ្លួនធ្វើទុក ដូចកុកដែលត្រូវកាត់កដាច់ព្រោះក្តាមដូច្នោះ ។ ព្រះមហាសត្វ កាលប្រកាសគាថានេះទើបសម្តែងធម៌ញ៉ាំងព្រៃឲ្យខ្ទរខ្ទារហើយ ។*

*ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចីវរវឌ្ឍកភិក្ខុអ្នកក្រុង ត្រូវចីវរវឌ្ឍកៈអ្នកស្រុកក្រៅបោកយ៉ាងនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែនទេ សូម្បីក្នុងអតីតកាល ក៏ត្រូវបោកហើយដូចគ្នា ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា កុកក្នុងកាលនោះ បានមកជាចីវរវឌ្ឍកៈអ្នកនៅក្នុងវត្តជេតពន ក្តាមក្នុងកាលនោះ បានមកជាចីវរ - វឌ្ឍកៈអ្នកស្រុកក្រៅ ចំណែករុក្ខទេវតាក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា ពកជាតក ទី ៨ ។

# អដ្ឋកថា នន្ទជាតក ទី ៩

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះសារីបុត្តត្ថេរ ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **មញ្ញេ សោវណ្ណយោ រាសិ** ដូច្នេះជាដើម ។

បានឮថា ភិក្ខុនោះជាអ្នកប្រដៅងាយ អត់ធន់ចំពោះពាក្យប្រៀនប្រដៅ ធ្វើឧបការៈដល់ព្រះថេរៈដោយឧស្សាហៈដ៏ច្រើន ។ សម័យថ្ងៃមួយ ព្រះថេរៈលាព្រះសាស្តាចារិកទៅ បានទៅកាន់ទក្ខិណាគិរីជនបទ ។ ក្នុងវេលាដែលព្រះថេរៈទៅកាន់ទក្ខិណាគិរីជនបទនោះ ភិក្ខុនោះ ក៏ក្លាយជាអ្នកប្រកាន់ខ្លួនមិនធ្វើតាមពាក្យរបស់លោក កាលព្រះថេរៈពោលថា អាវុសោ អ្នកចូរធ្វើកម្មឈ្មោះនេះ ក៏បានជាចំណែកផ្ទុយ ព្រះថេរៈមិនដឹងអធ្យាស្រ័យរបស់ភិក្ខុនោះ ត្រាច់ទៅក្នុងទក្ខិណាគិរីជនបទហើយវិលត្រឡប់មកកាន់វត្តជេតពនវិញ ចាប់តាំងអំពីព្រះថេរៈមកកាន់វត្តជេតពនមហាវិហារ ភិក្ខុនោះក៏មានសភាពដូច្នោះវិញ ។ ព្រះថេរៈក៏ក្រាបទូលរឿងនោះដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សទ្ធិវិហារិកមួយរូបរបស់ខ្ញុំព្រះអង្គ ក្នុងទីមួយកន្លែងមានសភាពដូចជាទាសៈដែលលោះមកដោយទ្រព្យ ១០០ ប៉ុន្តែក្នុងទីមួយកន្លែង ក៏ក្លាយជាអ្នកប្រកាន់ខ្លួន កាលខ្ញុំព្រះអង្គប្រាប់ថា ចូរធ្វើកម្មឈ្មោះនេះ ក៏ត្រឡប់ជាធ្វើផ្ទុយអំពីនោះ ។ ព្រះបរមសាស្តាត្រាស់ថា ម្នាលសារីបុត្ត ភិក្ខុនេះជាអ្នកមាន

ប្រក្រតីយ៉ាងនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះ ក៏មិនមែន សូម្បីក្នុងកាលមុន ភិក្ខុនេះនៅក្នុងទីមួយកន្លែងហាក់ដូចជាទាសៈ ដែលលោះមកដោយទ្រព្យ ១០០ តែទៅកាន់ទីមួយកន្លែងទៀត ត្រឡប់ជាមានការប្រព្រឹត្តផ្ទុយជាសត្រូវ កាលព្រះថេរៈក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្តែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលកុដុម្ពិកៈមួយ ។ កុដុម្ពិកៈម្នាក់ដែលជាសម្លាញ់របស់ព្រះពោធិសត្វនោះជាមនុស្សចាស់ តែភរិយារបស់កុដុម្ពិកៈនោះជាស្ត្រីក្មេង នាងអាស្រ័យកុដុម្ពិកៈនោះក៏បានកូនប្រុស កុដុម្ពិកៈនោះគិតថា ស្រីនេះ កាលអញស្លាប់ទៅហើយនឹងបានបុរសដទៃជាស្វាមី ព្រោះខ្លួននៅក្មេង នឹងធ្វើទ្រព្យរបស់អញនេះឲ្យវិនាស មិនឲ្យដល់បុត្តរបស់អញ បើដូច្នោះ អញកប់ទ្រព្យនេះទុកក្នុងផែនដី ទើបហៅទាសៈក្នុងផ្ទះឈ្មោះនាយនន្ទៈទៅព្រៃ កប់ទ្រព្យនោះទុកមួយកន្លែងហើយប្រាប់ដល់នាយនន្ទៈនោះដោយពាក្យថា នែនន្ទៈ ទ្រព្យនេះ កាលអញស្លាប់ទៅហើយ ចូរឯងប្រាប់ដល់កូនរបស់អញ កុំបរិច្ចាគទ្រព្យនេះរបស់អញឡើយ ហើយក៏ស្លាប់ទៅ ។ កូនរបស់កុដុម្ពិកៈនោះ ជាអ្នកចម្រើនដោយវ័យតាមលំដាប់ ។ សម័យនោះ មាតាក៏ពោលនឹងបុត្តនោះថា

នែបា បិតារបស់កូននាំនន្ទទាសៈទៅកប់ទ្រព្យ ចូរកូននាំទ្រព្យ

នោះមកទុកជាសម្បត្តិ ។ ថ្ងៃមួយ កូននោះពោលនឹងទាសៈឈ្មោះនន្ទៈ នោះថា បពិត្រលោកអ៊ំ ទ្រព្យណាមួយដែលលោកឪពុករបស់ខ្ញុំកប់ទុក មានឬ ?

នន្ទទាសៈពោលថា មានលោកម្ចាស់ ។

កូនសេដ្ឋីនោះសួរថា កប់ទុកក្នុងទីណា ?

នន្ទទាសៈឆ្លើយថា នៅក្នុងព្រៃឯណោះ ។

កូនសេដ្ឋីនោះពោលថា បើដូច្នោះ ពួកយើងនាំគ្នាទៅ ហើយកាន់ចបនិងបង្គីទៅកាន់ទីកប់ទ្រព្យ ។ ( លុះទៅដល់ហើយ ) កូនសេដ្ឋីនោះសួរថា **កហំ មាតុល ធនំ** ទ្រព្យនៅក្នុងទីណាលោកអ៊ំ ?

នាយនន្ទៈនោះឡើងឈរលើកំណាប់ទ្រព្យ អាស្រ័យទ្រព្យធ្វើមានះឲ្យកើតឡើងជេរកុមារនោះថា **អរេ ទាសិបុត្ត ចេតក កុតោ តេ ឥមស្មឹ ឋានេ ធនំ** នែអាកូនទាសី ទ្រព្យក្នុងទីនេះរបស់អា មានមកអំពីណា ?

កុមារនោះ បានឮពាក្យគ្រោតគ្រាតហើយពោលថា បើយ៉ាងនោះ ពួកយើងនាំគ្នាត្រឡប់ចុះ ហើយនាំនាយនន្ទៈនោះត្រឡប់មក ។ កន្លងទៅពីរ-បីថ្ងៃ ក៏បានទៅទៀត នាយនន្ទៈនោះឈរជេរយ៉ាងនោះឯង កុមារមិនពោលពាក្យគ្រោតគ្រាតជាមួយទាសៈនោះ ដោយគិតថា ទាសៈនោះនឹងប្រាប់ទ្រព្យក្នុងពេលឈ្មោះនេះ ប៉ុន្តែទាសៈនោះក៏នៅតែជេរ កុមារ

មិនដឹងហេតុ ក្នុងសេចក្ដីនោះ ក៏គិតថា កុដុម្ពិកៈជាសម្លាញ់របស់បិតាអញមាន អញគួរសាកសួរនឹងកុដុម្ពិកៈនោះ ប្រហែលជាដឹងបាន ទើបទៅកាន់សម្នាក់របស់ព្រះបរមពោធិសត្វប្រាប់រឿងរ៉ាវទាំងអស់ ហើយសួរថា បពិត្រលោកឪពុក ព្រោះហេតុអ្វីហ្ន៎ ?

ព្រះមហាសត្វពោលថា នែបា នាយនន្ទៈនោះ ឈរជេរអ្នកក្នុងទីណា ទ្រព្យដែលជារបស់បិតារបស់អ្នកនៅក្នុងទីនោះឯង ព្រោះដូច្នោះ ក្នុងកាលណានាយនន្ទៈនោះជេរ ក្នុងកាលនោះ អ្នកចូរអូសនាយនន្ទៈនោះមកដោយពាក្យថា នែទាសៈ អ្នកជេរខ្ញុំ ហើយកាន់យកចបជីកទម្លាយក្នុងទីនោះ នាំយកទ្រព្យដែលជារបស់ត្រកូលមកចុះ កាលពោលដូច្នេះហើយ ទើបពោលគាថានេះថា

**មញ្ញេ សោវណ្ណយោ រាសិ សោវណ្ណមាលា ច នន្ទកោ**
**យត្ថ ទាសោ អាមជាតោ ឋិតោ ថុល្លានិ គជ្ជតីតិ ។**

យើងសម្គាល់ថា គំនរមាស និងកម្រងមាស មានក្នុងទីដែលខ្ញុំប្រុសឈ្មោះនន្ទកៈ ជាកូនរបស់ខ្ញុំស្រី ឈ្មោះអាមា ឈរពោលនូវពាក្យអាក្រក់នោះ ។

បណ្ដាបទទាំងនោះ បទថា **មញ្ញេ** ប្រែថា ខ្ញុំដឹងយ៉ាងនេះ ។

បទថា **សោវណ្ណយោ** សេចក្ដីថា ឈ្មោះថាសុវណ្ណ ព្រោះមានពណ៌ល្អ ។

សួរថា សុវណ្ណនោះ គឺអ្វី?

ឆ្លើយថា គឺរតនៈទាំងឡាយ មានប្រាក់ កែវមណី មាស និង កែវប្រពាលជាដើម ក្នុងឋានៈនេះ លោកបំណងយករតនៈទាំងអស់ ថា សុវណ្ណ គំនរនៃរតនៈទាំងនោះ ឈ្មោះថា **សោវណ្ណយ រាសិ** ប្រែថា គំនររតនៈដែលមានពណ៌ល្អ ។

បទថា **សោវណ្ណមាលា ច** សេចក្ដីថា ខ្ញុំរមែងដឹងថា សូម្បីកម្រងផ្កាមាសដែលជាទ្រព្យនៃបិតារបស់អ្នក ក៏មាននៅក្នុងទីនោះដូចគ្នា ។

បទថា **ឆន្នកោ យត្ថ ជាសោ** សេចក្ដីថា ទាសៈឈ្មោះនន្ទៈ ឈរក្នុងទីណា ។

បទថា **អាមជាតោ** សេចក្ដីថា បុត្តរបស់ទាសី ពោលគឺនាងអាមទាសី ព្រោះចូលដល់ភាពជាទាសៈ ដោយការពោលយ៉ាងនេះថា **អាម អហំ ភោ ជាសិ** ចាស ខ្ញុំជាទាសីរបស់លោក ។

បទថា **ឋិតោ ថុល្លានិ គជ្ជតិ** សេចក្ដីថា ទាសៈឈ្មោះនន្ទៈនោះ ឈរក្នុងទីណាពោលពាក្យគ្រោតគ្រាត គឺពាក្យទ្រគោះបោះបោក ទ្រព្យដែលជារបស់ត្រកូលនៃអ្នក មានក្នុងទីនោះឯង ខ្ញុំដឹងទ្រព្យនោះយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះពោធិសត្វប្រាប់ឧបាយជាគ្រឿងកាន់យកទ្រព្យដល់កុមារ ។

កុមារថ្វាយបង្គំព្រះពោធិសត្វហើយទៅកាន់ផ្ទះ នាំនាយនន្ទៈទៅ

*កាន់ទីកប់ទ្រព្យ បដិបត្តិតាមដែលព្រះពោធិសត្វប្រៀនប្រដៅ ហើយនាំយកទ្រព្យនោះមកទុកជាសម្បត្តិ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើម ក្នុងវេលាអស់ជីវិតក៏ទៅតាមយថាកម្ម ។*

*ព្រះបរមសាស្តាត្រាស់ថា ក្នុងកាលមុនសទ្ធិវិហារិករបស់សារីបុត្តនេះ ក៏ជាអ្នកមានប្រក្រតីយ៉ាងនេះដូចគ្នា ។*

*ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់បន្តអនុសន្ធិប្រជុំជាតកថា ទាសៈឈ្មោះនន្ទៈក្នុងកាលនោះ បានមកជាសទ្ធិវិហារិករបស់សារីបុត្ត កូនរបស់កុដុម្ពិកៈក្នុងកាលនោះ បានមកជាសារីបុត្ត ចំណែកកុដុម្ពិកៈដែលជាបណ្ឌិតក្នុងកាលនោះ គឺ* **តថាគត** *នេះឯង ៕*

ចប់ អដ្ឋកថា នន្ទជាតក ទី ៩ ។

# អដ្ឋកថា ខទិរង្គារជាតក ទី ១០

ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធទានរបស់អនាថបិណ្ឌិកសេដ្ឋី ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កាមំ បតាមិ និរយំ** ដូច្នេះជាដើម ។

សេចក្តីពិស្តារថា អនាថបិណ្ឌិកសេដ្ឋី ប្រារព្ធចំពោះវិហារប៉ុណ្ណោះផ្តើមសាបព្រោះនូវទ្រព្យ ៥៤ កោដិទុកក្នុងព្រះពុទ្ធសាសនា មិនបានធ្វើនូវការសម្គាល់ក្នុងវត្ថុដទៃថាជារតនៈ ក្រៅអំពីរតនៈទាំង ៣ នេះឡើយ កាលព្រះបរមសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន រមែងទៅកាន់ទីបម្រើធំ ៣ ដងក្នុងមួយថ្ងៃ ពេលព្រឹកទៅម្តង ទទួលទានអាហារព្រឹកហើយទៅម្តង ពេលល្ងាចទៅម្តង ឯក្នុងទីបម្រើក្នុងទីដទៃក៏ដូចគ្នា កាលនឹងទៅក៏មិនធ្លាប់ទៅដៃទទេ ដោយគិតថា សាមណេរឬភិក្ខុកំលោះទាំងឡាយកាលបើអាត្មាអញទៅហើយ គប្បីសម្លឹងមើលដៃរបស់អាត្មាអញដោយគិតថា លោកសេដ្ឋីកាន់អ្វីមកហ្ន៎ កាលទៅពេលព្រឹកឲ្យមនុស្សរែកបបរទៅ ទទួលទានអាហារព្រឹកហើយកាលនឹងទៅ ក៏ឲ្យមនុស្សកាន់សប្បិនវនីត ទឹកឃ្មុំ និងទឹកអំពៅជាដើមទៅ កាលនឹងទៅក្នុងវេលាល្ងាច ក៏កាន់គ្រឿងក្រអូប ផ្កាកម្រង និងសំពត់ កាលលោកសេដ្ឋីនោះ បរិច្ចាគទានរាល់ៗ ថ្ងៃ ប្រមាណក្នុងការបរិច្ចាគរមែងមិនមាន ។ ចំណែកមនុស្សដែលអាស្រ័យការលក់ដូរចិញ្ចឹមជីវិតជាច្រើន ធ្វើបញ្ជីទុកក្នុងដៃរបស់

លោកសេដ្ឋី ខ្ចីទ្រព្យទៅប្រមាណ ១៨ កោដិ លោកសេដ្ឋីឲ្យទារយកទ្រព្យអំពីមនុស្សទាំងនោះមក ( តែទារមិនបាន ) ម្យ៉ាងទៀត ទ្រព្យ ១៨ កោដិដទៃទៀត ដែលជាទ្រព្យប្រចាំត្រកូលរបស់សេដ្ឋីនោះ កប់ទុកត្រង់ច្រាំងស្ទឹង ទឹកស្ទឹងអចិរវតីក៏ច្រោះទម្លាយទីកប់ទ្រព្យ ទ្រព្យទាំងនោះក៏ហូរទៅកាន់មហាសមុទ្ទ ក្អមដែលដាក់ទ្រព្យតាមប្រក្រតីបិទទុកនិងបោះត្រាចំណាំនោះ ក៏រមៀលទៅក្នុងសមុទ្ទដែរ ។ ក្នុងផ្ទះរបស់សេដ្ឋីនោះមាននិច្ចភត្តជាប្រចាំសម្រាប់ភិក្ខុ ៥០០ រូប ពិតហើយ ផ្ទះរបស់សេដ្ឋីដូចគ្នានឹងស្រះបោក្ខរណីដែលជីកទុកក្នុងផ្លូវធំមានមុម ៤ សម្រាប់ភិក្ខុសង្ឃតាំងនៅក្នុងឋានៈជាមាតាបិតានៃភិក្ខុទាំងពួង ដោយហេតុនោះ សូម្បីព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់យាងទៅកាន់ផ្ទះរបស់សេដ្ឋីនោះ ចំណែកព្រះមហាថេរ ៨០ អង្គក៏ដូចគ្នា ឯភិក្ខុទាំងឡាយដ៏សេស មកហើយទៅ ទៅហើយមក មានប្រមាណមិនបាន ។

ផ្ទះនោះមាន ៧ ជាន់ ឯខ្លោងទ្វារក៏មាន ៧ ជាន់ មានទេវតាដែលជាមិច្ឆាទិដ្ឋិមួយអង្គអាស្រ័យនៅត្រង់ខ្លោងទ្វារជាន់ទី ៤ នៃផ្ទះនោះ ទេវតានោះ កាលព្រះសម្មាសម្ពុទ្ធទ្រង់យាងចូលផ្ទះនិងយាងចេញ មិនអាចតាំងនៅក្នុងវិមានរបស់ខ្លួនកាន់ដៃទារកចុះមកឈរលើផែនដី កាលព្រះមហាថេរ ៨០ អង្គចូលទៅនិងចេញមក ក៏ធ្វើយ៉ាងនោះដូចគ្នា ។ ទេវតានោះគិតថា កាលព្រះសមណគោតម និងពួកសាវករបស់ព្រះសមណគោតម

នោះ ចេញចូលក្នុងផ្ទះនេះ ឈ្មោះថា សេចក្ដីសុខរបស់អាត្មាអញមិនមាន អញមិនអាចចុះមកឈរលើផែនដីអស់កាលជានិច្ចបានឡើយ អញនឹងធ្វើដោយប្រការដែលសមណៈទាំងនេះ ចូលមកក្នុងផ្ទះនេះមិនបាន ទើបគួរ ។ ថ្ងៃមួយ ទេវតានោះក៏ទៅកាន់សម្នាក់របស់មហាកម្មន្តិកៈ ( អ្នកជំនួយការ ) ដែលកំពុងដេក ហើយឈរផ្សាយឱភាស កាលមហាកម្មន្តិកៈសួរថា អ្នកជានរណា ?

ទេវតានោះក៏ពោលថា ខ្ញុំជាទេវតា កើតត្រង់ខ្លោងទ្វារជាន់ទី ៤ ។

មហាកម្មន្តិកៈពោលថា អ្នកមកព្រោះហេតុអ្វី ?

ទេវតាពោលថា លោកមិនឃើញការធ្វើរបស់លោកសេដ្ឋីទេឬ ? លោកសេដ្ឋីមិនសម្លឹងមើលកាលដែលមានក្នុងកាលជាខាងក្រោយ នាំទ្រព្យចេញមកចំពោះព្រះសមណគោតមប៉ុណ្ណោះឲ្យពេញបរិបូណ៌ មិនប្រកបការជួញដូរ មិនផ្ដើមធ្វើការងារ លោកចូរឲ្យដំបូន្មានដល់សេដ្ឋី លោកចូរធ្វើដោយប្រការដែលសេដ្ឋីធ្វើការងាររបស់ខ្លួន នឹងធ្វើឲ្យព្រះសមណគោតមព្រមទាំងសាវក មិនចូលមកកាន់ផ្ទះនេះ ។ លំដាប់នោះ មហាកម្មន្តិកៈបានពោលនឹងទេវតានោះថា នែបុគ្គលអន្ធពាល លោកសេដ្ឋី កាលលះទ្រព្យ ក៏លះក្នុងព្រះពុទ្ធសាសនាដែលជាគ្រឿងនាំសត្វចេញចាកទុក្ខ លោកសេដ្ឋីនោះ ទោះបីចាប់ខ្ញុំត្រង់ផ្នួងសក់យកទៅលក់ ( ដើម្បីយកទ្រព្យមកធ្វើទាន ) ក៏ខ្ញុំមិនពោលពាក្យអ្វីឡើយ ចូរអ្នកទៅ

ចុះ ។ ក្រោយមក ទេវតានោះ ចូលទៅរកកូនប្រុសច្បងរបស់លោកសេដ្ឋី ហើយពោលដូចគ្នា ចំណែកបុត្តសេដ្ឋីក៏គំរាមទេវតានោះ ដោយន័យមុន នោះឯង ។ បន្ទាប់អំពីនោះមក ទេវតានោះមិនអាចពោលនឹងសេដ្ឋីបាន ឡើយ ចំណែកសេដ្ឋីឲ្យទានមិនដាច់ មិនធ្វើនូវជំនួញជួញដូរ កាលទ្រព្យ សម្បត្តិមានតិច ទ្រព្យក៏ដល់នូវការអស់ទៅ កាលសេដ្ឋីដល់នូវសភាពក្រី-ក្រដោយលំដាប់ សំពត់សាដក ទីដេកនិងភោជនដែលជាគ្រឿងបរិភោគ ប្រើប្រាស់ មិនដូចក្នុងកាលមុន សេដ្ឋីទោះបីជាមានសភាពបែបនេះ ក៏ នៅតែឲ្យទានដល់ភិក្ខុសង្ឃ តែមិនអាចឲ្យទានដ៏ប្រណីតៗ បាន ។ ថ្ងៃ មួយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរសេដ្ឋីដែលថ្វាយបង្គំហើយអង្គុយ ថា នែគហបតី ទានក្នុងត្រកូលរបស់អ្នកនៅប្រព្រឹត្តទៅឬ ?

សេដ្ឋីក្រាបទូលថា នៅព្រះអង្គ តែទានក្នុងកាលឥឡូវនេះ ជាទាន សៅហ្មង ជាបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ពីរ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងសេដ្ឋីថា នែគហបតី អ្នកកុំធ្វើចិត្តឲ្យសាំញ៉ាំឡើយ ថា អញឲ្យទានសៅហ្មង ដ្បិតថា បុគ្គលកាលមានចិត្តស្អាតបរិសុទ្ធ ទាន ដែលឲ្យដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវកទាំងឡាយ ឈ្មោះថា សៅហ្មងមិនមានឡើយ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះមានផលច្រើន សេចក្តីនេះ គួរជ្រាបយ៉ាងនេះ

*កាលអាចធ្វើចិត្តឲ្យប្រណីត ទានឈ្មោះថា សៅហ្មងមិនមានឡើយ សម ដូចព្រះតម្រាស់ថា*

**នត្ថិ ចិត្តេ បសន្នម្ហិ អប្បកា នាម ទក្ខិណា**
**តថាគតេ វា សម្ពុទ្ធេ អថ វា តស្ស សាវកេ ។**

*កាលបើចិត្តជ្រះថ្លា ចំពោះព្រះតថាគតជាសម្ពុទ្ធ ឬសាវក របស់ព្រះតថាគតហើយ ទក្ខិណាទានឈ្មោះថា មានផល តិចមិនមែនឡើយ* [១] ។

**ន កិរត្ថិ អនោមទស្សិសុ**
**បារិចរិយា ពុទ្ធេសុ អប្បកា**
**សុក្ខាយ អលោណិកាយ ច**
**បស្ស ផលំ កុម្មាសបិណ្ឌិយា ។**

*បានឮថា ការបម្រើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោក មានពោធិញ្ញាណ មិនថោកថយ មិនមែនមានផលានិសង្ស តិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលសោះ កក្រោះ ឥតរសប្រៃ* [២] ។

*ម្យ៉ាងទៀត ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី អ្នកឲ្យទាន*

---

*១- បិ. ៥៥ , ទំ. ១០០ ។ ២- បិ. ៥៩ , ទំ. ១០៧ ។*

សៅហ្មង ក៏គង់បានឲ្យដល់ព្រះអរិយបុគ្គល ៨ ពួក ឯតថាគត កាលនៅជាវេលាមព្រាហ្មណ៍ បានឲ្យរតនៈ ៧ ប្រការ ធ្វើជម្ពូទ្វីបទាំងមូល មិនចាំបាច់ឲ្យធ្វើស្រែ ញុំាងមហាទានឲ្យប្រព្រឹត្តទៅហូរដូចស្ទឹងធំ ៥ ខ្សែ ដែលប្រសព្វមុខតែមួយ ក៏មិនបានទក្ខិណេយ្យបុគ្គល សូម្បីតែដល់សរណៈ ៣ ឬជាអ្នកមានសីល ៥ ឡើយ ឈ្មោះថា បុគ្គលគួរដល់ទក្ខិណារកបានលំបាកយ៉ាងនេះ ព្រោះដូច្នោះ អ្នកកុំធ្វើចិត្តឲ្យស្មុគស្មាញ ថាទានរបស់អញសៅហ្មង ព្រះដ៏មានព្រះភាគ កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់វេលាមសូត្រ ។

កាលមុនទេវតានោះ មិនអាចពោលជាមួយសេដ្ឋី ក្នុងកាលដែលសេដ្ឋីនៅមានភាពជាធំ សម្គាល់ថា ឥឡូវនេះ សេដ្ឋីនេះនឹងជឿពាក្យរបស់ខ្លួន ព្រោះជាអ្នកធ្លាក់ខ្លួនក្រីក្រ ។ ក្នុងវេលាអធ្រាត្រក៏ចូលទៅកាន់បន្ទប់ដ៏មានសិរី ផ្សាយរស្មីឈរក្នុងអាកាស សេដ្ឋីឃើញដូច្នោះ ក៏សួរថា

អ្នកជានរណា ?

ទេវតានោះឆ្លើយថា លោកមហាសេដ្ឋី ខ្ញុំជាទេវតាអាស្រ័យត្រង់ខ្លោងទ្វារទី ៤ របស់លោក ។

សេដ្ឋីពោលថា អ្នកមកបំណងអ្វីហ្ន: ?

ទេវតាពោលថា ខ្ញុំបំណងមកទូន្មានលោក ។

សេដ្ឋីពោលថា បើយ៉ាងនោះ ចូរពោលមកចុះ ។

ទេវតាពោលថា នៃមហាសេដ្ឋី លោកមិនគិតដល់ពេលមុខ ពេលក្រោយ មិនគិតដល់បុត្តធីតា ខ្ជះខ្ជាយទ្រព្យ គឺបាចសាចចុះក្នុងព្រះពុទ្ធសាសនា គឺសាសនារបស់ព្រះសមណគោតម លោកធ្លាក់ខ្លួនជាបុគ្គលក្រីក្រ ព្រោះអាស្រ័យព្រះសមណគោតម ព្រោះលះទ្រព្យគ្មានព្រំដែន និងមិនធ្វើការជួញដូរប្រកបការងារឯណាទីមួយ ទោះបីជាធ្លាក់ខ្លួនដល់ម៉្លេះ ក៏លោកមិនលះបង់ព្រះសមណគោតម សព្វថ្ងៃនេះ សមណៈទាំងនោះ ក៏នៅតែចេញចូលក្នុងផ្ទះនោះឯង ទ្រព្យដែលពួកសមណៈទាំងនោះនាំយកទៅហើយ បុគ្គលមិនអាចនាំត្រឡប់មកបាន តាំងអំពីពេលនេះទៅ ខ្លួនលោកកុំគប្បីទៅកាន់សម្នាក់របស់ព្រះសមណគោតម ទាំងកុំគប្បីឲ្យសាវ័កទាំងឡាយរបស់ព្រះសមណគោតមនោះ ចូលមកក្នុងផ្ទះនេះ លោកសូមឲ្យព្រះសមណគោតមត្រឡប់ទៅហើយ ក៏កុំក្រឡេកមើល ចូរធ្វើនូវការប្តឹងទារទ្រព្យនិងការជួញដូររបស់ខ្លួនប្រមូលទ្រព្យសម្បត្តិចុះ ។

សេដ្ឋីពោលនឹងទេវតានោះថា នេះឬជាឱវាទរបស់អ្នក?

ទេវតាពោលថា អើ នេះជាឱវាទ ។

សេដ្ឋីពោលថា នៃទេវតា ខ្ញុំដែលព្រះមានព្រះភាគ ទ្រង់ធ្វើឲ្យជាបុគ្គលដែលទេវតាដូចអ្នក រាប់រយ រាប់ពាន់ រាប់សែន ធ្វើឲ្យញាប់ញ័រមិនបាន ឯសទ្ធារបស់ខ្ញុំមិនឃ្លេងឃ្លោងតាំងមាំល្អដូចភ្នំព្រះសិនេរុ ខ្ញុំលះ

បង់ទ្រព្យក្នុងរតនសាសនាដែលជាគ្រឿងនាំសត្វចេញចាកទុក្ខ អ្នកពោល ពាក្យមិនគួរ អ្នកមិនមានអាចារៈ ជាបុគ្គលទ្រុស្តសីល ជាកាឡកណ្ណីបែប នេះ ឲ្យនូវការប្រហារដល់ព្រះពុទ្ធសាសនា ខ្ញុំមិនមានកិច្ច គឺការនៅក្នុង ផ្ទះជាមួយអ្នក ចូរអ្នកប្រញាប់ចេញអំពីផ្ទះរបស់ខ្ញុំទៅកាន់ទីដទៃចុះ ។ ទេវតានោះបានស្តាប់ពាក្យរបស់អរិយសាវក ដែលជាសោតាបន្នមិនអាច តាំងនៅបាន ទើបទៅកាន់លំនៅរបស់ខ្លួន ហើយដឹកដៃទារកចេញទៅ កាលចេញទៅហើយមិនបានទីលំនៅដទៃ គិតថា អញនឹងឲ្យសេដ្ឋីអត់ ទោសហើយសូមខ្ទោងទ្វារនោះរស់នៅ ទើបទៅកាន់សម្នាក់ទេវបុត្តដែល រក្សានគរ ថ្វាយបង្គំទេវបុត្តនោះហើយឈរ ទេវបុត្តរក្សានគរសួរថា

អ្នកមកព្រោះអ្វី ?

ទេវតានោះឆ្លើយថា លោកម្ចាស់ ខ្ញុំមិនបានពិចារណា និយាយ ជាមួយលោកអនាថបិណ្ឌិកសេដ្ឋី លោកអនាថបិណ្ឌិកសេដ្ឋីនោះ ក្រោធ នឹងខ្ញុំ បណ្តេញខ្ញុំចេញអំពីលំនៅ សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់ លោកសេដ្ឋីឲ្យគាត់អត់ទោស ហើយឲ្យលំនៅដល់ខ្ញុំវិញ ។

ទេវបុត្តរក្សាព្រះនគរសួរថា អ្នកនិយាយដូចម្តេចជាមួយលោក សេដ្ឋីហ: ?

ទេវតានោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំពោលនឹងលោកសេដ្ឋី យ៉ាងនេះថា បពិត្រលោកសេដ្ឋី តាំងអំពីនេះទៅ លោកកុំធ្វើការឧបដ្ឋាក

ដល់ព្រះពុទ្ធនិងព្រះសង្ឃ លោកកុំឲ្យព្រះសមណគោតមចូលក្នុងផ្ទះ ។

ទេវបុត្តអ្នករក្សាទ្វារពោលថា អើអ្នកពោលពាក្យនោះមិនសមគួរ អ្នកឲ្យនូវការប្រហារក្នុងសាសនា ខ្ញុំមិនអាចនាំអ្នកទៅកាន់សម្នាក់របស់លោកសេដ្ឋីបានទេ ។ ទេវតានោះ មិនបានការជួយអំពីសម្នាក់របស់ទេវបុត្តនោះ ក៏ទៅកាន់សម្នាក់មហារាជទាំងបួន សូម្បីមហារាជទាំងបួនក៏បដិសេធយ៉ាងនោះ ទើបចូលទៅគាល់សក្កទេវរាជក្រាបទូលរឿងនោះហើយអង្វរថា បពិត្រទេវរាជ ខ្ញុំមិនបានទីលំនៅ ដឹកដៃទារកដើរអនាថា សូមទ្រង់ញ៉ាំងលោកសេដ្ឋីឲ្យអនុគ្រោះ ឲ្យនូវលំនៅដល់ខ្ញុំផងចុះ ដោយបុណ្យរបស់ទ្រង់ ។

សក្កទេវរាជត្រាស់នឹងទេវតានោះថា អ្នកធ្វើកម្មមិនសមគួរ អ្នកឲ្យនូវការប្រហារក្នុងសាសនារបស់ព្រះជិនស្រី ឯយើងក៏មិនអាចពោលនឹងសេដ្ឋីព្រោះអាស្រ័យអ្នក តែយើងនឹងប្រាប់ឧបាយណាមួយឲ្យសេដ្ឋីនោះអត់ទោសដល់អ្នក ។

ទេវតានោះក្រាបទូលថា សាធុ ទេវៈ សូមព្រះអង្គត្រាស់ប្រាប់ឧបាយនោះមកចុះ ។

សក្កទេវរាជក៏ត្រាស់ថា មនុស្សទាំងឡាយយកបញ្ជីទុកក្នុងដៃរបស់លោកសេដ្ឋី កាន់យកទ្រព្យ ១៨ កោដិ គឺខ្ចីទ្រព្យ ១៨ កោដិមានចូរអ្នកកាឡាខ្លួនជាស្មៀនរបស់សេដ្ឋីនោះ កុំឲ្យអ្នកណាស្គាល់ កាន់យក

បញ្ជីទាំងនោះ ដែលមានពួកយក្សកំលោះៗ ពីរ-បីនាក់ចោមរោម ដែមួយកាន់បញ្ជី ដៃមួយកាន់ដែកចារ ទៅកាន់ផ្ទះរបស់មនុស្សទាំងនោះ ឈរត្រង់កណ្តាលផ្ទះ ធ្វើមនុស្សទាំងនោះឲ្យភ័យខ្លាចដោយអានុភាពរបស់យក្ស ហើយទារយកបំណុល ១៨ កោដិ ធ្វើឃ្លាំងរបស់មហាសេដ្ឋីឲ្យពេញ ម្យ៉ាងទៀត ទ្រព្យដែលកប់ទុកត្រង់ឆ្នេរស្ទឹងអចិរវតីក៏មាន ទ្រព្យនោះត្រូវទឹកស្ទឹងហូរបន្សាត់ទៅកាន់មហាសមុទ្ទ ចូរអ្នកនាំយកទ្រព្យនោះមកដោយអានុភាពរបស់ខ្លួនដាក់ចូលក្នុងឃ្លាំងឲ្យពេញ ទ្រព្យដទៃទៀតប្រមាណ ១៨ កោដិ ជាទ្រព្យមិនមានម្ចាស់ថែរក្សា ក្នុងទីឈ្មោះឯណោះ ចូរអ្នកនាំទ្រព្យនោះមកធ្វើឃ្លាំងទទេឲ្យពេញ អ្នកចូរធ្វើឃ្លាំងទទេឲ្យពេញដោយទ្រព្យ ៥៤ កោដិ នេះឯងជាទណ្ឌកម្ម ហើយសឹមចូលទៅរកលោកមហាសេដ្ឋីឲ្យគាត់អត់ទោសឲ្យ ។

ទេវតានោះ ទទួលពាក្យរបស់សក្កទេវរាជថា សាធុ សាធុ ហើយនាំទ្រព្យមកទាំងអស់ ដោយន័យដូចពោលមកនោះឯង ។ ក្នុងវេលាកណ្តាលអធ្រាត្រ ក៏ចូលទៅកាន់បន្ទប់ដ៏មានសិរីរបស់សេដ្ឋី បានផ្សាយរស្មីហើយឈរនៅក្នុងអាកាស លោកសេដ្ឋីសួរថា អ្នកជានរណា ?

ទេវតាឆ្លើយថា លោកមហាសេដ្ឋី ខ្ញុំគឺទេវតាល្ងង់ដែលបិតនៅត្រង់ខ្លោងជាន់ទ្វារទី ៤ របស់លោក ខ្ញុំជាអ្នកវង្វេងព្រោះមោហៈ មិនស្គាល់គុណរបស់ព្រះពុទ្ធទាំងឡាយ បានពោលពាក្យណាមួយជាមួយ

លោកក្នុងកាលមុន សូមលោកអត់ទោសនោះដល់ខ្ញុំ ខ្ញុំនាំទ្រព្យ ៥៤ កោដិមកតាមព្រះតម្រាស់របស់សក្កទេវរាជ ទ្រព្យ ១៨ កោដិជាទ្រព្យដែលជម្រះបំណុល ទ្រព្យ ១៨ កោដិដែលជាទ្រព្យមិនមានម្ចាស់ក្នុងទីឈ្មោះឯណោះ និងធ្វើទណ្ឌកម្ម គឺប្រមូលទ្រព្យដែលហូរទៅក្នុងសមុទ្រធ្វើឃ្លាំងទទេរបស់លោកឲ្យពេញ ទ្រព្យដែលអស់ទៅព្រោះប្រារព្ធការកសាង ( ព្រះវិហារជេតពន ) ខ្ញុំបានប្រមូលមកទាំងអស់ កាលខ្ញុំមិនបានលំនៅរមែងលំបាក បពិត្រលោកសេដ្ឋី លោកកុំដាក់ចិត្តដាក់ថ្លើមក្នុងពាក្យរបស់ខ្ញុំ ព្រោះខ្ញុំមិនដឹង សូមលោកអត់ទោសផងចុះ ។

អនាថបិណ្ឌិកសេដ្ឋីបានស្តាប់ពាក្យរបស់ទេវតានោះហើយ គិតថាទេវតានេះបានពោលថា ខ្ញុំបានធ្វើទណ្ឌកម្ម ហើយនិងប្តេជ្ញាទទួលទោសរបស់ខ្លួន ព្រះបរមសាស្តា ទ្រង់នឹងទូន្មានទេវតានេះឲ្យស្គាល់គុណអាត្មាអញនឹងបង្ហាញទេវតានេះដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋីក៏ពោលនឹងទេវតានោះថា នែសម្លាញ់ បើអ្នកឲ្យខ្ញុំអត់ទោស ចូរទៅកាន់សម្នាក់របស់ព្រះបរមសាស្តា សូមឲ្យទ្រង់អត់ទោសសិនចុះ ។

ទេវតានោះពោលថា សាធុ ខ្ញុំនឹងធ្វើយ៉ាងនោះ ម្យ៉ាងទៀត សូមលោកនាំខ្ញុំទៅកាន់សម្នាក់របស់ព្រះសាស្តាផងចុះ ។

សេដ្ឋីពោលថា សាធុ ។ កាលរាត្រីអស់ហើយ ទើបនាំទេវតា

នោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាអំពីព្រលឹម ហើយក្រាបទូលកម្ម ដែលទេវតានោះធ្វើទាំងអស់ដល់ព្រះតថាគត ។

ព្រះបរមសាស្តា កាលទ្រង់ព្រះសណ្តាប់ពាក្យរបស់សេដ្ឋីហើយ ទើបត្រាស់ថា ម្នាលគហបតី បុគ្គលបាបក្នុងលោក រមែងឃើញសេចក្តីចម្រើន ដរាបណាបាបកម្មមិនទាន់ឲ្យផល លុះបាបកម្មឲ្យផល បុគ្គលបាបនោះ ក៏រមែងឃើញបាបប៉ុណ្ណោះ ក្នុងកាលនោះ ចំណែកមនុស្សល្អរមែងឃើញបាបទាំងឡាយ ដរាបណាដែលអំពើល្អមិនទាន់ឲ្យផល កាលណាអំពើល្អឲ្យផល មនុស្សល្អនោះ រមែងឃើញល្អប៉ុណ្ណោះ ក្នុងកាលនោះ ហើយទ្រង់ត្រាស់គាថាពីរក្នុង **ធម្មបទ** ដូច្នេះថា

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។**

*បាប មិនទាន់ឲ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែសេចក្តីចម្រើនត្រឹមណោះ លុះកាលណា បាបឲ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។*

**ភទ្រោបិ បស្សតី បាបំ យាវ ភទ្រំ ន បច្ចតិ**
**យទា ច បច្ចតី ភទ្រំ អថ (ភទ្រោ) ភទ្រានិ បស្សតិ ។**

*អំពើល្អ មិនទាន់ឲ្យផលត្រឹមណា មនុស្សល្អ នៅឃើញតែបាបត្រឹមណោះ លុះកាលណា អំពើល្អឲ្យផល មនុស្សល្អ ទើប*

ឃើញល្អក្នុងកាលនោះ [១] ។

ក្នុងវេលាចប់គាថានោះ ទេវតាតាំងនៅហើយក្នុងសោតាបត្តិផល ទេវតានោះ ក្រាបចុះទៀបព្រះបាទារបស់ព្រះសាស្តា ដែលប្រកបដោយចក្រ សូមឲ្យព្រះសាស្តាអត់ទោសថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គកាលរាគៈជ្រលក់ហើយ ទោសៈប្រទូស្តហើយ វង្វេងហើយដោយមោហៈ ងងឹតព្រោះអវិជ្ជា មិនដឹងគុណទាំងឡាយរបស់ព្រះអង្គ បានពោលពាក្យដ៏លាមក សូមទ្រង់អត់នូវទោសនោះ ដល់ខ្ញុំព្រះអង្គ (ទេវតានោះ កាលសូមខមាទោសព្រះសាស្តាហើយ) ក៏ញុំាងមហាសេដ្ឋីឲ្យអត់ទោស ។ សម័យនោះ អនាថបិណ្ឌិកសេដ្ឋី ពោលគុណរបស់ខ្លួនក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ទេវតានេះហាមខ្ញុំព្រះអង្គថា ចូរកុំធ្វើការឧបដ្ឋាកដល់ព្រះពុទ្ធជាដើម ក៏មិនអាចហាមខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គត្រូវទេវតានេះហាមថា មិនគួរឲ្យទាន ក៏នៅតែឲ្យទាននោះឯង បពិត្រព្រះអង្គដ៏ចម្រើន នេះជាគុណរបស់ខ្ញុំព្រះអង្គ មិនមែនឬ ?

ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី អ្នកជាអរិយសាវក ជាសោតាបន្ន មានសទ្ធាមិនញាប់ញ័រ មានទស្សនៈបរិសុទ្ធ ភាពដែលអ្នកត្រូវទេវតាមានសក្តិតូចនេះ ហាមឃាត់មិនបាន មិនជាអស្ចារ្យទេ ចំណែក

---

១-បិ.៥២ , ទំ. ៤៧ ។

បណ្ឌិតទាំងឡាយក្នុងកាលមុន កាលមិនមានព្រះពុទ្ធកើតឡើងក្នុងលោក តាំងនៅក្នុងញាណដែលមិនទាន់ចាស់ក្លា ត្រូវមារដែលជាធំក្នុងកាមាវចរភព ឈរក្នុងអាកាសសម្ដែងរណ្ដៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ដោយពោលថា បើអ្នកឲ្យទានសោត អ្នកនឹងឆេះក្នុងនរកនេះ ហើយហាមថា ចូរកុំឲ្យទាន ក៏បានឈរត្រង់កណ្ដាលផ្កាឈូកឲ្យទាន នេះទើបគួរជាការអស្ចារ្យ កាលអនាថបិណ្ឌិកសេដ្ឋីក្រាបទូលអារាធនាហើយ ទើបទ្រង់នាំយកអតីតនិទានមកសម្ដែងដូចតទៅនេះថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះមហាសត្វបដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងនគរពារាណសីនោះ ។ កាលញាតិទាំងឡាយឲ្យចម្រើន ព្រមដោយគ្រឿងឧបករណ៍ទាំងពួង មានប្រការផ្សេងៗ ដូចទេវកុមារ ដល់នូវភាពជាអ្នកដឹងក្ដីដោយលំដាប់ ក្នុងវេលាមានអាយុ ១៦ ឆ្នាំប៉ុណ្ណោះ ក៏ដល់នូវការសម្រេចក្នុងសិប្បៈទាំងពួង កាលមាតាបិតាអនិច្ចកម្មទៅ ព្រះពោធិសត្វនោះក៏តាំងនៅក្នុងតំណែងសេដ្ឋី ឲ្យសាងរោងទាន ៦ គឺត្រង់ទ្វារនគរទាំងបួន ៤ កណ្ដាលនគរ១ ត្រង់ទ្វារនិវេសន៍របស់ខ្លួន១ ហើយឲ្យមហាទាន រក្សាសីល ធ្វើឧបោសថកម្ម ។ ថ្ងៃមួយ ក្នុងវេលាអាហារព្រឹក កាលអ្នកបម្រើនាំយកភោជនដែលជាទីគាប់ចិត្ត មានរសដ៏ប្រសើរផ្សេងៗ ចូលមកជូនព្រះបរមពោធិសត្វ ។ សម័យនោះ ព្រះបច្ចេកពុទ្ធមួយអង្គ

( លោកចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ) ទើបតែចេញអំពីនិរោធ-សមាបត្តិ កំណត់វេលាភិក្ខាចារហើយ គិតថា ថ្ងៃនេះ អាត្មាអញគួរទៅកាន់ទ្វារផ្ទះរបស់សេដ្ឋីពារាណសីទើបគួរ ហើយទំពាឈើស្ទន់ឈ្មោះនាគលតា លុបមុខត្រង់អនោតត្តស្រះ ឈរលើផ្ទាំងមនោសិលា ស្លៀកស្បង់ ចងវត្តពន្ធចង្កេះ ដណ្តប់ចីវរ កាន់បាត្រដីដែលសម្រេចដោយឫទ្ធិមកតាមអាកាស លុះអ្នកបម្រើនាំកត្តចូលទៅជូនព្រះពោធិសត្វ ( ព្រះបច្ចេកពុទ្ធអង្គនោះ ) ក៏បានឈរត្រង់ទ្វារផ្ទះ ។ ព្រះពោធិសត្វគ្រាន់តែឃើញដូច្នោះ ក៏ក្រោកចាកអាសនៈ សម្តែងអាការឱនលំទោន ហើយសម្លឹងមើលបុរសអ្នកធ្វើការងារ កាលបុរសអ្នកធ្វើការងារពោលថា

**កឹ ករោមិ សាមិ** តើឲ្យខ្ញុំធ្វើអ្វី លោកម្ចាស់ ?

សេដ្ឋីពោធិសត្វក៏ពោលថា **អយ្យស្ស បត្តំ អាហរថ** ចូរអ្នកទៅយកបាត្ររបស់លោកម្ចាស់មក ។

លំដាប់នោះ មារមានចិត្តបាបក៏ស្ទុះស្ទាក្រោកឡើង ហើយគិតថា ព្រះបច្ចេកពុទ្ធនេះ អត់អាហារមក៧ថ្ងៃហើយ បើថ្ងៃនេះ មិនបានអាហារ ក៏នឹងដល់នូវសេចក្តីវិនាស អញនឹងធ្វើឲ្យព្រះបច្ចេកពុទ្ធនេះវិនាស ហើយនឹងធ្វើឲ្យអន្តរាយដល់ទានរបស់សេដ្ឋី ( គិតហើយមារនោះក៏ ) មកក្នុងខណៈនោះមួយរំពេច និម្មិតរណ្តៅរងើកភ្លើងប្រមាណ ៨០ ហត្ថ ក្នុងរវាងស្ថានដែលជាទីតាំង ពេញដោយរងើកភ្លើងគគីរ មានរងើករន្ទាល

ប្រាលផ្កា ប្រាកដដូចអវិចីមហានរក ។ កាលនិម្មិតរណ្តៅរងើកភ្លើង នោះហើយ ខ្លួនឯងក៏ទៅឈរក្នុងអាកាស បុរសដែលរត់មកយកបាត្រ ព្រះបច្ចេកពុទ្ធឃើញដូច្នោះក៏មានសេចក្តីភិតភ័យ ទើបត្រឡប់ទៅវិញ ។

ព្រះពោធិសត្វសួរថា នែបា អ្នកបានបាត្រហើយឬ ?

បុរសនោះឆ្លើយថា បពិត្រលោកម្ចាស់ រណ្តៅរងើកភ្លើងធំនៅកាត់មុខក្នុងទីឈ្មោះឯណោះ កាលបើដូច្នោះ មនុស្សអ្នកទៅមកទាំងអស់ដល់នូវសេចក្តីភ័យខ្លាច គេចទៅដោយរហ័ស ។ ព្រះមហាបុរសគិតថា ថ្ងៃនេះ វសវត្តីមារបំណងនឹងធ្វើឲ្យអន្តរាយដល់ទានរបស់អញ ដែលប្រ-កបឡើង តែវសវត្តីមារនោះ មិនដឹងថាអញជាបុគ្គលដែលមាររាប់រយរាប់ពាន់ រាប់សែនធ្វើឲ្យញាប់ញ័រមិនបាន ថ្ងៃនេះ អញនឹងដឹងថា មារនិងអាត្មាអញ តើអ្នកណាមានកម្លាំងជាង មានអានុភាពជាង? គិតហើយក៏កាន់យកថាសភត្តដែលគេត្រៀមទុកដើម្បីខ្លួន ចេញអំពីផ្ទះទៅឈរត្រង់មាត់រណ្តៅរងើកភ្លើង ហើយសម្លឹងមើលអាកាសឃើញមារ ទើបពោលថា អ្នកជានរណា?

មារពោលថា យើងជាមារ ។

ព្រះបរមពោធិសត្វសួរថា រណ្តៅរងើកភ្លើងនេះ អ្នកនិម្មិតឬ ?

មារពោលថា អើ យើងនិម្មិត ។

ព្រះបរមពោធិសត្វសួរថា តើអ្នកនិម្មិតដើម្បីអ្វី ?

មារពោលថា ដើម្បីធ្វើឲ្យអន្តរាយដល់ទានរបស់អ្នក និងដើម្បីឲ្យជីវិតរបស់ព្រះបច្ចេកពុទ្ធវិនាស ។

ព្រះបរមពោធិសត្វពោលថា ខ្ញុំមិនឲ្យអ្នកធ្វើសេចក្តីអន្តរាយដល់ទានរបស់ខ្ញុំ និងមិនឲ្យធ្វើសេចក្តីអន្តរាយដល់ជីវិតព្រះបច្ចេកពុទ្ធ ក្នុងថ្ងៃនេះ យើងនឹងដឹងថា ខ្ញុំនិងអ្នក នរណាមានកម្លាំងជាង នរណាមានអានុភាពជាង ហើយឈរត្រង់មាត់រណ្តៅរងើកភ្លើងពោលថា បពិត្រព្រះបច្ចេកពុទ្ធដ៏ចម្រើន ខ្ញុំព្រះករុណា សូម្បីមានក្បាលធ្លាក់ចុះក្នុងរណ្តៅរងើកភ្លើងនេះ ក៏មិនត្រឡប់ក្រោយដែរ សូមលោកម្ចាស់ទទួលភោជនដែលខ្ញុំប្រគេនតែម្យ៉ាង ហើយពោលគាថានេះថា

**កាមំ បតាមិ និរយំ ឧទ្ធំបាទោ អវំសិរោ**
**នានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហាតិ ។**

តាមពិត ខ្ញុំព្រះអង្គ ស៊ូមានជើងឡើងលើ មានក្បាលចុះ
ក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរ
ទេ បើដូច្នោះ សូមព្រះអង្គទទួលនូវចង្ហាន់បិណ្ឌបាតចុះ ។

ក្នុងគាថានោះ ប្រមូលសេចក្តីបានដូចតទៅនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំប្រគេនបិណ្ឌបាតដល់លោកម្ចាស់ ទោះបីជាមានក្បាលសំយុងចុះក្រោម មានជើងឡើងលើ ធ្លាក់ទៅក្នុងនរកនេះ ដោយពិត សូម្បីយ៉ាងនោះ ខ្ញុំនឹងមិនធ្វើការមិនឲ្យទាន និងការមិនរក្សាសីល

ដែលហៅថា អនរិយៈ ព្រោះបុគ្គលដែលប្រសើរមិនធ្វើ ធ្វើតែបុគ្គលមិនប្រសើរប៉ុណ្ណោះ សូមនិមន្តលោកម្ចាស់ទទួលដុំបាយដែលខ្ញុំប្រគេនចុះ ។

សព្ទថា **ហន្ទ** ក្នុងគាថានេះជានិបាត ប្រើក្នុងអត្ថថា នៃឧបសគ្គ ។

ព្រះមហាបុរស កាលពោលយ៉ាងនេះហើយ មានការសមាទានយ៉ាងមាំទាំ កាន់ថាសកត្តដើរខាងលើរណ្ដៅរងើកភ្លើងនោះ រំពេចនោះឯង មហាបទុម គឺផ្កាឈូកក្រហម រីកស្កុសស្កាយឡើងជាជាន់ៗ អំពីរណ្ដៅរងើកភ្លើងជម្រៅ ៨០ ហត្ថ ផុសឡើងទទួលជើងទាំងពីររបស់ព្រះពោធិសត្វ បន្ទាប់អំពីនោះ កេសរដែលមានប្រមាណមួយនាឡិធំ ផុសឡើងតាំងនៅលើសីសៈរបស់ព្រះមហាសត្វ ជ្រុះរោយរាយមក ធ្វើរាង-កាយទាំងមូលឲ្យដូចជាបាចសាចដោយលម្អងមាស ព្រះពោធិសត្វឈរលើផ្កាឈូក ញុំាងភោជនមានរសដ៏ប្រសើរផ្សេងៗ ឲ្យប្រតិស្ឋានក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ ។ ព្រះបច្ចេកពុទ្ធទទួលភោជននោះហើយ ធ្វើអនុ-មោទនាបោះបាត្រទៅក្នុងអាកាស កាលមហាជនកំពុងឃើញនោះឯងក៏ហោះទៅកាន់វេហា មានមុខឆ្ពោះទៅកាន់ព្រៃហិមពាន្ត ដូចជាន់ពពកមានប្រការផ្សេងៗទៅដូច្នោះ ចំណែកមារចាញ់ហើយដល់នូវទោមនស្សក៏ទៅកាន់លំនៅរបស់ខ្លួននោះឯង ។ ព្រះបរមពោធិសត្វឈរលើផ្កាឈូកសម្ដែងធម៌ដល់មហាជនដោយពណ៌នាដល់ទាននិងសីល កាលមហាជនគឺបរិវារចោមរោមហើយក៏ចូលទៅកាន់និវេសន៍របស់ខ្លួន ធ្វើបុណ្យទាំង

ឡាយមានទានជាដើម ដរាបដល់អស់ជីវិត ហើយក៏ទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលគហបតី កាលដែលអ្នកសម្បូណ៌ដោយទស្សនៈយ៉ាងនេះ ដែលទេវតាឲ្យញាប់ញ័រមិនបានក្នុងកាលឥឡូវនេះ មិនជាអស្ចារ្យទេ កម្មដែលបណ្ឌិតទាំងឡាយបានធ្វើទុកក្នុងកាលមុនប៉ុណ្ណោះ ទើបគួរអស្ចារ្យ ។

ព្រះបរមសាស្តា កាលទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់បន្តអនុសន្ធិ សមោធានជាតកថា **តទា បច្ចេកពុទ្ធោ តត្ថេវ បរិនិព្វាយិ មារំបរាជេត្វា បទុមកណ្ណិកាយ ឋត្វា បច្ចេកពុទ្ធស្ស បិណ្ឌបាតទាយកោ ពារាណសិសេដ្ឋី បន អហមេវ អហោសិន្តិ ។** ព្រះបច្ចេកពុទ្ធក្នុងកាលនោះ បានបរិនិព្វានទៅហើយក្នុងកាលនោះឯង ចំណែកពារាណសីសេដ្ឋី ដែលជាអ្នកធ្វើមារឲ្យចាលចាញ់ ឈរនៅលើផ្កាឈូក ហើយប្រគេនបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ គឺ **តថាគត** នេះឯង ៕

ចប់ អដ្ឋកថា ខទិរង្គារជាតក ទី ១០ ។

ចប់ កុលាវកវគ្គ ទី ៤ ។

# រួមជាតកដែលមាននៅក្នុងវគ្គនេះ គឺ

*កុលាវកជាតក ១  នច្ចជាតក ១  សម្មោទមានជាតក ១ មច្ឆជាតក ១ វដ្ដកជាតក ១ សកុណជាតក ១ តិត្តិរជាតក ១ ពកជាតក ១ នន្ទជាតក ១  ខទិរង្គារជាតក ១ ។*

# រួមវគ្គដែលមាននៅក្នុង ឯកនិបាតជាតក ភាគទី ១ នេះ គឺ

*អបណ្ណកវគ្គ ១  សីលវគ្គ ១  កុរុង្គវគ្គ ១ កុលាវកវគ្គ ១ ។*

ចប់ អដ្ឋកថាជាតក ឯកនិបាត ភាគ ១ ។

# នាមពុទ្ធបរិស័ទជួយពិនិត្យអក្ខរាវិរុទ្ធ

*ព្រះមហាសីលបញ្ញោ* *ភិក្ខុរតននាថោ មាស សាពួន*

*ភិក្ខុវជិរប្បបញ្ញោ គូ សុភាព*

*លោកគ្រូធម្មាចារ្យ អ៊ុម វ៉ែយ៉ា* *ឧ.ស.ឡាន សុខុម*

*ឧ.ស. លឹម ធន់* *ឧ.ស. ឈិន គឹមឆេង*

*ឧ.សិ. ហេង ចន្ទបុញ្ញវន្តី* *ឧ.សិ.ទី សុធី*

*ឧ.សិ. ពាម សាយឿន* *ឧ.សិ.ស៊ីម យ៉េកហួយ*

*ឧ.សិ.ហេង ចន្ទរចនា* *ឧ.សិ. អ៊ុក ផាសុកាន ។*

# នាមពុទ្ធបរិស័ទវាយអត្ថបទ

*ឧ.សិ. ហេង ចន្ទរចនា* *ឧ.សិ. ហេង ចន្ទបុញ្ញវន្តី*

# នាមពុទ្ធបរិស័ទជួយឧបត្ថម្ភសម្ភារៈ និងប្រាក់សម្រាប់ការវាយធម្មទាន

*ឧ.ស. ហេង វីរិន្ទ* *ឧ.ស. ហេង វណ្ណៈ* *ឧ.ស.ហេង វណ្ណា*

*ឧ.សិ.ហេង ចន្ទកុលសុកៈ* *ឧ.ស.ហេង រស្មី និងក្រុមគ្រួសារ ។*

*ឧ.សិ.ប៉ាល់ធីតា + ស្វាមី និង កូនចៅ* *ឧ.សិ.ខាំ នាងសុខី ។*

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការខារធម្មទាន

ភិក្ខុរតននាថោ មាស សាពួន
លោកម្ចាស់ ប៉ាន់ ឈា
លោកម្ចាស់ង៉ែត ប៊ុននឿន
លោកម្ចាស់ វង្ស វុឌ្ឍិ
លោកម្ចាស់ គឹម ម៉ានិត
លោកម្ចាស់ កែវ វុទ្ធី
ឧ.សិ.ជុន ស៊ូគី
ឧ.សិ. ស៊ីម យ៉េកហួយ
ឧ.ស.ឃិច ឈីន
ឧ.សិ. ហេង៍ចន្ទកុលសុភ:
ឧ.សិ. ឌួង ធរីវណ្ណ
ឧ.សិ.ទេព ផលម៉ាឡា
ឧ.សិ. ស្រី វណ្ណី
ឧ.សិ.សូ យឿន
ឧ.ស. ភោគ

ភិក្ខុសន្តស្សិកត្ថេរោ ហ៊ី ហេង៍
លោកម្ចាស់ មិត្ត កំសាន្ត
លោកម្ចាស់ ផល ផានិត
ភិក្ខុ សិរីធម្មាធិបតេយ្យ ធុច សិរីមុនី
លោកម្ចាស់ ឡោះ សូវៀត
លោកម្ចាស់ តា សំ សាន
ឧ.សិ.ឈឹម សុខែម
ឧ.សិ.ឃឹម វ៉ន
ឧ.សិ. តែ សុមាលី ( បួយ )
ឧ.សិ.សរ យ៉ាត
ឧ.សិ. រស់ គឹមថាន
ឧ.សិ. ខាំ នាង៍សុខី
ឧ.សិ. ហ៊ឹង៍ ស៊ីមណៃ
ឧ.សិ. យ៉ា សុខគីម
ឧ.សិ. ឈិត សាម៉េន ។

# នាមពុទ្ធបរិស័ទដែលមានសទ្ធា បរិច្ចាគប្រាក់ បោះពុម្ពសៀវភៅនេះ ផ្នែកព្រះសង្ឃ

១- ព្រះតេជគុណ ព្រះសព សួស
២- ភិក្ខុមង្គលជោតិប្បញ្ញោ អ៊ឹម ឌុន
៣- ព្រះតេជគុណ អ៊ុក វ៉ន
៤- ព្រះតេជគុណ ហ៊ី
(១-៤) ........................... ៤០ $

៥- លោកម្ចាស់ ប៉ិច វណ្ណនុច (វត្តសំពៅមាស) ...................... ២៥ $

៦- ភិក្ខុ ដោក ដេន (វត្តសំពៅមាស) ...................... ២០ $

៧- ភិក្ខុ ជយបណ្ឌិតោ លាង សុវណ្ណ (វត្តសំពៅមាស) ....... ២០ $

៨- ភិក្ខុ ធម្មបាលោ ប្រេម លីម (វត្តសំពៅមាស) ............... ២០ $

៩- ភិក្ខុសន្តុស្សិកត្ថេរោ ហ៊ី ហេង (វត្តសំពៅមាស) ............ ១០ $

១០- ភិក្ខុ ផល ផានិត (វត្តសំពៅមាស) ...................... ១០ $

១១- សាមណេរ ឆែម ឈីន (វត្តសំពៅមាស) ......................... ១០ $

១២- លោកម្ចាស់តា សំ សាន (វត្តសំពៅមាស) .................... ១០ $

១៣-សាមណេរ អន ថៃ (វត្តសំពៅមាស) ............. ១០ $

១៤- ភិក្ខុវជិរប្បញ្ញោ គួ សុភាព (វត្តនិគ្រោធវ័ន) ........... ៥០.០០០៛

១៥- លោកម្ចាស់ជា ម៉ុន (វត្តសំពៅមាស) ............ ១០.០០០៛

# នាមពុទ្ធបរិស័ទដែលមានសទ្ធា បរិច្ចាគប្រាក់ បោះពុម្ពសៀវភៅនេះ

១- លោក.ហួរ ណារិទ្ធ + ភរិយា ព្រមទាំងបុត្រ ........................ ២៥០ $

២-ឧ.សិ.ជួន ស៊ីមហ៊ន និង ឧ.សិ.ជួន ស្រី ព្រមទាំងកូនចៅ ........... ២០០ $

៣- ឧ.សិ.ស៊ី ឈុនហ៊ាង ព្រមទាំងកូនចៅ .................................. ២០០ $

៤-ឧ.សិ.ឈិន ប៉ោ + កូនចៅ សូមឧទ្ទិសជូន ឧ.ស. អ៊ិត លឹមតេក .... ១០០ $

៥-ឧ.សិ.តឹក អេងគី ព្រមទាំងកូនចៅ ..................................... ៥០ $

៦-ឧ.ស.កែប ស៊ីឈាង ឧ.សិ.ប៉ែន គា ព្រមទាំងកូនចៅ .............. ៥០ $

៧-ឧ.ស.តាំង សុផល ឧ.សិ.ឡុង កេង ព្រមទាំងកូនចៅ ......... ៣០$

៨-ឧ.សិ.ជាម ធុច និង ក្រុមគ្រួសារ ............................. ២០ $

៩-ឧ.ស.ហុក ហេង ឧ.សិ.ស៊ុយ ឡៃ + កូនចៅ
១០-ឧ.ស.ហេង វិរិន្ទភរិយា + កូនចៅ ............. ២០ $

១១-ឧ.ស.ជួន ហ៊ី ឧ.សិ.ខ្វាន់ ទឹម + កូនចៅ
១២-ឧ.ស.ហុក តាំងអ៊ន់ ឧ.សិ.ជួន ស៊ីមយន់ + កូនចៅ ............. ២០ $

១៣-ឧ.សិ.កាំង ប៉ោទៀង និង ស្វាមី ព្រមទាំងកូនចៅ ................... ១០ $

១៤-ឧ.ស.អ៊ុក សំណាង ឧ.សិ.ប៉ាល់ ធីតា + កូនចៅ ............. ១០ $

១៥-ឧ.សិ.គីម ឆេង ព្រមទាំងកូនចៅ ..................... ១០ $

១៦-ឧ.សិ.ស៊ូ អ៊ឹង និង ស្វាមី ព្រមទាំងកូនចៅ ................... ១០ $

១៧-ឧ.ស. ហេង សមអាន និង ភរិយា ព្រមទាំងបុត្រ ..................... ១០ $

១៨-ឧ.សិ. ទី សុធី និង កូនហែម តុលា ...................... ១០ $

១៩-ឧ.សិ.ស្រី នាង និង ស្វាមី ព្រមទាំងកូនចៅ .................... ៩ $

២០-ឧ.សិ.ស៊ុន ដា (ហៅ កៅ ដា) និងកូនចៅ ......... ៨ $

២១-ឧ.ស.យូ ត្រា ឧ.សិ. ព្រំ អាំងលី ព្រមទាំងកូនចៅ ...................... ៨ $

២២-ឧ.សិ.ឡាប តុ (ហៅមុំ) និង ស្វាមី ព្រមទាំងបុត្រ ............... ៨ $

២៣-ឧ.ស.សំ ចេង ព្រមទាំងកូនចៅ ................................ ៥ $

២៤-ឧ.ស.តាក គីអ៊ាង+ ឧ.សិ.ឱម លាងគ្រី +កូន តាក វីរវណ្ណ +កូនចៅ ៥ $

២៥-ឧ.សិ.មិន គឹមស៊ាន ព្រមទាំងកូនចៅ .......................... ៥ $

២៦-ឧ.សិ.លឹម ហេង និង ស្វាមី ព្រមទាំងបុត្រ ............................... ៥ $

២៧-ឧ.សិ.កែវ ជីន ព្រមទាំងកូនចៅ ...................................... ៥ $

២៨-ឧ.សិ.នង រ៉េ និង ស្វាមី ព្រមទាំងបុត្រ ........................... ៥ $

២៩-ឧ.សិ.វណ្ណ មុនី ព្រមទាំងកូនចៅ ....................................... ៥ $

៣០-ឧ.ស.ម៉ម សេង និង ឧ.សិ. ខាត់ រតនា ព្រមទាំងកូនចៅ ....... ៥ $

៣១-ឧ.ស.ម៉ៅ សុវណ្ណឌ្ឍន៍ និង ភរិយា ព្រមទាំងបុត្រ ............................ ៥ $

៣២-ឧ.សិ.ប៊ុន រ៉ាវី ព្រមទាំងកូនចៅ .................................... ៥ $

៣៣-ឧ.សិ.យស នឹម និង កូនចៅ ........................... ៥ $

៣៤-ឧ.សិ.ហាស់ សុខុម ព្រមទាំងកូនចៅ .................................. ៥ $

៣៥-ឧ.សិ.ហាក់ គៀនសុខ ព្រមទាំងកូនចៅ ................................. ៥ $

៣៦-ឧ.សិកែវ.សុខុម និង ស្វាមី ព្រមទាំងបុត្រ .............................. ៥ $

៣៧-ឱ.សិ.ទូច ចន្ថា ព្រមទាំងញាតិ ........................ ៦០០០៛+ ៤$

៣៨-ឱ.សិ.សាន ស៊ាន ព្រមទាំងកូនចៅ .................................. ៤$

៣៩-ឱ.សិ.សំ ចន្ថា និង ស្វាមី ព្រមទាំងបុត្រ .............................. ៤$

៤០-ឱ.សិ. ទូច សាម៉ែ ព្រមទាំងកូនចៅ ................................ ៤$

៤១-ឱ.សិ. ជន បុប្ផាក្ងង់ ព្រមទាំងកូនចៅ ................................... ៤$

៤២-ឱ.សិ. សុខ ស៊ីវន ព្រមទាំងកូនចៅ ........................... ៤$

៤៣-ឱ.សិ.ផន ចន្ថា និង ស្វាមី ព្រមទាំងបុត្រ ............................ ៤$

៤៤-ឱ.សិ.ព្រំ សុខា និង កូនចៅ ............................ ៤$

៤៥-ឱ.សិ.យូ ស៊ីយ៉ាន និង កូនចៅ ............................. ៤$

៤៦-ឱ.សិ.លី ឡៃហ៊ាង ព្រមទាំងកូនចៅ ................. ១០០.០០០៛

៤៧-ឱ.ស.ហង់ ច័ន្ទរិទ្ធ ឱ.សិ. ដួង រ៉ាវី ព្រមទាំងបុត្រ ............. ៩០.០០០៛

៤៨-ឱ.ស.អ៊ឹង សុខលីម និងភរិយា ព្រមទាំងបុត្រ ................. ៨៥.០០០៛

៤៩-ឱ.សិ.ហុង ទូច ព្រមទាំងកូនចៅ ................. ៦០.០០០៛

៥០-ឱ.សិ.បាក់ ចិន្ថា+ឱ.សិ.ហ៊ាង ...................... ៥០.០០០៛

៥១-ឱ.សិ.យូ ប៉ូលីន និង ស្វាមី ព្រមទាំងបុត្រ ...................... ៤០.០០០៛

៥២-ឱ.សិ. ញឹប ណាន ព្រមទាំងកូនចៅ .................... ៤០.០០០៛

៥៣-ឱ.សិ.តាំង ប៉ោជីង (ហៅទន់) ព្រមទាំងបុត្រ .......... ៤០.០០០៛

៥៤-ឱ.សិ. គឹម យុន ព្រមទាំងកូនចៅ .................... ៤០.០០០៛

៥៥-ឱ.សិ.សួន គីមផល និងស្វាមី+កូនចៅ ........................... ៣៥.០០០៛

៥៦-ឧ.សិ.នាង សេង និង ឧ.សិ. មាន ហរិតា .................... ៣២.០០០៛

៥៧-ឧ.សិ.ង៉ូវឡេង ស៊ីវហេង ព្រមទាំងបុត្រ ................. ៣២.០០០៛

៥៨-ឧ.សិ.ហេង ស៊ុនួន ព្រមទាំងកូនចៅ .................. ៣០.០០០៛

៥៩-ឧ.សិ.លីវ ណាយ ព្រមទាំងកូនចៅ ..................... ៣០.០០០៛

៦០-ឧ.សិ.អ៊ុក ផាសុកាន ព្រមទាំងកូនចៅ ................ ៣០.០០០៛

៦១-ឧ.សិ.ម៉ៅ គឹមស្រ៊ុន ព្រមទាំងកូនចៅ ...................... ២៦.០០០៛

៦២-ឧ.សិ.ដួង វណ្ណថន + ឧ.សិ. ឌី សុភី + ឧ.សិ.ម៉ិល មម .... ២៥.០០០៛

៦៣-ឧ.សិ.ឈួន សុ ឧ.សិ. ថ្វាង តាំងគាន កូនចៅ ....... ២៥.០០០៛

៦៤-ឧ.សិ.រស់ វណ្ណា ព្រមទាំងកូនចៅ .................................. ២០.០០០៛

៦៥-ឧ.សិ ឈឹម ហាន ព្រមទាំងកូនចៅ ..................... ២០.០០០៛

៦៦-ឧ.សិ មួយ ហុង ព្រមទាំងកូនចៅ ..................... ២០.០០០៛

៦៧-ឧ.សិ រាម សាឃឿន ព្រមទាំងកូនចៅ ..................... ២០.០០០៛

៦៨-ឧ.ស.សួន សារី ព្រមទាំងកូនចៅ ....................... ២០.០០០៛

៦៩-ឧ.សិ គ្រុយ លាងចាយ ព្រមទាំងកូនចៅ ..................... ២០.០០០៛

៧០- ឧ.សិ.ចន្ទី ...................................... ២០.០០០៛

៧១-ឧ.ស.អ៊ឹង ប៉េងយាង ព្រមទាំងកូនចៅ ............. ២០.០០០៛

៧២-ឧ.សិ.នៅ សុធានី និង ស្វាមី ព្រមទាំងបុត្រ ................. ២០.០០០៛

៧៣-ឧ.ស.ឈិម ហុក អ៊ាន ព្រមទាំងកូនចៅ ........... ២០.០០០៛

៧៤-ឧ.សិ.វ៉េង ឆេងលាង ព្រមទាំងកូនចៅ ............ ២០.០០០៛

៧៥-ឧ.សិ.ម៉ី ម៉ារិន និងស្វាមី ព្រមទាំងបុត្រ ............ ២០.០០០៛

៧៦-ឧ.សិ.អ៊ួង ឈុនហួង និងស្វាមី ព្រមទាំងបុត្រ .......... ២០.០០០៛

៧៧-ឧ.សិ.ម៉ន ចិន្តា ព្រមទាំងកូនចៅ .................... ២០.០០០៛

៧៨-ឧ.ស.នរៈ មេត្តា ឧ.សិ.ឌួង គុយអេង + កូនចៅ ......... ២០.០០០៛

៧៩-ឧ.សិ.ជ្រុន ស៊ីដេត ព្រមទាំងកូនចៅ ............ ២០.០០០៛

៨០-ឧ.ស.ឈឹម សួន ឧ.សិ. ឈឹម ផារិន ព្រមទាំងបុត្រ ............. ២០.០០០៛

៨១-ឧ.សិ.ស៊ុំ សូនី ព្រមទាំងកូនចៅ .......................... ២០.០០០៛

៨២-ឧ.សិ.អ៊ុច ណារី ព្រមទាំងបុត្រ .......................... ២០.០០០៛

៨៣-ឧ.សិ.ចុង ថូ+ ឧ.សិ.ឈាន សុខាន់ និងស្វាមី បុត្រ ........ ២០.០០០៛

៨៤-ឧ.សិ.ស្រី ស៊ីវុឌ្ឍថា និង ស្វាមី ព្រមទាំងបុត្រ ....... ២០.០០០៛

៨៥-ឧ.សិ.ពិន ណារិន ព្រមទាំងកូនចៅ ............................ ២០.០០០៛

៨៦-ឧ.សិ.មូល វណ្ណថេត + ក្រុមគ្រួសារ .......... ២០.០០០៛

៨៧-ឧ.សិ.អ៊ុយ សំណាង ព្រមទាំងកូនចៅ ..................... ២០.០០០៛

៨៨-ឧ.សិ.ម៉ៅ ថេង និង ស្វាមី ព្រមទាំងបុត្រ ................. ២០.០០០៛

៨៩-ឧ.សិ.ណុប សុគន្ធ និង ស្វាមី ព្រមទាំងកូនចៅ ................ ២០.០០០៛

៩០-ឧ.សិ.សេង យក់លីម និង ស្វាមី ព្រមទាំងបុត្រ ..... ២០.០០០៛

៩១-ឧ.សិ.មិន សំអឿន ព្រមទាំងកូនចៅ ........................... ២០.០០០៛

៩២-ឧ.សិ.ញ៉ែម ទេពបូរី សួរសឿន ព្រមទាំងកូនចៅ ............. ២០.០០០៛

៩៣-ឧ.ស.នៅ យី ព្រមទាំងកូនចៅ ........................... ២០.០០០៛

៩៤-ឧ.ស.អឿ សៅ ព្រមទាំងកូនចៅ ............................ ២០.០០០៛

៩៥-ឧ.សិ.កង កញ្ញា និង ស្វាមី ព្រមទាំងបុត្រ ............. ២០.០០០៛

៩៦-ឧ.សិ.ថោង សានណារី ព្រមទាំងកូនចៅ ...................... ២០.០០០៛

៩៧-ឧ.សិ.ជុំ ស៊ីម៉ុន និង ឧ.សិ. អ៊ុក ទិព្វ ..................... ២០.០០០៛

៩៨- ឧ.សិ. តាំង មួយអេង ឧ.សិ. តាំង មួយខេង + កូនចៅ ..... ២០.០០០៛

៩៩-ឧ.សិ.ញឹក ទូច ឧ.សិ. អៀវ ងីម កូនចៅ .............. ២០ .០០០៛

១០០-ឧ.សិ.កៅ គាវ ឧ.សិ. អ៊ីង សៀកមួយ កូនចៅ ...... ១៨ .០០០៛

១០១-ក្មួយស្រី ព្រុំ សុភ័ក្ត្រណា .................... ១៧.០០០៛

១០២-ឧ.សិ.ប៉ែន សិរីសុខុម និង ស្វាមី សុខ សាមឿន ........... ១៦.៥០០៛

១០៣-ឧ.សិ.ហេង ឃីម និង ស្វាមី ព្រមទាំងបុត្រ ....... ១៦.០០០៛

១០៤-ឧ.ស.ហង់ វណ្ណៈ និងភរិយា ព្រមទាំងបុត្រ .................. ១៦.០០០៛

១០៥-ឧ.ស.កួវ ធីម ឧ.សិ. តឹកលី គីមឡាយ +បុត្រ .............. ១៦.០០០៛

១០៦-ឧ.សិ.នេត្រ តារា ព្រមទាំងកូនចៅ ............................ ១៦.០០០៛

១០៧-ឧ.សិ.សំ សង់វីន ព្រមទាំងបុត្រ ........................ ១៦.០០០៛

១០៨-ឧ.សិ.នាង សាម៉ិច ព្រមទាំងកូនចៅ ..................... ១៦.០០០៛

១០៩-ឧ.សិ.រ៉ាយ វុទ្ធា ព្រមទាំងកូនចៅ ..................... ១៦.០០០៛

១១០-ឧ.សិ.ទូច ណាយ ព្រមទាំងកូនចៅ ................ ១៦.០០០៛

១១១-ឧ.សិ.មាន ផល (គួយ) និងស្វាមី ព្រមទាំងបុត្រ ..... ១៦.០០០៛

១១២- ឧ.សិ.ហឿន ហ៊ន ព្រមទាំងកូនចៅ ......................... ១៦.០០០៛

១១៣-ឧ.សិ.ហ៊ិន សុខេង ព្រមទាំងកូនចៅ ...................... ១៦.០០០៛

១១៤-ឧ.សិ.លឹម ម៉ាលីន ព្រមទាំងកូនចៅ ......................... ១៦.០០០៛

១១៥-ឧ.សិ.ប៉ុក សុខ ព្រមទាំងកូនចៅ .................... ១៦.០០០៛

១១៦-ឧ.សិ.ម៉ៅ ស៊ីវន និងស្វាមី ព្រមទាំងកូនចៅ ....... .. ១៦.០០០៛

១១៧-ឧ.សិ.គង់ ពៅ ព្រមទាំងកូនចៅ ................................ ១៦.០០០៛

១១៨-ឧ.សិ.ម៉ម ឈាំងសាត ឧ.សិ. លឹម លីគាង+កូនចៅ ...... ១៦.០០០៛

១១៩-ឧ.សិ.អ៊ូ សុខសាន្ត ................................................. ១៦ .០០០៛

១២០-ឧ.សិ.ឌីម សុខមុំ ................................................. ១៦ .០០០៛

១២១-ឧ.សិ.សុខ សារឿន ព្រមទាំងកូនចៅ .................. ១៦.០០០៛

១២២-ឧ.សិ.កាន់ គិរីសុខា ព្រមទាំងកូនចៅ .................. ១៦.០០០៛

១២៣-ឧ.សិ.ឃុន ឃិន ព្រមទាំងកូនចៅ .................. ១៦.០០០៛

១២៤-ឧ.សិ. ឈាង ហ៊ិតសួរ ........................... ១៦.០០០៛

១២៥-ឧ.សិ. អ៊ួង ណារឿន ព្រមទាំងបុត្រ ............... ១៦.០០០៛

១២៦-ឧ.សិ. មិនស្គាល់ឈ្មោះ ព្រមទាំងបុត្រ .................. ១៦.០០០៛

១២៧-ឧ.សិ.ជា សុខ ព្រមទាំងកូនចៅ ..................... ១៥ .០០០៛

១២៨-ឧ.សិ.ម៉ៅ ផេង+ ឧ.សិ. ម៉ៅ វណ្ណា កូនចៅ ......... ១៥ .០០០៛

១២៩-ឧ.សិ.ទូច ឆេងនាម ឧ.សិ. ប៊ុន ហួង កូនចៅ ...... ១៥ .០០០៛

-ពុទ្ធបរិស័ទ អ្នកដែលចូល ១០.០០០៛ មានចំនួន ១៦ នាក់

-ពុទ្ធបរិស័ទ អ្នកដែលចូល ៥.០០០៛ មានចំនួន ៨ នាក់

## តាមរយៈ ឧ.សិ. ហេង ចន្ទកុលសុភៈ

១- លោកស្រី.ហួរ សុបុណ្យ +ស្វាមី ព្រមទាំងបុត្រ ......................... ៤០ $

២-ឧ.សិ. ឃួន ប៉ាច ព្រមទាំងកូនចៅ .......................... ៣០ $

៣- លោកស្រី.មី រ៉ាណែត និង ស្វាមី ព្រមទាំងបុត្រ ................... ២៥ $

៤-លោកស្រី ម៉ានារី ខាន និងស្វាមី ព្រមទាំងកូនចៅ ............. ២០ $

៥-អ្នកម្តាយ ទូន បុប្ផាធារី និងបងប្រុស ហេង មរកត ................... ២០ $

៦- លោកស្រី.ហួរ សំណាង (ស៊ីណេត) និងក្រុមគ្រួសារ .......... ២០ $

៧-ឧ.សិ.ហៀង រ៉េត ( ហៅ បាត់ ) ................... ២០ $

៨- ឧ.សិ. តឹក សុខសួរ ព្រមទាំងកូនចៅ ......................... ១០ $

៩-ឧ.សិ.ឈឹម ម៉ុម និង ស្វាមី ព្រមទាំងបុត្រ ......................... ១០ $

១០- លោកស្រី.ហួរ យុឡេង ព្រមទាំងបុត្រ .................................. ១០ $

១១ឧ.សិ ស៊ី មន និង ស្វាមី ព្រមទាំងបុត្រ ........................... ៥ $

១២- ឧ.ស.ថោ សុថាន ឧ.សិ អៀង ណាយ បុត្រ ........................... ៥ $

១៣- អាខា .................... ១៥.០០០៛

## តាមរយៈ ភិក្ខុ មិត្ត កំសាន្ត

១-ភិក្ខុ ធម្មជោត ថាត ផល្លា (សុធន់ ) ........................... ៥ $

២-ភិក្ខុ ប៉ុល ចន្ថា ......................................................... ៥ $

៣-ភិក្ខុ រឿន សំបូរ ............................................... ៥ $

៤-ឧ.ស.ប៉ិច សុខម៉ូវ + ឧ.សិ.ឡេង មួយ + កូនចៅ ............. ៥០.០០០៛

៥-ឧ.ស.ហោ ថាល់ ................................... ៥០.០០០៛

៦-ឧ.សិ.ប៉ិច សូភី ................................... ២០.០០០៛

៧-ឧ.សិ.ម៉ូវ មួយ ................................... ២០.០០០៛

៨-ឧ.ស.ខឹម អ៊ន់ + ឧ.សិ.ឈិន សុខុម + កូនចៅ ............. ២០.០០០៛

៩-ឧ.សិ.សារី ហេង ................................. ១៦.០០០៛

១០-ឧ.ស.តឹក ឆេង + ឧ.សិ.ឡៅ ងីមខេង + កូនចៅ ............ ១៦.០០០៛

១១-ឧ.សិ.សាន ហិន ................................. ១៦.០០០៛

១២-ឧ.សិ.ហេង ផុស ................................. ១៦.០០០៛

១៣-ឧ.សិ.សាន ៣ ................................. ១៦.០០០៛

## តាមរយៈ ឧ.សិ.ស្រី វណ្ណី និង ឧ.សិ.យ៉ា សុខគីម

១-ឧ.សិ. យ៉ា សុខគីម +មិត្តព្រះធម៌ ព្រមទាំងកូនចៅ ...... ១០$ + ១០.០០០៛

២-ឧ.សិ.កូវ សីហា និងស្វាមី ព្រមទាំងបុត្រ ........................... ៩$

៣-លោកស្រី ឃុន ណារី និង ស្វាមី ព្រមទាំងបុត្រ .................. ៨$

៤-ឧ.សិ.ស្រី វណ្ណី និង ស្វាមី ព្រមទាំងកូនចៅ ...................... ៥$

៥-ឧ.សិ.សាត សំអឿន ព្រមទាំងកូនចៅ ........................... ៥$

៦-ឧ.ស.គង់ សំអុល និងភរិយា ព្រមទាំងកូនចៅ ............................ ៥$

៧-ឧ.សិ.ផាន់ ហួត + ឧ.សិ. តាន់ ស៊ីទីន ព្រមទាំងកូនចៅ .............. ៥$

៨-លោកយាយ ហុង លោកតា ស្រេង + កូនចៅ ......... ៤ $ + ៣៤.០០០៛

៩-ឧ.សិ.អ៊ីង យឹមស្រ៊ាន ព្រមទាំងកូនចៅ ........................... ៤ $

១០-លោកជួន ម៉ាលីស និង ភរិយា ព្រមទាំងកូនចៅ ..... ៣២.០០០៛

១១-ឧ.សិ. ជូ នី + ឧ.សិ. តែ សុភាព ព្រមទាំងកូនចៅ ............ ២០.០០០៛

១២-ឧ.សិ.សាត សំអឿន ព្រមទាំងកូនចៅ ..................... ១៦.០០០៛

១៣-ឧ.សិ.ឡុង ចាន់ថន និងស្វាមី ព្រមទាំងបុត្រ ................ ១៦.០០០៛

១៤-ឧ.សិ.នាង លី ព្រមទាំងបុត្រ ......................... ១៦.០០០៛

១៥-ឧ.សិ.អ៊ិត សំអឿន ព្រមទាំងកូនចៅ ......................... ១៦.០០០៛

## តាមរយៈ ភិក្ខុ ប៉ាន់ ឈា

១- ព្រះគ្រូធម្មាចារ្យ ចិត្តសំវរោ គឿន សំណាង ........................... ៨ $

២- ភិក្ខុ ប៉ាន់ ឈា ..................................... ៥ $

៣- ភិក្ខុ ឧត្តរបញ្ញត្តិ អ៊ុជ យឿន ( ហៅនាង ) ...................... ៥ $

៤- ភិក្ខុ ធម្មានន្ទោ សុខ សុវណ្ណី ................................ ៥ $

៥- ភិក្ខុ អត្តវិរោ នៅ កុសល .................... ៤ $

៦- ភិក្ខុ ចន្ទបញ្ញោ ប្រាក់ កង ............................ ៤ $

៧- ភិក្ខុ នន្ទបណ្ឌិតោ មុត រស្មី .......................... ៤ $

៨- សាមណេរ ធឿន រដ្ឋា ....................... ២០.០០០៛

៩- ភិក្ខុ នូវ ដារ៉ាវុធ ............................... ១៦.០០០៛

## តាមរយៈ ឧ.សិ. ឌួង ធរីវណ្ណា

១-លោក វេជ្ជ បណ្ឌិត ម៉ី សំបូរ +ភរិយា ឌួង ធរីវណ្ណា + បុត្រ .......... ៣០ $

២-ឧ.សិ.ឡាំង គីមឆេង និង ស្វាមី ព្រមទាំងបុត្រ .................... ២០ $

៣-ឧ.សិ.ឡាំង គីមជាង និង ស្វាមី ព្រមទាំងបុត្រ .................... ២០ $

៤-ឧ.សិ.ឌួង ច័ន្ទបុប្ផា ព្រមទាំងបុត្រ ........................ ២០ $

៥-ឧ.សិ.ឌួង បភាវតី និង ស្វាមី ព្រមទាំងបុត្រ ................... ២០ $

៦-ឧ.សិ.ឡាំង នារី និង ស្វាមី ព្រមទាំងបុត្រ ....................... ២០ $

## តាមរយៈ ឧ.សិ.ខាំ នាងសុខី

១-ឧ.សិ.ខាំ នាងសុខី .......................................... ៤០.០០០៛

២-ឧ.សិ.ម៉ឹង យ៉ុម ព្រមទាំងកូនចៅ ......................... ២០.០០០៛

៣-ឧ.សិ.ម៉ី យន + កូនចៅ ................................. ២០.០០០៛

៤-លោកជំទាវ លន់ រតនា + កូនចៅ ................... ២០.០០០៛

៥-ឧ.សិ.ហោ ឆៃហ៊ាង + កូនចៅ ........................... ២០.០០០៛

៦-ឧ.សិ.ស៊ុំ គឹមមុច + កូនចៅ ............................... ២០.០០០៛

## តាមរយៈ អ្នកគ្រូ ឈឹម សុខែម

១-ឧ.សិ. ចៅ សម្ផស្ស ព្រមទាំងមិត្តព្រះធម៌ ........... ១០០ $ +១០១.០០០៛

២-ឧ.សិ. លឹម ណៃហួយ ព្រមទាំងកូនចៅ ........................... ៣០ $

៣-ឧ.សិ. ស៊ីវ ខេង ព្រមទាំងកូនចៅ ........................... ១០ $

៤-ឧ.សិ. យ៉ន ព្រមទាំងកូនចៅ ( ភូមិតាឡី ) .......................... ១០ $

៥-ឧ.សិ. សុខ ស៊ីវជីង + ឧ.សិ. សុខ ថាវី ...................... ៤ $ + ៥.០០០៛

៦-ឧ.សិ. សាយ សាអ៊ីម ព្រមទាំងកូនចៅ ........................... ៤ $

៧-ឧ.សិ. ឈឹម សុខែម ព្រមទាំងកូនចៅ ........................... ៤ $

៨-ឧ.សិ. ហេង យី ព្រមទាំងកូនចៅ .......................... ៤ $

៩-ឧ.ស.អេង អេលីយ៉ាន + ភរិយា ព្រមទាំងបុត្រ (ផ្សារដីហុយ) ......... ៤$

១០- បុត្រ ធីតា របស់ ឧ.ស. ស៊ុំ មុន្នី .......................... ៤ $

១១-ឧ.សិ. ពេជ្រ និង ស្វាមី ព្រមទាំងបុត្រ ........................... ៤ $

១២-ឧ.សិ. ខឹម ឋាន ព្រមទាំងកូនចៅ ( ភូមិថ្មី ) .................. ៤ $

១៣-ឧ.សិ.ហៀង និមល ............................ ៤ $

១៤-ឧ.សិ.ប៉ោ សារ៉េត ព្រមទាំងកូនចៅ ( ភូមិតាឡី ) ............. ៤០.០០០៛

១៥-ឧ.សិ.លាង រាសី ............................. ២០.០០០៛

១៦-ឧ.សិ.លាង មន្ថា និង ស្វាមី ព្រមទាំងកូនចៅ .................... ២០.០០០៛

១៧-ឧ.សិ.អ៊ីង ចន្ទនារី + លោក យ៉េន សុខា ព្រមទាំងបុត្រ ....... ២០.០០០៛

១៨-ឧ.សិ.ច័ន្ទ ភិរម្យ .......................................................... ២០.០០០៛

១៩-ឧ.សិ.លាង រាសី និង ស្វាមី ព្រមទាំងកូនចៅ .................. ២០.០០០៛

២០-ឧ.សិ.លាង មន្ថា និង ស្វាមី ព្រមទាំងកូនចៅ ................... ២០.០០០៛

២១-ឧ.សិ. ទេព ប៊ុច ព្រមទាំងកូនចៅ ..................... ២០.០០០៛

២២-ឧ.សិ.ប៉ោ សារ៉េត ព្រមទាំងកូនចៅ ( ភូមិតាឡី ) ............. ២០.០០០៛

២៣-ឧ.សិ.អ៊ុន និង ស្វាមី ព្រមទាំងកូនចៅ (ភូមិតាឡី ) ............ ១៧.០០០៛

២៤-ឧ.សិ.ជ័យ ណុម និង ស្វាមី + កូនចៅ (ភូមិតាឡី ) .......... ១៦.៥០០៛

២៥-ឧ.សិ.ខន ធឿន និង ស្វាមី + កូនចៅ (ភូមិតាឡី ) .......... ១៦.១០០៛

២៦-ឧ.សិ.ឡូ សែហៀង .............................. ១៦.០០០៛

២៧-ឧ.សិ. ឡាយ មួយ ព្រមទាំងបុត្រ ..................... ១៦.០០០៛

២៨-ឧ.សិ. អ៊ិន វណ្ណា + ប្អូន សុគី និង ក្លូយ ......................... ១៦.០០០៛

២៩-ឧ.សិ.អាំ ចិន ព្រមទាំងកូនចៅ .................... ១៦.០០០៛

៣០-ឧ.សិ.អាំ ចិន ព្រមទាំងកូនចៅ ..................... ១៦.០០០៛

៣១-ឧ.សិ.អ៊ឹម វ៉ាន ព្រមទាំងកូនចៅ ..................... ១៦.០០០៛

៣២-ឧ.ស.ធូរ បូរិន + ឧ.សិ. ហែម យ៉ានី ព្រមទាំងកូនចៅ ........ ១៦.០០០៛

៣៣-ឧ.សិ.លឹម ម៉ាលី និង ស្វាមី ព្រមទាំងកូនចៅ ................ ១៦.០០០៛

-ពុទ្ធបរិស័ទ អ្នកដែលចូល ១០.០០០៛ មានចំនួន ១០ នាក់

-ពុទ្ធបរិស័ទ អ្នកដែលចូល ៥.០០០៛ មានចំនួន ៩ នាក់

## តាមរយៈ ភិក្ខុ មាស សាពួន ( សៀមរាប )

១- ភិក្ខុ មាស សាពួន និង ញោមប្រុស ញោមស្រី .................... ១៣ $

២-ភិក្ខុសទ្ធាធរោ ហោ ផេងអាន (ហៅ ហៃ ហោឡោ ) ........... ១០ $

៣-ភិក្ខុ ហោ តូរ៉ា ............................................ ១០ $

៤-ភិក្ខុ មុត សំបាន ( វិសុទ្ធិមគ្គ ) .............................. ៥ $

៥-ភិក្ខុ អគ្គ សុមនោ ផាន់ សារី .......................... ៥ $

៦-ភិក្ខុ វ៉ាត ជំនាញ .......................................... ៥ $

៧-សាមណេរ ឡឹង លីន .................................... ៥ $

៨-សាមណេរ ធឿន សារ៉ាង ................................ ៥ $

៩-សាមណេរ ថាយ ថុល ........................................ ៥ $

១០-សាមណេរ សៃ សឿប ........................................ ៥ $

១១-សាមណេរ សុខ សៃ .............................. ៥ $

១២-សាមណេរ គ្រួច ណាត .......................... ៥ $

១៣-សាមណេរ ឡុច សុភ័ណ ............................ ៥ $

១៤-សាមណេរ វ៉ុន ស៊ុនបៀ + សាមណេរ ឡូន ឈិត ........... ៥ $

១៥-ឧ.សិ. សេង ហៃ ព្រមទាំងកូនចៅ .............................. ២០ $

១៦- ឧ.សិ. សូរីឡា+ ឧ.សិ. ណារ៉ុត .............................. ១០ $

១៧-ឧ.សិ.ខេង ច័ន្ទលីណា និង ស្វាមី ព្រមទាំងបុត្រ .............. ១០ $

១៨-ឧ.សិ.ខេង ចរិយា និង ស្វាមី ព្រមទាំងបុត្រ ................ ១០ $

១៩-ឧ.សិ.ដា លីដា + រស្មី + ស្វាមី ...................... ១០ $

២០-ឧ.ស. ឃុត សេង + ឧ.សិ.ចៃ គីមលី ព្រមទាំងបុត្រ ................ ១០$

២១-ឧ.ស. លាវ សុមនោ + ឧ.សិ.សូ សេដ្ឋា ព្រមទាំងបុត្រ ............ ១០$

២២-ឧ.សិ.លី ផល្លា ព្រមទាំងកូនចៅ ................................. ៨ $

២៣-ឧ.ស. ម៉ា + ឧ.សិ.ម៉េង ព្រមទាំងបុត្រ ........................ ៥ $

២៤-ទាយិកា.ហោ ច័ន្ទលក្ខិណា .............................. ៥ $

២៥-អ្នកគ្រូ ពេជ្រ ភួងសុភាព + ស្វាមី ឌី ចិន្តា ព្រមទាំងបុត្រ ........ ៥ $

២៦-ឧ.សិ.ញ៉ែម សុខន ព្រមទាំងកូនចៅ ................................. ៤ $

២៧-ឧ.សិ.ចាន់ ណារី ព្រមទាំងកូនចៅ ................................ ៤ $

២៨-លោក និក គីមទៀប + ឧ.សិ. យុង ទ្រុម ព្រមទាំងកូនចៅ ............. ៤ $

២៩-លោក សួ ប៉ូ និង ភរិយា ព្រមទាំងកូនចៅ .................. ៤ $

៣០-ឧ.សិ.លួយ + ឧ.សិ. សូត្រ + ឧ.សិ. យេ ( វត្តរើ ) ............ ២០.៥០០៛

៣១-ឧ.ស. ឧ.សិ.សយ តុងហាន់ ព្រមទាំងកូនចៅ ............. ២០.០០០៛

៣២-ឧ.សិ. ទូក សំអួន ព្រមទាំងកូនចៅ .................. ២០.០០០៛

៣៣-ឧ.សិ. ស្រី ពេជ្រ និង ស្វាមី ព្រមទាំងបុត្រ ............. ២០.០០០៛

៣៤-ឧ.សិ.លី ចិន្តា ព្រមទាំងកូន និង ក្មួយ .................. ២០.០០០៛

៣៥- ឧ.ស.បឿយ បូរ ឧ.សិ.អ៊ី សារឿត + កូន បូរ វិបុល ...... ២០.០០០៛

៣៦-ឧ.សិ. លីណា ព្រមទាំងកូនចៅ .................. ១៨.០០០៛

៣៧-ឧ.សិ.សន +ស្វាមី -ឧ.សិ.សាំង + ស្វាមី ............... ១៧.០០០៛

៣៨-ឧ.សិ. ហោ ច័ន្ទរដ្ឋា ព្រមទាំងបុត្រ .................. ១៦.០០០៛

៣៩-ឧ.សិ. កាន់ ញ៉ុង ( ហៅ ណារី ) .................. ១៦.០០០៛

៤០-លោក អ៊ាត អាត + ដឿត ម៉ាប់ + បុត្រ (ភូមិរើល ) ....... ១៦.០០០៛

៤១-លោក យង់ សេរីវុធ + សួ មុំ ព្រមទាំងបុត្រ ( សរ ) ........ ១៦.០០០៛

៤២-ឧ.សិ. ញ៉ែម សុខា និង ស្វាមី ព្រមទាំងបុត្រ ............ ១៦.០០០៛

៤៣-អ្នកគ្រូ ពេជ្រ ផល្លី + កែវ បូចាន់ ព្រមទាំងបុត្រ ......... ១៥.០០០៛

៤៤-ឧ.សិ. សែម រ៉ម ឧ.សិ. រុន ( វត្តរើ ) ................ ១៤.៥០០៛

-ពុទ្ធបរិស័ទវត្តរើ ចំនួន ១៦ នាក់ ......................... ១ $ + ៥៨.០០០៛

-ពុទ្ធបរិស័ទ ឥតមានឈ្មោះ ................................. ៣៣.៤០០៛

-សីលវ៉ា ចំនួន ៧ នាក់ ................................ ២៧.០០០៛

-ពុទ្ធបរិស័ទ អ្នកដែលចូល ១២.០០០៛ មានចំនួន ២ នាក់

-ពុទ្ធបរិស័ទ អ្នកដែលចូល ១០.០០០៛ មានចំនួន ១០ នាក់

-ពុទ្ធបរិស័ទ អ្នកដែលចូល ៥.០០០៛ មានចំនួន ១២ នាក់

## តាមរយៈឧ.សិ. រស់ គឹមថាន

១- លោកស្រី ច័ន្ទ សុវត្ថិ និង ស្វាមី ព្រមទាំងបុត្រ ................ ១២០.០០០៛

២-ឧ.សិ.រស់ គឹមថាន និង ស្វាមី ព្រមទាំងបុត្រ ................... ៨០.០០០៛

៣-អ្នកស្រី អាំង គីណូ និង លោកកែវ សាម៉ុឌី +បុត្រ ............. ៥០.០០០៛

៤- លោកស្រី ថុង ចាន់ឡៀប និង ស្វាមី ព្រមទាំងបុត្រ .............. ៥០.០០០៛

៥- ឧ.សិ. នៅ សេងអាន និង ស្វាមី ព្រមទាំងបុត្រ ............... ២០.០០០៛

៦- លោកស្រី ប្រាង នី និង ស្វាមី ព្រមទាំងបុត្រ ................. ២០.០០០៛

៧- ឧ.សិ. ទូច ដានី និង ស្វាមី ព្រមទាំងបុត្រ ...................... ២០.០០០៛

## តាមរយៈឧ.សិ. ហ៊ីង ស៊ីមណៃ

១-ឧ.ស.ហ៊ី អ៊ុនសេង ឧ.សិ. ហ៊ីង ស៊ីមណៃ + កូនចៅ ............... ៨ $

២-ឧ.ស.តែ គឹមហ៊ុន ឧ.សិ. តាំង សុខអ៊ីម + កូនចៅ ............... ៨ $

៣-ឧ.ស.ឡុង សំអោក ឧ.សិ. ហ៊ីង ម៉ាឡៃ + កូនចៅ ............... ៨ $

៤- ឧ.សិ. ឈាវ គឹមស៊ាង + កូនចៅ .............................. ៤ $

៥- ឧ.សិ. កៅ គឹមជ្រី ព្រមទាំងបុត្រ .................................. ៣២.០០០៛

៦- ឧ.សិ. កូ អ៊ុយរួច ព្រមទាំងបុត្រ .................................. ៣២.០០០៛

៧- ឧ.សិ. កែវ កល្យាណ និង ស្វាមី ព្រមទាំងបុត្រ ............. ១៦.០០០៛

៨- ឧ.សិ. ញឹក សុផល ព្រមទាំងកូនចៅ ......................... ១៦.០០០៛

៩- ឧ.សិ. គឹម ថេង ហៅ អៀង មុិញ ព្រមទាំងបុត្រ ............. ១៦.០០០៛

## តាមរយៈឧ.ស. ផាន់ គោគ

១- ឧ.ស.ផាន់ គោគ .......................................... ៥ $

២-ឧ.ស.សំ ខាន់ឌី ឧ.សិ.កៅ គឹមលី ព្រមទាំងបុត្រ ............. ៤ $

៣-លោក ម៉ាក់ វិសាល ភរិយា កែវ កល្យាណ + បុត្រ ........... ១៦.០០០៛

៤-ឧ.ស.កែវ សារ៉ែន និងឧ.សិ.ហួង តារាវី + បុត្រ ............ ១៦.០០០៛

៥-ឧ.សិ.យស គឹមសាង ព្រមទាំងកូនចៅ និង ចៅទួត .......... ១៦.០០០៛

៦-ឧ.ស.ទេព ផា ឧ.សិ.ទិត្យ ឌី ព្រមទាំងបុត្រ ................. ១៦.០០០៛

៧-ឧ.ស.សុខ យិន ឧ.សិ.ចិន គុង ព្រមទាំងបុត្រ ............. ១៥.៦០០៛

៨-ឧ.ស.ឡើក សំហៀង ឧ.សិ.សោម សាន + បុត្រ ........... ១៥.០០០៛

## តាមរយៈឧ.សិ.ឃឹម វ៉ន

១-ឧ.សិ.ឃឹម វ៉ន ព្រមទាំងមិត្តព្រះធម៌ .......... ២៣ $ + ២.០២៥.៨០០ ៛

២- ឧ.សិ.គឹម ឈុនធាយ៉ាព៉ាណែត ................................ ១០ $

៣- ឧ.សិ.គឹម ឈុនធាយ៉ាវត្តី .................................... ១០ $

៤- ឧ.ស. ខាំនី ឧ.សិ. គួច គីមឡាង ព្រមទាំងបុត្រនិងចៅ ....... ១០ $

៥- ឧ.សិ. កែវ សុខុម និង ស្វាមី ព្រមទាំងកូនចៅ ........................ ៥ $

៦- ឧ.សិ.លី សុខា ព្រមទាំងកូនចៅ .................................... ៤ $

៧-ហម ស៊ុនទៀង ព្រមទាំងគ្រួសារ ........................ ៤ $

៨- ឧ.សិ.ឈន ឃឹម ព្រមទាំងកូនចៅ .................................... ៤ $

៩-សល់ ខេ ព្រមទាំងបុត្រ ..................................... ៤ $

១០- ឧ.សិ.លីវ ណាយ ព្រមទាំងកូនចៅ ................................ ៤ $

១១- លោក អ៊ា ព្រំ និង ភរិយា ព្រមទាំងបុត្រ .......................... ៤ $

១២- លោក យន់ វុទ្ធី និង ភរិយា ព្រមទាំងបុត្រ ....................... ៤ $

១៣- ឧ.សិ.ក្លឹង សុខលីម និង ស្វាមី ព្រមទាំងកូនចៅ ....... ៣៣.០០០៛

១៤- បង វណ្ណ ឈឿន ............................... ២០.០០០៛

១៥-លោក ហ៊ិន កឿន + អ្នកស្រី ពៅ សុខហៀង ( ភូមិតាឡឹង ) ២០.០០០៛

១៦- លោក ផួន និង អ្នកស្រី ផុន ( ភូមិតាឡឹង ... តាកែវ ) .... ២០.០០០៛

១៧-លោក ហង់ ច័ន្ទរិទ្ធ ឧ.សិ. ដួង ក៉ាវី ព្រមទាំងបុត្រ ....... ២០.០០០៛
១៨- ឧ.សិ.សោម ច័ន្ទដារ៉ា និង អ្នកម្តាយ ................. ២០.០០០៛
១៩- ឧ.សិ.អ៊ុក ចន្ទធីតា ................................ ២០.០០០៛
២០- ឧ.សិ.រស់ មន .................................... ២០.០០០៛
២១- ឧ.ស.គួច គីហ៊ាង + ភរិយា ព្រមទាំងបុត្រ ......... ២០.០០០៛
២២-ឧ.សិ. លី តាំងគួយ + ឧ.សិ. លីម លីហៀង ............ ២០.០០០៛
២៣- ឧ.សិ.លី មួយ .................................... ២០.០០០៛
២៤- ឧ.សិ.ងិន ភិន ................................... ២០.០០០៛
២៥- វណ្ណ ឈឿន ..................................... ១៦.០០០៛
២៦- ឧ.សិ.ប្រាក់ គីមលី ព្រមទាំងកូនចៅ និង មិត្តព្រះធម៌ .... ១៦.០០០៛
២៧- ឧ.ស.ចុង សំអុល និង ឧ.សិ. គ្រី ង៉ែត ......................... ១៦.០០០៛
២៨- ឧ.សិ.ហាក់ តេងស៊ីម ........................ ១៦.០០០៛
២៩- ឧ.សិ.ពៅ និង ឧ.សិ. លីវ ណាយ .......................... ១៥.០០០៛
៣០- ឧ.សិ.ទឹម រ៉ី និង ឧ.សិ. យ៉ាន់ សាំងហេង .............. ១៥.០០០៛
៣១- ឧ.សិ.យាយ ចន ព្រមទាំងបុត្រ ................... ១៥.០០០៛
៣២- សួយ ខេង + វ៉ាត់ ឃីម + ឈឿន ធារី ............... ១៥.០០០៛
៣៣- យាយ រីប + តា ថោ + តុន វឿន ................. ១៥.០០០៛
៣៤- ឧ.សិ.នួន ម៉ុន .................................. ១៥.០០០៛
៣៥- វ៉ែន ជា + ឈាង គា + សល់ សុខនឿន .................. ១៥.០០០៛

# តាមរយៈ ឧ.សិ. ស៊ីម យ៉េកហ្វយ ( កំពង់ចាម )

១- ឧ.សិ. អ៊ីង ចាន់ផា និងស្វាមី ព្រមទាំងបុត្រ ( កាណាដា ) ........... ៥០ $

២- ឧ.សិ. អ៊ីង វិដ្ឋា ព្រមទាំងកូនចៅ ( កាណាដា ) ................ ៥០ $

៣-ឧ.ស.ហេង ផុណ្ណា ឧ.សិ.ឡាយ សំណាង ព្រមទាំងបុត្រ ........... ៥០ $

៤-ឧ.សិ. ស៊ីម យ៉េកហួយ និង អ្នកម្តាយ វ៉ា គីមស៊ី .................... ២០ $

៥- ឧ.សិ. ជា យានារី ព្រមទាំងកូនចៅ ............................. ១០ $

៦- ឧ.ស. ជា យាវ ឧ.សិ.គៀត រឿន ព្រមទាំងកូនចៅ ............. ១០ $

៧- ឧ.សិ. កើត ស្រ៊ុន ព្រមទាំងកូនចៅ ................................. ១០ $

៨- ឧ.សិ. ហួត លាងហួរ លោក តាន់ វ៉ាន់ថុន ព្រមទាំងបុត្រ ........... ១០$

៩-ឧ.សិ. សំណាង ស្រីពៅ និងក្រុមគ្រួសារ ........................... ៨ $

១០-ឧ.សិ. សំណាង ទ្រព្យ ព្រមទាំងកូនចៅ ............................... ៨ $

១១- ឧ.សិ. ហួត ឆេងហ៊ុន លោក ឪពុក ហួតផេង ............ ៥ $

១២-ឧ.សិ.ចាន់ លីណា + នុត សំអាង ព្រមទាំងបុត្រ .................... ៥ $

១៣-ឧ.សិ.ចាំង គីមថាយ ទាយក ញាណ ជ័យ និងកូនចៅ ...... ៨០.០០០៛

១៤- ជា ប៉េងហៀក ........................................................ ៤០.០០០៛

១៥- ឧ.ស. អ៊ាម ង្វួនឆេង ឧ.សិ.ឌិ ដាលី ព្រមទាំងកូនចៅ ....... ៤០.០០០៛

១៦-ទាយក ឌី សូលីណា ទាយិកា អៀង រតនា និងកូនចៅ ....... ៤០.០០០៛

១៧- ឧ.សិ. ស៊ុំ លាងអេង ................................................ ៣០.០០០ ៛

១៨- ឧ.ស. កៅ ប៊ុនណា ឧ.សិ.ស៊ុយ ស៊ីណោត និងកូនចៅ ....... ៣០.០០០៛

១៩- ឧ.សិ. យឹម ស៊ីវហេង ព្រមទាំងកូនចៅ .................... ២០.៥០០៛

២០- ឧ.សិ. តន់ ស៊ិត ព្រមទាំងកូនចៅ .......................... ២០.០០០៛

២១-ឧ.សិ. ជៃ សុន្ទរី ទាយក សេក សារឿន ព្រមទាំងបុត្រ ..... ២០.០០០៛

២២- ឧ.ស.កែប ទី ឧ.សិ. ឃួន សារីម ព្រមទាំងកូនចៅ ........ ២០.០០០៛

២៣- ឧ.ស.ជឿង ថេង ឧ.សិ. នូ សុខុម ព្រមទាំងកូនចៅ .......... ២០.០០០៛

២៤- ឧ.សិ. គឹម សុខុន ព្រមទាំងកូនចៅ ............................. ២០.០០០៛

២៥- ឧ.ស.ជឹង ផេង ឧ.សិ. ឈូ បាក់លី ព្រមទាំងកូនចៅ ......... ២០.០០០៛

២៦-ឧ.ស.ឈាង លឹមហួន ឧ.សិ. ផៃ រ៉ន ព្រមទាំងកូនចៅ ........ ២០.០០០៛

២៧-ទាយក ហៀក លាងស្រេង ឧ.សិ.ម៉ម សុផល្លា និងកូនចៅ ..... ២០.០០០៛

២៨-ទាយក ឌុល ចាន់ដេត និង ភរិយា ព្រមទាំងបុត្រ ........... ២០.០០០៛

២៩-ឧ.ស.កែវ ប៊ុនឡេង ទាយិកា នួន ស៊ីគន្ធ និងកូនចៅ ..... ២០.០០០៛

៣០-ទាយិកា ម៉ែន សូលីណា ព្រមទាំងប្អូន និងកូនចៅ .......... ២០.០០០៛

៣១-ទាយក ខុម សុគន្ធា ទាយិកា សុង លឹមរ៉ុង និងកូនចៅ ....... ២០.០០០៛

៣២-ទាយក មិន ជី និង ភរិយា ព្រមទាំងបុត្រ ................. ២០.០០០៛

៣៣- ឧ.សិ. កែវ ណារិន ព្រមទាំងបុត្រ ............................. ២០.០០០៛

៣៤-ឧ.សិ.កែ គឹមយឿង+ទាយក អៀង ផល្លី+ទាយិកា លឹម ស៊ីវវ៉េត ..... ២០.០០០៛

៣៥- ឧ.ស.ឌិក សឿន ឧ.សិ. វ៉ាគីមជូ ព្រមទាំងកូនចៅ .......... ២០.០០០៛

៣៦- ឧ.សិ. ហាក់ ហុងលន់ ព្រមទាំងកូនចៅ ................. ១៦.៥០០៛

៣៧- ឧ.សិ. លី ប៊ុននាង ព្រមទាំងកូនចៅ .......................... ១៦.៥០០៛

៣៨ - ឧ.សិ. ខឹង ធូ និង លោក ហ៊ឺ ថេង ព្រមទាំងបុត្រ ........... ១៦.០០០៛

៣៩- ទាយិកា ងិន ថាវី និងក្រុមគ្រួសារ ............................ ១៥.០០០៛

៤០- ឧ.ស. សេង ហំ ព្រមទាំងកូនចៅ ............................ ១៥.០០០៛

## តាមរយៈ ឧ.សិ.ទេព ផលម៉ាឡា

១- ឧ.ស.ឡុង សត្ថា ឧ.សិ.ទេព ផលម៉ាឡា + បុត្រ ................................. ៥ $

២-លោក ថន វណ្ណឌី + ភរិយា ឡុង សូឡានី .............................. ៥ $

៣-លោកស្រី គី ខេងលី ព្រមទាំងបុត្រ .......................................... ៥ $

៤-ឯក ឧត្តម វ៉ាន់ ពុទ្ធិពល លោកជំទាវ អ៊ូច ផល្លី +បុត្រ ............... ៥ $

៥- ឧ.ស. វ៉ាន់ សេរី និង ភរិយា ព្រមទាំងបុត្រ .................. ៥ $

៦- ឧ.សិ. ខាំ សារួម និង ស្វាមី ព្រមទាំងបុត្រ .................. ២៥.០០០៛

៧- ឧ.ស. តុប គីមឡុង ឧ.សិ. ឈាង ហ៊ិតស៊្វរ + កូនចៅ ........ ២០.០០០៛

៨-លោក ទេព ឫទ្ធី និង សូរិយា ......................................... ២០.០០០៛

៩-ឧ.សិ. សួន ធីរ៉ាត់ ព្រមទាំងបុត្រ .................................. ២០.០០០៛

១០- សំ វណ្ណលីស ...................................... ២០.០០០៛

១១-ឧ.សិ.ហែម ជឿន និង ស្វាមី + កូនចៅ ...................... ២០.០០០៛

១២-ឧ.សិ. ជ័យ ផា និង ស្រី អូន .............................. ២០.០០០៛

១៣-ឧ.សិ.សែម សុភា + កូនចៅ ...................................... ២០.០០០៛

១៤-ឧ.សិ.អ៊ុំ ស៊ីថា និង ស្វាមី+ កូនចៅ ............................ ២០.០០០៛

១៥- ឧ.សិ. សួង ភីនី ........................................ ២ $ + ៨.០០០៛

## តាមរយៈ លោកម្ចាស់ ចែត ប៊ុនឡើន

១-លោកស្រី តាំង ហ៊ុយម៉េង + ស្វាមី + មាតាបិតា +កូនចៅ ....... ៨០ $

២- ឧ.សិ.យូ ផល្វា ព្រមទាំងក្រុមមិត្តព្រះធម៌ ....................... ២៤ $

៣- ឧ.សិ. ឈាវ សុភី ព្រមទាំងបុត្រ ....................... ៤ $

៤- ឧ.សិ.សៅ ចំរើន ព្រមទាំងបុត្រ ....................... ៤ $

៥- ឧ.ស. ញឹម សុវណ្ណ និង ភរិយា ព្រមទាំងបុត្រ ............ ២០.០០០៛

៦- ឧ.សិ. លី សុខន ព្រមទាំងបុត្រ ....................... ២០.០០០៛

៧-ឧ.សិ. ជុំ ទូច ព្រមទាំងបុត្រ ........................... ១៦.០០០៛

៨- លោកគ្រូ លាង សំណាង .................................. ១៦.០០០៛

## តាមរយៈ ឧ.សិ. ជុន ស៊ូគី

១- ឧ.សិ.ស្រេង ឡេង ព្រមទាំងបុត្រ និងចៅ .......................... ២០០ $

២- ឧ.សិ.ជុន ស៊ូគី និង ក្មួយស្រី ង៉ូវ សុភាព + ស្វាមី បុត្រ ............. ២០ $

៣-ឧ.សិ.ហួត អេងហៀង ព្រមទាំងប្អូននិងក្មួយ ..................... ២០ $

៤- ឧ.សិ.ជា សុណារី និងក្មួយស្រី ជា សុមេធាធីតា .................. ១០ $

៥-លោកអ៊ឹង ផៃស្រ៊ុន និង ភរិយា ឡុង សុភាព + បុត្រ ........... ១០ $

៦-ឧ.សិ. ហ៊ាន ហ៊ង ព្រមទាំងបុត្រ និងចៅ ................................ ១០ $

៧-ឧ.សិ. ប៉ោ សេងអ៊ាត ព្រមទាំងកូនចៅ .................................. ១០ $

៨-ឧ.សិ. ទិត្យ ស៊ុន ព្រមទាំងកូនចៅ .................................. ១០ $

៩-ឧ.សិ.ឈិត សាម៉េន ព្រមទាំងកូនចៅ .................................... ៥ $

១០-ឧ.សិ. គី លីអៀង ព្រមទាំងបុត្រ .................................... ៥ $

១១-ឧ.សិ. ម៉ា លីណា ព្រមទាំងបុត្រ .......................................... ៥ $

១២-ឧ.សិ. ប៊ិន ចន្ថា ( ហៅពៅ) ព្រមទាំងបុត្រ ............................. ៥ $

១៣- ឧ.សិ. កូ តាំង ម៉ី និង ស្វាមី ព្រមទាំងបុត្រ ....................... ៥ $

១៤-ឧ.សិ. ឈឺ សៀមលន់ ព្រមទាំងបុត្រ និងចៅ ................. ១០០.០០០៛

១៥-ឧ.សិ. លី ណារី ព្រមទាំងបុត្រ និងបងប្អូន ....................... ៤០.០០០៛

១៦- ឧ.សិ.ឈុន ចំណាន ព្រមទាំងកូនចៅ ............... ៤០.០០០៛

១៧-ឧ.ស. រ៉ុង ឧ.សិ. សៀក ហ៊ុន ព្រមទាំងកូនចៅ ............. ៤០.០០០៛

១៨- អ្នកស្រី សួង ម៉ារី និង ស្វាមី ព្រមទាំងបុត្រ ................... ២០.០០០៛

១៩- ឧ.សិ. ប៉ាល់ ស្រីពៅ ព្រមទាំងបុត្រ ................... ២០.០០០៛

២០-កញ្ញា កាំង កៅស៊ីថា ( ស្តង់ផ្ទៃឈើ) ................... ២០.០០០៛

២១- ឧ.សិ. សុខ ខេន ព្រមទាំងបុត្រ និងចៅ ................... ២០.០០០៛

២២- ឧ.សិ.ចុង ទូច ឧ.ស. ជា ប៉ាវ ព្រមទាំងកូនចៅ ........ ២០.០០០៛

២៣- ឧ.សិ. អ៊ុំ យន់ ព្រមទាំងបុត្រ និងចៅ ................... ២០.០០០៛

## តាមរយៈ ឧ.សិ.សូ យឿន

១- ឧ.សិ. ចាន់ មុនី ព្រមទាំងប្អូន ៗ .................... ៣២.០០០៛

២- ឧ.សិ. សូ យឿន ព្រមទាំងកូនចៅ ...................... ២០.០០០៛

៣- ឧ.ស. ប្រាក់ សំអុល និងភរិយា ព្រមទាំងបុត្រ ......... ១៦.០០០៛

៤- ឧ.សិ. ឡោ គឹមរួច ព្រមទាំងកូនចៅ .............. ១៦.០០០៛

៥- ឧ.សិ. សុខ ស៊ីផុន ព្រមទាំងកូនចៅ ......... ១៦.០០០៛

៦- ឧ.សិ. ឈឹម ណារ៉ុម និង ស្វាមី ព្រមទាំងកូនចៅ .......... ១៦.០០០៛

៧- ឧ.សិ. ក្លូត ស៊ីណាត និង ស្វាមី ព្រមទាំងកូនចៅ .......... ១០.៧០០៛

## តាមរយៈ ឧ.ស. យិច ឈីន + ឧ.សិ.តែ សុមាលី ( ប្អួយ )

១-ឧ.សិ. កុំ សុខែម ឧ.សិ. កុំ សរបូរី +កូនចៅ ................... ២០ $

២-ឧ.ស. យិច ឈីន ឧ.សិ. តែ សុមាលី (ប្អួយ ) +កូនចៅ ....... ១០ $

៣-ឧ.ស. ជា ខេង ឧ.សិ. សៀង យូលាភ +កូនចៅ ................. ៥ $

៤-ឧ.សិ. យឹម សុខុម +បុត្រី ទូច សុខគង់ ...................... ៥ $

៥-ឧ.ស. សុខ សេន ឧ.សិ. ប្រាក់ សារី +កូនចៅ ................. ៥ $

៦-ឧ.សិ. ប្រាក់ សារាម ព្រមទាំងកូនចៅ ........................ ៥ $

៧-ឧ.សិ. ប្រាក់ សារុំ ព្រមទាំងកូនចៅ .......................... ៥ $

៨-ឧ.ស.សំ សុផល ឧ.សិ.ម៉ៅ ចន្ថា (ហៅអ៊ុច) ព្រមទាំងបុត្រ ....... ៥ $

៩- ក- សុក ចាន់ណា + ក- សុត ស្រីមុំ + ក-ចាន់ ធូ ..................... ៥ $

១០-ឧ.ស. គង់ គីម ឧ.សិ. លន់ ថាន់ (ពៅ) + កូនចៅ ........... ៥ $

១១- លោក សួន សារ៉េត អ្នកស្រី ហង់ ដានី ព្រមទាំងបុត្រ ............ ៥ $

១២-ឧ.សិ. ព្រហ្ម ស្រីមុំ និង ស្វាមី ព្រមទាំងបុត្រ ........................... ៥ $

១៣-អ្នកស្រី ផាត វ៉ាន់ណោន និង ស្វាមី ព្រមទាំងបុត្រ ................. ៥ $

១៤-ឧ.សិ. សៀង គឹមហុន ឧ.ស. ជា ធឿន ព្រមទាំងកូនចៅ .......... ៥ $

១៥- លោក គីម ឡុង ឧ.សិ.កាំង ដានី ព្រមទាំងបុត្រ ............ ៥ $

១៦-ឧ.ស. ឈុន ប៊ុនសាធ ឧ.សិ. ទិត សាផានី ព្រមទាំងបុត្រ ........... ៥ $

១៧-ឧ.សិ. ស្រេង គ្រឹង និង ឧ.សិ. ឃ្វាំង ថាវុធថា +កូនចៅ +ចៅទួត .. ៥ $

១៨-ឧ.សិ. សានី ទីនី ព្រមទាំងកូនចៅ ..................... ៥ $

១៩- ឧ.សិ.ឡៃ សំអឿន និង លោក រស់ សំបូរ ព្រមទាំងបុត្រ ...... ៥ $

២០-ឧ.សិ. ស៊ីវ ស៊ីនួន ព្រមទាំងកូនចៅ ..................... ៥ $

២១-ឧ.សិ. អូយ មិនា លោក អ៊ឹម ពុធសិលៈ ព្រមទាំងកូនចៅ .......... ៥ $

២២-ឧ.ស. ជា ត្រី ព្រមទាំងកូនចៅ ........................ ៥ $

២៣-ឧ.សិ. សុខ ណាព៉ា ព្រមទាំងកូនចៅ ...................... ៥ $

២៤-ឧ.សិ. រស់ ស៊ីនួន + ក - ស្រី ល័ក្ខស្មីវតេយ្យ ព្រមទាំងបុត្រ ...... ៥ $

២៥-ឧ.ស. ធន់ សាម៉េន ឧ.សិ. អ៊ឹម គ្រឿន ព្រមទាំងបុត្រ .......... ៥ $

២៦- អ្នកគ្រូ យួន វណ្ណា លោកគ្រូ ជុំណាត ព្រមទាំងកូនចៅ ............ ៥ $

២៧-ឧ.សិ. ជ័យ ជួនសុផល + ប្អូន ព្រមទាំងកូនចៅ ............... ៥ $

២៨-ឧ.សិ. មាន ប៊ុនណាត ព្រមទាំងកូនចៅ ...................... ៥ $

២៩-ឧ.ស. សាយ បូរ៉ុំ ព្រមទាំងកូនចៅ ................... ៥$

៣០- លោក យុត សំណាង និង អ្នកម្តាយ ម៉ម សាត ................... ៥$

៣១-ឧ.ស. កែវ ម៉ាលិស ឧ.សិ. អួន មុន្នីលាភ ព្រមទាំងកូនចៅ .... ៥$

៣២- លោក យុន ណារិន អ្នកស្រី ងិន សុន្ទរី ............. ៥$

៣៣-ឧ.សិ. សា គីមសាង ព្រមទាំងកូនចៅ .................... ៥$

៣៤-ឧ.សិ. សាធ ណាត្រី ព្រមទាំងកូនចៅ ....................... ៥$

៣៥-ឧ.ស. វាល់ វឿន ឧ.សិ. កែ វង្ស ព្រមទាំងកូនចៅ ............ ៥$

៣៦-ឧ.ស. សេង ហ៊ ឧ.សិ. អ៊ុក សុខចាន់ (ណែត) + កូនចៅ .. ២០.០០០៛

៣៧- អ្នកស្រី ម៉ា ស៊ីនឿន .................................... ២០.០០០៛

៣៨-ឧ.សិ. ឌឹម សុខហេង ព្រមទាំងកូនចៅ .................... ២០.០០០៛

៣៩-ឧ.សិ. អ៊ា គឹមហេង ព្រមទាំងកូនចៅ ..................... ២០.០០០៛

៤០-ឧ.សិ.ហាស់ សំជិន ព្រមទាំងកូនចៅ .................. ២០.០០០៛

៤១ -ឧ.សិ. អោ គន្ធារី ឧ.ស. សោម សាមឿន + កូនចៅ .... ២០.០០០៛

៤២- ឧ.សិ. ស៊ឹម ណែម ឧ.ស. ហ៊ុន អៀ ព្រមទាំងកូនចៅ ... ២០.០០០៛

៤៣-ឧ.សិ. រស់ សូរិយា ឧ.សិ. ម៉ៅ ថៃ ព្រមទាំងកូនចៅ ..... ២០.០០០៛

៤៤-ឧ.សិ. លាស់ សាវឿន ឧ.ស.ពៅ សាមុត ព្រមទាំងកូនចៅ ... ២០.០០០៛

៤៥-ឧ.ស. ជុច សាប៊ុល ឧ.សិ. ទុយ ស៊ាងលី ព្រមទាំងកូនចៅ .. ២០.០០០៛

៤៦-ឧ.ស. ព្រំ យឿន ឧ.សិ. ពាម សាយឿន ព្រមទាំងកូនចៅ ... ២០.០០០៛

៤៧-ឧ.ស. ឆេង ហ៊ន ឧ.សិ. ជួប ម៉ាព៉ា ព្រមទាំងកូនចៅ .... ២០.០០០៛

៤៨-ឯក សាឡាស់ ព្រមទាំងកូនចៅ .................. ២០.០០០៛

៤៩-ឧ.សិ.ឯក សាឡូត ព្រមទាំងកូនចៅ ............. ២០.០០០៛

៥០-ឧ.សិ.ផាន់ សុវណ្ណ ព្រមទាំងកូនចៅ ...................... ២០.០០០៛

៥១-ឧ.សិ.ឆេង អាយ ព្រមទាំងកូនចៅ ................................ ២០.០០០៛

៥២-ឧ.សិ.សំរិទ្ធ អឿន ព្រមទាំងកូនចៅ ........................ ២០.០០០៛

៥៣-ឧ.សិ.ហ៊ុយ ផានី ព្រមទាំងអ្នកម្ដាយ ....................... ២០.០០០៛

៥៤-ឧ.សិ.យ៉ា សុធារី ព្រមទាំងលោកឪពុក ............... ២០.០០០៛

៥៥-ឧ.សិ.ខៀវ សារិទ្ធ ព្រមទាំងកូនចៅ .................. ២០.០០០៛

៥៦-ឧ.សិ.លុយ គឹមហ៊ាង ព្រមទាំងកូនចៅ ................ ២០.០០០៛

៥៧-ឧ.សិ.យឹម សយ ព្រមទាំងកូនចៅ ................ ២០.០០០៛

៥៨-ឧ.សិ.លី ស៊ីម ព្រមទាំងកូនចៅ ................... ២០.០០០៛

៥៩-ឧ.សិ.ចាន់ ណៃ ព្រមទាំងកូនចៅ ..................... ២០.០០០៛

៦០-ឧ.សិ. អ៊ួង ណាវឿន ព្រមទាំងបុត្រ .............. ១៦.០០០៛